# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ២ : គន្ថីទី ៤


រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី



ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា
នៅឆ្នាំ ២០១០។

កម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
គឺជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស
រវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិអ្នកនិពន្ធ © ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
ISBN: 9789995083366

| | អ្នកនិពន្ធ |
|---|---|
| ជំពូកទី ១ ទៅ ជំពូកទី ៧<br>(ក្រៅពីកថាភាគីទី១ ផ្នែកទី ១ ជំពូកទី ៧) | លោកសាស្ត្រាចារ្យ **Nomi Yoshihisa** |
| កថាភាគីទី១ ផ្នែកទី ១ ជំពូកទី ៧ | លោកសាស្ត្រាចារ្យ **Niimi Ikufumi** |
| ជំពូកទី ៨ | លោកសាស្ត្រាចារ្យ **Yamamoto Yutaka** |
| ជំពូកទី ៩ | លោកសាស្ត្រាចារ្យ **Nomura Toyohiro** |

<u>កំណត់សម្គាល់</u>

នៅក្នុងសេចក្តីកំណត់នៃមាត្រានីមួយៗ មានសេចក្តីកំណត់ខ្លះដែលមានការបង្ហាញអំពីការបកស្រាយរបស់អ្នកដែលបានរៀបចំសេចក្តីព្រាងដើមនៃមាត្រានោះ ។ សូមចាត់ទុកការបកស្រាយនោះជាទស្សនៈមួយក្នុងចំណោមការបកស្រាយជាច្រើនដែលអាចមាន ដើម្បីយកទៅចាត់ចែងកិច្ចការជាក់ស្តែងនៅប្រទេសកម្ពុជា ។

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ក្នុងការណែនាំជូននូវ សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសេចក្តីសង្ឃឹមដ៏មុតមាំថា សៀវភៅនេះនឹងក្លាយជាជំនួយដ៏សំខាន់មួយ ដើម្បីជួយសម្រួលដល់ការស្វែងយល់របស់បណ្តាអ្នកស្រាវជ្រាវនានា ជាពិសេសរបស់មន្ត្រី និងភ្នាក់ងារដែលត្រូវអនុវត្តក្រមរដ្ឋប្បវេណីនេះ ដោយផ្ទាល់តែម្តង ។

ដូចយើងទាំងអស់គ្នាបានដឹងហើយថា វិស័យគតិយុត្តកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល ដែលក្នុងនោះ ច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់នានា សម្រាប់អនុវត្តទៅលើរឿងក្តីរដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយដែរ ។ ឧទាហរណ៍ ដូចជាចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកដល់មុនពេលអនុម័តក្រមរដ្ឋប្បវេណីថ្មី កម្ពុជាយើងមិនមានច្បាប់សារធាតុគ្រប់គ្រាន់ ដើម្បីយកមកដោះស្រាយរឿងក្តីរដ្ឋប្បវេណីទេ ។ អ្វីដែលជាការកត់សម្គាល់ គឺកម្ពុជាមានត្រឹមតែ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ច្បាប់ភូមិបាលដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ និងអមដោយអនុក្រឹត្យ ព្រមទាំងប្រកាស និងសារាចរណែនាំខ្លះៗផ្សេងទៀតរបស់ក្រសួងយុត្តិធម៌តែប៉ុណ្ណោះ ។

ដោយសារកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តគំនិតផ្តួចផ្តើមក្នុងការបង្កើតឡើងវិញនូវក្រមរដ្ឋប្បវេណីកម្ពុជា ក៏បានលេចចេញជារូបរាងឡើង ។ ជាលទ្ធផល **ក្រមរដ្ឋប្បវេណី** ត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ៣ របស់ខ្លួន ហើយព្រឹទ្ធសភាក៏បានផ្តល់ការយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ។ ក្រមនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ កន្លងទៅ ។ ការសម្រេចបាននូវ **ក្រមរដ្ឋប្បវេណី** នេះ គឺជាសមិទ្ធផលដ៏ថ្មីស្រឡាងនិងជាទីមោទនៈមួយទៀតនៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា ហើយនេះ ក៏ជាជំហានថ្មីមួយទៀត នៅក្នុងការចូលរួមអនុវត្តនូវគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមគ្នានេះដែរ ដើម្បីជាការបន្ថែមលើវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយស្តីពី **ក្រមរដ្ឋប្បវេណី** និងដើម្បីធ្វើឱ្យមានភាពជឿជាក់ថា ក្រមនេះ ត្រូវបានយល់ជ្រួតជ្រាបទៅក្នុងចំណោមមហាជន ក៏ដូចជា

ជួយសម្រួលដល់ការស្វែងយល់ ការបកស្រាយ និងការអនុវត្តដោយមន្ត្រី និងស្ថាប័នអនុវត្ត សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចងក្រង និងបោះពុម្ពឡើង។ ទាំងអស់នេះ គឺបានប្រសូតចេញពីកិច្ចខំប្រឹងប្រែង ជិតមួយទសវត្សរ៍របស់ក្រុមការងារនៃក្រសួងយុត្តិធម៌កម្ពុជានិងក្រុមការងារជប៉ុន ក្នុងបុព្វហេតុក្រមរដ្ឋប្បវេណីកម្ពុជាមួយ ប្រកបដោយការផ្លាស់ប្តូរនិងប្រសិទ្ធភាពខ្ពស់សំដៅឆ្ពោះទៅរកការរួមចំណែកកសាងនីតិរដ្ឋ នៅកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្ស វឌ្ឍនា

**គន្ថីទី ៥ កាតព្វកិច្ច** ........ ១
**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ........ ១
ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃទស្សនៈផ្សេងៗ ........ ១
ផ្នែកទី ២ ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច ........ ៦
ផ្នែកទី ៣ ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល ........ ២០
កថាភាគទី ១ ល័ក្ខខ័ណ្ឌ ........ ២០
កថាភាគទី ២ ការកំណត់ពេល ........ ២៦
កថាភាគទី ៣ អំឡុងពេល ........ ៣០
**ជំពូកទី ២ ការបង្ហាញឆន្ទៈ និង កិច្ចសន្យា** ........ ៣៤
ផ្នែកទី ១ ការបង្កើតកិច្ចសន្យា ........ ៣៤
ផ្នែកទី ២ វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា ........ ៤៦
ផ្នែកទី ៣ មោឃភាព និង ការលុបចោល ........ ៦៥
ផ្នែកទី ៤ ការតំណាង ........ ៧១
ផ្នែកទី ៥ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ........ ៩១
**ជំពូកទី ៣ ការអនុវត្តកិច្ចសន្យា** ........ ៩៨
**ជំពូកទី ៤ ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា** ........ ១០២
ផ្នែកទី ១ បទប្បញ្ញត្តិទូទៅស្ដីពីការមិនអនុវត្តកាតព្វកិច្ច ........ ១០២
ផ្នែកទី ២ ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ ........ ១០៩
ផ្នែកទី ៣ សំណងនៃការខូចខាត ........ ១១១
ផ្នែកទី ៤ ការរំលាយកិច្ចសន្យា ........ ១២២
**ជំពូកទី ៥ ការទទួលបន្ទុកហានិភ័យ** ........ ១៣៣
**ជំពូកទី ៦ អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន** ........ ១៤០
ផ្នែកទី ១ ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល ........ ១៤០
ផ្នែកទី ២ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ........ ១៤៧
**ជំពូកទី ៧ ការរលត់កាតព្វកិច្ច** ........ ១៥៤
ផ្នែកទី ១ ការសង ........ ១៥៥
កថាភាគទី ១ គោលការណ៍ទូទៅស្ដីពីការសង ........ ១៥៥
កថាភាគទី ២ ការកាត់បំណុល ........ ១៧០

កថាភាគទី ៣ សំណើផ្តល់ការសង និង ការតម្កល់ . . . . . . . . . . . . . . ១៧៤

កថាភាគទី ៤ ឧបាទេសកម្មដោយការសង . . . . . . . . . . . . . . . ១៨២

ផ្នែកទី ២ ការទូទាត់ . . . . . . . . . . . . . . . . . . . ១៨៩

ផ្នែកទី ៣ ការលើកលែង . . . . . . . . . . . . . . . . . ២០០

ផ្នែកទី ៤ នវកម្ម . . . . . . . . . . . . . . . . . . . ២០១

ផ្នែកទី ៥ ព្យាកុលភាព . . . . . . . . . . . . . . . . . . ២០៥

**ជំពូកទី ៨ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល . . . . . . . . . . . . . ២០៥**

**ជំពូកទី ៩ អនុប្បទានសិទ្ធិលើបំណុល ការទទួលកាតព្វកិច្ច . . . . . . . . . . . . ២២៥**

ផ្នែកទី ១ អនុប្បទានសិទ្ធិលើបំណុល . . . . . . . . . . . . . . ២២៥

ផ្នែកទី ២ ការទទួលកាតព្វកិច្ច . . . . . . . . . . . . . . . ២៣១

ផ្នែកទី ៣ អនុប្បទានឋានៈក្នុងកិច្ចសន្យា . . . . . . . . . . . . . ២៣៤


Khmer Law's Association

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្តម **អង្គ វង្ស វឌ្ឍនា** | រដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ១) |
| ឯកឧត្តម **អ៊ឹ ជន** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ២) |
| ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុជាតិ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **យូ ម៉ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្តម **គង់ ស្រ៊ីម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្តម **ម៉ិន ហ៊ិន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ជួន គោជ** | អគ្គាធិការរង, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ផូច សំគី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សារិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ធារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ុង ធីម្ចទ្ធិ** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| លោក **នួច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក **និត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ត្រាចារ្យកិត្តិយស, សកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក **Kamata Kaoru** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Matsumoto Tsuneo** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក **Minami Toshifumi** | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

| | |
|---|---|
| លោក **Motoyama Atsushi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan |
| លោក **Niimi Ikufumi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji |
| លោក **Nomi Yoshihisa** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo |
| លោក **Nomura Toyohiro** | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin |
| លោក **Sato Keita** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Chuo |
| លោក **Tanamura Masayuki** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Urakawa Michitaro** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Yamamoto Yutaka** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto |
| លោក **Hatanaka Hisaya** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Fukuoka |

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ :**

| | |
|---|---|
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Yamada Yoichi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Imaizumi Manabu** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោកស្រី **Homma Yoshiko** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kai Mineo** | អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kamiki Atsushi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Manabe Kana** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Terauchi Kozue** | អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kiyohara Hiroshi** | ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

**អ្នកបកប្រែ :**

| | |
|---|---|
| លោក **សរ សិនិត** | អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ជិន មុនី** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **គង់ ផល្លះ** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **បញ្ញា អ៊ិន** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **អ៊ុំ សំគី** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **ហេង ឆាយ** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **កែវ ទារ៉ន្តី** | ជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

# គន្ថីទី ៤ កាតព្វកិច្ច

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យផ្សេងៗ

(កំណត់)

គន្ថីទី ៤ ស្តីពី "កាតព្វកិច្ច" ចែងអំពីគោលការណ៍ទូទៅនៃប្រភេទផ្សេងៗនៃកាតព្វកិច្ច ។ មូលហេតុនៃការបង្កើតឱ្យមានទំនាក់ទំនងនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច រួមមានកិច្ចសន្យាប្រភេទផ្សេងៗ ការគ្រប់គ្រងដោយឈ្នួលសេចក្តីចម្រើនដោយឥតហេតុ និង អំពើអនីត្យានុកូល ។ ជាគោលការណ៍ ទោះបីជាកាតព្វកិច្ចត្រូវបានបង្កើតឡើងដោយមូលហេតុអ្វីក៏ដោយ ក៏បញ្ញត្តិនៃគន្ថីទី ៤ ស្តីពី "កាតព្វកិច្ច" ត្រូវយកមកអនុវត្តចំពោះរាល់ប្រភេទនៃកាតព្វកិច្ចដែរ លើកលែងតែមានបញ្ញត្តិពិសេស ។

**មាត្រា ៣០៨.-** និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវវត្ថាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃកាតព្វកិច្ច ។ ក្នុងចំណោមក្រមរដ្ឋប្បវេណីនៃបណ្តាប្រទេសនានា ក្រមរដ្ឋប្បវេណីដែលទើបតែបង្កើតថ្មីៗ មានបញ្ញត្តិស្តីពីនិយមន័យនៃកាតព្វកិច្ច ។ ដោយយោងតាមគោលនយោបាយនីតិកម្មសម្រាប់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏មានមាត្រាកំណត់និយមន័យនៃកាតព្វកិច្ចនេះផងដែរ ។

ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តរវាងបុគ្គល ។ ភាគីម្ខាងដែលទទួលប្រយោជន៍ហៅថា ម្ចាស់បំណុល រីឯភាគីម្ខាងទៀតដែលទទួលបន្ទុកហៅថា កូនបំណុល ។ ឧទាហរណ៍ ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ដែលកើតឡើងតាមកិច្ចសន្យាលក់ទិញ ភាគីដែលសន្យាបង់ថ្លៃលក់ (អ្នកទិញ) គឺជាកូនបំណុល រីឯអ្នកលក់ដែលអាចទាមទារឱ្យអ្នកទិញបង់ថ្លៃលក់ គឺជាម្ចាស់បំណុល ។ ផ្ទុយទៅវិញ កិច្ចសន្យាលក់ទិញ ក៏បង្កើតឱ្យមានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ និង កាតព្វកិច្ចផ្ទេរការកាន់កាប់វត្ថុនោះផងដែរ ។ ចំពោះកាតព្វកិច្ចនេះ

អ្នកលក់ គឺជាកូនបំណុល រីឯអ្នកទិញជាម្ចាស់បំណុលវិញ ។

ករណីយកិច្ចដែលកូនបំណុលត្រូវទទួលបន្ទុកចំពោះម្ចាស់បំណុល មានទំហំខុសប្លែកគ្នា ។ ករណីយកិច្ចចម្បងបំផុតគឺជា "ករណីយកិច្ចផ្តល់តាវកាលិក" (ករណីយកិច្ចផ្តល់វត្ថុ ឬ សេវា ដែលម្ចាស់បំណុលអាចទាមទារឱ្យផ្តល់តាវកាលិក) ។ ករណីយកិច្ចមួយទៀត គឺ "ករណីយកិច្ចបន្ទាប់បន្សំ" ដែលកើតឡើងដោយបន្ទាប់បន្សំជាមួយនឹងករណីយកិច្ចចម្បង ។ ទោះបីជាករណីយកិច្ចទាំងពីរនេះ មានទំនាក់ទំនងរវាងគ្នា និង ប្រែប្រួលចុះឡើងក៏ដោយ ក៏ម្ចាស់បំណុលមិនអាចទាមទារឱ្យផ្តល់តាវកាលិកចំពោះ "ករណីយកិច្ចបន្ទាប់បន្សំ" ទេ ប៉ុន្តែ អាចទាមទារឱ្យសងសំណងការខូចខាត ក្នុងករណីដែលមិនអនុវត្តករណីយកិច្ចបន្ទាប់បន្សំនោះ (មាត្រា ២៤១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ១៣៧១ នៃក្រមរដ្ឋប្បវេណីកេបិច ។ ក្រមរដ្ឋប្បវេណីជប៉ុនគ្មានបញ្ញត្តិដូចមាត្រានេះទេ ។

**មាត្រា ៣០៩.–** ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។

(កំណត់)

មាត្រានេះរៀបរាប់ និង ពន្យល់អំពីមូលហេតុដែលបង្កើតឡើងនូវកាតព្វកិច្ច ។ កិច្ចសន្យា គឺជាកិច្ចព្រមព្រៀងរវាងភាគីពីរ ឬ ច្រើនរូប ។ ទោះបីជាកិច្ចសន្យាជាច្រើន ដូចជាកិច្ចសន្យាលក់ទិញ ជាដើម ត្រូវធ្វើឡើងរវាងពីរភាគីក៏ដោយ ក៏មានកិច្ចសន្យាមួយចំនួន ដូចជាកិច្ចសន្យាក្រុមហ៊ុន ត្រូវធ្វើឡើងដោយកិច្ចព្រមព្រៀងដោយភាគីច្រើន ។ ពេលខ្លះ

សកម្មភាពចុះកិច្ចព្រមព្រៀងអំពីលក្ខន្តិកៈដោយភាគីពីរ ឬ ច្រើននាក់ ដើម្បីបង្កើតនីតិបុគ្គល ហៅថា "សកម្មភាពរួមគ្នា" ។ ប៉ុន្តែ ដោយហេតុថា សកម្មភាពនេះជាប្រភេទមួយនៃកិច្ចសន្យា ការចុះកិច្ចព្រមព្រៀងប្រភេទនេះ មិនត្រូវបានកំណត់ក្នុងមាត្រានេះទេ ។ សកម្មភាពឯកតោភាគី សំដៅលើករណីដែលកាតព្វកិច្ចកើតឡើងដោយការបង្ហាញឆន្ទៈជាឯកតោភាគីរបស់បុគ្គលម្នាក់ ។ ឧទាហរណ៍មួយចំនួន រួមមានអច្ច័យទាន ការរំលាយកិច្ចសន្យា និង ការបង្កើតមូលនិធិ ។ ឧទាហរណ៍ ចំពោះការរំលាយ នៅពេលដែលអនុវត្តសិទ្ធិរំលាយកិច្ចសន្យា កិច្ចសន្យានោះត្រូវបាត់បង់អានុភាព ហើយភាគីនៃកិច្ចសន្យា មានកាតព្វកិច្ចឱ្យធ្វើបដិទានឡើងវិញ ដើម្បីប្រគល់វិញនូវទ្រព្យ និង ប្រាក់ដែលត្រូវបានផ្ទេរដោយផ្អែកលើការណ៍ដែលកិច្ចសន្យានោះមានសុពលភាព ។ កាតព្វកិច្ចធ្វើបដិទាននេះ មិនមែនកើតឡើងតាមកិច្ចសន្យាទេ គឺកើតឡើងដោយការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាដែលជាសកម្មភាពឯកតោភាគី ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលបុគ្គលណាម្នាក់បង្កឱ្យមានការខូចខាតដល់អ្នកដទៃ ដោយកំហុសចេតនា ឬ កំហុសអចេតនា ប្រសិនបើទង្វើនេះបំពេញល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូលដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី បុគ្គលនោះត្រូវមានកាតព្វកិច្ចសងសំណងការខូចខាតចំពោះជនរងគ្រោះ ។ រាល់កាតព្វកិច្ចទាំងឡាយណាដែលកើតឡើងដោយសកម្មភាពអនីត្យានុកូល ការគ្រប់គ្រងដោយឈឺឆ្អាល និង សេចក្ដីចម្រើនដោយឥតហេតុ គឺជាកាតព្វកិច្ចដែលត្រូវកើតឡើងក្នុងករណីដែលបំពេញល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ហេតុដូច្នេះ ត្រូវហៅថា "កាតព្វកិច្ចដែលកំណត់ដោយច្បាប់" ។ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ផ្សេងមួយចំនួនទៀត រួមមានកាតព្វកិច្ចបង់ពន្ធ និង ចំពោះករណីនៃប្រទេសជប៉ុន រួមមានកាតព្វកិច្ចម្ចាស់ទ្រព្យក្នុងការគ្រប់គ្រងទ្រព្យវប្បធម៌ឱ្យបានសមរម្យ និង កាតព្វកិច្ចហាមមិនឱ្យនាំចេញនូវទ្រព្យវប្បធម៌ទាំងនោះ (កាតព្វកិច្ចមិនធ្វើសកម្មភាព) តាមច្បាប់ស្ដីពីការការពារទ្រព្យសម្បត្តិវប្បធម៌ ។ កាតព្វកិច្ចទាំងនេះ កើតចេញដោយផ្ទាល់ពីបញ្ញត្តិនៃច្បាប់ ហេតុដូច្នេះ ជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។

ចំពោះកាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង សកម្មភាពឯកតោភាគី ភាគីមានគោលបំណងបង្កើតឥទ្ធិពលនៃកាតព្វកិច្ចនោះ ហើយអានុភាពគតិយុត្តក៏ត្រូវបានទទួលស្គាល់តាមគោលបំណងនេះដែរ ។ ផ្ទុយទៅវិញ ចំពោះកាតព្វកិច្ចដែលកំណត់ដោយច្បាប់វិញ អានុភាពគតិយុត្តនៃកាតព្វកិច្ចនេះ កើតឡើងដោយបញ្ញត្តិនៃច្បាប់ ដោយមិនទាក់ទងនឹងឆន្ទៈរបស់ភាគីទេ ។ នេះគឺជាភាពខុសគ្នាជាចម្បងរវាងប្រភេទនៃកាតព្វកិច្ចទាំងពីរដែលបានរៀបរាប់មកនេះ ។

ជំពូកទី ២ ដល់ជំពូកទី ៧ ត្រូវបានរៀបចំឡើង ដោយយកកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាជាមូលដ្ឋាន ។ ក្នុងចំណោមជំពូកទាំងនេះ ជំពូកទី ២ ដែលទាក់ទងនឹងការបង្កើតនូវកាតព្វកិច្ច មិនត្រូវយកមកអនុវត្តចំពោះកាតព្វកិច្ចដែលកំណត់ដោយច្បាប់ទេ ។ ប៉ុន្តែ ដោយសារវាមិនមែនជារឿងមិនសមហេតុផល ក្នុងការអនុវត្តជំពូកទី ៣ ដល់ជំពូកទី ៧ ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពអនីត្យានុកូល ជាអាទិ៍ បញ្ញត្តិចាប់ពី ជំពូកទី ៣ ដល់ជំពូកទី ៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិនៃជំពូកទី ៨ ស្ដីពី "អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល" និង ជំពូកទី ៩ ស្ដីពី "អនុប្បទានសិទ្ធិលើបំណុល និង ការទទួលកាតព្វកិច្ច" មិនកំណត់តែចំពោះកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាប៉ុណ្ណោះទេ ហេតុដូច្នេះ បញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តចំពោះកាតព្វកិច្ច

ដែលកំណត់ដោយច្បាប់ លើកលែងតែមានបញ្ញត្តិពិសេសចំពោះចំណុចជាក់លាក់នីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២១ ដល់មាត្រា ៧២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៣៧២ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣១០.–** និយមន័យនៃការបង្ហាញឆន្ទៈ

១-ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ ។

២-ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះ បានទៅដល់ភាគីម្ខាងទៀត ។

(កំណត់)

កថាខណ្ឌទី ១ កំណត់និយមន័យនៃការបង្ហាញឆន្ទៈ ។ កិច្ចសន្យា ត្រូវបង្កើតអានុភាពគតិយុត្តដោយការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា ។ ធាតុផ្សំនៃការព្រមព្រៀងនេះ គឺ "ការបង្ហាញឆន្ទៈ" របស់ភាគីទាំងពីរ ។ ដោយហេតុថា សកម្មភាពឯកតោភាគី (ដូចជាអច្ច័យទាន ជាដើម) ធ្វើឡើងដោយភាគីតែម្ខាង សកម្មភាពឯកតោភាគីនេះ ត្រូវបង្កើតអានុភាពគតិយុត្តដោយការបង្ហាញឆន្ទៈរបស់ភាគីនោះតែឯង ។

ច្បាប់នៃប្រទេសនានាបានប្រកាន់ជំហរពីរផ្សេងគ្នា ។ ឧទាហរណ៍ ច្បាប់ប្រទេសអាល្លឺម៉ង់ប្រកាន់ជំហរថា ការបង្ហាញឆន្ទៈ គឺជាធាតុផ្សំនៃកិច្ចសន្យា រីឯច្បាប់ប្រទេសបារាំង និង អង់គ្លូអាមេរិកប្រកាន់ជំហរថា ការបង្ហាញឆន្ទៈ ពុំមែនជាធាតុផ្សំនៃកិច្ចសន្យាទេ ។ ប៉ុន្តែ ដើម្បីពន្យល់អំពីអានុភាពចងនៃកិច្ចសន្យា តម្រូវឱ្យមាន "ស្ទីការរបស់ភាគី" ដែលព្រមព្រៀងលើកិច្ចសន្យា ។ ការនេះ ហៅថា ការបង្ហាញឆន្ទៈ ។ ក្រមរដ្ឋប្បវេណីរបស់កេបិច ដែលធ្វើឡើងដោយផ្អែកតាមក្រមរដ្ឋប្បវេណីបារាំង ចែងថា "ការដោះដូរស្ទីការ (exchange of consents)" មានភាពចាំបាច់ ដើម្បីបង្កើតកិច្ចសន្យា ។ ពាក្យថា "ស្ទីការ (consent)" នេះមានប្រភពពីពាក្យ "consentement" ក្នុងក្រមរដ្ឋប្បវេណីបារាំង ហើយមានន័យសារធាតុដូចគ្នានឹងពាក្យ "ការបង្ហាញឆន្ទៈ" ក្នុងមាត្រានេះ ។ ពាក្យថា "ការបង្ហាញ" ត្រូវបានប្រើក្នុងនេះ ដោយសារឆន្ទៈក្នុងការបង្កើតឱ្យមានអានុភាពគតិយុត្ត ត្រូវតែស្តែងចេញមកខាងក្រៅ ។

កថាខណ្ឌទី ២ ប្រកាន់យកគោលការណ៍ថា ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះ បានទៅដល់ភាគីម្ខាងទៀត ។ ការបង្ហាញឆន្ទៈ មានអានុភាពភ្លាម ក្នុងករណីដែលការបង្ហាញត្រូវបានធ្វើដោយផ្ទាល់ខ្លួន នៅចំពោះមុខភាគីម្ខាងទៀត ឬ តាមរយៈសារអេឡិចត្រូនិច ជាដើម ។ ក្នុងករណីដែលការបង្ហាញឆន្ទៈ ធ្វើឡើងតាមរយៈលិខិតដែលផ្ញើតាមប្រៃសណីយ៍ ពេលផ្ញើខុសពីពេលទទួលការជូនដំណឹង ។ ក្នុងករណីនេះ ការបង្ហាញឆន្ទៈនោះ ត្រូវមានអានុភាព នៅពេលបានទៅដល់ភាគីម្ខាងទៀត ។ សូមមើលមាត្រា ៣៣៧ សម្រាប់

ព័ត៌មានបន្ថែមអំពីស្ទីការក្នុងកិច្ចសន្យា ។

ប្រសិនបើប្រកាន់គោលការណ៍ដែលថា ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព នៅពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត បញ្ហាអាចនឹងកើតឡើង ក្នុងករណីដែលភាគីដែលបង្ហាញឆន្ទៈទទួលមរណភាព ឬ ត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព មុនពេលដែលការជូនដំណឹងអំពីបង្ហាញឆន្ទៈ បានទៅដល់ភាគីម្ខាងទៀត ។ ក្នុងករណីនេះ ត្រូវបកស្រាយថា ការបង្ហាញឆន្ទៈមានអានុភាព ទោះបីជាមិនមានចែងច្បាស់លាស់ក៏ដោយ ។

ការបានទៅដល់ មានន័យថា ការជូនដំណឹងនោះបានទៅដល់តំបន់ត្រួតត្រារបស់ភាគីម្ខាងទៀត ។ ហេតុដូច្នេះ គួរតែបកស្រាយថា ការបង្ហាញឆន្ទៈបានទៅដល់ភាគីម្ខាងទៀត នៅពេលការបង្ហាញនោះត្រូវបានដាក់ក្នុងប្រអប់សំបុត្ររបស់ភាគីម្ខាងទៀត ទោះបីជាភាគីម្ខាងទៀតពុំបានដឹងអំពីការមកដល់នោះក៏ដោយ ។

ដើម្បីសន្និដ្ឋានថាការបង្ហាញឆន្ទៈបានដល់ ភាគីម្ខាងទៀតដែលទទួលការបង្ហាញឆន្ទៈនោះ ចាំបាច់មានសមត្ថភាពក្នុងការវិនិច្ឆ័យ ។ ហេតុដូច្នេះ ប្រសិនបើភាគីម្ខាងទៀតគឺជាអនីតិជន ការបង្ហាញឆន្ទៈត្រូវធ្វើឡើងចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ។ ទោះបីជាពុំមានចែងច្បាស់លាស់អំពីចំណុចនេះក៏ដោយ អាចធ្វើសេចក្ដីសន្និដ្ឋានដូចគ្នា តាមរយៈការបកស្រាយមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨៦ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍ច្បាប់ស្ដីពីកិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២. ១០២

## **មាត្រា ៣១១.- និយមន័យនៃកិច្ចសន្យា**

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ។

(កំណត់)

មាត្រានេះ កំណត់និយមន័យនៃកិច្ចសន្យាតាមទស្សនវិស័យពីរ ។ ទស្សនវិស័យទីមួយថា កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈ ដោយផ្អែកលើគោលការណ៍នៃកិច្ចសន្យារបស់ប្រព័ន្ធច្បាប់ស៊ីវិល ។ ទស្សនវិស័យមួយទៀតថា ឆន្ទៈភាគីគឺចង់បង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច ។

កិច្ចសន្យាមានប្រភេទផ្សេងៗគ្នា ។ មានសារៈសំខាន់ក្នុងការបែងចែកកិច្ចសន្យាជា កិច្ចសន្យាអញ្ញមញ្ញ និង កិច្ចសន្យាឯកតោភាគី ។ លើសពីនេះ នៅមានការបែងចែកកិច្ចសន្យាជា កិច្ចសន្យាដែលយកតម្លៃថ្នូរ (មូលា) និង កិច្ចសន្យាមុធា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១០១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៨ នៃក្រម

រដ្ឋប្បវេណីកេបិច ។ ពុំមានបញ្ញត្តិអំពីនិយមន័យនៃកិច្ចសន្យាទេ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ៣១២.-** និយមន័យនៃសកម្មភាពឯកតោភាគី

១-សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី ៤ (ការតំណាង) នៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគី ។

(កំណត់)

តាមគោលការណ៍ ការផ្លាស់ប្តូរទំនាក់ទំនងកាតព្វកិច្ច (ការបង្កើត ការផ្លាស់ប្តូរ ឬ ការរំលត់កាតព្វកិច្ច) ពុំមានអានុភាព បើគ្មានការព្រមព្រៀងទៅវិញទៅមក ដោយសារការផ្លាស់ប្តូរនោះ នឹងធ្វើឱ្យមានឥទ្ធិពលដល់ម្ចាស់បំណុល ឬ កូនបំណុល ។ ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យា ឬ បញ្ញត្តិច្បាប់ផ្តល់ឱ្យភាគីណាមួយ នូវសិទ្ធិផ្លាស់ប្តូរទំនាក់ទំនងកាតព្វកិច្ច ការផ្លាស់ប្តូរអាចកើតឡើង បើបុគ្គលដែលត្រូវបានផ្តល់សិទ្ធិនេះអនុវត្តសិទ្ធិរបស់ខ្លួន ។ ឧទាហរណ៍អំពីការផ្លាស់ប្តូរដោយផ្អែកតាមកិច្ចសន្យា រួមមានសិទ្ធិរំលាយដែលកំណត់នៅក្នុងកិច្ចសន្យា ។ ការបង្ហាញឆន្ទៈក្នុងការអនុវត្តសិទ្ធិរំលាយដែលកំណត់នៅក្នុងកិច្ចសន្យានេះ គឺជាសកម្មភាពឯកតោភាគីរបស់ភាគីដែលមានសិទ្ធិរំលាយនេះ ។ ឧទាហរណ៍នៃសកម្មភាពឯកតោភាគីដែលកំណត់ដោយច្បាប់ រួមមានការបង្កើតមូលនិធិ ការលើកលែងកាតព្វកិច្ច អច្ច័យទាន និង ការបោះបង់កម្មសិទ្ធិ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

គោលការណ៍ច្បាប់ស្តីពីកិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២. ១០៧ មាត្រា ១១១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។ ពុំមានបញ្ញត្តិអំពីចំណុចនេះក្នុងក្រមរដ្ឋប្បវេណីជប៉ុនទេ ។

## ផ្នែកទី ២ ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច

**មាត្រា ៣១៣.-** ប្រភេទនៃកាតព្វកិច្ច

ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ។

( កំណត់)

មាត្រានេះរៀបរាប់ពីខ្លឹមសារនៃកាតព្វកិច្ចដែលច្បាប់អនុញ្ញាត ។ ច្បាស់ណាស់ដែលកាតព្វកិច្ចប្រគល់វត្ថុ ត្រូវបានអនុញ្ញាត ដូចជាកិច្ចសន្យាលក់ទិញ ។ កាតព្វកិច្ចដែលគោលបំណងធ្វើសកម្មភាពអ្វីមួយ ក៏ត្រូវបានអនុញ្ញាតដែរ ដូចជាកិច្ចសន្យាអាណត្តិ និង កិច្ចសន្យាការងារ ។ ទោះបីជាគ្មានបញ្ញត្តិចែងអំពីកាតព្វកិច្ចមិនធ្វើសកម្មភាព នៅក្នុងគន្លឹស្តីពីកិច្ចសន្យាផ្សេងៗក៏ដោយ ក៏មាត្រានេះបញ្ជាក់ថា ការមិនឱ្យធ្វើសកម្មភាពណាមួយ អាចក្លាយជាខ្លឹមសារនៃកាតព្វកិច្ចផងដែរ ។ ឧទាហរណ៍ រួមមានកិច្ចព្រមព្រៀងស្តីពីការទប់ស្កាត់ការបំពុលបរិយាកាសសាធារណៈ ដូចជាការតម្រូវមិនឱ្យមានសម្លេងថ្លង់លើសពីកម្រិតដែលបានកំណត់ និង មិនឱ្យចាក់ចោលសារធាតុគ្រោះថ្នាក់លើសពីចំនួនកំណត់ ជាអាទិ៍ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ២៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១១០១ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៣១៤.–** កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

( កំណត់)

កាតព្វកិច្ចប្រគល់វត្ថុ អាចបែងចែកជាកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ និង កាតព្វកិច្ចប្រគល់វត្ថុមិនជាក់លាក់ ។ មាត្រានេះចែងអំពីករណីយកិច្ចគ្រប់គ្រង ឬ ថែរក្សាវត្ថុដែលជាកម្មវត្ថុ រហូតដល់ពេលប្រគល់វត្ថុនោះ (តទៅនេះ ហៅថា "ករណីយកិច្ចថែរក្សាវត្ថុ") ក្នុងករណីដែលកាតព្វកិច្ច ជាកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ ។ ជាញឹកញយ ករណីយកិច្ចថែរក្សាវត្ថុ ពុំមានចែងក្នុងកិច្ចសន្យានោះទេ ។ ក្នុងករណីនេះ មាត្រានេះដើរតួនាទីជាបញ្ញត្តិតាមការស្ម័គ្រចិត្ត (បញ្ញត្តិដែលមិនត្រូវអនុវត្តដាច់ខាត ហើយភាគីអាចព្រមព្រៀងផ្សេងបាន តែបើគ្មានការព្រមព្រៀងផ្សេងរវាងភាគីទេ នឹងអនុវត្តតាមបញ្ញត្តិនោះ) ។ យោងតាមមាត្រានេះ កម្រិតដែលកូនបំណុលត្រូវទទួលបន្ទុកចំពោះការថែរក្សាវត្ថុ គឺជា "ករណីយកិច្ចក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ" ដែលជាបន្ទុកមួយដែលធ្ងន់ធ្ងរជាង "ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ខ្លួន" ទៅទៀត ។ ប្រសិនបើកូនបំណុលធ្វើឱ្យខូចខាត ឬ បាត់បង់វត្ថុដែលជាកម្មវត្ថុនោះ ដោយផ្ទុយនឹងករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ កូនបំណុលនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ដោយសន្មតថា មានកំហុស ។

"វត្ថុជាក់លាក់" គឺជាពាក្យផ្ទុយនឹង "វត្ថុមិនជាក់លាក់" និងមានភិនភាគសំគាល់មួយចំនួន ។ ឧទាហរណ៍អំពីវត្ថុ

ជាក់លាក់រួមមាន ដីធ្លី អគារ ស្នាដៃសិល្បៈ និង ឡានជំនំ ជាដើម ។ ប៉ុន្តែ ដីធ្លី អាចត្រូវកំណត់ថាជា "វត្ថុមិនជាក់លាក់" បានដែរ ប្រសិនបើដីធ្លីណាដែលបំពេញតាមល័ក្ខខ័ណ្ឌមួយចំនួន អាចយកមកធ្វើជាកម្មវត្ថុនៃកាតព្វកិច្ច ។ ក្នុងន័យនេះ ការកំណត់វត្ថុជាក់លាក់ ឬ មិនជាក់លាក់ ត្រូវផ្អែកលើកិច្ចសន្យានីមួយៗ ។ ដូចគ្នានេះដែរ ក្នុងការលក់បសុសត្វ បសុសត្វអាចជាក់លាក់ ឬ មិនជាក់លាក់ ដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ ។ ចំពោះសេះប្រណាំងដែលបានកំណត់ពិសេស ត្រូវជួញដូរជាវត្ថុជាក់លាក់ រីឯមាន់ម្ភៃក្បាល ត្រូវជួញដូរជាវត្ថុដែលបានកំណត់តាមប្រភេទ ។

ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ជាវត្ថុមិនជាក់លាក់ ឬ វត្ថុដែលបានកំណត់តាមប្រភេទ ទោះបីជាកូនបំណុលបំផ្លាញ ឬ ធ្វើឱ្យខូចខាតដល់វត្ថុមិនជាក់លាក់ ឬ វត្ថុដែលកំណត់តាមប្រភេទនោះក៏ដោយ ក៏ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច មិនត្រូវកើតឡើងឡើយ ។ ពីព្រោះមានវត្ថុមិនជាក់លាក់ ឬ វត្ថុដែលកំណត់តាមប្រភេទដែលដូចគ្នា ហើយកូនបំណុលអាចរកវត្ថុដែលដូចគ្នានោះមកជំនួស និង ផ្តល់តាវកាលិកនោះបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣១៥.–** កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវផ្តល់ មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពមធ្យម ។

២-ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះកំណត់អំពីករណីយកិច្ចដែលកូនបំណុលត្រូវទទួល ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចដែលត្រូវផ្តល់តាវកាលិក ជាវត្ថុកំណត់តាមប្រភេទ ។ មាត្រានេះចែងអំពីគុណភាពនៃវត្ថុដែលកូនបំណុលត្រូវផ្តល់តាវកាលិក និង វិធីកំណត់វត្ថុជាក់ស្តែងដែលផ្តល់តាវកាលិក ។

កាតព្វកិច្ចដែលបានកំណត់ប្រភេទ គឺជាកាតព្វកិច្ចដែលកម្មវត្ថុនោះត្រូវកំណត់ដោយផ្អែកលើប្រភេទ គុណភាព និង

បរិមាណ ។ ឧទាហរណ៍នៃកាតព្វកិច្ចបែបនេះ រួមមានការលក់ទិញរ៉ែដែកចំនួន ១០ តោន ស៊ុតចំនួន ១០០ គ្រាប់ និង ទូរទស្សន៍ថ្មីចំនួន ២០ គ្រឿង ជាដើម ។ ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ គុណភាពវត្ថុដែលកូនបំណុលត្រូវផ្តល់តាវកាលិក មានសារសំខាន់ពិសេស ។ ជាធម្មតា គុណភាពនោះត្រូវបានកំណត់ក្នុងកិច្ចសន្យា ប៉ុន្តែ ប្រសិនបើភាគីនៃកិច្ចសន្យា ពុំបានកំណត់គុណភាព កូនបំណុលអាចផ្តល់តាវកាលិកនូវវត្ថុដែលមាន "គុណភាពមធ្យម" បាន ។

កថាខណ្ឌទី ២ ចែងអំពីវិធីកំណត់វត្ថុជាក់ស្តែងដែលត្រូវប្រគល់ទៅម្ចាស់បំណុល ពីក្នុងចំណោមវត្ថុដែលកំណត់តាមប្រភេទជាច្រើននោះ ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាលក់ទិញទូរទស្សន៍ចំនួន ២០ គ្រឿង ប្រសិនបើអ្នកលក់មានទូរទស្សន៍ចំនួន ១០០ គ្រឿង ក្នុងឃ្លាំង អ្នកលក់ត្រូវជ្រើសរើសយកចំនួន ២០ គ្រឿង ។ ក្រោយពេលដែលកូនបំណុលបានជ្រើសរើសទូរទស្សន៍ចំនួន ២០ គ្រឿង និង បញ្ចប់ការរៀបចំប្រគល់វត្ថុដល់អ្នកទិញរួចហើយ ករណីយកិច្ចរបស់អ្នកលក់ ត្រូវកំណត់នៅត្រឹមករណីយកិច្ចផ្តល់តាវកាលិកនូវទូរទស្សន៍ទាំង ២០ គ្រឿងនោះ ។ ការនេះហៅថា ការកំណត់កាតព្វកិច្ចដែលបានកំណត់ប្រភេទ ។ ជាលទ្ធផលនៃការកំណត់នោះ អ្នកលក់មានករណីយកិច្ចថែរក្សាទូរទស្សន៍ទាំង ២០ គ្រឿងនោះ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ តាមមាត្រា ៣១៤ ដោយហេតុថា ស្ថានភាពនេះ ស្រដៀងនឹងការប្រគល់វត្ថុជាក់លាក់ដែរ ។ ប្រសិនបើអ្នកលក់ធ្វើឱ្យខូចខាត ឬ បាត់បង់ទូរទស្សន៍ទាំង ២០ គ្រឿងនោះ មុនកាលបរិច្ឆេទប្រគល់ បញ្ហាអាចនឹងកើតឡើងថា តើអ្នកលក់ត្រូវប្រគល់ទូរទស្សន៍ចំនួន ២០ គ្រឿងផ្សេងទៀតដែលមានប្រភេទដូចគ្នា ឬ គ្រាន់តែត្រូវសងសំណងការខូចខាត ។ ក្នុងករណីកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់ ដូចជា ការលក់ទិញអគារជាដើម អ្នកលក់គ្មានករណីយកិច្ចប្រគល់វត្ថុជំនួសទេ ជម្រើសតែមួយគឺត្រូវសងសំណងការខូចខាត ។ ក្នុងករណីនៃកាតព្វកិច្ចដែលបានកំណត់ប្រភេទវិញ អាចមានការបកស្រាយថា ទោះបីជាកាតព្វកិច្ចដែលបានកំណត់ប្រភេទ ត្រូវបានកំណត់ជាក់លាក់ក៏ដោយ ក៏កាតព្វកិច្ចនេះមិនត្រូវក្លាយជា "កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់" ដែរ ហើយមានវត្ថុដូចគ្នាដែលអាចយកជំនួសវត្ថុដែលខូចខាត ឬ បាត់បង់នោះបាន ហេតុដូច្នេះ ម្ចាស់បំណុលអាចទាមទារវត្ថុជំនួសវត្ថុដែលខូចខាត ឬ បាត់បង់ ដោយកំហុសរបស់កូនបំណុល ។ ទោះជាយ៉ាងណាក៏ដោយ ការដោះស្រាយបញ្ហានេះ ត្រូវពឹងផ្អែកលើយុត្តិសាស្ត្រ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣១៦.– កាតព្វកិច្ចជាប្រាក់

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ កូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និង កូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសបានដែរ ។

២-ក្នុងករណីដែលរូបិយវត្ថុពិសេសដែលបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការផ្តល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច ។

(កំណត់)

មាត្រានេះកំណត់អំពីរូបិយវត្ថុដែលអាចយកមកសងចំពោះកាតព្វកិច្ចដែលមានកម្មវត្ថុជាការផ្តល់តាវកាលិកនូវប្រាក់ដែលមានចំនួនកំណត់ ។

កថាខណ្ឌទី ១ ចែងថា រូបិយវត្ថុស្របច្បាប់ណាក៏អាចយកមកសងចំពោះកាតព្វកិច្ចជាប្រាក់បានដែរ ។ រូបិយវត្ថុសំដៅលើក្រដាសប្រាក់ក្តី ឬ កាក់ក្តីដែលអាចយកមកចាយវាយដោយស្របច្បាប់ ។ ប្រភេទនៃរូបិយវត្ថុ និង វិសាលភាពនៃភាពស្របច្បាប់ នឹងត្រូវបានកំណត់ដោយច្បាប់ផ្សេង ។ ក្នុងប្រទេសជប៉ុន វិសាលភាពនៃកាក់មានកម្រិតដោយហេតុថា ប្រសិនបើកូនបំណុលសងចំពោះកាតព្វកិច្ចជាប្រាក់ចំនួនច្រើន ដោយសងជាកាក់នោះ ម្ចាស់បំណុលនឹងមានការលំបាកក្នុងការទទួល ថែរក្សា និង គ្រប់គ្រង ។ រីឯចំពោះក្រដាសប្រាក់ដែលបោះពុម្ពដោយធនាគារកណ្តាលវិញ ពុំមានការកម្រិតណាមួយនោះទេ ។

កថាខណ្ឌទី ២ ចែងថា ទោះបីជាភាគីព្រមព្រៀងគ្នាថានឹងប្រើប្រាស់រូបិយវត្ថុពិសេសសម្រាប់ការសងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ក៏ដោយ ក៏កូនបំណុលត្រូវសងជារូបិយវត្ថុផ្សេងទៀតដែរ ក្នុងករណីដែលរូបិយវត្ថុពិសេសនោះ លែងស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច ។ ការតម្រូវដូច្នេះជារឿងសមរម្យ ដោយសារការសងជារូបិយវត្ថុដែលលែងស្របច្បាប់ទៅហើយនោះ មិនអាចក្លាយទៅជាការសងនោះទេ ។

កថាខណ្ឌទី ៣ ចែងថា ក្នុងករណីដែលភាគីព្រមព្រៀងគ្នាសងជារូបិយវត្ថុបរទេស កូនបំណុលអាចសង ដោយប្រើប្រភេទផ្សេងៗនៃរូបិយវត្ថុបរទេសនោះ ។ ឧទាហរណ៍ ប្រសិនបើបុគ្គលម្នាក់មានកាតព្វកិច្ចសងប្រាក់ចំនួន ១០០០ ដុល្លារ កូនបំណុលនោះអាចសងជារូបិយវត្ថុផ្សេងបាន ដូចជា ក្រដាសប្រាក់ ១ ដុល្លារ ក្រដាសប្រាក់ ១០ ដុល្លារ ក្រដាសប្រាក់ ២០ ដុល្លារ និង ក្រដាសប្រាក់ ១០០ ដុល្លារ ជាដើម ។ ក្នុងករណីនេះ មិនចាំបាច់ត្រូវតែគោរពតាមច្បាប់របស់សហរដ្ឋអាមេរិកចំពោះវិសាលភាពនៃភាពស្របច្បាប់ក្នុងការប្រើប្រាស់រូបិយវត្ថុនោះទេ ។ ទោះបីជាមានច្បាប់ក្នុងប្រទេសនោះកំណត់អំពីវិសាលភាពនៃរូបិយវត្ថុក៏ដោយ វិសាលភាពនៃភាពអាចប្រើប្រាស់រូបិយវត្ថុដុល្លារនេះ ត្រូវផ្អែកលើកត្តាសេដ្ឋកិច្ច និង សង្គមរបស់កម្ពុជា ។ កថាខណ្ឌទី ៣ ចែងថា បញ្ញត្តិនៃកថាខណ្ឌទី ២ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ មានន័យថា ប្រសិនបើកូនបំណុលសន្យាសង ១០០០ ដុល្លារ ជាក្រដាសប្រាក់ ១០ ដុល្លារ តែក្រដាសប្រាក់ ១០ ដុល្លារលែងជារូបិយវត្ថុស្របច្បាប់ នោះកូនបំណុលអាចសងជាក្រដាសដុល្លារផ្សេងទៀតបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៩៥ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៣១៧.-** កាតព្វកិច្ចជារូបិយវត្ថុបរទេស

១-ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

២-ក្នុងករណីដែលកូនបំណុលដែលមានការយឺតយ៉ាវក្នុងការអនុវត្ត សងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលសង ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេសនៅពេលកំណត់អនុវត្ត ឬ នៅពេលដែលកូនបំណុលសងបាន ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

(កំណត់)

មាត្រានេះចែងនូវវិធានស្តីពីកាតព្វកិច្ចជាប្រាក់ដែលត្រូវបានកំណត់ជារូបិយវត្ថុបរទេស ។

បញ្ហាដែលអាចកើតឡើងចំពោះកាតព្វកិច្ចជាប្រាក់ដែលត្រូវបានកំណត់ជារូបិយវត្ថុបរទេស គឺថា តើម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលសងជារូបិយវត្ថុបរទេសបាន ឬ មិនបាន ។ បញ្ហានេះកើតឡើង ដោយសាររូបិយវត្ថុបរទេសគ្មានភាពស្របច្បាប់ (អានុភាពក្នុងការបង្ខំឱ្យទទួល) ។ ម្យ៉ាងទៀត មានករណីខ្លះដែលមានផលពិបាកសម្រាប់កូនបំណុល ក្នុងការរករូបិយវត្ថុបរទេសដែរ ។ ហេតុដូច្នេះ មាត្រានេះចែងថា ទោះបីជាចំនួនទឹកប្រាក់នៃកាតព្វកិច្ច ត្រូវបានកំណត់ជារូបិយវត្ថុបរទេសក៏ដោយ ក៏កូនបំណុលអាចជ្រើសរើសសងជារូបិយវត្ថុជាតិបាន ពោលគឺ ប្រាក់រៀល ដែលជារូបិយប័ណ្ណរបស់ព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើកូនបំណុលជ្រើសរើសសងជារូបិយវត្ថុជាតិ ចាំបាច់ត្រូវប្តូរជារូបិយវត្ថុជាតិនូវចំនួនដែលត្រូវបានកំណត់ជារូបិយវត្ថុបរទេស ។ ក្នុងករណីនេះ មានបញ្ហាថា តើយកអត្រាប្តូររូបិយវត្ថុ នៅពេលណា និង នៅកន្លែងណា ។ ចំពោះបញ្ហានេះ អត្រាប្តូររូបិយវត្ថុនោះ ត្រូវយកតាមអត្រាប្តូររូបិយវត្ថុនៃទីកន្លែង និង ពេលវេលាដែលកូនបំណុលអនុវត្តកាតព្វកិច្ច ។ ជាគោលការណ៍ កូនបំណុលអាចសងជារូបិយវត្ថុជាតិបាន ប៉ុន្តែ ក្នុងករណីដែលកូនបំណុល និង ម្ចាស់បំណុលបានសន្យាសងជារូបិយវត្ថុបរទេស កូនបំណុលត្រូវសងជារូបិយវត្ថុបរទេសនោះ ។

កថាខណ្ឌទី ២ កំណត់អំពីការចាត់ចែងក្នុងករណីដែលមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។ ករណីនេះខុសពីករណីដែលកូនបំណុលអនុវត្តកាតព្វកិច្ចនៅពេលកំណត់សង គឺកូនបំណុលមិនគួរមានសិទ្ធិជ្រើសរើសយករូបិយវត្ថុដែលធ្វើឱ្យខ្លួនមានប្រៀបលើម្ចាស់បំណុល តាមអត្រាប្តូររូបិយវត្ថុបានទេ ដោយសារខ្លួនមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។ ឧទាហរណ៍ ប្រសិនបើអត្រាប្តូររូបិយវត្ថុបរទេសនៅពេលសងជាក់ស្តែង ទាបជាងអត្រាតាមកាលបរិច្ឆេទកំណត់តាមកិច្ចសន្យា ហើយប្រសិនបើអនុញ្ញាតឱ្យកូនបំណុលសងជារូបិយវត្ថុកម្ពុជា នោះកូនបំណុលនឹងអាចទទួលផលប្រយោជន៍ហួសហេតុ (ទោះបីជាកូនបំណុលសងជារូបិយវត្ថុបរទេសក៏ដោយ ម្ចាស់បំណុលនឹងខាតអត្រាប្តូររូបិយវត្ថុ ប្រសិនបើខ្លួនត្រូវប្តូរចំនួននៃកាតព្វកិច្ចនោះជារូបិយវត្ថុជាតិ ប៉ុន្តែ នេះគឺជាភាពប្រថុយប្រថានដែលមិនអាចជៀសវាងបានក្នុងការកំណត់កាតព្វកិច្ចជារូបិយវត្ថុបរទេស) ។ ហេតុដូច្នេះ កថាខណ្ឌទី ២ នេះបានកំណត់ថា ក្នុងករណីដែលមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចជារូបិយវត្ថុបរទេស ទោះបីជាកូនបំណុលអាចសងជារូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ម្ចាស់បំណុលអាចកំណត់យកអត្រាប្តូររូបិយវត្ថុពេលកំណត់សងតាមការសន្យាក៏បាន ឬ អត្រាពេលសងជាក់ស្តែងក៏បាន ។ ឧទាហរណ៍ ប្រាក់ដុល្លារពេលសងជាក់ស្តែងដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ធ្លាក់ពី ៥០០០ រៀល ក្នុងមួយដុល្លារ ដល់ ៣០០០ រៀល ក្នុងមួយដុល្លារ នៅកាលបរិច្ឆេទសងតាមកិច្ចសន្យា (តម្លៃរៀលឡើង) ។ ម្ចាស់បំណុល អាចទទួលបាននូវចំនួនទឹកប្រាក់នៃកាតព្វកិច្ច ដោយគិតតាមអត្រា ៥០០០ រៀល ក្នុងមួយដុល្លារ ប្រសិនបើកូនបំណុល សងតាមកំណត់ពេល ។ គោលបំណងនៃកថាខណ្ឌទី ២ គឺ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល ។ ប្រសិនបើមិនទទួលស្គាល់សិទ្ធិជ្រើសរើសដូច្នេះចំពោះម្ចាស់បំណុលទេ នៅពេលដែលតម្លៃដុល្លារកំពុងធ្លាក់ កូនបំណុលនឹងពន្យារការសងដើម្បីរង់ចាំដល់ពេលប្រាក់រៀលឡើងថ្លៃ ហើយសងជាប្រាក់រៀល ។ ផលប្រយោជន៍របស់ភាគីទាំងពីរ ក៏អាចត្រូវបានសម្របសម្រួលដោយឱ្យកូនបំណុលសងការខូចខាតចំពោះការឡើង ឬ ចុះនៃអត្រាប្តូររូបិយវត្ថុដោយសារការយឺតយ៉ាវរបស់ខ្លួនក្នុងការអនុវត្តកាតព្វកិច្ចផងដែរ ។ ប៉ុន្តែ មានបញ្ហាថា ការខាតបង់ដែលបណ្តាលពីការឡើងចុះនៃអត្រាប្តូររូបិយវត្ថុ តើត្រូវទទួលស្គាល់ក្នុងកម្រិតណាថាជាការខូចខាតចំពោះម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចជាប្រាក់ ។ ហេតុដូច្នេះ កថាខណ្ឌទី ២ ដោះស្រាយបញ្ហានេះ ដោយបង្កើតឱ្យមានជាវិធានស្តីពីអត្រាប្តូររូបិយវត្ថុ ក្នុងករណីដែលកូនបំណុលអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសរូបិយវត្ថុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០៣ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣១៨.– អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ។

(កំណត់)

មាត្រានេះចែងអំពីអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ។

អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ត្រូវអនុវត្តចំពោះករណីដែលកាតព្វកិច្ចដែលភ្ជាប់នឹងការប្រាក់ តាមច្បាប់ ឬ តាមកិច្ចសន្យា លើកលែងតែភាគីព្រមព្រៀងអំពីអត្រាផ្សេងពីនេះ ។

ការប្រាក់ សំដៅលើទឹកប្រាក់ ឬ វត្ថុជំនួសផ្សេងទៀត ដែលត្រូវសងជាថ្នូរនឹងការប្រើប្រាស់ប្រាក់ ឬ វត្ថុដើម តាមរយៈពេលនៃការប្រើប្រាស់ ។ ដូច្នេះ កាតព្វកិច្ចដែលជាប្រាក់ ឬ វត្ថុដើម ត្រូវតែមានលក្ខណៈអាចជំនួសបាន ដូចជា កាតព្វកិច្ចជាប្រាក់ ឬ អង្ករ ជាអាទិ៍ ហើយត្រូវតែជាអ្វីដែលក្លាយជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគ ។

កាតព្វកិច្ចដែលមានការប្រាក់ សំដៅលើកាតព្វកិច្ចដែលការប្រាក់នឹងកើតឡើង តាមច្បាប់ ឬ តាមកិច្ចសន្យា ។ ឧទាហរណ៍ចម្បងនៃកាតព្វកិច្ចដែលការប្រាក់នឹងកើតឡើងតាមកិច្ចសន្យា គឺកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីបរិភោគដែលភ្ជាប់នឹងការប្រាក់ ។ ចំពោះកាតព្វកិច្ចដែលភ្ជាប់នឹងការប្រាក់តាមផ្លូវច្បាប់ មានប្រទេសខ្លះដែលមានបញ្ញត្តិស្ដីពីការប្រាក់ដែលត្រូវបន្ថែមលើសិទ្ធិទាមទារសំណងការខូចខាតដោយអំពើអនីត្យាកូល (មាត្រា ៨៤៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់) ។ ប៉ុន្តែ ទោះបីជាគ្មានបញ្ញត្តិនេះក៏ដោយ ក៏អាចទទួលលទ្ធផលដូចគ្នានេះដែរ ដោយអនុវត្តមាត្រា ៣៣៩ នៃក្រមនេះ ដែលចែងអំពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។ មានន័យថា ក្នុងករណីដែលកាតព្វកិច្ចត្រូវសងសំណងការខូចខាតដោយអំពើអនីត្យានុកូល កូនបំណុលធ្លាក់ទៅក្នុងស្ថានភាពនៃការយឺតយ៉ាវ ចាប់ពីពេលដែលការខូចខាតនោះបានកើតឡើង ហេតុដូច្នេះ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ត្រូវគិតពីពេលនោះទៅ ។ តាមន័យនេះ កាតព្វកិច្ចសងសំណងការខូចខាតដោយអំពើអនីត្យានុកូល ត្រូវចាត់ទុកជា "កាតព្វកិច្ចដែលភ្ជាប់នឹងការប្រាក់" ។

នាពេលថ្មីៗនេះ ជំនួសឱ្យអត្រាការប្រាក់ដែលកំណត់ដោយច្បាប់មិនប្រែប្រួល ប្រទេសមួយចំនួនយកអត្រាការប្រាក់ផ្លូវការដែលកំណត់ដោយធនាគារជាតិ មកធ្វើជាអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ។ ដោយសារសេចក្ដីសម្រេចថា តើត្រូវអនុវត្តអត្រាការប្រាក់ដែលអាចប្រែប្រួលបាននេះ មិនត្រឹមតែតម្រូវឱ្យមានការពិចារណាផ្នែកច្បាប់ប៉ុណ្ណោះទេ តែត្រូវគិតទាំងផ្នែកសេដ្ឋកិច្ច និង នយោបាយថែមទៀត នោះវិធីសាស្ត្រជាទំនៀមទម្លាប់នៃការកំណត់អត្រាការប្រាក់ដែលមិនប្រែប្រួល ត្រូវបានយកមកប្រើប្រាស់ក្នុងក្រមនេះ ។ អត្រាដែលសមរម្យគឺ ៤ ទៅ ៦ ភាគរយ ។ ក្រមនេះកំណត់យកចំណុចកណ្ដាលគឺ ៥ ភាគរយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០៤ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៤៦ និង មាត្រា ២៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣១៩.– ការប្រាក់សមាស

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានដាស់តឿនឱ្យសងយ៉ាងណាក៏

ដោយ ក៏កូនបំណុលមិនព្រមសងការប្រាក់នោះ ម្ចាស់បំណុលអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

(កំណត់)

មាត្រានេះកំណត់អំពីការប្រាក់លើការប្រាក់ ឬ ហៅថា ការប្រាក់សមាស ។ ការប្រាក់សមាស សំដៅលើការបន្ថែមការប្រាក់ទៅលើការប្រាក់ដែលមិនទាន់បានសង ។ ឧទាហរណ៍ ប្រសិនបើទឹកប្រាក់ចំនួន ១០០០ ដុល្លារ ត្រូវបានឱ្យខ្ចីដោយមានការប្រាក់ ៨ ភាគរយ ក្នុងមួយឆ្នាំ ចំនួនទឹកប្រាក់សរុបនៃប្រាក់ដើម និង ការប្រាក់ គឺ ១០៨០ ដុល្លារ រយៈពេលមួយឆ្នាំ ក្រោយមក ។ ភាគីទាំងពីរអាចព្រមព្រៀងពិសេសថា ការប្រាក់ត្រូវគិតតាមប្រាក់ដើម ១០៨០ ដុល្លារ នៅឆ្នាំទី ២ ។ ដោយសារការប្រាក់សមាសបន្ថែមបន្ទុកចំពោះកូនបំណុល ការប្រាក់សមាសនេះអាចធ្វើបាន លុះត្រាតែបំពេញតាមល័ក្ខខ័ណ្ឌកំណត់ ។ មាត្រានេះអនុញ្ញាតឱ្យយកការប្រាក់សមាស តែក្នុងករណីដែលកូនបំណុលខានសងការប្រាក់ចាប់ពី ១ (មួយ) ឆ្នាំឡើងទៅតែប៉ុណ្ណោះ ។ ការកំណត់អត្រាការប្រាក់ប្រចាំខែ និង បញ្ចូលការប្រាក់នោះជាប្រាក់ដើម មួយខែក្រោយកូនបំណុលមិនសងការប្រាក់ ត្រូវតែហាមឃាត់ តាមមាត្រានេះ ។ ហេតុនេះ ទោះបីជាមានការព្រមព្រៀងរវាងភាគីក៏ដោយ ការព្រមព្រេងនេះ គ្មានសុពលភាពនោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០៥ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៤៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣២០.- កាតព្វកិច្ចអនិយ័ត

ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមការផ្តល់ច្រើនប្រភេទ កូនបំណុលត្រូវមានសិទ្ធិជ្រើសរើស ។ ប៉ុន្តែ ភាគីនៃកិច្ចសន្យាអាចឱ្យសិទ្ធិជ្រើសរើសនោះទៅម្ចាស់បំណុល ឬ តតិយជន តាមការកំណត់ផ្សេងបាន ។

(កំណត់)

មាត្រានេះចែងអំពីកាតព្វកិច្ចអនិយ័ត (alternative obligation) ។ ដូចដែលបានកំណត់និយមន័យក្នុងមាត្រានេះ កាតព្វកិច្ចអនិយ័ត សំដៅលើករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ ដោយការជ្រើសរើសក្នុងចំណោមការផ្តល់តាវកាលិកច្រើនប្រភេទ ។ ឧទាហរណ៍ដូចជា កាតព្វកិច្ចដែលកូនបំណុលត្រូវសងប្រាក់ ៥០០ ដុល្លារ ឬ សេះមួយក្បាល ។ ប្រសិនបើកូនបំណុលផ្តល់តាវកាលិកណាមួយ ក្នុងចំណោមជម្រើសកាតព្វកិច្ចទាំងពីរ កាតព្វកិច្ចត្រូវចាត់ទុកថា ត្រូវបានអនុវត្តចប់សព្វគ្រប់ ។

បញ្ហាចម្បងទាក់ទងនឹងកាតព្វកិច្ចអនិយ័ត គឺបញ្ហាថា តើអ្នកណាមានសិទ្ធិជ្រើសរើស ។ ដោយហេតុថា ជាទូទៅភាគីនៃកិច្ចសន្យាដែលព្រមព្រៀងអំពីកាតព្វកិច្ចអនិយ័ត ផ្តល់សិទ្ធិនេះទៅកូនបំណុល មាត្រានេះបានផ្តល់សិទ្ធិជ្រើសរើស

ឱ្យកូនបំណុល ដោយចែងបន្ថែមថា កិច្ចព្រមព្រៀងដែលផ្តល់សិទ្ធិនេះទៅអ្នកផ្សេងទៀត ក៏មានសុពលភាពផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០៦ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៦២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៥៤៥ និង មាត្រា ១៥៤៦ នៃក្រមរដ្ឋប្បវេណីកេបិច

## មាត្រា ៣២១.– ការអនុវត្តសិទ្ធិជ្រើសរើស

១-សិទ្ធិជ្រើសរើសត្រូវបានអនុវត្តដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។ ក្នុងករណីដែលកូនបំណុលមានសិទ្ធិជ្រើសរើស ការផ្តល់នូវកម្មវត្ថុដែលកូនបំណុលបានជ្រើសរើស ត្រូវចាត់ទុកថា បានអនុវត្តនូវសិទ្ធិជ្រើសរើសនោះ ។ ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស សិទ្ធិនេះត្រូវបានអនុវត្តដោយការជូនដំណឹងទៅឱ្យកូនបំណុល និង ម្ចាស់បំណុល ។

២-ការជ្រើសរើស ត្រូវមានអានុភាពប្រតិសកម្ម ចាប់តាំងពីពេលដែលកាតព្វកិច្ចបានកើតឡើង ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីរបៀបអនុវត្តសិទ្ធិជ្រើសរើស ។

ដោយសារការកំណត់ខ្លឹមសារនៃកាតព្វកិច្ចដោយការអនុវត្តសិទ្ធិជ្រើសរើស មានសារៈសំខាន់ទាំងចំពោះម្ចាស់បំណុល និង កូនបំណុល ចាំបាច់ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតអំពីការអនុវត្តសិទ្ធិនេះ ទោះបីជាសិទ្ធិនេះជារបស់ម្ចាស់បំណុល ឬ កូនបំណុលក៏ដោយ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសិទ្ធិជ្រើសរើស ពុំមានការខាតបង់ប្រយោជន៍ភាគីទាំងពីរទេ បើចាត់ទុកថា សិទ្ធិជ្រើសរើសត្រូវបានអនុវត្ត នៅពេលកូនបំណុលផ្តល់នូវកម្មវត្ថុដែលជ្រើសរើស ។ ដូច្នេះ មាត្រានេះកំណត់អំពីចំណុចនេះ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិជ្រើសរើសវិញនោះ ម្ចាស់បំណុលត្រូវជូនដំណឹងទៅកូនបំណុលអំពីការអនុវត្តសិទ្ធិនេះ ដោយហេតុថា កូនបំណុលត្រូវរៀបចំដើម្បីផ្តល់តាវកាលិកតាមការជ្រើសរើសរបស់ម្ចាស់បំណុល ។

ប្រសិនបើតតិយជនអនុវត្តសិទ្ធិជ្រើសរើស វាជារឿងធម្មតាដែលតតិយជនត្រូវជូនដំណឹងដល់កូនបំណុល ដែលត្រូវរៀបចំដើម្បីផ្តល់តាវកលិកតាមការជ្រើសរើសនោះ ហើយតតិយជនក៏ត្រូវជូនដំណឹងដល់ម្ចាស់បំណុលផងដែរ ដោយហេតុថា ម្ចាស់បំណុលមានផលប្រយោជន៍ក្នុងនោះ (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីជប៉ុនសរសេរថា "ម្ចាស់បំណុល ឬ កូនបំណុល") ។

កថាខណ្ឌទី ២ ចែងអំពីអានុភាពប្រតិសកម្មនៃការជ្រើសរើស ។ ជាលទ្ធផលនៃការជ្រើសរើស កាតព្វកិច្ចអនិយ័ត

ត្រូវកំណត់ជាកាតព្វកិច្ចដែលមានកម្មវត្ថុនៃតាវកាលិកតែមួយ ។ ប៉ុន្តែ ដោយសារអានុភាពនោះមានប្រតិសកម្ម ត្រូវចាត់ទុកតាវកាលិកដែលបានកំណត់នោះ ថាជាកម្មវត្ថុនៃកាតព្វកិច្ច ចាប់តាំងពីពេលដែលកាតព្វកិច្ចនោះបានកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង កថាខណ្ឌទី ១ នៃមាត្រា ២៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង កថាខណ្ឌទី ២ នៃមាត្រា ២៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

**មាត្រា ៣២២.–** ការផ្ទេរសិទ្ធិជ្រើសរើស

១-ក្នុងករណីដែលកាតព្វកិច្ចដល់ពេលកំណត់សង ទោះបីជាកូនបំណុល ឬ ម្ចាស់បំណុលដែលមានសិទ្ធិជ្រើសរើស បានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះ ក្នុងអំឡុងពេលសមរម្យដែលភាគីម្ខាងទៀតបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

២-ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស ទោះបីជាតតិយជននោះបានទទួលការដាស់តឿនឱ្យអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលសមរម្យដែលកូនបំណុល ឬ ម្ចាស់បំណុលបានកំណត់ក៏ដោយ តែមិនបានជ្រើសរើសក្នុងអំឡុងពេលនោះ សិទ្ធិជ្រើសរើសនោះត្រូវផ្ទេរទៅកូនបំណុលវិញ ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅឱ្យភាគីម្ខាងទៀត ក្នុងករណីដែលភាគីដែលមានសិទ្ធិជ្រើសរើសមិនអនុវត្តសិទ្ធិនេះ ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលមានសិទ្ធិជ្រើសរើស តែមិនអនុវត្តសិទ្ធិនេះ កម្មវត្ថុនៃកាតព្វកិច្ចមិនត្រូវបានកំណត់ ហេតុដូច្នេះ ទោះបីជាកូនបំណុលធ្លាក់ទៅក្នុងស្ថានភាពនៃការមិនអនុវត្តកាតព្វកិច្ច ដោយហួសពេលកំណត់សងក៏ដោយ ក៏ម្ចាស់បំណុលមិនអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចភ្លាមបានឡើយ ។ ច្បាប់ប្រទេសខ្លះកំណត់ថា ក្នុងករណីនេះ ម្ចាស់បំណុលអាចជ្រើសរើសតាវកាលិកមួយដែលជាជម្រើស ហើយអាចអនុវត្តដោយបង្ខំ ចំពោះកូនបំណុលបាន (ក្រមរដ្ឋប្បវេណីប្រទេសអាល្លឺម៉ង់) ។ ប៉ុន្តែ ការធ្វើដូច្នេះ តម្រូវឱ្យមានការបង្កើតឱ្យមាននូវបញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំ និង មានឥទ្ធិពលយ៉ាងខ្លាំងក្លា ។ ម្យ៉ាងទៀត ទោះបីជាគ្មានបញ្ញត្តិពិសេសស្ដីពីការអនុវត្តដោយបង្ខំចំពោះករណីនេះក៏ដោយ ក៏ម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តសិទ្ធិជ្រើសរើសបានដែរ (ការបង្ខំដោយប្រយោល ឬ ការអនុវត្តជំនួស) ។ ប៉ុន្តែ ការធ្វើដូច្នេះ ត្រូវចំណាយពេល និង ជាវិធីដែលស្មុគស្មាញ ។ ដូច្នេះ មាត្រានេះគ្រាន់តែចែង

យ៉ាងសាមញ្ញថា ប្រសិនបើកូនបំណុលមិនអនុវត្តសិទ្ធិជ្រើសរើសទេ សិទ្ធិនេះត្រូវផ្ទេរទៅឱ្យម្ចាស់បំណុល ។ ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិជ្រើសរើសតាំងពីដំបូងមក ប្រសិនបើម្ចាស់បំណុលមិនអនុវត្តសិទ្ធិនេះទេ សិទ្ធិនេះត្រូវផ្ទេរទៅឱ្យកូនបំណុល ។ ប្រសិនបើតតិយជនមានសិទ្ធិនេះ តែមិនអនុវត្ត សិទ្ធិនេះត្រូវផ្ទេរឱ្យកូនបំណុល ដោយសារនេះជារឿងដែលសមហេតុផលមួយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០៨ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, កថាខណ្ឌទី ២ មាត្រា ១៥៤៦ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣២៣.-** ការកំណត់កាតព្វកិច្ចអនិយ័តដោយអលទ្ធភាព

១-ប្រសិនបើការផ្តល់តាវកាលិកណាមួយក្នុងចំណោមតាវកាលិកច្រើនដែលអាចជាកម្មវត្ថុនៃកាតព្វកិច្ចអនិយ័ត មិនអាចប្រព្រឹត្តទៅបានចាប់តាំងពីពេលបង្កើត ឬ ក្រោយពេលបង្កើតកិច្ចសន្យា ដោយគ្មានកំហុសរបស់ភាគី កម្មវត្ថុនៃកាតព្វកិច្ចត្រូវតែជាតាវកាលិកដែលនៅសល់ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣២១ (ការអនុវត្តសិទ្ធិជ្រើសរើស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

២-ប្រសិនបើភាគីដែលមានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។

៣-ប្រសិនបើកូនបំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក អ្នកដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចទាមទារសំណងនៃការខូចខាត ចំពោះកូនបំណុលនោះបាន ។

៤-ប្រសិនបើម្ចាស់បំណុលដែលគ្មានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាពនៃការផ្តល់តាវកាលិក កូនបំណុលដែលមានសិទ្ធិជ្រើសរើសអាចជ្រើសរើសតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ និង អាចរួចផុតពីកាតព្វកិច្ចបាន ។

(កំណត់)

មាត្រានេះចែងអំពីវិធីដោះស្រាយក្នុងករណីដែលការផ្តល់តាវកាលិកណាមួយ ក្នុងចំណោមការផ្តល់តាវកាលិកនានាមិនអាចប្រព្រឹត្តទៅបាន ។

បញ្ហាចម្បងនៅទីនេះ គឺថា ក្នុងករណីដែលតាវកាលិកមួយក្នុងចំណោមតាវកាលិកនានានៃកាតព្វកិច្ចអនិយ័ត ក្លាយជាមិនអាចប្រព្រឹត្តទៅបាន តើតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាននោះ នៅតែអាចត្រូវជ្រើសរើស ឬ គួរកំណត់តាវកាលិកផ្សេងទៀតជាកម្មវត្ថុនៃកាតព្វកិច្ចអនិយ័តជំនួសវិញ ។ ប្រសិនបើតាវកាលិកដែលមិនអាចប្រព្រឹត្តទៅបានអាចនៅតែត្រូវបានជ្រើសរើស នឹងធ្វើឱ្យមានការខុសគ្នាយ៉ាងខ្លាំងចំពោះភាគី ពោលគឺ កាតព្វកិច្ចនឹងត្រូវរលត់ ប្រសិនបើតាវកាលិកមិនអាចប្រព្រឹត្តទៅបាន ដោយគ្មានកំហុសរបស់កូនបំណុល ហើយប្រសិនបើតាវកាលិកមិនអាចប្រព្រឹត្តទៅបានដោយសារកំហុសរបស់កូនបំណុល កាតព្វកិច្ចនឹងត្រូវប្តូរទៅជាការទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ។ ដូច្នេះ មាត្រានេះ បែងចែកករណី ដោយផ្អែកតាមអ្នកដែលមានសិទ្ធិជ្រើសរើស និង អ្នកដែលទទួលខុសត្រូវចំពោះអលទ្ធភាព ។

កថាខណ្ឌទី ១ រៀបរាប់អំពីករណីដែលគ្មានភាគីណាមួយនៃកិច្ចសន្យាគ្មានកំហុសចំពោះអលទ្ធភាព ។ ក្នុងករណីនេះ ប្រសិនបើកូនបំណុលអាចជ្រើសរើសតាវកាលិកដែលក្លាយជាមិនអាចប្រព្រឹត្តទៅរួច ម្ចាស់បំណុលនឹងទទួលការខូចខាតដល់ផលប្រយោជន៍ធ្ងន់ធ្ងរ ដោយសារម្ចាស់បំណុលមិនអាចទាមទារសំណងការខូចខាតជំនួសតាវកាលិកនោះបានទេ ។ ដូច្នេះ ពុំគួរអនុញ្ញាតឱ្យជ្រើសរើសយកតាវកាលិកដែលក្លាយជាមិនអាចប្រព្រឹត្តទៅរួចទេ ហើយគួរតែកំណត់ការផ្តល់តាវកាលិកមួយផ្សេងទៀត ។ គួរអនុវត្តដូចគ្នានេះដែរ ក្នុងករណីដែលតតិយជនមានសិទ្ធិជ្រើសរើស ហើយការផ្តល់តាវកាលិកមួយក្លាយជាមិនអាចប្រព្រឹត្តទៅបាន ដោយកំហុសរបស់តតិយជននោះ ។

កថាខណ្ឌទី ២ ទាក់ទងនឹងករណីដែលភាគីដែលមានសិទ្ធិជ្រើសរើស មានកំហុសចំពោះអលទ្ធភាព ។ ក្នុងករណីនេះ សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅភាគីម្ខាងទៀត ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលមានសិទ្ធិជ្រើសរើស ហើយការប្រគល់សេះក្លាយជាមិនអាចប្រព្រឹត្តទៅរួច ដោយសារកំហុសរបស់កូនបំណុលនោះ សិទ្ធិជ្រើសរើសត្រូវផ្ទេរទៅឱ្យម្ចាស់បំណុល ។ ហេតុដូច្នេះ ម្ចាស់បំណុលអាចជ្រើសរើសការផ្តល់តាវកាលិកជាប្រាក់ក៏បាន ឬ ទាមទារសំណងការខូចខាតដោយអលទ្ធភាពចំពោះកូនបំណុល ដោយជ្រើសរើសការផ្តល់តាវកាលិកជាសេះដែលមិនអាចធ្វើទៅរួចក៏បានដែរ ។ ប្រសិនបើតតិយជនមានសិទ្ធិជ្រើសរើស ហើយមានកំហុសចំពោះអលទ្ធភាព កថាខណ្ឌទី ១ ដែលបានរៀបរាប់ខាងលើ ត្រូវយកមកអនុវត្តដូចគ្នា ។

កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ ទាក់ទងនឹងករណីដែលភាគីដែលគ្មានសិទ្ធិជ្រើសរើស (កូនបំណុល ឬ ម្ចាស់បំណុល) មានកំហុសចំពោះអលទ្ធភាព ។ កថាខណ្ឌទី ៣ អនុវត្តចំពោះករណីដែលម្ចាស់បំណុលមានសិទ្ធិជ្រើសរើស ហើយកូនបំណុលដែលគ្មានសិទ្ធិជ្រើសរើសធ្វើឱ្យការផ្តល់តាវកាលិកមួយក្នុងចំណោមការផ្តល់តាវកាលិកច្រើន (នៅក្នុងឧទាហរណ៍ខាងលើ គឺការប្រគល់សេះ) មិនអាចប្រព្រឹត្តទៅរួច ។ ម្ចាស់បំណុលអាចជ្រើសរើសយកការផ្តល់តាវកាលិកដែលក្លាយជាមិនអាចប្រព្រឹត្តទៅរួចនោះ ហើយទាមទារឱ្យកូនបំណុលសងសំណងការខូចខាតចំពោះអលទ្ធភាពបាន ។ កថាខណ្ឌទី ៤ អនុវត្តចំពោះករណីដែលកូនបំណុលមានសិទ្ធិជ្រើសរើស ហើយម្ចាស់បំណុលធ្វើឱ្យការផ្តល់តាវកាលិកមួយក្នុងចំណោមការផ្តល់តាវកាលិកច្រើន (ការប្រគល់សេះ) មិនអាចប្រព្រឹត្តទៅរួច ។ ក្នុងករណីនេះ កូនបំណុលអាចជ្រើសរើសយកការផ្តល់តាវកាលិកដែលមិនអាចប្រព្រឹត្តទៅបាន ។ ដោយសារអលទ្ធភាពនោះមិនមែនជាកំហុសរបស់

កូនបំណុល កូនបំណុលត្រូវរួចពីករណីយកិច្ចក្នុងការអនុវត្ត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៦៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៥៤៨ ដល់មាត្រា ១៥៥០ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣២៤.–** សិទ្ធិលើបំណុល និង កាតព្វកិច្ចដែលមានភាគីច្រើននាក់

១-ក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់ ចំពោះកាតព្វកិច្ចមួយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈផ្សេង ម្ចាស់បំណុលម្នាក់ៗ មានសិទ្ធិ ដោយមានភាគស្មើគ្នា ។

២-ក្នុងករណីដែលការអនុវត្តកាតព្វកិច្ច មិនអាចបែងចែកបាន តាមលក្ខណៈនៃកាតព្វកិច្ចនេះ ឬ ដោយការបង្ហាញឆន្ទៈរបស់ភាគី ប្រសិនបើមានម្ចាស់បំណុលច្រើននាក់ ម្ចាស់បំណុលម្នាក់ៗអាចទាមទារឱ្យអនុវត្ត សម្រាប់ម្ចាស់បំណុលទាំងអស់ ហើយកូនបំណុលអាចអនុវត្តចំពោះម្ចាស់បំណុលម្នាក់ៗ សម្រាប់ម្ចាស់បំណុលទាំងអស់បាន ។

៣-ចំពោះកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ សកម្មភាពរបស់ម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ហេតុដែលបានកើតឡើងចំពោះម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ មិនត្រូវមានអានុភាពចំពោះម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀតឡើយ ។ ក្នុងករណីដែលកូនបំណុលធ្វើនវកម្មជាមួយម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ឬ ទទួលការលើកលែងពីម្ចាស់បំណុលអវិភាគីយ៍ណាម្នាក់ ប្រសិនបើកូនបំណុលនោះអនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលអវិភាគីយ៍ផ្សេងទៀត កូនបំណុលអាចទាមទារឱ្យសងមកវិញនូវផលប្រយោជន៍ដែលម្ចាស់បំណុលអវិភាគីយ៍ម្នាក់នោះត្រូវទទួល ប្រសិនបើម្ចាស់បំណុលអវិភាគីយ៍នោះមិនបានបាត់បង់សិទ្ធិរបស់ខ្លួន ។

៤-ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព និង ករណីផ្សេងទៀតដែលមានកូនបំណុលច្រើននាក់ ត្រូវអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) ដល់មាត្រា ៩៣៧ (កាតព្វកិច្ចអវិភាគីយ៍ និង កាតព្វកិច្ចដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកាតព្វកិច្ចដោយសាមគ្គីភាព និង កាតព្វកិច្ចវិភាគីយ៍) ។

(កំណត់)

មាត្រានេះ កំណត់អំពីទំនាក់ទំនងសិទ្ធិលើបំណុល ក្នុងករណីដែលមានម្ចាស់បំណុលច្រើនចំពោះសិទ្ធិលើបំណុលមួយ ។

កថាខណ្ឌទី ១ បង្កើតឱ្យមានជាវិធានទូទៅសម្រាប់ករណីដែលមានម្ចាស់បំណុលច្រើននាក់ ។ លើកលែងតែមានការបង្ហាញឆន្ទៈផ្ទុយពីនេះ សិទ្ធិលើបំណុលនោះ ត្រូវក្លាយទៅជាសិទ្ធិលើបំណុលដែលត្រូវបានបែងចែកទៅម្ចាស់បំណុលនីមួយៗដោយមានភាគស្មើគ្នា ។ ឧទាហរណ៍ រួមមានសិទ្ធិលើបំណុលចំពោះថ្លៃលក់វត្ថុដែលជាកម្មសិទ្ធិអវិភាគ និងសិទ្ធិលើបំណុលចំពោះសំណងការខូចខាតដល់វត្ថុដែលជាកម្មសិទ្ធិអវិភាគ ដោយអំពើអនីត្យានុកូល ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលសិទ្ធិលើបំណុលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិលើបំណុល ឬ ដោយការបង្ហាញឆន្ទៈរបស់ភាគី សិទ្ធិលើបំណុលនោះ ត្រូវក្លាយទៅជាសិទ្ធិលើបំណុលអវិភាគីយ៍ ។ ឧទាហរណ៍ទាក់ទងនឹងសិទ្ធិលើបំណុលអវិភាគីយ៍តាមលក្ខណៈនៃសិទ្ធិលើបំណុលនោះ មានសិទ្ធិទាមទារឱ្យបើចេញពីផ្ទះមួយដែលមានភតិបតីច្រើននាក់ ជាអាទិ៍ ។ ហើយសិទ្ធិលើបំណុលអវិភាគីយ៍ដោយការបង្ហាញឆន្ទៈរបស់ភាគី អាចយកជាការបាននៅពេលដែលមានការបង្ហាញដែលមានអានុភាពតាមការរៀបរាប់ខាងក្រោម ។

សិទ្ធិលើបំណុលអវិភាគីយ៍ សំដៅលើសិទ្ធិលើបំណុលដែលម្ចាស់បំណុលអវិភាគីយ៍នីមួយៗ អាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច សម្រាប់ម្ចាស់បំណុលទាំងអស់បាន ហើយកូនបំណុលអាចអនុវត្តកាតព្វកិច្ច ចំពោះម្ចាស់បំណុលទាំងអស់ (កថាខណ្ឌទី ២) និង ជាសិទ្ធិលើបំណុលដែលហេតុដែលបានកើតឡើងចំពោះម្ចាស់បំណុលម្នាក់ ពុំមានអានុភាពចំពោះម្ចាស់បំណុលឯទៀតនោះទេ (កថាខណ្ឌទី ៣) ។ ប៉ុន្តែ ប្រសិនបើហេតុដែលបានកើតឡើងចំពោះម្ចាស់បំណុលម្នាក់ ជានវកម្ម ឬ ការលើកលែង ត្រូវមានអានុភាពមួយចំនួន ចំពោះម្ចាស់បំណុលផ្សេងទៀត នៅក្រោមល័ក្ខខ័ណ្ឌជាកំណត់ (កថាខណ្ឌទី ៣) ។

ដើម្បីបញ្ជាក់ កថាខណ្ឌទី ៤ ចែងថា បញ្ញត្តិនៃមាត្រា ៩២១ ដល់ មាត្រា ៩៣៧ ត្រូវយកមកអនុវត្តចំពោះករណីដែលមានកូនបំណុលច្រើនចំពោះកាតព្វកិច្ចតែមួយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៧ និង មាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល

### កថាភាគទី ១ ល័ក្ខខ័ណ្ឌ

**មាត្រា ៣២៥.–** អត្ថន័យនៃល័ក្ខខ័ណ្ឌ

១-ភាគីនៃកិច្ចសន្យា អាចដាក់ល័ក្ខខ័ណ្ឌលើការបង្កើត ឬ ការរលត់អានុភាពនៃកិច្ចសន្យានោះ ។ ចំពោះសកម្មភាពឯកតោភាគី ភាគីនោះអាចដាក់ល័ក្ខខ័ណ្ឌបាន លុះត្រាតែ

មិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

២-ល័ក្ខខ័ណ្ឌគឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយដែលមិនទៀងទាត់ ។

៣-ក្នុងករណីដែលដាក់ល័ក្ខខ័ណ្ឌបង្អង់លើកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះ ត្រូវកើតឡើងចាប់តាំងពីពេលដែលល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញ ។ ក្នុងករណីដែលដាក់ល័ក្ខខ័ណ្ឌរំលាយកាតព្វកិច្ច ឬ សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី អានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិនោះត្រូវរលត់នៅពេលដែលល័ក្ខខ័ណ្ឌរំលាយនោះត្រូវបានបំពេញ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលអាចដាក់ល័ក្ខខ័ណ្ឌបាន និង កំណត់និយមន័យនៃល័ក្ខខ័ណ្ឌ និង អត្ថន័យនៃការដាក់ល័ក្ខខ័ណ្ឌ ។

កថាខណ្ឌទី ១ ចែងថា ល័ក្ខខ័ណ្ឌអាចដាក់លើអានុភាពនៃកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។ មាត្រានេះក៏បញ្ជាក់អំពីអត្ថន័យនៃការដាក់ ល័ក្ខខ័ណ្ឌផងដែរ ។ ប៉ុន្តែ ប្រសិនបើដាក់ល័ក្ខខ័ណ្ឌលើសកម្មភាពឯកតោភាគី ភាគីម្ខាងទៀតអាចនឹងស្ថិតនៅក្នុងស្ថានភាពមួយដែលគ្មានស្ថិរភាព ។ ដោយហេតុនេះ អាចដាក់ល័ក្ខខ័ណ្ឌលើសកម្មភាពឯកតោភាគីដែលស្របច្បាប់បាន "លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត" ។ ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិរំលាយកាតព្វកិច្ច ដោយសារកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចបង្ហាញឆន្ទៈរំលាយនោះ ក្នុងល័ក្ខខ័ណ្ឌថា កូនបំណុលខកខានមិនបានសងក្នុងអំឡុងពេលមួយជាក់លាក់ ។ ទោះបីជានេះជាការដាក់ល័ក្ខខ័ណ្ឌបង្អង់លើសកម្មភាពឯកតោភាគី (ការរំលាយ) ក៏ដោយ ក៏ការដាក់ល័ក្ខខ័ណ្ឌបង្អង់នេះមានលក្ខណៈត្រឹមត្រូវដោយសារថា វាមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀតនោះទេ ។

ម្យ៉ាងទៀត កថាខណ្ឌទី ១ បញ្ជាក់ថា ល័ក្ខខ័ណ្ឌអាចដាក់លើអានុភាពនៃកិច្ចសន្យា ។ មានន័យថា ក្នុងករណីដែលដាក់ល័ក្ខខ័ណ្ឌលើកិច្ចសន្យា ល័ក្ខខ័ណ្ឌនោះត្រូវបានដាក់ចំពោះអានុភាពនៃកាតព្វកិច្ច ឬ សិទ្ធិដែលកើតកិច្ចសន្យានោះ ។ ឧទាហរណ៍ ប្រសិនបើល័ក្ខខ័ណ្ឌដែលថា "A នឹងធ្វើប្រទានកម្មនូវឡានមួយឱ្យ B ប្រសិនបើ B រៀបអាពាហ៍ពិពាហ៍" ត្រូវបានដាក់ ចំពោះកិច្ចសន្យាប្រទានកម្មដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ កិច្ចសន្យាប្រទានកម្មនេះមានសុពលភាព ប៉ុន្តែល័ក្ខខ័ណ្ឌនេះត្រូវភ្ជាប់ទៅនឹងអានុភាពនៃកាតព្វកិច្ចរបស់ទាយក ឬ សិទ្ធិរបស់បដិគ្គាហកដែលកើតចេញពីកិច្ចសន្យាប្រទានកម្មនោះ ។ នេះគឺជាអត្ថន័យនៃពាក្យ "ដាក់ល័ក្ខខ័ណ្ឌលើការបង្កើត ឬ ការរលត់អានុភាពនៃកិច្ចសន្យា" នៅក្នុងកថាខណ្ឌទី ១ ។

ទោះបីជាញឹកញាប់ល័ក្ខខ័ណ្ឌត្រូវបានដាក់លើការបង្កើតនូវ "កាតព្វកិច្ច ឬ សិទ្ធិលើបំណុល" ដែលកើតពីកិច្ចសន្យាក៏ដោយ ក៏មានករណីខ្លះដែលសិទ្ធិប្រត្យក្សអាចកើតឡើង ឬ ផ្លាស់ប្តូរ តាមកិច្ចសន្យាដែរ ។ ដូច្នេះ ដោយពិចារណាលើករណីដែលល័ក្ខខ័ណ្ឌត្រូវបានដាក់លើសិទ្ធិប្រត្យក្ស កថាខណ្ឌទី ៣ ប្រើប្រាស់ពាក្យ "កាតព្វកិច្ច ឬ សិទ្ធិ" ។ ឧទាហរណ៍នៃករណីដែលដាក់ល័ក្ខខ័ណ្ឌលើសិទ្ធិប្រត្យក្ស មានឧទាហរណ៍ដូចខាងក្រោម ។ ក្នុងកិច្ចសន្យាដែលធនាគារបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ចំពោះអ្នកលក់រាយ លើទំនិញក្នុងឃ្លាំងរបស់អ្នកលក់រាយនោះ ដើម្បីធានានូវសិទ្ធិលើបំណុលចំពោះការឱ្យខ្ចីប្រាក់ ភាគីនៃកិច្ចសន្យាកំណត់ថា សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង្កើតលើទំនិញ ដោយបំពេញល័ក្ខខ័ណ្ឌបង្អង់ជាការដាក់ទំនិញក្នុងឃ្លាំង ហើយផ្ទុយទៅវិញ សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវរលត់ ដោយបំពេញល័ក្ខខ័ណ្ឌរំលាយ ក្នុងករណីដែលកូនបំណុលលក់ទំនិញក្នុងឃ្លាំងក្នុងលក្ខណៈជាសកម្មភាពធ្វើអាជីវកម្មធម្មតា ។

កថាខណ្ឌទី ២ កំណត់និយមន័យនៃល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌត្រូវតែជាព្រឹត្តិការណ៍មិនប្រាកដប្រជា ។ ព្រឹត្តិការណ៍អតីតកាល មិនអាចយកមកធ្វើជាល័ក្ខខ័ណ្ឌបានទេ ដោយសារព្រឹត្តិការណ៍នោះមានភាពប្រាកដប្រជា និង បានកើតរួចទៅហើយ ។ ព្រឹត្តិការណ៍អនាគតក៏មិនអាចយកមកធ្វើជាល័ក្ខខ័ណ្ឌបានឡើយ ប្រសិនបើព្រឹត្តិការណ៍នោះច្បាស់ជានឹងកើតឡើង ។ ប្រសិនបើព្រឹត្តិការណ៍ច្បាស់ជានឹងកើតឡើង តែមិនប្រាកដថានឹងកើតនៅពេលណានោះ នេះជាកំណត់ពេលមិនពិតប្រាកដ ។ ប៉ុន្តែ ក្នុងករណីខ្លះ មានការពិបាកនឹងកំណត់ថា តើព្រឹត្តិការណ៍មួយជាល័ក្ខខ័ណ្ឌ ឬ ជាកំណត់ពេលមិនពិតប្រាកដ (ឧទាហរណ៍ មានការពិបាកក្នុងការកំណត់ថា "ប្រសិនបើមានការរញ្ជួយផែនដីនៅទីក្រុងតូក្យូ" ជាល័ក្ខខ័ណ្ឌ ឬ ជាកំណត់ពេលមិនពិតប្រាកដ) ។

ល័ក្ខខ័ណ្ឌត្រូវចាត់ទុកជាមោឃៈ ប្រសិនបើល័ក្ខខ័ណ្ឌនោះមានភាពខុសច្បាប់ (ឧទាហរណ៍ដូចជាល័ក្ខខ័ណ្ឌដែលថា ត្រូវប្រព្រឹត្តបទល្មើស) ឬ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ (ឧទាហរណ៍ ក្នុងករណីនៃកិច្ចសន្យាប្រទានកម្មមានកំណត់ល័ក្ខខ័ណ្ឌថា ប្រសិនបើលែងលះ នឹងផ្តល់ប្រាក់ ល័ក្ខខ័ណ្ឌនោះមានសុពលភាព ប្រសិនបើគោលបំណង គឺដើម្បីជួយដល់អ្នកលែងលះដែលអាចធ្លាក់ខ្លួនក្របន្ទាប់ពីការលែងលះ ប៉ុន្តែ មិនមានសុពលភាពទេ ប្រសិនបើគោលបំណងគឺដើម្បីជំរុញឱ្យលែងលះ) ។ មោឃភាពនៃល័ក្ខខ័ណ្ឌនោះ ជួនកាល នឹងនាំឱ្យមានមោឃភាពនៃកិច្ចសន្យាទាំងមូលតែម្តង ។

កថាខណ្ឌទី ៣ កំណត់ថា ល័ក្ខខ័ណ្ឌត្រូវបែងចែកជាល័ក្ខខ័ណ្ឌបង្អង់ និង ល័ក្ខខ័ណ្ឌរំលាយ ។ សូមអានឧទាហរណ៍ខាងលើអំពីសិទ្ធិប្រាតិភោគដោយអនុប្បទានលើចលនវត្ថុប្រមូលផ្តុំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៧ នៃ ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៥៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣២៦.- ការចាត់ចែងសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ

សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ អាចក្លាយជាកម្មវត្ថុនៃសន្តតិកម្ម ឬ ការចាត់ចែង ឬ ប្រាតិភោគបាន ។ រីឯកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌត្រូវបានបន្តដោយយោងទៅតាមបញ្ញត្តិនៃសន្តតិកម្ម និង បញ្ញត្តិផ្សេងទៀត ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិ និងករណីយកិច្ចដែលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌ អាចជាកម្មវត្ថុនៃការចាត់ចែង ជាដើម បាន ។ គោលបំណងនៃច្បាប់នេះ គឺដើម្បីការពារសិទ្ធិដែលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌ ។

ឧទាហរណ៍ បុគ្គលដែលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន (កូនបំណុល) មានសិទ្ធិទទួលបានមកវិញនូវកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន (សិទ្ធិទទួលការប្រគល់វិញ) ប្រសិនបើបុគ្គលនោះសងកាតព្វកិច្ច ។ សិទ្ធិនេះ គឺជាសិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើកម្មសិទ្ធិ ដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ ។ បុគ្គលនោះអាចធ្វើអនុប្បទាននូវសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់នេះ ទៅឱ្យតតិយជនបាន ។ ដោយសារសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ មានតម្លៃផ្នែកសេដ្ឋកិច្ច សិទ្ធិបែបនេះអាចក្លាយជាកម្មវត្ថុនៃការជួញដូរបាន ។ ម្យ៉ាងទៀត ប្រសិនបើបុគ្គលនោះទទួលមរណភាព សិទ្ធិទទួលការប្រគល់វិញ ត្រូវបានបន្តដោយសន្តតិកម្ម ជាមួយគ្នានឹងឋានៈរបស់បុគ្គលនោះ ។ ជារឿងសមរម្យក្នុងការកំណត់ដូច្នេះ ចំពោះសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ដោយសារសិទ្ធិនោះមានតម្លៃផ្នែកសេដ្ឋកិច្ច ។

ប្រសិនបើល័ក្ខខ័ណ្ឌបង្អង់ ត្រូវភ្ជាប់នឹងកាតព្វកិច្ច មានភាពពិបាកនឹងគិតថា កាតព្វកិច្ចនេះ នឹងត្រូវបានចាត់ចែង ប៉ុន្តែកាតព្វកិច្ចដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់នោះ អាចត្រូវបន្ត តាមរយៈសន្តតិកម្ម ឬ ការទទួលកាតព្វកិច្ច ។ ឧទាហរណ៍ ក្នុងករណីដែលពូ A និង ក្មួយ B ចុះកិច្ចសន្យាប្រទានកម្មក្រោមល័ក្ខខ័ណ្ឌថា "A នឹងផ្តល់ដីទំហំ ១០០ ម៉ែត្រការ៉េឱ្យទៅ B ប្រសិនបើ B រៀបអាពាហ៍ពិពាហ៍" ប្រសិនបើ A ទទួលមរណភាព មុនពេលល័ក្ខខ័ណ្ឌត្រូវបានបំពេញ សន្តតិជនរបស់ A នឹងទទួលបន្តនូវកាតព្វកិច្ចដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌនេះ ។ ការធ្វើដូច្នេះ ក៏ដើម្បីការពារសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌរបស់ B ផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៧៩ និង មាត្រា ១១៨០ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៦០ នៃ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៣២៧.-** ការបំពានសិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ

១-ក្នុងករណីដែលមិនទាន់ច្បាស់ថា ល័ក្ខខ័ណ្ឌត្រូវបានបំពេញ ឬ មិនទាន់បានបំពេញ ភាគីនីមួយៗនៃកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌនោះ មិនអាចបំពានផលប្រយោជន៍របស់ភាគីម្ខាងទៀតដែលនឹងកើតឡើងដោយសារល័ក្ខខ័ណ្ឌនោះ ត្រូវបាន

បំពេញឡើយ ។

២-ក្នុងករណីដែលតតិយជនបានបំពានផលប្រយោជន៍ដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអំពើនេះជាអំពើអនីត្យានុកូល តតិយជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ។

(កំណត់)

មាត្រានេះចែងអំពីការការពារសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ។

កថាខណ្ឌទី ១ កំណត់អំពីការទទួលខុសត្រូវនៅពេលដែលភាគីម្ខាងក្នុងទំនាក់ទំនងសិទ្ធិលើបំណុល និង កាតព្វកិច្ច ធ្វើឱ្យខូចប្រយោជន៍ដែលភាគីម្ខាងទៀតនឹងទទួលនៅពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញ ។ ឧទាហរណ៍ ប្រសិនបើ ពូ A ចុះកិច្ចសន្យាប្រទានកម្ម ក្រោមល័ក្ខខ័ណ្ឌថា "ប្រសិនបើក្មួយ B រៀបអាពាហ៍ពិពាហ៍ A នឹងជូនជាអំណោយនូវដីទំហំ ១០០ ម៉ែត្រការ៉េ ឱ្យទៅ B" តែផ្ទុយទៅវិញ A នោះ ធ្វើឱ្យមានជាឧបសគ្គដល់ការរៀបអាពាហ៍ពិពាហ៍របស់ក្មួយ B នោះ ការបង្កជាឧបសគ្គនេះត្រូវចាត់ទុកថាជាការបំពានលើសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌរបស់ B ។ ឧទាហរណ៍ផ្សេងទៀតក្នុងករណីដែលកូនបំណុល D ផ្ទេរកម្មសិទ្ធិលើវត្ថុណាមួយ ក្នុងគោលបំណងដាក់ប្រាតិភោគ ទៅម្ចាស់បំណុល C ហើយមានការសន្យាថា C នឹងត្រូវផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ទៅឱ្យកូនបំណុល D វិញ ប្រសិនបើ D អនុវត្តកាតព្វកិច្ចសងតាមកំណត់ពេល តែផ្ទុយទៅវិញ ម្ចាស់បំណុល C បង្កជាឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសងរបស់កូនបំណុល D សកម្មភាពរបស់ C ត្រូវចាត់ទុកថាជាការបំពានលើសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌផងដែរ ។ ក្នុងករណីដែលបានរៀបរាប់ខាងលើនេះ A និង B ហើយ C និង D គឺជាភាគីនៃកិច្ចសន្យា ហេតុដូច្នេះ A និង C ត្រូវមានករណីយកិច្ចលើកិច្ចសន្យា ដែលមិនត្រូវធ្វើឱ្យខូចប្រយោជន៍ដែលភាគីម្ខាងទៀត B និង D នឹងទទួល នៅពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញនោះឡើយ ។ ហេតុដូច្នេះ ប្រសិនបើសកម្មភាពរបស់ភាគីម្ខាងធ្វើឱ្យខូចប្រយោជន៍របស់ភាគីម្ខាងទៀត ដោយទប់ស្កាត់មិនឱ្យបំពេញល័ក្ខខ័ណ្ឌ ភាគីដែលធ្វើឱ្យខូចប្រយោជន៍ភាគីម្ខាងទៀតនោះ ត្រូវទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច ដូចគ្នានឹងការមិនអនុវត្តកាតព្វកិច្ចធម្មតាដែរ ។ ក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ A ធ្វើប្រទានកម្មនូវដីទាំងអស់របស់ខ្លួនទៅអ្នកដទៃ មុនពេល B រៀបអាពាហ៍ពិពាហ៍ ទោះបីជាមិនច្បាស់ថា ល័ក្ខខ័ណ្ឌនឹងត្រូវបំពេញ ឬមិនបំពេញក៏ដោយ ក៏ A ត្រូវទទួលខុសត្រូវចំពោះការបំពានដល់សិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌរបស់ B ដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ពិបាកនឹង កំណត់ថា តើ A ត្រូវសងសំណងការខូចខាតចំនួនប៉ុន្មានដល់ B ។ ដោយសារមិនច្បាស់ថាតើល័ក្ខខ័ណ្ឌ នឹងត្រូវបំពេញ ឬ មិនបំពេញនោះ វាមិនមែនជារឿងដែលសមហេតុផលនោះទេ ដែលត្រូវផ្តល់ផលប្រយោជន៍ ១០០% ដល់ B ដោយសន្មតថា លក្ខ័ខ័ណ្ឌនឹងត្រូវបំពេញ ។ ជាការសមហេតុផលក្នុងការវាយតម្លៃលទ្ធភាពនៃការបំពេញល័ក្ខខ័ណ្ឌតាមភាគរយ ហើយយកការវាយតម្លៃនេះ កំណត់ជាចំនួននៃសំណងការខូចខាត ។ ម្យ៉ាងទៀត មាត្រា ៣២៨ ចែងអំពីការទប់ស្កាត់ដោយចេតនាចំពោះការបំពេញល័ក្ខខ័ណ្ឌ ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលតតិយជនដែលមិនមែនជាភាគីនៃកិច្ចសន្យា បំពានលើសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ។ ករណីបែបនេះមានលក្ខណៈស្រដៀងនឹងការបំពានលើសិទ្ធិលើបំណុលដោយតតិយជន ប៉ុន្តែ ក្នុងករណីនៃការបំពានលើសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌនេះ អានុភាពនៃសិទ្ធិលើបំណុលពុំទាន់កើតឡើយ ។ កថាខណ្ឌទី ២ កំណត់ថា សិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបែបនេះ (ហៅថា សិទ្ធិដែលបានរំពឹងទុក) ត្រូវទទួលការការពារ ពីអំពើអនីត្យានុកូលរបស់តតិយជន ។ សិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ មានសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ និង សិទ្ធិប្រត្យក្សដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ។ ចំពោះសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌនោះ សិទ្ធិខ្លះអាចទទួលល័ក្ខខ័ណ្ឌតតាំងនឹងតតិយជន (វិធីសាស្ត្រនៃការបង្ហាញជាសាធារណៈ) ដូចជាករណីដែលអាចចុះបញ្ជីជាបណ្តោះអាសន្ន ហើយសិទ្ធិមួយចំនួនផ្សេងទៀត មិនអាចទទួលបាននូវល័ក្ខខ័ណ្ឌតតាំង (វិធីសាស្ត្រនៃការបង្ហាញជាសាធារណៈ) បានទេ ។ កាលៈទេសៈទាំងនេះ ត្រូវបានលើកយកមកពិចារណានៅពេលដែលមានការកំណត់ថា តើសកម្មភាពមួយជាអំពើអនីត្យានុកូល ឬ មិនមែន ។ ប្រសិនបើត្រូវបំពេញល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល មានបញ្ហាដូចគ្នានឹងបញ្ហាដែលបានលើកឡើងចំពោះកថាខណ្ឌទី ១ ចំពោះចំនួននៃសំណងការខូចខាត។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦០ និង ១៦១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣២៨.– ការចាត់ទុកថាល័ក្ខខ័ណ្ឌត្រូវបានបំពេញ

ប្រសិនបើភាគីដែលនឹងទទួលការខូចផលប្រយោជន៍ដោយសារល័ក្ខខ័ណ្ឌត្រូវបានបំពេញ ហើយភាគីនោះបានរារាំងមិនឱ្យល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញដោយចេតនា ភាគីម្ខាងទៀតអាចចាត់ទុកថា ល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញរួចហើយ ។

(កំណត់)

មាត្រានេះចែងអំពីវិធីក្នុងការដោះស្រាយករណីដែលភាគីណាមួយរារាំងមិនឱ្យល័ក្ខខ័ណ្ឌត្រូវបានបំពេញ ដោយចេតនា ។ ប្រសិនបើមានការរារាំងមិនឱ្យបំពេញល័ក្ខខ័ណ្ឌដោយចេតនា ការទទួលខុសត្រូវចំពោះសំណងការខូចខាតកើតមាន ដោយយោងតាមមាត្រា ៣២៧ ហើយលើសពីនេះ ល័ក្ខខ័ណ្ឌត្រូវចាត់ទុកថាត្រូវបានបំពេញដោយយោងតាមមាត្រានេះ ។ គោលបំណងនៃមាត្រាទាំងនេះ គឺដើម្បីការពារបុគ្គលដែលនឹងទទួលផលប្រយោជន៍ពីការបំពេញល័ក្ខខ័ណ្ឌ ។ ឧទាហរណ៍ ក្នុងករណីដែល A ចុះកិច្ចសន្យាជាមួយ B ថា នឹងធ្វើប្រទានកម្មនូវដីដល់ B ដោយយកអាពាហ៍ពិពាហ៍របស់ B មកធ្វើជាល័ក្ខខ័ណ្ឌ ប្រសិនបើ A រារាំងមិនឱ្យ B រៀបអាពាហ៍ពិពាហ៍ ដោយចេតនា នោះ B អាចទាមទារប្រទានកម្មជាដីនោះបាន ដោយចាត់ទុកថា ល័ក្ខខ័ណ្ឌត្រូវបានបំពេញ ទោះបីជាល័ក្ខខ័ណ្ឌនោះមិនត្រូវបានបំពេញក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៦២ នៃក្រមរដ្ឋប្ប-

# កថាភាគទី ២ ការកំណត់ពេល

**មាត្រា ៣២៩.–** អត្ថន័យនៃការកំណត់ពេល

១-ក្នុងករណីដែលមានកំណត់ពេលចាប់ផ្ដើម ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះមិនត្រូវកើតឡើង រហូតដល់ពេលកំណត់នោះមកដល់ ។ ក្នុងករណីដែលមានកំណត់ពេលចាប់ផ្ដើម ចំពោះការអនុវត្តកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច មុនពេលកំណត់នោះបានឡើយ ។

២-ក្នុងករណីដែលមានកំណត់ពេលចប់ ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះត្រូវរលត់នៅពេលកំណត់នោះមកដល់ ។

៣-ចំពោះសកម្មភាពឯកតោភាគី ភាគីអាចកំណត់ពេលចាប់ផ្ដើមក្នុងន័យនៃកថាខណ្ឌទី ១ ឬ ពេលចប់ក្នុងន័យនៃកថាខណ្ឌទី ២ ខាងលើនេះបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃការកំណត់ពេល ។ ខុសពីល័ក្ខខ័ណ្ឌ ពេលកំណត់សំដៅលើអង្គហេតុដែលច្បាស់ថានឹងកើតឡើងនៅពេលអនាគត ។ ពេលកំណត់មាន ២ ប្រភេទ គឺ "ពេលកំណត់ពិតប្រាកដ" ដែលកំណត់កាលបរិច្ឆេទច្បាស់លាស់ និង "ពេលកំណត់មិនពិតប្រាកដ" ដែលមិនច្បាស់ថា អង្គហេតុនោះកើតឡើងនៅពេលណា ប៉ុន្តែ ច្បាស់ថានឹងកើតឡើងនាពេលអនាគត ។

កថាខណ្ឌទី ១ ចែងពីពេលចាប់ផ្ដើម ។ ឧទាហរណ៍ ឈ្មោះ A និង B ចុះកិច្ចសន្យាជាមួយគ្នា នៅថ្ងៃទី ១ ខែ ធ្នូ ដោយមានខ្លឹមសារថា "A នឹងផ្ដល់ទំនិញទៅ B ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំក្រោយ" ។ ក្នុងករណីនេះ ពេលចាប់ផ្ដើម គឺថ្ងៃទី ១ ខែ មករា ឆ្នាំក្រោយ ។ ចំពោះអត្ថន័យនៃពេលចាប់ផ្ដើមក្នុងករណីនេះ មានវិធីពីរក្នុងការគិតអំពីពេលចាប់ផ្ដើមទេ។ វិធីទី ១ គឺកិច្ចសន្យាត្រូវបានបង្កើតនៅថ្ងៃទី ១ ខែ ធ្នូ ប៉ុន្តែ នឹងមិនមានអានុភាពរហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំក្រោយ ។ វិធីមួយទៀត គឺ កិច្ចសន្យាត្រូវបានបង្កើត និង មានអានុភាពនៅថ្ងៃទី ១ ខែ ធ្នូ ប៉ុន្តែ ពេលកំណត់អនុវត្ត គឺថ្ងៃទី ១ ខែ មករា ឆ្នាំក្រោយ ។ បើពិនិត្យមើលពីទស្សនៈរបស់ម្ចាស់បំណុល វិធីទាំងពីរនេះមានលក្ខណៈដូចគ្នា ត្រង់ថា ម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច រហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំក្រោយបានទេ ។ ចំណុចខុសគ្នា គឺនៅត្រង់ថា តើកិច្ចសន្យាមានអានុភាព ឬ ក៏មិនទាន់មាន និង ថាតើសិទ្ធិ និង ករណីយកិច្ចកើតឡើង

តាមកិច្ចសន្យា ឬ មិនទាន់មាននៅឡើយ ។ កថាខណ្ឌទី ១ នៃមាត្រានេះកំណត់ថា បញ្ហាទាំងនេះគួរត្រូវដោះស្រាយតាមខ្លឹមសារនៃការព្រមព្រៀងរបស់ភាគីទាំងពី ពោលគឺការបកស្រាយកិច្ចសន្យា ។

កថាខណ្ឌទី ២ ចែងពីពេលចប់ ។ ជាទូទៅ ភាគីនៃកិច្ចសន្យាមានឆន្ទៈបញ្ចប់អានុភាពនៃកិច្ចសន្យា នៅពេលដែលពេលចប់នោះមកដល់ ។

កថាខណ្ឌទី ៣ ចែងអំពីករណីដែលពេលកំណត់ត្រូវបានភ្ជាប់នឹងសកម្មភាពឯកតោភាគី ។ ទោះបីជាការកំណត់ពេលសម្រាប់សកម្មភាពឯកតោភាគី គឺជាចំណុចដែលអាចជជែកវែកញែកដេញដោលគ្នាបានក៏ដោយ ក៏ការកំណត់ពេលអាចត្រូវបានអនុញ្ញាត "លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត" ។ ឧទាហរណ៍ ប្រសិនបើម្ចាស់បំណុលនៃកិច្ចសន្យាធនលាភសាមយិកមួយជីវិតដែលទទួលតាវកាលិកជាប្រាក់រៀងរាល់ឆ្នាំ លើកលែងកាតព្វកិច្ចរបស់កូនបំណុលក្នុងការផ្ដល់ប្រាក់ នៅថ្ងៃទី ៣១ ខែ ធ្នូ បីឆ្នាំក្រោយ ការលើកលែងកាតព្វកិច្ចនេះមានអានុភាពដោយសារនេះជាសកម្មភាពឯកតោភាគីដែលភ្ជាប់នឹងការកំណត់ពេលចប់ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៨៥ និង ១១៨៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៣៣០.–** ប្រយោជន៍នៃការកំណត់ពេល

១-ការកំណត់ពេល ត្រូវបានសន្មតថា បានជាប្រយោជន៍របស់កូនបំណុល ។

២-ប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ ដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើការបោះបង់ចោលនោះធ្វើឱ្យមានការខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀត ភាគីដែលធ្វើឱ្យមានការខូចខាតនោះ ត្រូវសងការខូចខាតដល់ភាគីម្ខាងទៀត ។

( កំណត់)

មាត្រានេះចែងអំពីអ្នកដែលទទួលផលប្រយោជន៍នៃការកំណត់ពេល និង ការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេល ។

កថាខណ្ឌទី ១ សន្មតថា ផលប្រយោជន៍នៃការកំណត់ពេលជារបស់កូនបំណុល ។ ជាទ្រឹស្ដី មាន ៣ ករណីទាក់ទងនឹងបញ្ហានេះ ។ ករណីទី ១ គឺការកំណត់ពេលជាផលប្រយោជន៍របស់កូនបំណុល ។ ករណីទី ២ គឺការកំណត់ពេលជាផលប្រយោជន៍របស់ម្ចាស់បំណុល និង ករណីទី ៣ គឺការកំណត់ពេលជាផលប្រយោជន៍របស់កូនបំណុលផង និង ម្ចាស់បំណុលផង ។ ការសម្រេចថា តើការកំណត់ពេលក្នុងកិច្ចសន្យានីមួយៗត្រូវនឹងករណីណានោះ អាស្រ័យទៅលើការបកស្រាយ

កិច្ចសន្យានីមួយៗនោះ ។ ចំពោះ "ពេលចាប់ផ្តើមដែលទាក់ទងនឹងការអនុវត្ត" ដែលត្រូវបានប្រើប្រាស់ ជាញឹកញាប់នោះ មានករណីច្រើនដែលការកំណត់ពេលនោះជាផលប្រយោជន៍របស់កូនបំណុល ក្នុងន័យថា កូនបំណុលពុំចាំបាច់អនុវត្តកាតព្វកិច្ច រហូតដល់ពេលកំណត់អនុវត្ត ។ ដូច្នេះ មាត្រានេះសន្មតថា ការកំណត់ពេលជាផលប្រយោជន៍របស់កូនបំណុល ។

ប៉ុន្តែ មានករណីខ្លះដែលត្រូវនឹងករណីទី ២ ឬ ទី ៣ ដោយផ្អែកលើការបកស្រាយកិច្ចសន្យានីមួយៗ ។ ឧទាហរណ៍អំពីករណីទី ២ រួមមានបញ្ញើមុធា ឬ ហៅម្យ៉ាងទៀតថា បញ្ញើឥតគិតថ្លៃ ។ ក្នុងករណីបញ្ញើមុធា ទោះបីជាមានកំណត់ពេលប្រគល់មកវិញនូវវត្ថុផ្ញើក៏ដោយ ក៏អ្នកផ្ញើ (ម្ចាស់បំណុល) អាចទាមទារឱ្យប្រគល់មកវិញនូវវត្ថុផ្ញើ នៅពេលណាក៏បានដែរ ។ នេះគឺដោយសារថា ពេលប្រគល់វត្ថុផ្ញើមកវិញនោះ ត្រូវបានកំណត់សម្រាប់ផលប្រយោជន៍របស់អ្នកផ្ញើ (ម្ចាស់បំណុល) ។ បានសេចក្តីថា អ្នកផ្ញើ (ម្ចាស់បំណុល) អាចទាមទារឱ្យអ្នកទទួលបញ្ញើថែរក្សាវត្ថុផ្ញើ រហូតដល់ពេលដែលត្រូវប្រគល់មកវិញ ។ ការណ៍នេះ មានន័យម្យ៉ាងទៀតថា អ្នកទទួលបញ្ញើ (កូនបំណុល) ត្រូវតែថែរក្សាវត្ថុផ្ញើ ហើយមិនអាចប្រគល់វត្ថុផ្ញើនោះមកវិញបានទេ រហូតដល់ពេលកំណត់ប្រគល់វិញ ។ តាមន័យនេះ ពេលកំណត់សម្រាប់បញ្ញើមុធា ត្រូវបានកំណត់សម្រាប់ផលប្រយោជន៍របស់ម្ចាស់បំណុល (អ្នកផ្ញើ) ។ ដូច្នេះ អ្នកទទួលបញ្ញើត្រូវគោរពពេលកំណត់ ប៉ុន្តែ អ្នកផ្ញើ (ម្ចាស់បំណុល) អាចទាមទារឱ្យប្រគល់មកវិញនូវវត្ថុផ្ញើ មុនពេលកំណត់បាន ដោយបោះបង់ចោលនូវផលប្រយោជន៍ដែលអាចឱ្យអ្នកទទួលបញ្ញើថែរក្សាវត្ថុរហូតដល់ពេលកំណត់ ។ ឧទាហរណ៍អំពីករណីទី ៣ រួមមាន ប្រាក់បញ្ញើមានកាលកំណត់ដែលភ្ជាប់នឹងការប្រាក់ ។ កូនបំណុល (ធនាគារ) មានផលប្រយោជន៍នៃការកំណត់ពេល ត្រង់ថា ខ្លួនមិនចាំបាច់ប្រគល់ប្រាក់បញ្ញើ រហូតដល់ពេលកំណត់ ។ រីឯម្ចាស់បំណុល (អ្នកដាក់ប្រាក់បញ្ញើ) ក៏មានផលប្រយោជន៍នៃការកំណត់ពេលផងដែរ ដោយសារខ្លួនអាចទទួលបានការប្រាក់ សម្រាប់រយៈពេលរហូតដល់ពេលកំណត់។

កថាខណ្ឌទី ២ កំណត់គោលការណ៍ស្តីពីករណីដែលអាចបោះបង់ចោលប្រយោជន៍នៃការកំណត់ពេលបាន ។ តាមស្តង់ដារអរូបី ផលប្រយោជន៍នៃការកំណត់ពេល អាចបោះបង់ចោលបាន "លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ" ដល់ភាគីម្ខាងទៀត ។ ចំណុចនេះអាចបកស្រាយដោយច្បាស់លាស់ ដូចខាងក្រោម ។ ក្នុងចំណោមករណីទាំងបីដូចបានរៀបរាប់ខាងលើ ដោយសារផលប្រយោជន៍នៃការកំណត់ពេលជារបស់កូនបំណុលតែឯងក្នុងករណីទី ១ កូនបំណុលអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលនោះបាន ។ ឧទាហរណ៍ ក្នុងករណីកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ កូនបំណុលមានផលប្រយោជន៍នៃការកំណត់ពេល ដោយសារខ្លួនមិនចាំបាច់សងប្រាក់ដែលខ្ចី រហូតដល់ពេលកំណត់ ប៉ុន្តែ កូនបំណុលមានសេរីភាពពេញលេញក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេល ហើយសងប្រាក់កម្ចីនោះមុនពេលកំណត់បាន ។ ម្យ៉ាងវិញទៀត ក្នុងករណីនេះ ដោយសារការធ្វើនេះមិននាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀត កូនបំណុលមិនចាំបាច់សងសំណងការខូចខាតអ្វីទេ ។ ក្នុងករណីទី ៣ (ដែលភាគីទាំងសងខាងមានផលប្រយោជន៍នៃការកំណត់ពេល) ទោះបីជាកូនបំណុលអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលក៏ដោយ ក៏មានករណីខ្លះដែលនាំឱ្យខូចខាតដល់ម្ចាស់បំណុល ដោយសារម្ចាស់បំណុលក៏មានផលប្រយោជន៍នៃការកំណត់ពេលផងដែរ ។ ឧទាហរណ៍ ទោះបីជាធនាគារដែលជាកូនបំណុលនៃប្រាក់បញ្ញើមានកាលកំណត់ដែលមានការប្រាក់ អាចប្រគល់

ប្រាក់បញ្ញើឱ្យអ្នកដាក់ប្រាក់ផ្ញើ នៅមុនពេលកំណត់ក៏ដោយ ធនាគារត្រូវសងជាសំណងការខូចខាត ទៅឱ្យអ្នកដាក់ប្រាក់ផ្ញើនូវការប្រាក់សម្រាប់រយៈពេលរហូតដល់ពេលកំណត់ (អ្នកដាក់ប្រាក់ផ្ញើអាចប្រើប្រាស់ប្រាក់បញ្ញើសម្រាប់គោលបំណងផ្សេងទៀតបាន ប្រសិនបើខ្លួនទទួលប្រាក់បញ្ញើនោះមុនពេលកំណត់ ហើយក្នុងស្ថានភាពបែបនេះ អាចនាំឱ្យមានការជជែកវែកញែកគ្នាទាក់ទងនឹងបញ្ហាថា តើត្រូវទូទាត់ការប្រាក់ជាមួយនឹងផលចំណេញដែលអ្នកដាក់ប្រាក់បញ្ញើទទួលពីការប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតនោះដែរឬយ៉ាងណា) ។ ក្នុងករណីទី ២ (ដែលម្ចាស់បំណុលមានផលប្រយោជន៍នៃការកំណត់ពេល) កូនបំណុលមិនអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលបានទេ ។ ឧទាហរណ៍ ក្នុងករណីបញ្ញើមុធា អ្នកទទួលបញ្ញើមិនអាចប្រគល់វិញនូវវត្ថុផ្ញើមុនពេលកំណត់ទេ ទោះបីជាអ្នកទទួលបញ្ញើនោះស្ម័គ្រចិត្តសងសំណងការខូចខាតក៏ដោយ ។

ស្តង់ដារដែលបានរៀបរាប់ខាងលើនេះ គឺគោលការណ៍ទូទៅ ហើយអាចមានស្តង់ដារផ្សេងទៀតផងដែរ ។ ឧទាហរណ៍ ក្នុងករណីដែលភាគីទាំងសងខាងមានផលប្រយោជន៍នៃការកំណត់ពេល ប្រសិនបើការបោះបង់ចោលរបស់កូនបំណុលនូវផលប្រយោជន៍នៃការកំណត់ពេល អាចនាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ម្ចាស់បំណុល កូនបំណុលមិនអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលបានឡើយ ។ ឃ្លាដែលថា "នាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ" មិនចាំបាច់មានន័យថា ចំនួនទឹកប្រាក់នៃការខូចខាតមានបរិមាណច្រើននោះទេ ។ អាចមានន័យថា ម្ចាស់បំណុលពិបាកនឹងចាត់វិធានការចាត់ចែងចំពោះការខូចខាតនោះ ។ សម្រាប់បញ្ហាជាក់ស្តែង សូមអានមាត្រា ៤៤៣ និង សេចក្តីកំណត់នៃមាត្រានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១១៨៧ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៣៣១.- ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល

កូនបំណុលត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ក្នុងករណីដូចតទៅ :

ក-កូនបំណុលត្រូវបានប្រកាសក្ស័យធន ។

ខ-កូនបំណុលបានធ្វើឱ្យខូចខាតប្រាតិភោគ ។

គ-កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែ មិនបានបំពេញករណីយកិច្ចនេះ ។

ឃ-មានហេតុដែលគូភាគីបានព្រមព្រៀងគ្នា បានកើតឡើង ។

(កំណត់)

ទោះបីជាកូនបំណុលមានផលប្រយោជន៍នៃការកំណត់ពេលក៏ដោយ ក៏កូនបំណុលមិនគួរអាចអះអាងផលប្រយោជន៍

នៃការកំណត់ពេល ប្រសិនបើហេតុដូចមានចែងក្នុងមាត្រានេះ កើតឡើងដែរ ។ ហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ចំណុច គ គឺជាករណីដែលកូនបំណុលបានបាត់បង់ ឬ ទំនងជាបាត់បង់សាធនភាព ឬ ឥណទាន ។ ក្នុងករណីបែបនេះ ប្រសិនបើម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច រហូតដល់ពេលកំណត់ ម្ចាស់បំណុលអាចមានហានិភ័យជាការមិនអាចទទួលការសង ។ ដូច្នេះ មាត្រានេះចែងអំពីការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលរបស់កូនបំណុល ដើម្បីឱ្យពេលកំណត់សងមកដល់ភ្លាម១។

ឧទាហរណ៍ ប្រសិនបើកូនបំណុលធ្វើឱ្យខូចខាតប្រាតិភោគ ដូចបានចែងក្នុងចំណុច ខ ម្ចាស់បំណុលដែលពឹងលើប្រាតិភោគនោះ ដោយសារតែសម្លឹងឃើញទ្រព្យទូទៅរបស់កូនបំណុលមានតិចតួច អាចនឹងមានហានិភ័យជាការមិនអាចទទួលការសង ប្រសិនបើម្ចាស់បំណុលមិនអាចឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចរហូតដល់ពេលកំណត់ ។

ចំណុច ឃ រៀបរាប់អំពីករណីដែលភាគីទាំងពីរបានព្រមព្រៀងលើហេតុនៃការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ។ ក្រៅពីករណីដូចបានរៀបរាប់ក្នុងចំណុច ក ខ និង គ នៅមានហេតុផ្សេងៗទៀតដែលមិនអាចឱ្យម្ចាស់បំណុលទទួលបាននូវការសង ។ ឧទាហរណ៍រួមមានករណីដែលកូនបំណុលត្រូវអនុវត្តដោយបង្ខំពីម្ចាស់បំណុលផ្សេងទៀត និងករណីដែលអ្នកធានាត្រូវបានប្រកាសក្ស័យធន ។ ករណីទាំងនេះ ក៏ជាហេតុដែលបង្កឱ្យមានមន្ទិលសង្ស័យថា តើកូនបំណុលអាចសងនៅពេលកំណត់បាន ឬ មិនបាន ។ ហេតុដូច្នេះ ភាគីទាំងពីរអាចកំណត់ហេតុទាំងនេះជាហេតុនៃការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល តាមការព្រមព្រៀងជាមុន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណីបារាំង

## កថាភាគទី ៣ អំឡុងពេល

### មាត្រា ៣៣២.– របៀបកំណត់អំឡុងពេល

អំឡុងពេលអាចកំណត់ជា ម៉ោង នាទី វិនាទី ថ្ងៃ សប្ដាហ៍ ខែ ឬ ឆ្នាំ បាន ។

(កំណត់)

មាត្រានេះចែងពីរបៀបកំណត់អំឡុងពេល ក្នុងករណីចាំបាច់ ។ ភាគីទាំងសងខាងនៃកិច្ចសន្យា អាចសម្រេចពីរបៀបគណនាអំឡុងពេល តាមការព្រមព្រៀង ប្រសិនបើចាំបាច់គណនាអំឡុងពេលសម្រាប់កិច្ចសន្យា ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាជួលឡាន ថ្លៃឈ្នួលអាចកំណត់ តាមចំនួននាទី ឬ ចំនួនថ្ងៃ ។ ក្រៅពីកិច្ចសន្យា នៅមានបញ្ហាផ្សេងទៀតជាច្រើនដែលរបៀបគណនាអំឡុងពេលមានសារៈសំខាន់ ។ ឧទាហរណ៍ដូចជាអំឡុងពេលនៃអាជ្ញាយុកាល ជាដើម ។ ក្រមរដ្ឋប្បវេណីចែងថា អំឡុងពេលនៃអាជ្ញាយុកាលត្រូវគណនា តាមចំនួនឆ្នាំ ហើយមិនអាចគណនា តាមចំនួនម៉ោង ឬ ថ្ងៃបានទេ។

(មាត្រាពាក់ព័ន្ធ)

មាត្រាយោងពុំមានកំណត់នៅក្នុងប្រទេសផ្សេងទៀតទេ ។

**មាត្រា ៣៣៣.–** ការគណនាអំឡុងពេលជាម៉ោង នាទី ឬ វិនាទី

ប្រសិនបើបានកំណត់អំឡុងពេលជាម៉ោង នាទី ឬ វិនាទី ត្រូវធ្វើការគណនាពីពេលចាប់ផ្តើមរហូតដល់ពេលចប់នៃអំឡុងពេលនោះ ។

(កំណត់)

មាត្រានេះចែងអំពីរបៀបគណនាអំឡុងពេលជាម៉ោង នាទី ឬ វិនាទី ។ នៅពេលកំណត់ថា អំឡុងពេលគឺមានរយៈពេល មួយម៉ោង ចាប់ពីម៉ោង ១:៣០ បានន័យថា អំឡុងពេលត្រូវចាប់ផ្តើមនៅម៉ោង ១:៣០ និង បញ្ចប់នៅម៉ោង ២:៣០ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៣៤.–** ការគណនាអំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំ

១-ប្រសិនបើបានកំណត់អំឡុងពេលជាថ្ងៃ សប្តាហ៍ ខែ ឬ ឆ្នាំវិញ មិនត្រូវគិតបញ្ចូលថ្ងៃដែលចាប់ផ្តើមនៃអំឡុងពេលនេះទេ លើកលែងតែអំឡុងពេលនេះបានចាប់ផ្តើមពីម៉ោងសូន្យទៅ ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃចុងក្រោយនៃអំឡុងពេលនោះ ។

៣-ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេលត្រូវជាថ្ងៃបុណ្យ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ អំឡុងពេលត្រូវចប់ពេញលេញនៅពេលផុតថ្ងៃធ្វើការបន្ទាប់ពីថ្ងៃឈប់នោះ ។

(កំណត់)

មាត្រានេះចែងអំពីថ្ងៃចាប់ផ្តើម និង ថ្ងៃបញ្ចប់អំឡុងពេល ក្នុងករណីអំឡុងពេលត្រូវបានគណនាជាថ្ងៃ ឬ ឯកតាពេលវេលាធំជាងនេះ ។

កថាខណ្ឌទី ១ ចែងពី "គោលការណ៍នៃការមិនគិតបញ្ចូលថ្ងៃដំបូង" ។ ឧទាហរណ៍ ប្រសិនបើធ្វើការសន្យានៅម៉ោង ១១:០០ ថ្ងៃត្រង់ នៅថ្ងៃទី ១៥ ខែ មីនា ថា ការងារនឹងត្រូវបញ្ចប់ក្នុងអំឡុងពេល ១០ ថ្ងៃ ពេលចាប់ផ្តើមអំឡុងពេល

១០ ថ្ងៃនេះ គឺ ម៉ោង 0:00 នៃថ្ងៃទី ១៦ ខែ មីនា ហើយថ្ងៃចុងក្រោយនៃអំឡុងពេល គឺ ថ្ងៃទី ២៥ ខែ មីនា ។ ប្រសិនបើបញ្ចូលថ្ងៃដំបូង ថ្ងៃចុងក្រោយ ក្នុងឧទាហរណ៍ខាងលើនេះ នឹងត្រូវជាថ្ងៃទី ២៤ ខែ មីនា វិញ ។ ក្នុងករណីនេះ ដោយសារកូនបំណុលមិនអាចប្រើប្រាស់ថ្ងៃដំបូង (ថ្ងៃទី ១៥ ខែ មីនា) ពេញលេញទេ កូនបំណុលនឹងមិនទទួលបាននូវរយៈពេល ១០ ថ្ងៃ ពេញលេញនោះទេ ។ ដូច្នេះ ថ្ងៃដំបូងមិនត្រូវគិតបញ្ចូលទេ ដើម្បីឱ្យកូនបំណុលអាចទទួលបានរយៈពេល ១០ ថ្ងៃ ពេញលេញ ។ ប៉ុន្តែ ប្រសិនបើចែងថា អំឡុងពេលគួរតែ ១០ ថ្ងៃ ចាប់ពីម៉ោង 0:00 ថ្ងៃទី ១៥ ខែ មីនា ថ្ងៃដំបូងត្រូវបញ្ចូល ដោយសារម្ចាស់បំណុលអាចប្រើប្រាស់ថ្ងៃដំបូងដោយពេញលេញ ។

កថាខណ្ឌទី ២ ចែងអំពីពេលដែលអំឡុងពេលត្រូវផុតកំណត់ នៅថ្ងៃចុងក្រោយ ។ អំឡុងពេលផុតកំណត់នៅថ្ងៃចុងក្រោយ គឺនៅម៉ោង ២៤:00 កណ្ដាលអាធ្រាត នៅថ្ងៃចុងក្រោយ ។ ទោះបីជាអាចអនុវត្តបានចំពោះការគណនាអំឡុងពេលបែបនេះក៏ដោយ ប្រសិនបើម្ចាស់បំណុលចាំបាច់ត្រូវទទួលការអនុវត្តកាតព្វកិច្ច មិនគួរឱ្យម្ចាស់បំណុលទទួលនៅម៉ោង ២៤:00 កណ្ដាលអាធ្រាតនោះទេ ។ មានន័យថា កូនបំណុលត្រូវអនុវត្តកាតព្វកិច្ច នៅពេលសមរម្យ ដែលម្ចាស់បំណុលអាចទទួលបានការអនុវត្តកាតព្វកិច្ចនោះ ។ ប្រសិនបើម្ចាស់បំណុលប្រកបរបរអាជីវកម្ម កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចឱ្យបានសម្រេច ក្នុងម៉ោងធ្វើការនៃថ្ងៃចុងក្រោយ ។ ប៉ុន្តែ ចំពោះការគណនាអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្មវិញ ដោយសារពុំមានបញ្ហាដែលភាគីម្ខាងទៀតត្រូវទទួល គោលការណ៍នៃផុតកំណត់នៅចុងបញ្ចប់នៃថ្ងៃចុងក្រោយអាចយកមកអនុវត្តបាន ។

កថាខណ្ឌទី ៣ ចែងអំពីករណីដែលថ្ងៃចុងក្រោយជាថ្ងៃបុណ្យ ឬ ថ្ងៃឈប់សម្រាក ។ មិនសមរម្យនឹងអនុវត្តកាតព្វកិច្ចនៅថ្ងៃបុណ្យ និង ថ្ងៃឈប់សម្រាកនោះទេ ។ ដូច្នេះ ប្រសិនបើចាំបាច់ត្រូវអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលជាក់លាក់មួយ ហើយក្នុងនោះមានប៉ះចំថ្ងៃបុណ្យ ឬ ថ្ងៃឈប់សម្រាក អំឡុងពេលត្រូវពន្យារទៅថ្ងៃធ្វើការបន្ទាប់ ។

នឹងមានបញ្ហាថា តើគួរអនុវត្តកថាខណ្ឌទី ៣ ឬ មិនគួរ ចំពោះការគណនាអំឡុងពេលដែលមិនទាក់ទងនឹងកិច្ចការជួញដូរ ដូចជាអាជ្ញាយុកាលនៃលទ្ធកម្ម ។ ប៉ុន្តែ ដោយសារម្ចាស់សិទ្ធិមិនអាចដាក់ពាក្យបណ្ដឹង ដើម្បីផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម នៅថ្ងៃបុណ្យ ឬ ថ្ងៃឈប់សម្រាកបានទេនោះ គួរតែកំណត់យកថ្ងៃធ្វើការទីមួយបន្ទាប់ពីថ្ងៃបុណ្យ ឬ ថ្ងៃឈប់សម្រាក ធ្វើជាថ្ងៃចុងក្រោយនៃអំឡុងពេល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤០ ១៤១ និង ១៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២២៦០ និង ២២៦១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៨៧ ១៨៨ និង ១៩៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣៣៥.- ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ

១-ក្នុងករណីដែលធ្វើការគណនាអំឡុងពេលជាសប្ដាហ៍ ខែ ឬ ឆ្នាំ ត្រូវធ្វើការគណនាតាមប្រតិទិនសុរិយគតិ ។

២-ក្នុងករណីដែលមិនធ្វើការគណនាអំឡុងពេលដោយគិតពីដើមសប្តាហ៍ ដើមខែ ឬ ដើមឆ្នាំទេ អំឡុងពេលនេះត្រូវចប់ពេញលេញនៅមួយថ្ងៃមុនថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើមរាប់នៃសប្តាហ៍ចុងក្រោយ ខែចុងក្រោយ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេល ។ ប៉ុន្តែ ក្នុងករណីដែលត្រូវគណនាអំឡុងពេលជាខែ ឬ ជាឆ្នាំវិញ ប្រសិនបើខែ ឬ ឆ្នាំចុងក្រោយនៃអំឡុងពេលនោះ គ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្តើមទេ ថ្ងៃចុងក្រោយនៃខែនោះ ត្រូវជាថ្ងៃដែលអំឡុងពេលត្រូវចប់ពេញលេញ ។

(កំណត់)

មាត្រានេះចែងអំពីរបៀបគណនាអំឡុងពេលតាមសប្តាហ៍ ខែ ឬ ឆ្នាំ ។

កថាខណ្ឌទី ១ កំណត់ថា អំឡុងពេលត្រូវគណនាតាមប្រតិទិនសុរិយគតិ ។

កថាខណ្ឌទី ២ បញ្ជាក់អំពីពេលដែលអំឡុងពេលត្រូវចប់ដោយពេញលេញ ។ ប្រសិនបើកូនបំណុលសន្យានៅម៉ោង ១០:០០ ព្រឹក ថ្ងៃទី ៤ ខែ មករា ថានឹងអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេល ៤ សប្តាហ៍ ថ្ងៃចាប់ផ្តើមគឺថ្ងៃទី ៥ ខែ មករា ដោយសារ "គោលការណ៍នៃការមិនគិតបញ្ចូលថ្ងៃដំបូង" ដូចបានកំណត់ក្នុងមាត្រា ៣៣៤ នៃក្រមនេះ ។ ប្រសិនបើអំឡុងពេល ៤ សប្តាហ៍នេះ គណនាតាមប្រតិទិនសុរិយគតិ "ថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើម" គឺ ថ្ងៃទី ២ ខែ កុម្ភៈ ។ ដូច្នេះ អំឡុងពេល ៤ សប្តាហ៍ត្រូវចប់ដោយពេញលេញ នៅបញ្ចប់នៃថ្ងៃទី ១ ខែ កុម្ភៈ មួយថ្ងៃមុនថ្ងៃទី ២ ខែ កុម្ភៈ ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ចែងអំពីរបៀបដោះស្រាយករណីដែលគ្មានថ្ងៃដែលត្រូវនឹងថ្ងៃដែលអំឡុងពេលបានចាប់ផ្តើម ។ ឧទាហរណ៍ ប្រសិនបើកិច្ចសន្យាដែលចែងថា ត្រូវអនុវត្តកាតព្វកិច្ចក្នុងរយៈពេល ១ ខែ ត្រូវបានចុះ នៅម៉ោង ១០:០០ ព្រឹក ថ្ងៃទី ៣០ ខែ សីហា ថ្ងៃចាប់ផ្តើមគឺថ្ងៃទី ៣១ ខែ សីហា ហើយ "ថ្ងៃដែលត្រូវនឹងថ្ងៃចាប់ផ្តើម" គឺថ្ងៃទី ៣១ ខែ កញ្ញា ។ ប៉ុន្តែ ដោយសារគ្មានថ្ងៃទី ៣១ ខែ កញ្ញា ក្នុងប្រតិទិនសុរិយគតិទេនោះ ថ្ងៃចុងក្រោយនៃអំឡុងពេលតាមកិច្ចសន្យា គឺថ្ងៃចុងក្រោយនៃខែកញ្ញា ពោលគឺថ្ងៃទី ៣០ ខែ កញ្ញា ។ ម្យ៉ាងវិញទៀត ប្រសិនបើកិច្ចសន្យាដូចគ្នាត្រូវចុះនៅម៉ោង ១០:០០ ព្រឹក ថ្ងៃទី ៣០ ខែ មករា ថ្ងៃចាប់ផ្តើម គឺថ្ងៃទី ៣១ ខែ មករា ហើយថ្ងៃចុងក្រោយ គឺថ្ងៃទី ៣១ ខែ កុម្ភៈ ។ ប៉ុន្តែ ដោយពុំមានថ្ងៃទី ៣១ ខែ កុម្ភៈ ក្នុងប្រតិទិនសុរិយគតិទេនោះ ថ្ងៃចុងក្រោយនៃអំឡុងពេលគឺថ្ងៃចុងក្រោយនៃខែ កុម្ភៈ ពោលគឺថ្ងៃទី ២៨ ខែ កុម្ភៈ លើកលែងតែឆ្នាំដែលមាន ៣៦៦ ថ្ងៃ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## ជំពូកទី ២ ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

### ផ្នែកទី ១ ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.-** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

(កំណត់)

កថាខណ្ឌទី ១ ចែងថា កិច្ចសន្យាមានអានុភាពដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករបស់ភាគីទាំងពីរតែប៉ុណ្ណោះ ។ កថាខណ្ឌទី ១ នេះចែងផងដែរអំពីគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា មានន័យថា ជាគោលការណ៍ការព្រមព្រៀងគ្នាទៅវិញទៅមក គឺជាកត្តាចាំបាច់សម្រាប់ការបង្កើតកិច្ចសន្យា ហើយក្រៅពីការព្រមព្រៀងនោះ ច្បាប់មិនតម្រូវឱ្យមានល័ក្ខខ័ណ្ឌផ្សេងទៀតទេ ។

ទោះបីជាយ៉ាងនេះក៏ដោយ តាមទស្សនាទាននៃគោលនយោបាយនីតិកម្ម ច្បាប់អាចតម្រូវឱ្យមានមានល័ក្ខខ័ណ្ឌបន្ថែមចំពោះការបង្កើតកិច្ចសន្យាមួយចំនួន ដូចជាការប្រគល់វត្ថុ (កិច្ចសន្យាដែលត្រូវបានបង្កើតដោយការប្រគល់វត្ថុ) ឬការរៀបចំលិខិត ដែលជាល័ក្ខខ័ណ្ឌចាំបាច់បន្ថែមលើការព្រមព្រៀងគ្នាទៅវិញទៅមក ។ ចំពោះប្រភេទកិច្ចសន្យានីមួយៗដែលតម្រូវឱ្យមានការប្រគល់វត្ថុ ឬ ការរៀបចំលិខិត សូមមើលការពន្យល់នៃមាត្រាពាក់ព័ន្ធ ។ រីឯកថាខណ្ឌទី ២ នៃមាត្រានេះចែងថា លិខិតយថាភូត គឺជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់កិច្ចសន្យាដែលបង្កើត "ករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ" ឬ "ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" ។ បញ្ញត្តិនេះដូចគ្នានឹងបញ្ញត្តិនៃមាត្រា ៣១១ b (១) នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់ ។

មានហេតុផលបីយ៉ាងថា ហេតុអ្វីបានជាលិខិតយថាភូតគឺជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការបង្កើត "កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" ។ ហេតុផលទី ១ គឺដើម្បីការពារអនុប្បទាយី ។ ការរៀបចំនូវលិខិតយថាភូត គឺដើម្បីការពារកសិករ ជាអាទិ៍ ពីការធ្វើអនុប្បទានដោយគ្មានការគិតគូរ ឬ ការដកហូតដីធ្លី ។ នៅពេលក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់ត្រូវបានធ្វើនៅឆ្នាំ ១៩០០ ក្រមនោះក៏ផ្អែកលើទស្សនាទាននេះដែរ ។ ហេតុផលទី ២ គឺដើម្បីការពារអនុប្បទានិក ។ នេះគឺជាហេតុផលដែលមាត្រានេះចែងអំពី "ករណីយកិច្ចធ្វើលទ្ធកម្ម" ។ ការធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុដែលជាទ្រព្យសំខាន់ តម្រូវ

ជាពិសេស ឱ្យមានកិច្ចសន្យាដែលមានខ្លឹមសារត្រឹមត្រូវ ។ ជាពិសេស ការធ្វើកិច្ចសន្យាស្តីពីការធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលក្រុមហ៊ុនអចលនវត្ថុមួយ ត្រូវលក់ដីឡូត៍ទៅឱ្យអ្នកទិញដែលជាអ្នកប្រើប្រាស់ ត្រូវមានការប្រុងប្រយ័ត្ន ចំពោះខនៃកិច្ចសន្យាដែលអាចរកឃើញពីភាពមិនត្រឹមត្រូវដោយសារការី ។ ហេតុផលទី ៣ គឺនៅពេលដែលមានវិវាទ កើតឡើង អំពីកិច្ចសន្យានៃការធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ អត្ថិភាពនៃភស្តុតាងសង្ឃឹមថា មានភាពច្បាស់ លាស់ ដើម្បីជួយសម្រួលក្នុងការដោះស្រាយជម្លោះ ឬ ការពារជម្លោះមិនឱ្យកើតឡើង ។

មាត្រានេះត្រូវអនុវត្តតែចំពោះកិច្ចសន្យាស្តីពីការធ្វើអនុប្បទាននូវ "កម្មសិទ្ធិលើអចលនវត្ថុ" ប៉ុណ្ណោះ ប៉ុន្តែ មិនអាច អនុវត្តចំពោះកិច្ចសន្យាបង្កើតសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុទេ (ក្រមរដ្ឋប្បវេណីរបស់ប្រទេស អាល្លឺម៉ង់ ទាមទារឱ្យមានលិខិតយថាភូតផងដែរ សម្រាប់កិច្ចសន្យាបង្កើតសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល លើអចលនវត្ថុ ដូចជាផលុភោគ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១១ ខ (១) នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់

**មាត្រា ៣៣៧.- និយមន័យនៃសំណើ និង ស្វីការ**

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយ នឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹង ពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃសំណើ និង ស្វីការនៃកិច្ចសន្យា និង បញ្ជាក់ច្បាស់អំពីពេលវេលាដែលសំណើ និង ស្វីការនោះមានអានុភាព ។ មាត្រា ៣៤០ ចែងថា កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអានុភាពនៃស្វីការកើតឡើង ។

កថាខណ្ឌទី ១ ឱ្យនិយមន័យនៃសំណើ ។ ប្រទេសមួយចំនួន ពុំមានបញ្ញត្តិចែងអំពីនិយមន័យនៃសំណើ នៅក្នុង

ក្រមរដ្ឋប្បវេណីរបស់គេទេ ប៉ុន្តែ ក្រមរដ្ឋប្បវេណីដែលបង្កើតថ្មីៗ ជាធម្មតា មានបញ្ញត្តិចែងអំពីនិយមន័យនៃសំណើ ។ ដូច្នេះ ក្រមរដ្ឋប្បវេណីនេះធ្វើតាមនិន្នាការនៅពេលថ្មីៗនេះ ។ សំណើ គឺជាការបង្ហាញឆន្ទៈថា នឹងភ្ជាប់ជាមួយនឹងចំណងគតិយុត្តនៃកិច្ចសន្យាដែលបង្កើតឡើង ក្នុងករណីដែលភាគីម្ខាងទៀតផ្តល់ស្វីការចំពោះសំណើនេះ ហើយកិច្ចសន្យាត្រូវបានបង្កើតឡើងដោយសំណើ និង ស្វីការត្រូវគ្នា ។ ក្នុងន័យនេះ សំណើខុសពីអ្វីដែលគេនិយាយថាជា "ហេតុដែលអញ្ជើញឱ្យធ្វើសំណើ" ។ ឧទាហរណ៍ ជាធម្មតា ការដាក់តាំងវត្ថុគំរូដែលដាក់ថ្លៃនៅតាមបង្អួចហាង មិនមែនជាសំណើទេ គឺជាហេតុដែលអញ្ជើញឱ្យធ្វើសំណើ ។ ប្រសិនបើអ្នកដើរកាត់ឃើញវត្ថុគំរូ ហើយនិយាយទៅកាន់អ្នកលក់ថា ចង់ទិញវត្ថុមួយក្នុងចំណោមវត្ថុតាំងនោះ កិច្ចសន្យានៅតែមិនទាន់បង្កើតនៅឡើយទេ ។ ការសំដែងឆន្ទៈរបស់គាត់ "ខ្ញុំចង់ទិញវត្ថុនេះ" ត្រូវបានចាត់ទុកជាសំណើ ។ នៅពេលដែលអ្នកលក់ពិនិត្យមើលទំនិញ ហើយយល់ព្រមលក់ទំនិញនោះ (ស្វីការ) ដោយឆ្លើយតបចំពោះសំណើ កិច្ចសន្យាលក់ទិញត្រូវបានបង្កើតឡើង ។ ការដែលកំណត់បែបនេះមកពីអ្នកលក់មិនបានដាក់តាំងវត្ថុគំរូក្រោម "ឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ" ទេ ។ ប្រសិនបើការដាក់តាំងវត្ថុគំរូ គឺជាសំណើនៃកិច្ចសន្យាលក់ ការសំដែងឆន្ទៈរបស់អ្នកដើរកាត់ថា ចង់ទិញវត្ថុមួយនោះ នឹងក្លាយទៅជាស្វីការហើយ ហើយកិច្ចសន្យាលក់ទិញនឹងត្រូវបង្កើតភ្លាម ។ ប្រសិនបើអ្នកលក់គ្មានទំនិញនៅសល់ទេ អ្នកលក់នឹងក្លាយជាអ្នកមិនអនុវត្តកាតព្វកិច្ច ។ អ្នកលក់ដែលដាក់តាំងវត្ថុគំរូ ជាធម្មតា ពុំមានបំណងទទួលខុសត្រូវបែបនេះទេ ហេតុដូច្នេះ វាជាការសមហេតុសមផលជាងដែលចាត់ទុកថា ការដាក់តាំងវត្ថុគំរូមិនមែនជាសំណើ ។

កថាខណ្ឌទី ២ ចែងអំពីពេលវេលាដែលសំណើត្រូវមានអានុភាព ។ សំណើមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ដោយអនុលោមតាមគោលការណ៍ទាក់ទងនឹងពេលវេលាដែលការបង្ហាញឆន្ទៈត្រូវមានអានុភាព ។ ទាក់ទងនឹងចំណុចនេះ មានបញ្ហាមួយដែលកើតឡើងថា តើនឹងមានអ្វីកើតឡើង ប្រសិនបើក្រោយពេលដែលការជូនដំណឹងអំពីសំណើត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតដែលនៅឆ្ងាយ ការជូនដំណឹងអំពីការដកសំណើមកវិញ ត្រូវបានបញ្ជូន និង ការជូនដំណឹងអំពីការដកសំណើនោះបានដល់ភាគីម្ខាងទៀត មុនពេល ឬ នៅពេលដំណាលគ្នានឹងការជូនដំណឹងអំពីសំណើនោះ ។ កថាខណ្ឌទី ២ បានកំណត់យកដំណោះស្រាយដែលថា ការដកសំណើមានអានុភាពក្នុងករណីនេះ ។ ទោះបីជាអានុភាពនៃការដកសំណើត្រូវបានទទួលស្គាល់ក៏ដោយ ក៏ករណីនេះមិនធ្វើឱ្យភាគីម្ខាងទៀតខូចប្រយោជន៍ឡើយ ពីព្រោះភាគីម្ខាងទៀតនោះមិនទាន់បានធ្វើអ្វីនៅឡើយទេ ។

កថាខណ្ឌទី ៣ ឱ្យនិយមន័យអំពីស្វីការ ។ ស្វីការគឺជាការបង្ហាញឆន្ទៈយល់ព្រមចំពោះសំណើ ។ នៅពេលគ្មានសំណើ ប្រសិនបើបុគ្គលម្នាក់បង្ហាញឆន្ទៈថា "ខ្ញុំចង់ទិញទំនិញនេះ" ការបង្ហាញឆន្ទៈនេះមិនមែនជាស្វីការទេ ប៉ុន្តែ ត្រូវបានបកស្រាយថាជាសំណើវិញ ។ ឧទាហរណ៍ ប្រសិនបើ A ជូនដំណឹងទៅ B ថា "ខ្ញុំចង់លក់ទំនិញនេះ" (ការបង្ហាញឆន្ទៈ) ប៉ុន្តែ B ជូនដំណឹងថា "ខ្ញុំចង់ទិញទំនិញនេះ" (ការបង្ហាញឆន្ទៈ) ដោយមិនបានដឹងថា មានអត្ថិភាពនៃសំណើរបស់ A ឬ មុនពេលការជូនដំណឹងអំពីសំណើរបស់ A មកដល់ B ជាគោលការណ៍ កិច្ចសន្យាមិនត្រូវបានបង្កើតទេ ពីព្រោះការជូនដំណឹងរបស់ B មិនចាត់ទុកតាមផ្លូវច្បាប់ថាជាស្វីការឡើយ ប៉ុន្តែ គឺជាសំណើតែប៉ុណ្ណោះ ។ បាតុភូតនេះហៅថា "សំណើ

ខ្មែរ" ហើយអ្នកខ្លះប្រកាន់យកជំហរថា កិច្ចសន្យាត្រូវបានបង្កើត ដោយពិចារណាអំពីខ្លឹមសារសារធាតុ ។ ប៉ុន្តែ មាត្រានេះមិនបានចែងច្បាស់អំពីចំណុចនេះទេ ។ ការបញ្ជាក់ឱ្យច្បាស់ គឺអាស្រ័យទៅតាមយុត្តិសាស្ត្រ ឬ ច្បាប់នៅកម្ពុជានៅពេលអនាគត ។ម្យ៉ាងទៀត ប្រសិនបើអ្នកទិញធ្វើសំណើទិញទំនិញជាក់លាក់ណាមួយ ហើយអ្នកលក់ផ្ញើទំនិញនោះទៅអ្នកទិញ គេអាចបកស្រាយថា សកម្មភាពផ្ញើទំនិញរបស់អ្នកលក់ចាត់ទុកជា "ស្វីការ" ទោះបីជាអ្នកលក់មិនបានបង្ហាញឆន្ទៈនៃ "ស្វីការ" យ៉ាងច្បាស់ក៏ដោយ ។ សូមមើលមាត្រា ៣៤៣ ផងដែរ ។ មាត្រា ៣៤៣ ចែងថា ទោះបីជាមានការពិបាកក្នុងការបកស្រាយថា សកម្មភាពមួយជា "ស្វីការ" ចេញពីទស្សនាទាននៃការបង្ហាញឆន្ទៈក៏ដោយ ក៏សកម្មភាពមួយចំនួនត្រូវចាត់ទុកជាស្វីការតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៤៣ នោះដែរ ។

កថាខណ្ឌទី ៤ ចែងអំពីពេលវេលាដែលស្វីការមានអានុភាព ។ ស្វីការក៏គោរពតាមគោលការណ៍ដែលការបង្ហាញឆន្ទៈមានអានុភាពនៅពេលដែលការបង្ហាញឆន្ទៈនោះទៅដល់ភាគីម្ខាងទៀត ។ បន្ថែមពីនេះ ដូចកថាខណ្ឌទី ២ ដែលចែងអំពីសំណើដែរ កថាខណ្ឌទី ៤ ចែងថា ស្វីការចំពោះសំណើមិនត្រូវមានអានុភាពទេ ប្រសិនបើការជូនដំណឹងអំពីការដកស្វីការទៅដល់ភាគីម្ខាងទៀត មុន ឬ នៅពេលដំណាលគ្នានឹងការមកដល់នៃការជូនដំណឹងអំពីស្វីការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីរបស់អាល្លឺម៉ង់, មាត្រា ១៤ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG), គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២០១ និង ២.២០៤

**មាត្រា ៣៣៨.-** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ ។ អំឡុងពេលសម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

(កំណត់)

មាត្រានេះចែងអំពីសំណើដែលមានអំឡុងពេលសម្រាប់ស្វីការ ។

កថាខណ្ឌទី ១ ចែងថា អំឡុងពេលសម្រាប់ធ្វើស្វីការអាចភ្ជាប់ជាមួយសំណើបាន ។ ដូចដែលមានចែងក្នុងកថាខណ្ឌទី ៣ សំណើត្រូវបាត់បង់អានុភាពប្រសិនបើភាគីម្ខាងទៀតមិនផ្តល់ស្វីការ ក្នុងអំឡុងពេលកំណត់សម្រាប់ស្វីការ ។ មាត្រានេះមិនបានដោះស្រាយបញ្ហាឱ្យច្បាស់លាស់ទេថា តើនៅពេលណាដែលអំឡុងពេលសម្រាប់ធ្វើស្វីការចាប់ផ្តើម ។ ការរៀបចំបញ្ញត្តិអំពីបញ្ហានេះ មានការលំបាក ពីព្រោះមានករណីផ្សេងៗគ្នា ។ ប្រសិនបើអ្នកធ្វើសំណើបញ្ជាក់អំពីកាលបរិច្ឆេទចាប់ផ្តើមនៃអំឡុងពេលសម្រាប់ធ្វើស្វីការ ភាគីទាំងពីរត្រូវគោរពតាមកាលបរិច្ឆេទនោះ ។ ប៉ុន្តែ ក្នុងករណីដែលលិខិតសំណើនិយាយថា "ខ្ញុំចង់ទទួលស្វីការក្នុងអំឡុងពេលមួយសប្តាហ៍" តើគេពិចារណាបញ្ហានេះតាមរបៀបណា ? កាលបរិច្ឆេទចាប់ផ្តើមអាចជាកាលបរិច្ឆេទដែលសរសេរក្នុងលិខិត កាលបរិច្ឆេទដែលបោះត្រាលើសំបុត្រ ឬ ថ្ងៃដែលសំបុត្របានមកដល់ភាគីម្ខាងទៀត ជាអាទិ៍ ។ កថាខណ្ឌទី ១ មាត្រា ២០ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិចែងថា ជាគោលការណ៍ កាលបរិច្ឆេទចាប់ផ្តើម គឺជាកាលបរិច្ឆេទដែលសរសេរលើសំបុត្រ ហើយប្រសិនបើគ្មានកាលបរិច្ឆេទនោះទេ គឺជាកាលបរិច្ឆេទដែលបញ្ជាក់លើស្រោមសំបុត្រ ។ ប៉ុន្តែ ប្រសិនបើលិខិតត្រូវបានផ្ញើ ក្រោយអំឡុងពេលមួយចំនួនកន្លងហួស ចាប់ពីកាលបរិច្ឆេទដែលសរសេរលើសំបុត្រ នោះការចាត់ទុកកាលបរិច្ឆេទដែលសរសេរលើសំបុត្រនោះ ជាកាលបរិច្ឆេទចាប់ផ្តើម មិនសមហេតុផលទេ ។ ទោះបីបញ្ហានេះវាអរូបីក៏ដោយ ក៏ការចែងថាកាលបរិច្ឆេទជូនដំណឹង គឺជាកាលបរិច្ឆេទចាប់ផ្តើម មានភាពសមរម្យផងដែរ ។ ហើយការចែងបែបនេះ មានភាពសមហេតុផលដែរ ក្នុងការសម្របសម្រួលផលប្រយោជន៍រវាងអ្នកធ្វើសំណើ និង អ្នកធ្វើស្វីការយ៉ាងត្រឹមត្រូវ ។ ផ្អែកតាមវិធាននេះ ប្រសិនបើកាលបរិច្ឆេទលើសំបុត្រ ខុសពីកាលបរិច្ឆេទនៃការផ្ញើសំបុត្រ អំឡុងពេលសម្រាប់ធ្វើស្វីការ ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការផ្ញើសំបុត្រ ។ ការបកស្រាយនេះមិនធ្វើឱ្យខូចប្រយោជន៍ដល់អ្នកធ្វើសំណើទេ ។ បន្ថែមពីលើនេះទៀត វាក៏មិនធ្វើឱ្យខូចប្រយោជន៍ដល់អ្នកធ្វើស្វីការផងដែរ ពីព្រោះកាលបរិច្ឆេទនៃការផ្ញើសំបុត្រអាចសន្មតយកតាមត្រានៅលើស្រោមសំបុត្រ ។

កថាខណ្ឌទី ២ ចែងថា សំណើដែលបញ្ជាក់ពីអំឡុងពេលសម្រាប់ស្វីការមិនអាចដកវិញបានឡើយ ។ ទោះបីជាអំឡុងពេលសម្រាប់ស្វីការបានកំណត់ក៏ដោយ ក៏សំណើទំនងជាអាចដកបានដែរ ។ ប៉ុន្តែ វាមិនសមរម្យទេក្នុងការអនុញ្ញាតឱ្យដកសំណើក្នុងអំឡុងពេលសម្រាប់ស្វីការ ពីព្រោះគោលបំណងដែលកំណត់អំឡុងពេលសម្រាប់ស្វីការ គឺដើម្បីបញ្ជាក់អំពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំអំឡុងពេលសម្រាប់ស្វីការ ។ ទោះបីជាក្រោមប្រព័ន្ធច្បាប់ដែលអនុញ្ញាតឱ្យមានការដកសំណើដោយទូលំទូលាយក៏ដោយ ក៏ការដកសំណើដែលអំឡុងពេលសម្រាប់ស្វីការត្រូវបានកំណត់ មិនត្រូវបានអនុញ្ញាតទេ (សូមមើលកថាខណ្ឌទី ២ មាត្រា ១៦ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ) ។ មាត្រានេះគឺយកតាមការគិតបែបនេះ ។

កថាខណ្ឌទី ៣ ចែងអំពីករណីដែលសំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការត្រូវបាត់បង់អានុភាព ។ សំណើ

ត្រូវបាត់បង់អានុភាពនៅពេលផុតអំឡុងពេលសម្រាប់ស្នីការ ។ ក្នុងករណីនេះ អ្នកស្នើមិនចាំបាច់ដកសំណើទេ ។ បន្ថែមពីលើនេះ សំណើត្រូវបានបាត់បង់អានុភាពជាស្ថាពរ ប្រសិនបើការជូនដំណឹងពីការបដិសេធសំណើ បានមកដល់ភាគីម្ខាងទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៤៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៣៣៩.-** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការ រវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលផ្ញើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្នីការ ។

(កំណត់)

មាត្រានេះចែងអំពីសំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការ ។

កថាខណ្ឌទី ១ ចែងអំពីពេលវេលាដែលសំណើដែលធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការ រវាងគូភាគីកំពុងនិយាយគ្នា ត្រូវបាត់បង់អានុភាព ។ គេអាចគិតថា អ្នកស្នើសង្ឃឹមថាអ្នកទទួលសំណើ ធ្វើការឆ្លើយតបភ្លាម ។ មាត្រានេះផ្អែកលើការសន្មតនៃឆន្ទៈសមរម្យបែបនេះរបស់អ្នកស្នើ ។

កថាខណ្ឌទី ២ ចែងអំពីសំណើដែលផ្ញើរវាងគូភាគីដែលមិននិយាយគ្នា ដូចជាតាមរយៈសំបុត្រ ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្នីការ ។ ក្នុងករណីនេះ ច្បាប់បណ្តាប្រទេសនានា មានបញ្ញត្តិផ្សេងគ្នាអំពីបញ្ហាថា តើសំណើអាចត្រូវដកបាន ឬ មិនបាន ។ ច្បាប់អង់គ្លូ-អាមេរិកាំង និង អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិដែលទទួលឥទ្ធិពលយ៉ាងខ្លាំងពីច្បាប់អង់គ្លូ-អាមេរិកាំង អនុញ្ញាតឱ្យមានការដកសំណើ ។ រីឯច្បាប់អាល្លឺម៉ង់មិនអនុញ្ញាតឱ្យមានការដកសំណើ ក្នុងអំឡុងពេលជាក់លាក់មួយ ។ ច្បាប់ដែលអនុញ្ញាតឱ្យមានការដកសំណើ ផ្តោតសំខាន់លើការប្រកួតប្រជែងដោយសេរី រហូតដល់ការបង្កើតកិច្ចសន្យា មានន័យថា នៅដំណាក់កាលនៃការចរចាបង្កើតកិច្ចសន្យា ។

ប៉ុន្តែ ប្រសិនបើទទួលស្គាល់អានុភាពចងនៃសំណើ អ្នកស្នើត្រូវជាប់ចំណងនោះក្នុងអំឡុងពេលជាក់លាក់មួយ ហើយមិនអាចចរចាជាមួយភាគីដែលមានប្រយោជន៍ជាងបានទេ នៅខណៈពេលដែលអ្នកទទួលសំណើអាចចរចាដោយសេរីជាមួយអ្នកស្នើផ្សេងទៀត ។ ការកំណត់បែបនេះធ្វើឱ្យមានអតុល្យភាព និង ខូចប្រយោជន៍របស់អ្នកស្នើតែម្ខាង ។ តាមគំនិតបែបនេះ ច្បាប់អង់គ្លូ-អាមេរិកាំងអនុញ្ញាតឱ្យមានការដកសំណើ ។ ផ្ទុយទៅវិញ ច្បាប់ដែលកម្រិតនូវការដកសំណើមានន័យថា ច្បាប់ដែលទទួលស្គាល់អានុភាពចំណងនៃសំណើ ផ្តោតសំខាន់លើការការពារនៃទំនុកចិត្តរបស់អ្នកទទួលសំណើ ។ រហូតដល់អ្នកទទួលសំណើសម្រេចចិត្តថា តើទទួលសំណើ ឬ បដិសេធសំណើ អ្នកទទួលសំណើ នឹងធ្វើការស៊ើបអង្កេតថា តើសំណើមានប្រយោជន៍ ឬ ពិនិត្យលើសំណើនោះដោយបដិសេធសំណើប្រហែលគ្នាពីអ្នកផ្សេងទៀត ។ ប្រសិនបើអ្នកស្នើដកសំណើក្នុងអំឡុងពេលដែលអ្នកទទួលសំណើកំពុងធ្វើការស៊ើបអង្កេត ឬ ការត្រួតពិនិត្យសំណើនេះ ពេលវេលា និង សោហ៊ុយសម្រាប់ការស៊ើបអង្កេត និង ការពិនិត្យ នឹងក្លាយជាគ្មានប្រយោជន៍ ហើយលើសពីនេះទៀតអ្នកទទួលសំណើនឹងអាចបាត់បង់ឱកាសក្នុងការទទួលយកសំណើផ្សេងទៀតដែលមានប្រយោជន៍ ។ ប៉ុន្តែ ប្រសិនបើសំណើមិនអាចដកវិញក្នុងអំឡុងពេលជាកំណត់ណាមួយនោះ អ្នកទទួលសំណើអាចពិនិត្យសំណើនោះ ដោយគ្មានការបារម្ភ ។ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ពីព្រោះតែមានបំណងចង់ឱ្យការចរចាអំពីកិច្ចសន្យាដោយគ្មានការបារម្ភ ទើបមាត្រានេះប្រកាន់យកជំហរថា សំណើមិនត្រូវបានដក ក្នុងអំឡុងពេលសមរម្យមួយបានទេ ។

"អំឡុងពេលសមរម្យ" ដែលអ្នកស្នើមិនអាចដកសំណើ សំដៅទៅលើអំឡុងពេលមួយដែលចាំបាច់សម្រាប់ការវិនិច្ឆ័យថា តើទទួលយកសំណើ ឬ បដិសេធ ក្នុងករណីធម្មតា ។ ថិរវេលានៃអំឡុងពេលនេះ អាស្រ័យទៅតាមខ្លឹមសារ និងប្រភេទនៃកិច្ចសន្យា ។ ឧទាហរណ៍ ប្រសិនបើចំនួនទឹកប្រាក់ក្នុងកិច្ចសន្យាមានចំនួនច្រើន ឬ ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាគឺជាវត្ថុដែលមានតម្លៃ ដូចជាអចលនវត្ថុ អំឡុងពេលសមរម្យនោះប្រហែលជាមានរយៈពេលវែង ។ ប្រសិនបើកិច្ចសន្យាសាមញ្ញធម្មតា អំឡុងពេលនោះមានរយៈពេលខ្លី ។

ប្រសិនបើអំឡុងពេលសមរម្យកន្លងផុត អ្នកស្នើអាចដកសំណើបាន ។ ចំណុចនេះពុំមានន័យថា សំណើត្រូវបាត់បង់អានុភាព ដោយសារអំឡុងពេលកន្លងផុតនោះទេ ។ ប្រសិនបើច្បាប់ចែងថា សំណើត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នោះនឹងនាំឱ្យវិវាទកើតឡើង ដោយសារមិនច្បាស់លាស់ថា តើសំណើបាត់បង់អានុភាពនៅពេលណា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ១៦ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG)

**មាត្រា ៣៤០.–** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្ទីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្ទីការ បានមកដល់អ្នកស្នើ ។

(កំណត់)

មាត្រានេះចែងអំពីពេលដែលស្ទីការត្រូវមានអានុភាព មានន័យថាជាពេលដែលកិច្ចសន្យាត្រូវបានបង្កើត ។

ចំពោះពេលវេលាដែលស្ទីការត្រូវមានអានុភាពនោះ មានគោលការណ៍ច្បាប់ពីរផ្ទុយគ្នាទៅវិញទៅមក ។ ផ្អែកលើយុត្តិសាស្ត្រ ច្បាប់អង់គ្លូ-អាមេរិកាំងយកគោលការណ៍នៃការជូនដំណឹង មានន័យថា ស្ទីការត្រូវមានអានុភាព នៅពេលដែលអ្នកផ្តល់ស្ទីការជូនដំណឹង ។ ម្យ៉ាងវិញទៀតច្បាប់អាល្លឺម៉ង់ យកគោលការណ៍នៃការមកដល់ មានន័យថា ស្ទីការត្រូវមានអានុភាព នៅពេលស្ទីការនោះទៅដល់អ្នកស្នើ ។

គោលការណ៍នៃការជូនដំណឹង ត្រូវបានគេនិយាយថា ធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចមានភាពរស់រវើក ដោយសារការបង្កើនល្បឿនក្នុងការបង្កើតកិច្ចសន្យា ប៉ុន្តែ ការដែលច្បាប់អង់គ្លូ-អាមេរិកាំងប្រកាន់យកគោលការណ៍នៃការជូនដំណឹងនេះ គឺដោយសារតែទទួលស្គាល់សេរីភាពរបស់អ្នកស្នើក្នុងការចរចាបង្កើតកិច្ចសន្យា ដោយអនុញ្ញាតឱ្យដកសំណើ ដូច្នេះដើម្បីធ្វើឱ្យមានតុល្យភាពជាមួយនឹងប្រយោជន៍នេះ ក៏ត្រូវផ្តល់ផលប្រយោជន៍ ចំពោះអ្នកទទួលសំណើផងដែរ ដោយឱ្យមានការបង្កើតកិច្ចសន្យាតាមរយៈការជូនដំណឹងអំពីស្ទីការ ។

ប៉ុន្តែ ប្រសិនបើស្ទីការត្រូវមានអានុភាព ដោយការជូនដំណឹង ហើយកិច្ចសន្យាត្រូវបានបង្កើត នៅពេលស្ទីការត្រូវបានជូនដំណឹង កិច្ចសន្យាត្រូវបានបង្កើតដោយគ្មានការដឹងឮរបស់អ្នកស្នើ ដែលធ្វើឱ្យខូចប្រយោជន៍របស់អ្នកស្នើ ។ ឧទាហរណ៍ អ្នកស្នើបានជូនដំណឹងនៃការដកសំណើ ហើយគិតថា សំណើត្រូវបានដកដោយមានប្រសិទ្ធភាព ពីព្រោះតែអ្នកស្នើមិនបានទទួលស្ទីការពីភាគីម្ខាងទៀត រហូតដល់ពេលដែលការជូនដំណឹងអំពីការដកសំណើនោះត្រូវទៅដល់ភាគីម្ខាងទៀតនោះ ។ ក្នុងករណីនេះ ប្រសិនបើអ្នកស្នើលក់វត្ថុដែលជាកម្មវត្ថុនៃសំណើនោះទៅឱ្យតតិយជន ប៉ុន្តែ ភាគីម្ខាងទៀត (អ្នកទទួលសំណើ) បានជូនដំណឹងអំពីស្ទីការ មុនពេលការជូនដំណឹងអំពីការដកសំណើទៅដល់ភាគីម្ខាងទៀត នោះអ្នកស្នើអាចត្រូវបានទាមទារឱ្យទទួលខុសត្រូវចំពោះការបំពានកិច្ចសន្យា ពីព្រោះកិច្ចសន្យាត្រូវបានបង្កើតហើយ ។ ផ្ទុយទៅវិញ ប្រសិនបើគោលការណ៍នៃការមកដល់ ត្រូវយកមកអនុវត្តចំពោះស្ទីការវិញ ការបំពានកិច្ចសន្យា និង ការបង្កើតកិច្ចសន្យាត្រូតគ្នា ដោយសារអ្នកស្នើមិនបានដឹងអំពីការបង្កើតកិច្ចសន្យា ស្ទើរតែមិនកើតឡើងទេ ។ ក្នុងករណីលើកលែងដែលការជូនដំណឹងអំពីការដកសំណើទៅដល់ភាគីម្ខាងទៀតមានការយឺតយ៉ាវក្នុងស្ថានភាពពិសេស ទោះបីជាការជូនដំណឹងនោះ ពិតជាត្រូវមកដល់ក្នុងអំឡុងពេលនោះក្នុងស្ថានភាពធម្មតា មានន័យថា ការជូនដំណឹងនោះទៅដល់ភាគីម្ខាងទៀត ក្រោយពេលការជូនដំណឹងអំពីស្ទីការទៅដល់អ្នកស្នើ នោះបញ្ហាដូចគ្នានឹងកើតឡើង ប្រសិនបើអ្នកស្នើគិតថា កិច្ចសន្យាមិនត្រូវបានបង្កើតឡើង ដោយសារអ្នកស្នើគិតថា ការជូនដំណឹងអំពីការដកបានដល់ភាគីម្ខាងទៀតមុន ដោយគិតពិចារណានូវថ្ងៃដែលការជូនដំណឹងអំពីស្ទីការមកដល់ ។ ប៉ុន្តែ ផ្អែកលើគោលការណ៍នៃការមកដល់ មានលទ្ធភាពខ្ពស់ដែលគេអាចជៀសវាងហានិភ័យនោះបាន ពីព្រោះអ្នកស្នើធ្វើការវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីការបង្កើតកិច្ចសន្យា ចំពោះករណីដែលការជូនដំណឹងអំពីស្ទីការបានមកដល់តែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន (គោលការណ៍នៃការជូនដំណឹង), មាត្រា ១៥១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (គោលការណ៍នៃការមកដល់) និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២០៥ (គោលការណ៍នៃការមកដល់)

**មាត្រា ៣៤១.-** ការមកដល់យឺតយ៉ាវនៃស្ទីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្ទីការ ចំពោះសំណើដែលមានអំឡុងពេលសម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព ។

២-អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី ។

(កំណត់)

មាត្រានេះចែងអំពីការមកដល់យឺតយ៉ាវនៃស្ទីការ ។

កថាខណ្ឌទី ១ ចែងថា ប្រសិនបើសំណើដែលមានអំឡុងពេលសម្រាប់ស្ទីការ ការជូនដំណឹងអំពីស្ទីការត្រូវទៅដល់អ្នកស្នើ ក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ ហើយប្រសិនបើការជូនដំណឹងមកដល់អ្នកស្នើក្រោយអំឡុងពេលនេះ ស្ទីការនឹងមិនត្រូវមានអានុភាពទេ ហើយកិច្ចសន្យាក៏មិនត្រូវបានបង្កើតដែរ ។ ប៉ុន្តែ ប្រសិនបើការជូនដំណឹងអំពីស្ទីការត្រូវបានជូនដំណឹង ដែលអាចមកដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា លើកលែងតែមានអ្វីកើតឡើងមិនប្រក្រតី អ្នកទទួលសំណើ ជាធម្មតា គិតថា កិច្ចសន្យាត្រូវបានបង្កើតដោយមានប្រសិទ្ធភាព ។ ហេតុដូច្នេះហើយ មានភាពចាំបាច់ឱ្យអ្នកស្នើជូនដំណឹងទៅភាគីម្ខាងទៀត អំពីការដែលការជូនដំណឹងអំពីស្ទីការបានមកដល់យឺតយ៉ាវ និង ការខកខានក្នុងការបង្កើតកិច្ចសន្យាដោយគ្មានការយឺតយ៉ាវ ដើម្បីការពារការខូចខាតដែលអាចកើតឡើង ដោយសារការយល់ខុសរបស់អ្នកទទួលសំណើ ។ អ្នកស្នើត្រូវទទួលករណីយកិច្ចនេះ ពីព្រោះការចរចាកិច្ចសន្យា ត្រូវអនុវត្តដោយភាពស្មោះត្រង់ ។ ហេតុដូច្នេះហើយមានមាត្រានេះចែងថា ប្រសិនបើអ្នកស្នើខកខានក្នុងការជូនដំណឹងអំពីការមកដល់យឺតយ៉ាវនៃ

ស្ទីការ ស្ទីការដែលមកដល់យឺតយ៉ាវនោះត្រូវចាត់ទុកថា មានអានុភាព ។ បញ្ញត្តិនេះ អនុលោមតាមនិន្នាការថ្មីៗនៃច្បាប់កិច្ចសន្យាដូចជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) ។

ប្រសិនបើស្ទីការត្រូវបានចាត់ទុកថា មានអានុភាពនោះ បញ្ហាដែលកើតឡើងគឺថា តើនៅពេលណាដែលកិច្ចសន្យាត្រូវបានបង្កើតឡើង ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) មិនបានចែងច្បាស់អំពីចំណុចនេះដែរ ប៉ុន្តែ មានមតិជាច្រើនគាំទ្រទ្រឹស្តីមួយថា កិច្ចសន្យាត្រូវបានបង្កើតនៅថ្ងៃដែលស្ទីការដែលមានការយឺតយ៉ាវនោះ ទៅដល់អ្នកធ្វើសំណើ ។ ការបកស្រាយបែបនេះក៏សមហេតុសមផលដែរ ផ្អែកតាមមាត្រានេះ ។

មាត្រានេះមិនបានចែងជាពិសេសអំពីសំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ធ្វើស្ទីការទេ ។ ជាការពិតណាស់ សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ មិនត្រូវបាត់បង់អានុភាព ដោយសារតែការកន្លងផុតនៃអំឡុងពេលសមរម្យទេ គឺចាំបាច់មានការដកសំណើនោះ ទើបបាត់បង់អានុភាព ហេតុដូច្នេះ ចំពោះអ្នកផ្តល់ស្ទីការវិញ មានករណីដែលមិនច្បាស់លាស់ថា តើកិច្ចសន្យាត្រូវបានបង្កើតដោយប្រសិទ្ធភាព ឬគ្មាននោះ នៅពេលដែលការជូនដំណឹងអំពីការដកសំណើមកដល់ ក្រោយការជូនដំណឹងអំពីស្ទីការ ។ ដោយសារហេតុនេះ អ្នកផ្តល់ស្ទីការគួរយកចិត្តទុកដាក់នៅពេលការជូនដំណឹងអំពីស្ទីការបានមកដល់អ្នកស្នើ ។ ចំណុចនេះក៏អនុវត្តផងដែរចំពោះករណីដែលការជូនដំណឹងអំពីស្ទីការមកដល់យឺតយ៉ាវ ។ ហេតុនេះហើយ ក្នុងករណីដែលអំឡុងពេលសម្រាប់ស្ទីការមិនបានកំណត់នៅក្នុងសំណើទេ អ្នកស្នើមិនចាំបាច់ជូនដំណឹងអំពីការយឺតយ៉ាវ ដូចការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះទេ ។ ម្យ៉ាងវិញទៀត ក្នុងករណីនេះ បញ្ហាដែលកើតឡើងថា តើអ្នកផ្តល់ស្ទីការត្រូវជូនដំណឹងទៅអ្នកដកសំណើ អំពីការយឺតយ៉ាវនៃការមកដល់នៃការជូនដំណឹងអំពីការដកសំណើ ឬ យ៉ាងណា ប្រសិនបើការជូនដំណឹងអំពីការដកសំណើនោះត្រូវបានធ្វើឡើង នៅពេលដែលអាចមកដល់អ្នកទទួលសំណើ មុនការមកដល់នៃការជូនដំណឹងអំពីស្ទីការ (មាត្រា ៥២៧ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងអំពីវិធីសង្គ្រោះ ចំពោះករណីនៃការយឺតយ៉ាវក្នុងការជូនដំណឹងអំពីការដកសំណើដែលមិនបានកំណត់អំឡុងពេលសម្រាប់ស្ទីការ) ។ ប៉ុន្តែ ប្រសិនបើអ្នកដកសំណើបានទទួលការជូនដំណឹងអំពីស្ទីការ ហើយមិនច្បាស់លាស់ថា តើកិច្ចសន្យាត្រូវបានបង្កើត ឬយ៉ាងណា អ្នកដកសំណើគួរតែពិនិត្យមើលកាលបរិច្ឆេទនៃការមកដល់នៃការជូនដំណឹងអំពីការដកសំណើ ហើយមិនត្រូវរង់ចាំការជូនដំណឹងអំពីការយឺតយ៉ាវពីភាគីម្ខាងទៀតទេ ។ ដោយយកចំណុចនេះមកពិចារណា ចំពោះការយឺតយ៉ាងក្នុងការជូនដំណឹងអំពីការដកសំណើ យើងសម្រេចមិនតម្រូវឱ្យមានការជូនដំណឹងអំពីការយឺតយ៉ាវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើកិច្ចសន្យាមិនត្រូវបង្កើតឱ្យមានប្រសិទ្ធភាព ដោយសារការយឺតយ៉ាវក្នុងការជូនដំណឹងអំពីស្ទីការ អ្នកស្នើអាចចាត់ទុកការជូនដំណឹងអំពីស្ទីការនោះជាសំណើថ្មីបាន ។ កថាខណ្ឌនេះត្រូវយកមកអនុវត្តចំពោះករណីដែលស្ទីការចំពោះសំណើដែលកំណត់អំឡុងពេលសម្រាប់ស្ទីការ បានមកដល់អ្នកស្នើ នៅក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ។ ប្រសិនបើអ្នកស្នើ បានដកសំណើដែលមិនកំណត់អំឡុងពេលសម្រាប់ស្ទីការ ហើយការដកសំណើនោះបង្កើតអានុភាព ការជូនដំណឹងអំពីស្ទីការមិនអាចចាត់ទុកថាជាសំណើថ្មីបានទេ ។ ការកំណត់បែបនេះ ជារឿង

ធម្មតា ដោយសារអ្នកផ្តល់ស្ទីការ នឹងគិតថា កិច្ចសន្យាមិនត្រូវបានបង្កើត ដោយសារការជូនដំណឹងអំពីការដកសំណើ ។
(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៥២២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២១ (២) នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២០៧ (២) ។ ចំពោះកថាខណ្ឌ ២ សូមមើលមាត្រា ៥២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២១ (១) នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២០៧ (១) ។

**មាត្រា ៣៤២.-** ស្ទីការដោយមានបន្ថែមការកែប្រែ

១-ស្ទីការដែលអ្នកធ្វើស្ទីការ បានដាក់ល័ក្ខខ័ណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ ។

២-ប្រសិនបើល័ក្ខខ័ណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម ។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ ។

(កំណត់)

មាត្រានេះចែងអំពីស្ទីការដែលមានបន្ថែមការកែប្រែចំពោះសំណើ ។

ជាមូលដ្ឋាន មាត្រានេះអនុលោមតាមនិន្នាការអន្តរជាតិថ្មីៗនេះដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ជាអាទិ៍ ។

មានន័យថា ស្ទីការដោយមានការបន្ថែមការកែប្រែសារធាតុចំពោះសំណើ មិនត្រូវក្លាយជាស្ទីការសុពលទេ តែស្ទីការនោះមានអានុភាពជាសំណើថ្មី ។ ប៉ុន្តែ ប្រសិនបើការកែប្រែនោះមិនធ្វើឱ្យមានការកែប្រែសារធាតុទេ ស្ទីការនោះ ត្រូវមានអានុភាពជាស្ទីការ ។ ប៉ុន្តែ ប្រសិនបើអ្នកស្នើតវ៉ាភ្លាម កិច្ចសន្យាមិនត្រូវបានបង្កើតទេ ។ គោលបំណងនៃមាត្រានេះគឺដើម្បីឱ្យមានការបង្កើតកិច្ចសន្យាតាមលទ្ធភាពដែលអាចធ្វើបាន តាមរយៈការសម្របសម្រួលរវាងផលប្រយោជន៍របស់ភាគីទាំងពីរក្នុងការចរចាលើកិច្ចសន្យា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញ

អន្តរជាតិ (CISG) និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២០៨

**មាត្រា ៣៤៣.–** ការបង្កើតកិច្ចសន្យាដោយសកម្មភាពដែលត្រូវបានចាត់ទុកថាជាស្វីការ

ក្នុងករណីដែលមិនចាំបាច់ឱ្យមានដំណឹងអំពីស្វីការ ដោយសារឆន្ទៈរបស់អ្នកស្នើ ឬ ដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលមានសកម្មភាពអាចទទួលស្គាល់ថាជាស្វីការ ។

(កំណត់)

មានករណីជាច្រើនដែលកិច្ចសន្យាអាចបង្កើតដោយគ្មានការបង្ហាញឆន្ទៈអំពីស្វីការចំពោះសំណើ ។ ឧទាហរណ៍ប្រសិនបើបុគ្គលម្នាក់ដែលមានបំណងទិញទំនិញពីអ្នកលក់ដើម្បីប្រគល់ទំនិញនេះឱ្យទៅបុគ្គលផ្សេងទៀតដែលខ្លួនស្គាល់ បញ្ជាទិញទំនិញ ដោយកំណត់អាសយដ្ឋានដែលត្រូវផ្ញើទំនិញនោះ ការបង្ហាញឆន្ទៈនេះគឺជាសំណើ ។ ក្នុងករណីនេះ ប្រសិនបើអ្នកលក់ផ្ញើទំនិញទៅតាមអាសយដ្ឋានដែលអ្នកស្នើកំណត់ ទោះបីជាអ្នកលក់មិនបង្ហាញឆន្ទៈអំពីស្វីការចំពោះអ្នកស្នើក៏ដោយ ក៏សកម្មភាពផ្ញើទំនិញនោះ ត្រូវបកស្រាយថាជាស្វីការដែរ ហើយកិច្ចសន្យាត្រូវបានបង្កើតនៅពេលដែលទំនិញមកដល់ផ្ទះរបស់បុគ្គលដែលអ្នកស្នើស្គាល់នោះ ។

មានករណីខ្លះដែលមានការពិបាកក្នុងការបែងចែក "សកម្មភាពដែលអាចទទួលស្គាល់ថាជាស្វីការ" ដែលបានចែងក្នុងមាត្រានេះ និង សកម្មភាពដែលត្រូវបានបកស្រាយថាជាការបង្ហាញឆន្ទៈអំពីស្វីការ ។ ផ្អែកលើករណីខាងលើ ប្រសិនបើទំនិញត្រូវផ្ញើទៅឱ្យអ្នកស្នើ មានច្រកសម្រាប់បកស្រាយថា ការផ្ញើទំនិញ ជាការបង្ហាញឆន្ទៈអំពីស្វីការ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.២១១

**មាត្រា ៣៤៤.–** ការដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់

សំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់តាមការផ្សាយជាសាធារណៈ ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

(កំណត់)

មាត្រានេះចែងអំពីសំណើចំពោះបុគ្គលដែលមិនកំណត់ជាក់លាក់ តាមរយៈកាសែត និង ការផ្សាយពាណិជ្ជកម្មជាអាទិ៍ ។

ជាបឋម មានបញ្ហាថា តើសំណើសម្រាប់បង្កើតកិច្ចសន្យាចំពោះបុគ្គលដែលមិនកំណត់ជាក់លាក់ អាចធ្វើបាន ឬមិនបាន ។ មាត្រានេះផ្អែកលើការយល់ឃើញថា សំណើបែបនេះត្រូវបានអនុញ្ញាតឱ្យមាន ។ ហើយដោយផ្អែកលើការយល់ឃើញនេះ មានបញ្ហាមួយចំនួនដូចខាងក្រោម :

បញ្ហាទី ១ មានត្រង់ចំណុចថា ប្រសិនបើសំណើត្រូវបានធ្វើចំពោះបុគ្គលដែលមិនកំណត់ជាក់លាក់ មានបុគ្គលជាច្រើនអាចជូនដំណឹងអំពីស្ទីការ ជាលទ្ធផល កិច្ចសន្យាជាច្រើនអាចត្រូវបានបង្កើតឡើងដោយមិនបានគិតទុកមុន ។ ក្នុងករណីដែលអ្នកស្នើជួបស្ថានភាពលំបាកប្រសិនបើមានបុគ្គលជាច្រើនធ្វើស្ទីការលើសំណើ ឧទាហរណ៍ ក្នុងករណីដែលមានវត្ថុតែមួយដើម្បីលក់ ជាអាទិ៍ នោះចាំបាច់ឱ្យអ្នកដែលមានបំណងលក់ ជាអាទិ៍ នោះបញ្ជាក់ថា ការផ្សាយពាណិជ្ជកម្មនេះមិនមែនជាសំណើទេ គឺជា "ហេតុដែលអញ្ជើញឱ្យធ្វើសំណើ" ។ ក្នុងករណីដែលធ្វើសំណើចំពោះបុគ្គលដែលមិនកំណត់ជាក់លាក់នេះដែរ អ្នកស្នើត្រូវភ្ជាប់ល័ក្ខខ័ណ្ឌចំពោះសំណើ ដើម្បីកាត់បន្ថយចំនួនកិច្ចសន្យា ។ ឧទាហរណ៍ ការភ្ជាប់ល័ក្ខខ័ណ្ឌកម្រិតស្ទីការត្រឹមមនុស្ស ចំនួន ១០០ នាក់ដំបូង អាចត្រូវបានអនុញ្ញាត តាមគោលការណ៍នៃសេរីភាពនៃកិច្ចសន្យា ។

បញ្ហាទី ២ គឺជាវិធីដកសំណើចំពោះបុគ្គលដែលមិនបានកំណត់ជាក់លាក់ ។ ជាគោលការណ៍ ការដកសំណើត្រូវធ្វើចំពោះបុគ្គលដែលបានទទួលសំណើ ។ ប៉ុន្តែ ក្នុងករណីដែលសំណើមិនបានកំណត់បុគ្គលជាក់លាក់ អ្នកស្នើមិនអាចដកសំណើនោះ ចំពោះបុគ្គលទាំងអស់ដែលបានទទួលសំណើទេ ។ ហេតុដូច្នេះហើយ ដើម្បីឱ្យមានភាពងាយស្រួល មាត្រានេះចែងថា អ្នកស្នើអាចដកសំណើ "តាមវិធីដូចគ្នានឹងការធ្វើសំណើនោះ" ។ ឧទាហរណ៍ ប្រសិនបើសំណើធ្វើតាមរយៈកាសែតណាមួយ ការដកក៏អាចធ្វើតាមរយៈកាសែតដូចគ្នាបានដែរ ។

ក្រមរដ្ឋប្បវេណីបារាំងចែងអំពីការផ្សាយពាណិជ្ជកម្មផ្តល់រង្វាន់ ។ ប៉ុន្តែ "សំណើដែលមិនកំណត់បុគ្គលជាក់លាក់" នៅក្នុងមាត្រានេះរួមបញ្ចូលទាំងការផ្សាយពាណិជ្ជកម្មផ្តល់រង្វាន់ដែរ ហេតុដូច្នេះ បញ្ញត្តិពិសេសទាក់ទងនឹងការផ្សាយពាណិជ្ជ-កម្មផ្តល់រង្វាន់ មិនត្រូវបានរៀបចំឡើងក្នុងក្រមនេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៩ ដល់មាត្រា ៥៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៣៩៥ នៃក្រមរដ្ឋប្បវេណីកេបិច

## ផ្នែកទី ២ វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

(កំណត់)

មាត្រានេះបញ្ជាក់ទិដ្ឋភាពទាំងអស់នៃការលុបចោលកិច្ចសន្យា ដោយរៀបរាប់ករណីដែលកិច្ចសន្យាអាចត្រូវបានលុបចោល ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ ។

កិច្ចសន្យាមានអានុភាព នៅពេលការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក ។ ហេតុដូច្នេះហើយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យាពុំមានចំណងចងភាគីទាំងពីរទេ ទោះជាបីជាកិច្ចសន្យាហាក់ដូចជាត្រូវបានបង្កើតឡើងបើមើលពីខាងក្រៅក៏ដោយ ។ តាមន័យនេះ ការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាល័ក្ខខ័ណ្ឌដើម្បីឱ្យកិច្ចសន្យាមានអានុភាពចងភាគីទាំងពីរ ។ ដូចដែលបានពន្យល់នៅក្នុងមាត្រា ៣១០ ជំហរដែលយកការបង្ហាញឆន្ទៈរបស់ភាគីនីមួយៗមកធ្វើជាទស្សនាទានគតិយុត្តមួយដែលជាធាតុផ្សំនៃកិច្ចសន្យា បានមកពីក្រមរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់ ។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំង និង ក្រមរដ្ឋប្បវេណីរបស់កេបិច ក៏បានយកពាក្យ "ការយល់ព្រម (consent)" មកប្រើជាទស្សនាទានគតិយុត្ត ដើម្បីធ្វើវិភាគនូវបញ្ហាទាក់ទងនឹង "ការយល់ព្រមរបស់ភាគីនីមួយៗ" នៃកិច្ចសន្យាដែរ ។ តាមន័យនេះ ពីព្រោះតែទស្សនាទាននៃការបង្ហាញឆន្ទៈមានលក្ខណៈងាយស្រួល ក្នុងការពិភាក្សាអំពីអានុភាពចងនៃកិច្ចសន្យា ក្រមរដ្ឋប្បវេណីកម្ពុជាក៏យកការបង្ហាញឆន្ទៈមកប្រើជាទស្សនាទានគតិយុត្តដែរ ។

បញ្ហាដែលកើតឡើងបន្ទាប់នោះ គឺរបៀបដោះស្រាយតាមផ្លូវច្បាប់ចំពោះករណីដែលការបង្ហាញឆន្ទៈរបស់ភាគីនីមួយៗ មានវិការៈ ហើយដែលការបង្ហាញឆន្ទៈនោះមិនត្រូវបានទទួលស្គាល់នូវអានុភាពទេ ។ មាត្រានេះចែងអំពីបញ្ហានេះ ។ ចំពោះបញ្ហានេះ វាអាចត្រឹមត្រូវដែរ ដោយប្រកាន់យកជំហរថា ប្រសិនបើការបង្ហាញឆន្ទៈមានវិការៈ ការបង្ហាញឆន្ទៈនោះអាចត្រូវបានលុបចោល ឬ ត្រូវទុកជាមោឃៈ ។ ប៉ុន្តែ ជំហរនេះមិនបានបញ្ជាក់ច្បាស់ថា តើ "កិច្ចសន្យា" ត្រូវបានចាត់ចែងដូចម្ដេច ក្នុងករណីដែលការបង្ហាញឆន្ទៈមោឃៈ ឬ ត្រូវបានការលុបចោល ។ ឧទាហរណ៍ ប្រសិនបើការបង្ហាញឆន្ទៈរបស់ភាគីម្ខាងមោឃៈ គេមានចម្ងល់ថា តើកិច្ចសន្យាមិនត្រូវបានបង្កើតតាំងពីដើម ឬយ៉ាងណា ។ គេក៏មានចម្ងល់ដូចគ្នាដែរ ប្រសិនបើការបង្ហាញឆន្ទៈត្រូវបានលុបចោល ។ ហេតុដូច្នេះហើយ មាត្រានេះចែងថា ប្រសិនបើការបង្ហាញឆន្ទៈរបស់ភាគីណាមួយមានវិការៈ ភាគីនោះមានសិទ្ធិលុបចោលកិច្ចសន្យា ។ នេះគឺជាអត្ថន័យនៃឃ្លាក្នុងមាត្រានេះថា "អាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ" ។

បញ្ហាបន្ទាប់មកទៀត គឺវិធានការសម្រាប់ដោះស្រាយករណីដែលការបង្ហាញឆន្ទៈរបស់ភាគីម្ខាងមានវិការៈ តាមរយៈផ្តល់លក្ខណសម្បត្តិរួមសម្រាប់ការ "លុបចោលកិច្ចសន្យា" ។ តាមក្រមរដ្ឋប្បវេណីរបស់អាល្លឺម៉ង់ និង ជប៉ុន ករណីដែលការបង្ហាញឆន្ទៈត្រូវទុកជាមោឃៈ ខុសពីករណីដែលការបង្ហាញឆន្ទៈអាចលុបចោល ។ ប្រសិនបើភាគីគ្មានឆន្ទៈពិតប្រាកដដើម្បីបង្កើតកិច្ចសន្យាទេ ក្រមទាំងពីរកំណត់ថា ការបង្ហាញឆន្ទៈនោះត្រូវទុកជាមោឃៈ ។ ប៉ុន្តែ ប្រសិនបើភាគីមានឆន្ទៈចង់បង្កើតកិច្ចសន្យា តែដំណើរការនៃការបង្កើតឆន្ទៈនោះមានវិការៈ ក្រមទាំងពីរកំណត់ថា ការបង្ហាញឆន្ទៈនោះ អាចលុបចោលបាន ។ ប៉ុន្តែ ការបែងចែកយ៉ាងដូច្នេះ មិនមែនថា មានភាពដាច់ខាតទេ ។ ឧទាហរណ៍ ការភាន់ច្រឡំគឺជាមូលហេតុនៃការលុបចោលកិច្ចសន្យា តាមក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ប៉ុន្តែ វាជាមូលហេតុនៃមោឃភាព តាមក្រមរដ្ឋប្បវេណីជប៉ុន ។ ចំណែកឯក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាវិញ ដោយធ្វើការពិចារណាអំពីនិន្នាការនៃនីតិកម្មអន្តរជាតិថ្មីៗនេះ មាត្រានេះចែងថា ក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ កិច្ចសន្យាមិនមែនមោឃៈទេ គឺអាចលុបចោលបានចំពោះករណីទាំងអស់ ។ ចំពោះការបង្ហាញឆន្ទៈមិនពិត និង ឋបនីយផ្លូវចិត្តដែលជាមូលហេតុនៃមោឃភាពនៃការបង្ហាញឆន្ទៈតាមក្រមរដ្ឋប្បវេណីជប៉ុន ក្រមនេះចែងបញ្ញត្តិពិសេស ។ ក្រមនេះចែងថា ការបង្ហាញឆន្ទៈមិនពិតគឺជាមូលហេតុនៃមោឃភាពនៃកិច្ចសន្យា ( មាត្រា ៣៥៣) ។ ចំពោះឋបនីយផ្លូវចិត្តវិញ តាមទ្រឹស្តី ភាគីដែលបង្ហាញឆន្ទៈគ្មានឆន្ទៈពិតប្រាកដទេ ដូច្នេះ ការបង្ហាញឆន្ទៈត្រូវទុកជាមោឃៈ ។ ប៉ុន្តែ វាមិនត្រឹមត្រូវទេដែលអនុញ្ញាតឱ្យមោឃៈ ឬលុបចោលការបង្ហាញឆន្ទៈដែលភាគីម្ខាងដែលបានធ្វើចំពោះអ្នកដទៃ ដោយដឹងច្បាស់លាស់ថា វាមិនមែនជាឆន្ទៈពិតប្រាកដរបស់ខ្លួន ។ ហេតុដូច្នេះហើយ ក្រមនេះចែងថា ជាគោលការណ៍ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយឋបនីយផ្លូវចិត្ត មានសុពលភាព ហើយប្រសិនបើភាគីម្ខាងទៀតបានដឹង ( ទុច្ចរិត) អំពីឋបនីយផ្លូវចិត្ត អ្នកបង្ហាញឆន្ទៈអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ( មាត្រា ៣៥២) ។

ដោយសារភាគីដែលការបង្ហាញឆន្ទៈរបស់ខ្លួនមានវិការៈ ដូចជាការភាន់ច្រឡំ ការឆបោក មានសិទ្ធិលុបចោលកិច្ចសន្យា ដូច្នេះ មានតែបុគ្គលដែលមានសិទ្ធិលុបចោលទេ ដែលអាចលុបចោលកិច្ចសន្យាបាន ។ បន្ថែមពីលើនេះ នៅពេលសិទ្ធិលុបចោល ត្រូវបាត់បង់អានុភាពដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិ កិច្ចសន្យាលែងអាចលុបចោលបានហើយ ។ លើសពីនេះទៀត បញ្ញត្តិរបស់ក្រមរដ្ឋប្បវេណីទាក់ទងនឹងសិទ្ធិលុបចោលត្រូវយកមកអនុវត្តដែរ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១១០៩ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៣៤៦.- ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមាន

វិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

៤-ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីការភាន់ច្រឡំ ។ ផ្អែកតាមប្រព័ន្ធច្បាប់នៃប្រទេសនីមួយៗ ការភាន់ច្រឡំត្រូវចាត់ទុកថាជាមូលហេតុនៃការបដិសេធអានុភាពនៃការបង្ហាញឆន្ទៈ ឬ កិច្ចសន្យា ។ ផ្អែកតាមក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ដូចដែលបានពន្យល់នៅមាត្រា ៣៤៥ ខាងលើរួចហើយ ជំនួសឱ្យការលុបចោលនៃការបង្ហាញឆន្ទៈ ភាគីដែលបានបង្ហាញឆន្ទៈដោយមានការភាន់ច្រឡំ អាចលុបចោលកិច្ចសន្យាបាន ។ ប៉ុន្តែ ប្រភេទនៃការភាន់ច្រឡំដែលប្រើជាមូលហេតុសម្រាប់ការបដិសេធនូវអានុភាពនៃការបង្ហាញឆន្ទៈ ឬ កិច្ចសន្យា មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ជំហរស្តីអំពីការភាន់ច្រឡំ ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ពីព្រោះការភាន់ច្រឡំបង្កឡើងដោយការយល់ច្រឡំជាឯកតោភាគីរបស់ភាគីម្ខាង ហើយជាធម្មតា ភាគីម្ខាងទៀតមិនបានចាប់អារម្មណ៍ទេ ។ ហេតុដូច្នេះ ប្រសិនបើការបដិសេធនូវអានុភាពនៃការបង្ហាញឆន្ទៈ ឬ កិច្ចសន្យាដោយសារការភាន់ច្រឡំ ត្រូវបានអនុញ្ញាតដោយងាយស្រួលនោះ ចំណុចនេះនឹងធ្វើឱ្យខូចខាតដល់សេចក្តីសង្ឃឹមរបស់ភាគីម្ខាងទៀត និង សន្តិសុខនៃកិច្ចការជំនួញ ។ ផ្ទុយទៅវិញ ប្រសិនបើមានការរឹតបន្តឹងខ្លាំងពេកចំពោះការអះអាងអំពីការភាន់ច្រឡំ អ្នកបង្ហាញឆន្ទៈមិនត្រូវបានការពារដោយពេញលេញទេ ។ ហេតុនេះ មានភាពចាំបាច់ត្រូវធ្វើឱ្យមានតុល្យភាពរវាងការការពារអ្នកបង្ហាញឆន្ទៈដែលមានការភាន់ច្រឡំ និង សេចក្តី

សង្ឃឹមរបស់ភាគីម្ខាងទៀត (សន្តិសុខនៃកិច្ចការជំនួញ) ។ ផ្ដើមចេញពីទស្សនាទាននេះហើយ មាត្រានេះអនុញ្ញាតឱ្យមានការលុបចោលនូវការបង្ហាញឆន្ទៈដែលមានការភាន់ច្រឡំ ដោយអនុលោមតាមការវិនិច្ឆ័យដូចខាងក្រោម :

កថាខណ្ឌទី ១ ចែងថា ភាគីដែលមានការភាន់ច្រឡំត្រូវបានអនុញ្ញាតឱ្យលុបចោលកិច្ចសន្យា ក្នុងល័ក្ខខ័ណ្ឌដែលមាន "ការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា" ហើយភាគីម្ខាងទៀតអាចដឹងថា មានការភាន់ច្រឡំ ។ តើចំណុចអ្វីដែលសំខាន់ក្នុងកិច្ចសន្យា គឺត្រូវកំណត់ដោយសត្យានុម័ត ទៅតាមប្រភេទនៃកិច្ចសន្យា និង កាលៈទេសៈជាក់ស្ដែងផ្សេងទៀត។ ឧទាហរណ៍ អ្នកលក់មិនអាចទាមទារលុបចោលកិច្ចសន្យាលក់ទិញបានឡើយ ទោះបីជាមានការភាន់ច្រឡំអំពីអ្នកទិញក៏ដោយ ពីព្រោះបញ្ហាក្នុងកិច្ចសន្យាលក់ទិញថា តើអ្នកណាជាអ្នកទិញ ជាទូទៅ មិនមែនជា "ចំណុចសំខាន់នៃកិច្ចសន្យា" ទេ ។ម្យ៉ាងវិញទៀត ការបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាចំណុចសំខាន់នៃកិច្ចសន្យាលក់ ហេតុដូច្នេះភាគីដែលមានការភាន់ច្រឡំអំពីចំណុចនេះអាចលុបចោលកិច្ចសន្យាបាន ។ ល័ក្ខខ័ណ្ឌផ្សេងទៀតសម្រាប់ការលុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ គឺជាលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ ។ ក្នុងករណីដែលអ្នកលក់ A មានដីពីរឡូតិ៍ គឺ X និង Y ហើយអ្នកទិញ B បានចុះ "កិច្ចសន្យាទិញដីឡូតិ៍ X" ជាមួយ A ដោយមានបំណងទិញដីឡូតិ៍ Y នោះ B មានការភាន់ច្រឡំ អំពីកម្មវត្ថុនៃការលក់ទិញដែលជាចំណុចសំខាន់នៃកិច្ចសន្យា ។ ប៉ុន្តែ ប្រសិនបើការលុបចោលនូវកិច្ចសន្យា ត្រូវបានអនុញ្ញាត ដោយសារតែការភាន់ច្រឡំរបស់ B តែប៉ុណ្ណោះ នោះ A ដែលមិនបានដឹងអំពីការភាន់ច្រឡំរបស់ B អាចទទួលរងនូវការខូចខាតដែលមិនបានគិតទុកមុន ។ហេតុដូច្នេះហើយ ដើម្បីឱ្យ B អាចទាមទារលុបចោលកិច្ចសន្យា ដោយសារការភាន់ច្រឡំបាន កថាខណ្ឌទី ១ នេះតម្រូវឱ្យមានល័ក្ខខ័ណ្ឌថា ភាគីម្ខាងទៀត A អាចដឹងអំពីការភាន់ច្រឡំរបស់ B នោះ ។ ចំណុចនេះមិនគ្រាន់តែរួមបញ្ចូលករណីដែល A បានដឹងអំពីការភាន់ច្រឡំរបស់ B ប៉ុណ្ណោះទេ ថែមទាំងករណីដែល A អាចដឹងផងដែរ ។ កថាខណ្ឌទី ១ នេះមានបំណងជំរុញសន្តិសុខក្នុងកិច្ចការជំនួញដោយកម្រិតក្នុងការអះអាងអំពីការភាន់ច្រឡំតាមរបៀបនេះ ។ ម្យ៉ាងទៀត ទោះបីជាកថាខណ្ឌនេះមិនបានបញ្ជាក់ច្បាស់លាស់ក៏ដោយ បើប្រៀបធៀបជាមួយកថាខណ្ឌទី ២ វាជាការត្រឹមត្រូវដែលគិតថា លទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀត មិនមែនជាល័ក្ខខ័ណ្ឌសកម្មដែលត្រូវតែបញ្ជាក់ដោយភាគីម្ខាងដែលមានការភាន់ច្រឡំនោះទេ ពោលគឺភាគីម្ខាងទៀតមានបន្ទុកក្នុងការបញ្ជាក់ ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំអំពីចំណុចដែលខ្លួនឯងយល់ដោយអត្តនោម័តថាសំខាន់ ។ ករណីនេះ ត្រូវបែងចែកជាពីរ ។

ករណីទី ១ គឺជាករណីដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំនៅផ្នែកណាមួយនៃកិច្ចសន្យាដែលជាធម្មតាមិនសំខាន់ទេ ទៅតាមប្រភេទនៃកិច្ចសន្យា ប៉ុន្តែ អ្នកបង្ហាញឆន្ទៈនោះយល់ឃើញខ្លួនឯងដោយអត្តនោម័តថា ចំណុចនេះសំខាន់ ។ ឧទាហរណ៍ ក្នុងករណីនៃការលក់ទិញរថយន្ត ទោះបីជាពណ៌របស់រថយន្ត ជាធម្មតា មិនមែនជា "ចំណុចសំខាន់នៃកិច្ចសន្យា" ក៏ដោយ ប្រសិនបើអ្នកទិញ ចាត់ទុក "ពណ៌" ថាជាចំណុចសំខាន់ដើម្បីប្រើប្រាស់រថយន្តក្នុងកិច្ចការជំនួញរបស់គាត់ អ្នកទិញអាចអនុញ្ញាតឱ្យលុបចោលកិច្ចសន្យា ដោយហេតុផលនៃការភាន់ច្រឡំអំពីពណ៌បាន ។ ប៉ុន្តែ វាមិន

ត្រឹមត្រូវទេដែលអនុញ្ញាតដោយងាយស្រួលបែបនេះ ពីព្រោះវាធ្វើឱ្យខូចប្រយោជន៍របស់ភាគីម្ខាងទៀត ។ ហេតុដូច្នេះ កថាខណ្ឌទី ២ ចែងអំពីល័ក្ខខ័ណ្ឌដែលភាគីម្ខាងទៀតអាចដឹងថា "ពណ៌" គឺជាចំណុចសំខាន់សម្រាប់អ្នកទិញ ហើយអាច ដឹងបានដែរថា អ្នកទិញមានការភាន់ច្រឡំ ។ បើប្រៀបធៀបជាមួយកថាខណ្ឌទី ១ លទ្ធភាពក្នុងការដឹងរបស់ភាគី ម្ខាងទៀតត្រូវតែបញ្ជាក់ដោយភាគីដែលមានការភាន់ច្រឡំ ។ ផ្តើមចេញពីចំណុចនេះ ការលុបចោលនូវកិច្ចសន្យាដោយ ការភាន់ច្រឡំក្នុងកថាខណ្ឌទី ២ នេះ មានការលំបាកជាងការលុបចោលនៅក្នុងកថាខណ្ឌទី ១ ទៀត ។

ករណីទី ២ គឺជាករណីដែលត្រូវបានហៅថា "ការភាន់ច្រឡំអំពីមូលហេតុ (mistake in motive, Motivirrtum)" ។ ឧទាហរណ៍ B បានបង្កើតកិច្ចសន្យាជាមួយ A ដើម្បីទិញភ្នំដែលមានព្រៃឈើ ដោយមានបំណងកាប់ដើមឈើ ប៉ុន្តែ B មិនបានដឹងថា ការកាប់ដើមឈើត្រូវបានហាមឃាត់នៅតំបន់នោះទេ ដោយសារការភាន់ច្រឡំរបស់ខ្លួន ។ ក្នុងករណីនេះ B មានការភាន់ច្រឡំអំពីមូលហេតុ (បំណង) នៃការបង្កើតកិច្ចសន្យាលក់ទិញ ដែលមានខ្លឹមសារថា "ពីព្រោះដើមឈើអាច ត្រូវបានកាប់បាន" ។ មូលហេតុ (បំណង) នៃការបង្កើតកិច្ចសន្យានេះ គឺជាហេតុផលអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈ ហើយជាធម្មតា ភាគីម្ខាងទៀតមិនអាចដឹងបានទេ ។ ហេតុដូច្នេះហើយ ប្រសិនបើការលុបចោលកិច្ចសន្យាត្រូវបាន អនុញ្ញាតដោយងាយស្រួលដោយហេតុផលនៃការភាន់ច្រឡំអំពីមូលហេតុនោះ សន្តិសុខក្នុងកិច្ចការជំនួញ នឹងត្រូវខូចខាត ។ ហេតុនេះហើយ ចំពោះការភាន់ច្រឡំអំពីមូលហេតុនេះ កថាខណ្ឌទី ២ នេះចែងថា ការលុបចោលកិច្ចសន្យាត្រូវបាន អនុញ្ញាត លុះត្រាតែក្នុងករណីដែលភាគីដែលមានការភាន់ច្រឡំបញ្ជាក់ថា ភាគីម្ខាងទៀត "អាចដឹង" អំពីការភាន់ច្រឡំ នោះ ។

កថាខណ្ឌទី ៣ ចែងអំពីការភាន់ច្រឡំរួម ។ ប្រសិនបើភាគីទាំងពីរមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា កិច្ចសន្យាអាចលុបចោលបាន ទោះបីជាភាគីម្ខាងគ្មានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ។ ការលុបចោលដោយការភាន់ច្រឡំដែលចែងក្នុងកថាខណ្ឌទី ៣ នេះ ខុសពីករណីនៃកថាខណ្ឌទី ១ ទាក់ទងនឹងចំណុចនេះ ។ ឧទាហរណ៍ អ្នកលក់ និង អ្នកទិញបានបង្កើតកិច្ចសន្យាលក់ទិញរូបភាពដែលភាគីទាំងពីរជឿជាក់ថា ត្រូវបានគូរដោយ វិចិត្រករ P ប៉ុន្តែ ក្រោយមក គេបានរកឃើញថា រូបភាពនោះគឺជាស្នាដៃរបស់វិចិត្រករ Q ។ ចំពោះការលុបចោល កិច្ចសន្យាដោយការភាន់ច្រឡំរួម កថាខណ្ឌទី ៣ នេះមិនបែងចែកថា តើកម្មវត្ថុនៃការភាន់ច្រឡំ គឺជាផ្នែកសំខាន់ ជាសត្យានុម័តនៃកិច្ចសន្យា ជាផ្នែកនៃកិច្ចសន្យាដែលភាគីយល់ឃើញដោយអត្តនោម័តថាសំខាន់ និង ជាមូលហេតុ (បំណង) នៃការបង្កើតកិច្ចសន្យាទេ ។

កថាខណ្ឌទី ៤ ចែងអំពីល័ក្ខខ័ណ្ឌតតាំងការលុបចោលនូវកិច្ចសន្យាចំពោះតតិយជន ក្នុងករណីដែលមានតតិយជន ដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយនឹងកិច្ចសន្យា ដែលត្រូវបានអនុញ្ញាតឱ្យលុបចោលដោយការភាន់ច្រឡំរវាង ភាគីនៃកិច្ចសន្យា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១១០ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១១៩ នៃក្រមរដ្ឋប្បវេណី

អាល្លឺម៉ង់, មាត្រា ១៤០០ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៣

**មាត្រា ៣៤៧.–** ការឆបោក

១-បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ ។

៣-ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិលុបចោលកិច្ចសន្យាត្រូវផ្តល់ឱ្យអ្នកបង្ហាញឆន្ទៈ ប្រសិនបើការបង្ហាញឆន្ទៈត្រូវបានធ្វើដោយមានការឆបោកដែលប្រព្រឹត្តដោយភាគីម្ខាងទៀត ឬ តតិយជន ។ ប្រសិនបើការបង្ហាញឆន្ទៈខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដោយសារការឆបោក ហើយកិច្ចសន្យានោះបានបង្កើតរួចទៀត ទោះបីជាអ្នកបង្ហាញឆន្ទៈត្រូវបានបន្ទោសថាឱ្យគេបោកក៏ដោយ ក៏ចាំបាច់នៅតែត្រូវការពារអ្នកបង្ហាញឆន្ទៈដែរ ។ ជាពិសេស ប្រសិនបើការបង្ហាញឆន្ទៈផ្អែកលើការឆបោករបស់ភាគីម្ខាងទៀត មានភាពចាំបាច់យ៉ាងខ្លាំងដែលត្រូវការពារអ្នកបង្ហាញឆន្ទៈ ។ ក្នុងករណីដែលការបង្ហាញឆន្ទៈត្រូវបានធ្វើឡើង ដោយការឆបោករបស់ភាគីម្ខាងទៀត វាមិនមានបញ្ហាអ្វីកើតឡើងទេ ប្រសិនបើការលុបចោលត្រូវបានអនុញ្ញាត ពីព្រោះគេមិនចាំបាច់ការពារភាគីម្ខាងទៀតឡើយ ។ ប៉ុន្តែ ក្នុងករណីដែល A ត្រូវបានបោកតាមរយៈការឆបោករបស់តតិយជន C ហើយបានបង្កើតកិច្ចសន្យាជាមួយ B ប្រសិនបើ A ត្រូវបានអនុញ្ញាតឱ្យលុបចោលកិច្ចសន្យាជាមួយ B ដោយហេតុផលនៃការឆបោករបស់ C នោះភាគីសុចរិត B អាចទទួលរងនូវការខូចខាតដែលមិនបានគិតទុកមុន ។ ហេតុដូច្នេះហើយ ក្នុងករណីនេះ ចាំបាច់សម្របសម្រួលនូវការការពារអ្នកបង្ហាញឆន្ទៈដែលត្រូវបានឆបោក ជាមួយនឹងផលប្រយោជន៍របស់ភាគីម្ខាងទៀត ។ នេះគឺជាហេតុផលដែលកថាខណ្ឌទី ២ អនុញ្ញាតឱ្យលុបចោលកិច្ចសន្យា លុះត្រាតែក្នុងករណីដែល "ភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការឆបោក" ។

កថាខណ្ឌទី ៣ ការពារតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការឆបោក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១១១៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៤០១ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៧

**មាត្រា ៣៤៨.–** ព័ត៌មានមិនពិត

១-នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស ។

៣-ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ ។

(កំណត់)

មាត្រានេះការពារភាគីបង្ហាញឆន្ទៈ ដោយផ្អែកលើព័ត៌មានមិនពិតដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត ។

ប្រសិនបើភាគីម្ខាងទៀតបង្ហាញព័ត៌មានមិនពិតដោយចេតនា សកម្មភាពនេះក្លាយទៅជាការឆបោក ហេតុដូច្នេះ អ្នកបង្ហាញឆន្ទៈត្រូវបានការពារដោយយោងតាមមាត្រា ៣៤៧ ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតមិនបានធ្វើដោយចេតនាទេ ការបង្ហាញឆន្ទៈនេះមិនអាចលុបចោលដោយហេតុផលនៃការឆបោកបានទេ ។ម្យ៉ាងទៀត ក្នុងករណីដែលព័ត៌មានមិនពិតត្រូវបានបង្ហាញដោយភាគីម្ខាងទៀត មានករណីច្រើនដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នេះ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំ ។ ប៉ុន្តែ ការលុបចោលនូវកិច្ចសន្យាដោយសារការភាន់ច្រឡំតម្រូវថា ការភាន់ច្រឡំត្រូវទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យា និង ភាគីម្ខាងទៀតត្រូវមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំនេះ (កថាខណ្ឌទី ១ នៃមាត្រា ៣៤៦) ហេតុដូច្នេះ ការលុបចោលនូវកិច្ចសន្យាមិនត្រូវបានអនុញ្ញាត

ជានិច្ចកាលឡើយ ។ ប៉ុន្តែ ទោះបីជាការបង្ហាញឆន្ទៈមិនអាចលុបចោលដោយការឆបោក ឬ ការភាន់ច្រឡំក៏ដោយ ក៏ការបង្ហាញឆន្ទៈអាចលុបចោលបានដែរ ប្រសិនបើការបង្ហាញឆន្ទៈនោះផ្អែកលើព័ត៌មានមិនពិតដែលត្រូវបានបង្ហាញដោយភាគីម្ខាងទៀត ។ ការកំណត់បែបនេះពីព្រោះវាមិនត្រឹមត្រូវទេដែលភាគីដែលបង្ហាញព័ត៌មានមិនពិត អាចទទួលបាននូវផលប្រយោជន៍នៃកិច្ចសន្យា ពីភាគីដែលបង្ហាញឆន្ទៈដោយផ្អែកលើព័ត៌មានមិនពិតនេះ ។ កំហុសរបស់ភាគីដែលបង្ហាញព័ត៌មានមិនពិត មិនមែនជាល័ក្ខខ័ណ្ឌទេ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើភាគីដែលបង្ហាញព័ត៌មានមិនពិត មានកំហុសក្នុងការបង្ហាញព័ត៌មានមិនពិតនេះ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ។ ក្នុងករណីនេះ គួរតែបកស្រាយថា ភាគីដែលទទួលរងនូវការខូចខាត អាចលុបចោលកិច្ចសន្យា និង ទាមទារសំណងនៃការខូចខាតដែលនៅសល់ក្រោយការលុបចោលបាន ឬ ក៏អាចទាមទារសំណងនៃការខូចខាតដោយមិនលុបចោលកិច្ចសន្យាបានដែរ ។ ក្នុងករណីនេះ ការកំណត់លំអិតអំពីការខូចខាតមានការលំបាក ។ ការលំបាកនេះទុកឱ្យដោះស្រាយតាមរយៈយុត្តិសាស្ត្រ និង ទ្រឹស្តី នៅពេលអនាគត ។

កថាខណ្ឌទី ៣ មានន័យថា ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារហេតុផលនៃព័ត៌មានមិនពិត អានុភាពនៃការលុបចោលកិច្ចសន្យាអាចតតាំងបាន មិនត្រឹមចំពោះភាគីម្ខាងទៀតប៉ុណ្ណោះទេ ថែមទាំងតតិយជន ដូចជាអ្នកដែលធ្វើលទ្ធកម្មជាបន្តបន្ទាប់ផងដែរ ។

(មាត្រាពាក់ព័ន្ធ)

គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៦

## មាត្រា ៣៤៩.- ការរំលោភបំពានលើស្ថានភាព

១-នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។[1]

២-ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ ។

---

[1] កថាខណ្ឌទី ១ នៃមាត្រា ៣៤៩ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលភាគីម្ខាងបង្ខំភាគីម្ខាងទៀតឱ្យចុះកិច្ចសន្យាតាមរយៈការប្រើឋានៈរបស់ខ្លួនដែលមានអាទិភាពជាងខាងផ្នែកសេដ្ឋកិច្ច ឬ សង្គម ។ ទោះបីជាករណីនេះមិនមែនជាការគម្រាមកំហែងក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈត្រូវបានបង្ខំឱ្យបង្ហាញឆន្ទៈដែលខ្លួនមិនមានបំណងធ្វើដែរ ហេតុដូច្នេះ ការបង្ហាញឆន្ទៈនោះមានវិការៈ ហើយមាត្រានេះអនុញ្ញាតឱ្យលុបចោលកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈបែបនេះជាធាតុផ្សំ ។ ប៉ុន្តែ មានករណីជាច្រើនដែលកិច្ចសន្យាត្រូវបានបង្កើតឡើងតាមរយៈការប្រើឋានៈដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ហើយមិនមែនគ្រប់ករណីទាំងអស់ដែលគេអាចលុបចោលនូវកិច្ចសន្យាបាននោះទេ ហេតុដូច្នេះ កថាខណ្ឌទី ១ ចែងថា អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន លុះត្រាតែក្នុងករណីដែលមាន "ការប្រើដោយមិនត្រឹមត្រូវ" នូវស្ថានភាពនេះប៉ុណ្ណោះ ។ តើការប្រើដោយមិនត្រឹមត្រូវ មានន័យបែបណានោះ ត្រូវតែវិនិច្ឆ័យផ្អែកតាមករណីនីមួយៗ ។

ការគិតបែបនេះហៅថា "ឥទ្ធិពលមិនត្រឹមត្រូវ (undue influence)" តាមច្បាប់អង់គ្លូ-អាមេរិកាំង ។ ក្នុងចំណោមប្រទេសច្បាប់ទ្វីប ច្បាប់ប្រទេសហូឡង់ចែងអំពីការលុបចោលដោយហេតុផលនៃ "ការរំលោភបំពានលើស្ថានភាព (abuse of circumstances)" នៅក្នុងគន្ថីទី ៣ មាត្រា ៤៤ នៃក្រមរដ្ឋប្បវេណី ។ កថាខណ្ឌទី ៤ នៃមាត្រា ៤៤ នៃក្រមរដ្ឋប្បវេណីហូឡង់មានប្រយោជន៍សម្រាប់ការយល់ដឹងអំពីមាត្រា ៣៤៩ នេះ ពីព្រោះ កថាខណ្ឌទី ៤ នៃមាត្រា ៤៤ នោះឱ្យនិយមន័យអំពីការរំលោភបំពានលើស្ថានភាពថា "ក្នុងករណីដែលភាគីម្ខាងដឹង ឬ គួរដឹងថា ភាគីម្ខាងទៀត ត្រូវបាននាំឱ្យធ្វើសកម្មភាពគតិយុត្តដែលជាលទ្ធផលនៃស្ថានភាពពិសេស ដូចជា ភាពចាំបាច់ ភាពពឹងពាក់ ការធ្វើសកម្មភាពភ្លាមៗដែលខ្វះការពិចារណា ស្ថានភាពខាងប្រាជ្ញាមិនប្រក្រតី ឬ ភាពខ្វះខាតបទពិសោធន៍ ហើយជំរុញឱ្យភាគីម្ខាងទៀតធ្វើសកម្មភាពបែបនេះ ទោះបីជាខ្លួនមិនគួរនាំឱ្យភាគីម្ខាងទៀតធ្វើសកម្មភាពនោះក៏ដោយ នោះភាគីនោះប្រព្រឹត្តសកម្មភាពរំលោភបំពានលើស្ថានភាព" ។ មាត្រានេះនឹងមានប្រយោជន៍ក្នុងការការពារអ្នកទន់ខ្សោយផ្នែកសេដ្ឋកិច្ច ឬ សង្គម ជាពិសេស អ្នកប្រើប្រាស់ ។

ម្យ៉ាងទៀត មាត្រា ៣៥១ (អំពើកេងចំណេញហួសហេតុ) ចែងថា "ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ" ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តចំពោះករណីដែលភាគីម្ខាងជាអាជីវករ និងភាគីម្ខាងទៀតជាអ្នកប្រើប្រាស់ ហើយដែលអាជីវករបានទទួលប្រាក់ចំណេញហួសហេតុ ដោយឆ្លៀតយកឱកាសពីភាពល្ងង់ ឬ ការខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់ ជាអាទិ៍ ។ ក្នុងចំណោមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៥១ ល័ក្ខខ័ណ្ឌដែល "ភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍" គឺស្រដៀងគ្នានឹងល័ក្ខខ័ណ្ឌនៃមាត្រានេះដែលថា "ភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ

បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ" ប៉ុន្តែ មាត្រា ៣៥១ បន្ថែមល័ក្ខខ័ណ្ឌមួយទៀតគឺការ "កេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់" ចំណែកឯមាត្រានេះគ្មានល័ក្ខខ័ណ្ឌនេះទេ ។ ការកំណត់បែបនេះ មកពីមូលហេតុថា ទោះបីជាវត្ថុ ឬ សេវាណាមួយត្រូវបានលក់ក្នុងតម្លៃសមរម្យ ហើយក្នុងន័យនេះមិនមាន "ការកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់" ក៏ដោយ ប្រសិនបើយល់ឃើញថា អ្នកទិញត្រូវបាននាំឱ្យធ្វើកិច្ចសន្យាលក់ទិញវត្ថុ ឬ សេវាមិនចាំបាច់ ដោយការរំលោភបំពានលើស្ថានភាព នោះក៏មានករណីដែលការលុបចោល គួរត្រូវបានអនុញ្ញាតដែរ ។ ហេតុដូច្នេះហើយ ដើម្បីរក្សាតុល្យភាពរវាងមាត្រា ៣៤៩ និង មាត្រា ៣៥១ គេត្រូវបកស្រាយថា ករណីដែល "ភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ឬ សង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ" នៅក្នុងមាត្រានេះ មានន័យថាជាករណីដែលទំហំនៃការបង្ខំភាគីម្ខាងទៀត ធំជាងករណីដែល "ភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍" ដូចក្នុងមាត្រា ៣៥១ នោះ ។ ប្រសិនបើមាត្រាទាំងពីរអាចអនុវត្តចំពោះករណីមួយ កិច្ចសន្យាអាចលុបចោលតាមមាត្រាណាមួយក៏បាន ។

កថាខណ្ឌទី ២ នៃមាត្រានេះចែងអំពីអានុភាពនៃការលុបចោលកិច្ចសន្យាដែលភាគីម្ខាងបានធ្វើដោយហេតុថា ភាគីម្ខាងទៀតបានប្រើឋានៈខ្លួនខាងផ្នែកសេដ្ឋកិច្ច ជាអាទិ៍ ចំពោះតតិយជន ។ ដើម្បីសម្របសម្រួលជាមួយនឹងផលប្រយោជន៍របស់តតិយជនដែលជាជនសុចរិតហើយគ្មានកំហុស កថាខណ្ឌនេះចែងថា ការលុបចោលកិច្ចសន្យាដោយហេតុនៃការរំលោភបំពានលើស្ថានភាព មិនអាចតតាំងចំពោះតតិយជនសុចរិតដែលគ្មានកំហុសបានឡើយ ។ ប្រសិនបើប្រៀបធៀបជាមួយការការពារចំពោះករណីនៃការគម្រាមកំហែងក្នុងមាត្រា ៣៥០ ការការពារចំពោះជនដែលបង្ហាញឆន្ទៈដោយសារការរំលោភបំពានលើស្ថានភាពនេះ ខ្សោយជាង ។

(មាត្រាពាក់ព័ន្ធ)

គន្លីទី ៣ មាត្រា ៤៤ នៃក្រមរដ្ឋប្បវេណីហូឡង់, មាត្រា ១៤០៣ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៩

## មាត្រា ៣៥០.- ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

(កំណត់)

មាត្រានេះចែងអំពីការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការគម្រាមកំហែង ។

ការបង្ហាញឆន្ទៈដោយការគម្រាមកំហែង ក៏ជាការបង្ហាញឆន្ទៈដែលអ្នកបង្ហាញឆន្ទៈគ្មានបំណងបង្ហាញដែរ ហេតុដូច្នេះ មាត្រានេះការពារអ្នកបង្ហាញឆន្ទៈដោយអនុញ្ញាតឱ្យអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា ។ ខុសគ្នានឹងករណីនៃការឆបោក ក្នុងករណីនៃការគម្រាមកំហែងដែលធ្វើដោយតតិយជន ក្រមនេះបានអនុម័តយកជំហរដែលកិច្ចសន្យាអាចលុបចោលបាន ទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងអំពីការគម្រាមកំហែងក៏ដោយ ។ ក្នុងករណីនៃការគម្រាមកំហែងដោយតតិយ-ជន ទោះបីជាក្រមរដ្ឋប្បវេណីខ្លះ (ដូចជាក្រមរដ្ឋប្បវេណីកេបិច) កម្រិតការលុបចោលកិច្ចសន្យាក៏ដោយ ក៏មាត្រានេះ អនុវត្តតាមក្រមរដ្ឋប្បវេណីជាច្រើនដែលអនុញ្ញាតឱ្យមានការលុបចោលដោយគ្មានល័ក្ខខ័ណ្ឌបន្ថែម (ក្រមរដ្ឋបវេណីជប៉ុន បារាំង និង អាល្លឺម៉ង់) ។

មាត្រានេះគ្មានបញ្ញត្តិដែលកម្រិតការតតាំងចំពោះអានុភាពនៃការលុបចោល ចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសទេ ។ ហេតុនេះហើយ ផ្អែកតាមគោលការណ៍ទូទៅ អានុភាពនៃការលុបចោលកិច្ចសន្យា ដោយសារ ការគម្រាមកំហែង អាចតតាំងចំពោះតតិយជន ដូចជាអ្នកធ្វើលទ្ធកម្មជាបន្តបន្ទាប់បាន ។ ការកំណត់បែបនេះ មាន គោលបំណងឱ្យជនរងគ្រោះនៃការគម្រាមកំហែង ទទួលបាននូវការការពារធំជាងជនរងគ្រោះនៃការឆបោក ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១១១១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៤០២ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៨

## មាត្រា ៣៥១.- អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀត កំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

(កំណត់)

មាត្រានេះចែងអំពីអំពើការកេងចំណេញហួសហេតុ ។

ប្រទេសដែលអនុម័តយកប្រព័ន្ធច្បាប់បារាំង ចែងអំពីការហាមឃាត់ការកេងចំណេញហួសហេតុ (lésion) ។ ប៉ុន្តែ មានការលំបាកក្នុងការនិយាយថា ជានិច្ចកាល ការទទួលបានចំណេញយ៉ាងច្រើនពីកិច្ចសន្យាដោយភាគីមួយ គឺជា សកម្មភាពមិនត្រឹមត្រូវ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីបារាំង បានកម្រិតការហាមឃាត់នៃការកេងចំណេញហួសហេតុ (lésion) ចំពោះករណីដែលភាគីម្ខាងទៀតជាអនីតិជន ជាអាទិ៍ តែប៉ុណ្ណោះ ។ មានបញ្ញត្តិស្រដៀងគ្នានៅក្នុងច្បាប់នៃ

ប្រទេសដែលយកប្រព័ន្ធច្បាប់អាល្លឺម៉ង់ដែរ ប៉ុន្តែ បញ្ញត្តិនេះបានធ្វើមោឃភាពនៃកិច្ចសន្យានេះ ដោយសារកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ ចំណែកឯមាត្រានេះ គឺជាបញ្ញត្តិទូទៅអំពីអំពើកេងយកចំណេញហួសហេតុ ដែលបង្កើតល័ក្ខខ័ណ្ឌរឹតបន្តឹង ហើយដែលមិនកម្រិតចំពោះតែករណីដែលភាគីម្ខាងទៀត ជាអនីតិជន ជាអាទិ៍ប៉ុណ្ណោះទេ ។ ម្យ៉ាងទៀត នេះមិនមែនជាបញ្ញត្តិក្នុងលក្ខណៈជាបញ្ហានៃភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនោះទេ ដូច្នេះ មានតែភាគីដែលបានទទួលការខូចផលប្រយោជន៍ប៉ុណ្ណោះ ដែលអាចលុបចោលកិច្ចសន្យាបាន ។

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យាគឺជាអាជីវករ ហើយភាគីម្ខាងទៀតគឺជាអ្នកប្រើប្រាស់ ជាអាទិ៍ ប្រសិនបើអាជីវករបានចំណេញហួសហេតុ ដោយឆ្លៀតឱកាសនៃភាពល្ងង់ ឬ ខ្វះបទពិសោធន៍របស់អ្នកប្រើប្រាស់ អ្នកប្រើប្រាស់នោះអាចលុបចោលកិច្ចសន្យាបាន ដោយយោងតាមមាត្រានេះ ។

ពីព្រោះតែពាក្យ "ការចំណេញហួសហេតុ" មានន័យខុសគ្នា ដោយអនុលោមតាមពេលវេលា និង ស្ថានភាព មិនអាចចែងឱ្យច្បាស់នៅក្នុងច្បាប់បានទេ ។ មានភាពចាំបាច់វិនិច្ឆ័យតាមរយៈការប្រើយុត្តិសាស្ត្រនៅពេលអនាគត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១១៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៤០៥ និង មាត្រា ១៤០៦ នៃក្រមរដ្ឋប្បវេណីកេបិច, មាត្រា ១៣៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០៩

## មាត្រា ៣៥២.- ថបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

(កំណត់)

មាត្រានេះចែងអំពីថបនីយផ្លូវចិត្ត (mental reservation) ។

ថបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ ។ ឧទាហរណ៍ A បង្ហាញឆន្ទៈ "ធ្វើប្រទានកម្មឱ្យទៅ B" ទោះបីជា A គ្មានបំណងធ្វើបែបនេះក៏ដោយ ។ ការបង្ហាញឆន្ទៈដែលមិនពិតគឺជាការបង្ហាញឆន្ទៈដែលមានវិការៈ ហើយតាមគោលការណ៍នៃកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន A ហាក់ដូចជាត្រូវបានអនុញ្ញាតឱ្យលុបចោលកិច្ចសន្យាប្រទានកម្ម ប៉ុន្តែ ការអនុញ្ញាតឱ្យលុបចោលក្នុងករណីនេះ ធ្វើឱ្យខូចប្រយោជន៍របស់ B យ៉ាងខ្លាំង ប្រសិនបើ B មិនដឹងថា ការបង្ហាញឆន្ទៈរបស់ A មិនពិតទេ ។ បន្ថែមពីនេះ ដោយសារ A បង្ហាញឆន្ទៈមិនពិត ដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិត វាមិនចាំបាច់ការពារអ្នកបង្ហាញ

ឆន្ទៈ A ដែលបានធ្វើឋបនីយផ្លូវចិត្តទេ ។ ហេតុដូច្នេះ មាត្រានេះចែងថា កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយឋបនីយផ្លូវចិត្ត មានសុពលភាព ។

ប្រសិនបើភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។ ករណីនេះមិនមែនមានន័យថា ការបដិសេធនូវអានុភាពនៃកិច្ចសន្យាទេ ។ ហេតុដូច្នេះហើយ ទោះបីជាភាគីម្ខាងទៀត B មិនអាចទាមទារការអនុវត្តកិច្ចសន្យាចំពោះ A ក៏ដោយ អ្នកធ្វើលទ្ធកម្មបន្ត C អាចធ្វើលទ្ធកម្មនូវសិទ្ធិរបស់ B ដោយមានសុពលភាពបាន ហើយ A មិនអាចអះអាងអ្វីចំពោះ C បានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៦ និង មាត្រា ១១៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៣៥៣.- ការបង្ហាញឆន្ទៈមិនពិត

១-កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ ។

២-មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

(កំណត់)

មាត្រានេះចែងថា កិច្ចសន្យាផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ ។

តើត្រូវដោះស្រាយការបង្ហាញឆន្ទៈមិនពិត (sumilation) ដែលបានធ្វើដោយឃុបឃិតជាមួយភាគីម្ខាងទៀតបែបណានោះ មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ប្រព័ន្ធក្រមរដ្ឋប្បវេណីអាល្លឺម៉ង់យកគោលការណ៍ថា ការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ ពីព្រោះឆន្ទៈពិត មិនត្រូវបានបង្ហាញចេញ ហើយការពារតតិយជនសុចរិតដោយយោងតាមបញ្ញត្តិទូទៅ ដូចជាបញ្ញត្តិទាក់ទងនឹងលទ្ធកម្មដោយសុចរិត ជាដើម ។ ផ្ទុយទៅវិញ ប្រព័ន្ធក្រមរដ្ឋប្បវេណីបារាំងមិនចាត់ទុកការបង្ហាញឆន្ទៈនោះជាមោឃៈ ឬ មានវិការៈដោយស្វ័យប្រវត្តិទេ ប៉ុន្តែ ចាត់ទុកវាថាជាការផ្ទុយគ្នារវាង "កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព" និង "ឆន្ទៈពិតដែលត្រូវបានលាក់បាំង" វិញ ។ ផ្អែកតាមក្រមរដ្ឋប្បវេណីបារាំង ការបង្ហាញឆន្ទៈមិនពិត ត្រូវបានដោះស្រាយតាម "ឆន្ទៈពិតដែលត្រូវបានលាក់បាំង" រវាងគូភាគី ហើយក្នុងទំនាក់ទំនងជាមួយតតិយជន តតិយជនអាចអះអាងអំពីគោលគំនិតណាមួយដែលមានផលប្រយោជន៍ច្រើនជាង

ចំពោះខ្លួន ក្នុងចំណោមការគិតទាំងពីរ ។ ឧទាហរណ៍ A បានធ្វើ "កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព" ជាមួយមិត្តភក្តិ B អំពីអនុប្បទានទ្រព្យសម្បត្តិរបស់ A ដើម្បីជៀសវាងពីការរឹបអូស របស់ម្ចាស់បំណុល C ប៉ុន្តែ "ឆន្ទៈពិតដែលត្រូវបានលាក់បាំង" មិនមែនជាការផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិទេ គឺជាអាណត្តិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។ ក្នុងករណីនេះ រវាង A និង B កម្មសិទ្ធិមិនត្រូវបានផ្ទេរទេ ហើយគ្រាន់តែទំនាក់ទំនងគតិយុត្តនៃអាណត្តិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិ កើតឡើងប៉ុណ្ណោះ ។ ដូច្នេះ តតិយជនដូចជាម្ចាស់បំណុល C អាចរឹបអូសទ្រព្យសម្បត្តិបាន ដោយអះអាងអំពី "ឆន្ទៈពិតដែលត្រូវបានលាក់បាំង" ។ ប៉ុន្តែ មានតតិយជនប្រភេទផ្សេងៗទៀត ។ ឧទាហរណ៍ ប្រសិនបើតតិយជន D បានទិញទ្រព្យសម្បត្តិពី B ដោយជឿជាក់ថា ទ្រព្យសម្បត្តិនោះជាកម្មសិទ្ធិរបស់ B នោះតតិយជន D ទំនងជាអះអាងអំពី "កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព" នេះ ។ ផ្អែកតាមក្រមរដ្ឋប្បវេណីបារាំង មានបញ្ហាលំបាកមួយដែលកើតឡើង ពីព្រោះប្រសិនបើមានតតិយជន ពីរ ឬ ច្រើន ពួកគេមានផលប្រយោជន៍ខុសៗគ្នា ។ ហេតុនេះហើយបានជាប្រទេសខ្លះ ក្នុងចំណោមប្រទេសដែលប្រើប្រាស់ប្រព័ន្ធច្បាប់បារាំង ឱ្យអាទិភាពលើ "កិច្ចព្រមព្រៀងដែលមានលក្ខណៈជារូបភាព" នៅពេលដែលមានទំនាស់ផលប្រយោជន៍របស់តតិយជន (មាត្រា ១៤៥២ នៃក្រមរដ្ឋប្បវេណីកេបិច) ។ ដោយពិចារណាលើភាពប្រឆាំងគ្នានៃច្បាប់ដូចបានរៀបរាប់ខាងលើនេះ មាត្រានេះបានយកជំហរមួយថា កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ ។ សូមធ្វើការកត់សំគាល់លើចំណុចខាងក្រោម :

ចំណុចទី ១ គឺកិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកជាមោឃៈ ។ មិនត្រឹមតែភាគីទាំងពីរនៃកិច្ចសន្យាទេ ប៉ុន្តែ ថែមទាំងតតិយជនផងដែរអាចអះអាងមោឃភាពនៃកិច្ចសន្យានោះបាន ។ ចំណុចនេះខុសពីករណីដែលកិច្ចសន្យាអាចលុបចោលបានដោយសារការភាន់ច្រឡំ ជាអាទិ៍ ។ ប៉ុន្តែ មានករណីជាច្រើន ដូចជាក្នុងករណីនៃឧទាហរណ៍ខាងលើ មោឃភាពនៃកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមិនពិត ត្រូវបានអះអាងដោយ A សន្តតិជនរបស់ A ឬម្ចាស់បំណុលរបស់ A រីឯ B ហើយបុគ្គលផ្សេងទៀតនៅខាង B នឹងអះអាងថា កិច្ចសន្យានោះមានសុពលភាព ។

ចំណុចទី ២ គឺពីព្រោះតែកិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ក៏មានអត្ថិភាពផងដែរ ក្នុងលក្ខណៈជារូបភាពសំបកក្រៅ ដូច្នេះ អាចនឹងមានតតិយជនដែលជឿជាក់លើកិច្ចសន្យានេះ ហើយបង្កើតឱ្យមានទំនាក់ទំនងកិច្ចការជំនួញជាមួយនឹង B ។ ហេតុដូច្នេះ មានភាពចាំបាច់ការពារផលប្រយោជន៍របស់តតិយជននោះ ។ មាត្រានេះចែងថា មោឃភាពនៃកិច្ចសន្យា មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិតហើយគ្មានកំហុសធ្ងន់ធ្ងរបានទេ ។ ក្នុងករណីដែលមានការភាន់ច្រឡំ តតិយជនត្រូវមានភាពសុចរិត និង គ្មានកំហុសដើម្បីលុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ ។ ប៉ុន្តែ ក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត ពីព្រោះស្ទើរតែគ្មានភាពចាំបាច់ការពារបុគ្គលដែលបង្ហាញឆន្ទៈមិនពិត មាត្រានេះចែងថា អ្នកបង្ហាញឆន្ទៈមិនពិត មិនអាចអះអាងមោឃភាពចំពោះតតិយជនបានឡើយ លើកលែងតែតតិយជនបានដឹងអំពីការបង្ហាញឆន្ទៈមិនពិត ឬ មិនដឹងការបង្ហាញឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣២១ នៃក្រមរដ្ឋប្ប-

វេណីបារាំង និង មាត្រា ១៤៥១ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣៥៤.–** ភាពខុសច្បាប់ ឬ ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ :

ក-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។

ខ-អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរត្រូវបានធ្វើដោយគ្មានមូលហេតុនៃមោឃភាព ឬ ការលុបចោលក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិដែលបដិសេធអានុភាពនៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ ។ បញ្ញត្តិបែបនេះកម្រិតទំហំនៃសេរីភាពក្នុងការធ្វើកិច្ចសន្យា ចំពោះចំណុចដែលចែងក្នុងបញ្ញត្តិនោះ ។ ហេតុដូច្នេះ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ កិច្ចសន្យានោះត្រូវទុកជាមោឃៈ ។ តើបញ្ញត្តិណាមួយគឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺអាស្រ័យលើការបកស្រាយច្បាប់ ឬ បញ្ញត្តិនីមួយៗ ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ជាធម្មតាគឺជាបញ្ញត្តិដែលមិនអនុវត្តដោយបង្ខំ ហេតុដូច្នេះ ភាគីទាំងពីរនៃកិច្ចសន្យា អាចយល់ព្រមពីអត្ថន័យដែលខុសពីបញ្ញត្តិនេះបាន ។ ប៉ុន្តែ ក្នុងចំណោមបញ្ញត្តិទាំងអស់នៅក្នុងក្រមរដ្ឋប្បវេណី មានបញ្ញត្តិជាច្រើនដែលចែងអំពីសណ្តាប់ធ្នាប់នៃឋានៈបុគ្គល និង សណ្តាប់ធ្នាប់នៃសិទ្ធិប្រត្យក្ស ជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ។ ឧទាហរណ៍ ក្រមរដ្ឋប្បវេណីនេះអនុញ្ញាតឱ្យប្តឹងទាមទារមោឃភាពនៃអាពាហ៍ពិពាហ៍ ប្រសិនបើមានហេតុផលមួយចំនួន ។ ប្រសិនបើគូភាគីនៃ

អាពាហ៍ពិពាហ៍បង្កើតកិច្ចសន្យាដែលមានខ្លឹមសារថា ក្នុងករណីណាក៏ដោយ ក៏មិនអះអាងមោឃភាពនៃអាពាហ៍ពិពាហ៍ កិច្ចសន្យានេះនាំឱ្យខូចផលប្រយោជន៍របស់ភាគីដែលត្រូវបានការពារដោយបញ្ញត្តិស្តីពីមោឃភាពនៃអាពាហ៍ពិពាហ៍ ដូច្នេះ កិច្ចសន្យាបែបនេះ ត្រូវចាត់ទុកជាមោឃៈ ដោយសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ។ បន្ថែមពីនេះ បញ្ញត្តិនៃច្បាប់ការងារដែលកំណត់អំពីកម្រិតអតិបរមានៃម៉ោងធ្វើការប្រចាំសប្តាហ៍ គឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ហើយប្រសិនបើនិយោជក និង កម្មករនិយោជិតចុះកិច្ចសន្យាដែលបញ្ចូលកិច្ចព្រមព្រៀងម៉ោងធ្វើការដែលហួសពីកម្រិតអតិបរមានោះ កិច្ចសន្យានេះត្រូវទុកជាមោឃៈដោយសារបំពាននឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំទាក់ទងនឹងម៉ោងធ្វើការ ។

ទោះបីជាគ្មានបញ្ញត្តិដែលអនុវត្តដោយបង្ខំក៏ដោយ ក៏កិច្ចសន្យាត្រូវទុកជាមោឃៈប្រសិនបើអត្ថន័យនៃកិច្ចសន្យានេះ បំពាននឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ ខ្លឹមសារនៃសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ មិនអាចបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងច្បាប់បានទេ។ អត្ថន័យនៃសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនេះ គួរត្រូវសម្រេចដោយយុត្តិសាស្ត្រ។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃការបំពាននឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។ ប្រសិនបើបុរសម្នាក់ដែលមានប្រពន្ធហើយ ចុះកិច្ចសន្យាជាមួយនារីម្នាក់ទៀតដើម្បីបានរួមភេទជាមួយនាង និង បង់កម្រៃឱ្យនាងនោះ កិច្ចសន្យានេះត្រូវទុកជាមោឃៈ ពីព្រោះអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ទោះបីជាគ្មានច្បាប់ណាហាមឃាត់កិច្ចសន្យាបែបនេះក៏ដោយ ។ បន្ថែមលើនេះទៀត នៅក្នុងសង្គមមូលធននិយមដែលសណ្តាប់ធ្នាប់នៃការប្រកួតប្រជែងដោយស្មោះត្រង់ និង ទីផ្សារ គឺជាការសំខាន់នោះ សកម្មភាពណាមួយដែលរារាំងការប្រកួតប្រជែងដោយស្មោះត្រង់ មិនត្រូវបានអនុញ្ញាតឡើយ ។ ឧទាហរណ៍ ប្រសិនបើអ្នកដេញថ្លៃសំណង់ការិយាល័យរបស់រដ្ឋាភិបាលមួយ យល់ព្រមគ្នាធ្វើឱ្យក្រុមហ៊ុនសាងសង់ជាក់លាក់ណាមួយក្លាយជាអ្នកដេញថ្លៃបានជោគជ័យ ហើយបង្កើតកិច្ចសន្យាដែលមានខ្លឹមសារថា ប្រសិនបើក្រុមហ៊ុននោះទទួលបានជោគជ័យនេះ ក្រុមហ៊ុននោះនឹងបង់ប្រាក់មួយចំនួនទៅអ្នកដេញថ្លៃផ្សេងទៀត ឬ នឹងធ្វើកិច្ចសន្យាម៉ៅការបន្ត ជាមួយអ្នកដេញថ្លៃផ្សេងទៀត កិច្ចសន្យាបែបនេះត្រូវចាត់ទុកជាមោឃៈដោយសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ សកម្មភាពនេះហៅថា "dango (ការគប់គំនិត)" នៅប្រទេសជប៉ុន ។

កថាខណ្ឌទី ២ ចែងអំពីបញ្ហាថា តើកិច្ចសន្យាមួយផ្នែកដែលមានបញ្ហា ឬ កិច្ចសន្យាទាំងមូលត្រូវទុកជាមោឃៈ ប្រសិនបើអត្ថន័យនៃផ្នែកណាមួយនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ ចំណុចនេះហៅថា "បញ្ហានៃមោឃភាពមួយផ្នែក" ។ មោឃភាពនៃកិច្ចសន្យាធ្វើឱ្យប៉ះពាល់បុគ្គលជាច្រើនដែលមានផលប្រយោជន៍ ដែលធ្វើសកម្មភាពដោយគិតថា កិច្ចសន្យានោះមានសុពលភាព ។ ដើម្បីកាត់បន្ថយការប៉ះពាល់នៃបញ្ហាមោឃភាពឱ្យបានច្រើនតាមតែអាចធ្វើបាន វាជាការសមរម្យដែលត្រូវទុកជាមោឃៈតែផ្នែកដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ប៉ុណ្ណោះ ។ ប៉ុន្តែ ឧទាហរណ៍ក្នុងករណីដែលបុគ្គលម្នាក់ដែលគ្មានទ្រព្យសម្បត្តិដែលអាចប្រើជាប្រាតិភោគ ហើយសេចក្តីទុកចិត្តរបស់គាត់មានកម្រិតទាប បានខ្ចីលុយរយៈពេលវែង តាមអត្រាការប្រាក់ដែលលើសពីកម្រិតអប្បបរមាដែលកំណត់ដោយច្បាប់ ប្រសិនបើមានតែផ្នែក

ទាក់ទងនឹងអត្រាការប្រាក់ដែលលើសពីកម្រិតអប្បបរមា ត្រូវទុកជាមោឃៈ ហើយផ្នែកផ្សេងទៀតទុកឱ្យនៅតែមានសុពលភាពនោះ អ្នកឱ្យខ្ចីត្រូវបានបង្ខំឱ្យផ្តល់ប្រាក់កម្ចីតាមអត្រាការប្រាក់ទាបក្នុងរយៈពេលវែង ដល់បុគ្គលដែលគេមិនទុកចិត្ត ។ ក្នុងករណីបែបនេះ វាជាការត្រឹមត្រូវដែលកិច្ចសន្យាទាំងមូលត្រូវទុកជាមោឃៈ ជាជាងមោឃភាពមួយផ្នែកនៃកិច្ចសន្យាដែលពាក់ព័ន្ធ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩០ និង មាត្រា ៩១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៤ និង មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១១៣៣ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៣៥៥.–** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងថា កិច្ចសន្យាមិនត្រូវចាត់ទុកជាមោឃៈទេ ដោយហេតុផលមួយដែលគេហៅថា "អលទ្ធភាពតាំងពីដំបូង" ។ អលទ្ធភាពតាំងពីដំបូងមានន័យថា នៅពេលកិច្ចសន្យាត្រូវបានបង្កើត មានភាពច្បាស់លាស់ជាស្ថាពរថាការអនុវត្តកិច្ចសន្យានេះមិនអាចធ្វើបានទេ ។ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់មុនពេលធ្វើវិសោធនកម្មឆ្នាំ ២០០២ ចែងថា ក្នុងករណីដែលអលទ្ធភាពតាំងពីដំបូង កិច្ចសន្យាត្រូវទុកជាមោឃៈ ប៉ុន្តែ បញ្ញត្តិនេះត្រូវបានលុបចោល ។ សព្វថ្ងៃនេះ ប្រទេសជាច្រើនមាននិន្នាការដែលមិនបានយកអលទ្ធភាពតាំងពីដំបូងធ្វើជាមូលហេតុនៃមោឃភាពនៃកិច្ចសន្យាទេ ហើយមាត្រានេះក៏បានយកជំហរនេះដែរ ។

ប្រសិនបើអលទ្ធភាពតាំងពីដំបូងមិនត្រូវចាត់ទុកជាមូលហេតុនៃមោឃភាពទេ កិច្ចសន្យាត្រូវបង្កើតឡើងដោយមានសុពលភាព ទោះបីជាមានអលទ្ធភាពតាំងពីដំបូងក៏ដោយ ។ ក្នុងករណីនេះ អលទ្ធភាពតាំងពីដំបូង ត្រូវបានដោះស្រាយជាបញ្ហាអលទ្ធភាពទូទៅនៃការអនុវត្ត ។ ហេតុដូច្នេះហើយ បញ្ហានេះត្រូវបានដោះស្រាយ តាមការរំលាយកិច្ចសន្យាដោយយកអលទ្ធភាពក្នុងការអនុវត្តមកធ្វើជាមូលហេតុ ឬ តាមសំណងការខូចខាត ។ ប្រសិនបើភាគីដែលធ្វើកិច្ចសន្យាដោយជឿជាក់ថា ខ្លឹមសារនៃកិច្ចសន្យាអាចអនុវត្តបាន បំពេញល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំ នោះភាគីអាចលុបចោលកិច្ចសន្យា ដោយហេតុថា មានការភាន់ច្រឡំ ។ ឧទាហរណ៍ ក្នុងករណីដែល A និង B បានបង្កើតកិច្ចសន្យាដូរ "រូបភាពរបស់វិចិត្រករ X" របស់ A ជាមួយនឹង "រូបចម្លាក់សេះរបស់ជាងចម្លាក់ Y" របស់ B ប្រសិនបើ "រូបចម្លាក់សេះរបស់ជាងចម្លាក់ Y" របស់ B គឺជារូបចម្លាក់ក្លែងក្លាយ ហើយជាងចម្លាក់ Y មិនដែលឆ្លាក់រូបចម្លាក់សេះទេ ការប្រគល់ "រូបចម្លាក់សេះរបស់ជាងចម្លាក់ Y" ពី B ទៅ A គឺជាអលទ្ធភាពតាំងពីដំបូង ។ ប្រសិនបើ A បានធ្វើកិច្ចសន្យាដូរនេះដោយជឿជាក់ថា ពិតជាមាន "រូបចម្លាក់សេះរបស់ជាងចម្លាក់ Y" នោះ A មានការភាន់ច្រឡំ ហើយប្រសិនបើ A បានបំពេញល័ក្ខខ័ណ្ឌសម្រាប់ការលុបចោលកិច្ចសន្យាដោយសារភាន់ច្រឡំ A អាចលុបចោលកិច្ចសន្យាដូរនោះបាន ។

បន្ថែមពីការទទួលខុសត្រូវទូទៅក្នុងការសងសំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ដូចដែលបានរៀបរាប់ខាងលើ ភាគីដែលបានដឹងអំពីអលទ្ធភាពតាំងពីដំបូងនៅពេលធ្វើកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ទៅភាគីម្ខាងទៀតដែលធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នេះ ។ នេះគឺជាបញ្ហានៃកំហុសក្នុងការបង្កើតកិច្ចសន្យា ។ កថាខណ្ឌទី ២ ចែងអំពីបញ្ហានេះ ។ ការទទួលខុសត្រូវដែលបានចែងក្នុងកថាខណ្ឌទី ២ នោះ ខុសពីការទទួលខុសត្រូវចំពោះការបង្កើតមូលហេតុនៃអលទ្ធភាព ។ ឧទាហរណ៍ ចំពោះកិច្ចសន្យាលក់ផ្ទះនៅស្រុកស្រែមួយរបស់ A ទៅឱ្យ B ប្រសិនបើផ្ទះនៅស្រុកស្រែនោះ ត្រូវបានឆេះ ដោយសារការដុតរបស់តតិយជននៅមុនថ្ងៃចុះកិច្ចសន្យា អ្នកលក់ A មិនចាំបាច់ទទួលខុសត្រូវពីអលទ្ធភាពក្នុងការអនុវត្ត ប៉ុន្តែ A គួរបានដឹងអំពីការឆេះកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមុនកាលបរិច្ឆេទចុះកិច្ចសន្យាដោយទទួលបានព័ត៌មានអំពីផ្ទះនោះ ។ ប្រសិនបើ A បានដឹង ហើយបានជូនដំណឹងទៅភាគីម្ខាងទៀត A អាចជៀសវាងមិនឱ្យភាគីម្ខាងទៀតធ្វើកិច្ចសន្យាដែលគ្មានប្រយោជន៍នេះបាន ។ កថាខណ្ឌទី ២ ចែងអំពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឱ្យភាគីម្ខាងទៀត B ក្នុងករណីបែបនេះ ។ មានភាពចម្រូងចម្រាស់គ្នាថា តើទំហំនៃការខូចខាតក្នុងករណីនេះ ត្រូវកម្រិតត្រឹមការសងការខូចខាតផលប្រយោជន៍ដែលកើតឡើងដោយសារភាគីជឿជាក់ថា មានកិច្ចសន្យា ឬ មានវិសាលភាពដល់ការសងការខូចខាតផលប្រយោជន៍ដែលអាចទទួលពីការអនុវត្តកិច្ចសន្យានោះ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៣០៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ( មុនការធ្វើវិសោធនកម្មនៅឆ្នាំ ២០០២), គោលការណ៍នៃច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៤.១០២

# ផ្នែកទី ៣ មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

(កំណត់)

មាត្រានេះចែងអំពីកម្មវត្ថុនៃមោឃភាព ឬ ការលុបចោល។ ជាការពិតណាស់ មានបញ្ហាផ្សេងៗគ្នាទាក់ទងនឹងមោឃភាព ឬ ការលុបចោល។ ក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាចែងថា ក្នុងករណីដែលយកវិការៈក្នុងការការបង្ហាញឆន្ទៈមកធ្វើជាមូលហេតុ កិច្ចសន្យាដែលមានវិការៈក្នុងការបង្ហាញឆន្ទៈអាចលុបចោលបាន (សូមមើលផ្នែកទី ២) ។ បញ្ញត្តិនៅផ្នែកទី ២ ចែងអំពី "កិច្ចសន្យា" តែប៉ុណ្ណោះ ពីព្រោះគន្លឹស្តីពីកាតព្វកិច្ចនៃក្រមរដ្ឋប្បវេណី ត្រូវបានតាក់តែងឡើង ដោយយក "កិច្ចសន្យា" មកធ្វើជាមូលដ្ឋាន ។ ប៉ុន្តែ ក្នុងករណីនៃសកម្មភាពឯកតោភាគី ប្រសិនបើមានវិការៈក្នុងការបង្ហាញឆន្ទៈដែលជាធាតុផ្សំនៃសកម្មភាពឯកតោភាគីនោះ សកម្មភាពឯកតោភាគីនោះអាចលុបចោលបាន ដូចកិច្ចសន្យាដែរ ។ បញ្ញត្តិនៅផ្នែកទី ២ ក៏អាចយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពជាឯកតោភាគី លើកលែងតែមានភាពមិនសមរម្យ (កថាខណ្ឌទី ២ នៃមាត្រា ៣១២)។ ហេតុដូច្នេះហើយ កម្មវត្ថុនៃការលុបចោលដោយហេតុថាមានវិការៈក្នុងការបង្ហាញឆន្ទៈ គឺជាកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

បន្ថែមពីលើនេះ ផ្នែកទី ២ ចែងថា ដូចជាក្នុងករណីដែលមានភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ កម្មវត្ថុនៃមោឃភាពគឺជាកិច្ចសន្យា ប៉ុន្តែ បញ្ញត្តិនៃផ្នែកទី ២ ស្តីពីមោឃភាពនៃកិច្ចសន្យាក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគីឱ្យតែគ្មានភាពមិនសមរម្យ (កថាខណ្ឌទី ២ នៃមាត្រា ៣១២) ហេតុដូច្នេះ កម្មវត្ថុនៃមោឃភាព ក៏ជាកិច្ចសន្យា និង សកម្មភាពឯកតោភាគីដែរ ។

ដោយធ្វើការពិចារណាលើបញ្ហាដែលរៀបរាប់ខាងលើនេះ ផ្នែកទី ៣ ចែងអំពីបញ្ញត្តិទូទៅនៃមោឃភាព និង ការលុបចោល ហេតុដូច្នេះ មាត្រានេះបញ្ជាក់ថា កម្មវត្ថុនៃមោឃភាព និងការលុបចោល គឺជាកិច្ចសន្យា និង សកម្មភាពឯកតោភាគី ហើយមាត្រានេះចែងយ៉ាងសាមញ្ញដោយហៅសកម្មភាពទាំងពីររួមគ្នាថា "សកម្មភាព"។

បន្ថែមពីលើនេះ ចំពោះការលុបចោលដោយហេតុថា ខ្វះសមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព ក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាចែងថា "សកម្មភាព" អាចលុបចោលដោយសារហេតុផលនេះបាន ហេតុនេះហើយ នៅក្នុងផ្នែកនេះ ពាក្យ "សកម្មភាព" ត្រូវបានប្រើផងដែរ ។

**មាត្រា ៣៥៧.–** អត្ថន័យនៃមោឃភាព

ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យនៃមោឃភាព។ ជាការពិតណាស់ មានករណីនៃមោឃភាពជាច្រើនរួមមានករណីដែលសកម្មភាពត្រូវទុកជាមោឃៈ ដោយសារអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ និង ករណីដែលសកម្មភាពត្រូវទុកជាមោឃៈ ដោយសារសកម្មភាពនោះ ផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយក្រមនេះ ឬ ច្បាប់ផ្សេង ។ ហេតុដូច្នេះហើយមាត្រានេះចែងថា ក្នុងករណីណាក៏ដោយ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យាបានដែរ ។

ក្នុងករណីដែលអត្ថន័យនៃកិច្ចសន្យា និង សកម្មភាពឯកតោភាគីត្រូវទុកជាមោឃៈដោយសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ មិនមែនតែភាគីនៃកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីទេ រួមទាំងបុគ្គលផ្សេងទៀតក៏អាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបានដែរ ។ ការកំណត់ថាសកម្មភាពមួយត្រូវទុកជាមោឃៈបែបនេះ គឺដើម្បីហាមឃាត់កិច្ចសន្យា ឬ សកម្មភាពឯកតោភាគី (មតកសាសន៍ជាអាទិ៍) ដែលផ្ទុយនឹងបទបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហេតុដូច្នេះវាត្រឹមត្រូវដែលបញ្ញត្តិនៃមាត្រានេះចែងថា ជនណាក៏អាចអះអាងអំពីមោឃភាពនៃសកម្មភាពបានដែរ ។ ហើយបញ្ញត្តិនេះក៏អនុវត្តដូចគ្នាដែរ ចំពោះមោឃភាពដោយសារការផ្ទុយទម្រង់ដែលត្រូវបានទាមទារដោយច្បាប់ ។

ភាគីអាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលទុកជាមោឃៈផងដែរ ប៉ុន្តែ ប្រសិនបើបញ្ញត្តិដែលអនុវត្តដោយបង្ខំដែលឱ្យសកម្មភាពក្លាយទៅជាមោឃៈ នៅតែមានអានុភាពនៅពេលផ្តល់សច្ចានុមតិ ឬ ការវាយតម្លៃអំពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនោះ នៅតែមិនមានការផ្លាស់ប្តូរនៅពេលផ្តល់សច្ចានុមតិទេ ទោះបីជាសកម្មភាពនោះត្រូវបានផ្តល់សច្ចានុមតិក៏ដោយ ក៏សកម្មភាពនោះមិនក្លាយទៅជាសកម្មភាពសុពលឡើយ ។ ប៉ុន្តែប្រសិនបើបញ្ញត្តិដែលអនុវត្តដោយបង្ខំត្រូវបានធ្វើឱ្យនិរាករណ៍ ឬ ការវាយតម្លៃពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនោះមានការផ្លាស់ប្តូរ កិច្ចសន្យាក្លាយជាមានសុពលភាព ប្រសិនបើភាគីសងខាងនៃកិច្ចសន្យាផ្តល់សច្ចានុមតិ លើកិច្ចសន្យានោះ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៤១៦ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣៥៨.–** សកម្មភាពដែលអាចលុបចោលបាន

១-សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ ។

២-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ។

៣-ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវមានសុពលភាពជាស្ថាពរ ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យនៃការលុបចោល ។

ការលុបចោលអាចធ្វើបាន ក្នុងករណីដែលកិច្ចសន្យាត្រូវបានលុបចោល ដោយមូលហេតុនៃវិការៈក្នុងការបង្ហាញឆន្ទៈ ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៣៤៦ ដល់មាត្រា ៣៥១ និង ករណីដែលលុបចោលសកម្មភាពដែលត្រូវបានធ្វើដោយជនដែលសមត្ថភាពខាងឆន្ទៈ ឬ សមត្ថភាពក្នុងការធ្វើសកម្មភាពត្រូវបានកម្រិត ដោយយោងតាមមាត្រា ១៤ មាត្រា ១៨ មាត្រា ២៦ និង មាត្រា ៣០ ។

កថាខណ្ឌទី ១ ចែងអំពីអត្ថន័យទូទៅនៃការលុបចោលដែលសកម្មភាពដែលអាចលុបចោល នៅតែមានអានុភាពរហូតដល់ពេលអ្នកដែលមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។ ចំពោះករណីនេះ វាខុសពីមោឃភាពដែលអានុភាពនៃសកម្មភាពត្រូវបានបដិសេធដោយស្វ័យប្រវត្តិតាំងពីដំបូង ។ បន្ថែមពីលើនេះ ភាពខុសគ្នាដ៏សំខាន់រវាងការលុបចោល និង មោឃភាព គឺអត្ថិភាព ឬ នត្ថិភាពនៃការកម្រិតពេលវេលាអំពីការអះអាង ។ ចំពោះមោឃភាព គ្មានការកំណត់ពេលវេលាទេ ប៉ុន្តែ ការលុបចោលមិនអាចអះអាងបានទេ ប្រសិនបើអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល កន្លងផុត ។ មាត្រា ៣៦៣ ចែងអំពីចំណុចនេះ ។

កថាខណ្ឌទី ២ ចែងអំពីអានុភាពក្នុងករណីដែលលុបចោលសកម្មភាព ។ ការលុបចោលមានអានុភាពប្រតិសកម្ម ។

កថាខណ្ឌទី ៣ ចែងអំពីអត្ថន័យនៃការផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៤១៩ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣៥៩.–** អ្នកដែលមានសិទ្ធិលុបចោល

១-ចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈដែលបានកំណត់ ចាប់ពីមាត្រា ៣៤៦ (ការភាន់ច្រឡំ) ដល់មាត្រា ៣៥១

(អំពើកេងយកចំណេញហួសហេតុ) នៃក្រមនេះ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ អាចលុបចោលនូវសកម្មភាពនោះបាន ។ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ ឬ អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

២-ចំពោះការលុបចោល ដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាព ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពផ្សេងទៀត សាមីខ្លួន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈនៃជននោះ អាចលុបចោលនូវសកម្មភាពបាន ។ សន្តតិជន ឬ អច្ច័យលាភីសកលរបស់សាមីខ្លួន ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

(កំណត់)

មាត្រានេះចែងអំពីអ្នកដែលមានសិទ្ធិលុបចោល ។

កថាខណ្ឌទី ១ ចែងអំពីជនដែលមានសិទ្ធិលុបចោល ក្នុងករណីដែលកិច្ចសន្យាអាចលុបចោល ដោយមូលហេតុដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៣៤៦ ដល់មាត្រា ៣៥១។ ក្រៅពីអ្នកបង្ហាញឆន្ទៈ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ ប្រសិនបើមាន ក៏មានសិទ្ធិលុបចោលផងដែរ ។ ឧទាហរណ៍មានដូចជាករណីដែលបន្ទាប់ពីបង្ហាញឆន្ទៈដោយការភាន់ច្រឡំ អ្នកបង្ហាញឆន្ទៈនោះត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព និង អ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសតាំងសម្រាប់អ្នកបង្ហាញឆន្ទៈនោះ ។ ម្យ៉ាងទៀត ជនដែលទទួលបន្តនូវឋានៈរបស់អ្នកដែលបានធ្វើការបង្ហាញឆន្ទៈដែលមានវិការៈ ក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលការលុបចោលត្រូវបានធ្វើ ដោយយកការកម្រិតសមត្ថភាពមកធ្វើជាមូលហេតុ ។ ជនដែលត្រូវបានកម្រិតសមត្ថភាព អាចអនុវត្តសិទ្ធិលុបចោល ។ ចំណុចនេះប្រដែងជាមួយសិទ្ធិលុបចោលរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៦០.-** វិធីនៃការលុបចោល ឬ សច្ចានុមតិ

ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ ។ អានុភាពនៃការលុបចោល ឬ សច្ចានុមតិ ត្រូវកើតឡើងនៅពេលដែល

ដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ ។

(កំណត់)

មាត្រានេះចែងអំពីវិធីនៃការលុបចោល ឬ សច្ចានុមតិ និង ពេលវេលាដែលការលុបចោល និង សច្ចានុមតិ បង្កើតអានុភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៦១.-** អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ

១-អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន ។ ប៉ុន្តែ ក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន ចាប់តាំងពីពេលដែលអ្នកមានសិទ្ធិលុបចោលនោះបានដឹងអំពីមូលហេតុនៃការលុបចោល ។ រីឯសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពវិញ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន នៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពផ្តល់សច្ចានុមតិ ។

(កំណត់)

មាត្រានេះចែងអំពីអ្នកមានសិទ្ធិផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ ។

សច្ចានុមតិ គឺជាសកម្មភាពដែលបុគ្គលដែលមានសិទ្ធិលុបចោល បង្ហាញជាស្ថាពរថា ខ្លួនមិនអនុវត្តសិទ្ធិលុបចោលដោយផ្អែកលើបុរេល័ក្ខខ័ណ្ឌដែលបានដឹងថា សកម្មភាពរបស់ខ្លួនអាចលុបចោលបាន ។ ហេតុនេះហើយ ការទទួលស្គាល់សកម្មភាពដោយជនដែលមិនបានដឹងថា មានមូលហេតុនៃការលុបចោល មិនមែនជាសច្ចានុមតិឡើយ ។ បន្ថែមពីលើនេះ ក្នុងករណីដែលការលុបចោលអាចធ្វើបានដោយមូលហេតុនៃការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជនដែលត្រូវបានកម្រិតសមត្ថភាព អាចលុបចោលសកម្មភាពបាន មុនពេលជននោះមានសមត្ថភាពក្នុងការធ្វើឡើងវិញ ឬ មុនពេលជននោះដល់នីតិភាព (មាត្រា ៣៥៩) ប៉ុន្តែ ជននោះមិនអាចផ្តល់សច្ចានុមតិ មុនពេលជននោះមានសមត្ថភាពក្នុងការ

ធ្វើសកម្មភាពឡើងវិញ ឬ ជននោះដល់នីតិភាពបានឡើយ ពីព្រោះសច្ចានុមតិគឺជាសកម្មភាពដែលធ្វើឱ្យសកម្មភាពនោះមានអានុភាពជាស្ថាពរ ។ ប៉ុន្តែ ចំណុចនេះមិនអនុវត្តទេចំពោះករណីដែលសច្ចានុមតិត្រូវបានផ្តល់ដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២២ និង មាត្រា ១២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៦២.–** សច្ចានុមតិដែលច្បាប់បានកំណត់

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ (អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ និង ល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិ) ខាងលើ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ :

ក-ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ ។

ខ-ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង ។

(កំណត់)

សកម្មភាពដែលត្រូវបានរៀបរាប់នៅក្នុងមាត្រានេះ គឺជាសកម្មភាពដែលត្រូវបានធ្វើឡើង ដោយផ្អែកលើអានុភាពនៃសកម្មភាពដែលអាចលុបចោលបាន ហេតុដូច្នេះ មាត្រានេះបញ្ជាក់ថា សកម្មភាពទាំងនោះមានអានុភាពដូចគ្នានឹងការផ្តល់សច្ចានុមតិដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៦៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្ដល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្ដីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះ ត្រូវរលត់ ។ បញ្ញត្តិស្ដីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ ការតំណាង

**មាត្រា ៣៦៤.-** និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺ ធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង ។

(កំណត់)

(១) មាត្រានេះចែងអំពីនិយមន័យនៃការតំណាង ហើយបញ្ជាក់ច្បាស់ថា អានុភាពសកម្មភាពរបស់អ្នកតំណាង មានចំពោះម្ចាស់សិទ្ធិដោយផ្ទាល់ ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកតំណាងបានចុះកិច្ចសន្យាលក់ទិញជាមួយភាគីម្ខាងទៀត

កិច្ចសន្យាលក់ទិញត្រូវបានបង្កើតឡើងរវាងម្ចាស់សិទ្ធិ និង ភាគីម្ខាងទៀតនោះ ។ គ្មានសិទ្ធិ និង ករណីយកិច្ច នឹងកើតឡើង ចំពោះអ្នកតំណាងតាមកិច្ចសន្យាលក់ទិញនោះទេ ។

ទំនាក់ទំនងតតិយុត្តពាក់ព័ន្ធនឹងការតំណាងនេះ គួរត្រូវបានចែងច្បាស់លាស់នៅក្នុងច្បាប់ ។ ជាពិសេស ក្រមរដ្ឋប្បវេណីបារាំង និង ក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជាដែលទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំង មិនបានបែងចែករវាងអាណត្តិ និង ការតំណាងទេ ហេតុដូច្នេះហើយ មាត្រានេះធ្វើការបែងចែងយ៉ាច្បាស់ថា ការតំណាង គឺជាប្រព័ន្ធផ្សេង និង ឯករាជ្យពីអាណត្តិ ។

(២) ការតំណាងអាចបែងចែកជាពីរប្រភេទ : ការតំណាងដែលម្ចាស់សិទ្ធិជ្រើសតាំងអ្នកតំណាង ហើយផ្តល់សិទ្ធិតំណាងក្នុងទំហំមួយជាក់លាក់ (ការតំណាងដោយឆន្ទៈ) និង ការតំណាងដែលច្បាប់បានកំណត់ ដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ ។ មាត្រានេះគ្របដណ្តប់តំណាងទាំងពីរប្រភេទ ។

(៣) ដូចដែលបានរៀបរាប់ខាងលើ មាត្រានេះមានគោលបំណងបែងចែកអាណត្តិ និង ការតំណាង ។ ការបែងចែកនេះ មានអត្ថន័យដូចខាងក្រោម :

ទី ១ ការតំណាងពាក់ព័ន្ធនឹងបញ្ហាខាងក្រៅដែលកើតឡើងនៅពេលដែលអ្នកតំណាងដែលមានសិទ្ធិតំណាង ធ្វើកិច្ចការជំនួញ ឬ ប្រតិបត្តិការ ជាមួយតតិយជនសម្រាប់ម្ចាស់សិទ្ធិ មានន័យថា តើអានុភាពអ្វីកើតឡើងចំពោះអ្នកណា ក្នុងទំនាក់ទំនងជាមួយនឹងតតិយជន ។ រីឯអាណត្តិពាក់ព័ន្ធនឹងទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ច (ទំនាក់ទំនងខាងក្នុង) រវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ។ ហេតុនេះហើយ អាណត្តិ និង ការតំណាងគួរត្រូវបានបែងចែកដាច់ពីគ្នា ។

ទី ២ ការតំណាងមិនគ្រាន់តែកើតឡើងពីកិច្ចសន្យាអាណត្តិតែប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងកើតឡើងពីកិច្ចសន្យាការងារជាអាទិ៍ ផងដែរ ។ ហេតុដូច្នេះ ការតំណាងគួរតែត្រូវបានចែង ដោយឯករាជ្យពីអាណត្តិ ។ បើមិនធ្វើដូច្នេះទេ ការតំណាងដែលកើតឡើងពីកិច្ចសន្យាការងារ មិនអាចត្រូវបានគ្របដណ្តប់ទេ ។ ម្យ៉ាងទៀត វាងាយស្រួលក្នុងការបង្កើតវិធានគតិយុត្តរួមដែលអាចអនុវត្តចំពោះការតំណាងដោយឆន្ទៈ និង ការតំណាងដែលច្បាប់បានកំណត់ ។ ដើម្បីធ្វើបែបនេះ មានភាពចាំបាច់ចែងបញ្ញត្តិស្តីពីការតំណាងឱ្យឯករាជ្យពីអាណត្តិ ដោយមិនចាត់ទុកថា ការតំណាងគឺជាទំនាក់ទំនងខាងក្រៅដែលកើតឡើងពីអាណត្តិ ។

ទី ៣ ប្រសិនបើប្រតិបត្តិការកាន់តែរីកចម្រើន ហើយកិច្ចសន្យាកាន់តែស្មុគស្មាញ នោះការបង្កើតកិច្ចសន្យាដោយប្រើការតំណាង មានកាន់តែច្រើនដែរ ។ ដូច្នេះ មានភាពចាំបាច់បញ្ជាក់ឱ្យច្បាស់លាស់អំពីនិយមន័យនៃការតំណាង ដើម្បីជៀសវាងវិវាទ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៣.២០២

**មាត្រា ៣៦៥.-** កំណើតនៃសិទ្ធិតំណាង

សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ឬ ដោយបញ្ញត្តិនៃច្បាប់ ។

(កំណត់)

(១) មាត្រានេះចែងអំពីមូលហេតុនៃការបង្កើតសិទ្ធិតំណាង ។ មានករណីពីរ : ករណីទី ១ សិទ្ធិតំណាងកើតឡើងដោយកិច្ចសន្យាប្រគល់សិទ្ធិតំណាង រវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ហើយករណីមួយទៀត អ្នកតំណាងត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃច្បាប់ ហើយទំហំនៃសិទ្ធិតំណាងក៏ត្រូវបានកំណត់ដោយបញ្ញត្តិនៃច្បាប់ដែរ ដូចជាទំនាក់ទំនងរវាងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព និង អ្នកអាណាព្យាបាល ។ ករណីទី ១ ហៅថា ការតំណាងដោយឆន្ទៈ ហើយករណីទី ២ ហៅថា ការតំណាងដែលច្បាប់បានកំណត់ ។ ជាគោលការណ៍ បញ្ញត្តិនៃផ្នែកនេះត្រូវអនុវត្តចំពោះការតំណាងទាំងពីរប្រភេទ ។

ប៉ុន្តែ តាមការពិត មានការតំណាងនៅចន្លោះរវាងការតំណាងដោយឆន្ទៈ និង ការតំណាងដែលច្បាប់បានកំណត់ ។ ទំនាក់ទំនងរវាងនីតិបុគ្គល និង អ្នកតំណាងរបស់នីតិបុគ្គលនោះ គឺជាទំនាក់ទំនាងរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ។ អ្នកតំណាងរបស់នីតិបុគ្គលនេះត្រូវបានជ្រើសតាំងដោយមហាសន្និបាតនៃសមាជិក ជាអាទិ៍ របស់នីតិបុគ្គលនោះ ដូច្នេះ ការតំណាងនៅក្នុងន័យនេះ មានលក្ខណៈជាការតំណាងដោយឆន្ទៈ ។ ប៉ុន្តែ ទោះបីជាទំហំនៃសិទ្ធិតំណាង អាចកំណត់ដោយកិច្ចសន្យាក៏ដោយ ប្រសិនបើគ្មានការកំណត់ពិសេសទេ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃច្បាប់ ។ ក្នុងន័យនេះ ការតំណាងនេះ ក៏មានលក្ខណៈជាតំណាងដែលច្បាប់បានកំណត់ដែរ ។

(២) មានបញ្ហាដែលកើតឡើងក្នុងករណីដែលសិទ្ធិតំណាងកើតឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ថា តើកិច្ចសន្យាចាំបាច់ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។ មាត្រា ១៩៨៥ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១២៧១ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា តម្រូវឱ្យកិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ប៉ុន្តែ មាត្រានេះមិនតម្រូវឱ្យមានកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរទេ ដោយសារកិច្ចសន្យាផ្ទាល់មាត់មានលក្ខណៈងាយស្រួល និង ឆាប់រហ័សក្នុងការធ្វើប្រតិបត្តិការសាមញ្ញ ។

**មាត្រា ៣៦៦.-** ទំហំនៃសិទ្ធិតំណាង

១-ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យាដែលប្រគល់សិទ្ធិតំណាងទៅឱ្យអ្នកតំណាង ។ ក្នុងករណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិនៃច្បាប់ ទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ដោយច្បាប់នោះដែរ ។

២-ក្នុងករណីដែលទំហំនៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិ

ចំពោះអំពើថែរក្សា និង អំពើកែលំអ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង ។

(កំណត់)

មាត្រានេះចែងអំពីទំហំនៃសិទ្ធិតំណាង។

ក្នុងករណីនៃការតំណាងដែលច្បាប់បានកំណត់ ជាធម្មតា ទំហំនៃសិទ្ធិតំណាងក៏ត្រូវបានកំណត់ដោយបញ្ញត្តិនៃច្បាប់ដែរ ។ ក្នុងករណីនៃការប្រគល់សិទ្ធិតំណាងដោយកិច្ចសន្យាវិញ ជាធម្មតា ទំហំនៃសិទ្ធិតំណាងក៏ត្រូវបានកំណត់នៅក្នុងកិច្ចសន្យាដែរ ។

ប៉ុន្តែ ប្រសិនបើគ្មានទំហំជាក់លាក់ណាមួយត្រូវបានកំណត់ចំពោះប្រភេទទាំងពីរនៃការតំណាង អ្នកតំណាងមានសិទ្ធិធ្វើ "សកម្មភាពថែរក្សា" និង "សកម្មភាពកែលំអដែលមិនផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធ" ។ "សកម្មភាពថែរក្សា" មានន័យថាជាសកម្មភាពដែលរក្សាការពារនូវវត្ថុ ឬ សិទ្ធិ ។ អ្នកតំណាងដែលថែរក្សាគ្រប់គ្រងវត្ថុ ត្រូវបានអនុញ្ញាតឱ្យស្នើសុំការជួសជុលវត្ថុនោះ ជាអាទិ៍ ទៅក្រុមហ៊ុនជួសជុល ក្នុងនាមជា "សកម្មភាពថែរក្សា" ។ ការដាក់ពាក្យបណ្តឹងដើម្បីបង្អាក់អាជ្ញាយុកាល ក៏ចាត់ទុកថាជា "សកម្មភាពថែរក្សា" ដែរ ។ "សកម្មភាពកែលំអ" មានន័យថាជាសកម្មភាពដែលបង្កើនតម្លៃនៃវត្ថុ ឬ សិទ្ធិ ។ ឧទាហរណ៍ ការជួសជុលដំបូលអាគារ ដោយប្រើសម្ភារៈដែលមានគុណភាពល្អជាងដំបូលដើម គឺជា "សកម្មភាពកែលំអ" ។ ប៉ុន្តែ សកម្មភាពកែលំអដែលទាមទារចំណាយច្រើន មិនអាចចាត់ទុកថានៅក្នុងទំហំនៃសិទ្ធិតំណាងដោយស្វ័យប្រវត្តិបានឡើយ ទោះបីជាសកម្មភាពនោះមិនប៉ះពាល់ដល់លក្ខណៈនៃវត្ថុ ឬ សិទ្ធិក៏ដោយ ។ កិច្ចសន្យាដែលអ្នកតំណាងបានធ្វើឡើងជាមួយតតិយជន ដើម្បីធ្វើសកម្មភាពថែរក្សា ឬ សកម្មភាពកែលំអដែលត្រូវបានចាត់ទុកថានៅក្នុងទំហំនៃសិទ្ធិតំណាង ត្រូវមានអានុភាពរវាងម្ចាស់សិទ្ធិ និង តតិយជននោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៩៨៨ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៣៦៧.- ការកម្រិតសិទ្ធិតំណាង

១-ទោះបីក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ចំពោះអំពើដែលផលប្រយោជន៍របស់អ្នកតំណាង និង របស់ម្ចាស់សិទ្ធិ មានភាពផ្ទុយគ្នា អ្នកតំណាងគ្មានសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការយល់ព្រម ពីម្ចាស់សិទ្ធិ ។

២-ចំពោះកិច្ចការជំនួញរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ត្រូវសន្មតថា ផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍អ្នកតំណាង មានភាពផ្ទុយគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផង

ដែរ ចំពោះករណីដែលអ្នកតំណាង ធ្វើជាតំណាងឱ្យម្ចាស់សិទ្ធិផង ធ្វើជាតំណាងឱ្យតតិយជនផង ហើយផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍តតិយជន មានភាពផ្ទុយគ្នា ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលសិទ្ធិតំណាងត្រូវបានកម្រិត ដោយសារផលប្រយោជន៍របស់ម្ចាស់សិទ្ធិ មានភាពផ្ទុយគ្នានឹងផលប្រយោជន៍របស់អ្នកតំណាង ។ ប្រសិនបើអ្នកតំណាងត្រូវបានអនុញ្ញាតឱ្យអនុវត្តសិទ្ធិតំណាង ចំពោះកិច្ចការដែលផលប្រយោជន៍របស់ម្ចាស់សិទ្ធិ មានភាពផ្ទុយគ្នានឹងផលប្រយោជន៍របស់អ្នកតំណាង ហានិភ័យដែលអ្នកតំណាងស្វែងរកផលប្រយោជន៍របស់ខ្លួន អាចកើតឡើងដែលធ្វើឱ្យម្ចាស់សិទ្ធិខូចប្រយោជន៍ ។ សកម្មភាពបែបនេះដែលផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និង របស់អ្នកតំណាងមានភាពផ្ទុយគ្នាទៅវិញទៅមក ហៅថា "សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា" ។ ប្រព័ន្ធច្បាប់នៃប្រទេសនីមួយៗ បានដាក់កម្រិតសិទ្ធិតំណាងចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នានេះ ។

សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា មានប្រភេទផ្សេងៗគ្នា ហើយកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ ចែងអំពីប្រភេទនេះ ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិទូទៅដែលដាក់កម្រិតសិទ្ធិតំណាងក្នុងករណីផលប្រយោជន៍រវាងម្ចាស់សិទ្ធិ មានភាពផ្ទុយនឹងផលប្រយោជន៍របស់អ្នកតំណាង ។ ឧទាហរណ៍ ក្នុងករណីដែលបុគ្គលម្នាក់ស្នើឱ្យអ្នកតំណាងលក់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់បុគ្គលនោះ ប្រសិនបើអ្នកតំណាងធ្វើកិច្ចសន្យាលក់ទិញទ្រព្យសម្បត្តិនោះ ក្នុងនាមជាអ្នកលក់តំណាងឱ្យបុគ្គលនោះ ហើយទន្ទឹមនឹងនេះ អ្នកតំណាងនោះធ្វើជាអ្នកទិញក្នុងនាមខ្លួនឯង សកម្មភាពរបស់អ្នកតំណាងនោះ ត្រូវក្លាយទៅជា "សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា" ។ សកម្មភាពនេះហៅថា "កិច្ចការជំនួញដោយខ្លួនឯង (self dealing)" ។ ក្នុងករណីនេះ ទោះបីជាអ្នកតំណាងមានបំណងទិញវត្ថុក្នុងតម្លៃខ្ពស់ជាងតម្លៃទីផ្សារក៏ដោយ ក៏សកម្មភាពនេះត្រូវក្លាយទៅជា "សកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា" ដែរ ហើយសិទ្ធិតំណាងគួរត្រូវបានកម្រិត ។ ហេតុដូច្នេះ កិច្ចការនេះចាត់ទុកថាជាការតំណាងដោយគ្មានសិទ្ធិ ហើយមិនមានអានុភាពចំពោះម្ចាស់សិទ្ធិឡើយ ។ មានន័យថា ម្ចាស់សិទ្ធិអាចបដិសេធអានុភាពនៃកិច្ចសន្យាលក់ទិញជាមួយអ្នកតំណាងបាន ហើយកិច្ចសន្យានោះមិនមានអានុភាពទេ លើកលែងតែម្ចាស់សិទ្ធិយល់ព្រម ។ ជាគោលការណ៍ ម្ចាស់សិទ្ធិមិនអាចផ្តល់ការយល់ព្រមទាំងស្រុងជាមុនបានឡើយ ប៉ុន្តែ ប្រសិនបើប្រភេទនៃប្រតិបត្តិការត្រូវបានកំណត់ច្បាស់លាស់ ម្ចាស់សិទ្ធិអាចផ្តល់ការយល់ព្រមជាមុនបាន ។ ចំពោះកិច្ចការជំនួញខ្លួនឯង (self dealing) ម្ចាស់សិទ្ធិមិនចាំបាច់បញ្ជាក់ថា កិច្ចការជំនួញខ្លួនឯងនោះ ជាសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នាឡើយ ពីព្រោះកិច្ចការជំនួញខ្លួនឯងនោះត្រូវបានសន្មតថាជាសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា ដោយយោងតាមកថាខណ្ឌទី ២ ។

ក្រៅពីកិច្ចការជំនួញដោយខ្លួនឯង (self dealing) មានសកម្មភាពឯកតោភាគីរបស់ម្ចាស់សិទ្ធិដែលក្លាយទៅជាសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា ។ ឧទាហរណ៍ ចំពោះទ្រព្យដែលជាកម្មសិទ្ធិអវិភាគរបស់ម្ចាស់សិទ្ធិ និង អ្នកតំណាង

សកម្មភាពរបស់ម្ចាស់សិទ្ធិដែលបោះបង់ចំណែកកម្មសិទ្ធិអវិភាគ នឹងធ្វើឱ្យអ្នកតំណាងដែលជាម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតទទួលផលប្រយោជន៍ដោយស្វ័យប្រវត្តិ ដូច្នេះ អ្នកតំណាង មិនអាចបោះបង់ចំណែកកម្មសិទ្ធិអវិភាគរបស់ម្ចាស់សិទ្ធិក្នុងនាមជាការតំណាងឱ្យម្ចាស់សិទ្ធិបានឡើយ ។ សកម្មភាពនេះ ក៏ត្រូវបានកម្រិតដោយកថាខណ្ឌទី ១ ដែរ ។

កថាខណ្ឌទី ៣ ចែងថា អ្នកតំណាងមិនអាចជាអ្នកតំណាងរបស់ម្ចាស់សិទ្ធិផង និង ជាអ្នកតំណាងរបស់តតិយជនផងនៅពេលដំណាលគ្នាបានឡើយ ក្នុងករណីដែលមានភាពផ្ទុយគ្នារវាងផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និង ផលប្រយោជន៍របស់តតិយជន ។ មានន័យថា កថាខណ្ឌទី ៣ នេះហាមឃាត់មិនឱ្យមានការតំណាងភាគីទាំងពីរទេ ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាលក់ទិញរវាងម្ចាស់សិទ្ធិ និង តតិយជន សកម្មភាពរបស់អ្នកតំណាងដែលធ្វើកិច្ចសន្យាលក់ទិញ ដោយធ្វើការតំណាងឱ្យភាគីទាំងពីរ គឺផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ។ ហេតុនេះហើយសកម្មភាពនេះ ត្រូវចាត់ទុកជាការតំណាងដោយគ្មានសិទ្ធិតំណាង ដូច្នេះ ម្ចាស់សិទ្ធិ និង តតិយជនអាចបដិសេធអានុភាពនៃកិច្ចសន្យាលក់ទិញនោះបាន ។

ដោយយកការសន្និដ្ឋានថាប្រតិបត្តិការរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ជាគោលការណ៍ ត្រូវសន្មតថាជាសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា មកធ្វើជាបុរេល័ក្ខខ័ណ្ឌ កថាខណ្ឌទី ២ ចែងថា កិច្ចការជំនួញដោយខ្លួនឯងមានសុពលភាព ប្រសិនបើភាគីដែលអះអាងសុពលភាពនៃសកម្មភាពជាក់លាក់ណាមួយ (អ្នកតំណាងក្នុងករណីនៃកិច្ចការជំនួញដោយខ្លួនឯង) បញ្ជាក់ថា សកម្មភាពនោះនឹងមិនធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់សិទ្ធិឡើយ ។ ថាតើការបញ្ជាក់បែបណាដែលអាចទទួលស្គាល់បានថា សកម្មភាពណាមួយនឹងមិនធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់សិទ្ធិនោះ គឺអាស្រ័យលើការវិនិច្ឆ័យនៃយុត្តិសាស្ត្រនៅពេលអនាគត ។ ជាទូទៅ កិច្ចសន្យាប្រទានកម្មដែលអ្នកតំណាងផ្ដល់អំណោយឱ្យម្ចាស់សិទ្ធិ ជាអាទិ៍ គ្រាន់តែផ្ដល់ផលប្រយោជន៍ដល់ម្ចាស់សិទ្ធិ ហើយមិនធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់សិទ្ធិទេ ហេតុដូច្នេះ មិនបានរាប់បញ្ចូលក្នុងសកម្មភាព ដែលផលប្រយោជន៍ផ្ទុយគ្នាទេ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ២១៤៦ និង មាត្រា ២១៤៧ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៣.២០៥

**មាត្រា ៣៦៨.-** មូលហេតុនៃការរលត់សិទ្ធិតំណាង

១-សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យា ត្រូវរលត់ដោយសារមូលហេតុខាងក្រោមនេះ:

ក-មរណភាព ធនក្ស័យ ឬ ការរំលាយរបស់ម្ចាស់សិទ្ធិ ។

ខ-មរណភាព ធនក្ស័យ ឬ ការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង ។

គ-ការបញ្ឈប់អាណត្តិ កិច្ចសន្យាការងារ ឬ ទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលបានប្រគល់សិទ្ធិតំណាង ។

២-ការតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់ដោយសារមូលហេតុដែលបានកំណត់ក្នុងច្បាប់ ។

(កំណត់)

មាត្រានេះចែងអំពីមូលហេតុនៃការរលត់សិទ្ធិតំណាង ។

ចំណុច ក នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលសិទ្ធិតំណាងត្រូវរលត់ដោយសារហេតុផលដែលកើតឡើងចំពោះម្ចាស់សិទ្ធិ ។ ក្នុងករណីដែលសិទ្ធិតំណាងកើតឡើងដោយកិច្ចសន្យា មាត្រានេះចែងថា សិទ្ធិតំណាងត្រូវរលត់ ប្រសិនបើម្ចាស់សិទ្ធិទទួលមរណភាព ដោយហេតុថា អ្នកតំណាងត្រូវបានជ្រើសតាំងតាមរយៈការទុកចិត្តរបស់ម្ចាស់សិទ្ធិ ។ ក្នុងករណីដែលសន្តតិជនរបស់ម្ចាស់សិទ្ធិមានបំណងឱ្យអ្នកតំណាងពីដំបូងបន្តអនុវត្តសកម្មភាពតំណាង ចាំបាច់ប្រគល់សិទ្ធិតំណាងឱ្យអ្នកតំណាងសាជាថ្មី ។ ការចាត់ចែងបែបនេះត្រូវបានធ្វើដោយផ្អែកលើហេតុផលថា បញ្ញត្តិនេះយកចិត្តទុកដាក់លើទំនាក់ទំនងឯកជនរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ។ ប៉ុន្តែ ការចាត់ចែងបែបនេះមិនបង្កលក្ខណៈងាយស្រួលទេ ប្រសិនបើម្ចាស់សិទ្ធិធ្វើអាជីវកម្មជំនួញឯកជន ជាអាទិ៍ ។ នៅពេលដែលរៀបចំក្រមពាណិជ្ជកម្ម មានលទ្ធភាពចែងថា សិទ្ធិតំណាងមិនត្រូវរលត់ទេ បើទោះបីជាម្ចាស់សិទ្ធិបានទទួលមរណភាពក៏ដោយ (មាត្រា ៥០៦ នៃក្រមពាណិជ្ជកម្មជប៉ុន ប្រកាន់យកជំហរនេះ) ។ ទោះបីជាក្រមពាណិជ្ជកម្មមិនបានចែងក៏ដោយ នៅពេលដែលម្ចាស់សិទ្ធិ ធ្វើកិច្ចសន្យាប្រគល់សិទ្ធិតំណាងឱ្យអ្នកតំណាង បញ្ហានេះអាចត្រូវបានដោះស្រាយតាមរយៈការសន្យាពិសេសដែលចែងថា សិទ្ធិតំណាងមិនត្រូវរលត់ទោះបីជាម្ចាស់សិទ្ធិទទួលមរណភាពក៏ដោយ ។

ក្នុងករណីដែលម្ចាស់សិទ្ធិក្ស័យធន វាត្រឹមត្រូវដែលត្រូវរលត់សិទ្ធិតំណាង ពីព្រោះអភិបាលបណ្ដោះអាសន្ននឹងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ម្ចាស់សិទ្ធិ ។ ប្រសិនបើមានការចាំបាច់ឱ្យអ្នកតំណាងពីដំបូង បន្តអនុវត្តសកម្មភាពតំណាង អភិបាលបណ្ដោះអាសន្ននោះអាចជ្រើសតាំងអ្នកតំណាងដដែលនោះម្ដងទៀត ដោយប្រគល់សិទ្ធិតំណាងបាន ។

ក្នុងករណីដែលម្ចាស់សិទ្ធិ គឺជាសហគ្រាស ហើយសហគ្រាសនោះត្រូវរំលាយ ដោយសារនីតិបុគ្គលគ្មានសន្តតិជនដូចរូបវន្តបុគ្គលទេ ជាធម្មតាទេដែលសិទ្ធិតំណាងត្រូវរលត់ លើកលែងតែការរំលាយនោះ ដោយសារការរំលាយសហគ្រាសបញ្ចូលគ្នា ។ ប្រសិនបើសហគ្រាសដែលជាម្ចាស់សិទ្ធិត្រូវរំលាយ ដោយសារការរំលាយសហគ្រាសបញ្ចូលគ្នា ឋានៈរបស់សហគ្រាសដែលរំលាយ នឹងត្រូវបន្តដោយសហគ្រាសដែលកើតថ្មី ប៉ុន្តែ វាត្រឹមត្រូវដែលត្រូវរលត់សិទ្ធិតំណាង ដោយសារហេតុផលដូចគ្នានឹងករណីមរណភាពរបស់ម្ចាស់សិទ្ធិដែរ ។ ប្រសិនបើវាមិនមានលក្ខណៈងាយស្រួលក្នុងការរលត់សិទ្ធិតំណាង បញ្ហានេះអាចធ្វើបានតាមរយៈការសន្យាពិសេសបាន ។

ចំណុច ខ ចែងថា សិទ្ធិតំណាងត្រូវរលត់នៅពេលមានហេតុផលមួយចំនួនដែលកើតឡើងចំពោះអ្នកតំណាង ។ នៅ

ពេលដែលអ្នកតំណាងទទួលមរណភាព វាមិនត្រឹមត្រូវទេដែលឱ្យសន្តតិជនរបស់អ្នកតំណាងបន្តធ្វើសកម្មភាពតំណាង ប្រសិនបើទំនាក់ទំនងជឿជាក់គ្នារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ត្រូវបានយកមកពិចារណា ។ ក្នុងករណីដែលអ្នកតំណាងក្ស័យធន ដោយហេតុថា អ្នកតំណាងនោះគ្មានសមត្ថភាពខាងគ្រប់គ្រងទ្រព្យសម្បត្តិទេ វាក៏មិនត្រឹមត្រូវដែរដែលអនុញ្ញាតឱ្យអ្នកតំណាងដែលក្ស័យធនចុះកិច្ចសន្យាក្នុងនាមម្ចាស់សិទ្ធិ ។ ក្នុងករណីដែលអ្នកតំណាងត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព មាត្រានេះចែងថា សិទ្ធិតំណាងត្រូវរលត់ ដោយសារការកម្រិតនេះផ្ទុយនឹងសេចក្តីសង្ឃឹមរបស់ម្ចាស់សិទ្ធិដែលបានជ្រើសតាំងសមត្ថជនជាអ្នកតំណាង ។ ប៉ុន្តែ គួរកត់សម្គាល់ថា ម្ចាស់សិទ្ធិអាចជ្រើសតាំងជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ធ្វើជាអ្នកតំណាងបាន ។ ប្រសិនបើម្ចាស់សិទ្ធិជ្រើសតាំងជនដែលត្រូវបានកម្រិតសមត្ថភាព ធ្វើជាអ្នកតំណាង តាំងពីដំបូង ហើយឱ្យធ្វើកិច្ចការតំណាងដែលជននោះអាចធ្វើបាន សកម្មភាពនេះត្រូវមានសុពលភាព ហើយមិនចាំបាច់មានអន្តរាគមន៍ផ្នែកច្បាប់ទេ ។

ក្រៅពីករណីខាងលើ សិទ្ធិតំណាងត្រូវរលត់ប្រសិនបើទំនាក់ទំនងគតិយុត្តដែលបង្កើតឱ្យមានសិទ្ធិតំណាងឈប់មានអត្ថិភាព ។ ឧទាហរណ៍ ប្រសិនបើសិទ្ធិតំណាងត្រូវបានប្រគល់តាមរយៈកិច្ចសន្យាអាណត្តិ ឬ កិច្ចសន្យាការងារ សិទ្ធិតំណាងនោះត្រូវរលត់នៅពេលដែលកិច្ចសន្យាអាណត្តិ ឬ កិច្ចសន្យាការងារត្រូវរលត់ ។ ចំពោះមូលហេតុនៃការរលត់កិច្ចសន្យាអាណត្តិ ឬ កិច្ចសន្យាការងារ សូមមើលមាត្រាដែលពាក់ព័ន្ធ ។

កថាខណ្ឌទី ២ ចែងអំពីអ្នកតំណាងដែលច្បាប់បានកំណត់ ។ សិទ្ធិតំណាងដែលកើតឡើងដោយច្បាប់ នឹងត្រូវរលត់នៅពេលដែលមូលហេតុនៃការបង្កើតសិទ្ធិតំណាងដែលចែងដោយច្បាប់នោះឈប់មានអត្ថិភាព ។ ឧទាហរណ៍ បុគ្គលដែលមានអំណាចមេបាមានសិទ្ធិតំណាងឱ្យកូនដែលជាអនីតិជន ប៉ុន្តែ សិទ្ធិតំណាងនេះនឹងត្រូវរលត់ប្រសិនបើបុគ្គលនោះត្រូវបានដកហូតអំណាចមេបា ។ ប្តី និងប្រពន្ធមានសិទ្ធិតំណាងទៅវិញទៅមកក្នុងទំហំនៃកិច្ចការគ្រួសារប្រចាំថ្ងៃ ប៉ុន្តែ សិទ្ធិតំណាងនេះត្រូវរលត់ នៅពេលលែងលះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១១ នៃក្រមរដ្ឋប្បវេណីជប៉ុន: មាត្រា ១៦៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ៥០៦ នៃក្រមពាណិជ្ជកម្មជប៉ុន

## មាត្រា ៣៦៩.– ការតំណាងដោយគ្មានសិទ្ធិ

១-អំពើដែលអ្នកគ្មានសិទ្ធិតំណាងធ្វើក្នុងនាមជាអ្នកតំណាងរបស់អ្នកដទៃ មិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់សិទ្ធិបានផ្តល់សច្ចានុមតិចំពោះអំពើនោះ ។

២-ភាគីម្ខាងទៀតនៃសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ មិនអាចអះអាងថា

អានុភាពនៃសកម្មភាពត្រូវមាន ចំពោះអ្នកតំណាងដោយគ្មានសិទ្ធិឡើយ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវរារាំងភាគីម្ខាងទៀត ក្នុងការទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិទទួលខុសត្រូវ ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៧១ (ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការតំណាងដោយគ្មានសិទ្ធិ មានន័យថា ករណីដែលបុគ្គលដែលគ្មានសិទ្ធិតំណាង ធ្វើសកម្មភាពតំណាងឱ្យម្ចាស់សិទ្ធិ ។

ទី ១ ក្នុងករណីនៃការតំណាងដោយគ្មានសិទ្ធិ សកម្មភាពដែលអ្នកតំណាងបានធ្វើសម្រាប់ម្ចាស់សិទ្ធិ មិនមានអានុភាពចំពោះម្ចាស់សិទ្ធិទេ ហេតុដូច្នេះ មិនត្រូវចងម្ចាស់សិទ្ធិទេ ។ ហេតុដូច្នេះហើយ ម្ចាស់សិទ្ធិអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។ ចំពោះមោឃភាពក្នុងករណីនេះ ខុសពីមោឃភាពទូទៅ ប្រសិនបើម្ចាស់សិទ្ធិផ្ដល់សច្ចានុមតិ សកម្មភាពនោះនឹងត្រូវមានសុពលភាពដោយប្រតិសកម្ម (មាត្រា ៣៧០) ។

ទី ២ គួរកត់សម្គាល់ថា សកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ មិនត្រូវចាត់ទុកថាមោឃៈដោយស្វ័យប្រវត្តិសម្រាប់ភាគីម្ខាងទៀតឡើយ ។ សកម្មភាពនោះមិនចាំបាច់ត្រូវតែមោឃភាពដោយស្វ័យប្រវត្តិឡើយ ពីព្រោះភាគីម្ខាងទៀត អាចសម្រេចគោលបំណងពីដំបូងនៃកិច្ចសន្យាដែលបានបង្កើតជាមួយអ្នកតំណាងដោយគ្មានសិទ្ធិបាន ប្រសិនបើម្ចាស់សិទ្ធិផ្ដល់សច្ចានុមតិចំពោះសកម្មភាព ។ ភាគីម្ខាងទៀតត្រូវបានការពារ តាមរយៈសិទ្ធិដាស់តឿនសច្ចានុមតិ និងសិទ្ធិលុបចោលកិច្ចសន្យា ដោយអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៣៧០ ។

ទី ៣ អានុភាពនៃសកម្មភាពតំណាងដោយគ្មានសិទ្ធិ ជាគោលការណ៍ មិនមានអានុភាពចំពោះអ្នកតំណាងដោយគ្មានសិទ្ធិទេ ។ ការកំណត់បែបនេះពីព្រោះតែ ទោះបីជាអ្នកតំណាងគ្មានសិទ្ធិក៏ដោយ ក៏អ្នកតំណាងនោះមានបំណងធ្វើសកម្មភាពសម្រាប់ម្ចាស់សិទ្ធិដែរ ហេតុនេះហើយអានុភាពនៃសកម្មភាពនោះ មិនមានអានុភាពចំពោះអ្នកតំណាងដោយគ្មានសិទ្ធិទេ ។ ហេតុដូច្នេះ ភាគីម្ខាងទៀតមិនអាចទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិអនុវត្តកិច្ចសន្យា ដោយអះអាងថាអានុភាពនៃកិច្ចសន្យាគួរតែមានចំពោះអ្នកតំណាងដែលគ្មានសិទ្ធិទេ ។ ប៉ុន្តែ ក្នុងគោលបំណងការពារភាគីម្ខាងទៀត មាត្រា ៣៧១ តម្រូវឱ្យអ្នកតំណាងដែលគ្មានសិទ្ធិទទួលខុសត្រូវចំពោះភាគីម្ខាងទៀត ដោយអនុលោមតាមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៧០.–** សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិ និង សិទ្ធិលុបចោលរបស់

ភាគីម្ខាងទៀត

១-ប្រសិនបើមិនបានផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀតទេ ម្ចាស់សិទ្ធិមិនអាចអះអាងអានុភាពនៃសច្ចានុមតិនោះ ចំពោះភាគីម្ខាងទៀតបានឡើយ ។

២-អំពើតំណាងដោយគ្មានសិទ្ធិ ត្រូវមានសុពលភាពប្រតិសកម្ម ដោយសច្ចានុមតិតាំងពីពេលដែលអំពើនោះ ត្រូវបានធ្វើឡើង ។ ប៉ុន្តែ សច្ចានុមតិនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍តតិយជន ដែលបានកើតឡើងក្នុងអំឡុងពេល ចាប់តាំងពីពេលដែលអំពើតំណាងដោយគ្មានសិទ្ធិនោះត្រូវបានធ្វើឡើង រហូតដល់ពេលផ្តល់សច្ចានុមតិ ។

៣-ភាគីម្ខាងទៀតនៃអំពើតំណាងដោយគ្មានសិទ្ធិ អាចដាស់តឿនឱ្យម្ចាស់សិទ្ធិឆ្លើយអំពីការផ្តល់ ឬ មិនផ្តល់សច្ចានុមតិ ដោយកំណត់អំឡុងពេលមួយសមរម្យដើម្បីឆ្លើយ ។ ប្រសិនបើម្ចាស់សិទ្ធិមិនឆ្លើយក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា ម្ចាស់សិទ្ធិបដិសេធការផ្តល់សច្ចានុមតិ ។

៤-ភាគីម្ខាងទៀតអាចលុបចោលកិច្ចសន្យាដែលត្រូវបានធ្វើដោយអ្នកគ្មានសិទ្ធិតំណាង មុនពេលម្ចាស់សិទ្ធិផ្តល់សច្ចានុមតិបាន ។ នៅក្រោយពេលភាគីម្ខាងទៀតបានលុបចោលកិច្ចសន្យា ម្ចាស់សិទ្ធិមិនអាចផ្តល់សច្ចានុមតិចំពោះអំពើតំណាងដោយគ្មានសិទ្ធិបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីសច្ចានុមតិដោយម្ចាស់សិទ្ធិ ចំពោះសកម្មភាពតំណាងដោយគ្មានសិទ្ធិ និង សិទ្ធិដាស់តឿនសច្ចានុមតិ និង សិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត ។

កថាខណ្ឌទី ១ ចែងអំពីវិធីផ្តល់សច្ចានុមតិដោយម្ចាស់សិទ្ធិនូវសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិ ។ កថាខណ្ឌទី ១ នៃមាត្រា ៣៦៩ ចែងថា សកម្មភាពតំណាងដោយគ្មានសិទ្ធិត្រូវទុកជាមោឃៈចំពោះម្ចាស់សិទ្ធិ លើកលែងតែមានសច្ចានុមតិ រីឯកថាខណ្ឌទី ១ នៃមាត្រានេះតម្រូវឱ្យម្ចាស់សិទ្ធិផ្តល់សច្ចានុមតិចំពោះភាគីម្ខាងទៀត ដើម្បីឱ្យសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិមានសុពលភាព ។ ការអះអាងចំពោះអ្នកតំណាងដោយគ្មានសិទ្ធិ មិនមានភាពគ្រប់គ្រាន់ឡើយ ។

កថាខណ្ឌទី ២ ចែងអំពីអានុភាពនៃសច្ចានុមតិ ។ សកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិនឹងត្រូវមានសុពលភាពដោយប្រតិសកម្មចាប់ពីពេលដែលធ្វើសកម្មភាពនោះ ពីព្រោះវាមិនដូចជាមោឃភាពទូទៅទេ ។ ការចែងបែបនេះមានមូលហេតុថា ជាធម្មតា ម្ចាស់សិទ្ធិមានបំណងធ្វើឱ្យសកម្មភាពនោះមានអានុភាពតាំងពីដំបូង ។ ម្យ៉ាងទៀត ចំពោះភាគីម្ខាងទៀត សកម្មភាពតំណាងដោយគ្មានសិទ្ធិ មិនមែនជាសកម្មភាពមោឃៈដាច់ខាតទេ គឺជាសកម្មភាពដែល

អាចលុបចោលបាន (មានន័យថា មានសុពលភាពរហូតដល់ពេលលុបចោល) ហេតុដូច្នេះ ដើម្បីជៀសវាងទំនាក់ទំនងស្មុគស្មាញ កថាខណ្ឌទី ២ នេះ ចែងថា អំពើតំណាងដោយគ្មានសិទ្ធិ ត្រូវមានសុពលភាពប្រតិសកម្ម ដោយសច្ចានុមតិរបស់ម្ចាស់សិទ្ធិ ។

កថាខណ្ឌទី ៣ ចែងអំពីការការពារភាគីម្ខាងទៀតក្នុងករណីដែលមានសកម្មភាពតំណាងដោយគ្មានសិទ្ធិ ។ ក្នុងករណីដែលមានសកម្មភាពតំណាងដោយគ្មានសិទ្ធិនេះ ភាគីម្ខាងទៀតស្ថិតនៅក្នុងស្ថានភាពមិនស្ថិតស្ថេរដែលមិនដឹងថា តើសកម្មភាពនោះត្រូវបានផ្តល់សច្ចានុមតិ និង មានសុពលភាពប្រតិសកម្ម ឬ ត្រូវក្លាយទៅជាមោឃៈដោយការបដិសេធផ្តល់សច្ចានុមតិ ។ ដើម្បីដោះស្រាយនូវស្ថានភាពមិនស្ថិតស្ថេរនេះ កថាខណ្ឌទី ៣ នេះ អនុញ្ញាតឱ្យភាគីម្ខាងទៀតដាស់តឿនឱ្យម្ចាស់សិទ្ធិឆ្លើយថា តើផ្តល់សច្ចានុមតិ ឬ មិនផ្តល់ ។ ប្រសិនបើម្ចាស់សិទ្ធិមិនឆ្លើយតបការដាស់តឿននេះទេ ត្រូវចាត់ទុកថា ម្ចាស់សិទ្ធិបដិសេធការផ្តល់សច្ចានុមតិ ។ ប្រសិនបើសច្ចានុមតិត្រូវបានបដិសេធ សកម្មភាពតំណាង ត្រូវទុកជាមោឃៈជាស្ថាពរ ។

កថាខណ្ឌទី ៤ អនុញ្ញាតឱ្យភាគីម្ខាងទៀតលុបចោលនូវសកម្មភាពតំណាងដោយគ្មានសិទ្ធិដែលគ្មានស្ថិរភាព ។ ដោយសារការលុបចោលនេះ សកម្មភាពតំណាងដោយគ្មានសិទ្ធិត្រូវទុកជាមោឃៈជាស្ថាពរ ។ ម្ចាស់សិទ្ធិដែលមានបំណងផ្តល់សច្ចានុមតិនូវសកម្មភាពតំណាងដោយគ្មានសិទ្ធិ ត្រូវផ្តល់សច្ចានុមតិ មុនពេលភាគីម្ខាងទៀតអនុវត្តសិទ្ធិលុបចោល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣ មាត្រា ១១៤ និង មាត្រា ១១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧៧ និង មាត្រា ១៧៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៣៧១.-** ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ប្រសិនបើជនដែលធ្វើកិច្ចសន្យាក្នុងនាមជាអ្នកតំណាងសម្រាប់ជនដទៃ មិនអាចបញ្ជាក់នូវសិទ្ធិតំណាង ឬ មិនអាចទទួលសច្ចានុមតិពីសាមីខ្លួនបានទេ ជននោះត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬ ទទួលខុសត្រូវក្នុងការសងការខូចខាត តាមការជ្រើសរើសរបស់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង អ្នកតំណាងដោយគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវនោះបាន ។ អ្នកតំណាងដោយគ្មានសិទ្ធិដែលគ្មានកំហុស ក្នុងការធ្វើអំពើតំណាងដោយគ្មានសិទ្ធិ ក៏អាចរួចផុតពីការទទួលខុសត្រូវដែលបានកំណត់ក្នុងមាត្រានេះបានដែរ ទោះបីជាភាគីម្ខាងទៀតមិនបានដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាង ដោយកំហុសក៏ដោយ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ។

ដូចដែលបានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៦៩ ក្នុងករណីនៃការតំណាងដោយគ្មានសិទ្ធិ ភាគីម្ខាងទៀតមិនអាចអះអាងថា អានុភាពនៃសកម្មភាពត្រូវមានចំពោះអ្នកតំណាងដោយគ្មានសិទ្ធិបានទេ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានដឹងថា អ្នកតំណាងគ្មានសិទ្ធិតំណាង មានភាពចាំបាច់ការពារភាគីម្ខាងទៀតនោះ ហេតុដូច្នេះមាត្រានេះចែងថា ភាគីម្ខាងទៀតអាចទាមទារឱ្យសងសំណងការខូចខាត ឬ ឱ្យអនុវត្តកិច្ចសន្យាដែលគ្មានសុពលភាពចំពោះម្ចាស់សិទ្ធិបាន ។ ប្រសិនបើភាគីម្ខាងទៀតទាមទារឱ្យអ្នកតំណាងដោយគ្មានសិទ្ធិអនុវត្តកិច្ចសន្យា អ្នកតំណាងនោះមានករណីយកិច្ចត្រូវអនុវត្ត ។ ប្រសិនបើខ្លឹមសារនៃការអនុវត្តជាការផ្តល់តាវកាលិកនូវវត្ថុដែលមិនបានកំណត់ជាក់លាក់ អ្នកតំណាងដោយគ្មានសិទ្ធិអាចអនុវត្តសកម្មភាពនោះបាន ។ ប៉ុន្តែ ប្រសិនបើខ្លឹមសារនៃការអនុវត្តជាការផ្តល់តាវកាលិកនូវវត្ថុដែលកំណត់ជាក់លាក់ដែលជាកម្មសិទ្ធិរបស់ម្ចាស់សិទ្ធិ អ្នកតំណាងដោយគ្មានសិទ្ធិត្រូវតែទិញវត្ថុនោះពីម្ចាស់សិទ្ធិ ហើយប្រគល់វាទៅឱ្យភាគីម្ខាងទៀត ។ ប្រសិនបើម្ចាស់សិទ្ធិមិនព្រមលក់ អ្នកតំណាងដោយគ្មានសិទ្ធិនោះនឹងមិនអាចអនុវត្តការផ្តល់តាវកាលិកបានទេ ។ ក្នុងករណីនេះ ភាគីម្ខាងទៀតគ្មានវិធីផ្សេងទៀតក្រៅពីការទាមទារឱ្យសងសំណងការខូចខាតទេ ។

ភាគីម្ខាងទៀតអាចទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិបាន លុះត្រាតែភាគីនោះមិនបានដឹងថា អ្នកតំណាងនោះគ្មានសិទ្ធិតំណាង ។ ការកំណត់បែបនេះពីព្រោះភាគីម្ខាងទៀតដែលបានដឹងអំពីការខ្វះខាតសិទ្ធិតំណាង ត្រូវដឹងថា កិច្ចសន្យាជាមួយម្ចាស់សិទ្ធិនឹងគ្មានសុពលភាព ហេតុនេះហើយ វាដូចជាជ្រុលបន្តិចដែលផ្តល់សិទ្ធិឱ្យភាគីនោះទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ទោះបីជាម្ចាស់សិទ្ធិមិនបានផ្តល់សច្ចា-នុមតិ ហើយកិច្ចសន្យាមិនត្រូវបានបង្កើតក៏ដោយ ។ ភាគីម្ខាងទៀតមិនតម្រូវឱ្យបញ្ជាក់ អំពីភាពសុចរិតរបស់ខ្លួនទេជំនួសមកវិញ អ្នកតំណាងដោយគ្មានសិទ្ធិដែលមានបំណងរួចផុតពីការទទួលខុសត្រូវដែលបានកំណត់នៅក្នុងមាត្រានេះត្រូវបញ្ជាក់អំពីភាពទុច្ចរិតរបស់ភាគីម្ខាងទៀត ។ តើមានអ្វីកើតឡើងប្រសិនបើភាគីម្ខាងទៀតមិនបានដឹងថា អ្នកតំណាងគ្មានសិទ្ធិ ប៉ុន្តែ ការមិនបានដឹងនេះដោយសារតែកំហុសរបស់ខ្លួន ? អាចមានមតិដែលសន្និដ្ឋានថា ភាគីម្ខាងទៀតដែលមិនបានដឹងអំពីការខ្វះសិទ្ធិតំណាងដោយសារកំហុស មិនសមទទួលបាននូវការការពារទេ ប៉ុន្តែ អាចមានមតិផ្សេងទៀតថាភាគីម្ខាងទៀតដែលជាជនសុចរិត ត្រូវបានអនុញ្ញាតឱ្យទាមទារការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិដែលជាជនទុច្ចរិត ទោះបីជាភាគីនោះមានកំហុសក៏ដោយ ។ មាត្រានេះបានជ្រើសរើសយកជំហរខាងក្រោយនេះ ។ ប៉ុន្តែដូចដែលបានពន្យល់ខាងក្រោមនេះ ភាគីម្ខាងទៀតដែលសុចរិត តែមានកំហុស មិនអាចទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិបានទេ ប្រសិនបើអ្នកតំណាងដោយគ្មានសិទ្ធិនេះគ្មានកំហុសក្នុងការធ្វើសកម្មភាពតំណាងដោយគ្មានសិទ្ធិ ។

ភាគីម្ខាងទៀតអាចទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិបាន ទោះបីជាអ្នកតំណាងនោះគ្មានកំហុសក៏ដោយ ។ ក្នុងន័យនេះ ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិដែលចែងក្នុងមាត្រានេះ គឺជា

ការទទួលខុសត្រូវដែលកំហុសមិនមែនជាល័ក្ខខ័ណ្ឌ ។ អ្នកតំណាងដោយគ្មានសិទ្ធិដែលគ្មានកំហុសក្នុងការធ្វើសកម្មភាពតំណាងដោយគ្មានសិទ្ធិត្រូវទទួលខុសត្រូវ ក្នុងករណីដែលភាគីម្ខាងទៀតជាជនសុចរិត និង គ្មានកំហុស ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតសុចរិត តែមានកំហុស អ្នកតំណាងដោយគ្មានសិទ្ធិអាចរួចផុតពីការទទួលខុសត្រូវ ដោយសារវាមិនត្រឹមត្រូវទេ ដែលអនុញ្ញាតឱ្យភាគីម្ខាងទៀតទាមទារឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ ដែលគ្មានកំហុស ទោះបីជាភាគីម្ខាងទៀតមានកំហុសខ្លួនឯងក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៣.២០៤

**មាត្រា ៣៧២.-** ការតំណាងដែលមានលក្ខណៈជារូបភាព

១-ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យា ដោយហួសពីទំហំនៃសិទ្ធិតំណាង ប្រសិនបើភាគីម្ខាងទៀតជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះទេ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះ ចំពោះភាគីម្ខាងទៀត ។

២-ក្រោយពីពេលដែលសិទ្ធិតំណាងបានរលត់ ប្រសិនបើភាគីម្ខាងទៀតបានធ្វើកិច្ចសន្យា ជាមួយនឹងអ្នកដែលបង្ហាញខ្លួនថា ជាអ្នកតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យានោះចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីការរលត់នៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីការរលត់នោះដោយមានកំហុស ។

៣-ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងទៅអ្នកផ្សេង ប៉ុន្តែ ម្ចាស់សិទ្ធិបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនោះទៅឱ្យអ្នកផ្សេង ឬ អនុញ្ញាតឱ្យអ្នកផ្សេងនោះបង្ហាញថា អ្នកនោះមានសិទ្ធិតំណាង ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវក្នុងការអនុវត្តកិច្ចសន្យាចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដឹងអំពីនត្ថិភាពនៃសិទ្ធិតំណាងនោះ ឬ មិនដឹងអំពីនត្ថិភាពនោះដោយមានកំហុស ។

(កំណត់)

មាត្រានេះចែងអំពីការការពារភាគីម្ខាងទៀតដែលជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាង មានន័យថា បញ្ញត្តិទាក់

ទងនឹងការតំណាងដែលមានលក្ខណៈជារូបភាព ។ ការតំណាងដែលមានលក្ខណៈជារូបភាពមាន ៣ ប្រភេទ ។

កថាខណ្ឌទី ១ មានគោលបំណងការពារភាគីម្ខាងទៀត ក្នុងករណីដែលអ្នកតំណាងធ្វើសកម្មភាពហួសពីទំហំនៃសិទ្ធិតំណាង ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់សិទ្ធិប្រគល់សិទ្ធិតំណាង ឱ្យបុគ្គលម្នាក់លក់រថយន្ត ប៉ុន្តែ អ្នកតំណាងនោះបែរជាលក់ផ្ទះរបស់ម្ចាស់សិទ្ធិ ។ ប្រសិនបើភាគីម្ខាងទៀតជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងលក់ផ្ទះ ហើយគ្មានកំហុសក្នុងការជឿជាក់ដូច្នេះទេ ភាគីនោះអាចអះអាងចំពោះម្ចាស់សិទ្ធិថា កិច្ចសន្យាលក់ផ្ទះនោះមានសុពលភាព ផ្អែកតាមមាត្រានេះ ។ ការតំណាងបែបនេះអាចហៅបានថា "ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសសិទ្ធិតំណាង" ។ ភាគីម្ខាងទៀតដែលអាចទាមទារឱ្យម្ចាស់សិទ្ធិអនុវត្តកិច្ចសន្យា មានករណីយកិច្ចត្រូវបង់តម្លៃថ្នូរទៅឱ្យម្ចាស់សិទ្ធិ ប្រសិនបើកិច្ចសន្យានោះ ជាកិច្ចសន្យាអញ្ញមញ្ញ ។

កថាខណ្ឌទី ២ ចែងអំពីការការពារភាគីម្ខាងទៀត នៅក្នុងករណីដែលអ្នកតំណាងធ្វើសកម្មភាព ក្នុងទំហំនៃសិទ្ធិតំណាងដែលធ្លាប់មានអត្ថិភាព ក្រោយពេលដែលសិទ្ធិតំណាងបានរលត់ ។ ក្នុងករណីនេះ ក៏ភាគីម្ខាងទៀតអាចអះអាងចំពោះម្ចាស់សិទ្ធិបានផងដែរថា កិច្ចសន្យាលក់ផ្ទះនោះមានសុពលភាព ប្រសិនបើភាគីនោះមានភាពសុចរិត និង គ្មានកំហុសចំពោះការរលត់នៃសិទ្ធិតំណាង ។ ចំណុចនេះអាចហៅបានថា "ការតំណាងដែលមានលក្ខណៈជារូបភាព ក្រោយការរលត់នៃសិទ្ធិតំណាង" ។ ការទទួលខុសត្រូវក្នុងការបញ្ជាក់ភាពសុចរិត និង គ្មានកំហុស មិនត្រូវធ្លាក់លើភាគីម្ខាងទៀតទេ គឺជាបន្ទុករបស់ម្ចាស់សិទ្ធិ ។ មានន័យថា ម្ចាស់សិទ្ធិដែលមានបំណងបដិសេធការទទួលខុសត្រូវចំពោះការតំណាងដែលមានលក្ខណៈជារូបភាព ត្រូវបញ្ជាក់ថា ភាគីម្ខាងទៀតបានដឹង ឬ មានកំហុសក្នុងការមិនបានដឹង ។

កថាខណ្ឌទី ៣ ចែងអំពីការការពារភាគីម្ខាងទៀតដែលបានទុកចិត្តម្ចាស់សិទ្ធិដែលបានបង្ហាញដូចជាខ្លួនបានប្រគល់សិទ្ធិតំណាងនេះទៅឱ្យអ្នកផ្សេង ឬ ធ្វើសកម្មភាពដែលឱ្យគេភាន់ច្រឡំថា អ្នកផ្សេងនោះជាអ្នកតំណាងរបស់ម្ចាស់សិទ្ធិ ទោះបីជាជាក់ស្តែង មិនដែលបានប្រគល់សិទ្ធិតំណាងក៏ដោយ ។ ចំណុចនេះអាចហៅបានថា "ការតំណាងដែលមានលក្ខណៈជារូបភាព ដោយបង្ហាញនូវការប្រគល់សិទ្ធិតំណាង" ។ ឧទាហរណ៍ បុគ្គលម្នាក់ (ម្ចាស់សិទ្ធិ) ដែលជាម្ចាស់ភោជនីយដ្ឋាន A អនុញ្ញាតឱ្យអតីតបុគ្គលិកដែលឯករាជ្យម្នាក់ បើកភោជនីយដ្ឋានដែលមានឈ្មោះ A ផងដែរ ។ ក្នុងករណីនេះ ទោះបីជាម្ចាស់សិទ្ធិមិនបានប្រគល់សិទ្ធិតំណាងក៏ដោយ ក៏សកម្មភាពនេះបង្ហាញដល់តតិយជនថា ម្ចាស់សិទ្ធិហាក់ដូចជាបានប្រគល់សិទ្ធិតំណាងឱ្យអតីតបុគ្គលិកគ្រប់គ្រងភោជនីយដ្ឋាន A ។ ហេតុដូច្នេះ ភាគីម្ខាងទៀតដែលលក់គ្រឿងម្ហូបទៅឱ្យអតីតបុគ្គលនោះ ដោយជឿជាក់ថា បុគ្គលនោះជាអ្នកតំណាងរបស់ម្ចាស់សិទ្ធិ អាចអះអាងអំពីអានុភាពនៃកិច្ចសន្យាចំពោះម្ចាស់សិទ្ធិបាន ។

ម្យ៉ាងវិញទៀត ម្ចាស់សិទ្ធិអាចរួចផុតពីការទទួលខុសត្រូវដែលបានកំណត់នៅក្នុងមាត្រានេះ ប្រសិនបើម្ចាស់សិទ្ធិនោះបញ្ជាក់ថា ភាគីម្ខាងទៀតបានដឹង ឬ មានកំហុសក្នុងការមិនបានដឹង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា១០៩ មាត្រា ១១០ និង មាត្រា ១១២ នៃក្រមរដ្ឋប្បវេណីជប៉ុន និងមាត្រា ៣.២០១ នៃគោលការណ៍ច្បាប់

**មាត្រា ៣៧៣.–** អំពើតំណាងដែលមិនបង្ហាញច្បាស់លាស់

១-ក្នុងករណីដែលអ្នកតំណាងមានឆន្ទៈក្នុងការធ្វើកិច្ចការសម្រាប់ម្ចាស់សិទ្ធិ តែបានធ្វើកិច្ចការនោះ ដោយមិនបង្ហាញថា ធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតអាចអះអាងថា កិច្ចសន្យាត្រូវបានបង្កើតឡើងជាមួយនឹងអ្នកតំណាងនោះបាន ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងនៅពេលបង្កើតកិច្ចសន្យាថា អ្នកតំណាងធ្វើកិច្ចសន្យានោះ សម្រាប់ម្ចាស់សិទ្ធិ ភាគីម្ខាងទៀតនោះអាចអះអាងអំពីការបង្កើតកិច្ចសន្យាតែជាមួយម្ចាស់សិទ្ធិប៉ុណ្ណោះ ។

២-ប្រសិនបើភាគីម្ខាងទៀតបែរជាដឹងអំពីអត្ថិភាពនៃម្ចាស់សិទ្ធិ ក្រោយពេលបង្កើតកិច្ចសន្យាជាមួយនឹងអ្នកតំណាងដែលបានធ្វើកិច្ចការ ដោយមិនបង្ហាញថា ធ្វើសម្រាប់ម្ចាស់សិទ្ធិទេ ភាគីម្ខាងទៀតនោះអាចអះអាងការបង្កើតកិច្ចសន្យា ជាមួយម្ចាស់សិទ្ធិបាន ។

(កំណត់)

ដើម្បីធ្វើឱ្យមានអានុភាពនៃសកម្មភាពដែលធ្វើដោយអ្នកតំណាង ចំពោះម្ចាស់សិទ្ធិ អ្នកតំណាងចាំបាច់បង្ហាញថា ខ្លួនធ្វើសកម្មភាពនោះសម្រាប់ម្ចាស់សិទ្ធិ (ការបញ្ជាក់ឈ្មោះ) (មាត្រា ៣៦៤) ។ ប៉ុន្តែ តើមានអ្វីកើតឡើងប្រសិនបើអ្នកតំណាងមិនបង្ហាញឈ្មោះម្ចាស់សិទ្ធិ ? មាត្រានេះចែងអំពីបញ្ហានេះ ។

ក្នុងករណីដែលអ្នកតំណាងខកខានក្នុងការបង្ហាញឈ្មោះម្ចាស់សិទ្ធិនៅពេលចុះកិច្ចសន្យាជាមួយភាគីម្ខាងទៀត ភាគីម្ខាងទៀតនោះ ប្រហែលជាជឿជាក់ថា អ្នកតំណាងគឺជាភាគីនៃកិច្ចសន្យា ។ ការជឿជាក់របស់ភាគីម្ខាងទៀតនេះ ត្រូវតែទទួលបាននូវការការពារ ។ ដូច្នេះ ភាគីម្ខាងទៀតអាចអះអាងថា កិច្ចសន្យាត្រូវបានបង្កើតឡើងជាមួយអ្នកតំណាង ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងទៀតបានដឹងថា ភាគីនៃកិច្ចសន្យាមិនមែនជាអ្នកតំណាងទេ គឺជាអ្នកផ្សេង (ម្ចាស់សិទ្ធិ) វាមិនត្រឹមត្រូវទេដែលធ្វើឱ្យកិច្ចសន្យាជាមួយអ្នកតំណាងមានអានុភាព ។ ក្នុងករណីនេះ កិច្ចសន្យាត្រូវបានបង្កើតឡើងរវាងម្ចាស់សិទ្ធិ និង ភាគីម្ខាងទៀត ។

ក្នុងករណីដែលភាគីម្ខាងទៀតជឿជាក់ពីដំបូងថា អ្នកតំណាងគឺជាភាគីនៃកិច្ចសន្យា ដោយសារអ្នកតំណាងមិនបានបង្ហាញឈ្មោះម្ចាស់សិទ្ធិនៅពេលចុះកិច្ចសន្យា ប៉ុន្តែ ក្រោយមក បានដឹងថា កិច្ចសន្យានោះបានចុះសម្រាប់ភាគីផ្សេងទៀតដែលជាម្ចាស់សិទ្ធិ ហើយមានឆន្ទៈទទួលយកកិច្ចសន្យានេះជាមួយម្ចាស់សិទ្ធិនោះ ភាគីម្ខាងទៀតនោះអាចអះអាងអំពីកិច្ចសន្យាជាមួយម្ចាស់សិទ្ធិបាន ។ ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចអះអាងអំពីការបង្កើតកិច្ចសន្យារបស់ខ្លួនបានទេ ។ (មាត្រាពាក់ព័ន្ធ)

មាត្រា ៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៣.២០៣ និង មាត្រា ៥០៤ នៃក្រមពាណិជ្ជកម្មជប៉ុន

**មាត្រា ៣៧៤.–** វិការៈនៃអំពើតំណាង

១-ក្នុងករណីដែលអានុភាពនៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈបង្កើត ត្រូវទទួលនូវឥទ្ធិពល ដោយសារមានការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ឬ ដោយសារមានកំហុសក្នុងការដឹង ឬ មិនដឹងហេតុណាមួយ អត្ថិភាព ឬ នត្ថិភាពនៃហេតុនោះ ត្រូវវិនិច្ឆ័យចំពោះអ្នកតំណាង ។

២-ក្នុងការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បើម្ចាស់សិទ្ធិបានប្រគល់ឱ្យអ្នកតំណាងធ្វើកិច្ចសន្យាដែលត្រូវបានកំណត់ពិសេស ម្ចាស់សិទ្ធិមិនអាចអះអាងថា អ្នកតំណាងមិនបានដឹងនូវហេតុណាដែលម្ចាស់សិទ្ធិដឹងនោះ បានឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះហេតុដែលម្ចាស់សិទ្ធិមិនបានដឹងដោយមានកំហុស ។

(កំណត់)

ក្នុងករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយអ្នកតំណាង បញ្ហាកើតឡើងថា តើត្រូវគិតពិចារណាអំពីវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាការភាន់ច្រឡំ ជាអាទិ៍ របស់អ្នកតំណាង ឬ ម្ចាស់សិទ្ធិ ។ មាត្រានេះចែងថា វិការៈនេះជាគោលការណ៍ ត្រូវវិនិច្ឆ័យចំពោះអ្នកតំណាង ។ អ្នកតំណាងជាអ្នកដែលបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យា ហេតុដូច្នេះស្ថានភាពដូចជាអត្ថិភាព ឬ នត្ថិភាពនៃការភាន់ច្រឡំ ជាអាទិ៍ ត្រូវគិតពិចារណាចំពោះអ្នកតំណាង ។

ប៉ុន្តែ ក្នុងករណីដែលម្ចាស់សិទ្ធិបានប្រគល់សិទ្ធិឱ្យអ្នកតំណាងធ្វើកិច្ចសន្យាជាក់លាក់ណាមួយ កាលៈទេសៈណាមួយដែលម្ចាស់សិទ្ធិដឹង ត្រូវចាត់ទុកថា អ្នកតំណាងក៏បានដឹងផងដែរ ។ ឧទាហរណ៍ ម្ចាស់សិទ្ធិបានទិញចលនវត្ថុតាមរយៈអ្នកតំណាង ពីភាគីម្ខាងទៀតដែលមិនមែនជាម្ចាស់កម្មសិទ្ធិ ក្នុងករណីដែលម្ចាស់សិទ្ធិបានដឹង ឬ អាចដឹងថា ភាគីម្ខាងទៀតមិនមែនជាម្ចាស់កម្មសិទ្ធិនៃចលនវត្ថុនោះ ម្ចាស់សិទ្ធិមិនអាចទាមទារនូវលទ្ធកម្មដោយសុចរិតបានឡើយ ទោះបីជាអ្នកតំណាងមិនបានដឹងដោយគ្មានកំហុសក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៧៥.–** សមត្ថភាពនៃអ្នកតំណាង

ម្ចាស់សិទ្ធិក៏អាចប្រគល់សិទ្ធិតំណាងដល់ជនដែលត្រូវបានកម្រិតសមត្ថភាពបានដែរ ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិមិនអាចលុបចោលនូវកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលជាជនដែលត្រូវបានកម្រិតសមត្ថភាព ជាមួយនឹងភាគីម្ខាងទៀត ដោយយកមូលហេតុនៃការកម្រិតសមត្ថភាពរបស់អ្នកតំណាងនោះ បានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីសមត្ថភាពក្នុងការធ្វើសកម្មភាពតំណាងដែលអ្នកតំណាងត្រូវបានទាមទារឱ្យមាន ។

ក្នុងករណីដែលម្ចាស់សិទ្ធិបានដឹងអំពីការកម្រិតសមត្ថភាព ហើយជ្រើសតាំងអ្នកតំណាងដែលជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ការប្រគល់សិទ្ធិតំណាងនេះមានសុពលភាព ។ ម្ចាស់សិទ្ធិមិនអាចលុបចោលកិច្ចសន្យាប្រគល់សិទ្ធិតំណាង ដោយយកការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាងមកជាមូលហេតុបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣៧៦.– អនុតំណាង

អ្នកតំណាងដោយកិច្ចសន្យាជាមួយនឹងម្ចាស់សិទ្ធិ មិនអាចជ្រើសតាំងអនុតំណាងបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានទទួលការយល់ព្រមពីម្ចាស់សិទ្ធិ ឬ មានហេតុដែលជៀសវាងមិនបាន។

(កំណត់)

មាត្រានេះចែងអំពីអនុតំណាងក្នុងករណីនៃការតំណាងដោយឆន្ទៈ ។ ក្នុងការតំណាងដោយឆន្ទៈ អ្នកតំណាងត្រូវបានជ្រើសតាំងដោយសារការជឿជាក់លើបុគ្គលិកលក្ខណៈ និង សមត្ថភាពរបស់គាត់ ហេតុដូច្នេះ ជាគោលការណ៍ អ្នកតំណាងនោះគួរតែធ្វើសកម្មភាពតំណាងដោយខ្លួនឯង ហើយមិនត្រូវប្រគល់សិទ្ធិឱ្យបុគ្គលផ្សេងទៀតឱ្យធ្វើសកម្មភាពតំណាងឡើយ ។ ចំណុចនេះហៅថា "ករណីយកិច្ចអនុវត្តដោយខ្លួនឯង" ។ ប៉ុន្តែ ជាធម្មតាទេដែលអនុញ្ញាតឱ្យអ្នកតំណាងធ្វើអាណត្តិឱ្យអនុតំណាងឱ្យបំពេញសកម្មភាពតំណាង ប្រសិនបើម្ចាស់សិទ្ធិយល់ព្រម ។ មានបញ្ហាមួយថា តើករណីលើកលែងផ្សេងពីនេះគួរតែត្រូវទទួលស្គាល់ ឬ មិនគួរទទួលស្គាល់ ។ មាត្រានេះចែងថា ទោះបីជាគ្មានការយល់ព្រមពីម្ចាស់សិទ្ធិក៏ដោយ អ្នកតំណាងនៅតែអាចជ្រើសតាំងអនុតំណាងបានដែរ "ប្រសិនបើមានហេតុដែលជៀសវាងមិនបាន" ។ តើមាន "ហេតុដែលជៀសវាងមិនបាន" ឬ គ្មាននោះ ត្រូវវិនិច្ឆ័យដោយពិចារណានូវកាលៈទេសៈជុំវិញផ្សេងៗ ដូចជា ខ្លឹមសារនៃ

សកម្មភាពដែលម្ចាស់សិទ្ធិប្រគល់សិទ្ធិឱ្យអ្នកតំណាងធ្វើ ភាពបន្ទាន់នៃសកម្មភាពនោះ និង ហេតុផលដែលអ្នកតំណាងមិនអាចធ្វើសកម្មភាពបាន ជាអាទិ៍ ។ ឧទាហរណ៍ ជម្ងឺរបស់អ្នកតំណាងជា "ហេតុដែលជៀសវាងមិនបាន" ប៉ុន្តែ ប្រសិនបើសកម្មភាពតំណាងនោះមិនមានភាពបន្ទាន់ទេ អ្នកតំណាងអាចរង់ចាំរហូតដល់ជាសះស្បើយពីជម្ងឺ ហើយហេតុនេះហើយការជ្រើសតាំងអនុតំណាងជាបន្ទាន់មិនត្រូវបានទទួលស្គាល់ទេក្នុងករណីនេះ ។ ប៉ុន្តែ ប្រសិនបើសកម្មភាពដែលអ្នកតំណាងត្រូវធ្វើ ជាសកម្មភាពងាយស្រួល ដូចជាការផ្ទេរប្រាក់នៅធនាគារ អ្នកតំណាងដែលឈឺនោះ អាចប្រគល់កិច្ចការនេះឱ្យអនុតំណាងបាន ។

ម្យ៉ាងទៀត បញ្ញត្តិនៃមាត្រានេះចែងអំពីការតំណាងដោយឆន្ទៈ មិនមែនការតំណាងដែលច្បាប់បានកំណត់ទេ។ ក្នុងករណីនៃការតំណាងដែលច្បាប់បានកំណត់ បញ្ញត្តិទាក់ទងនឹងការតំណាងដែលច្បាប់បានកំណត់នីមួយៗ ចែងអំពីលទ្ធភាពក្នុងការជ្រើសតាំងអនុតំណាង ដូច្នេះហើយមិនបានចែងនៅក្នុងមាត្រានេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៤ និង មាត្រា ១០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៣.២០៦

**មាត្រា ៣៧៧.–** ការទទួលខុសត្រូវរបស់អ្នកតំណាង ក្នុងករណីដែលបានជ្រើសតាំងអនុតំណាង

១-នៅពេលដែលអ្នកតំណាង បានជ្រើសតាំងអនុតំណាង តាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើ អ្នកតំណាងត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ត្រួតពិនិត្យអនុតំណាងនោះ ចំពោះម្ចាស់សិទ្ធិ ។

២-ក្នុងករណីដែលអ្នកតំណាងបានជ្រើសតាំងអនុតំណាង តាមការកំណត់របស់ម្ចាស់សិទ្ធិ អ្នកតំណាងមិនត្រូវទទួលខុសត្រូវនូវអំពើរបស់អនុតំណាងនោះ លើកលែងតែក្នុងករណីដែលអ្នកតំណាងបានដឹងអំពីភាពមិនសមស្រប ឬ ភាពមិនស្មោះត្រង់របស់អនុ-តំណាង តែមិនបានជូនដំណឹងអំពីភាពនោះទៅម្ចាស់សិទ្ធិ ឬ មិនបានដកអនុតំណាងចេញ ។

៣-ប្រសិនបើអ្នកតំណាងបានជ្រើសតាំងអនុតំណាង ដោយមិនធ្វើតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ មាត្រា ៣៧៦ (អនុតំណាង) ខាងលើទេ អំពើរបស់អនុតំណាងគ្មានអានុភាពទៅលើម្ចាស់សិទ្ធិឡើយ ។ ប៉ុន្តែ ភាគីម្ខាងទៀតដែលមិនបានដឹងថា អនុតំណាងនោះគ្មានសិទ្ធិទេ អាចអះអាងនូវការទទួលខុសត្រូវក្នុងការអនុវត្ត ឬ ក្នុងការសងការ

ខូចខាត ចំពោះអ្នកតំណាងបាន បើខ្លួនគ្មានកំហុសក្នុងការមិនបានដឹងនោះ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់អ្នកតំណាងដោយឆន្ទៈ ក្នុងករណីដែលអ្នកតំណាងដោយឆន្ទៈនោះជ្រើសតាំងអនុតំណាង ។

កថាខណ្ឌទី ១ ចែងអំពីទស្សនៈជាគោលការណ៍មូលដ្ឋាននៃមាត្រានេះ ។ ក្នុងករណីដែលម្ចាស់សិទ្ធិទទួលការខូចខាតដោយសារសកម្មភាពរបស់អនុតំណាង អ្នកតំណាងត្រូវទទួលខុសត្រូវចំពោះម្ចាស់សិទ្ធិក្នុងការជ្រើសតាំង និង ត្រួតពិនិត្យអនុតំណាងតែប៉ុណ្ណោះ ។ ការទទួលខុសត្រូវក្នុងការជ្រើសតាំង មានន័យថា អ្នកតំណាងត្រូវទទួលខុសត្រូវចំពោះម្ចាស់សិទ្ធិក្នុងការសងសំណងនៃការខូចខាត ប្រសិនបើការខូចខាតនោះកើតឡើងដោយសារអ្នកតំណាងបានជ្រើសតាំងអនុតំណាងមិនសមស្រប ។ ទោះបីជាអ្នកតំណាងមិនបានដឹងថា អនុតំណាងដែលខ្លួនបានជ្រើសតាំងមិនមានភាពសមរម្យក៏ដោយ ក៏អ្នកតំណាងនេះត្រូវទទួលខុសត្រូវដែរ ក្នុងករណីដែលអ្នកតំណាងគួរតែបានដឹងអំពីការណ៍នោះបើខ្លួនប្រុងប្រយ័ត្ន ។ ម្យ៉ាងទៀត អ្នកតំណាងត្រូវទទួលខុសត្រូវផងដែរ ប្រសិនបើការខូចខាតកើតឡើងចំពោះម្ចាស់សិទ្ធិដោយសារអ្នកតំណាងមិនបានត្រួតពិនិត្យអនុតំណាងដោយត្រឹមត្រូវ ។

ទំហំនៃការទទួលខុសត្រូវរបស់អ្នកតំណាងត្រូវបានកម្រិតដូចករណីដែលបានរៀបរាប់ខាងលើតែប៉ុណ្ណោះ ។ មានន័យថា អ្នកតំណាងមិនចាំបាច់ទទួលខុសត្រូវចំពោះការខូចខាតទាំងអស់ដែលបង្កដោយអនុតំណាងដែលមានកំហុសទេ ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលម្ចាស់សិទ្ធិកំណត់អនុតំណាង ។ ក្នុងករណីនេះ ជាគោលការណ៍ អ្នកតំណាងមិនត្រូវទទួលខុសត្រូវនូវសកម្មភាពរបស់អនុតំណាងទេ ។ ទំហំនៃការទទួលខុសត្រូវរបស់អ្នកតំណាង ត្រូវបានកម្រិតជាងករណីដែលបានចែងក្នុងកថាខណ្ឌទី ១ ។ ប៉ុន្តែ ទោះបីជាអ្នកតំណាងដឹងថា អនុតំណាងដែលត្រូវបានកំណត់ដោយម្ចាស់សិទ្ធិនោះមិនសមស្របធ្វើជាអនុតំណាងក៏ដោយ ប្រសិនបើអ្នកតំណាងខកខានក្នុងការជូនដំណឹងទៅម្ចាស់សិទ្ធិអំពីការណ៍នោះ ឬ មិនបានដកអនុតំណាងចេញ នោះអ្នកតំណាងត្រូវទទួលខុសត្រូវ ។

កថាខណ្ឌទី ៣ ចែងអំពីអានុភាពដែលកើតឡើងក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការជ្រើសតាំងអនុតំណាងមិនត្រូវបានបំពេញ ។ អ្នកតំណាងដែលត្រូវបានជ្រើសតាំងដោយកិច្ចសន្យា មិនអាចជ្រើសតាំងអនុតំណាងបានទេ លើកលែងតែម្ចាស់សិទ្ធិយល់ព្រម ឬ មានហេតុផលដែលមិនអាចជៀសវាងបាន ដូច្នេះ អនុតំណាងដែលត្រូវបានជ្រើសតាំងដោយអ្នកតំណាងដែលមិនបានបំពេញល័ក្ខខ័ណ្ឌនេះទេ មិនមានសិទ្ធិតំណាងឱ្យម្ចាស់សិទ្ធិបានឡើយ ។ ដូច្នេះ សកម្មភាពណាមួយដែលត្រូវបានធ្វើដោយអនុតំណាងបែបនេះ ក៏មិនមានអានុភាពចំពោះម្ចាស់សិទ្ធិដែរ ។ នេះគឺជាប្រភេទមួយនៃការតំណាងដោយគ្មានសិទ្ធិ ។ ប៉ុន្តែ ការការពារម្ចាស់សិទ្ធិក្នុងករណីនេះ អាចធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀតដែលជឿជាក់ថា អនុតំណាង ពិតជាមានសិទ្ធិតំណាងនោះ ហើយហេតុដូច្នេះហើយ មានបញ្ហាកើតឡើងទាក់ទងនឹងការការពារភាគីម្ខាងទៀត ក្នុងកាលៈទេសៈបែបនេះ ។ ចំពោះបញ្ហានេះ មានមធ្យោបាយពីរដើម្បីការពារភាគីម្ខាងទៀត ។ មធ្យោបាយទី

១ គឺអនុញ្ញាតឱ្យមានការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិចំពោះការតំណាងដែលមានលក្ខណៈជារូបភាព (មាត្រា ៣៧២) ក្នុងករណីដែលម្ចាស់សិទ្ធិស្ងៀមស្ងាត់ចំពោះសកម្មភាពរបស់អនុតំណាងដែលគ្មានសិទ្ធិតំណាង ។ ការទទួលខុសត្រូវរបស់ម្ចាស់សិទ្ធិចំពោះការតំណាងដែលមានលក្ខណៈជារូបភាព ត្រូវបានដោះស្រាយដោយអនុលោមតាមមាត្រា ៣៧២ ។ មធ្យោបាយមួយទៀតគឺអនុញ្ញាតឱ្យមានការទទួលខុសត្រូវរបស់អ្នកតំណាងដែលមានចែងក្នុងមាត្រា ៣៧១ ដោយចាត់ទុកសកម្មភាពនៃការតំណាងដោយគ្មានសិទ្ធិរបស់អនុតំណាងថា ជាសកម្មភាពនៃតំណាងដោយគ្មានសិទ្ធិរបស់អ្នកតំណាង ។ ប៉ុន្តែ បើនិយាយឱ្យដាច់ខាតទៅ ពីព្រោះវាជាសកម្មភាពដែលធ្វើដោយអនុតំណាងដែលគ្មានសិទ្ធិតំណាង ផ្អែកតាមមាត្រា ៣៧១ មានតែអនុតំណាងប៉ុណ្ណោះដែលត្រូវទទួលខុសត្រូវ ។ ទោះបីជាយ៉ាងនេះក៏ដោយ ពីព្រោះបញ្ហានោះបានកើតឡើងដោយសារអ្នកតំណាងបានជ្រើសតាំងអនុតំណាង ទោះបីជាខ្លួនមិនអាចជ្រើសតាំងក៏ដោយ ហេតុដូច្នេះ អ្នកតំណាងត្រូវទទួលខុសត្រូវ ជំនួសអនុតំណាង ។ ហេតុនេះហើយ កថាខណ្ឌទី ៣ នៃមាត្រានេះចែងថា ភាគីម្ខាងទៀតអាចទាមទារឱ្យមានការទទួលខុសត្រូវពីអ្នកតំណាងបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣៧៨.– ឋានៈនៃអនុតំណាង

១-អំពើដែលអនុតំណាងបានធ្វើក្នុងទំហំនៃសិទ្ធិរបស់ខ្លួន ដោយបញ្ជាក់ថាធ្វើសម្រាប់ម្ចាស់សិទ្ធិ ត្រូវជាចំណងចងម្ចាស់សិទ្ធិ ។

២-អនុតំណាងត្រូវមានសិទ្ធិ និង ករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ដូចអ្នកតំណាង ។

៣-បញ្ញត្តិនៃផ្នែកទី ៤ នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អនុតំណាង ដោយចាត់ទុកថា អនុតំណាងជាអ្នកតំណាង ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងរវាងអនុតំណាង និង ម្ចាស់សិទ្ធិ ។

កថាខណ្ឌទី ១ ចែងថា សកម្មភាពដែលអនុតំណាងបានធ្វើក្នុងទំហំនៃសិទ្ធិរបស់ខ្លួន ត្រូវមានអានុភាពចងម្ចាស់សិទ្ធិ ។ សិទ្ធិតំណាងរបស់អនុតំណាង គឺជាសិទ្ធិតំណាងឱ្យម្ចាស់សិទ្ធិ ដូច្នេះ វាជាធម្មតាទេដែលសកម្មភាពដែលធ្វើដោយអនុ-តំណាងនេះ មានអានុភាពចំពោះម្ចាស់សិទ្ធិ និង ចងម្ចាស់សិទ្ធិ ។ ប្រសិនបើអនុតំណាងត្រូវបានជ្រើសតាំងត្រឹមត្រូវដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៧៦ បានធ្វើសកម្មភាពក្រៅទំហំនៃសិទ្ធិរបស់ខ្លួន ករណីនេះចាត់ទុកថាជាការតំណាងដោយគ្មានសិទ្ធិ ហើយម្ចាស់សិទ្ធិទទួលខុសត្រូវនូវតំណាងដែលមានលក្ខណៈជារូបភាព ប្រសិនបើល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៧២ ត្រូវបានបំពេញ ។

កថាខណ្ឌទី ២ ចែងអំពីទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ចរវាងម្ចាស់សិទ្ធិ និង អនុតំណាង ។ អនុតំណាងមានទំនាក់ទំនងកិច្ចសន្យាអាណត្តិជាមួយនឹងអ្នកតំណាង ហើយក្នុងនេះ អនុតំណាងជាអាណត្តិគាហក និង អ្នកតំណាងជាអាណត្តិទាយក ។ ចំណែកឯអនុតំណាង និង ម្ចាស់សិទ្ធិវិញ គ្មានទំនាក់ទំនងកិច្ចសន្យាដោយផ្ទាល់ទេ ។ ប៉ុន្តែប្រសិនបើអនុតំណាងមានវត្ថុដែលទទួលបានពីភាគីម្ខាងទៀតតាមរយៈសកម្មភាពនៃការតំណាង វាត្រឹមត្រូវសម្រាប់ឱ្យអនុតំណាងមានករណីយកិច្ចដោយផ្ទាល់ចំពោះម្ចាស់សិទ្ធិក្នុងការប្រគល់វត្ថុនោះ ពីព្រោះអនុតំណាងអនុវត្តសិទ្ធិតំណាងសម្រាប់ម្ចាស់សិទ្ធិ ។ ស្របពេលដំណាលគ្នានេះដែរ អនុតំណាងអាចទាមទារសោហ៊ុយដែលកើតពីសកម្មភាពនៃការតំណាង ហើយវាត្រឹមត្រូវដែលឱ្យអនុតំណាងមានសិទ្ធិទាមទារនេះមិនត្រឹមតែពីអ្នកតំណាងដែលជ្រើសតាំងអនុតំណាងប៉ុណ្ណោះទេ ថែមទាំងពីម្ចាស់សិទ្ធិផងដែរ ដោយហេតុផលថា ម្ចាស់សិទ្ធិគឺជាអ្នកដែលទទួលផលប្រយោជន៍ពីសកម្មភាពរបស់អនុតំណាង ដូច្នេះ ម្ចាស់សិទ្ធិត្រូវទទួលខុសត្រូវបន្ទុកនូវសោហ៊ុយសម្រាប់សកម្មភាពតំណាងនោះ ។ ដោយពិចារណាលើចំណុចនេះហើយ កថាខណ្ឌនេះចែងថា ទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ច ត្រូវកើតឡើងដោយផ្ទាល់រវាងអនុតំណាង និង ម្ចាស់សិទ្ធិ ។ ប៉ុន្តែ អនុតំណាងមិនគ្រាន់តែមានទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ចដោយផ្ទាល់ ជាមួយម្ចាស់សិទ្ធិដោយយោងតាមមាត្រានេះប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានទំនាក់ទំនងនៃអាណត្តិជាមួយអ្នកតំណាងផងដែរ ហេតុដូច្នេះជួនកាល បង្កើតឱ្យមានបញ្ហា ។ ឧទាហរណ៍ ក្នុងករណីដែលអនុតំណាងទទួលបានពីភាគីម្ខាងទៀតនូវវត្ថុដែលត្រូវប្រគល់ឱ្យម្ចាស់សិទ្ធិ តើអនុតំណាងត្រូវចាត់ចែងវត្ថុដែលខ្លួនបានទទួលនោះដូចម្តេច ? ដោយហេតុថា អនុតំណាងមានទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ចចំពោះអ្នកតំណាងផង និង ម្ចាស់សិទ្ធិផង អនុតំណាងនេះមានករណីយកិច្ចត្រូវប្រគល់វត្ថុទៅឱ្យអ្នកទាំងពីរ ។ ក្នុងករណីនេះ អនុតំណាងបានបំពេញករណីយកិច្ចរបស់ខ្លួន ដោយការប្រគល់វត្ថុនោះ ទៅឱ្យម្ចាស់សិទ្ធិ ឬ អ្នកតំណាង ហេតុនេះហើយ វាមិនមែនជាការបំពានករណីយកិច្ចទេ ទោះបីជាមិនបានប្រគល់វត្ថុទៅឱ្យអ្នកម្ខាងទៀតក៏ដោយ ។

បន្ថែមពីលើនេះ ពីព្រោះតែទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អនុតំណាង មានលក្ខណៈដូចជាទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អ្នកតំណាងដែរនោះ កថាខណ្ឌទី ៣ នៃមាត្រានេះចែងថា បញ្ញត្តិស្តីពីការតំណាងត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងអនុតំណាង និង ម្ចាស់សិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៥ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន

**មាត្រា ៣៧៩.–** និយមន័យ

១-ភាគីនៃកិច្ចសន្យា អាចឱ្យតតិយជនទទួលសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា

នោះបាន ។ ក្នុងករណីនេះ អ្នកដែលត្រូវផ្តល់តាវកាលិកទៅតតិយជននោះ ហៅថា "អ្នកព្រមផ្តល់" ។ រីឯភាគីម្ខាងទៀតរបស់អ្នកព្រមផ្តល់នោះ ហៅថា "អ្នកទាមទារការផ្តល់" ។ម្យ៉ាងទៀត តតិយជនដែលនឹងទទួលតាវកាលិក ហៅថា "អ្នកទទួលផលប្រយោជន៍" ។

២-អ្នកទទួលផលប្រយោជន៍ អាចទាមទារអ្នកព្រមផ្តល់ឱ្យផ្តល់តាវកាលិកដោយចំពោះបាន ។

(កំណត់)

មាត្រានេះចែងអំពី "កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន (contract for the benefit of a third party)" ។

ជាគោលការណ៍ អានុភាពនៃកិច្ចសន្យាចងតែភាគីប៉ុណ្ណោះ ហើយមិនប៉ះពាល់ចំពោះតតិយជនទេ ។ ប៉ុន្តែ ភាគីមានលទ្ធភាពផ្តល់សិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដល់តតិយជនបាន ដោយសារជាធម្មតា វាមិនធ្វើឱ្យខូចប្រយោជន៍ដល់តតិយជនឡើយ ។ ក្នុងករណីនេះ តើតតិយជននឹងធ្វើលទ្ធកម្មនូវសិទ្ធិដោយស្វ័យប្រវត្តិ ឬ ដោយការបង្ហាញឆន្ទៈអំពីការទទួលផលប្រយោជន៍ (ការយល់ព្រម) របស់តតិយជន គឺជាបញ្ហាសំខាន់ ហើយត្រូវតែកំណត់ជាមុននៅក្នុងច្បាប់ ។ តាមទិន្នាការជាច្រើនក្នុងនីតិកម្មនៃបណ្តាប្រទេសនានា បញ្ញត្តិចាប់ពីមាត្រានេះ បានអនុម័តយកជំហរមួយថា តតិយជនមិនត្រូវបានតម្រូវឱ្យបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ ដើម្បីធ្វើលទ្ធកម្មលើសិទ្ធិទេ ។ ប៉ុន្តែ អ្នកទាមទារការផ្តល់អាចដកការសន្យាផ្តល់សិទ្ធិឱ្យទៅតតិយជនបាន រហូតដល់តតិយជនបង្ហាញឆន្ទៈទទួលយកផលប្រយោជន៍នោះ (មាត្រា ៣៨១) ។

កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនមានតួនាទីសំខាន់នៅក្នុងសង្គម ។ ឧទាហរណ៍ ក្នុងករណីកិច្ចសន្យាលក់ទិញរវាងភាគី A និង B ប្រសិនបើអ្នកលក់ A ផ្តល់សិទ្ធិលើបំណុលចំពោះថ្លៃលក់ដែល A ទទួលដោយកិច្ចសន្យាលក់ទិញនោះឱ្យទៅតតិយជន C កិច្ចសន្យានេះគឺជាឧទាហរណ៍ចម្បងនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ។ កិច្ចសន្យានេះត្រូវបានបង្កើតឡើងដោយមានគោលបំណងផ្សេងៗ ដូចជាករណីដែលភាគី A ធ្វើប្រទានកម្មឱ្យតតិយជន C ឬករណីដែល A មានបំណុលចំពោះ C ហើយមានបំណងទូទាត់បំណុលដោយផ្តល់សិទ្ធិលើបំណុលចំពោះថ្លៃលក់ឱ្យទៅ C ដើម្បីសងបំណុលនោះ ជាអាទិ៍ ។ កិច្ចសន្យាបែបនេះ មានភាពសាមញ្ញ និង ប្រសិទ្ធភាព ដោយសារថ្លៃលក់ត្រូវបានប្រគល់ពី B ទៅ C ដោយផ្ទាល់ ជំនួសវិធីដែល A ទទួលថ្លៃលក់ពី B សិន ហើយបន្ទាប់មក ប្រគល់ថ្លៃលក់នោះឱ្យទៅ C ។ ឧទាហរណ៍មួយទៀតនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន គឺកិច្ចសន្យាធានារ៉ាប់រងដែលភាគី D បានធ្វើជាមួយក្រុមហ៊ុនធានារ៉ាប់រង E ហើយផ្តល់ឱ្យតតិយជន F នូវសិទ្ធិទាមទារប្រាក់ធានារ៉ាប់រង ។ ក្នុងករណីទាំងនេះ វាមិនត្រឹមត្រូវទេដែលមិនផ្ទុកផ្ដាក់សិទ្ធិនេះទៅឱ្យតតិយជន ទាល់តែតតិយជននេះបង្ហាញឆន្ទៈអំពីការទទួលប្រយោជន៍ ។ ផ្ទុយទៅវិញ នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ជាអាទិ៍ នៅក្នុងប្រទេសជាច្រើន គឺគេផ្តល់ឱ្យតតិយជននូវសិទ្ធិទាមទារប្រាក់ធានារ៉ាប់រង

ស្របគ្នានឹងពេលដែលកិច្ចសន្យាធានារ៉ាប់រងត្រូវបានបង្កើតឡើង ។

នៅក្នុងកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន តតិយជនមិនត្រូវធ្វើលទ្ធកម្មនូវឋានៈជាភាគីនៃកិច្ចសន្យាទេ ។ តតិយជននេះគ្រាន់តែធ្វើលទ្ធកម្មនូវសិទ្ធិដែលកើតឡើងពីកិច្ចសន្យាប៉ុណ្ណោះ ។ ហេតុដូច្នេះហើយ ក្នុងករណីខាងលើដែល C ធ្វើលទ្ធកម្មនូវសិទ្ធិទាមទារថ្លៃលក់ដែលកើតឡើងពីកិច្ចសន្យាលក់ទិញរវាង A និង B តាមកិច្ចសន្យានេះ C មិនត្រូវទទួលបន្តនូវឋានៈជាភាគីនៃកិច្ចសន្យា (អ្នកលក់) ទេ ហេតុដូច្នេះ តតិយជន C គ្មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញចំពោះអ្នកទិញ និង ក៏គ្មានការទទួលខុសត្រូវចំពោះវិការៈនៃវត្ថុនោះដែរ ទោះបីជាមានវិការៈក៏ដោយ។ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ត្រូវបែងចែកឱ្យដាច់ពីការទទួលបន្តនូវឋានៈជាអ្នកលក់ (ការទទួលបន្តនូវឋានៈក្នុងកិច្ចសន្យា) ។

ម្យ៉ាងទៀត កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ក៏ខុសពីអនុប្បទានសិទ្ធិលើបំណុលចំពោះថ្លៃលក់ដែលអ្នកលក់ A ធ្វើលទ្ធកម្មឱ្យទៅ C ផងដែរ ។ ក្នុងករណីនៃអនុប្បទានសិទ្ធិលើបំណុល ជាដំបូង A ធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលចំពោះថ្លៃលក់ តាមកិច្ចសន្យារវាងភាគី A និង B ប៉ុន្តែ ក្នុងករណីនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនវិញ សិទ្ធិលើបំណុលចំពោះថ្លៃលក់ត្រូវធ្លាក់ទៅ C តាំងពីដើមដំបូងនៅពេលកិច្ចសន្យារវាងភាគី A និង B ត្រូវបានបង្កើតឡើង ។ ភាពខុសគ្នារវាងករណីទាំងពីរនេះ លេចឡើងនៅពេលដែលម្ចាស់បំណុលរបស់ A មានបំណងរឹបអូសសិទ្ធិលើបំណុលចំពោះថ្លៃលក់ ។ ក្នុងករណីនៃអនុប្បទានសិទ្ធិលើបំណុល ប្រសិនបើម្ចាស់បំណុលរបស់ A រឹបអូសសិទ្ធិលើបំណុលចំពោះថ្លៃលក់ មុនពេលដែល A ធ្វើអនុប្បទានសិទ្ធិលើបំណុលនោះទៅឱ្យតតិយជន ម្ចាស់បំណុលរបស់ A អាចប្រមូលថ្លៃលក់ពី B បាន ។ ប៉ុន្តែ ក្នុងករណីនៃកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនវិញ ដោយសារសិទ្ធិលើបំណុលចំពោះថ្លៃលក់ក្លាយជារបស់ C ដោយផ្ទាល់ ម្ចាស់បំណុលរបស់ A មិនអាចរឹបអូសសិទ្ធិលើបំណុលនេះបានទេ ។ ប្រសិនបើ A មានបំណងធ្វើឱ្យតតិយជន C ទទួលសិទ្ធិណាមួយ វាមានសុវត្ថិភាពជាងដែលត្រូវធ្វើកិច្ចសន្យាសម្រាប់តតិយជន។ ប៉ុន្តែ ប្រសិនបើអ្នកទាមទារការផ្តល់គ្មានធនធានហិរញ្ញវត្ថុទេ សកម្មភាពនៃការផ្តល់សិទ្ធិទៅតតិយជននេះ អាចចាត់ទុកថាជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១២១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣២៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៤៤៤ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៦.១១០

## មាត្រា ៣៨០.- អ្នកទទួលផលប្រយោជន៍

នៅពេលធ្វើការសន្យា មិនចាំបាច់មានអត្ថិភាពអ្នកទទួលផលប្រយោជន៍ឡើយ ប្រសិនបើលក្ខខណ្ឌដើម្បីកំណត់អ្នកទទួលផលប្រយោជន៍នោះ មានភាពច្បាស់លាស់ ។

ប៉ុន្តែ ក្នុងករណីដែលគ្មានអ្នកទទួលផលប្រយោជន៍ នៅពេលដែលអ្នកព្រមផ្តល់ត្រូវផ្តល់តាវកាលិក នោះការសន្យាដែលត្រូវផ្តល់តាវកាលិកឱ្យតតិយជន ត្រូវបាត់បង់អានុភាព ហើយអ្នកព្រមផ្តល់ អាចរួចផុតពីការទទួលខុសត្រូវបាន ដោយអនុវត្តចំពោះអ្នកទាមទារការផ្តល់ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌទាក់ទងនឹងអ្នកទទួលផលប្រយោជន៍ ។

ចំពោះកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន តើតតិយជនត្រូវមានអត្ថិភាពនៅពេលណា ? ប្រសិនបើសិទ្ធិរបស់តតិយជននេះកើតឡើងព្រមជាមួយពេលដែលកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជននោះត្រូវបានបង្កើតឡើង វាហាក់ដូចជាចម្លែកដែលគ្មានអ្នកទទួលផលប្រយោជន៍នៅពេលនោះ ប៉ុន្តែ គ្មានការខូចប្រយោជន៍ទេ ទោះបីជាគ្មានអ្នកទទួលផលប្រយោជន៍នៅពេលបង្កើតកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនក៏ដោយ ។ ម្យ៉ាងទៀត តាមទស្សនាទាននៃកិច្ចការជាក់ស្តែង ក៏គួរតែមានលទ្ធភាពកំណត់កូនដែលមិនទាន់កើតថាជាអ្នកទទួលផលប្រយោជន៍ ហើយផ្តល់សិទ្ធិឱ្យកូននោះដែរ ។ ក្នុងករណីនេះ កិច្ចសន្យាដែលធ្វើឱ្យតតិយជនទទួលផលប្រយោជន៍ នឹងត្រូវមានអានុភាព ដោយយកអត្ថិភាពរបស់តតិយជននាពេលអនាគតមកធ្វើជាល័ក្ខខ័ណ្ឌ ។ ហេតុដូច្នេះហើយ នៅពេលធ្វើកិច្ចសន្យា មិនចាំបាច់មានអត្ថិភាពនៃអ្នកទទួលប្រយោជន៍ឡើយ ប៉ុន្តែ ល័ក្ខខ័ណ្ឌដើម្បីកំណត់អ្នកទទួលផលប្រយោជន៍ ចាំបាច់ត្រូវមានអត្ថិភាពនៅពេលធ្វើកិច្ចសន្យា ។ ម្យ៉ាងទៀត អ្នកទទួលផលប្រយោជន៍អាចមានច្រើននាក់ ក៏បានដែរ ។ ប្រសិនបើអ្នកទទួលផលប្រយោជន៍ច្រើននាក់ត្រូវបានកំណត់ជាតតិយជន សិទ្ធិត្រូវផ្តល់ឱ្យតតិយជនទាំងអស់គ្នា ។

ប្រសិនបើគ្មានតតិយជននៅពេលអនុវត្តកិច្ចសន្យាទេ កូនបំណុលដែលសន្យាផ្តល់តាវកាលិក (អ្នកព្រមផ្តល់) នឹងមានបញ្ហា ពីព្រោះអ្នកព្រមផ្តល់នេះគ្មានអ្នកណាម្នាក់ត្រូវអនុវត្តកាតព្វកិច្ច ដូច្នេះ ចាំបាច់ត្រូវធានាផលប្រយោជន៍របស់កូនបំណុលក្នុងការរួចផុតពីកាតព្វកិច្ចដោយការអនុវត្ត ។ គេអាចពិចារណាផងដែរថា កូនបំណុលអាចរួចផុតពីកាតព្វកិច្ចតាមរយៈការតម្កល់ ប៉ុន្តែ វាមិនត្រឹមត្រូវទេដែលអនុញ្ញាតឱ្យតម្កល់ ពីព្រោះអវត្តមាននៃម្ចាស់បំណុលក្នុងករណីនេះគឺហួសពីទំហំនៃគោលបំណងនៃប្រព័ន្ធតម្កល់ ។ ដូច្នេះ ដោយការពិចារណាលើចំណុចនេះ មាត្រានេះកំណត់ថា អ្នកព្រមផ្តល់អាចរួចផុតពីកាតព្វកិច្ច ដោយអនុវត្តកិច្ចសន្យាចំពោះអ្នកទាមទារការផ្តល់ ។

តើត្រូវដោះស្រាយបែបណាចំពោះស្ថានភាពដែលអ្នកទទួលផលប្រយោជន៍គ្មានអត្ថិភាព ប៉ុន្តែ អាចកំណត់បាននៅពេលអនុវត្តកិច្ចសន្យា ? ឧទាហរណ៍ ភាគី A ធ្វើកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនជាមួយភាគី B ដែលមានខ្លឹមសារថា ផ្តល់សិទ្ធិលើបំណុលចំពោះថ្លៃលក់ឱ្យ "កូនរបស់ A" ហើយកូនរបស់ A នោះមិនទាន់ចាប់កំណើត នៅពេលអនុវត្តកិច្ចសន្យា ប៉ុន្តែ មានភាពច្បាស់លាស់ថា នឹងកើតមកនៅពេល ៣ ឬ ៤ ខែ ក្រោយមក ។ នៅប្រទេសជប៉ុន និងប្រទេសផ្សេងទៀតដែលមានប្រព័ន្ធ "trust" ផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ដែលមិនទាន់មានវត្តមាននៅ

ឡើយ ប៉ុន្តែ ត្រូវបានកំណត់ថានឹងមានវត្តមាន ត្រូវបានការពារ ។ ប៉ុន្តែ មានបញ្ហាថា តាមរយៈប្រព័ន្ធកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន តើអ្នកទទួលផលប្រយោជន៍ដែលមិនទាន់មានអត្ថិភាព គួរត្រូវបានការពារដល់កម្រិតនេះដែរឬទេ ។ កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន មិនមែនជាប្រព័ន្ធដែលតម្រូវឱ្យអ្នកព្រមផ្តល់ គ្រប់គ្រងទ្រព្យសម្បត្តិក្នុងអំឡុងពេលវែង សម្រាប់អ្នកទទួលផលប្រយោជន៍ដែលទំនងជាមានវត្តមាននៅពេលអនាគតទេ ហេតុដូច្នេះ វាជាការត្រឹមត្រូវដែលអនុញ្ញាតឱ្យអ្នកព្រមផ្តល់រួចផុតពីការណីយកិច្ចនៃកូនបំណុល ប្រសិនបើអនុវត្តកិច្ចសន្យាចំពោះអ្នកទាមទារការផ្តល់ ក្នុងករណីដែលអ្នកទទួលផលប្រយោជន៍គ្មានអត្ថិភាពនៅពេលអនុវត្ត ។ ចំពោះគោលបំណងនៃការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់តតិយជនក្នុងរយៈពេលវែង ប្រព័ន្ធច្បាប់ស្តីពី "trust system" គួរតែត្រូវបានបង្កើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៤៥ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៣៨១.–** ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍

១-ក្នុងអំឡុងពេលដែលអ្នកទទួលផលប្រយោជន៍មិនទាន់បង្ហាញឆន្ទៈទទួលផលប្រយោជន៍ ចំពោះអ្នកព្រមផ្តល់ ឬ អ្នកទាមទារការផ្តល់ អ្នកទាមទារការផ្តល់អាចដកការសន្យាផ្តល់សិទ្ធិឱ្យទៅអ្នកទទួលផលប្រយោជន៍នោះ នៅពេលណាក៏បានដែរ ដោយជូនដំណឹងទៅអ្នកព្រមផ្តល់ និង អ្នកទទួលផលប្រយោជន៍នោះ ។

២-ក្រោយពីអ្នកទទួលផលប្រយោជន៍បានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ ភាគីនៃកិច្ចសន្យាមិនអាចប្តូរ ឬ រំលត់នូវសិទ្ធិរបស់អ្នកទទួលផលប្រយោជន៍នេះបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យនៃការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ ។

ក្នុងករណីដែលកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនត្រូវបានបង្កើតឡើង ទោះបីជាតតិយជននោះមិនបង្ហាញឆន្ទៈ ក្នុងការទទួលផលប្រយោជន៍ក៏ដោយ ក៏សិទ្ធិត្រូវបានផ្តល់ទៅឱ្យតតិយជនដោយស្វ័យប្រវត្តិដែរ ប៉ុន្តែ អ្នកទាមទារការផ្តល់ ដែលបានផ្តល់សិទ្ធិឱ្យតតិយជន អាចដកការសន្យាផ្តល់សិទ្ធិនោះបាន នៅគ្រប់ពេលវេលាមុនពេលដែលអ្នកទទួលផលប្រយោជន៍បង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ ។ មានន័យថា អ្នកទាមទារការផ្តល់អាចដកផ្នែកនៃការព្រមព្រៀង "ដែលសិទ្ធិរបស់ភាគី A ត្រូវបានផ្តល់ឱ្យតតិយជន C" បាន ។ គោលបំណងនេះគឺដើម្បីធ្វើឱ្យមានតុល្យភាពនៃផលប្រយោជន៍រវាងអ្នកទាមទារការផ្តល់ និង អ្នកទទួលផលប្រយោជន៍ ។ សកម្មភាពរបស់អ្នកទាមទារការផ្តល់ដែលផ្តល់សិទ្ធិរបស់ខ្លួនទៅអ្នកទទួលផលប្រយោជន៍ គឺជាសកម្មភាពឥតគិតកម្រៃថ្នូរ ហើយជាធម្មតា ចំពោះសកម្មភាពឥតគិតកម្រៃថ្នូរ មានអានុភាពចងនៃកិច្ចសន្យាមិនខ្លាំងទេ ។ បន្ថែមពីនេះទៀត កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន គឺជា

កិច្ចសន្យារវាងអ្នកទាមទារការផ្តល់ និង អ្នកព្រមផ្តល់ មិនមែនជាកិច្ចសន្យារវាងអ្នកទាមទារការផ្តល់ និង អ្នកទទួលផលប្រយោជន៍ទេ ។ ហេតុដូច្នេះ វាត្រឹមត្រូវដែលអនុញ្ញាតឱ្យអ្នកទាមទារការផ្តល់ ដកការព្រមព្រៀងដែលផ្តល់សិទ្ធិឱ្យអ្នកទទួលផលប្រយោជន៍ ដូចជាក្នុងករណីនៃកិច្ចសន្យាប្រទានកម្មដែលមិនទាន់បានអនុវត្ត ។ ការចាត់ចែងបែបនេះត្រូវបានចែងដូចគ្នាផងដែរ នៅក្នុងប្រព័ន្ធច្បាប់នៃប្រទេសជាច្រើនដែលមានកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ។

ក្រោយពេលអ្នកទទួលផលប្រយោជន៍បានបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ហើយ ការព្រមព្រៀងដែលផ្តល់សិទ្ធិឱ្យទៅតតិយជន មិនអាចដកទេ ហើយខ្លឹមសារនៃសិទ្ធិក៏មិនអាចកែប្រែបានដែរ ។ ប៉ុន្តែ អ្នកព្រមផ្តល់អាចរំលាយកិច្ចសន្យាដោយហេតុនៃការមិនអនុវត្តរបស់អ្នកទាមទារការផ្តល់បាន (មាត្រា ៣៨២) ។ ចំណុចនេះគឺជាបញ្ហាផ្សេងពីលទ្ធភាពក្នុងការដកការព្រមព្រៀង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៤៦ នៃក្រមរដ្ឋប្បវេណីកេបិច និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៦.១១០

## មាត្រា ៣៨២.- ការតវ៉ារបស់អ្នកព្រមផ្តល់

អ្នកព្រមផ្តល់អាចអះអាងការតវ៉ាដែលកើតមកពីកិច្ចសន្យា ចំពោះអ្នកទទួលផលប្រយោជន៍បាន ។

(កំណត់)

មាត្រានេះចែងថា អ្នកព្រមផ្តល់អាចអះអាងអំពីការតវ៉ាដែលកើតឡើងពីកិច្ចសន្យារវាងអ្នកទាមទារការផ្តល់ និង អ្នកព្រមផ្តល់ ចំពោះអ្នកទទួលផលប្រយោជន៍បាន ។

ឧទាហរណ៍ ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះថ្លៃលក់របស់ A ក្នុងកិច្ចសន្យាលក់ទិញរវាង A និង B ត្រូវបានផ្តល់ឱ្យទៅតតិយជន C តាមកិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ប្រសិនបើអ្នកលក់ A បានប្រគល់វត្ថុដែលជាកម្មវត្ថុមានវិការៈ ឬ មានការមិនអនុវត្តកាតព្វកិច្ចប្រភេទផ្សេងទៀត អ្នកទិញ B ត្រូវបានអនុញ្ញាតឱ្យអះអាងអំពីការរំលាយកិច្ចសន្យាលក់ទិញ ឬ ទាមទារការសង្គ្រោះផ្សេងទៀត ។ ម្យ៉ាងទៀត ប្រសិនបើអ្នកលក់ A មានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច អ្នកទិញ B ត្រូវបានអនុញ្ញាតឱ្យបដិសេធបង់ថ្លៃលក់ ដោយអនុវត្តសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ។ ការតវ៉ា ឬ ការអះអាងដោយអ្នកទិញ B ត្រូវបានអនុញ្ញាតឱ្យ C ផងដែរ ប្រសិនបើសិទ្ធិត្រូវបានផ្តល់ឱ្យ C ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៥០ នៃក្រមរដ្ឋប្បវេណីកេបិច

## មាត្រា ៣៨៣.- មោឃភាព ការលុបចោល និង ការរំលាយកិច្ចសន្យា

១-ក្នុងករណីដែលកិច្ចសន្យាមានមូលហេតុនៃមោឃភាព ឬ ការលុបចោល រវាងអ្នកទាមទារការផ្តល់ និង អ្នកព្រមផ្តល់ ភាគីនៃកិច្ចសន្យាអាចអះអាងនូវមោឃភាពនៃកិច្ចសន្យា ឬ ការលុបចោលកិច្ចសន្យានោះបាន តាមបញ្ញត្តិស្តីពីមោឃភាព និង ការលុបចោល ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នៃជំពូកទី ២ ទោះបីជាមានការសន្យាផ្តល់សិទ្ធិដល់តតិយជនក៏ដោយ ។

២-អ្នកព្រមផ្តល់អាចរំលាយកិច្ចសន្យា ដោយយកមូលហេតុនៃការបំពានកិច្ចសន្យារបស់អ្នកទាមទារការផ្តល់បាន ។ ក្នុងករណីដែលយកការបំពានកិច្ចសន្យារបស់អ្នកព្រមផ្តល់មកជាមូលហេតុនៃការរំលាយ បើមានអ្នកទទួលប្រយោជន៍ដែលបានបង្ហាញឆន្ទៈទទួលផលប្រយោជន៍ អ្នកទាមទារការផ្តល់អាចរំលាយកិច្ចសន្យា ដោយទទួលការយល់ព្រមពីតតិយជននោះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពចំពោះសិទ្ធិរបស់តតិយជនដោយការរលត់កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជនរវាងអ្នកទាមទារការផ្តល់ និង អ្នកព្រមផ្តល់ ។ បញ្ហានេះក៏ជាបញ្ហានៃការតវ៉ាដែលបានចែងក្នុងមាត្រា ៣៨២ ខាងលើដែរ ប៉ុន្តែក្នុងចំណោមការតវ៉ាផ្សេងៗ បញ្ហានេះមានសារៈសំខាន់យ៉ាងខ្លាំង ដូច្នេះត្រូវបានចែងដាច់ដោយឡែកនៅក្នុងមាត្រានេះ ។ម្យ៉ាងទៀត បញ្ហាទាក់ទងនឹងការរលត់នៃកិច្ចសន្យា គឺមានលក្ខណៈធំជាងបញ្ហាដែលទាក់ទងនឹងការអះអាងនូវការតវ៉ារបស់អ្នកព្រមផ្តល់ចំពោះអ្នកទទួលផលប្រយោជន៍ ។ មានន័យថា ចំពោះកិច្ចសន្យារវាងអ្នកទាមទារការផ្តល់ A និងអ្នកព្រមផ្តល់ B ប្រសិនបើអ្នកព្រមផ្តល់ B មិនអនុវត្តកាតព្វកិច្ច មានករណីដែលអ្នកទាមទារការផ្តល់ A មានបំណងរំលាយកិច្ចសន្យា ។ ហើយប្រសិនបើអ្នកទាមទារការផ្តល់ A អាចរំលាយកិច្ចសន្យានោះ ផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ត្រូវបានប៉ះពាល់ ។ ដូច្នេះ សំណួរសួរថា តើអ្នកទាមទារការផ្តល់ A គួរត្រូវបានអនុញ្ញាតឱ្យធ្វើបែបនេះឬទេ ។ ហេតុនេះហើយ បញ្ហានៃការរលត់នៃកិច្ចសន្យា ត្រូវបានរៀបចំឡើងតាមមាត្រាដាច់ដោយឡែកមួយ ។

កថាខណ្ឌទី ១ ចែងអំពីករណីដែលកិច្ចសន្យារវាងអ្នកទាមទារការផ្តល់ A និង អ្នកព្រមផ្តល់ B មានមូលហេតុនៃមោឃភាព ឬ ការលុបចោល ។ ភាគីដែលពាក់ព័ន្ធអាចអះអាងអំពីមោឃភាព ឬ ការលុបចោលកិច្ចសន្យាបាន ទោះបីជាមានអ្នកទទួលផលប្រយោជន៍ក៏ដោយ ។ ក្នុងករណីដែលអ្នកទាមទារការផ្តល់ A អះអាងអំពីមោឃភាព ឬ ការលុបចោលកិច្ចសន្យា អ្នកទាមទារការផ្តល់ A មិនចាំបាច់ទទួលការយល់ព្រមពីអ្នកទទួលផលប្រយោជន៍ ពីព្រោះការការពារអ្នកទាមទារការផ្តល់ក្នុងការអះអាងមោឃភាព ឬ ការលុបចោល មានអាទិភាពជាងផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ ។

កថាខណ្ឌទី ២ ចែងអំពីការរំលាយដោយសារការបំពានកិច្ចសន្យា ។ គ្មានបញ្ហាអ្វីទេអំពីការរំលាយកិច្ចសន្យាដោយអ្នកព្រមផ្តល់ B ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកទាមទារការផ្តល់ A ។ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយ អ្នកព្រមផ្តល់ B អាចអះអាងអំពីការរំលាយកិច្ចសន្យាចំពោះអ្នកទទួលផលប្រយោជន៍ C បាន ។ ការអះអាងអំពីការរំលាយដោយអ្នកទាមទារការផ្តល់ A ដោយសារការបំពានកិច្ចសន្យាដោយអ្នកព្រមផ្តល់ B គឺជាបញ្ហាលំបាកមួយ ។ ទោះបីជាអ្នកព្រមផ្តល់ B មិនអនុវត្តកាតព្វកិច្ចក៏ដោយ ជាគោលការណ៍ សិទ្ធិដែលត្រូវបានផ្តល់ទៅឱ្យតតិយជនរួចហើយតាមកិច្ចសន្យានោះ មិនមែនជាសិទ្ធិរបស់អ្នកទាមទារការផ្តល់ A ទេ ហេតុដូច្នេះ អ្នកទាមទារការផ្តល់ A គ្មានផលប្រយោជន៍ផ្ទាល់ក្នុងការទាមទារការទទួលខុសត្រូវរបស់អ្នកព្រមផ្តល់ B ក្នុងការមិនអនុវត្តកាតព្វកិច្ចឡើយ ដោយសារអ្នកទទួលផលប្រយោជន៍ C គឺជាអ្នកដែលមានផលប្រយោជន៍ចំពោះការអនុវត្តដោយអនុលោមតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ អ្នកទទួលផលប្រយោជន៍ C មិនមែនជាអ្នកទទួលបន្ទុកឋានៈក្នុងកិច្ចសន្យាទេ ហេតុដូច្នេះ អ្នកទទួលផលប្រយោជន៍ C គ្មានសិទ្ធិរំលាយកិច្ចសន្យាឡើយ ។ អ្នកដែលមានសិទ្ធិរំលាយកិច្ចសន្យា គឺជាអ្នកទាមទារការផ្តល់ A ដែលជាភាគីនៃកិច្ចសន្យា ។ ដូច្នេះ អ្នកទាមទារការផ្តល់ A ជាអ្នកដែលអាចអនុវត្តសិទ្ធិរំលាយបាន ប៉ុន្តែវាត្រឹមត្រូវដែលត្រូវចែងថា ចាំបាច់ទទួលការយល់ព្រមពីអ្នកទទួលផលប្រយោជន៍ C ដែលនឹងត្រូវបានប៉ះពាល់ដោយសារការរំលាយនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៥០ នៃក្រមរដ្ឋប្បវេណីកេបិច

## ជំពូកទី ៣ ការអនុវត្តកិច្ចសន្យា

(កំណត់)

ជំពូកទី ៣ នេះ ចែងអំពីចំណុចទូទៅទាក់ទងនឹងករណីយកិច្ចអនុវត្តរបស់គូភាគី ដែលកើតឡើងដោយអានុភាពនៃកិច្ចសន្យា ដូចជា ការដែលករណីយកិច្ចត្រូវអនុវត្តកើតឡើងចំពោះគូភាគី និង ទំនាក់ទំនងនៃការអនុវត្តព្រមគ្នាដែលជាបញ្ហាក្នុងដំណាក់កាលនៃការអនុវត្តកិច្ចសន្យា ជាអាទិ៍ ។

ក្រៅពីចំណុចទូទៅខាងលើ ចំពោះការអនុវត្ត បញ្ហាអាចកើតមាននៅក្នុងដំណាក់កាលពីរផ្សេងគ្នា : ដំណាក់កាលដំបូង គឺជាករណីដែលកាតព្វកិច្ចត្រូវបានអនុវត្ត និង គោលបំណងនៃកិច្ចសន្យាត្រូវបានសម្រេច ក្នុងដំណើរការធម្មតានៃកិច្ចសន្យា ។ ចំណុចលំអិតទាក់ទងនឹងដំណាក់កាលនេះចែងនៅក្នុងជំពូកទី ៨ អំពីការសងដែលរំលត់កាតពកិច្ច ។ ដំណាក់កាលទីពីរ គឺជាករណីដែលម្ចាស់បំណុលទាមទារឱ្យអនុវត្តកិច្ចសន្យាដោយសារកូនបំណុលមិនអនុវត្តករណីយកិច្ច ។ បញ្ហានេះត្រូវបានចែងជាសិទ្ធិទាមទារឱ្យអនុវត្ត នៅក្នុងជំពូកទី ៤ ។

**មាត្រា ៣៨៤.–** ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកាតព្វកិច្ចរលត់ ។

(កំណត់)

មាត្រានេះចែងថា កិច្ចសន្យាបង្កើតឡើងនូវករណីយកិច្ចអនុវត្ត (កាតព្វកិច្ច) ចំពោះភាគីនៃកិច្ចសន្យា ហើយកាតព្វកិច្ចនេះត្រូវបានអនុវត្តឱ្យសមស្របទៅតាម "ខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់" ។

មាត្រានេះបញ្ជាក់ថា រាល់ការអនុវត្តទាំងឡាយដែលបំពេញល័ក្ខខ័ណ្ឌខាងលើនេះ នាំឱ្យកាតព្វកិច្ចរលត់ ។ ដើម្បីរលត់កាតព្វកិច្ច បញ្ហាថា តើត្រូវធ្វើការអនុវត្តយ៉ាងម្ដេច ដូចជាពេលវេលា និង ទីកន្លែងនៃការអនុវត្ត (ការសង) ជាអាទិ៍ បានចែងនៅក្នុងជំពូកទី ៧ ។

ពាក្យ "ការអនុវត្ត" និង "ការសង" សំដៅទៅលើសកម្មភាពដូចគ្នា ។ ពាក្យ "ការអនុវត្ត" សម្គាល់សកម្មភាពបំពេញករណីយកិច្ចរបស់កូនបំណុល រីឯពាក្យ "ការសង" សម្គាល់ការរលត់កាតព្វកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៩.១០១ និង ៩.១០២

**មាត្រា ៣៨៥.-** សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចក្រៅផ្លូវតុលាការ ឬ តាមផ្លូវតុលាការ ។[២]

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្ត តាមផ្លូវតុលាការ ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ដោយសារមានករណីត្រូវនឹងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុល

---

[២] កថាខណ្ឌទី ១ នៃមាត្រា ៣៨៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

បានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តហើយ ម្ចាស់បំណុលអាចទទួល និង រក្សាទុកនូវតាវកាលិកនេះ ដោយចាត់ទុកថាជាការសងបាន ។

(កំណត់)

នៅពេលដែលពិចារណាអំពីករណីយកិច្ចរបស់កូនបំណុលដែលកើតឡើងពីកិច្ចសន្យា តាមទស្សនៈរបស់ម្ចាស់បំណុល មាត្រានេះ ចែងថា ម្ចាស់បំណុលមានសិទ្ធិទាមទារឱ្យអនុវត្ត ។ សិទ្ធិទាមទារឱ្យអនុវត្ត ឧស្សាហ៍ត្រូវបានពិចារណាថាជាវិធីសង្គ្រោះ ចំពោះការមិនអនុវត្តកាតព្វកិច្ច ក្នុងករណីដែលកូនបំណុលមិនអនុវត្ត ។ ប៉ុន្តែ មុននឹងដំណាក់កាលនៃការមិនអនុវត្តកាតព្វកិច្ច សិទ្ធិទាមទារឱ្យអនុវត្តត្រូវបានគិតពិចារណាថាជាបញ្ហាទាក់ទងនឹងអានុភាពនៃកិច្ចសន្យា ក្នុងន័យដែលម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តបាននៅពេលកំណត់ត្រូវអនុវត្ត ។ កថាខណ្ឌទី ១ នៃមាត្រានេះ បានចែងអំពីសិទ្ធិទាមទារឱ្យអនុវត្ត ក្នុងន័យនេះ ។ សិទ្ធិទាមទារឱ្យអនុវត្តដែលជាអានុភាពនៃកិច្ចសន្យានេះ ជាធម្មតា ត្រូវបានអនុវត្តក្រៅផ្លូវតុលាការ ប៉ុន្តែ ក៏អាចត្រូវបានអនុវត្តតាមផ្លូវតុលាការផងដែរ នៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត ។ ក្នុងករណីទាមទារឱ្យអនុវត្តតាមផ្លូវតុលាការ សិទ្ធិទាមទារឱ្យអនុវត្តនេះ ក្លាយទៅជាបញ្ហាទាក់ទងនឹងការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែ ដើម្បីឱ្យមានភាពងាយស្រួល ករណីនេះក៏បានចែងនៅក្នុងមាត្រានេះដែរ ។

កថាខណ្ឌទី ២ ចែងថា ភាគីនៃកិច្ចសន្យាអាចព្រមព្រៀងគ្នាថា មិនបង្ខំឱ្យអនុវត្ត ហើយចែងអំពីអានុភាពនៃការព្រមព្រៀងនេះ ។ កាតព្វកិច្ចបែបនេះ ត្រូវហៅថា "កាតព្វកិច្ចធម្មជាតិ (obligation naturelle, naturalis obligatio)" ។

កថាខណ្ឌទី ៣ ចែងច្បាស់ថា ទោះបីជាមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានក៏ដោយ ប្រសិនបើកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក៏ម្ចាស់បំណុលមានសិទ្ធិទទួលការអនុវត្តនេះដែរ ហើយការទទួលការអនុវត្តនេះមិនក្លាយទៅជាសេចក្ដីចម្រើនដោយឥតហេតុនោះទេ ។

## មាត្រា ៣៨៦.- ការតវ៉ាឱ្យអនុវត្តព្រមគ្នា

ភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញអាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ពេលដែលភាគីម្ខាងទៀតផ្ដល់នូវការអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ។ ក្នុងកិច្ចសន្យាអញ្ញមញ្ញ វាមិនមានសមភាពទេប្រសិនបើតម្រូវឱ្យភាគីតែម្ខាងអនុវត្តកាតព្វកិច្ច ហេតុដូច្នេះ ភាគីម្ខាងនៃកិច្ចសន្យាត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិប្រកែកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ភាគីម្ខាងអនុវត្តកាតព្វកិច្ច ។

ឧទាហរណ៍ ក្នុងករណីកិច្ចសន្យាលក់រវាងអ្នកលក់ A និង អ្នកទិញ B ប្រសិនបើពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ច មកដល់ ភាគីទីមួយៗស្ថិតនៅក្នុងស្ថានភាពដែលអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចបាន ។ ប៉ុន្តែ ដើម្បី ទាមទារឱ្យភាគីអ្នកទិញ B បង់ថ្លៃលក់ អ្នកលក់ A ចាំបាច់ត្រៀមខ្លួនទុកជាមុនក្នុងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃ ការលក់ទិញឱ្យទៅអ្នកទិញ B ( មានន័យថា ធ្វើ "សំណើផ្តល់ការសង") ។

វាក្យខណ្ឌទី ២ គឺជាបញ្ញត្តិអំពីករណីដែលពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចរបស់ភាគីសងខាងនៃកិច្ចសន្យាអញ្ញមញ្ញ ខុសគ្នា ។ ប្រសិនបើពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានមកដល់មុន ហើយពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ច របស់ភាគីម្ខាងទៀតមិនទាន់មកដល់ឡើយ ភាគីដែលពេលកំណត់បានមកដល់រួច មិនអាចលើកឡើងនូវសិទ្ធិតវ៉ាឱ្យអនុវត្ត ព្រមគ្នា នៅពេលភាគីម្ខាងទៀតទាមទារឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៩.២០១ ( ១)

## **មាត្រា ៣៨៧.–** ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិន ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឱ្យកត់សម្គាល់ ថា ភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយក មកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការ ផ្សេងទៀត ដើម្បីរំលត់ការបារម្ភនោះ ។

( កំណត់)

មាត្រានេះចែងអំពីប្រពន្ធ័ដែលហៅថា "ការតវ៉ាដោយមានការបារម្ភ" ។

ក្នុងករណីដែលភាគីម្ខាងមានការបារម្ភថា ភាគីម្ខាងទៀតនឹងមិនអនុវត្តកាតព្វកិច្ចតប ប្រសិនបើភាគីដែលត្រូវអនុវត្ត កាតព្វកិច្ចមុន អនុវត្តកាតព្វកិច្ច ភាគីនោះនឹងអាចទទួលនូវការខូចខាត នៅពេលដែលភាគីម្ខាងទៀតមិនអនុវត្ត កាតព្វកិច្ចតប ។ ទោះជាក្នុងករណីនេះក៏ដោយ ក៏ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចមុននោះ មិនអាចអនុវត្តសិទ្ធិតវ៉ាឱ្យ អនុវត្តព្រមគ្នាឡើយ ។ ហេតុដូច្នេះ ដើម្បីឱ្យមានសមភាព "ការតវ៉ាដោយមានការបារម្ភ" ត្រូវបានបង្កើតឡើងក្នុងបរិបទ នៃទ្រឹស្តីច្បាប់កិច្ចសន្យា ហើយមានប្រទេសមួយចំនួនដែលចែងបញ្ញត្តិនៅក្នុងច្បាប់ ។ មាត្រានេះមានគោលបំណងអនុម័ត យកគោលការណ៍នេះ ។

( មាត្រាពាក់ព័ន្ធ)

គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ៩.២០១ ( ២)

**មាត្រា ៣៨៨.-** ការអនុវត្តតាមបញ្ញត្តិស្តីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) នេះ បញ្ញត្តិស្តីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី ១ (ការសង) នៃជំពូកទី ៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តកិច្ចសន្យា ។

(កំណត់)

ដូចដែលបានពន្យល់នៅក្នុងកំណត់សម្រាប់ជំពូកទី ៣ "ការអនុវត្តកិច្ចសន្យា" ទាក់ទងនឹង "ការសង" ដែលជាមូលដ្ឋាននៃការរំលត់កាតព្វកិច្ចផងដែរ ហេតុដូច្នេះ មាត្រានេះត្រូវរៀបចំឡើងដើម្បីអនុវត្តបញ្ញត្តិស្តីពីការសង ។

## ជំពូកទី ៤ ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច

**មាត្រា ៣៨៩.-** និយមន័យ និង ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា ។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចខាងក្រោមនេះ :

ក-កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលកំណត់ត្រូវអនុវត្ត ដោយសារការយឺតយ៉ាវក្នុងការអនុវត្ត ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ។

គ-កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច ។

ឃ-ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យ និង ប្រភេទនីមួយៗនៃការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ។

និយមន័យនៃការមិនអនុវត្តកាតព្វកិច្ច គឺជាការមិនអនុវត្ត "ករណីយកិច្ចដែលកើតឡើងពីកិច្ចសន្យា" ។ ហេតុដូច្នេះ ដើម្បីយល់បានថា តើករណីណាមួយជាការមិនអនុវត្តកាតព្វកិច្ច មានភាពចាំបាច់ត្រូវពិចារណាថា តើកូនបំណុលត្រូវមានករណីយកិច្ចណា "ដែលកើតឡើងពីកិច្ចសន្យា" ។ នេះគឺជាកិច្ចការកំណត់នូវខ្លឹមសារនៃកិច្ចសន្យា ហើយត្រូវអាស្រ័យទៅលើការបកស្រាយកិច្ចសន្យា ។

ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច បង្ហាញប្រភេទនីមួយៗនៃការមិនអនុវត្តកាតព្វកិច្ចដែលផ្តល់ភាពងាយស្រួលក្នុង

ការធ្វើសេចក្ដីសម្រេចថា មានករណីមិនអនុវត្តកិច្ចសន្យានេះកើតឡើងដែរ ឬទេ ។ ជាទូទៅ ក្រមរដ្ឋប្បវេណីនៃប្រទេសណាក៏ដោយ ក៏មានការចែងអំពីប្រភេទបែបនេះដែរ ។ មាត្រានេះរៀបរាប់ "ការយឺតយ៉ាវក្នុងការអនុវត្ត" "អលទ្ធភាពក្នុងការអនុវត្ត" និង "ការអនុវត្តមិនបានពេញលេញ" ហើយក្រៅពីប្រភេទទាំង ៣ នេះ មាត្រានេះចែងបន្ថែម "ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច" ដោយពិនិត្យទៅលើករណីដែលមានការលំបាកក្នុងការសន្និដ្ឋានថាជាការមិនអនុវត្តកាតព្វកិច្ចប្រភេទណាមួយ ក្នុងចំណោមប្រភេទទាំង ៣ ខាងលើ ។

ឧទាហរណ៍ចម្បងនៃ "ការអនុវត្តមិនបានពេញលេញ" ដែលបានចែងក្នុងចំណុច គ មានដូចជាករណីដែលរថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ មានវិការៈ ។ ទោះបីជាអ្នកលក់ត្រូវផ្ដល់តាវកាលិកនូវរថយន្តដែលមានលក្ខណៈពេញលេញក៏ដោយ ក៏រថយន្តដែលអ្នកលក់បានផ្ដល់តាវកាលិកជារថយន្តដែលមានវិការៈ (មិនពេញលក្ខណៈ) ហេតុដូច្នេះករណីនេះអាចចាត់ទុកថាជា "ការអនុវត្តមិនបានពេញលេញ" ។

ប៉ុន្តែ មានករណីមួយចំនួនទៀតដែលមានការលំបាកក្នុងការសន្និដ្ឋានថាជាប្រភេទណាមួយនៃការមិនអនុវត្តកាតព្វកិច្ចក្នុងចំណោម "ការយឺតយ៉ាវក្នុងការអនុវត្ត" "អលទ្ធភាពក្នុងការអនុវត្ត" និង "ការអនុវត្តមិនបានពេញលេញ" ។ ឧទាហរណ៍ដូចជាក្នុងករណីដែលម្ចាស់រោងចក្របានធ្វើកិច្ចសន្យាជាមួយប្រជាជនរស់នៅក្បែររោងចក្រនោះ ស្ដីពីការទប់ស្កាត់ការបំពុលបរិស្ថាន និង ការទទួលខុសត្រូវនូវករណីយកិច្ចមិនធ្វើសកម្មភាព ជាការមិនបញ្ចេញផ្សែងពុលដែលប៉ះពាល់ដល់សុខភាព ដោយហួសកម្រិតណាមួយ ប៉ុន្តែ ផ្ទុយទៅវិញ រោងចក្រនោះបានបញ្ចេញផ្សែងពុលនោះ ដោយមិនស្របទៅតាមកិច្ចសន្យានោះ ។ ការចាត់ថ្នាក់ចំពោះករណីនេះទៅនឹងប្រភេទណាមួយនៃការមិនអនុវត្តកាតព្វកិច្ច ក្នុងចំណោមប្រភេទទាំង ៣ ខាងលើនេះ អាចធ្វើទៅបាន ។ ប៉ុន្តែ ប្រសិនបើចែងអំពី "ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា" ដូចចំណុច ឃ ទេ នោះវាមានការងាយស្រួលក្នុងការកំណត់ករណីទាំងនេះដូចជាឧទាហរណ៍នេះដែរ ។ ក្នុងករណីដែលកម្មកររោងចក្រម្នាក់ទទួលរងរបួសក្នុងពេលបំពេញការងារ ដោយមូលហេតុមិនមានឧបករណ៍សុវត្ថិភាពគ្រប់គ្រាន់ កម្មករនោះអាចទាមទារឱ្យរោងចក្រទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ដោយធ្វើសេចក្ដីសន្និដ្ឋានថា ករណីនេះត្រូវនឹងចំណុច ឃ ។ នេះគឺជាបញ្ហាដែលត្រូវបានហៅថាជា "ករណីយកិច្ចក្នុងការយកចិត្តទុកដាក់អំពីសុវត្ថិភាព" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៩០.–** វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តដោយបង្ខំ សងសំណងនៃការខូចខាត ឬ រំលាយកិច្ចសន្យា ដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី ២ ដល់ផ្នែកទី ៤ នៃជំពូកទី ៤ នេះបាន ។

( កំណត់)

មាត្រានេះបង្ហាញនូវវិធីសង្គ្រោះសម្រាប់សិទ្ធិលើបំណុល ៣ យ៉ាង ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ច : ការឱ្យអនុវត្តដោយបង្ខំ សំណងការខូចខាត និង ការរំលាយកិច្ចសន្យា ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៤ មាត្រា ៤១៥ និង មាត្រា ៥៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៩១.-** ការយឺតយ៉ាវក្នុងការអនុវត្ត

កូនបំណុលត្រូវបានចាត់ទុកថា មានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដល់កាលកំណត់នោះ ។

ខ-ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថា ដល់ពេលកំណត់ហើយ ។

គ-ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត ។

( កំណត់)

មាត្រានេះចែងអំពី "ការយឺតយ៉ាវក្នុងការអនុវត្ត" ដែលជាប្រភេទមួយនៃការមិនអនុវត្តកាតព្វកិច្ច ។ ការយឺតយ៉ាវក្នុងការអនុវត្តនឹងកើតឡើង ប្រសិនបើ "កំណត់ពេលត្រូវអនុវត្ត" ដែលជាពេលវេលាដែលកូនបំណុលត្រូវផ្តល់តាវកាលិកកន្លងហួស ។ មានវិធីជាច្រើនដើម្បីកំណត់ពេលត្រូវអនុវត្ត ហើយតាមវិធីកំណត់ពេលត្រូវអនុវត្តនីមួយៗ មានភាពខុសគ្នាក្នុងការសម្រេចអំពីការកន្លងហួសនៃកំណត់ពេលត្រូវអនុវត្ត ។ ហេតុដូច្នេះ មាត្រានេះរៀបចំនូវវិធីសម្រេចអំពីការយឺតយ៉ាវក្នុងការអនុវត្ត តាមវិធីនីមួយៗនៃការកំណត់ពេល ។

កំណត់ពេលពិតប្រាកដ សំដៅទៅលើកំណត់ពេលជាក់លាក់ ដូចជា ថ្ងៃទី ១ ខែ កក្កដា ។ ប្រសិនបើកូនបំណុលអនុវត្តថ្ងៃទី ១ ខែ កក្កដា គ្មានបញ្ហាទេ ប៉ុន្តែ ប្រសិនបើកូនបំណុលមិនបានអនុវត្ត នៅមុន ឬ នៅថ្ងៃទី ០១ ខែ កក្កដា ហើយថ្ងៃទី ០២ ខែ កក្កដា បានមកដល់ នោះត្រូវចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្ត ។

កំណត់ពេលមិនពិតប្រាកដ គឺជាកាលបរិច្ឆេទដែលពិតជាឈានមកដល់ ប៉ុន្តែ មិនដឹងពិតប្រាកដថា នឹងមកដល់ពេលណា ។ ឧទាហរណ៍ដូចជាករណីដែលកូនបំណុល B ធ្វើការសន្យាជាមួយភាគី A ថា នឹងសងប្រាក់កម្ចីទៅភាគី A វិញ

នៅពេលដែលឪពុកមារបស់ខ្លួនទទួលមរណភាព ដោយ B មានជំនឿថា ខ្លួនអាចសងលុយទៅឱ្យ A វិញបាន ប្រសិនបើខ្លួនធ្វើសន្តតិកម្មពីឪពុកមារបស់ខ្លួន ។ ក្នុងករណីនេះ កំណត់ពេលនេះ គឺជាកំណត់ពេលមិនពិតប្រាកដ ។

មានករណីមួយចំនួនដែលភាគីនៃកិច្ចសន្យាមិនបានកំណត់ពេល ។ ក្នុងករណីនេះ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចនៅពេលណាក៏បានដែរ ហើយប្រសិនបើកូនបំណុលទទួលការទាមទារនេះ កូនបំណុលចាំបាច់ត្រូវអនុវត្តនៅថ្ងៃនោះ ។ ប្រសិនបើថ្ងៃដែលទទួលការទាមទារកន្លងហួស នោះនឹងត្រូវចាត់ទុកជាការមិនអនុវត្តកាតព្វកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣៩២.- អលទ្ធភាពក្នុងការអនុវត្ត

១-ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព ។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះត្រូវបានវាយតម្លៃថា មិនអាចធ្វើកើត តាមស្ថានភាពសង្គម ឬ សេដ្ឋកិច្ច ។

២-ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ ។

(កំណត់)

មាត្រានេះចែងអំពីអលទ្ធភាពក្នុងការអនុវត្ត ។ អត្ថប្រយោជន៍ដែលយកអលទ្ធភាពក្នុងការអនុវត្ត មកធ្វើជាប្រភេទមួយនៃការមិនអនុវត្តកាតព្វកិច្ច ដោយឡែកពីការយឺតយ៉ាវក្នុងការអនុវត្ត មាននៅត្រង់ចំណុចថា ប្រសិនបើការអនុវត្តកាតព្វកិច្ចក្លាយទៅជាអលទ្ធភាព កូនបំណុលនឹងធ្លាក់ទៅក្នុងស្ថានភាពនៃការមិនអនុវត្តកាតព្វកិច្ច ទោះបីជាមុនកំណត់ពេលត្រូវអនុវត្តក៏ដោយ ហើយការទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ជាអាទិ៍ នឹងកើតឡើង ។ កថាខណ្ឌទី ២ បញ្ជាក់អំពីចំណុចនេះ ។

កថាខណ្ឌទី ១ ផ្តល់និយមន័យនៃអលទ្ធភាពក្នុងការអនុវត្ត ។ ក្នុងករណីដែលកម្មវត្ថុនៃការផ្តល់តាវកាលិក គឺជាវត្ថុជាក់លាក់ ប្រសិនបើវត្ថុជាក់លាក់នោះបានបាត់បង់ នោះការអនុវត្តកាតព្វកិច្ចនោះត្រូវក្លាយទៅជាអលទ្ធភាព ។ ក្នុងការលក់ទិញកុលាលភាជន៍បូរាណ ប្រសិនបើអ្នកលក់ធ្វើឱ្យបែកកុលាលភាជន៍បូរាណដែលជាកម្មវត្ថុនៃការលក់ទិញនោះមុនពេលប្រគល់ឱ្យទៅអ្នកទិញ ការអនុវត្តក្លាយទៅជាអលទ្ធភាព តាមរូបភាពជាក់ស្តែង ។ ប្រសិនកុលាលភាជន៍បូរាណនោះត្រូវបានលួច នោះមានលទ្ធភាពដែលចោរលួចនោះត្រូវបានចាប់ខ្លួន ហើយកុលាលភាជន៍បូរាណនោះនឹងត្រូវបានប្រគល់ជូនវិញ នាពេលអនាគត ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ តាមទស្សនៈនៃសង្គម ការអនុវត្តអាចចាត់

ទុកថាជាអលទ្ធភាព ។ ក្នុងករណីនេះ អ្នកទិញអាចទាមទារសំណងការខូចខាតពីអ្នកលក់ ដោយយកអលទ្ធភាពមកធ្វើជាមូលហេតុបាន ទោះបីជាវាកើតឡើងមុនពេលបំពេញកាតព្វកិច្ចក៏ដោយ ។ ម្យ៉ាងទៀត ក្នុងករណីដែលកប៉ាល់របស់សហគ្រាសដឹកជញ្ជូនដែលដឹកឥវ៉ាន់របស់ម្ចាស់ឥវ៉ាន់នោះ បានលិចជាមួយនឹងឥវ៉ាន់ទាំងនោះ ការជួយស្រង់កប៉ាល់នេះមានលទ្ធភាពតាមរូបសាស្ត្រ ប៉ុន្តែ វាត្រូវការចំណាយយ៉ាងច្រើន ។ ហេតុដូច្នេះ វាអាចសន្និដ្ឋានបានថាជាអលទ្ធភាព តាមទស្សនៈនៃសេដ្ឋកិច្ច ។ ថ្វីត្បិតមិនមានព្រំដែនច្បាស់លាស់រវាងអលទ្ធភាពសង្គម និង អលទ្ធភាពសេដ្ឋកិច្ច ចំណុចសំខាន់មិនស្ថិតនៅលើការបែងចែករវាងអលទ្ធភាពទាំងពីរនេះទេ ពោលគឺមូលហេតុនៃអលទ្ធភាពនេះ មិនត្រូវបានកម្រិតតែអលទ្ធភាពជាក់ស្តែង (តាមរូបសាស្ត្រ) ប៉ុណ្ណោះទេ ។

ប្រសិនបើការអនុវត្តកាតព្វកិច្ចក្លាយទៅជាអលទ្ធភាព ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តការផ្តល់តាវកាលិកពីដំបូងបានទេ ហើយអាចទាមទារត្រឹមតែសំណងការខូចខាតប៉ុណ្ណោះ ។ មាត្រា ៤១៥ ចែងអំពីចំណុចនេះ ។ ម្ចាស់ឥវ៉ាន់ដែលជាម្ចាស់បំណុល មិនអាចទាមទារឱ្យសហគ្រាសដឹកជញ្ជូនដែលជាកូនបំណុល ស្រោចស្រង់ឥវ៉ាន់ទាំងនោះពីបាតសមុទ្របានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ និង មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣៩៣.- ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ

ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ សំដៅទៅលើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់តាវកាលិកមិនពេញលេញ ឬ ករណីដែលបានអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬ ករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច ។[៣]

(កំណត់)

មាត្រានេះមានគោលបំណងបញ្ជាក់អំពីទស្សនាទាននៃការអនុវត្តកាតព្វកិច្ចមិនបានពេញលេញដែលជាប្រភេទមួយនៃការមិនអនុវត្តបំពេញកាតព្វកិច្ច ។ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ សំដៅទៅលើករណីដែលកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែ ការអនុវត្តនោះមិនបានពេញលេញ ។ ឧទាហរណ៍ចម្បងគឺជាករណីដែលផ្តល់តាវកាលិកនូវផលិតផលដែលមានវិការៈ ។ ក្រៅពីនេះ ក្នុងកិច្ចសន្យាដែលភាគីម្ខាងបានព្រមព្រៀងលក់រថយន្តតូយ៉ូតាជំនំនាំចូលចំនួន ១០០ គ្រឿង ប្រសិនបើអ្នកទិញបានទទួលរថយន្តទាំងនោះហើយរកឃើញថា ទទួលបានរថយន្តតែចំនួន ៩៧ គ្រឿង

---

[៣] មាត្រា ៣៩៣ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ករណីនេះក៏អាចក្លាយជាករណីអនុវត្តកាតព្វកិច្ចមិនបានពេញលេញដែរ ។ ប៉ុន្តែ ក្នុងករណីដែលចំនួនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញដែលបានទទួល ខុសពីចំនួនដែលបានកំណត់នៅក្នុងកិច្ចសន្យា ករណីនេះអាចត្រូវបានដោះស្រាយថាជាការយឺតយ៉ាវក្នុងការអនុវត្តមួយផ្នែក ឬ អលទ្ធភាពមួយផ្នែកក្នុងការអនុវត្តបានដែរ ។ ប្រសិនបើអ្នកលក់មិនអាចរៀបចំដោយងាយស្រួលនូវចំនួនខ្វះនៃរថយន្តតូយ៉ូតាជំនំនោះ ករណីនេះគឺជាអលទ្ធភាពមួយផ្នែកក្នុងការអនុវត្ត ។ ម្យ៉ាងទៀត ប្រសិនបើអ្នកលក់អាចមានលទ្ធភាពរៀបចំចំនួនខ្វះនោះ ប៉ុន្តែ ត្រូវចំណាយពេលវេលា ហើយមិនអាចធ្វើបានឱ្យទាន់ពេលកំណត់តាមកិច្ចសន្យា ករណីនេះអាចត្រូវបានដោះស្រាយថាជាការយឺតយ៉ាវក្នុងការអនុវត្តមួយផ្នែកបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ មាត្រា ៥៧០ និង មាត្រា ៥៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៣៩៤.- ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច

ក្រៅពីបញ្ញត្តិនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) មាត្រា ៣៩២ (អលទ្ធភាពក្នុងការអនុវត្ត) និង មាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) នៃក្រមនេះ ករណីដែលមានការបំពានករណីយកិច្ចផ្សេងដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ជាការមិនអនុវត្តកាតព្វកិច្ចដែរ ។

(កំណត់)

មាត្រានេះចែងអំពីការមិនអនុវត្ត ឬ ការបំពានកិច្ចសន្យាដែលមិនមានលក្ខណៈស្របនឹងការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត ឬ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ។ បទប្បញ្ញត្តិនេះមិនមានភាពចាំបាច់ទេ ប្រសិនបើមានបញ្ញត្តិទូទៅដែលគ្របដណ្តប់រាល់ការមិនអនុវត្តកាតព្វកិច្ច ។ ផ្ទុយទៅវិញ ក្នុងករណីការចែកដាច់ពីគ្នានូវការមិនអនុវត្តកាតព្វកិច្ចតាមប្រភេទនីមួយៗ ដូចជាការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត និង ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ដើម្បីបញ្ជាក់អំពីទស្សនាទាននៃការមិនអនុវត្តកាតព្វកិច្ច បញ្ហាចោទកើតមានឡើងថាតើត្រូវដោះស្រាយបែបណាចំពោះករណីដែលមិនស្ថិតនៅក្នុងប្រភេទណាមួយនៃការមិនអនុវត្តកាតព្វកិច្ចនេះ ។ មាត្រានេះបានផ្តល់នូវមធ្យោបាយចុងក្រោយដើម្បីដោះស្រាយជាមួយស្ថានការណ៍បែបនេះ ។ ហេតុដូច្នេះ ដើម្បីកំណត់ថាតើមានការមិនអនុវត្តកាតព្វកិច្ចនេះកើតឡើង ឬយ៉ាងណា ទោះបីជាមានលក្ខណៈស្របនឹង "ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច" ក៏ដោយ ប្រសិនបើអាចត្រូវបានដោះស្រាយថាជាការយឺតយ៉ាវក្នុងការអនុវត្ត ឬ អលទ្ធភាពក្នុងការអនុវត្តបាន នោះគ្មានភាពចាំបាច់ក្នុងការបដិសេធមិនឱ្យអនុវត្តបញ្ញត្តិអំពីការយឺតយ៉ាវក្នុងការអនុវត្ត ឬ អលទ្ធភាពក្នុងការអនុវត្ត ដើម្បីដោះស្រាយករណីនេះទេ ។ ឱ្យតែសកម្មភាពរបស់កូនបំណុលស្ថិតនៅក្នុងប្រភេទណាមួយនៃការមិនអនុវត្តកាតព្វកិច្ចនេះ វាមានលក្ខណៈគ្រប់គ្រាន់ដើម្បីទាមទារឱ្យទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ។

ឧទាហរណ៍នៃការមិនអនុវត្តកាតព្វកិច្ចដែលមានការលំបាកក្នុងការពន្យល់ស្របនឹងប្រភេទនៃការមិនអនុវត្តកាតព្វកិច្ចទាំងបីនេះ (ការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត និង ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) គឺការបំពានករណីយកិច្ចត្រូវធ្វើ ឬ មិនត្រូវធ្វើសកម្មភាពណាមួយ ។ ម្យ៉ាងទៀត ក្នុងករណីដែលអ្នកលក់ផ្ដល់ជាវកាលិកជាបសុសត្វដែលមានវិការៈ (ជម្ងឺ) ឱ្យទៅអ្នកទិញ ប្រសិនបើជម្ងឺនេះឆ្លងទៅបសុសត្វរបស់អ្នកទិញផងដែរនោះ ករណីនេះអាចដោះស្រាយតាមការអនុវត្តកាតព្វកិច្ចមិនបានពេញលេញបានដែរ ប៉ុន្តែ ការដែលជម្ងឺឆ្លងទៅបសុសត្វរបស់អ្នកទិញមិនត្រឹមតែជាការអនុវត្តកាតព្វកិច្ចមិនបានពេញលេញទេ គឺនាំឱ្យមានការខូចខាតសកម្មចំពោះភាគីម្ខាងទៀត ហេតុដូច្នេះវាគួរត្រូវបានបកស្រាយថាជា "ករណីផ្សេងនៃការមិនអនុវត្តកាតព្វកិច្ច" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុន

## មាត្រា ៣៩៥.- ពហុមធ្យោបាយសង្គ្រោះ

ក្នុងករណីដែលមធ្យោបាយសង្គ្រោះមានច្រើនយ៉ាងអនុញ្ញាតចំពោះម្ចាស់បំណុលនោះម្ចាស់បំណុលអាចជ្រើសរើសមធ្យោបាយណាមួយ ឬ ច្រើន កុំឱ្យតែមធ្យោបាយទាំងនោះមានភាពផ្ទុយគ្នា ។

(កំណត់)

ដូចដែលបានរៀបរាប់រួចមកហើយ ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ច មធ្យោបាយសង្គ្រោះផ្សេងៗ ត្រូវបានទទួលស្គាល់ ដូចជាការទាមទារឱ្យអនុវត្តដោយបង្ខំ សំណងនៃការខូចខាត និង ការរំលាយកិច្ចសន្យា ជាអាទិ៍ ។ មាត្រានេះមានចែងអំពីគំនិតជាមូលដ្ឋានស្ដីពីទំនាក់ទំនងរវាងមធ្យោបាយសង្គ្រោះទាំងនេះ ។

គំនិតជាមូលដ្ឋានដែលមានចែងនៅក្នុងបញ្ញត្តិនេះ គឺម្ចាស់បំណុលអាចជ្រើសរើសមធ្យោបាយសង្គ្រោះច្រើនបាន កុំឱ្យតែមធ្យោបាយសង្គ្រោះទាំងនោះមានភាពផ្ទុយគ្នា ។ ឧទាហរណ៍ ម្ចាស់បំណុលអាចរំលាយកិច្ចសន្យា និង ទាមទារឱ្យសងសំណងការខូចខាតបាន ។ ម្យ៉ាងទៀត ជាដំបូង ម្ចាស់បំណុលទាមទារឱ្យអនុវត្តកាតព្វកិច្ច ហើយប្រសិនបើកូនបំណុលមិនអនុវត្តទេ ម្ចាស់បំណុលនេះអាចរំលាយកិច្ចសន្យា និង ទាមទារឱ្យសងសំណងការខូចខាតបានដែរ ។ ប៉ុន្តែការរំលាយកិច្ចសន្យា និង ទាមទារឱ្យអនុវត្ត មានភាពផ្ទុយគ្នាទៅវិញទៅមក ហេតុដូច្នេះ ម្ចាស់បំណុលមិនអាចជ្រើសរើសមធ្យោបាយពីរនេះបានឡើយ ។

ម្ចាស់បំណុលក៏អាចទាមទារនូវសំណងការខូចខាតទាំងនេះដោយមិនរំលាយកិច្ចសន្យាបានដែរ ។

## ផ្នែកទី ២ ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

**មាត្រា ៣៩៦.-** ដីកាបង្គាប់ឱ្យអនុវត្តកាតព្វកិច្ចដោយតុលាការ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

(កំណត់)

ម្ចាស់បំណុលមានសិទ្ធិទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ហើយប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត នោះម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចនេះ ទៅតាមនីតិវិធីអនុវត្តដោយបង្ខំ ។

វិធីអនុវត្តដោយបង្ខំមាន ៣ ប្រភេទ គឺការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស និង ការបង្ខំដោយប្រយោល ហើយចំណុចលម្អិតនៃវិធីទាំង ៣ នេះ បានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។ នៅក្នុងក្រមរដ្ឋប្បវេណីវិញ មាត្រានេះគ្រាន់តែចែងនូវគោលការណ៍ដែលម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន ក្នុងករណីដែលកាតព្វកិច្ចនោះមានលក្ខណៈដែលអាចអនុវត្តដោយបង្ខំបាន ។ ក្រមរដ្ឋប្បវេណីចែងអំពីគោលការណ៍នេះ ដោយសារការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំនេះ មិនត្រឹមតែជាបញ្ហានៃនីតិវិធីប៉ុណ្ណោះទេ ប៉ុន្តែ គឺជាបញ្ហាច្បាប់សារធាតុថាតើសិទ្ធិលើបំណុលមានអានុភាពអ្វីខ្លះ ។

ការអនុវត្តដោយបង្ខំ ជាទូទៅ អាចធ្វើទៅបាន ចំពោះកាតព្វកិច្ចដែលមានខ្លឹមសារនៃការប្រគល់វត្ថុ ។ ឧទាហរណ៍ អ្នកទិញដីម្នាក់ដែលបានបង់ថ្លៃលក់ដីរួចរាល់ហើយនោះ អាចទាមទារឱ្យអ្នកលក់ដី ចុះបញ្ជីអំពីការផ្ទេរ និង ទាមទារឱ្យប្រគល់ដីមកឱ្យខ្លួនបាន ហើយប្រសិនបើអ្នកលក់មិនព្រមចុះបញ្ជីដោយស្ម័គ្រចិត្តទេ អ្នកទិញអាចអនុវត្តនីតិវិធីចុះបញ្ជីដោយបង្ខំបាន ។ អ្នកទិញក៏អាចទាមទារឱ្យអនុវត្តដោយបង្ខំ ចំពោះការប្រគល់ដីនោះដែរ ។ ប៉ុន្តែ ប្រសិនបើអ្នកទិញដីមិនបានបង់ថ្លៃលក់រួចរាល់នៅឡើយ អ្នកលក់ដីមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដែលអាចបដិសេធក្នុងការប្រគល់ដីនោះរហូតដល់ពេលការបង់ថ្លៃលក់ត្រូវបានធ្វើរួចរាល់ ហេតុដូច្នេះ អ្នកទិញមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយបង្ខំទេ ។

ចំពោះកាតព្វកិច្ចត្រូវផ្តល់សេវាការងារតាមកិច្ចសន្យាការងារ ការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបានទេ ដោយសារការអនុវត្តដោយបង្ខំនេះមិនគោរពបុគ្គលភាពរបស់កូនបំណុល ។ ប្រសិនបើនិយោជិតមិនបានធ្វើតាមការណែនាំ និយោជកមានតែមធ្យោបាយរំលាយកិច្ចសន្យាការងារ ឬ ទាមទារសំណងនៃការខូចខាតប៉ុណ្ណោះ ។ ជាទូទៅ ចំពោះកាតព្វកិច្ចដែលត្រូវធ្វើសកម្មភាពណាមួយ គ្មានភាពសមរម្យដែលឱ្យកូនបំណុលអនុវត្តដោយបង្ខំ ហេតុដូច្នេះ ការអនុវត្តដោយបង្ខំមិនអាចធ្វើបានឡើយ លើកលែងតែកាតព្វកិច្ចនេះតម្រូវឱ្យធ្វើសកម្មភាពដែលងាយស្រួល និង មានទម្រង់ជាក់លាក់

ណាមួយ ។

ទោះជាយ៉ាងណាក៏ដោយ មានការលំបាកក្នុងការចែងនៅក្នុងច្បាប់អំពីកាតព្វកិច្ចដែលមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ។ តុលាការនឹងសម្រេចសេចក្តី នៅពេលដែលម្ចាស់បំណុលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៩៧.–** ទំនាក់ទំនងរវាងការទាមទារឱ្យអនុវត្តកាតព្វកិច្ច និង មធ្យោបាយផ្សេងៗ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឱ្យសងការខូចខាត ជំនួសការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬ ជាមួយការទាមទារឱ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា ។

(កំណត់)

មាត្រានេះដាក់ចេញជាក់ស្តែងនូវគោលបំណងនៃមាត្រា ៣៩៥ ចំពោះទំនាក់ទំនងរវាងសិទ្ធិទាមទារឱ្យអនុវត្ត និង សិទ្ធិទាមទារសំណងនៃការខូចខាត ។ សំណងនៃការខូចខាត ត្រូវបែងចែកជា ២ ប្រភេទ តាមទំនាក់ទំនងជាមួយនឹងការអនុវត្តកាតព្វកិច្ច ។

ប្រភេទទី ១ នៃសំណងនៃការខូចខាត គឺជាសំណងការខូចខាតជំនួសតាវកាលិកដើមដែលជាខ្លឹមសារនៃកាតព្វកិច្ច ។ ដូចជាសំណងការខូចខាត ក្នុងករណីនៃអលទ្ធភាពក្នុងការអនុវត្ត ឬ ការរំលាយកិច្ចសន្យា ។ សំណងនៃការខូចខាតប្រភេទនេះ ត្រូវហៅថា "សំណងការខូចខាតជំនួស" ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាលក់ទិញរថយន្ត ប្រសិនបើអ្នកលក់បានធ្វើឱ្យបាក់បែកទៅលើរថយន្តបណ្តាលមកពីកំហុសរបស់ខ្លួន នោះអ្នកទិញអាចទាមទារសំណងនៃការខូចខាតដែលមានចំនួនទឹកប្រាក់ស្មើនឹងតម្លៃថ្លៃនៃរថយន្តនោះ ។ សំណងការខូចខាតជំនួសនេះមានវិសមិតភាពជាមួយនឹងការទាមទារឱ្យអនុវត្តកាតព្វកិច្ច ។ ម្ចាស់បំណុលមិនត្រូវបានអនុញ្ញាតឱ្យទទួលការអនុវត្ត ដោយទាមទារឱ្យអនុវត្តកាតព្វកិច្ច ហើយទទួលសំណងការខូចខាតជំនួស នៅពេលជាមួយគ្នាឡើយ ។ ម្ចាស់បំណុល "ត្រូវបានអនុញ្ញាតឱ្យទាមទារសំណងការខូចខាតជំនួសការទាមទារឱ្យអនុវត្តកាតព្វកិច្ច" ។

ប្រភេទី ២ នៃសំណងនៃការខូចខាត គឺជាសំណងការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ដែលត្រូវហៅថា "សំណងការខូចខាតចំពោះការយឺតយ៉ាវ" ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកទិញជួលរថយន្តដើម្បីធ្វើកិច្ចការរបស់ខ្លួន ដោយសារអ្នកលក់មិនបានប្រគល់រថយន្តនៅពេលកំណត់ នោះអ្នកទិញអាចទាមទារនូវសំណងការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច មានន័យថា អាចទាមទារសំណងការខូចខាតនូវចំនួនទឹកប្រាក់ស្មើនឹងតម្លៃជួលរថយន្តក្នុងអំឡុងពេលនៃការយឺតយ៉ាវក្នុងការអនុវត្ត ។ សំណងការខូចខាតចំពោះការ

យឺតយ៉ាវ គ្មានវិសមិតភាពជាមួយនឹងការទាមទារឱ្យអនុវត្តកាតព្វកិច្ច ហេតុដូច្នេះ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្ត ហើយអាចទាមទារឱ្យសងសំណងការខូចខាតព្រមជាមួយគ្នាបាន ។

ប្រសិនបើម្ចាស់បំណុលរំលាយកិច្ចសន្យា ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចបានទេ ប៉ុន្តែ គ្រាន់តែអាចទាមទារសំណងការខូចខាតជំនួសបានប៉ុណ្ណោះ ។

## ផ្នែកទី ៣ សំណងនៃការខូចខាត

**មាត្រា ៣៩៨.–** ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត

១-ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត ។

២-ក្នុងករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបានទេ លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ ។

(កំណត់)

មាត្រានេះចែងថា "ការមិនអនុវត្តកាតព្វកិច្ច" និង "កំហុស" គឺជាល័ក្ខខ័ណ្ឌចាំបាច់ដើម្បីទាមទារសំណងការខូចខាត ។ ចំពោះការមិនអនុវត្តកាតព្វកិច្ច មានបញ្ញត្តិចាប់ពីមាត្រា ៣១៩ ដល់មាត្រា ៣៩៤ ។ បន្ទុកក្នុងការបញ្ជាក់អំពីការមិនអនុវត្តកាតព្វកិច្ចនេះ ធ្លាក់ទៅលើម្ចាស់បំណុល ។ "កំហុស" មានន័យថាជាការមិនគោរពករណីយកិច្ចត្រូវប្រុងប្រយ័ត្នដែលត្រូវបានតម្រូវឱ្យមានចំពោះកូនបំណុល ។

មាត្រា ៣១៤ បានចែងអំពីករណីយកិច្ចថែរក្សាវត្ថុរបស់កូនបំណុលដែលមានកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ ។ ប្រសិនបើកូនបំណុលមិនគោរពករណីយកិច្ចថែរក្សានេះ កូនបំណុលនេះក្លាយទៅជាមានកំហុស ហើយត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ។ ចំពោះករណីនៃការយឺតយ៉ាវក្នុងការអនុវត្តវិញ ការណ៍ដែលពេលកំណត់ត្រូវអនុវត្តកន្លងហួស គឺជាការមិនអនុវត្តកាតព្វកិច្ច ហើយប្រសិនបើកូនបំណុលមានកំហុសចំពោះការកន្លងផុតនៃពេលកំណត់ត្រូវអនុវត្តនេះ កូនបំណុលត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ។ ចំពោះកំហុសក្នុងការកន្លងហួសនៃពេល

កំណត់ត្រូវអនុវត្ត កូនបំណុលត្រូវបញ្ជាក់ថា ខ្លួនមិនមានកំហុស ដោយសារ ជាទូទៅ កូនបំណុលត្រូវបានសន្មតថា មានកំហុស បើពេលកំណត់ត្រូវអនុវត្តកន្លងហួស ។ ការបញ្ជាក់អំពីភាពគ្មានកំហុស មិនត្រូវបានទទួលស្គាល់ដោយងាយស្រួលឡើយ ។ ឧទាហរណ៍ ក្នុងករណីដែលវត្ថុមួយត្រូវបានលក់ពីភាគី A ទៅភាគី B និង លក់បន្តទៅភាគី C ហើយភាគី B មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះ ឱ្យទៅភាគី C ប្រសិនបើភាគី B មិនអាចប្រគល់វត្ថុនោះឱ្យទៅភាគី C នៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ច ដោយមូលហេតុថា ភាគី A មិនបានប្រគល់វត្ថុនោះមកឱ្យភាគី B នោះមានករណីខ្លះដែលភាគី B អាចបញ្ជាក់បានថា ខ្លួនគ្មានកំហុស ។ ជាធម្មតា វាមានការលំបាកក្នុងការបញ្ជាក់អំពីភាពគ្មានកំហុស ប៉ុន្តែ ការមិនអាចអនុវត្តកាតព្វកិច្ចតាមកំណត់ពេល ដោយហេតុថា មិនអាចប្រើមធ្យោបាយដឹកជញ្ជូនដោយសារមហន្តរាយទឹកជំនន់ ជាអាទិ៍ អាចក្លាយជាការបញ្ជាក់អំពីភាពគ្មានកំហុសបាន ។

កថាខណ្ឌទី ២ ចែងនូវវិធីវិនិច្ឆ័យអំពីការទទួលខុសត្រូវរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលនេះប្រើប្រាស់អ្នកជំនួយឱ្យអនុវត្តកាតព្វកិច្ច ហើយការមិនអនុវត្តកាតព្វកិច្ច បានកើតឡើងដោយសារសកម្មភាពរបស់អ្នកជំនួយនេះ ។ ដោយហេតុថា អ្នកជំនួយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់កូនបំណុល ជាគោលការណ៍ កូនបំណុលត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់អ្នកជំនួយ ។

មាត្រានេះមិនបានចែងច្បាស់អំពីនិយមន័យនៃពាក្យ "អ្នកជំនួយ" ទេ ប៉ុន្តែ ពាក្យនេះសំដៅទៅលើបុគ្គលដែលកូនបំណុលអាចត្រួតពិនិត្យបាន ។ ដូច្នេះ ក្នុងករណីដែលកូនបំណុលអនុវត្តកាតព្វកិច្ច ដោយប្រើនិយោជិត ឬ សមាជិកក្រុមគ្រួសាររបស់ខ្លួន នោះនិយោជិត ឬ សមាជិកក្រុមគ្រួសារគឺជាអ្នកជំនួយ ។ ផ្ទុយទៅវិញ ក្នុងករណីដែលកូនបំណុលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ច ដោយប្រើសេវាកម្មប្រៃសណីយ៍ ឬ សហគ្រាសដឹកជញ្ជូន ប្រសិនបើវត្ថុនោះបានបាត់បង់ ដោយសារកំហុសមន្ត្រីប្រៃសណីយ៍ ឬ សហគ្រាសដឹកជញ្ជូន នោះមន្ត្រីប្រៃសណីយ៍ ឬ សហគ្រាសដឹកជញ្ជូនមិនមែនជាអ្នកជំនួយរបស់កូនបំណុលដែលបានកំណត់នៅក្នុងមាត្រានេះទេ ដោយមូលហេតុថា កូនបំណុលមិនស្ថិតនៅក្នុងឋានៈដែលអាចត្រួតពិនិត្យបុគ្គលទាំងនោះ ហេតុដូច្នេះហើយវាជាការមិនត្រឹមត្រូវទេដែលតម្រូវឱ្យកូនបំណុលទទួលខុសត្រូវចំពោះកំហុសរបស់បុគ្គលទាំងនោះដោយស្វ័យប្រវត្តិ ។ ទោះជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ក្នុងការបញ្ជាក់ឱ្យបានលម្អិត តាមយុត្តិសាស្ត្ររបស់តុលាការនាពេលអនាគត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៣៩៩.–** បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសិអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះ

បានដែរ ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះ ត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ ។ បើអត្រាការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា ។

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

(កំណត់)

ចំពោះការមិនអនុវត្តកាតព្វកិច្ចជាប្រាក់ បើប្រៀបធៀបជាមួយនឹងការមិនអនុវត្តកាតព្វកិច្ចទូទៅ មានភាពចាំបាច់ក្នុងការបង្កើតករណីលើកលែងមួយចំនួន ។ មាត្រានេះចែងអំពីករណីលើកលែងនេះ ។

ទី ១ ចំពោះកាតព្វកិច្ចជាប្រាក់ មិនមានអលទ្ធភាពក្នុងការអនុវត្តឡើយ ។ ក្នុងករណីនៃអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចផ្សេងទៀតក្រៅពីកាតព្វកិច្ចជាប្រាក់ ប្រសិនបើកូនបំណុលមានកំហុស នោះកាតព្វកិច្ចដំបូងនឹងក្លាយទៅជាកាតព្វកិច្ចនៃសំណងការខូចខាត ។ ប្រសិនបើកូនបំណុលគ្មានកំហុស នោះកាតព្វកិច្ចដំបូងនឹងរលត់ ហើយបញ្ហាដែលត្រូវយកមកពិចារណា គឺការទទួលបន្ទុកហានិភ័យ ។ ផ្ទុយទៅវិញ ក្នុងករណីកាតព្វកិច្ចជាប្រាក់ កាតព្វកិច្ចដំបូងមិនត្រូវរលត់ដោយអលទ្ធភាពក្នុងការអនុវត្តទេ ។ រាល់ករណីដែលកូនបំណុលមិនអាចសងចំពោះកាតព្វកិច្ចជាប្រាក់ គឺជាការយឺតយ៉ាវក្នុងការអនុវត្ត ហើយម្ចាស់បំណុលអាចទាមទារសំណងការខូចខាតបាន ។ ទោះបីជាមាត្រានេះមិនចែងច្បាស់លាស់អំពីចំណុចនេះក៏ដោយ ក៏ឃ្លាដែលចែងថា "ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ" បង្ហាញអំពីការយល់ឃើញបែបនេះ ។ សរុបសេចក្តីមក ការកន្លងហួសនៃកំណត់ពេលត្រូវអនុវត្តកាតព្វកិច្ចជាប្រាក់ត្រូវក្លាយទៅជាការយឺតយ៉ាវក្នុងការអនុវត្តជានិច្ច ហើយការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវដែលជាសំណងនៃការខូចខាត ត្រូវបានទទួលស្គាល់ ដោយមិនគិតពិចារណានូវអត្ថិភាព ឬ នត្ថិភាពនៃកំហុសរបស់កូនបំណុល ។

ទី ២ ជាគោលការណ៍ ចំនួនទឹកប្រាក់នៃសំណងការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ច ជាចំនួននៃប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដែលត្រូវបានគណនាទៅតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ ឬទៅតាមអត្រាការប្រាក់ដែលត្រូវបានព្រមព្រៀងគ្នា ។ ប៉ុន្តែ ប្រសិនបើកូនបំណុលមានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ច នោះម្ចាស់បំណុលអាចទាមទារសំណងការខូចខាត ចំពោះការខូចខាតដែលលើសពីចំនួនទឹកប្រាក់នៃការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវបាន ។ ប៉ុន្តែ ក្នុងករណីនេះ បន្ទុកក្នុងការបញ្ជាក់អំពីកំហុស ត្រូវបានប្តូរ មានន័យថា កូនបំណុលអាចរួចផុតពីការទទួលខុសត្រូវ ចំពោះការខូចខាតទាំងឡាយដែលលើសពីការប្រាក់ក្នុងអំឡុងពេលនៃការ

យឺតយ៉ាវ ប្រសិនបើកូនបំណុលនោះបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ ។ ឧទាហរណ៍នៃសំណងការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ គឺករណីដែលអ្នកឱ្យខ្ចី (ម្ចាស់បំណុល) បានពន្យល់ទៅអ្នកខ្ចី (កូនបំណុល) ថា អ្នកឱ្យខ្ចីនឹងជួបប្រទះការលំបាក ប្រសិនបើខ្លួនមិនបានទទួលប្រាក់កម្ចីនោះតាមពេលកំណត់ ពីព្រោះខ្លួនត្រូវប្រើប្រាស់ប្រាក់កម្ចីនេះដើម្បីបង់ថ្លៃលក់ទៅតាមកិច្ចសន្យាលក់ទិញឱ្យទៅតតិយជន ប៉ុន្តែកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ (ពេលកំណត់បានកន្លងហួស) ហេតុដូច្នេះ តតិយជនរំលាយកិច្ច-សន្យាលក់ទិញ ហើយអ្នកឱ្យខ្ចីទទួលការខូចខាត ។

ចំពោះការខូចខាតដែលកើតឡើងដោយសារស្ថានភាពពិសេសរបស់ម្ចាស់បំណុល ប្រសិនបើកូនបំណុលមានកំហុស ការខូចខាតនោះអាចក្លាយទៅជាកម្មវត្ថុនៃសំណងការខូចខាត ប៉ុន្តែ អាស្រ័យទៅលើការអនុវត្តលក្ខណៈវិនិច្ឆ័យទូទៅដែលកំណត់អំពីទំហំនៃការខូចខាតនេះ ។ មានន័យថា បញ្ញត្តិនៃមាត្រា ៤០១ ត្រូវយកមកអនុវត្តចំពោះករណីនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០០.- ទស្សនៈអំពីការខូចខាត

១-ម្ចាស់បំណុលអាចទាមទារនូវសំណងនៃការខូចខាត គឺ អាចទាមទារនូវសំណងនៃផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយក្រៅពីនេះ អាចទាមទារផងដែរនូវចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត និងចំណាយ ឬ បន្ទុកដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការអនុវត្ត ។

២-តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្តដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ ។ ចំពោះចំនួនសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីទស្សនៈនៃការខូចខាត មានន័យថាជាការខូចខាតដែលអាចត្រូវបានទាមទារសំណង ។

សំណងនៃការខូចខាត គឺជាសំណងដែលមានកម្មវត្ថុជាផលប្រយោជន៍ពីការអនុវត្ត មានន័យថាជាផលប្រយោជន៍ដែលអាចទទួលបានប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្ត ។ ប៉ុន្តែ ការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារការមិនអនុវត្ត មិនត្រឹមតែជាផលប្រយោជន៍ពីការអនុវត្តប៉ុណ្ណោះទេ ។

ឧទាហរណ៍ ដោយសារកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលត្រូវផ្ញើលិខិតទាមទារតាមប្រៃសណីយ៍ និង

ពិគ្រោះយោបល់ជាមួយមេធាវី ។ សោហ៊ុយចំណាយទាំងនេះ គឺជាការខូចខាតដែលម្ចាស់បំណុលអាចទាមទារសំណងបាន។ ការខូចខាតនេះ គឺជា "ចំណាយដែលបង្កើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច" ។

"ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត" មានដូចជាសោហ៊ុយចំណាយដើម្បីបង្កើតកិច្ចសន្យា ជាអាទិ៍ ។ ប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្ត ចំណាយទាំងនេះនឹងក្លាយជាបន្ទុករបស់ភាគីនីមួយៗនៃកិច្ចសន្យា ហើយភាគីម្ខាងមិនអាចទាមទារឱ្យភាគីម្ខាងទៀតទទួលបន្ទុកចំណាយនេះបានឡើយ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលមិនអាចសម្រេចនូវគោលបំណងក្នុងការបង្កើតកិច្ចសន្យាបាន ដោយសារអលទ្ធភាពក្នុងការអនុវត្តកិច្ចសន្យានោះ មាត្រានេះអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការចំណាយទាំងនេះជាសំណងការខូចខាត ចំពោះកូនបំណុល ។ ឧទាហរណ៍ ភាគី A ធ្វើកិច្ចសន្យាលក់វត្ថុបុរាណឱ្យទៅភាគី B ក្នុងតម្លៃ ១.០០០ (មួយពាន់) ដុល្លារ ហើយភាគី B បង់ប្រាក់ចំនួន ៥០ (ហាសិប) ដុល្លារឱ្យទៅតតិយជនដើម្បីធ្វើការវាយតម្លៃវត្ថុនោះ ។ ប៉ុន្តែ ភាគី A បានធ្វើឱ្យបែកវត្ថុនោះ ដោយសារកំហុសរបស់ខ្លួន ។ ប្រសិនបើភាគី B រំលាយកិច្ចសន្យាលក់ទិញនេះដោយមូលហេតុនៃអលទ្ធភាពក្នុងការអនុវត្ត ហើយមានបំណងទាមទារសំណងការខូចខាតចំនួន ១.០០០ (មួយពាន់) ដុល្លារ ពីភាគី A ក្នុងករណីនេះ B នឹងរួចផុតពីកាតព្វកិច្ចបង់ថ្លៃលក់ដោយសារការរំលាយ ហេតុដូច្នេះ ប្រសិនបើទូទាត់ផលប្រយោជន៍របស់ A ក្នុងការរួចផុតពីកាតព្វកិច្ចបង់ថ្លៃលក់ជាមួយនឹងសំណងការខូចខាត នោះ B ហាក់ដូចជាមិនអាចទាមទារអ្វីពីភាគី A បានឡើយ ។ ប៉ុន្តែ ភាគី B ក៏នៅចង់ទាមទារសោហ៊ុយវាយតម្លៃដែលបានក្លាយជាគ្មានប្រយោជន៍ពី A ដោយយកសោហ៊ុយនោះអះអាងថា ជាសំណងការខូចខាត ។ មាត្រានេះត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឱ្យមានការទាមទារប្រភេទនេះ ។ ចំពោះជំហរនេះ មានមតិប្រឆាំងផងដែរ ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិដែលទទួលស្គាល់សំណងនៃការខូចខាតខាងផ្លូវចិត្ត ។ សេចក្តីលម្អិតនៃការខូចខាតនេះនឹងត្រូវកំណត់ដោយតុលាការ ។

## មាត្រា ៤០១.- ទំហំនៃសំណងការខូចខាត

កូនបំណុលត្រូវសងការខូចខាត ដូចខាងក្រោមនេះ :

ក-ការខូចខាតដែលកើតមានឡើងជាធម្មតាចំពោះម្ចាស់បំណុល ដោយសារការមិនបានអនុវត្តកាតព្វកិច្ច ។

ខ-ការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេស បើគូភាគីនៃកិច្ចសន្យាអាចព្យាករបាននូវការខូចខាតនោះដែលនឹងអាចកើតឡើងនៅពេលធ្វើកិច្ចសន្យានោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីនៃកិច្ចសន្យា មិនបានគិតពិចារណាអំពីការខូចខាតពិសេសនោះ នៅពេលធ្វើ

កិច្ចសន្យា ។

គ-ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានឆន្ទៈល្មើស ឬដោយអំពើមិនស្មោះត្រង់ហួសហេតុ តុលាការអាចបង្គាប់ឱ្យកូនបំណុលសងផលប្រយោជន៍ដែលកូនបំណុលបានទទួលពីអំពើដែលជាការមិនអនុវត្តកាតព្វកិច្ច ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបាន ទោះបីមានបញ្ញត្តិក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះក៏ដោយ ។

(កំណត់)

មាត្រានេះចែងអំពី "ទំហំនៃសំណងការខូចខាត" ។ បញ្ញត្តិនេះមានចែងនូវក្របខ័ណ្ឌដើម្បីកំណត់ទំហំនោះ ប៉ុន្តែបញ្ហាថា តើការខូចខាតជាក់លាក់ណាត្រូវបានបញ្ចូលទៅក្នុងទំហំនៃសំណងនោះ នឹងត្រូវបានសម្រេចតាមករណីនីមួយ១ ដោយយុត្តិសាស្ត្រនាពេលអនាគត ។

ទី ១ "ការខូចខាតដែលកើតឡើងជាធម្មតា" ស្ថិតនៅក្នុងទំហំនៃសំណង ។ ជាធម្មតា ទាំងកូនបំណុល និងម្ចាស់បំណុល បានព្យាករជាមុនថា "ការខូចខាតកើតឡើងជាធម្មតា" អាចកើតឡើងក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ច ទើបភាគីទាំងពីរនេះបង្កើតកិច្ចសន្យា ដោយយកការដែលការខូចខាតនោះស្ថិតនៅក្នុងទំហំនៃសំណង មកធ្វើជាបុរេល័ក្ខខ័ណ្ឌ ។ ក្នុងករណីដែលអ្នកលក់នៃកិច្ចសន្យាលក់ទិញមិនអាចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនេះឱ្យទៅអ្នកទិញ ការបាត់បង់ផលប្រយោជន៍នៃការអនុវត្តដែលកើតឡើងចំពោះម្ចាស់បំណុល គឺជា "ការខូចខាតកើតឡើងជាធម្មតា" ។ ក្នុងករណីធម្មតា ការខូចខាតនេះនឹងត្រូវបានគណនាទៅតាមតម្លៃថ្លៃនៃវត្ថុដែលជាកម្មវត្ថុនៃការលក់ ។

"ការខូចខាតដែលកើតឡើងដោយសារកាលៈទេសៈពិសេស" គឺសំដៅលើការខូចខាតដែលភាគីមិនអាចព្យាករបាន ។ បានសេចក្តីថា មានតែក្នុងករណីដែលគូភាគីអាចព្យាករបាន នៅពេលធ្វើកិច្ចសន្យាប៉ុណ្ណោះ ដែលត្រូវក្លាយជាកម្មវត្ថុនៃសំណងការខូចខាត ។ ឧទាហរណ៍ បុគ្គលដែលធ្វើកិច្ចសន្យាជាមួយម្ចាស់វត្ថុសិល្បៈមួយដែលមានតម្លៃខ្ពស់ និងមានលក្ខណៈងាយបែក ដោយសន្យាដឹកជញ្ជូនវត្ថុសិល្បៈនោះ ព្យាករជាមុនថា ប្រសិនបើវត្ថុសិល្បៈដែលមានតម្លៃខ្ពស់នោះត្រូវបានបែកដោយសារភាពមិនត្រឹមត្រូវក្នុងការដឹកជញ្ជូន ការខូចខាតនឹងមានតម្លៃខ្ពស់ជាងវត្ថុសិល្បៈធម្មតា ។ ក្នុងករណីបែបនេះ ប្រសិនបើវត្ថុសិល្បៈទទួលការខូចខាតដោយសារកំហុសរបស់អ្នកដឹកជញ្ជូន នោះម្ចាស់វត្ថុសិល្បៈនោះអាចទាមទារឱ្យសងសំណងការខូចខាតដែលមានចំនួនទឹកប្រាក់ច្រើននោះ ដោយអះអាងថា ការខូចខាតនោះ ជា "សំណងការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេស" ។ ប៉ុន្តែ ដោយសារវាត្រូវចំណាយច្រើនក្នុងការដឹកជញ្ជូនវត្ថុសិល្បៈមានតម្លៃខ្ពស់នេះ ដោយយកចិត្តទុកដាក់កុំឱ្យបែកនោះ អ្នកដឹកជញ្ជូន ជាទូទៅ គិតបញ្ចូលនូវតម្លៃបន្ថែមចំពោះការដឹកជញ្ជូនបែបនេះ ។ ប្រសិនបើម្ចាស់វត្ថុសិល្បៈស្ទាក់ស្ទើរក្នុងការបង់ថ្លៃបន្ថែម និង មិនធ្វើកិច្ចសន្យាសម្រាប់រៀបចំការដឹកជញ្ជូនពិសេស ដោយដឹងនូវការតម្រូវឱ្យបង់ថ្លៃបន្ថែមនេះ វាបង្ហាញឱ្យឃើញថា ភាគីនៃកិច្ចសន្យា

ដឹងថា វត្ថុសិល្បៈនោះមានតម្លៃខ្ពស់ ប៉ុន្តែ គ្មានឆន្ទៈរៀបចំការដឹកជញ្ជូនពិសេស ហេតុដូច្នេះ ក្នុងករណីនេះ ភាគីនៃកិច្ច-សន្យា "មិនបានគិតពិចារណាអំពីការខូចខាតពិសេស" ដែលកើតឡើងដោយសារកាលៈទេសៈពិសេស ហើយអ្នកដឹក-ជញ្ជូនមិនចាំបាច់សងសំណងការខូចខាតមានតម្លៃខ្ពស់នេះទេ ។

ចំណុច គ ពង្រីកទំហំនៃសំណងការខូចខាត ក្នុងករណីដែលការមិនអនុវត្តកាតព្វកិច្ចកើតឡើង "ដោយមានឆន្ទៈព្យាបាទ ឬ ដោយអំពើមិនស្មោះត្រង់ហួសហេតុ" របស់កូនបំណុល ។ ឧទាហរណ៍ ភាគី A ដែលទទួលបញ្ញើភាគហ៊ុនរបស់អ្នកដទៃ ទទួលចំណេញតាមការលក់ភាគហ៊ុនរបស់ភាគី B ដោយគ្មានការអនុញ្ញាតពីភាគី B ហើយទិញភាគហ៊ុននោះមកវិញ ។ ក្នុងស្ថានភាពនេះ គ្មានការខូចខាតណាមួយកើតឡើងចំពោះម្ចាស់ហ៊ុន B ឡើយ ប៉ុន្តែ ភាគី A បានទទួលផលចំណេញដោយមិនត្រឹមត្រូវ ។ នៅក្រោមប្រព័ន្ធនៃសំណងការខូចខាតដែលបានកំណត់នៅក្នុងចំណុច ក និង ចំណុច ខ ភាគី A មិនប្រឈមទៅនឹងការទទួលខុសត្រូវឡើយ ។ វាក៏មិនអាចធ្វើទៅរួចដែរក្នុងការដោះស្រាយតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ។ ប្រសិនបើគ្មានបញ្ញត្តិណាដែលចែងអំពីចំណុចនេះ អំពើទាំងឡាយដែលមានលក្ខណៈដូចគ្នាទៅនឹងអំពើរបស់ភាគី A មិនអាចត្រូវបានទប់ស្កាត់ទេ ។ នៅក្នុងន័យនេះ ចំណុច គ នេះមានគោលបំណងយកផលប្រយោជន៍ដែលភាគី A បានទទួលមកជាកម្មវត្ថុនៃសំណងការខូចខាត ដោយចាត់ទុកផលប្រយោជន៍នោះថាជាការខូចខាត ។ ខ្លឹមសារជាក់ស្តែងនៃភាព "មិនស្មោះត្រង់ហួសហេតុ" មានភាពមិនច្បាស់លាស់ ប៉ុន្តែ ជាទូទៅ ជនណាដែលទទួលបញ្ញើនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ មានករណីយកិច្ចត្រូវគ្រប់គ្រងទ្រព្យសម្បត្តិនោះសម្រាប់អ្នកផ្ញើ ដោយសុចរិត ហេតុដូច្នេះ ក្នុងករណីដែលជននោះធ្វើសកម្មភាពដើម្បីបន្លំដោយគ្មានការយល់ព្រមពីអ្នកផ្ញើដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន នោះគួរតែសន្និដ្ឋានថា ជននោះ "មិនស្មោះត្រង់ហួសហេតុ" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៦ នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុន

## មាត្រា ៤០២.- ហេតុដែលនាំឱ្យបន្ថយសំណងនៃការខូចខាត

១-កាលបើការមិនបានអនុវត្តកាតព្វកិច្ច ឬ ការខូចខាតកើតឡើង ផ្នែកខ្លះត្រូវបានបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល តុលាការអាចបន្ថយនូវចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមកម្រិតនៃការបង្កនោះ ។

២-ក្នុងករណីដែលការខូចខាតបានកើនឡើង ដោយសារម្ចាស់បំណុលធ្វេសប្រហែសក្នុងការសម្រាលការខូចខាតនោះ តុលាការអាចបន្ថយចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមចំនួននៃការខូចខាតដែលម្ចាស់បំណុលអាចសម្រាលបាននោះ ។

(កំណត់)

មាត្រានេះចែងថា ករណីយកិច្ចត្រូវសងសំណងការខូចខាតរបស់កូនបំណុល ត្រូវបានកាត់បន្ថយ ក្នុងករណីដែលកំហុសរបស់ម្ចាស់បំណុលធ្វើឱ្យការខូចខាតកើតឡើង ឬ បណ្តាលឱ្យមានការខូចខាតកាន់តែធំ ។

កថាខណ្ឌទី ១ ពាក់ព័ន្ធនឹងករណីដែលកំហុសរបស់ម្ចាស់បំណុលបណ្តាលឱ្យការមិនអនុវត្តកាតព្វកិច្ច ឬ ការខូចខាតកើតឡើង ។ ឧទាហរណ៍ ក្នុងករណីអ្នកជម្ងឺដែលមានលក្ខណៈពិសេសចំពោះសុខភាព មិនបានជូនដំណឹងដល់វេជ្ជបណ្ឌិតអំពីលក្ខណៈពិសេស ហើយការព្យាបាលអ្នកជម្ងឺមិនទទួលបានជោគជ័យដោយសារប្រតិកម្មនៃថ្នាំស្ពឹក និង អ្នកជម្ងឺទទួលផលប៉ះពាល់ ។ ប្រសិនបើអ្នកជម្ងឺនោះបានជូនដំណឹងអំពីលក្ខណៈពិសេសនៃសុខភាពរបស់ខ្លួន ការព្យាបាលអាចទទួលបានជោគជ័យ ហេតុដូច្នេះ តុលាការអាចកាត់បន្ថយចំនួនទឹកប្រាក់នៃសំណងការខូចខាតដែលវេជ្ជបណ្ឌិតត្រូវសង ដោយពិចារណាទៅលើកម្រិតនៃកំហុសរបស់អ្នកជម្ងឺ ។

កថាខណ្ឌទី ២ ពាក់ព័ន្ធនឹងករណីដែលកំហុស (ការធ្វេសប្រហែស) របស់កូនបំណុលបានធ្វើឱ្យការខូចខាតមានទំហំកាន់តែធំ ។ ដោយហេតុថាការវះកាត់នៅមន្ទីរពេទ្យមិនបានទទួលជោគជ័យបណ្តាលមកពីកំហុសរបស់វេជ្ជបណ្ឌិត ការទទួលខុសត្រូវចំពោះការខូចខាតនេះគួរតែជាបន្ទុករបស់វេជ្ជបណ្ឌិត ។ ប៉ុន្តែ ប្រសិនបើអ្នកជម្ងឺមិនអនុវត្តតាមការណែនាំរបស់វេជ្ជបណ្ឌិត និង ខិតខំប្រឹងប្រែងហាត់ប្រាណពេលគាត់សម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ហើយកូនបំណុលនេះនឹងត្រូវស្នាក់នៅក្នុងមន្ទីរពេទ្យយូរជាងពេលធម្មតា នោះកូនបំណុលត្រូវទទួលបន្ទុកចំណាយរបស់មន្ទីរពេទ្យសម្រាប់រយៈពេលពន្យារនៃការស្នាក់នៅមន្ទីរពេទ្យ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤០៣.–** ការកំណត់ជាមុននូវចំនួននៃសំណង ជាអាទិ៍

១-ម្ចាស់បំណុល និង កូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីល័ក្ខខ័ណ្ឌ និង ចំនួនសំណងការខូចខាតបាន ។

២-ការសន្យាពិសេសដែលឱ្យកូនបំណុលរួចផុតជាមុនពីការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងររបស់ខ្លួន មិនមានអានុភាពឡើយ ។

៣-ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននោះបានទេ ។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគីទាំងសងខាងបានកំណត់ជាមុននោះ ច្រើនហួសហេតុពេក ឬ

តិចហួសហេតុពេក បើប្រៀបធៀបទៅនឹងការខូចខាតដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះ ទើបតុលាការអាចបន្ថែម ឬ បន្ថយនូវប្រាក់សំណងដែលបានកំណត់ជាមុនបាន ។

៤-ការកំណត់ជាមុននូវចំនួននៃសំណង មិនរារាំងការទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងគូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

(កំណត់)

ប្រព័ន្ធដែលម្ចាស់បំណុល និង កូនបំណុលព្រមព្រៀងគ្នាជាមុនអំពីសំណងនៃការខូចខាតចំពោះករណីនៃការមិនអនុវត្តកាតព្វកិច្ច ត្រូវបានហៅថា "ការកំណត់ជាមុននូវចំនួននៃសំណងការខូចខាត" ដែលបានចែងនៅក្នុងមាត្រានេះ ។ ដោយហេតុថា វាមានការលំបាកសម្រាប់ករណីមួយចំនួនក្នុងការបញ្ជាក់អំពីចំនួនទឹកប្រាក់នៃការខូចខាត ប្រសិនបើមានការព្រមព្រៀងជាមុនអំពីចំនួននៃសំណងការខូចខាត ម្ចាស់បំណុលអាចជៀសវាងការលំបាកនោះបាន ។ ម្យ៉ាងទៀត ចំពោះកូនបំណុល ប្រសិនបើមានការព្រមព្រៀងអំពីចំនួននៃសំណងការខូចខាតសមហេតុផលជាមុន ក៏អាចមានលទ្ធភាពត្រៀមខ្លួនចំពោះការបារម្ភថា មិនដឹងជាតុលាការតម្រូវឱ្យសងសំណងចំនួនប៉ុន្មាន ។ ក្រៅពី "ចំនួននៃសំណងការខូចខាត" ភាគីទាំងពីរ ក៏អាចបង្កើតការសន្យាពិសេសអំពីល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតបានដែរ ។ ឧទាហរណ៍ ភាគីនៃកិច្ចសន្យាលក់ទិញ អាចបង្កើតការសន្យាពិសេសដែលមានខ្លឹមសារថា ប្រសិនបើអ្នកលក់មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់ នោះអ្នកលក់ត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ទោះបីជាអ្នកលក់មានកំហុស ឬ គ្មានកំហុសក៏ដោយ ។ ចំពោះល័ក្ខខ័ណ្ឌនៃកំហុសក្នុងការមិនអនុវត្តកាតព្វកិច្ច មានវិវាទច្រើនដែលកើតឡើងដោយមានការអះអាងផ្ទុយគ្នារវាងភាគីអំពីការបំពេញ ឬ មិនបំពេញល័ក្ខខ័ណ្ឌនោះ ។ ភាគីទាំងឡាយដែលមានបំណងជៀសវាងបញ្ហានេះ អាចជ្រើសរើសយកការព្រមព្រៀងគ្នាទុកជាមុន អំពីល័ក្ខខ័ណ្ឌនៃសំណងនៃការខូចខាត ។

ការសន្យាពិសេសអំពីការអនុគ្រោះឱ្យរួចផុតពីការទទួលខុសត្រូវ ឬ ការសម្រាលបន្ថយការទទួលខុសត្រូវ គឺជាប្រភេទមួយនៃការសន្យាពិសេសដែលបានចែងនៅក្នុងកថាខណ្ឌទី ១ ផងដែរ ។ ប៉ុន្តែ ប្រសិនបើកូនបំណុលមានឥទ្ធិពលខ្លាំងលើម្ចាស់បំណុល នោះម្ចាស់បំណុលនឹងត្រូវប្រឈមមុខទៅនឹងការបង្ខំឱ្យធ្វើការសន្យាពិសេសស្តីពីការអនុគ្រោះឱ្យរួច

ផុតពីការទទួលខុសត្រូវដើម្បីផ្តល់ប្រយោជន៍ហួសហេតុដល់កូនបំណុល ។ វាមិនមែនជាបញ្ហាទេក្នុងការបង្កើតការសន្យាពិសេសដើម្បីលើកលែងការទទួលខុសត្រូវចំពោះកំហុសស្រាល ប៉ុន្តែ មាត្រានេះបញ្ញត្តថា ការសន្យាពិសេសដែលផ្តល់ការលើកលែងដល់កូនបំណុលពីការទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចដោយចេតនា ឬ កំហុសធ្ងន់ធ្ងរនោះមិនមានសុពលភាពឡើយ ។ ការសន្យាបែបនេះអាចចាត់ទុកជាមោឃៈ ដោយយកភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ មកធ្វើជាមូលហេតុបានដែរ ប៉ុន្តែ ដោយហេតុថា សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អនេះគ្មានមាត្រដ្ឋានច្បាស់លាស់ទេ ដូច្នេះ មាត្រានេះចែងយ៉ាងច្បាស់ថា ការសន្យាបែបនេះត្រូវចាត់ទុកជាមោឃៈ ។

កថាខណ្ឌទី ៣ ចែងថា តុលាការមិនអាចបន្ថែម ឬ បន្ថយចំនួននៃសំណងការខូចខាតដែលត្រូវបានកំណត់ជាមុនទេ ។ ដោយហេតុថា បញ្ញត្តិនៅក្នុងមាត្រានេះមានគោលបំណងជៀសវាងនូវវិវាទដែលមិនចាំបាច់ទៅលើទំហំនៃការខូចខាត វាមិនមែនជាការត្រឹមត្រូវនោះទេដែលអនុញ្ញាតឱ្យចៅក្រមណាម្នាក់ធ្វើការផ្លាស់ប្តូរទំហំនៃការខូចខាតនេះ នៅពេលដែលរឿងក្តីនេះ ត្រូវបានបញ្ជូនទៅតុលាការ ។ វិធានការដូចគ្នានេះត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់របស់បណ្តាប្រទេសជាច្រើន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០៤.- គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

(កំណត់)

មាត្រានេះមានគោលបំណងបង្ហាញអំពីគោលការណ៍នៃការសងការខូចខាតជាប្រាក់។ ច្បាប់ខ្លះនៅតាមបណ្តាប្រទេសមួយចំនួនអនុវត្តតាមទស្សនៈនៃសំណងការខូចខាតដោយបដិទានទៅសភាពដើម។ យោងតាមទស្សនៈនេះ ប្រសិនបើជនណាម្នាក់បានធ្វើឱ្យបែកវត្ថុ នោះជននោះត្រូវតម្រូវឱ្យធ្វើសំណងការខូចខាតចំពោះវត្ថុនោះ ដោយធ្វើការជួសជុលវត្ថុនោះ។ ប្រសិនបើជនណាម្នាក់បានធ្វើឱ្យវត្ថុនោះប្រឡាក់ ជននោះត្រូវតម្រូវឱ្យសងសំណងការខូចខាតដោយធ្វើការសំអាតវត្ថុនោះ ។ ប៉ុន្តែ ទោះបីជាក្នុងករណីនេះក៏ដោយ វាមានភាពងាយស្រួលក្នុងការទាមទារឱ្យពួកគេបង់ថ្លៃជាទឹកប្រាក់ទៅលើការចំណាយជួសជុល ឬ សំអាតវត្ថុនោះ ។ ដូច្នេះហើយ គោលកាណ៍នៃការសងសំណងខូចខាតជាទឹកប្រាក់ត្រូវបានយកមកអនុវត្ត ។

ទោះបីជាយ៉ាងនេះក៏ដោយ ប្រសិនបើភាគីពាក់ពន្ធ័ទាំងអស់ព្រមព្រៀងទៅលើវិធីផ្សេងពីការសងជាប្រាក់ វិធីនោះ

ក៏ត្រូវបានអនុញ្ញាតដែរ ។

ចំពោះបញ្ហាដូចជាការខូចខាតដល់បរិស្ថាន ជាអាទិ៍ ការសងសំណងការខូចខាតដោយការធ្វើបដិទាន មានតួនាទីដ៏សំខាន់ ។ ប៉ុន្តែ ទស្សនៈនេះនឹងចែងនៅក្នុងច្បាប់ ឬ វិធានដោយឡែក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០៥.- ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

(កំណត់)

មាត្រានេះចែងអំពីប្រព័ន្ធផ្តល់នូវសមភាពនៃផលប្រយោជន៍រវាងភាគីដែលសងសំណងការខូចខាត និង ភាគីដែលទទួលសំណងការខូចខាតនេះ ។

ឧទាហរណ៍ ក្នុងករណីដែលអ្នកទទួលបញ្ញើដែលថែរក្សាថូដែលជាកម្មសិទ្ធិរបស់អ្នកផ្ញើ ដោយផ្អែកលើកិច្ចសន្យាបញ្ញើបានធ្វើឱ្យបែកថូនោះ ដោយកំហុសក្នុងការគ្រប់គ្រង នោះអ្នកទទួលបញ្ញើត្រូវសងសំណងការខូចខាតជាទឹកប្រាក់ស្មើទៅនឹងតម្លៃនៃថូ ។ ហើយប្រសិនបើអ្នកផ្ញើទទួលបានសំណងជាទឹកប្រាក់ស្មើនឹងតម្លៃនៃថូ កម្មសិទ្ធិលើថូបែកនឹងត្រូវផ្ទេរទៅអ្នកទទួលបញ្ញើដែលសងសំណងការខូចខាត ។ អ្នកទទួលបញ្ញើនោះអាចយកថូដែលបែកនេះទៅជួសជុល និង ធ្វើជាកម្មសិទ្ធិករនៃថូនេះ ។

ម្យ៉ាងទៀត ក្នុងករណីដែលថូត្រូវបានបែកដោយអំពើអនីត្យានុកូលរបស់តតិយជន នៅពេលដែលអ្នកទទួលបញ្ញើកំពុងគ្រប់គ្រង ប្រសិនបើអ្នកទទួលបញ្ញើបានសងសំណងនៃការខូចខាតទៅឱ្យអ្នកផ្ញើ ដោយយកកំហុសក្នុងការគ្រប់គ្រងមកធ្វើជាមូលហេតុ សិទ្ធិទាមទារឱ្យសងសំណងការខូចខាតចំពោះតតិយជនដែលបានធ្វើឱ្យបែកថូដោយផ្ទាល់ នឹងត្រូវផ្ទេរពីអ្នកផ្ញើដែលជាកម្មសិទ្ធិករដើមនៃថូ ទៅអ្នកទទួលបញ្ញើដែលបានសងសំណងការខូចខាតនេះ ។ អ្នកទទួលបញ្ញើដែលបានទទួលការផ្ទេរសិទ្ធិនោះ អាចទាមទារឱ្យចារីសងសំណងការខូចខាតបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០៦.- អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

(កំណត់)

មាត្រានេះចែងអំពីពេលចាប់ផ្ដើមគណនា និង អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងខូចខាតដែលបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ច ។

នៅពេលដែលការមិនអនុវត្តកាតព្វកិច្ចណាមួយកើតមានឡើង ម្ចាស់បំណុលអាចអនុវត្តវិធីសង្គ្រោះជាច្រើន ដូចជាការទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាត និង ការរំលាយកិច្ចសន្យា ជាអាទិ៍ ។ ចំពោះវិធីសង្គ្រោះនីមួយៗ អំឡុងពេលនៃអាជ្ញាយុកាល ចាំបាច់ត្រូវបានពិចារណា ។ បញ្ញត្តិនៅក្នុងមាត្រានេះចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងការខូចខាត ។

អំឡុងពេលនៃអាជ្ញាយុកាល អាចត្រូវបានគិតចាប់ពីពេលដែលមានការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែ វាគួរតែគិតបន្ទាប់ពីការចាប់ផ្ដើមកើតមានការខូចខាត ដោយហេតុថា ភាគីណាម្នាក់អាចទាមទារសំណងបានលុះត្រាតែការខូចខាតណាមួយកើតឡើង ។ ដូច្នេះហើយ អំឡុងពេលនៃអាជ្ញាយុកាលត្រូវបានគណនាចាប់ពីពេលដែលការខូចខាតកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.–** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃការរំលាយកិច្ចសន្យាដែលត្រូវយកចិត្តទុកដាក់ទៅលើកត្តាពីរចំណុច ។

ទី ១ ការរំលាយកិច្ចសន្យាអាចធ្វើទៅបានចំពោះតែកិច្ចសន្យាអញ្ញមញ្ញប៉ុណ្ណោះ ដោយសារការរំលាយកិច្ចសន្យាគឺជាប្រព័ន្ធដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ដោយយកការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុ ។ ឧទាហរណ៍ ក្នុងករណីអ្នកលក់ A និង អ្នកទិញ B បានចុះកិច្ចសន្យាលក់ទិញដីមួយកន្លែង ប្រសិនបើអ្នកទិញមិនបានបង់ថ្លៃលក់ អ្នកលក់អាចនឹងស្វែងរកអ្នកទិញដីនេះផ្សេងទៀត ។ ប៉ុន្តែ ប្រសិនបើអ្នកលក់ដីមិនរំលត់កាតព្វកិច្ចប្រគល់ដីដែលខ្លួនមានតាមកិច្ចសន្យាលក់ទិញ ដោយរំលាយកិច្ចសន្យាលក់ទិញដីនេះ អ្នកលក់ A ត្រូវទទួល

ខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច នៅពេលដែលអ្នកទិញ B ស្នើផ្តល់ថ្លៃលក់នៅពេលក្រោយវិញ ។ ដូច្នេះហើយ វាជាការចាំបាច់ចំពោះអ្នកលក់ដែលត្រូវរំលាយកិច្ចសន្យាជាមុនសិន មុននឹងស្វែងរកអ្នកទិញផ្សេងទៀត ។ អាស្រ័យហេតុនេះ ចំពោះកិច្ចសន្យាឯកតោភាគី (កិច្ចសន្យាដែលភាគីតែម្ខាងមានកាតព្វកិច្ច) ដូចជាកិច្ចសន្យាប្រទានកម្ម មិនចាំបាច់ទទួលស្គាល់ការរំលាយទេ ។ ម្ចាស់បំណុលនៃកិច្ចសន្យាប្រទានកម្ម គ្មានផលប្រយោជន៍ក្នុងការរំលាយកិច្ចសន្យានោះទេ ក្នុងករណីដែលទាយកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។

ទី ២ បញ្ញត្តិនៃមាត្រានេះតម្រូវឱ្យមានមិនគ្រាន់តែការមិនអនុវត្តកាតព្វកិច្ចទេ គឺឱ្យមាន "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" ជាល័ក្ខខ័ណ្ឌដើម្បីរំលាយកិច្ចសន្យា ។ នេះគឺជានិន្នាការដែលអនុវត្តទូទាំងពិភពលោក ។ ដោយហេតុថាការរំលាយកិច្ចសន្យានេះ គឺជាឧបករណ៍ដ៏មានឥទ្ធិពលដែលទទួលស្គាល់ឱ្យភាគីម្ខាងនៃកិច្ចសន្យាអាចបដិសេធចោលនូវកិច្ចសន្យាដោយឯកឯង ដូច្នេះ វាមិនសមហេតុផលទេក្នុងការអនុញ្ញាតឱ្យភាគីម្ខាងរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តកាតព្វកិច្ចបន្តិចបន្តួច ។ ដូច្នេះហើយ ការរំលាយកិច្ចសន្យាអាចធ្វើទៅបាន តែក្នុងករណីដែលមាន "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ខុសគ្នានឹងករណីនៃសំណងការខូចខាត ការរំលាយកិច្ចសន្យាមិនតម្រូវឱ្យមានកំហុសរបស់កូនបំណុលទេ។ ការចែងបែបនេះគឺយោងទៅតាមនិន្នាការថ្មីៗនៅក្នុងពិភពលោក ដូចជាអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ច-សន្យាលក់ទំនិញអន្តរជាតិ និង គោលការណ៍នៃច្បាប់កិច្ចសន្យាពាណិជ្ជកម្មអឺរ៉ុប ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤១ និង មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០៨.- ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

១-ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត ។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ :

ក- ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ។

ខ-ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ ។

គ-ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ។

ឃ-ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ។

២-ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន បានឡើយ ។

(កំណត់)

មាត្រានេះកំណត់អំពី "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" ដែលជាល័ក្ខខ័ណ្ឌនៃការរំលាយកិច្ចសន្យា ។

ការរំលាយកិច្ចសន្យា មិនមែនជាការដាក់ទណ្ឌកម្មប្រឆាំងទៅនឹងភាគីជាដៃគូដែលខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ប៉ុន្តែ គឺជាប្រព័ន្ធដែលផ្តាច់ចំណងនៃកិច្ចសន្យាអញ្ចឹមញ្ចឹ នៅពេលដែលគោលបំណងក្នុងការបង្កើតកិច្ចសន្យានោះ មិនអាចសម្រេចបានដោយសារមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ហើយដែលយល់ឃើញថា ការបន្តឱ្យមានចំណងនៃកិច្ចសន្យាអញ្ចឹមញ្ចឹនោះ គ្មានភាពសមហេតុសមផល ។ យោងតាមឧទាហរណ៍នៅក្នុងមាត្រា ៤០៧ ខាងលើ ប្រសិនបើអ្នកទិញមិនបង់ថ្លៃលក់ អ្នកលក់មិនអាចសម្រេចគោលបំណងនៃការចុះកិច្ចសន្យាលក់ទិញនេះទេ ។ លើសពីនេះ ប្រសិនបើចំណងនៃកិច្ចសន្យាបន្តមានអានុភាព អ្នកលក់ក៏មិនអាចលក់វត្ថុនេះឱ្យទៅអ្នកផ្សេងទៀតបានឡើយ ។ ក្នុងករណីដែលមាន "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" នោះគ្មានសង្ឃឹមថា ភាគីម្ខាងទៀតនឹងអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយវាជាការមិនសមស្របក្នុងការរក្សាទំនាក់ទំនងកិច្ចសន្យាឱ្យនៅមានអានុភាព ហេតុដូច្នេះ ច្បាប់អនុញ្ញាតឱ្យរំលាយកិច្ចសន្យា ។

ដូច្នេះហើយ ចំពោះសកម្មភាព ឬ អសកម្មភាពដែលនឹងត្រូវចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនោះ ត្រូវកំណត់ អនុលោមតាមអង្គហេតុថា តើករណីនោះជា "ករណីដែលគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបានទេ" ឬមិនមែន ។ ករណីដែលត្រូវបានយល់ឃើញថាជា "ករណីដែលគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបានទេ" ត្រូវបានរៀបរាប់ចាប់ពីចំណុច ក ដល់ ចំណុច ឃ នៃកថាខណ្ឌទី ១ ។ ហេតុទាំងនេះត្រូវបានចាត់ទុកថាជា "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" ។ ចំណុច ក គឺជាករណីដែលភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច ប៉ុន្តែ ភាគីម្ខាងទៀត នៅតែមិនអនុវត្តកាតព្វកិច្ច ទោះបីជាខ្លួនត្រូវបានដាស់តឿនដូច្នេះក៏ដោយ ។ ចំណុច ខ ទាក់ទងនឹងករណីដែលហៅថា សកម្មភាពកំណត់ពេលវេលាពិសេស ។ ឧទាហរណ៍ ក្នុងករណីដែលភាគីម្ខាងសុំឱ្យជាងកាត់ដេរកាត់សម្លៀកបំពាក់សម្រាប់ចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ ប៉ុន្តែ ជាងកាត់ដេរសម្លៀកបំពាក់ខកខានមិនបានធ្វើតាមពេលវេលាកំណត់ នោះភាគីមានសិទ្ធិរំលាយកិច្ចសន្យានេះនៅពេលដែលភាគីនោះរកឃើញថា ជាងកាត់ដេរមិនអាចកាត់សម្លៀកបំពាក់ឱ្យរួចស្រេចទាន់ពេលកំណត់ ដោយហេតុថា ភាគីនោះគ្មានអត្ថប្រយោជន៍ក្នុងការទទួលការអនុវត្តកាតព្វកិច្ច

នៅក្រោយពេលពិធីរៀបអាពាហ៍ពិពាហ៍ ។ ប្រភេទនៃការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនេះអាចត្រូវបានហៅថា "អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលា" ។ ចំណុច គ គឺជាករណីនៃអលទ្ធភាពក្នុងការអនុវត្ត ។ ចំណុច ឃ ចែងអំពីការរំលាយកិច្ចសន្យាដោយមូលហេតុនៃការបាត់បង់នូវទំនុកចិត្ត ។ ឧទាហរណ៍ ក្នុងករណីកិច្ចសន្យាផ្គត់ផ្គង់គ្រឿងសម្រាប់ផលិតផលណាមួយ ប្រសិនអ្នកផ្គត់ផ្គង់យឺតយ៉ាវម្តងហើយម្តងទៀតក្នុងការផ្គត់ផ្គង់គ្រឿងនោះ ហើយតាមការជាក់ស្តែងមានការយឺតយ៉ាវច្រើនហួសហេតុ នោះមានករណីខ្លះដែលសកម្មភាពរបស់អ្នកផ្គត់ផ្គង់នេះនឹងត្រូវចាត់ទុកថាជាអំពើធ្វើឱ្យបាត់បង់ទំនាក់ទំនងជឿទុកចិត្ត ។ ទោះបីជាការយឺតយ៉ាវម្តងមិនចាត់ទុកថាមានភាពធ្ងន់ធ្ងរក៏ដោយ ប្រសិនបើករណីទាំងមូលនៃការបំពានតូចតាចនេះ អាចត្រូវបានយល់ឃើញថា "ការបំពានកិច្ចសន្យាមានភាពហួសហេតុ" នោះការរំលាយកិច្ចសន្យាត្រូវបានអនុញ្ញាតដែរ។ ម្យ៉ាងទៀត ទោះបីជាករណីណាមួយមិនស្ថិតនៅក្នុងករណីនៃការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីចំណុច ក ដល់ចំណុច ឃ ក៏ដោយ ក៏តុលាការអាចទទួលស្គាល់ថា មាន "ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ" អាស្រ័យទៅតាមស្ថានការណ៍បានដែរ ។ ចំណុចនេះទុកឱ្យបកស្រាយតាមយុត្តិសាស្ត្រ នាពេលអនាគត ។

កាថាខណ្ឌទី ២ បញ្ជាក់ថា កំហុសរបស់កូនបំណុលមិនមែនជាល័ក្ខខ័ណ្ឌសម្រាប់ការរំលាយកិច្ចសន្យាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤១ និង មាត្រា ៥៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤០៩.- វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

១-ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន ។

២-ការបង្ហាញឆន្ទៈរំលាយនេះ មិនអាចដកវិញបានទេ ។

៣-ការបង្ហាញឆន្ទៈរំលាយនេះ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ។

(កំណត់)

មាត្រានេះចែងអំពីវិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ។ សិទ្ធិរំលាយនេះត្រូវកើតឡើង ប្រសិនបើល័ក្ខខ័ណ្ឌសម្រាប់ការរំលាយកិច្ចសន្យាដែលបានចែងនៅក្នុងមាត្រា ៤០៧ និង មាត្រា ៤០៨ ត្រូវបានបំពេញ ។ ជាដំបូង មាត្រានេះចែងថា ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈរំលាយ ។ ស្របតាមគោលការណ៍ទូទៅនៃការបង្ហាញឆន្ទៈ ការបង្ហាញឆន្ទៈរំលាយនេះ ត្រូវមានអានុភាពនៅពេលដែលការបង្ហាញឆន្ទៈនោះបានដល់ភាគីម្ខាងទៀត ។

ទី ២ កាបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើឡើងនៅក្រៅតុលាការបាន ។ តាមច្បាប់បារាំង ការរំលាយតម្រូវឱ្យ

មានសេចក្ដីសម្រេចរបស់តុលាការ ប៉ុន្តែ មាត្រានេះចែងថា ការរំលាយអាចធ្វើឡើងបានដោយការបង្ហាញឆន្ទៈក្រៅតុលាការ ដោយហេតុថា វាជាការលំបាកក្នុងការសុំឱ្យតុលាការចេញសេចក្ដីសម្រេចនៅគ្រប់ពេលដែលភាគីម្ខាងមានបំណងរំលាយកិច្ចសន្យា ទោះបីជាភាគីនេះពុំមានវិវាទធ្ងន់ធ្ងរជាមួយភាគីម្ខាងទៀតក៏ដោយ ។ ប្រសិនបើការរំលាយកិច្ចសន្យានៅក្រៅតុលាការអាចធ្វើទៅបាន វិវាទនេះនឹងអាចដោះស្រាយបានដរាបណាភាគីម្ខាងទៀតគ្មានបំណងជំទាស់ ហើយប្រសិនបើភាគីម្ខាងមិនព្រមទទួលការរំលាយកិច្ចសន្យានេះ ភាគីដែលបានរំលាយកិច្ចសន្យានោះ នឹងប្ដឹងទៅតុលាការដើម្បីទាមទារសេចក្ដីសម្រេច ។

មាត្រានេះទាក់ទងនឹងការរំលាយកិច្ចសន្យាដោយយកការមិនអនុវត្តកាតព្វកិច្ចមកធ្វើជាមូលហេតុ ។ ក្រៅពីនេះករណីមួយចំនួនដែលមានលក្ខណៈស្រដៀងគ្នានេះ រួមមាន (១) ករណីដែលសិទ្ធិរំលាយកិច្ចសន្យាត្រូវបានផ្ដល់ឱ្យទៅភាគីម្ខាង ឬ ភាគីសងខាងតាមកិច្ចសន្យា និង (២) ករណីដែលភាគីពាក់ព័ន្ធព្រមព្រៀងគ្នារំលាយកិច្ចសន្យា ។ ករណីទី (១) ហៅថា "សិទ្ធិរំលាយដែលកំណត់ក្នុងកិច្ចសន្យា" ពីព្រោះសិទ្ធិនេះផ្ដល់ដោយកិច្ចសន្យា ។ ឧទាហរណ៍ ចំពោះកិច្ចសន្យាបន្តរយៈពេលវែង អាចមានខសន្យាដែលចែងថា "ក្នុងស្ថានការណ៍ផ្នែកសេដ្ឋកិច្ចមានការផ្លាស់ប្ដូរ ភាគីទាំងសងខាងអាចរំលាយកិច្ចសន្យា ដោយធ្វើសេចក្ដីជូនដំណឹងជាមុនរយៈពេល ៦ ខែ" ។ ក្នុងករណីនេះ ភាគីពាក់ព័ន្ធនឹងបង្ហាញឆន្ទៈក្នុងការប្រើប្រាស់សិទ្ធិរំលាយកិច្ចសន្យា ហេតុដូច្នេះ មាត្រានេះអាចយកមកអនុវត្តដោយសទិសភាពចំពោះករណីនេះបាន ។ ករណីទី (២) គឺជាករណីដែលគ្មានការសន្យាជាមុនអំពីសិទ្ធិរំលាយក្នុងកិច្ចសន្យាទេ ប៉ុន្តែ ការរំលាយកិច្ចសន្យាត្រូវបានធ្វើឡើងដោយកិច្ចសន្យា ។ ចំពោះករណីនេះ គ្មានលទ្ធភាពក្នុងការអនុវត្តមាត្រានេះដោយសទិសភាពទេ ។ សម្រាប់សេចក្ដីពន្យល់លម្អិត សូមមើលមាត្រា ៤១៤ ។

កថាខណ្ឌទី ២ មិនអនុញ្ញាតឱ្យដកការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ដោយហេតុថា អាចកើតឡើងនូវភាពច្របូកច្របល់ដែលមិនចាំបាច់ ប្រសិនបើអនុញ្ញាតឱ្យមានការដក និង កិច្ចសន្យាដែលត្រូវបានរំលាយហើយនោះ ប្រែក្លាយទៅជាមានអានុភាពឡើងវិញ ។ ប៉ុន្តែ គោលការណ៍ទូទៅនៃការបង្ហាញឆន្ទៈត្រូវយកមកអនុវត្ត ចំពោះការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ហេតុដូច្នេះ ការរំលាយកិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ឬ ការរំលាយដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាការភាន់ច្រឡំ ឬ ការគម្រាមកំហែង ជាអាទិ៍ អាចត្រូវបានលុបចោលនៅពេលក្រោយ ។

កថាខណ្ឌទី ៣ ចែងថា ការបង្ហាញឆន្ទៈរំលាយអាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ដោយសារការអាចធ្វើដូច្នេះមានលក្ខណៈងាយស្រួល ។ ឧទាហរណ៍ ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ហើយភាគីម្ខាងទៀតដាស់តឿនឱ្យអនុវត្តកាតព្វកិច្ចដោយកំណត់ពេលជាក់លាក់ដើម្បីអនុវត្ត មានករណីច្រើនដែលភាគីម្ខាងទៀតនោះបង្ហាញឆន្ទៈថា "នឹងរំលាយកិច្ចសន្យា ប្រសិនបើមិនអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលកំណត់នោះ" ។ ឧទាហរណ៍នេះ គឺជាករណីដែលភ្ជាប់ល័ក្ខខ័ណ្ឌបង្អង់ចំពោះការបង្កើតអានុភាពនៃការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤១០.-** ការរំលាយកិច្ចសន្យាដែលភាគីម្ខាងមានច្រើននាក់

១-ក្នុងករណីដែលភាគីម្ខាងមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយបុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់ សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ ។

(កំណត់)

ក្នុងករណីភាគីម្ខាងនៃកិច្ចសន្យាមានចំនួនលើសពីម្នាក់ វានឹងមានភាពស្មុគស្មាញ និង មិនសមហេតុផល ប្រសិនបើការរំលាយកិច្ចសន្យាធ្វើឡើងសម្រាប់អ្នកមួយចំនួន ប៉ុន្តែ វាគ្មានអានុភាពចំពោះអ្នកដទៃទៀតក្នុងចំណោមភាគីម្ខាងនេះ។ ដូច្នេះហើយ ទស្សនះស្តីពី "អវិភាគភាពនៃសិទ្ធិរំលាយកិច្ចសន្យា" ត្រូវបានយកមកអនុវត្ត ។ មានករណីដែលភាគីរំលាយកិច្ចសន្យា មានច្រើននាក់ និង ករណីដែលការរំលាយកិច្ចសន្យាធ្វើឡើងចំពោះភាគីម្ខាងទៀតដែលមានគ្នាច្រើនជាងម្នាក់។ មាត្រានេះត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីទាំងពីរ ។

ឧទាហរណ៍ ក្នុងករណីដែលភាគីរំលាយកិច្ចសន្យាមានគ្នាច្រើននាក់ ប្រសិនបើអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយត្រូវបានសម្រេចចំពោះជនម្នាក់ក្នុងចំណោមភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា មិនមែនតែជនម្នាក់នេះទេ ដែលមិនអាចអនុវត្តសិទ្ធិរំលាយ គឺសិទ្ធិរំលាយរបស់ជនដទៃទៀតទាំងអស់ក្នុងចំណោមភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ ។ បញ្ញត្តិបែបនេះត្រូវបានរៀបចំដោយផ្អែកលើទស្សនះយល់ឃើញថា រាល់កិច្ចសន្យាទាំងឡាយដែលបានព្រមព្រៀងគ្នារួចគួរតែត្រូវបានរក្សាទុក ប្រសិនបើអាចធ្វើទៅបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤១១.-** អានុភាពនៃការរំលាយកិច្ចសន្យា

១-ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។

២-ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមាន

ករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា ។

៣-ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬ ជាតាវកាលិកផ្សេងដែលខ្លួនបានទទួល ទៅភាគីម្ខាងទៀតដោយសារការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះផងដែរ ។

៤-ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពផ្សេងៗដែលកើតចេញពីការរំលាយកិច្ចសន្យា ។

កថាខណ្ឌទី ១ ចែងថា ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ចំណងកិច្ចសន្យានេះនឹងត្រូវរលត់ ។ ការរំលាយកិច្ចសន្យានឹងរំលត់រាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និង នាំឱ្យភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះ ។ ប៉ុន្តែ ក្នុងករណីរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តកាតព្វកិច្ច នោះករណីយកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ច នៅតែមានអានុភាព ។ ហេតុដូច្នេះហើយ ឃ្លា "លើកលែងតែកាតព្វកិច្ចសងការខូចខាត" មានចែងនៅក្នុងបញ្ញត្តិនេះ ។

កថាខណ្ឌទី ២ ចែងអំពីករណីយកិច្ចធ្វើបដិទានដែលបណ្តាលមកពីការរំលាយកិច្ចសន្យា និង ទំនាក់ទំនងជាមួយនឹងការអនុវត្តករណីយកិច្ចនេះនៅពេលជាមួយគ្នា ។

កថាខណ្ឌទី ៣ ចែងអំពីទំហំនៃករណីយកិច្ចធ្វើបដិទាន ។ ក្រៅពីតាវកាលិក (ប្រាក់) ដែលខ្លួនបានទទួល ភាគីត្រូវសងទៅវិញទៅមកផងដែរ នូវការប្រាក់នៃប្រាក់ដែលបានទទួល និង ផលប្រយោជន៍ទាំងឡាយបានមកពីការប្រើតាវកាលិកដែលបានទទួល ។ ឧទាហរណ៍ ចំពោះកិច្ចសន្យាលក់ទិញរថយន្ត អ្នកលក់បានប្រគល់រថយន្តដល់អ្នកទិញ ប៉ុន្តែអ្នកទិញបង់ថ្លៃទិញរថយន្តតែពាក់កណ្តាល ដូច្នេះហើយអ្នកលក់បានរំលាយកិច្ចសន្យាលក់វិញ ។ ក្នុងករណីនេះ អ្នកទិញត្រូវប្រគល់វិញទាំងរថយន្ត និង ទឹកប្រាក់ដែលមានតម្លៃស្មើនឹងថ្លៃជួលរថយន្តសម្រាប់រយៈពេលដែលអ្នកទិញ បានប្រើប្រាស់រថយន្តនេះ ដែលជា "ផលប្រយោជន៍បានមកពីវត្ថុនោះ" ។ ចំពោះអ្នកលក់វិញ ដោយហេតុថា កិច្ចសន្យាត្រូវបានរំលាយ អ្នកលក់នោះ ត្រូវសងវិញនូវទឹកប្រាក់ពាក់កណ្តាលដែលខ្លួនបានទទួលពីអ្នកទិញ ហើយជាមួយគ្នានេះ អ្នកលក់ក៏ត្រូវសងការប្រាក់ គិតចាប់ពីពេលដែលខ្លួនបានទទួលទឹកប្រាក់ពាក់កណ្តាលនេះ ។

កថាខណ្ឌទី ៤ ចែងថា ក្នុងករណីដែលមានតតិយជនដែលមានទំនាក់ទំនងនៃផលប្រយោជន៍ អានុភាពនៃការរំលាយ

កិច្ចសន្យាមិនធ្វើឱ្យមានឥទ្ធិពលដល់តតិយជនឡើយ ។ ប៉ុន្តែ វាមានការលំបាកក្នុងការកំណត់និយមន័យនៃតតិយជនដែលទទួលបាននូវការការពារតាមមាត្រានេះ ។ ឧទាហរណ៍ថា អ្នកលក់ A និងអ្នកទិញ B បានចុះកិច្ចសន្យាលក់ទិញដីជាមួយគ្នា ដែលអ្នកទិញ B នឹងបង់ថ្លៃលក់ដីជាវគ្គ ហើយបានចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិឱ្យទៅអ្នកទិញ B ។ ប៉ុន្តែ អ្នកទិញ B ខកខានក្នុងការបង់ថ្លៃលក់ ហើយអ្នកលក់ A រំលាយកិច្ចសន្យានេះ ។ បញ្ហាកើតមានឡើងនៅពេលដែលអ្នកទិញ B បានលក់ដីនេះបន្ត ឬ ឱ្យជួលដីនេះ ឱ្យទៅតតិយជន C មុនពេលអ្នកលក់ A បង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ ។ កម្មសិទ្ធិលើដីដែលបានផ្ទេរទៅអ្នកទិញ B នឹងត្រូវត្រឡប់មកអ្នកលក់ A វិញដោយសារការរំលាយកិច្ចសន្យា ហេតុដូច្នេះអ្នកទិញ B ត្រូវបាត់បង់កម្មសិទ្ធិនេះ ។ គ្មានបញ្ហាណាមួយកើតឡើងទេ ត្រង់ចំណុចនេះ ។ បញ្ហាគឺជាការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអានុភាពប្រតិសកម្មនៃការរំលាយ ។ ដោយហេតុថា នេះគឺជាបញ្ហាដែលមានលក្ខណៈទ្រឹស្តីស្មុគស្មាញ បញ្ហានេះត្រូវបានទុកឱ្យដោះស្រាយតាមយុត្តិសាស្ត្រនាពេលអនាគត ដោយមិនចែងនៅក្នុងក្រមរដ្ឋប្បវេណី ។ នាពេលនេះ មានការពន្យល់មួយចំនួនអំពីភាពខុសគ្នារវាងករណីដែលទទួលស្គាល់អានុភាពប្រតិសកម្ម និង ករណីដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មនៃការរំលាយ ។

ទស្សនៈឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យាមានដូចខាងក្រោម ។ ប្រសិនបើការរំលាយមានអានុភាពប្រតិសកម្ម អ្នកទិញ B មិនមែនជាកម្មសិទ្ធិករនៃដី "តាំងពីដំបូង" ដោយសារការរំលាយ ។ ហេតុនេះហើយ តតិយជន C ត្រូវបានចាត់ទុកថា បានទិញដីពីអ្នកទិញ B ដែលមិនមានកម្មសិទ្ធិលើដីនេះ ដូច្នេះ តតិយជន C មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះបានទេ ។ ប៉ុន្តែ ក្នុងករណីដែលតតិយជន C បានចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិរួចហើយ ប្រសិនបើតតិយជន C មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះដោយសារការរំលាយដោយអ្នកលក់ A នោះតតិយជន C នឹងទទួលការខូចខាតដែលខ្លួនមិនអាចព្យាករទុកជាមុនបាន ហើយមានការរងគ្រោះធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់តតិយជន C ដែលបានធ្វើប្រតិបត្តិការដោយជឿទុកចិត្តលើការចុះបញ្ជីកម្មសិទ្ធិរបស់ B ។ ដូច្នេះហើយ នៅក្នុងករណីនេះ អាចបកស្រាយថាតតិយជន C ត្រូវទទួលការការពារ ប្រសិនបើ C បានចុះបញ្ជីអំពីការផ្ទេរ ហើយមិនបានដឹងថា អ្នកទិញ B មិនទាន់បញ្ចប់ការបង់ថ្លៃលក់ដី ឱ្យទៅអ្នកលក់ A ។ ប៉ុន្តែ តើគួរតែការពារតតិយជន C ក្នុងករណីដែល C បានចុះបញ្ជីតែមានភាពទុច្ចរិត ឬ គួរតម្រូវឱ្យមានភាពសុចរិត ដើម្បីទទួលការការពារ ឬ តម្រូវឱ្យមានភាពគ្មានកំហុស ? បញ្ហាទាំងនេះនឹងត្រូវទុកឱ្យដោះស្រាយតាមយុត្តិសាស្ត្រនាពេលអនាគត ។ ហេតុដូច្នេះ បញ្ញត្តិនៃមាត្រានេះចែងថា មិនអាចធ្វើឱ្យខូច "ផលប្រយោជន៍ត្រឹមត្រូវ" របស់តតិយជនបានឡើយ ។

តាមទស្សនៈដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មនៃការរំលាយ ទោះបីជាអ្នកលក់ A រំលាយកិច្ចសន្យាលក់ទិញក៏ដោយ ក៏អ្នកទិញ B មិនត្រូវបានចាត់ទុកថាគ្មានកម្មសិទ្ធិលើដីតាំងពីដំបូងទេ ប៉ុន្តែ នៅពេលអ្នកលក់ A បង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ កម្មសិទ្ធិនឹងត្រូវបង្វិលពីតតិយជន C មកឱ្យអ្នកលក់ A វិញ ។ ចំពោះការផ្ទេរបង្វិលកម្មសិទ្ធិក្នុងករណីនេះ ការចុះបញ្ជីគឺជាល័ក្ខខ័ណ្ឌតតាំងចំពោះអចលនវត្ថុ (មាត្រា ១៣៤) ។ ហេតុដូច្នេះ ទោះបីជាអ្នកលក់ A បានទទួលកម្មសិទ្ធិដីពីអ្នកទិញ B ដោយការរំលាយកិច្ចសន្យាក៏ដោយ ប្រសិនបើតតិយជន C បានចុះបញ្ជីអំពីការផ្ទេរ

មុនអ្នកលក់ A ចុះបញ្ជីអំពីការផ្ទេរបង្វិលនោះ តតិយជន C នឹងមានអាទិភាព ហើយអ្នកលក់ A មិនអាចទាមទារឱ្យលុបចោលការចុះបញ្ជីរបស់តតិយជន C បានឡើយ ។ វាហាក់ដូចជាសមស្របក្នុងការមិនអនុញ្ញាតឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា ដើម្បីធានានូវសុវត្ថិភាពក្នុងកិច្ចការជំនួញ ប៉ុន្តែ តាមទស្សនៈនេះ ទោះបីជាតតិយជន C ដឹងថាអ្នកទិញ B មិនទាន់បញ្ចប់ការបង់ថ្លៃលក់ដីក៏ដោយ ក៏ C នៅតែមានអាទិភាពជាង A ដែរ ប្រសិនបើ C បានចុះបញ្ជីមុន ។ ទោះជាយ៉ាងនេះក្តី ដោយហេតុថា មាត្រានេះប្រើពាក្យថា "ផលប្រយោជន៍ត្រឹមត្រូវ" វានៅតែមានលទ្ធភាពបដិសេធការការពារប្រយោជន៍របស់តតិយជន C ក្នុងករណីដែល C ជាជនទុច្ចរិត ដោយសន្និដ្ឋានថា C គ្មានផលប្រយោជន៍ត្រឹមត្រូវ ។

សេចក្តីពន្យល់លម្អិតខាងលើនេះបង្ហាញថា បញ្ហានេះមានភាពស្មុគស្មាញ ។ ទោះបីជាតាមមធ្យោបាយមួយណាក៏ដោយ វាជាការសមស្របក្នុងការការពារតតិយជនដែលបានចុះបញ្ជី និង ដែលជាជនសុចរិត និង គ្មានកំហុស ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤១២.- សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់

១-សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យមានការខូចខាត ឬ ការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញបានដោយចេតនា ឬ ធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទម្រង់ដោយចេតនា ។

២-បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃវត្ថុដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា ។[៤]

៣-ក្នុងករណីដែលភាគីម្ខាងទៀតមានកំហុស ឬ មានមូលហេតុក្នុងការខូចខាត ឬ ការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីយកិច្ចក្នុងការសងជាប្រាក់នូវតម្លៃនៃវត្ថុនោះ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះឡើយ ។

(កំណត់)

[៤] កថាខណ្ឌទី ២ នៃមាត្រា ៤១២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ភាគីនៃកិច្ចសន្យានោះមានករណីយកិច្ចធ្វើបដិទានដែលត្រូវប្រគល់វិញនូវវត្ថុដែលខ្លួនបានទទួលនោះឱ្យទៅភាគីម្ខាងទៀត ។ បញ្ហាចោទមានឡើងត្រង់ថា សិទ្ធិរំលាយកិច្ចសន្យាអាចអនុវត្តបានដែរឬទេ នៅពេលភាគីនោះមិនអាចប្រគល់វិញនូវវត្ថុនោះបាន ដោយសារវត្ថុដែលត្រូវប្រគល់វិញនោះបានបាត់បង់ ឬ ទទួលការខូចខាត ។ មាត្រានេះមានចែងអំពីបញ្ហានេះ ។

កថាខណ្ឌទី ១ ចែងថា សិទ្ធិរំលាយកិច្ចសន្យារបស់ភាគីដែលបានធ្វើឱ្យបាត់បង់ ជាអាទិ៍ នូវវត្ថុដែលជាកម្មវត្ថុ ដោយចេតនា ត្រូវរលត់ ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកទិញរថយន្តរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុរថយន្តនោះមានវិការៈ ប្រសិនបើអ្នកទិញនោះធ្វើឱ្យខូចខាតដោយចេតនាដល់រថយន្តដែលខ្លួនត្រូវប្រគល់វិញ បើខ្លួនរំលាយកិច្ចសន្យានោះអ្នកទិញនោះ ត្រូវបាត់បង់សិទ្ធិរំលាយ ។ ប្រសិនបើរថយន្តទទួលរងការខូចខាតដោយកំហុសក្នុងគ្រោះថ្នាក់ចរាចរណ៍ អ្នកទិញនោះនៅតែមានសិទ្ធិរំលាយ ពីព្រោះគ្រោះថ្នាក់ចរាចរណ៍មិនមែនកើតឡើងដោយចេតនា ។

កថាខណ្ឌទី ២ ចែងអំពីករណីដែលអ្នកទិញនៅតែមានសិទ្ធិរំលាយកិច្ចសន្យា គឺដូចគ្នាទៅនឹងឧទាហរណ៍ខាងលើនេះដែលអ្នកទិញបានធ្វើឱ្យខូចខាតដល់រថយន្តដោយមកពីកំហុសក្នុងពេលបើកបរ ។ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ប៉ុន្តែអ្នកទិញនោះត្រូវសងជាទឹកប្រាក់ ចំពោះតម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតនៃរថយន្តនោះ ។

ចំពោះកថាខណ្ឌទី ៣ ក្នុងករណីដែលអ្នកទិញរំលាយកិច្ចសន្យាលក់ទិញរថយន្តដោយមូលហេតុដែលរថយន្តនោះមានវិការៈ ប្រសិនបើរថយន្តខូចបណ្តាលមកពីវិការៈនោះ (ឧទាហរណ៍ រថយន្តបានបុកបង្គោលខ្សែទូរស័ព្ទដោយមកពីហ្វ្រាំងមិនជាប់ល្អ) អ្នកទិញគ្មានការទទួលខុសត្រូវចំពោះការខូចខាតនៃរថយន្តនោះទេ ហើយអ្នកលក់មានការទទួលខុសត្រូវ ឬបង្កើតមូលហេតុនៃការខូចខាតនោះ ហេតុដូច្នេះ អ្នកទិញមិនចាំបាច់សងជាប្រាក់ចំពោះផ្នែកដែលបាក់បែករបស់រថយន្តនោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤១៣.- អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា

**អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច ។**

(កំណត់)

មាត្រានេះចែងអំពីអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា និង សិទ្ធិទាមទារឱ្យធ្វើបដិទានបន្ទាប់ពីការរំលាយកិច្ចសន្យា ។ វាមិនដូចនឹងការទាមទារឱ្យសងសំណងការខូចខាតទេ អាជ្ញាយុកាលនៃសិទ្ធិរំលាយ ចាប់គិតពីពេលដែលមាន

ការមិនអនុវត្តកាតព្វកិច្ច ។ ក្នុងករណីនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច សិទ្ធិរំលាយកិច្ចសន្យាមិនត្រូវកើតឡើង ប្រសិនបើម្ចាស់បំណុលមិនបានដាស់តឿន ។ ប៉ុន្តែ ប្រសិនបើការអនុវត្តកាតព្វកិច្ចនេះមានការយឺតយ៉ាវនោះ ម្ចាស់បំណុលអាចបង្កើតសិទ្ធិរំលាយដោយធ្វើការដាស់តឿននៅពេលណាក៏បានដែរ ។ ហេតុដូច្នេះ គ្មានបញ្ហាទេចំពោះការចែងថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ចាប់គិតពីពេលនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។

ចំពោះសិទ្ធិទាមទារឱ្យធ្វើបដិទានដែលកើតឡើងដោយអនុវត្តសិទ្ធិរំលាយ គ្មានអាជ្ញាយុកាលដោយឡែកពិសេសទេ ហេតុដូច្នេះ សិទ្ធិទាមទារឱ្យធ្វើបដិទាននេះនឹងត្រូវរលត់ ប្រសិនបើមិនទាមទារឱ្យធ្វើបដិទានមុនអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយត្រូវបានសម្រេច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤១៤.- សិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀងគ្នា

១-គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង ឬ សងខាងមានសិទ្ធិរំលាយ នៅក្នុងកិច្ចសន្យានោះបាន ។ បញ្ញត្តិពីមាត្រា ៤០៩ (វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា) ដល់មាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់) នៃក្រមនេះ ស្ដីពីការរំលាយដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធីអនុវត្ត និង អានុភាពនៃសិទ្ធិរំលាយ ដែលបានកំណត់ដោយកិច្ចសន្យា លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង ។

២-ទោះបីជាគ្មានការកំណត់សិទ្ធិរំលាយក្នុងកិច្ចសន្យាក៏ដោយ ក៏គូភាគីអាចរំលាយកិច្ចសន្យាដោយការព្រមព្រៀងគ្នាបានដែរ ។ ប៉ុន្តែ ការរំលាយនោះមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានទេ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀង ។ ចំពោះសិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា និង ការរំលាយដោយការព្រមព្រៀងនេះ មានការពន្យល់នៅក្នុងសេចក្ដីកំណត់នៃមាត្រា ៤០៩ ។ សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយដែលត្រូវបានផ្ដល់ឱ្យទៅភាគីនៃកិច្ចសន្យាក្នុងការរំលាយកិច្ចសន្យាក្នុងករណីដែលបានកំណត់មួយចំនួន ទោះបីជាមិនមានការមិនអនុវត្ត

កាតព្វកិច្ចក៏ដោយ ។ សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យានេះ ត្រូវបានអនុវត្តតាមការបង្ហាញឆន្ទៈឯកតោភាគីរបស់អ្នកដែលមានសិទ្ធិរំលាយ ហើយនៅក្នុងន័យនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច (ការរំលាយដែលច្បាប់បានកំណត់) ។ ហេតុនេះហើយ បញ្ញត្តិអំពីវិធីអនុវត្តសិទ្ធិរំលាយដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសិទ្ធិរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា ។

ម្យ៉ាងទៀត ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ត្រូវអាស្រ័យទៅតាមខ្លឹមសារនៃការព្រមព្រៀងដែលមានគោលបំណងរំលាយកិច្ចសន្យា ហេតុដូច្នេះ មិនចាំបាច់មានបញ្ញត្តិពិសេសណាមួយឡើយ ។ ប៉ុន្តែ ដោយហេតុថាជាការមិនសមស្របក្នុងការធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជន បញ្ញត្តិដែលការពារដល់តតិយជនត្រូវបានចែងក្នុងមាត្រានេះ ។ ពាក្យ "ផលប្រយោជន៍របស់តតិយជន" ក្នុងមាត្រានេះ មានអត្ថន័យទូលំទូលាយជាងតតិយជនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៤១១ ។ ដោយហេតុថា ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ធ្វើឡើងដោយសារមូលហេតុផ្ទាល់ខ្លួនរបស់ភាគីនៃកិច្ចសន្យា នោះវាជាការធម្មតាដែលមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ។ ឧទាហរណ៍ ក្នុងករណីដែលភាគី A លក់ដីឱ្យទៅភាគី B ហើយបន្ទាប់មកភាគី B លក់បន្តឱ្យទៅភាគី C ទោះបីជាភាគី C មិនទាន់បានចុះបញ្ជី ដោយគ្រាន់តែបង្កើតកិច្ចសន្យាលក់ទិញជាមួយភាគី B ក៏ដោយ ក៏ភាគី A និង C មិនអាចរំលាយកិច្ចសន្យាលក់ទិញដោយការព្រមព្រៀងបានឡើយ ។

# ជំពូកទី ៥ ការទទួលបន្ទុកហានិភ័យ

## មាត្រា ៤១៥.- ការរលត់កាតព្វកិច្ចដោយអលទ្ធភាព

បើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពនោះ កាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ ។

(កំណត់)

មាត្រានេះចែងនូវគោលការណ៍មួយដែលមានខ្លឹមសារថា កាតព្វកិច្ចមួយត្រូវរលត់ ប្រសិនបើការអនុវត្តកាតព្វកិច្ចនោះក្លាយជាអលទ្ធភាពដោយសត្យានុម័ត ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញសេះជាក់លាក់ណាមួយ ប្រសិនបើសេះនោះបានស្លាប់ដោយជម្ងឺ នោះកាតព្វកិច្ចរបស់អ្នកលក់ត្រូវរលត់ ហើយចំណុចដែលត្រូវពិចារណានោះ គឺបន្ទុកនៃហានិភ័យ ។ យោងទៅតាមបញ្ញត្តិនៃមាត្រា ៤១៦ ជាគោលការណ៍ កាតព្វកិច្ចរបស់អ្នកទិញក្នុងការបង់ប្រាក់ក៏ត្រូវរលត់ដូចគ្នាដែរ ។

ប្រសិនបើកូនបំណុលមានកំហុសចំពោះមូលហេតុនៃអលទ្ធភាពនេះ នោះកាតព្វកិច្ចរបស់អ្នកលក់នឹងមិនរលត់ទេ ប៉ុន្តែនឹងនៅបន្តមានជាកាតព្វកិច្ចក្នុងការសងសំណងការខូចខាត ។ ក្នុងករណីនេះ កាតព្វកិច្ចរបស់អ្នកទិញក្នុងការបង់ប្រាក់

ក៏នៅតែបន្តមានអត្ថិភាព ។ ដូច្នេះហើយ អ្នកទិញត្រូវធ្វើការជ្រើសរើសក្នុងការរំលាយកិច្ចសន្យា ឬ ធ្វើការទូទាត់នូវកាតព្វកិច្ចក្នុងការបង់ប្រាក់ ជាមួយនឹងសិទ្ធិទាមទារឱ្យអ្នកលក់សងសំណងការខូចខាត ដោយមិនរំលាយកិច្ចសន្យា ។

សម្រាប់សេចក្តីលម្អិតទាក់ទងនឹងអលទ្ធភាពក្នុងការអនុវត្ត សូមមើលមាត្រា ៣៩២ និង សេចក្តីកំណត់សម្រាប់មាត្រានោះ ។

## មាត្រា ៤១៦.- ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់

១-ក្នុងកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីដែលវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យនោះ ហើយមិនអាចទាមទារតាវកាលិកតប ពីម្ចាស់បំណុលបានទេ ។

២-លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា ហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅម្ចាស់បំណុលនៅពេលណាមួយក្នុងចំណោមពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ពេលដែលប្រគល់វត្ថុជាកម្មវត្ថុទៅម្ចាស់បំណុល ឬ ពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬ ពេលផ្សេងទៀតដែលយល់ឃើញថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុជាកម្មវត្ថុត្រូវបានផ្ទេរទៅម្ចាស់បំណុល ។

ខ-ពេលដែលកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ ។

គ-ពេលដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលការអនុវត្តរបស់កូនបំណុលដោយគ្មានមូលហេតុត្រឹមត្រូវ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិស្តីពីការទទួលបន្ទុកហានិភ័យ ក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធលើវត្ថុដែលបានកំណត់ជាក់លាក់ ។

ក្នុងកិច្ចសន្យាអញ្ញមញ្ញ កាតព្វកិច្ចនឹងត្រូវរលត់ ប្រសិនបើកាតព្វកិច្ចរបស់ភាគីណាមួយក្លាយជាអលទ្ធភាពក្នុងការអនុវត្ត ទោះបីជាគ្មានកំហុសពីសំណាក់ភាគីទាំងសងខាងក៏ដោយ (មាត្រា ៤១៥) ។ បន្ទុកហានិភ័យគឺទាក់ទងទៅនឹងកាតព្វកិច្ចមួយទៀតដែលមានជាថ្នូរទៅនឹងកាតព្វកិច្ចដែលរលត់ទៅនោះ ។ ដោយសារតែចំណុចនេះទាក់ទងទៅនឹងភាគីដែលត្រូវទទួលបន្ទុកចំពោះករណីដែលគ្មានកំហុសរបស់ភាគីណាម្នាក់នោះ បញ្ហានេះត្រូវហៅថាជា "បន្ទុកហានិភ័យ" ។

ចំណុចនេះត្រូវបានលើកយកមកពិភាក្សាក្នុងបរិបទ "ហានិភ័យ" ក្នុងបណ្ដាប្រទេសមួយចំនួនក្នុងពិភពលោក ។

ប្រភេទចម្បងនៃកិច្ចសន្យាដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ គឺជាកិច្ចសន្យាលក់ទិញ ប៉ុន្តែ កិច្ចសន្យាដូរក៏ស្ថិតក្នុងប្រភេទនៃកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុជាក់លាក់ដែរ ។ តទៅនេះគឺជាសេចក្ដីពន្យល់ដោយយកកិច្ចសន្យាលក់ទិញដែលជាកិច្ចសន្យាមួយប្រភេទដែលមានសារៈសំខាន់បំផុត មកធ្វើជាឧទាហរណ៍ ។

កថាខណ្ឌទី ១ បានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងករណីនេះ ជាគោលការណ៍ "កូនបំណុលទទួលបន្ទុកហានិភ័យ" ។ កូនបំណុលនៅក្នុងករណីនេះមានន័យថាជាកូនបំណុលនៃកាតព្វកិច្ចដែលនឹងត្រូវរលត់ដោយសារអលទ្ធភាពក្នុងការអនុវត្ត។ ក្នុងករណីនៃកិច្ចសន្យាលក់ទិញ កូនបំណុលគឺជាអ្នកលក់ ដូច្នេះ អ្នកលក់ត្រូវទទួលបន្ទុកហានិភ័យនេះ ។ អត្ថន័យនៃការដែល "អ្នកលក់ត្រូវទទួលបន្ទុកហានិភ័យ" ត្រូវបានបញ្ជាក់ផងដែរនៅក្នុងបញ្ញត្តិនេះ ។ បានសេចក្ដីថា អ្នកលក់មិនអាចទាមទារតាវកាលិកតប ពោលគឺមិនអាចទាមទារឱ្យបង់ថ្លៃលក់បានឡើយ ។ ជាចុងក្រោយនោះ ភាគីអ្នកលក់នៃកិច្ចសន្យាលក់ទិញ បានបាត់នូវវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ហើយមិនអាចទាមទារឱ្យបង់ថ្លៃលក់វត្ថុនោះ ដូច្នេះ ភាគីអ្នកលក់ត្រូវទទួលការខូចខាតនេះ ។ គោលការណ៍តម្រូវឱ្យកូនបំណុលទទួលបន្ទុកហានិភ័យ គឺផ្អែកទៅលើទស្សនៈដែលថាអ្នកលក់គួរទទួលបន្ទុកហានិភ័យនៃការបាត់បង់ ព្រោះថាអ្នកលក់គឺជាអ្នកកាន់កាប់ ក្ដាប់ទុក និង គ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលវត្ថុនោះត្រូវបានប្រគល់ឱ្យទៅអ្នកទិញ ។

កថាខណ្ឌទី ២ បានចែងអំពីការកំណត់ពេលនៃការផ្ទេរហានិភ័យទៅឱ្យអ្នកទិញ (ម្ចាស់បំណុល) ។

នៅក្នុងចំណុច ក នៃកថាខណ្ឌនេះបានបង្ហាញថា នៅពេលការគ្រប់គ្រងជាក់ស្ដែងលើវត្ថុដែលជាកម្មវត្ថុនោះ ត្រូវបានផ្ទេរទៅឱ្យអ្នកទិញ តាមរយៈការប្រគល់ ឬ ការចុះបញ្ជីអំពីការផ្ទេរ ជាអាទិ៍ នោះអ្នកទិញត្រូវទទួលបន្ទុកហានិភ័យផងដែរ ។ ប្រសិនបើហានិភ័យត្រូវបានផ្ទេរទៅឱ្យអ្នកទិញ ទោះបីជាវត្ថុដែលជាកម្មវត្ថុនោះបានបាត់ក៏ដោយ ក៏អ្នកទិញត្រូវបង់ថ្លៃលក់ឱ្យទៅអ្នកលក់ដែរ ។

ចំណុច ខ ទាក់ទងនឹងការផ្ទេរហានិភ័យដោយការផ្ដល់ការសង (ការផ្ដល់ការអនុវត្តកាតព្វកិច្ច) ។ ប្រសិនបើអ្នកលក់បានត្រៀមខ្លួនរួចរាល់ក្នុងការប្រគល់វត្ថុទៅឱ្យអ្នកទិញ ប៉ុន្តែ អ្នកទិញ (ម្ចាស់បំណុល) មិនបានទទួលការសងនោះ ទោះបីជាវត្ថុនោះនៅតែស្ថិតក្នុងការគ្រប់គ្រងរបស់អ្នកលក់ក៏ដោយ ក៏អ្នកទិញត្រូវតែទទួលបន្ទុកហានិភ័យ ចំពោះករណីដែលវត្ថុនោះត្រូវបានបាត់បង់ដោយសារករណីប្រធានសក្តិដែរ។

ចំណុច គ ទាក់ទងនឹងការផ្ទេរហានិភ័យដោយសារការប្រកែកមិនព្រមទទួលការអនុវត្តកាតព្វកិច្ច ។ វាមានលក្ខណៈខុសគ្នាដែលគួរឱ្យកត់សម្គាល់ពីចំណុច ខ គឺដូចជាករណីដែលម្ចាស់បំណុលប្រកាសទៅកូនបំណុលថា ខ្លួនមិនទទួលនូវការផ្ដល់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលឡើយ នៅពេលដែលអ្នកលក់ (កូនបំណុល) មិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការអនុវត្តកាតព្វកិច្ច (ការផ្ដល់ការអនុវត្ត) ។ ក្នុងករណីនេះ អ្នកលក់អាចតម្កល់វត្ថុនោះ ប៉ុន្តែ ទោះបីជាខ្លួនមិនតម្កល់ក៏ដោយ ក៏មិនមានការទទួលខុសត្រូវឡើយ ។ ហើយទោះបីជាវត្ថុនោះត្រូវបានបាត់បង់ដោយករណីប្រធានសក្តិនៅក្នុងអំឡុងពេលដែលអ្នកលក់ថែរក្សាវត្ថុនោះ ដោយមូលហេតុកូនបំណុលប្រកែកមិនព្រមទទួលការអនុវត្តកាតព្វកិច្ចដោយគ្មាន

មូលហេតុត្រឹមត្រូវក៏ដោយ ក៏បន្ទុកនេះនឹងត្រូវទទួលដោយអ្នកទិញ មិនមែនដោយអ្នកលក់ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤១៧.–** ការទទួលបន្ទុកហានិភ័យចំពោះសិទ្ធិផ្សេងទៀត

បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបង្កើត ឬ ការផ្ទេរសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ ឬ សិទ្ធិលើបំណុល ឬ សិទ្ធិផ្សេងទៀត ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលត្រូវយកមកអនុវត្តចំពោះករណីដែលវត្ថុដែលជាកម្មវត្ថុនៃភតិសន្យា ត្រូវបានបាត់បង់ដោយករណីប្រធានសក្តិ មុនពេលដែលភតិបតីប្រគល់វត្ថុនោះទៅឱ្យភតិកៈដោយស្របទៅតាមភតិសន្យា ជាអាទិ៍ ។ ក្នុងករណីនេះ ក៏គោលការណ៍តម្រូវឱ្យកូនបំណុលទទួលបន្ទុកហានិភ័យ ត្រូវយកមកអនុវត្តដែរ ។ ដោយសារតែភតិបតីជាអ្នកទទួលបន្ទុកហានិភ័យ ហើយវត្ថុនោះត្រូវបានបាត់បង់ នោះភតិបតីពុំអាចទាមទារនូវថ្លៃឈ្នួលបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤១៨.–** ករណីដែលកម្មវត្ថុជាវត្ថុដែលមិនបានកំណត់ជាក់លាក់

១-ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុដែលមិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួនបានរៀបចំដើម្បីអនុវត្តបាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនោះមិនត្រូវរលត់ដែរ ហើយកូនបំណុលនោះនៅតែមានករណីយកិច្ចអនុវត្ត ។

២-ក្រោយពេលបានកំណត់កម្មវត្ថុដែលត្រូវផ្តល់ហើយ បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(កំណត់)

មាត្រានេះចែងអំពីបន្ទុកហានិភ័យក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាគឺជាវត្ថុដែលមិនបានកំណត់ជាក់លាក់ ។

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញស្រូវចំនួន ១ តោន តើត្រូវមានដំណោះស្រាយរបៀបណាប្រសិនបើអ្នកលក់រក្សាទុកស្រូវចំនួន ១ តោននោះនៅក្នុងឃ្លាំងស្រូវរបស់ខ្លួន ប៉ុន្តែ ដោយសារការរាលដាលអគ្គិភ័យពីផ្ទះអ្នកជិតខាង ឃ្លាំងស្រូវ និង ស្រូវទាំងអស់ត្រូវបានឆាបឆេះអស់ ? អ្នកលក់ត្រូវទទួលបន្ទុកហានិភ័យ ប្រសិនបើអ្នកលក់ពុំទាន់បានធ្វើ "ការកំណត់ជាក់លាក់នូវវត្ថុ ក្នុងចំណោមវត្ថុដែលបានកំណត់ប្រភេទនៃវត្ថុ" ដែលបានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣១៥ ។ បន្ថែមលើនេះទៀត វាខុសគ្នាពីការលក់ទិញនូវវត្ថុដែលបានកំណត់ជាក់លាក់ កាតព្វកិច្ចរបស់អ្នកលក់ មិនត្រូវរលត់ទេ ដូច្នេះហើយ អ្នកលក់ត្រូវរកស្រូវចំនួន ១ តោន សាជាថ្មី ហើយប្រគល់ទៅឱ្យអ្នកទិញ ។

នៅក្នុងករណីដែលអ្នកលក់បានកំណត់ជាក់លាក់នូវវត្ថុដូចដែលបានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣១៥ បន្ទុកហានិភ័យត្រូវកំណត់តាមរបៀបដូចគ្នាទៅនឹងការលក់ទិញវត្ថុដែលបានកំណត់ជាក់លាក់ដែរ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៥៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤១៩.-** ករណីដែលកិច្ចសន្យាមានល័ក្ខខ័ណ្ឌបង្អង់

ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានល័ក្ខខ័ណ្ឌបង្អង់ ក្នុងករណីដែលកម្មវត្ថុត្រូវបានបាត់បង់ ឬ ខូចខាត មុនពេលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ដោយគ្មានកំហុសរបស់កូនបំណុលទេ នោះកូនបំណុលត្រូវទទួលបន្ទុកហានិភ័យ ។ ក្រោយពីល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញហើយ បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(កំណត់)

មាត្រានេះទាក់ទងទៅនឹងការទទួលបន្ទុកហានិភ័យ ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានល័ក្ខខ័ណ្ឌបង្អង់ ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យានោះត្រូវបានបាត់បង់ដោយគ្មានកំហុសរបស់គូភាគីទាំងសងខាង ។ ឧទាហរណ៍ ក្នុងករណីដែលកាតព្វកិច្ចរបស់អ្នកលក់ក្នុងការប្រគល់នូវវត្ថុមួយ ភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ដូចជា "ប្រគល់វត្ថុនោះ បើទទួលការអនុញ្ញាតពីរដ្ឋាភិបាល" ជាអាទិ៍ ។ ក្នុងករណីនេះ អ្នកលក់ជាអ្នកទទួលបន្ទុកហានិភ័យ ដោយហេតុថា អ្នកលក់មានសិទ្ធិគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចនោះ រហូតដល់ល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញចប់សព្វគ្រប់ ។ បញ្ញត្តិនៃមាត្រានេះ ឆ្លុះបញ្ចាំងពីរឿងធម្មតា ។ ប៉ុន្តែ ការសន្និដ្ឋានផ្សេងមួយនឹងត្រូវធ្វើឡើង ប្រសិនបើអ្នកលក់បានប្រគល់វត្ថុដែលជាកម្មវត្ថុរួចរាល់ទៅឱ្យអ្នកទិញ មុនពេលដែលល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ។ ទោះបីជាវត្ថុដែលជាកម្មវត្ថុនោះ ត្រូវបានប្រគល់ទៅឱ្យអ្នកទិញដោយហេតុផលណាមួយក៏ដោយ ក៏អ្នកលក់នៅតែបន្តទទួលបន្ទុកហានិភ័យ រហូតដល់ល័ក្ខខ័ណ្ឌបង្អង់ត្រូវបានបំពេញ ។ ឧទាហរណ៍ ទោះបីជាកម្មវត្ថុនោះត្រូវបានប្រគល់ទៅឱ្យអ្នកទិញដើម្បីឱ្យអ្នកទិញប្រើប្រាស់សាកល្បង

មុនពេលល័ក្ខខ័ណ្ឌបង្អង់នៃការទទួលការអនុញ្ញាតពីរដ្ឋាភិបាលត្រូវបានសម្រេចក៏ដោយ ក៏វាជាការមិនត្រឹមត្រូវដែរក្នុងការផ្ទេរនូវហានិភ័យទៅឱ្យអ្នកទិញ ។ ពាក់ព័ន្ធនឹងបន្ទុកហានិភ័យនេះ វាជាការត្រឹមត្រូវក្នុងការបញ្ជាក់ពីសារៈសំខាន់ផ្នែកច្បាប់នៃការបំពេញនូវល័ក្ខខ័ណ្ឌបង្អង់ ។

នៅពេលដែលល័ក្ខខ័ណ្ឌបង្អង់នេះត្រូវបានបំពេញហើយ បញ្ញត្តិនៃមាត្រា ៤១៦ នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។ ម្យ៉ាងទៀត ទោះបីជាកាតព្វកិច្ចភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ក៏ដោយ ប្រសិនបើវត្ថុដែលជាកម្មវត្ថុត្រូវបានបាត់បង់ដោយគ្មានកំហុសរបស់ភាគីណាមួយទេនោះ ក៏កាតព្វកិច្ចនោះត្រូវរលត់ដោយសារអលទ្ធភាព ។ ដូច្នេះហើយ បញ្ញត្តិនៃមាត្រា ៤១៥ ត្រូវយកមកអនុវត្តចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានល័ក្ខខ័ណ្ឌបង្អង់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤២០.- ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ ឬ មិនត្រូវធ្វើ

ចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យឱ្យភាគីម្ខាងត្រូវធ្វើ ឬ មិនត្រូវធ្វើ ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កាតព្វកិច្ចនោះត្រូវរលត់ ។ ក្នុងករណីនេះ កូនបំណុលមិនអាចទាមទារតាវកាលិកតបពីម្ចាស់បំណុលបានទេ ។[៥]

(កំណត់)

មាត្រានេះចែងអំពីបន្ទុកហានិភ័យចំពោះកាតព្វកិច្ចក្នុងការធ្វើ ឬ មិនត្រូវធ្វើនូវសកម្មភាពជាក់លាក់ណាមួយ ដែលមិនមែនជាកាតព្វកិច្ចត្រូវប្រគល់វត្ថុណាមួយ ។

ក្នុងមាត្រានេះ ក៏គោលការណ៍តម្រូវឱ្យកូនបំណុលទទួលបន្ទុកហានិភ័យត្រូវបានយកមកអនុវត្តដែរ ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាអាណត្តិដែលយកតម្លៃថ្នូរ ក្នុងករណីដែលអាណត្តិគាហកអាចទាមទារកម្រៃសម្រាប់ធ្វើការស្រាវជ្រាវវាស់វែងដី ប្រសិនបើដីនោះត្រូវបានកំណត់ថា ស្ថិតនៅក្នុងតំបន់ហាមឃាត់ ហើយអាណត្តិគាហកមិនអាចធ្វើការស្រាវជ្រាវវាស់វែងដីនោះបាន នោះកាតព្វកិច្ចក្នុងការស្រាវជ្រាវរបស់អាណត្តិគាហកនឹងត្រូវរលត់ ហើយស្របគ្នានេះដែរ សិទ្ធិក្នុងការទាមទារតាវកាលិកតប (កម្រៃ) ក៏ត្រូវរលត់ផងដែរ ។

ក្នុងកិច្ចសន្យាការងារ ប្រសិនបើកម្មករនិយោជិតម្នាក់មិនអាចធ្វើការដោយសារបានឆ្លងជម្ងឺ ករណីនេះគឺជា

---

[៥] កថាខណ្ឌទី ២ នៃមាត្រា ៤២០ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចរបស់កម្មករនិយោជិតនោះ ហើយកម្មករនិយោជិតនេះមិនអាចទាមទារនូវប្រាក់ឈ្នួលរបស់ខ្លួនបានឡើយ ។ ទោះបីវាហាក់ដូចជាមានភាពអយុត្តិធម៌ចំពោះកម្មករនិយោជិត ប្រសិនបើកម្មករនិយោជិតនេះពុំបានទទួលនូវប្រាក់ឈ្នួលទាល់តែសោះដោយសារតែការឆ្លងជម្ងឺនេះក៏ដោយ ក៏វិធានការនានាក្នុងការការពារកម្មករនិយោជិត នឹងត្រូវបញ្ចូលក្នុងច្បាប់ពិសេសស្តីពីការងារដែរ (ដូចជានិយោជកត្រូវផ្តល់នូវប្រាក់ឈ្នួលក្នុងកម្រិតមួយជាក់លាក់ដល់កម្មករនិយោជិតណាដែលអវត្តមានដោយសារជម្ងឺ ជាអាទិ៍) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤២១.– អលទ្ធភាពក្នុងការអនុវត្តដោយកំហុសរបស់ម្ចាស់បំណុល

ក្នុងករណីដែលការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាពដោយគ្មានកំហុសរបស់កូនបំណុល ហើយអលទ្ធភាពនោះកើតឡើងដោយមានកំហុសរបស់ម្ចាស់បំណុលវិញ កូនបំណុលមិនត្រូវបាត់បង់នូវតាវកាលិកតបពីម្ចាស់បំណុលទេ ។ ប៉ុន្តែ ប្រសិនបើកូនបំណុលបានទទួលផលប្រយោជន៍ ដោយការរួចផុតពីកាតព្វកិច្ចរបស់ខ្លួន កូនបំណុលត្រូវប្រគល់ផលប្រយោជន៍នេះទៅម្ចាស់បំណុលវិញ ។

(កំណត់)

ក្នុងករណីដែលអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចបណ្តាលមកពីកំហុសរបស់ម្ចាស់បំណុល នោះម្ចាស់បំណុលត្រូវទទួលបន្ទុកហានិភ័យ ដោយមិនប្រកាន់ថា កាតព្វកិច្ចនៅជាកាតព្វកិច្ចក្នុងការប្រគល់វត្ថុ កាតព្វកិច្ចត្រូវធ្វើ ឬ មិនធ្វើសកម្មភាពណាមួយឡើយ ។ ក្នុងករណីដែលមូលហេតុដែលកម្មករនិយោជិតមិនអាចធ្វើការបាន បណ្តាលមកពីការរងគ្រោះដែលកើតឡើងដោយសារបរិក្ខាររបស់រោងចក្រពុំមានសុវត្ថិភាពគ្រប់គ្រាន់ នោះម្ចាស់បំណុល (និយោជក) មានកំហុស ដូច្នេះ កម្មករនិយោជិតអាចទាមទារប្រាក់ឈ្នួលបាន ។ ជាងនេះទៅទៀត នៅក្នុងករណីនេះ កម្មករនិយោជិតមានសិទ្ធិទាមទារសំណងការខូចខាតចំពោះនិយោជកផងដែរ ដោយសារខ្លួនត្រូវបានរងគ្រោះដោយសារកំហុសរបស់និយោជក (ផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល) ។ ដោយសារកម្មករនិយោជិតនឹងមិនត្រូវបាត់បង់សិទ្ធិក្នុងការទាមទារប្រាក់ឈ្នួល កម្មករនិយោជិតនេះអាចទាមទារនូវសំណងការខូចខាត ចំពោះការចំណាយលើការព្យាបាល និង ការចំណាយផ្សេងៗទៀត ។

មានសំណួរលំបាកមួយដែលពាក់ព័ន្ធទៅនឹងចំណុចថា តើមាត្រា ៤២០ និង មាត្រា ៤២១ គួរយកមកអនុវត្តក្នុងករណីដែលកម្មករនិយោជិតមិនអាចផ្តល់សេវាការងារដែលមានចែងក្នុងកិច្ចសន្យាការងារ ដោយមូលហេតុរោងចក្រត្រូវបានបំផ្លាញដោយអគ្គិភ័យ បានដែរ ឬ ទេ។

ប្រសិនបើករណីដែលកម្មករនិយោជិតមិនអាចបំពេញការងារដោយសារអគ្គិភ័យរោងចក្រនេះ ត្រូវបានគិតថាជាបញ្ហានៃការទទួលបន្ទុកហានិភ័យ ក្នុងករណីដែលនិយោជកគ្មានកំហុសចំពោះការបំផ្លាញរោងចក្រដោយអគ្គិភ័យនោះ កម្មករនិយោជិតនឹងត្រូវបាត់បង់សិទ្ធិក្នុងការទាមទារប្រាក់ឈ្នួល ដោយយោងតាមមាត្រា ៤២០ ប៉ុន្តែ ប្រសិនបើមូលហេតុនៃអគ្គិភ័យបណ្តាលមកពីកំហុសរបស់និយោជក កម្មករនិយោជិតនោះនឹងមិនបាត់បង់សិទ្ធិនោះឡើយ ដោយយោងតាមមាត្រា ៤២១ ។ ប៉ុន្តែ នៅក្នុងករណីដែលកម្មករនិយោជិតមិនអាចធ្វើការដោយសារតែកន្លែងធ្វើការត្រូវរងនូវអគ្គិភ័យ កម្មករនិយោជិតនោះនៅតែមានបំណងផ្តល់នូវសេវាការងារ ដូច្នេះ វាជាការមិនត្រឹមត្រូវទេក្នុងការគិតថាកាតព្វកិច្ចរបស់កម្មករនិយោជិតគឺអលទ្ធភាព ។ ដូច្នេះ អគ្គិភ័យរោងចក្រគួរតែត្រូវគិតថា មិនមែនជាបញ្ហានៃការទទួលបន្ទុកហានិភ័យ ប៉ុន្តែ ជាបញ្ហាដែលនិយោជក (ម្ចាស់បំណុល) មិនអាចទទួលការអនុវត្តដែលត្រូវបានផ្តល់បាន ។ បញ្ហានេះត្រូវហៅថា "ការយឺតយ៉ាវក្នុងការទទួល" ដូចដែលបានចែងក្នុងមាត្រា ៤៥៦ ។ ប៉ុន្តែ ទោះបីជាករណីខាងលើនេះត្រូវបានដោះស្រាយស្របតាមតាមមាត្រា ៤៥៦ ក៏ដោយ ក៏កម្មករនិយោជិតនឹងមិនអាចទាមទារនូវសំណងខូចខាតដែលមានតម្លៃស្មើនឹងប្រាក់ឈ្នួលរបស់ខ្លួនបានឡើយ លើកលែងនិយោជក (ម្ចាស់បំណុល) មានកំហុស ។

សរុបមក នៅពេលដែលគ្មានកំហុសរបស់ម្ចាស់បំណុល (នៅក្នុងឧទាហរណ៍នេះ គឺនិយោជក) កម្មករនិយោជិតនឹងមិនអាចទាមទារនូវប្រាក់ឈ្នួលបានឡើយ ទោះបីជាបញ្ហានេះត្រូវបានដោះស្រាយតាមមាត្រា ៤២០ និង មាត្រា ៤២១ ឬ តាមមាត្រា ៤៥៦ ក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៥៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៦ អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន

## ផ្នែកទី ១ ឧបាទេសកម្មដោយអ្នកមានសិទ្ធិលើបំណុល

**មាត្រា ៤២២.-** សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

១-ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិដែលកូនបំណុលមាន ជំនួសកូនបំណុលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិផ្តាច់មុខរបស់កូនបំណុលផ្ទាល់ សិទ្ធិដែលកូនបំណុលអាចសម្រេចដោយឆន្ទៈសេរីរបស់ខ្លួនក្នុងការអនុវត្ត និង សិទ្ធិដែលហាមមិនឱ្យរឹបអូស ។

២-ក្នុងករណីដែលចាំបាច់ដើម្បីទទួលការបំពេញចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុល របស់កូនបំណុលដែលមានការទាក់ទងយ៉ាងខ្លាំង

នឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះ ដោយឧបាទេសកម្មបាន ។

(កំណត់)

មាត្រានេះបញ្ញត្តពីសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល ។

ម្ចាស់បំណុលត្រូវបានទទួលស្គាល់នូវសិទ្ធិធ្វើអន្តរាគមន៍ដល់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនបំណុល ក្នុងទំហំចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ។ វិធីមួយក្នុងការធ្វើបែបនេះ គឺជាសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល និងវិធីមួយទៀត គឺសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍ ដែលបានចែងក្នុងមាត្រា ៤២៨ និង មាត្រាបន្តបន្ទាប់ ។ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌសម្រាប់វិធីទីមួយ គឺសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល ។

កថាខណ្ឌទី ១ មានអត្ថន័យដូចតទៅ ៖ ម្ចាស់បំណុលត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត លើកលែងតែការបង្ខំឱ្យអនុវត្តដែលនឹងត្រូវធ្វើឡើងដោយមានអន្តរាគមន៍ពីស្ថាប័នតុលាការ ។ ប៉ុន្តែ ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលអាចធ្លាក់ទៅក្នុងស្ថានភាពដែលមិនអាចសម្រេចបាន ប្រសិនបើម្ចាស់បំណុលរង់ចាំកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត នោះម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់កូនបំណុលជំនួសកូនបំណុលបាន ។ ឧទាហរណ៍ កូនបំណុល B បានខ្ចីប្រាក់ពីម្ចាស់បំណុល A ចំនួន ៥០០ ដុល្លារ ។ B ពុំមានលទ្ធភាពសងប្រាក់នេះ ទៅម្ចាស់បំណុលវិញ ប៉ុន្តែ កូនបំណុល B មានផ្ទះមួយដែលកំពុងជួលឱ្យភាគី C ហើយ B មានសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល (៥០ ដុល្លារក្នុង ១ ខែ) ។ ក្នុងកាលៈទេសៈបែបនេះ "ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន" ម្ចាស់បំណុល A អាចអនុវត្តសិទ្ធិលើបំណុលរបស់កូនបំណុល B ក្នុងការទាមទារនូវថ្លៃឈ្នួលផ្ទះចំនួន ៥០ ដុល្លារពីភាគី C ជំនួសកូនបំណុល B ហើយទាមទារឱ្យភាគី C បង់មកឱ្យខ្លួននូវប្រាក់ឈ្នួលចំនួន ៥០ ដុល្លារ នោះបាន ។ ពាក្យ "ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន" សំដៅដល់ស្ថានភាពដែលកូនបំណុលពុំមានធនធានហិរញ្ញវត្ថុ ហើយការសងចំពោះម្ចាស់បំណុលនឹងពុំអាចធ្វើទៅរួច លើកលែងតែម្ចាស់បំណុលអនុវត្តនូវសិទ្ធិលើបំណុលរបស់កូនបំណុល ហើយធ្វើការប្រមូលសិទ្ធិលើបំណុលនោះពីកូនបំណុលទី ៣ ។

ប៉ុន្តែ ក៏មានករណីខ្លះដែរដែលមិនអនុញ្ញាតឱ្យផ្តល់នូវសិទ្ធិឧបាទេសកម្មដល់ម្ចាស់បំណុល ។ (១) ក្នុងករណីដែលកូនបំណុលត្រូវធ្វើការសម្រេចចិត្តថា តើខ្លួនអនុវត្តសិទ្ធិលើបំណុល ឬទេនោះ វាជារឿងមិនត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិលើបំណុលជំនួសកូនបំណុល ហេតុដូច្នេះ ឧបាទេសកម្មរបស់ម្ចាស់បំណុលមិនត្រូវបានទទួលស្គាល់ឡើយ ។ ឧទាហរណ៍សាមញ្ញមួយចំនួន មានដូចជាសិទ្ធិទាមទារឱ្យបែងចែកទ្រព្យសម្បត្តិនៅក្នុងករណីលែងលះគ្នា និងសិទ្ធិទាមទារសងជម្ងឺចិត្តក្នុងករណីបរិហាកេរ្តិ៍ ជាអាទិ៍ ។ (២) ទោះបីជាវាមានលក្ខណៈខុសប្លែកគ្នាបន្តិចនឹងសិទ្ធិផ្តាច់មុខរបស់រូបវន្តបុគ្គលមួយរូបក៏ដោយ ស្ទីការ (ការយល់ព្រម) ទៅនឹងសំណើនៃកិច្ចសន្យាមួយ គឺជាករណីមួយផ្សេងទៀតដែលតម្រូវឱ្យកូនបំណុលធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ ម្ចាស់បំណុលនឹងទទួលបានប្រយោជន៍ ប្រសិនបើបុគ្គលម្នាក់ (កូនបំណុល) ផ្តល់នូវស្ទីការចំពោះសំណើមួយដែលធ្វើឡើងដោយម្ចាស់រថយន្តមួយក្នុងការធ្វើប្រទានកម្មនូវរថយន្តនោះ

ដល់កូនបំណុល ។ ប៉ុន្តែ កូនបំណុលដែលជាអ្នកទទួលនូវសំណើនោះគួរតែជាអ្នកសម្រេចចិត្តថា តើគួរផ្តល់ស្ទីការទៅនឹងកិច្ចសន្យានេះ ហើយម្ចាស់បំណុលមិនត្រូវបានអនុញ្ញាតឱ្យផ្តល់ស្ទីការជំនួសកូនបំណុលឡើយ ។ ម្យ៉ាងទៀត នៅក្នុងករណីដែលមានសំណើមួយនៃកិច្ចសន្យាលក់ទិញ តាមរយៈស្ទីការ អ្នកដែលធ្វើស្ទីការនឹងទទួលបន្ទុកនូវកាតព្វកិច្ច ចំពោះសំណើនោះ (កិច្ចសន្យាអញ្ញមញ្ញ) ដូច្នេះ ស្ទីការនេះមិនអាចក្លាយទៅជាកម្មវត្ថុនៃឧបាទេសកម្មរបស់ម្ចាស់បំណុល តាំងពីដំបូងឡើយ ។ ម្ចាស់បំណុលអាចធ្វើឧបាទេសកម្មបាន លុះត្រាតែសិទ្ធិដែលជាកម្មវត្ថុនៃឧបាទេសកម្មជាសិទ្ធិរបស់កូនបំណុល ។ (៣) សិទ្ធិដែលហាមមិនឱ្យរឹបអូស ដូចជាសិទ្ធិក្នុងការទទួលប្រាក់បៀវត្ស មិនអាចក្លាយជាកម្មវត្ថុនៃឧបាទេសកម្មដោយម្ចាស់បំណុលបានឡើយ ទោះបីជាសិទ្ធិនោះជាសិទ្ធិរបស់កូនបំណុលក៏ដោយ (សិទ្ធិលើបំណុលចំពោះប្រាក់បៀវត្សមួយផ្នែកត្រូវបានហាមមិនឱ្យរឹបអូស តាមមាត្រា ៣៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។ សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការប្រមូលសិទ្ធិលើបំណុលពីកូនបំណុលទី ៣ បន្ទាប់ពីម្ចាស់បំណុលធ្វើការរឹបអូសនូវសិទ្ធិរបស់កូនបំណុល ស្របទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ប៉ុន្តែ វាមានតួនាទីខុសប្លែកគ្នាបន្តិចបន្តួច ។ ទី ១ សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលមិនតម្រូវឱ្យមានការពាក់ព័ន្ធនឹងស្ថាប័នតុលាការទេ ដូច្នេះ វាមានភាពងាយស្រួលនៅពេលគេត្រូវការធ្វើចំណាត់ការបន្ទាន់ ដូចជាក្នុងករណីដែលម្ចាស់បំណុលមានបំណងធ្វើការផ្អាកអាជ្ញាយុកាលចំពោះសិទ្ធិលើបំណុលរបស់កូនបំណុល ជាដើម ។ ទី ២ នៅក្នុងករណីដែលកូនបំណុលមានសិទ្ធិលុបចោលនូវកិច្ចសន្យា (ការលុបចោលដោយការឆបោក) ម្ចាស់បំណុលដែលមានបំណងលុបចោលនូវកិច្ចសន្យារបស់កូនបំណុលជាមួយតតិយជនដែលនាំឱ្យមានការខូចផលប្រយោជន៍របស់ខ្លួន ដោយធ្វើឧបាទេសកម្មនូវសិទ្ធិលុបចោលនេះ មិនអាចប្រើប្រព័ន្ធអនុវត្តដោយបង្ខំបានឡើយ ដូច្នេះ សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល មានលក្ខណៈសំខាន់ពិសេស ។

កថាខណ្ឌទី ២ មានន័យដូចតទៅ ៖ ក្នុងករណីដែលជនរងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍មួយដែលមានសិទ្ធិទាមទារឱ្យសងសំណងការខូចខាតពីចារី មានបំណងធ្វើឧបាទេសកម្មនូវសិទ្ធិលើបំណុលរបស់ចារីនោះក្នុងការទាមទារបុព្វលាភពីក្រុមហ៊ុនធានារ៉ាប់រង ដោយសារតែសិទ្ធិទាមទារបុព្វលាភធានារ៉ាប់រងរបស់ចារីដែលជាកូនបំណុល នឹងត្រូវយកមកប្រើសម្រាប់សំណងការខូចខាតដល់ជនរងគ្រោះ នោះសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលអាចត្រូវបានទទួលស្គាល់ ទោះបីជាកូនបំណុលមានធនធានហិរញ្ញវត្ថុក៏ដោយ ។ ល័ក្ខខ័ណ្ឌនៃ "ការទាក់ទងយ៉ាងខ្លាំង" មានលក្ខណៈអរូបីនៅក្នុងមាត្រានេះ ប៉ុន្តែ នឹងមានលក្ខណៈច្បាស់លាស់ជាងនេះ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការនាពេលខាងមុខ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤២៣.- ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម

១-ដើម្បីអនុវត្តសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ៤២២ (សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល) ខាងលើ កូនបំណុលត្រូវតែមិនទាន់បានអនុវត្តសិទ្ធិរបស់ខ្លួន ។

២-នៅពេលដែលពេលកំណត់នៃសិទ្ធិលើបំណុលរបស់ខ្លួនមិនទាន់ដល់ទេ ម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្មបានទេ លើកលែងតែករណីដែលបានទទួលការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះសកម្មភាពរក្សាទុក ។

(កំណត់)

មាត្រា ៤២២ ចែងអំពីល័ក្ខខ័ណ្ឌសារធាតុនៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល រីឯមាត្រានេះវិញចែងអំពីល័ក្ខខ័ណ្ឌនៃនីតិវិធី ។

កថាខណ្ឌទី ១ ចែងថា ដើម្បីអាចឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិឧបាទេសកម្មបាន កូនបំណុលត្រូវតែមិនទាន់បានអនុវត្តសិទ្ធិរបស់ខ្លួននោះ ដោយសារវាជាការមិនត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុលធ្វើអន្តរាគមន៍ទៅលើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនបំណុល ដោយអនុវត្តសិទ្ធិឧបាទេសកម្ម ក្នុងករណីដែលកូនបំណុលបានអនុវត្តសិទ្ធិនោះរួចហើយ ។

កថាខណ្ឌទី ២ ចែងអំពីនីតិវិធីនៃការធ្វើឧបាទេសកម្ម នៅក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមិនទាន់ដល់ពេលកំណត់ត្រូវសង ។ ការមិនអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ចំពោះសិទ្ធិលើបំណុលទាំងអស់ដែលពេលកំណត់ត្រូវសងមិនទាន់ដល់ គ្មានភាពសមរម្យទេ ពីព្រោះថា ទ្រព្យសម្បត្តិរបស់កូនបំណុលអាចនឹងត្រូវបាត់បង់មុនដល់ពេលកំណត់នោះ ។ ប៉ុន្តែ ការអនុញ្ញាតឱ្យអនុវត្តនូវសិទ្ធិឧបាទេសកម្ម ចំពោះសិទ្ធិលើបំណុលដែលពេលកំណត់ត្រូវសងមិនទាន់ដល់ ទៅតាមរបៀបដូចគ្នាទៅនឹងករណីដែលសិទ្ធិលើបំណុលដល់ពេលកំណត់ ក៏មានបញ្ហាដែរ ដោយសារការធ្វើបែបនោះមានន័យថាជាការអនុញ្ញាតឱ្យម្ចាស់បំណុលធ្វើអន្តរាគមន៍ហួសហេតុទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល ។ ហេតុដូច្នេះ កថាខណ្ឌទី ២ នេះចែងថា ម្ចាស់បំណុលត្រូវទទួលការអនុញ្ញាតពីតុលាការជាមុន ដើម្បីធ្វើឧបាទេសកម្មនូវសិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសង ។ ប៉ុន្តែ ចំពោះសកម្មភាពរក្សាទុក ដូចជាការផ្អាកអាជ្ញាយុកាល ជាអាទិ៍ ទំហំនៃការធ្វើអន្តរាគមន៍ទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល មានកម្រិតទាប ហើយក្នុងករណីជាច្រើន មានភាពបន្ទាន់ ហេតុដូច្នេះ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិឧបាទេសកម្មដោយពុំចាំបាច់មានការអនុញ្ញាតពីតុលាការបាន ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៤២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤២៤.- ការតតាំងនៃកូនបំណុលទី ៣

កូនបំណុលទី ៣ ដែលទទួលការអនុវត្តសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល អាចតតាំងចំពោះម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម ដោយយកការតវ៉ាដែលកូនបំណុលទី ៣ នោះមានចំពោះម្ចាស់បំណុលរបស់ខ្លួន ។

(កំណត់)

ដោយសារសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលគឺជាយន្តការមួយដែលតាមរយៈនោះម្ចាស់បំណុល (ភាគី A) អនុវត្តនូវសិទ្ធិដែលកូនបំណុល (ភាគី B) មាន ជំនួសឱ្យកូនបំណុលនោះ នោះវាពុំមានការចាំបាច់ក្នុងការកម្រិតទៅលើសិទ្ធិតវ៉ាដែលកូនបំណុលទី ៣ (ភាគី C) មានរួចជាស្រេចចំពោះម្ចាស់បំណុលរបស់ខ្លួន (ភាគី B) ឡើយ ។ ឧទាហរណ៍ នៅក្នុងករណីដែលកូនបំណុលទី ៣ (ភាគី C) មានសិទ្ធិលើបំណុលតបចំពោះកូនបំណុល (ភាគី B) នោះភាគី C អាចអះអាងការទូទាត់ ចំពោះការទាមទាររបស់ម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម (ភាគី A) បាន ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលកូនបំណុលទី ៣ (ភាគី C) ស្រាប់តែមានសិទ្ធិលើបំណុលតបចំពោះម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម (ភាគី A) ដែរ នោះនឹងកើតមាននូវបញ្ហាពិបាកមួយឡើងដែលពាក់ព័ន្ធទៅនឹងចំណុចថា តើភាគី C គួរត្រូវបានអនុញ្ញាតឱ្យអះអាងអំពីការទូទាត់ ចំពោះការទាមទារដោយឧបាទេសកម្ម ជាមួយនឹងសិទ្ធិលើបំណុលតបរបស់ខ្លួន ឬទេ ។ ជាគោលការណ៍ ការទូទាត់បែបនេះមិនគួរត្រូវបានអនុញ្ញាតឡើយ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម ទាមទារឱ្យកូនបំណុលទី ៣ ប្រគល់តាវកាលិកដោយផ្ទាល់ ឬ ក្នុងករណីដែលម្ចាស់បំណុលអនុវត្តសិទ្ធិឧបាទេសកម្ម ចំពោះសិទ្ធិលើបំណុលរបស់កូនបំណុលដែលមានការទាក់ទងយ៉ាងខ្លាំងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល (កថាខណ្ឌទី ២ នៃមាត្រា ៤២២) កូនបំណុលទី ៣ នោះហាក់ដូចជាគួរតែអាចអះអាងអំពីការតវ៉ា (ការតតាំង) ដែលខ្លួនមានដោយឡែកដោយចំពោះម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម ។ មាត្រានេះមិនបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះ ដោយទុកឱ្យមានការបកស្រាយតាមយុត្តិសាស្ត្រនៅក្នុងពេលអនាគត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦២៩ នៃក្រមរដ្ឋប្បវេណីកេបិច

## មាត្រា ៤២៥.- ទំនាក់ទំនងរវាងម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម និង កូនបំណុល

ក្នុងករណីដែលម្ចាស់បំណុលបានជូនដំណឹងទៅកូនបំណុលថា ខ្លួនបានអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្ម កូនបំណុលមិនអាចអនុវត្តសិទ្ធិចំពោះកូនបំណុលទី ៣ ដោយជាន់គ្នាបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងកូនបំណុលក្នុងការទទួលការសងពីកូនបំណុលទី ៣ ឡើយ ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីការកម្រិតទៅលើអំណាចរបស់កូនបំណុល ក្នុងករណីដែលសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលត្រូវបានអនុវត្ត ។

ជាទូទៅ ចំពោះអានុភាពដែលបណ្តាលមកពីការអនុវត្តនូវសិទ្ធឧបាទេសកម្មរបស់ម្ចាស់បំណុល គឺមានបញ្ហាចំនួន

បីកើតឡើង ។

បញ្ហាទី ១ ពាក់ព័ន្ធនឹងចំណុចថា ក្នុងករណីដែលសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលត្រូវបានអនុវត្ត តើសិទ្ធិអំណាចរបស់កូនបំណុល ត្រូវបានកម្រិតចំពោះសិទ្ធិលើបំណុលដែលត្រូវបានអនុវត្តដោយឧបាទេសកម្មនោះ ឬទេ ឬ តើសិទ្ធិរបស់កូនបំណុលក្នុងការធ្វើនីតិវិធីនៃបណ្តឹង និង សិទ្ធិក្នុងការទទួលការសងពីកូនបំណុលទី ៣ ត្រូវទទួលឥទ្ធិពល ឬទេ ។ បញ្ហានេះត្រូវចែងនៅក្នុងមាត្រានេះ ។

បញ្ហាទី ២ ពាក់ព័ន្ធនឹងចំណុចថា តើម្ចាស់បំណុលដែលធ្វើឧបាទេសកម្មអាចទាមទារឱ្យកូនបំណុលទី ៣ ផ្តល់តាវកាលិកដល់ខ្លួនដោយចំពោះដែរឬទេ ឬ អាចទាមទារត្រឹមតែឱ្យកូនបំណុលទី ៣ នោះផ្តល់តាវកាលិកដល់កូនបំណុលប៉ុណ្ណោះ ។ បញ្ញត្តិនៃមាត្រា ៤២៦ ចែងអំពីបញ្ហានេះ ។

បញ្ហាទី ៣ ចោទឡើងថា ក្នុងករណីដែលម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលទី ៣ ផ្តល់តាវកាលិកដល់ខ្លួនដោយចំពោះ តើម្ចាស់បំណុលផ្សេងទៀតរបស់កូនបំណុល អាចទទួលចំណែកពីការវកាលិក ដូចជាការចូលរួមក្នុងការចែកចំណែកបានទេ ឬ ម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម អាចទទួលបាននូវផលប្រយោជន៍ដោយផ្តាច់មុខ ។ មាត្រា ៤២៧ ផ្តល់នូវចម្លើយសម្រាប់ញ្ហានេះ ។

ទាក់ទងនឹងបញ្ហាទី ១ មាត្រានេះចែងថា កូនបំណុលត្រូវទទួលការកម្រិត ចំពោះសិទ្ធិរបស់ខ្លួនដែលជាកម្មវត្ថុនៃឧបាទេសកម្ម ដោយការអនុវត្តសិទ្ធិឧបាទេសកម្មដោយម្ចាស់បំណុល ។ ដោយផ្អែកលើទស្សនៈនេះ សំណួរដូចតទៅនេះនឹងកើតមានឡើង ។ សំណួរទី ១ : តើកូនបំណុលអាចទាមទារឱ្យកូនបំណុលទី ៣ សងកាតព្វកិច្ចចំពោះខ្លួនបានទេ ។ ចំណុចនេះមិនត្រូវបានអនុញ្ញាតឡើយ ដោយសារតែបើអនុញ្ញាតឱ្យធ្វើដូច្នេះ ផលប្រយោជន៍របស់ម្ចាស់បំណុលដែលអនុវត្តសិទ្ធិឧបាទេសកម្មនឹងត្រូវបានប៉ះពាល់ ហើយកូនបំណុលទី ៣ ក៏មានការលំបាកក្នុងការកំណត់ថា ខ្លួនគួរសងកាតព្វកិច្ចទៅអ្នកណាដែរ ។ បញ្ហាមួយទៀតទាក់ទងនឹងចំណុចថា ប្រសិនបើមានការសងដោយស្ម័គ្រចិត្តដោយកូនបំណុលទី ៣ តើការសងនេះមានសុពលភាព ឬទេ ។ ប្រសិនបើកូនបំណុលទទួលការកម្រិតលើសិទ្ធិអំណាចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយសារការអនុវត្តសិទ្ធិឧបាទេសកម្មដោយម្ចាស់បំណុល នោះគេអាចពិចារណាថា សិទ្ធិក្នុងការទទួលការសងដោយស្ម័គ្រចិត្តពីកូនបំណុលទី ៣ ក៏គួរត្រូវបានបដិសេធដែរ ។ ប៉ុន្តែ មាត្រានេះបានកំណត់ថា ការសងនេះមានសុពលភាព ដោយផ្អែកលើហេតុផលថា សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល មានអត្ថប្រយោជន៍ ក្នុងករណីដែលកូនបំណុលមិនបានរក្សាការពារនូវទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងសកម្ម ដូច្នេះ ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មនឹងមិនទទួលរងនូវការខូចខាតជាក់លាក់ណាមួយឡើយ ប្រសិនបើកូនបំណុលទទួលការសងដោយស្ម័គ្រចិត្តពីកូនបំណុលទី ៣ ។

## **មាត្រា ៤២៦.-** អានុភាពនៃសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល

១-ក្នុងករណីដែលម្ចាស់បំណុលអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្ម អានុភាពត្រូវមានលើកូនបំណុលដោយផ្ទាល់ ។

២-ក្នុងករណីដែលកូនបំណុលមិនអាចទទួលតាវកាលិកពីកូនបំណុលទី ៣ បានទេ ម្ចាស់បំណុលដែលអនុវត្តសិទ្ធិឧបាទេសកម្ម អាចទាមទារឱ្យកូនបំណុលទី ៣ នោះ ផ្តល់តាវកាលិកចំពោះខ្លួនផ្ទាល់បាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ការអនុវត្តសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលត្រូវមានអានុភាពលើកូនបំណុល ។

ការពន្យល់កថាខណ្ឌទី ១ : ក្នុងករណីដែលម្ចាស់បំណុល A បានទទួលការសងនូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចពីកូនបំណុលទី ៣ C តាមរយៈការអនុវត្តសិទ្ធិឧបាទេសកម្ម នោះការសងរបស់កូនបំណុលទី ៣ C នឹងត្រូវចាត់ទុកថាជាការសងចំពោះម្ចាស់បំណុលផ្ទាល់របស់ខ្លួន គឺម្ចាស់បំណុល B (កូនបំណុល) ដូច្នេះ កាតព្វកិច្ចរបស់កូនបំណុលទី ៣ C ត្រូវរលត់ ។

ការពន្យល់កថាខណ្ឌទី ២ : កថាខណ្ឌនេះទាក់ទងទៅនឹងបញ្ហាថា តើម្ចាស់បំណុល A ដែលធ្វើឧបាទេសកម្ម អាចទាមទារឱ្យកូនបំណុលទី ៣ C ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិរបស់ខ្លួនមកខ្លួនផ្ទាល់ ឬ អាចទាមទារគ្រាន់តែឱ្យកូនបំណុលទី ៣ C ប្រគល់នូវវត្ថុនោះដល់កូនបំណុល B ប៉ុណ្ណោះទេ ។ មាត្រានេះបញ្ញត្តថា ជាគោលការណ៍ ម្ចាស់បំណុល A ត្រូវទាមទារឱ្យកូនបំណុលទី ៣ C ផ្តល់តាវកាលិកដល់កូនបំណុល B ។

ប៉ុន្តែ ប្រសិនបើគ្មានកិច្ចសហការពីកូនបំណុល មានការលំបាកក្នុងការធ្វើឱ្យកូនបំណុលទទួលនូវវត្ថុនោះ ហេតុដូច្នេះ មាត្រានេះទទួលស្គាល់ឱ្យម្ចាស់បំណុលដែលធ្វើឧបាទេសកម្មអាចមានសិទ្ធិទាមទារឱ្យកូនបំណុលទី ៣ ប្រគល់នូវវត្ថុនោះមកខ្លួនដោយផ្ទាល់ ប្រសិនបើកូនបំណុលមិនសហការក្នុងការទទួលតាវកាលិកនោះ ឬ បើមានមូលហេតុផ្សេងទៀតដែលមិនអាចឱ្យកូនបំណុលទទួលតាវកាលិកបាន ។

ករណីដែលការទាមទារឱ្យប្រគល់ដោយផ្ទាល់ត្រូវបានទទួលស្គាល់ គឺអាស្រ័យទៅលើប្រភេទនៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិដែលត្រូវបានធ្វើឧបាទេសកម្មនោះ ។ ចំពោះការទាមទារឱ្យធ្វើការចុះបញ្ជីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលត្រូវបានលក់ជាបន្តបន្ទាប់ពីភាគី C ទៅ B រួចទៅ A ប្រសិនបើ A អនុវត្តសិទ្ធិរបស់ B ក្នុងទាមទារឱ្យ C ចុះបញ្ជីការផ្ទេរកម្មសិទ្ធិដោយឧបាទេសកម្ម នោះការចុះបញ្ជីនេះត្រូវបញ្ជាក់អំពីការផ្ទេរពីភាគី C ទៅភាគី B ។ មានន័យថា ភាគី A មិនអាចទាមទារឱ្យភាគី C ធ្វើការផ្ទេរដោយផ្ទាល់មកឱ្យខ្លួនដែលជាម្ចាស់បំណុលដែលធ្វើឧបាទេសកម្មបានឡើយ ។

ចំពោះសិទ្ធិទាមទារឱ្យប្រគល់ប្រាក់ ឬ ចលនវត្ថុ មុនដំបូង ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មត្រូវទាមទារឱ្យភាគី C ប្រគល់វត្ថុនោះទៅឱ្យកូនបំណុល B ហើយប្រសិនបើកូនបំណុល B មិនព្រមទទួលការប្រគល់នោះ ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មអាចទាមទារឱ្យភាគី C ប្រគល់វត្ថុនោះដោយផ្ទាល់មកឱ្យខ្លួន (ភាគី A) បាន ។ សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលអាចអនុវត្តក្រៅផ្លូវតុលាការបាន ប៉ុន្តែ ប្រសិនបើអនុវត្តសិទ្ធិនោះតាមផ្លូវតុលាការ វានឹងទាមទារឱ្យមាននូវភាពប៉ិនប្រសប់ក្នុងការសរសេរសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ ក្នុងការអនុវត្តដោយបង្ខំ ។

**មាត្រា ៤២៧.-** អានុភាពនៃការអនុវត្តសិទ្ធិឧបាទេសកម្ម និង ម្ចាស់បំណុលផ្សេង

ម្ចាស់បំណុលដែលបានអនុវត្តសិទ្ធិឧបាទេសកម្ម មានករណីយកិច្ចរក្សាទុកនូវតាវកាលិកដែលខ្លួនបានទទួលពីកូនបំណុលទី ៣ សម្រាប់ម្ចាស់បំណុលទាំងអស់ រហូតដល់ពេលប្រគល់តាវកាលិកនោះទៅកូនបំណុល ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤២២ (សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងរវាងម្ចាស់បំណុលដែលធ្វើឧបាទេសកម្ម និង ម្ចាស់បំណុលផ្សេងៗទៀត ។ មាត្រានេះបញ្ញត្តថា ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មពុំមានអាទិភាពណាមួយ ក្នុងការទទួលការសម្រេចនូវសិទ្ធិលើបំណុលរបស់ខ្លួនមុននឹងម្ចាស់បំណុលផ្សេងទៀតឡើយ ។

សិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុលគឺជាសិទ្ធិអំណាចមួយដែលត្រូវបានប្រគល់ជូនម្ចាស់បំណុល ដើម្បីរក្សាការពារសិទ្ធិរបស់ខ្លួន នៅក្នុងករណីដែលកូនបំណុលមិនអនុវត្តសិទ្ធិរបស់ខ្លួន ហើយពុំមាន "ទ្រព្យសម្បត្តិទទួលខុសត្រូវ"[៦] គ្រប់គ្រាន់សម្រាប់ម្ចាស់បំណុល ហើយដោយហេតុនេះ វាអាចធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុល លើកលែងតែម្ចាស់បំណុលត្រូវបានអនុញ្ញាតឱ្យចាត់វិធានការតបជាក់លាក់ ។ មានន័យថា ប្រព័ន្ធនៃសិទ្ធិឧបាទេសកម្ម គ្មានគោលបំណងទទួលស្គាល់នូវអាទិភាពរបស់ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មក្នុងការទទួលការសងឡើយ ។ ហេតុដូច្នេះ ម្ចាស់បំណុលផ្សេងៗទៀតអាចទាមទារឱ្យចែកចំណែកនូវវត្ថុដែលម្ចាស់បំណុលដែលធ្វើឧបាទេសកម្មបានទទួលដោយផ្ទាល់ពីកូនបំណុលទី ៣ ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៤២៦ ។ ជាងនេះទៅទៀត ម្ចាស់បំណុលដែលធ្វើឧបាទេសកម្មមិនត្រូវបានអនុញ្ញាតឱ្យធ្វើការទូទាត់នូវសិទ្ធិលើបំណុលដែលខ្លួនមានចំពោះកូនបំណុល ជាមួយនឹងកាតព្វកិច្ចដែលខ្លួនត្រូវសងទៅកូនបំណុលឡើយ ។

## ផ្នែកទី ២ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

(កំណត់)

ប្រព័ន្ធនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍ គឺជាប្រព័ន្ធមួយដែលអនុញ្ញាតឱ្យម្ចាស់បំណុលលុប

[៦] ចំពោះពាក្យ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" សូមមើលកថាភាគទី ១ ផ្នែកទី ៣ ជំពូកទី ២ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ : ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ" (ក្រសួងយុត្តិធម៌ ២០០៩) ។

ចោលនូវអំពើណាមួយរបស់កូនបំណុលដែលធ្វើឱ្យបន្ថយ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" របស់ខ្លួន ទោះបីជាកូនបំណុលពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការសងចំពោះម្ចាស់បំណុលក៏ដោយ ។ ប្រព័ន្ធនេះ មានគោលបំណងអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារឱ្យបញ្ចូលទ្រព្យដែលបានបាត់បង់មកវិញនៅក្នុង "ទ្រព្យសម្បត្តិទទួលខុសត្រូវ" ដោយការលុបចោលអំពើរបស់កូនបំណុល ។ ប្រព័ន្ធនេះមានភាពប្រហាក់ប្រហែលគ្នានឹងសិទ្ធិក្នុងការបដិសេធនៅក្នុងករណីក្ស័យធនដែរ ។ យើងក៏ឃើញមាននូវទស្សនៈដែលថា ប្រព័ន្ធក្ស័យធនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលក្នុងករណីខាងលើនេះ ហើយដែលពុំចាំបាច់បង្កើតនូវប្រព័ន្ធនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍ ។ ប៉ុន្តែការក្ស័យធនមានការប៉ះពាល់យ៉ាងខ្លាំងដល់កូនបំណុល ហើយដំណើរការរបស់វាត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន និងត្រូវចំណាយពេលវេលាច្រើន ហេតុដូច្នេះ មានករណីជាច្រើនរបៀបនេះបញ្ចប់ទៅដោយពុំធ្វើការដាក់ពាក្យសុំក្ស័យធន ។ ក្នុងកាលៈទេសៈបែបនេះ សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍ មានមុខងារពិសេសមួយក្នុងការបង្ការកុំឱ្យបន្ថយទ្រព្យសម្បត្តិរបស់កូនបំណុល ។

**មាត្រា ៤២៨.-** លក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

១-ម្ចាស់បំណុលអាចលុបចោលនូវអំពើដែលកូនបំណុលបានធ្វើដោយដឹងថា អំពើនោះធ្វើឱ្យខូចខាតផលប្រយោជន៍ដល់ម្ចាស់បំណុលនោះ ហើយទាមទារឱ្យអ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះ ឬ អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ សងមកវិញនូវវត្ថុដែលអ្នកនោះបានទទួលជាតាវកាលិក ឬ ទឹកប្រាក់ដែលជាតម្លៃនៃវត្ថុនោះ តាមផ្លូវតុលាការបាន ។[៧]

២-ប្រសិនបើអ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុល ឬ អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ មិនបានដឹងអំពីហេតុដែលធ្វើឱ្យខូចផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលដែលកូនបំណុលធ្វើអំពើនោះ ឬ ពេលដែលខ្លួនបានទទួលបន្តវត្ថុនោះទេ ការលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចត្រូវបានអនុញ្ញាតឡើយ ។ ប៉ុន្តែ ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្ត ដោយមិនបង់ថ្លៃទេ ទោះបីជាអ្នកនោះមិនបានដឹងអំពីហេតុដែលធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលក៏ដោយ ក៏ម្ចាស់បំណុលនោះអាចអះអាងនូវការលុប

[៧] កថាខណ្ឌទី ១ នៃមាត្រា ៤២៨ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

បោលបានដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអំពើដែលមានកម្មវត្ថុមិនមែនជាសិទ្ធិលើទ្រព្យសម្បត្តិទេ ។

(កំណត់)

មាត្រានេះចែងអំពីប្រព័ន្ធនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ដែលមានខ្លឹមសារថា តុលាការអាចលុបចោលអំពើរបស់កូនបំណុលដែលនាំឱ្យខូចខាតផលប្រយោជន៍របស់ម្ចាស់បំណុលបាន តាមការទាមទាររបស់ម្ចាស់បំណុល ដូចជាករណីដែលកូនបំណុលធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យតតិយជន ទោះបីជាខ្លួនគ្មានសាធនភាពគ្រប់គ្រាន់ក្នុងការសងកាតព្វកិច្ចទៅម្ចាស់បំណុល ។

កថាខណ្ឌទី ១ ចែងអំពីល័ក្ខខ័ណ្ឌសម្រាប់ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ ល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងមាត្រានេះគឺ "អំពើដែលកូនបំណុលបានធ្វើដោយដឹងថា អំពើនោះធ្វើឱ្យខូចខាតផលប្រយោជន៍ដល់សិទ្ធិលើបំណុល" របស់ម្ចាស់បំណុល ។ តាមការជាក់ស្តែង គេត្រូវពិនិត្យអំពើជាក់លាក់មួយថា អំពើនោះជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ឬ មិនមែន ដោយផ្អែកលើទស្សនៈ ២ គឺអំពើដែលបណ្តាលឱ្យបន្ថយទ្រព្យសម្បត្តិ (អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ជាសត្យានុម័ត) និង ឆន្ទៈរបស់កូនបំណុលក្នុងការនាំឱ្យខូចខាតផលប្រយោជន៍ (ល័ក្ខខ័ណ្ឌជាអត្តនោម័ត) ។ ហេតុដូច្នេះ ល័ក្ខខ័ណ្ឌសម្រាប់ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺជា (១) ការនាំឱ្យខូចខាតផលប្រយោជន៍ដល់ម្ចាស់បំណុល (ការនាំឱ្យខូចខាតផលប្រយោជន៍ជាសត្យានុម័ត) និង (២) ឆន្ទៈរបស់កូនបំណុលក្នុងការនាំឱ្យខូចខាតផលប្រយោជន៍ ("ដោយដឹងថា អំពើនោះធ្វើឱ្យខូចខាតផលប្រយោជន៍") ។

ខុសគ្នាពីសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ មិនអាចអនុវត្តក្រៅផ្លូវតុលាការបានឡើយ ។ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារឱ្យលុបចោលនូវអំពើនោះ និង ទាមទារឱ្យប្រគល់មកវិញនូវទ្រព្យដែលត្រូវបានចាត់ចែង ។ ចំពោះបញ្ហាថា តើអ្នកណាត្រូវបានយកជាចុងចម្លើយនៅក្នុងបណ្តឹងនេះ មានមតិផ្សេងគ្នា ប៉ុន្តែ មាត្រានេះមិនបានបញ្ជាក់អំពីចំណុចនេះ ហើយទុកសម្រាប់ការបកស្រាយនៅក្នុងយុត្តិសាស្ត្រនៅក្នុងពេលខាងមុខ ។ ចំណុចសង្ខេបដែលត្រូវគិតពិចារណាអំពីបញ្ហានេះ មានដូចតទៅ : ជាដំបូង មានបញ្ហាថា តើកូនបំណុលគួរត្រូវបានកំណត់ថាជាចុងចម្លើយ ឬទេ ។ ទោះបីវាហាក់ដូចជាសមហេតុផលក្នុងការកំណត់ដូចនេះ ដោយហេតុផលថា កូនបំណុលគឺជាជនដែលបានប្រព្រឹត្តនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍ក៏ដោយ ក៏នឹងមានបញ្ហាលំបាកដែរ ពីព្រោះអាចធ្វើឱ្យមានការយឺតយ៉ាវក្នុងការសម្រេចសេចក្តី និង បង្កភាពស្មុគស្មាញដល់ដំណើរការនៃការវិនិច្ឆ័យ ប្រសិនបើចុងចម្លើយមានច្រើននាក់ ។ ប៉ុន្តែ ទោះជាយល់ឃើញពីគុណវិបត្តិនេះក៏ដោយ ក៏ការសម្រេចសេចក្តីដោយយកកូនបំណុលមកធ្វើជាចុងចម្លើយមួយរូប បង្កឱ្យមានលក្ខណៈងាយស្រួលយល់បំផុតដែរ ។ ម្យ៉ាងទៀត បញ្ហាមួយទៀតដែលអាចត្រូវបានគិតពិចារណា គឺចំណុចថា តើត្រូវយកកូនបំណុលជាចុងចម្លើយដោយគ្មានករណីលើក

លែង ឬ គ្រាន់តែអាចយកកូនបំណុលនៅមកជាចុងចម្លើយ ។ ប្រសិនបើទាមទារឱ្យយកកូនបំណុលជាចុងចម្លើយដោយគ្មានករណីលើកលែងនោះ ម្ចាស់បំណុលនឹងអាចមានភាពលំបាកក្នុងការដាក់ពាក្យបណ្ដឹងទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ទៅតុលាការ ។ ហេតុដូច្នេះ វាជាការសមរម្យក្នុងការបកស្រាយថា កូនបំណុល "អាច" ត្រូវបានយកមកជាចុងចម្លើយបាន ។ លើសពីនេះទៀត ដោយសារម្ចាស់បំណុលទាមទារឱ្យប្រគល់មកវិញនូវទ្រព្យដែលត្រូវបានចាត់ចែង អ្នកកាន់កាប់បច្ចុប្បន្ននៃទ្រព្យនោះ (អ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តជាអាទិ៍) នឹងត្រូវបានយកមកធ្វើជាចុងចម្លើយផងដែរ ។ ម្យ៉ាងទៀត ពាក្យ "អ្នកដែលបានទទួលបន្តវត្ថុពីអ្នកនោះ" មិនមែនមានតែបុគ្គលដែលធ្វើលទ្ធកម្មបន្តនូវវត្ថុដោយផ្ទាល់ពីអ្នកដែលបានទទួលផលប្រយោជន៍ប៉ុណ្ណោះទេ តែរាប់បញ្ចូលទាំងបុគ្គលដែលធ្វើលទ្ធកម្មបន្តៗទៀតផងដែរ ។

ការពន្យល់កថាខណ្ឌទី ២ : ទោះបីជាល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ត្រូវបានបំពេញ ហើយសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍បានកើតឡើងក៏ដោយ ក៏ចាំបាច់មានភាពទុច្ចរិតរបស់អ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្ត ដើម្បីទាមទារឱ្យជនទាំងនោះប្រគល់មកវិញនូវទ្រព្យដែលជននោះបានទទួល (ប៉ុន្តែ អ្នកដែលបានទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តត្រូវមានបន្ទុកក្នុងការបញ្ជាក់អំពីភាពសុចរិត) ។ ចំណុចនេះអាចត្រូវបានសន្និដ្ឋានថាជាល័ក្ខខ័ណ្ឌដើម្បីអនុវត្តនូវសិទ្ធិលុបចោលនេះ ។ ដោយយោងតាមបញ្ញត្តិនានាក្នុងច្បាប់បណ្ដាប្រទេសផ្សេងទៀត មាត្រានេះចែងថា ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលុបចោលនោះ ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តដោយមិនបង់ថ្លៃបាន ទោះបីជាជនទាំងនោះជាជនសុចរិតក៏ដោយ ។

ការពន្យល់កថាខណ្ឌទី ៣ : អំពើរបស់កូនបំណុលដែលអាចក្លាយទៅជាកម្មវត្ថុនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ គឺជាអំពើទាក់ទងនឹងទ្រព្យសម្បត្តិ ហើយចំពោះអំពើដែលមិនពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ និង អំពើដែលទាក់ទងនឹងឋានៈបុគ្គល មិនអាចក្លាយទៅជាកម្មវត្ថុនៃសិទ្ធិលុបចោលនោះឡើយ ។ ជួនកាល អាពាហ៍ពិពាហ៍អាចធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុលមានការធ្លាក់ចុះ ប៉ុន្តែ ម្ចាស់បំណុលមិនអាចជ្រៀតជ្រែកបានឡើយ ។ ករណីលំបាកគឺការបោះបង់សន្តតិកម្ម ។ បំណុលនឹងទទួលបាននូវទ្រព្យសម្បត្តិជាក់លាក់មួយចំនួន ប្រសិនបើខ្លួនធ្វើសន្តតិកម្ម ប៉ុន្តែ នឹងមិនទទួលបាននូវទ្រព្យសម្បត្តិនោះ បើខ្លួនបោះបង់សន្តតិកម្មនោះ ។ ទោះបីជាការបោះបង់សន្តតិកម្ម គឺជាអំពើមួយដែលមានទំនាក់ទំនងជិតស្និទ្ធនឹងទ្រព្យសម្បត្តិក៏ដោយ ក៏វាគឺជាចំណុចដែលសន្តតិជនត្រូវធ្វើការសម្រេចចិត្តដោយផ្អែកលើឆន្ទៈផ្ទាល់ខ្លួនដែរ ។ ហេតុដូច្នេះ វាការមិនត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុលជ្រៀតជ្រែក ដូចជាការលុបចោលនូវការបោះបង់សន្តតិកម្មនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨៤៥ ដល់មាត្រា ៨៤៨ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា, មាត្រា ១១៦៧ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១៦៣១ ដល់មាត្រា ១៦៣៤ នៃក្រមរដ្ឋប្បវេណីកេបិច ។

**មាត្រា ៤២៩.-** សិទ្ធិដែលត្រូវបានរក្សាការពារ

បញ្ញត្តិនៃមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលក្រៅពីសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ។ ប៉ុន្តែ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ដែលទាក់ទងនឹងសាលក្រម ឬ សាលដីកាដែលលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ សិទ្ធិលើបំណុលនេះ ត្រូវប្តូរទៅជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់វិញ ។[៨]

(កំណត់)

មាត្រានេះចែងអំពីប្រភេទនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។

ដោយសារប្រព័ន្ធនៃសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងថែរក្សានូវ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" របស់កូនបំណុល វាជាការមិនត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុល A ដែលមានសិទ្ធិទាមទារឱ្យប្រគល់នូវវត្ថុជាក់លាក់ណាមួយ (ឧទាហរណ៍ អ្នកទិញវត្ថុជាក់លាក់) អនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍បាន ដើម្បីសម្រេចការប្រគល់វត្ថុជាក់លាក់នោះឡើយ ។ ដូច្នេះ ជាគោលការណ៍ សិទ្ធិដែលត្រូវបានរក្សាការពារត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។ ប៉ុន្តែ នៅពេលដែលអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះមិនចាំបាច់មានគោលបំណងឱ្យសងជាប្រាក់ឡើយ ។ មានន័យថា សិទ្ធិលើបំណុលនោះចាំបាច់ត្រូវក្លាយជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដែលទាក់ទងនឹងសាលក្រម ឬ សាលដីកាដែលលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុល A មានសិទ្ធិទាមទារឱ្យប្រគល់នូវវត្ថុជាក់លាក់ (ដី) ដោយទិញដីនោះពីកូនបំណុល B ប្រសិនបើកូនបំណុល B ធ្វើប្រទានកម្មដីនោះ ទៅបដិគ្គាហក C ដោយឥតគិតថ្លៃ នោះកាតព្វកិច្ចរបស់កូនបំណុល B ក្នុងការប្រគល់ដីទៅម្ចាស់បំណុល A ត្រូវក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្ត ហើយសិទ្ធិលើបំណុលរបស់ A នឹងប្តូរទៅជាសិទ្ធិទាមទារឱ្យសងសំណងការខូចខាត ។ ម្ចាស់បំណុល A អាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតប្រយោជន៍បាន ដោយផ្អែកលើសិទ្ធិទាមទារឱ្យសងសំណងការខូចខាតនោះ ។

---

[៨] វាក្យខណ្ឌទី ២ នៃមាត្រា ៤២៩ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១៦៣៤ នៃក្រមរដ្ឋប្បវេណីកេបិច

**មាត្រា ៤៣០.-** វិធីលុបចោលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

ក្នុងករណីដែលគ្មានវិធីសមរម្យផ្សេងដើម្បីឱ្យអ្នកដែលបានទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តវត្ថុផ្ញើបដិទាន ម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោលអាចទាមទារឱ្យអ្នកដែលបានទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តវត្ថុនោះ តម្កល់នូវវត្ថុដែលទទួលបាន ។

( កំណត់)

មាត្រានេះបញ្ញត្តថា តើម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ អាចធ្វើការទាមទារអ្វីខ្លះ ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្ត ។ មាត្រានេះបានថែងពីទស្សនៈដែលថា ម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកដែលទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្ត ប្រគល់នូវទ្រព្យសម្បត្តិដែលបានចេញពីកូនបំណុល ទៅឱ្យខ្លួនដោយចំពោះបានឡើយ ។ ដូច្នេះ ម្ចាស់បំណុលដែលអនុវត្តសិទ្ធិលុបចោល ជាដំបូងអាចទាមទារអ្នកដែលទទួលប្រយោជន៍ ឬ អ្នកដែលបានទទួលបន្តនោះឱ្យប្រគល់វត្ថុនោះត្រឡប់ទៅឱ្យកូនបំណុលវិញបាន ។ ប៉ុន្តែ នៅក្នុងករណីដែលកូនបំណុលមិនទទួលទ្រព្យនោះ ឬ ករណីផ្សេងទៀតដែលបដិទានតាមវិធីប្រគល់វិញនូវវត្ថុនោះ ទៅឱ្យកូនបំណុល គ្មានភាពសមរម្យ មាត្រានេះបានអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារឱ្យតម្កល់នូវវត្ថុនោះ ។

ការតាក់តែងនេះបានត្រូវធ្វើឡើងដោយយោងលើហេតុផលថា វាជាការមិនត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារឱ្យប្រគល់នូវវត្ថុនោះដោយចំពោះមកខ្លួន ដោយសារវានឹងមានន័យថា តាមការជាក់ស្តែង ម្ចាស់បំណុលនោះមានអាទិភាពក្នុងការទទួលការសង ដែលនាំឱ្យមានភាពមិនស្របគ្នាជាមួយនឹងគោលបំណងដែលសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នឹងត្រូវបានបង្កើតឡើងសម្រាប់ផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ។

**មាត្រា ៤៣១.-** អានុភាពនៃសិទ្ធិលុបចោលដែលនាំឱ្យខូចខាតផលប្រយោជន៍

ការលុបចោលដែលត្រូវបានធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) នៃក្រមនេះ ត្រូវបង្កើតអានុភាពសម្រាប់ផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ។

( កំណត់)

នៅក្នុងករណីដែលសិទ្ធិលុបចោលត្រូវបានអនុវត្ត ហើយទ្រព្យសម្បត្តិដែលកូនបំណុលបានបាត់បង់ត្រូវបានប្រគល់មកវិញ ទ្រព្យសម្បត្តិនោះនឹងត្រូវក្លាយជាទ្រព្យសម្បត្តិដែលត្រូវបានចែកចំណែកសម្រាប់ម្ចាស់បំណុលទាំងអស់ ។ ឧទាហរណ៍ ប្រសិនបើអំពើរបស់កូនបំណុល B ដែលធ្វើអនុប្បទានដីទៅ C ដោយឥតគិតថ្លៃ ត្រូវបានលុបចោលដោយសារវាជាអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ នោះការចុះបញ្ជីដីក្រោមឈ្មោះភាគី C នឹងត្រូវបានលុបចោល ។ នៅពេលនោះ ដីនោះនឹងត្រូវត្រឡប់មកស្ថិតនៅក្រោមឈ្មោះរបស់កូនបំណុល B វិញ ហើយរាល់ម្ចាស់បំណុលគ្រប់រូបរបស់កូនបំណុល B មានសិទ្ធិក្នុងការប្រមូលបំណុលពីដីនោះបាន ។ មានន័យថា ម្ចាស់បំណុលដែលអនុវត្តនូវសិទ្ធិលុបចោល ព្រមទាំងម្ចាស់បំណុលផ្សេងទៀត អាចអនុវត្តដោយបង្ខំចំពោះដីនោះ ឬ ចូលរួមក្នុងការចែកចំណែក ប្រសិនបើម្ចាស់បំណុលផ្សេងទៀតបានធ្វើការអនុវត្តដោយបង្ខំ ។

ទោះជាយ៉ាងនេះក៏ដោយ វាជាការសំខាន់ក្នុងការធ្វើឱ្យអានុភាពដែលបានរៀបរាប់ខាងលើមានប្រសិទ្ធភាព ដោយកំណត់នូវវិធានជានីតិវិធី និង រៀបចំនូវប្រព័ន្ធចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

ម្រាត្រា ៤២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៣២.– អំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍

១-សិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែលបានកំណត់នៅក្នុងមាត្រា ៤២៨ (ល័ក្ខខ័ណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍) នៃក្រមនេះ នឹងត្រូវរលត់ នៅពេលដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីពេលដែលម្ចាស់បំណុលនោះបានដឹងអំពីមូលហេតុនៃការលុបចោលនោះ ។ សិទ្ធិនោះនឹងត្រូវរលត់ដែរ នៅពេលដែលអំឡុងពេល ៣ (បី) ឆ្នាំ កន្លងផុតបន្ទាប់ពីពេលដែលអំពើត្រូវបានធ្វើឡើង ។

២-បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល មិនត្រូវយកមកអនុវត្តឡើយ ចំពោះអាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះកំណត់អំពីអំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ អំឡុងពេលខ្លី (១ ឆ្នាំ) និង អំឡុងពេល ៣ ឆ្នាំដែលបានកំណត់នៅក្នុងមាត្រានេះ មិនមែនជាអំឡុងពេលនៃអាជ្ញាយុកាលទេ គឺជាអំឡុងពេលដាច់ខាតដើម្បីអនុវត្តសិទ្ធិ (អាចសន្និដ្ឋានថាជាអំឡុងពេលដែលច្បាប់បានកំណត់ជាមុន (délai préfix)

បាន ដែរ) ។ ហេតុដូច្នេះ បញ្ញត្តិដែលទាក់ទងទៅនឹងការផ្អាកអាជ្ញាយុកាល មិនត្រូវយកមកអនុវត្តចំពោះអំឡុងពេលនេះឡើយ ។

ប្រសិនបើអំពើណាមួយរបស់កូនបំណុល ត្រូវបានលុបចោលតាមរយៈសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ហើយទ្រព្យដែលបានធ្លាក់ក្នុងកណ្ដាប់ដៃរបស់បុគ្គលផ្សេងៗបានត្រឡប់មកស្ថិតក្រោមការគ្រប់គ្រងរបស់កូនបំណុលវិញនោះ វានឹងបណ្ដាលឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងថា ដំណើរការនេះអាចប៉ះពាល់ដល់ស្ថិរភាពក្នុងការធ្វើប្រតិបត្តិការ ។ ដូច្នេះ អំឡុងពេលនៃការអនុវត្តនូវសិទ្ធិលុបចោលនេះត្រូវបានកំណត់ជាអំឡុងពេលដាច់ខាតមួយ ដែលមិនអាចត្រូវបានពន្យារបានដោយសារការផ្អាកអាជ្ញាយុកាលឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៧ ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.-** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ព្យាកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

(កំណត់)

មាត្រានេះរៀបរាប់យ៉ាងលម្អិតអំពីមូលហេតុនៃការរលត់កាតព្វកិច្ច ។ ប៉ុន្តែ ជំពូកទី ៧ មិនកំណត់អំពីរាល់មូលហេតុទាំងអស់នោះទេ ។ ពាក្យថា "ការរលត់កាតព្វកិច្ច" មានន័យថា កាតព្វកិច្ចដែលត្រូវបានបង្កើតឡើងម្តង រលត់ដោយសារហេតុផលមួយចំនួន ។ ហេតុដូច្នេះ ពាក្យនេះ មិនរាប់បញ្ចូលករណីដែលកាតព្វកិច្ចត្រូវចាត់ទុកថាជាមោឃៈតាំងពីដំបូងមកទេ ។ ការលុបចោល ត្រូវបានបញ្ចូលក្នុងមាត្រានេះ ដោយសារកាតព្វកិច្ចរលត់ លុះត្រាតែមានការអនុវត្តសិទ្ធិលុបចោល ។ ប៉ុន្តែ ការលុបចោល គឺជាករណីដែលកាតព្វកិច្ចត្រូវរលត់ ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ តាំងពីពេលចាប់ផ្តើមបង្កើតកាតព្វកិច្ចមក ហើយមានលក្ខណៈខុសប្លែកពីមូលហេតុឯទៀតដែលមានរៀបរាប់ក្នុងមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ១២៣៤ នៃក្រមរដ្ឋប្បវេណីបារាំង

# ផ្នែកទី ១ ការសង

## កថាភាគទី ១ គោលការណ៍ទូទៅស្តីពីការសង

**មាត្រា ៤៣៤.-** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល ។

៣-ម្ចាស់បំណុល និង កូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា តើការសងរបស់បុគ្គលណាដែលក្លាយអាចជាការសងបាន ។ ជាទូទៅ ការសងដោយកូនបំណុលក្លាយជាការសងដែលមានអានុភាពផ្នែកច្បាប់ ហេតុដូច្នេះ មិនចាំបាច់រៀបរាប់អំពីចំណុចនេះក្នុងមាត្រានេះទេ ។ បញ្ហាគឺនៅត្រង់ចំណុចថា តើតតិយជនអាចសងជំនួសកូនបំណុលបាន ឬ មិនបាន ។ មាត្រានេះបញ្ញត្តថា ជាគោលការណ៍ តតិយជនអាចសងជំនួសកូនបំណុលបាន ។

ប៉ុន្តែ ក្នុងករណីដែលរៀបរាប់ខាងក្រោមនេះ តតិយជនមិនអាចសងជំនួសកូនបំណុលបានឡើយ ។

ទី ១ ក្នុងករណីដែលបានធ្វើកិច្ចសន្យា ដោយសារកូនបំណុលខ្លួនឯងជាអ្នកអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ឧទាហរណ៍ កិច្ចសន្យាការងារដែលផ្តល់សេវាការងារ ឬ កិច្ចសន្យាគូររូប ជាដើម គ្មានភាពសមរម្យក្នុងការទទួលស្គាល់សកម្មភាព

ដែលតតិយជនធ្វើជំនួសកូនបំណុលថាជាការសងទេ ។ កថាខណ្ឌទី ២ ចែងអំពីចំណុចនេះ ។ និយាយឱ្យងាយយល់ នេះគឺគ្រាន់តែជារឿងទូទៅមួយទៅហើយ ។ លក្ខណៈពិសេសនៃមាត្រានេះ មានត្រង់ចំណុចថា តតិយជនអាចសងជំនួសកូនបំណុលបាន ប្រសិនបើម្ចាស់បំណុលយល់ព្រម ។

ទី ២ គឺជាករណីដែលកិច្ចព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល មិនអនុញ្ញាតឱ្យតតិយជនសងជំនួសកូនបំណុល ។ មានន័យថា តតិយជនអាចសងជំនួសកូនបំណុលបាន ទោះបីជាការសងនោះផ្ទុយនឹងឆន្ទៈរបស់ភាគីម្ខាងនៃកិច្ចសន្យាក៏ដោយ លើកលែងតែមានកិច្ចព្រមព្រៀងរវាងភាគីពាក់ព័ន្ធកំណត់ថា តតិយជនមិនអាចសងជំនួសកូនបំណុល។ អ្វីដែលបង្កឱ្យមានបញ្ហាក្នុងករណីជាក់លាក់នេះ គឺការសងដោយផ្ទុយនឹងឆន្ទៈរបស់កូនបំណុល ។ ប្រសិនបើតតិយជនសង តតិយជននោះត្រូវធ្វើលទ្ធកម្មនូវសិទ្ធិរបស់ម្ចាស់បំណុល តាមប្រព័ន្ធឧបាទេសកម្មដោយការសង ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៤៩៩ និង មាត្រាបន្តបន្ទាប់ ។ ដោយមូលហេតុនេះ ក្នុងករណីជាក់ស្តែងខ្លះ តតិយជនដែលបានសងធ្វើការប្រមូលបំណុលក្នុងនាមម្ចាស់បំណុលយ៉ាងតឹងរ៉ឹងជាងម្ចាស់បំណុលដើម ដូច្នេះ ការអនុញ្ញាតឱ្យតតិយជនសង ឬមិនឱ្យនោះ នឹងមានឥទ្ធិពលខ្លាំងទៅនឹងផលប្រយោជន៍របស់កូនបំណុល ។ ក្នុងកាលៈទេសៈនេះ ច្បាប់របស់ប្រទេសមួយចំនួន (ឧទាហរណ៍ កថាខណ្ឌទី ២ មាត្រា ៤៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន) បញ្ញត្តថា កូនបំណុលអាចបដិសេធតាមឆន្ទៈផ្ទាល់របស់ខ្លួន ចំពោះការសងដោយតតិយជនដែលគ្មានពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងការសងបាន ។ ប៉ុន្តែ អនុប្បទានសិទ្ធិលើបំណុលដែលមានលក្ខណៈស្រដៀងខាងផ្នែកតួនាទី ទៅនឹងការសងដោយតតិយជន អាចធ្វើបានដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលនោះទេ ហេតុដូច្នេះ ដោយពិចារណាលើតុល្យភាពរវាងអនុប្បទានសិទ្ធិលើបំណុល និង ការសងដោយតតិយជន បញ្ញត្តិនេះចែងថា កូនបំណុលតែម្នាក់ឯងមិនអាចបដិសេធការសងដោយតតិយជនបានឡើយ ហើយការមិនអនុញ្ញាតឱ្យតតិយជនសង អាចធ្វើបាន លុះត្រាតែមានការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ។

ប្រសិនបើតតិយជនបានសង ទំនាក់ទំនងគតិយុត្តរវាងភាគីពាក់ព័ន្ធនឹងមានលក្ខណៈដូចខាងក្រោម ។ ប្រសិនបើតតិយជនបានធ្វើការសងដោយមានសុពលភាព កាតព្វកិច្ចត្រូវរលត់ដោយសារការសងនោះ ហើយកូនបំណុលត្រូវរួចផុតពីបន្ទុកនៃកាតព្វកិច្ច ប៉ុន្តែ តតិយជនដែលបានសង ត្រូវទទួលបាននូវសិទ្ធិទាមទារសំណងពីកូនបំណុល ដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ជាដើម ។ម្យ៉ាងវិញទៀត អនុលោមតាមបញ្ញត្តិនៃមាត្រា ៤៩៩ ស្តីពី "ឧបាទេសកម្មដោយការសង" អ្នកសងអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មបាន ។ ហេតុដូច្នេះ ការសងដោយតតិយជន មានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងការផ្លាស់ប្តូរម្ចាស់បំណុល (អនុប្បទានសិទ្ធិលើបំណុល) ។ គួរកត់សម្គាល់ថា ក្នុងករណីដែលមានទំនាក់ទំនងនៃកិច្ចសន្យាអញ្ញមញ្ញ ប្រសិនបើតតិយជនសង ទំនាក់ទំនងស្មុគស្មាញក្នុងចំណោមភាគីពាក់ព័ន្ធ នឹងកើតឡើង។ ឧទាហរណ៍ ក្នុងករណីដែលតតិយជនទទួលបានការអនុញ្ញាតពីនិយោជកឱ្យផ្តល់នូវពលកម្មតាមកិច្ចសន្យាការងារ បញ្ហាដែលអាចមាន គឺនៅត្រង់ចំណុចថា តើនិយោជកគួរបង់ប្រាក់ឈ្នួលឱ្យទៅនរណា ។ ទោះបីជាមានការសងដោយតតិយជនក៏ដោយ ក៏ទំនាក់ទំនងនៃកិច្ចសន្យានោះពុំមានផ្លាស់ប្តូរល័ក្ខខ័ណ្ឌអ្វីឡើយ ដូច្នេះ និយោជកត្រូវបង់ប្រាក់ឈ្នួលទៅឱ្យ

កូនបំណុលដើមនៃកិច្ចសន្យា (កូនបំណុលមានសិទ្ធិទាមទារប្រាក់ឈ្នួល) ។ ប៉ុន្តែ ក្នុងទំនាក់ទំនងរវាងកូនបំណុល និង តតិយជនវិញនោះ ការដែលកូនបំណុលទទួលប្រាក់ឈ្នួល ត្រូវក្លាយទៅជាសេចក្តីចម្រើនដោយឥតហេតុ ។ ហេតុដូច្នេះ កូនបំណុលចាំបាច់ត្រូវប្រគល់ឱ្យតតិយជននូវប្រាក់ឈ្នួលដែលខ្លួនបានទទួល ។

ដោយសារអ្នកធានា និង កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព មានកាតព្វកិច្ចរបស់ខ្លួនផ្ទាល់ ចំពោះម្ចាស់បំណុល អ្នកទាំងនោះត្រូវសងចំពោះកាតព្វកិច្ចផ្ទាល់របស់ខ្លួន ។ ហេតុដូច្នេះ អ្នកទាំងនោះ មិនត្រូវបានរាប់បញ្ចូលនៅក្នុង "តតិយជន" ដែលបានកំណត់ក្នុងមាត្រានេះទេ ។ ផ្ទុយទៅវិញ អ្នកធានាដោយវត្ថុដែលបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួនសម្រាប់កូនបំណុលចម្បង ឬ តតិយជនដែលបានធ្វើលទ្ធកម្ម ដែលទិញអចលនវត្ថុដែលភ្ជាប់នឹងហ៊ីប៉ូតែក គ្មានកាតព្វកិច្ចរបស់ខ្លួន ចំពោះម្ចាស់បំណុលទេ ដូច្នេះ អ្នកទាំងនេះ គឺជាឧទាហរណ៍ចម្បងនៃតតិយជនដែលមានការពាក់ព័ន្ធ នឹងផលប្រយោជន៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៣៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៩១ និង ៨៩២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៤៣៥.–** សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍

១-ប្រសិនបើអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិ ឬ មិនមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការសងទេ ការសងរបស់អ្នកសងនោះមិនមានសុពលភាពឡើយ ។

២-ក្នុងករណីដែលអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងទេ អ្នកសងនោះមិនអាចយកវត្ថុនោះមកវិញបានឡើយ លើកលែងតែមានការសងម្តងទៀតដែលមានសុពលភាព ។ ប៉ុន្តែ អ្នកដែលមានកម្មសិទ្ធិលើវត្ថុនោះ អាចយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទទួលការសងមកវិញបាន ។

៣-ក្នុងករណីដែលអ្នកសងគ្មានសមត្ថភាពចាត់ចែងកម្មវត្ថុនៃការសងទេ អ្នកសងនោះអាចលុបចោលនូវអំពើសងដែលខ្លួនបានធ្វើ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រគល់កម្មវត្ថុនៃការសងវិញ ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីគោលការណ៍ដែលមានខ្លឹមសារថា ដើម្បីចាត់ទុកថា ការសងមានសុពលភាព អ្នកសងត្រូវមាន

កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសង និង មានសមត្ថភាពក្នុងការចាត់ចែងវត្ថុនោះ (កថាខណ្ឌទី ១) ហើយបញ្ជាក់ថា តើមានអ្វីនឹងកើតឡើង ក្នុងករណីដែលអ្នកសងគ្មានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសង ឬ គ្មានសមត្ថភាពចាត់ចែងវត្ថុនោះ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។

ក្នុងករណីអ្នកសងគ្មានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសង នឹងមានស្ថានភាពដូចខាងក្រោមនេះ (កថាខណ្ឌទី ២) ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកលក់ A លក់គោមួយក្បាលឱ្យអ្នកទិញ B ប្រសិនបើអ្នកលក់ A គ្មានកម្មសិទ្ធិលើគោដែលត្រូវបានប្រគល់ជាការសងឱ្យអ្នកទិញ B ទេនោះ ការសងនេះមិនមែនជាការសងដែលមានសុពលភាពទេ ។ ក្នុងករណីនេះ C ដែលជាម្ចាស់កម្មសិទ្ធិលើគោមួយក្បាលនោះ អាចយកគោដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទិញ B វិញ បាន។ ប៉ុន្តែ ប្រសិនបើអ្នកសង A មិនបានប្រគល់ទៅឱ្យអ្នកទិញ B នូវគោដែលខ្លួនផ្ទាល់មានកម្មសិទ្ធិទេនោះ អ្នកសង A នោះមិនអាចយកគោ (របស់ម្ចាស់កម្មសិទ្ធិ C) ដែលខ្លួនបានប្រគល់ជាការសងឱ្យអ្នកទិញ B បានទេ ។

ករណីដែលអ្នកសងគ្មានសមត្ថភាពក្នុងការចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃការសងទេ មានដូចជាករណីដែលការសងត្រូវបានធ្វើដោយអនីតិជន ឬ ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (កថាខណ្ឌទី ៣) ។ ក្នុងករណីនេះ បើទោះជាអនីតិជន ជាអាទិ៍ មានកម្មសិទ្ធិលើវត្ថុនោះក៏ដោយ ក៏សកម្មភាពសងដែលខ្លួនបានធ្វើ អាចត្រូវបានលុបចោលដោយសារមូលហេតុនៃការកម្រិតសមត្ថភាព ។

ចាំបាច់ត្រូវប្រុងប្រយ័ត្ននៅពេលដែលការសងត្រូវធ្វើឡើងក្នុងរូបភាពជាប្រាក់ ។ កម្មសិទ្ធិលើប្រាក់ គឺជាបញ្ហាទាក់ទងនឹងច្បាប់អំពីសិទ្ធិប្រត្យក្ស ប៉ុន្តែ ជាទូទៅ ការចរាចរនៃប្រាក់ចាំបាច់ត្រូវបានការពារដោយគ្រប់គ្រាន់ ។ ម្ចាស់បំណុលដែលទទួលបាននូវប្រាក់ មិនចាំបាច់បញ្ជាក់ថា កូនបំណុលមានកម្មសិទ្ធិលើប្រាក់នោះទេ ព្រោះថា ប្រសិនបើម្ចាស់បំណុលចាំបាច់ត្រូវបញ្ជាក់អំពីកម្មសិទ្ធិលើប្រាក់នោះរាល់ពេល ប្រាក់នឹងមិនអាចត្រូវបានធ្វើចរាចរយ៉ាងទូលំទូលាយបានទេ ។ ដូច្នេះ ក្នុងករណីដែលការសងត្រូវធ្វើឡើងជាប្រាក់ ជាគោលការណ៍ ការសងនោះត្រូវចាត់ថាមានសុពលភាព ទោះបីជាអ្នកសង ប្រើប្រាស់ប្រាក់ដែលខ្លួនលួចពីអ្នកដទៃសម្រាប់ការសងក៏ដោយ ។ មាត្រានេះពុំមានចែងពីចំណុចនេះឱ្យបានច្បាស់លាស់ទេ ប៉ុន្តែ ចំណុចនេះអាចដោះស្រាយបានដោយផ្អែកលើទ្រឹស្តីស្តីពីកម្មសិទ្ធិលើប្រាក់ ។ មានន័យថា បើទោះជាអ្នកសងធ្វើការសងដោយប្រើប្រាស់ប្រាក់ដែលខ្លួនលួចពីអ្នកដទៃក៏ដោយ ដោយសារប្រាក់នោះក្លាយជាប្រាក់របស់អ្នកសងនោះ តាមការទទួលបាននូវការកាន់កាប់ប្រាក់នោះ ដូច្នេះ ចំពោះការសង គឺអ្នកសងធ្វើការសងដោយប្រើប្រាស់ប្រាក់របស់ខ្លួនផ្ទាល់ដែរ ។ ហេតុដូច្នេះ ករណីបែបនេះ ដោះស្រាយបានដោយយោងតាមមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៤៧៥ និង មាត្រា ៤៧៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៣៦.- ការប្រើប្រាស់ ឬ អនុប្បទានរបស់ម្ចាស់បំណុល និង ការទទួលដោយសុចរិត

១-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៣៥ (សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍) ខាងលើនេះ បើកម្មវត្ថុនៃការសងជាចលនវត្ថុ ហើយម្ចាស់បំណុលបានបរិភោគ ឬ ធ្វើអនុប្បទានដោយសុចរិត នូវវត្ថុដែលបានទទួលពីការសង ការសងនោះត្រូវចាត់ទុកថាមានសុពលភាព ហើយអ្នកសងមិនអាចទាមទារឱ្យប្រគល់កម្មវត្ថុនៃការសងនោះ មកវិញបានទេ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលមានកម្មសិទ្ធិលើកម្មវត្ថុនៃការសង អាចទាមទារនូវសំណងនៃការខូចខាតចំពោះកម្មវត្ថុនៃការសងនោះពីអ្នកទទួលការសងបាន លើកលែងតែអ្នកទទួលការសងនោះបានទទួលកម្មសិទ្ធិលើវត្ថុនៃការសង ដោយស្របទៅតាមបញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ ម្ចាស់បំណុលដែលបានសងការខូចខាតទៅម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងនោះ អាចទាមទារឱ្យកូនបំណុលសងជាប្រាក់នូវតម្លៃដែលខ្លួនបានសងនោះវិញបាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ទោះបីជាការសងគ្មានសុពលភាព ដោយសារមិនបំពេញល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣៥ ក៏ដោយ ក្នុងករណីដែលម្ចាស់បំណុលបានបរិភោគដោយសុចរិតនូវវត្ថុដែលបានទទួលជាការសង ក៏ការសងនេះត្រូវចាត់ទុកថា មានសុពលភាព នៅក្នុងទំនាក់ទំនងរវាងម្ចាស់បំណុល និង កូនបំណុលដែរ (កថាខណ្ឌទី ១) ។ ប៉ុន្តែ នេះមិនមែនមានន័យថា ម្ចាស់កម្មសិទ្ធិពិតប្រាកដនៃវត្ថុ បាត់បង់នូវកម្មសិទ្ធិលើវត្ថុរបស់ខ្លួនដែលត្រូវបានប្រើប្រាស់សម្រាប់ការសងនោះទេ ។ ករណីដែលម្ចាស់កម្មសិទ្ធិពិតប្រាកដនៃវត្ថុ បាត់បង់កម្មសិទ្ធិវត្ថុនោះ គឺមានតែករណីដែលលទ្ធកម្មដោយសុចរិត ឬ អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ត្រូវបានសម្រេចប៉ុណ្ណោះ ។ ប្រសិនបើលទ្ធកម្មដោយសុចរិត ឬ អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ត្រូវបានសម្រេច ការសងក៏មានសុពលភាពដែរ (កថាខណ្ឌទី ២) ។

ម្យ៉ាងទៀត មាត្រានេះពុំបញ្ញត្តដោយផ្ទាល់ទេ តែវិធីក្នុងការគិតដែលជាបុរេល័ក្ខខ័ណ្ឌនៃមាត្រានេះ គឺផ្អែកលើសេចក្តីសន្និដ្ឋានថា ក្នុងករណីដែលសកម្មភាពរបស់ម្ចាស់បំណុលក្នុងការទទួលនូវវត្ថុជាការសង បំពេញល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិត (មាត្រា ១៩៣) ម្ចាស់បំណុលធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលខ្លួនបានទទួលជាការសងនោះ តាមលទ្ធកម្មដោយសុចរិត ។ ក្នុងករណីនេះ កម្មសិទ្ធិករពិតប្រាកដនៃវត្ថុដែលជាកម្មវត្ថុនៃការសង ក៏មិនអាចទាមទារឱ្យប្រគល់វិញនូវវត្ថុនោះឡើយ ។ ដូច្នេះ មាត្រានេះមានគោលបំណងការពារម្ចាស់បំណុលសុចរិតដែលបានទទួលការសង ទោះបីជាមិនបំពេញល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិតក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១២៣៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៣៧.-** សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬ អ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង ។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀត តាមការទាមទារពីម្ចាស់បំណុលនោះ ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឱ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ការសងមានសុពលភាព លុះត្រាតែការសងនោះត្រូវធ្វើឡើងចំពោះបុគ្គលដែលមានសិទ្ធិទទួលការសង ។ ខ្លឹមសារនៃមាត្រានេះ គឺជារឿងធម្មតា ប៉ុន្តែ ការចែងនេះគឺដើម្បីធ្វើឱ្យប្រាកដច្បាស់លាស់ ។

បុគ្គលដែលមានសិទ្ធិទទួលការសង ក្រៅពីម្ចាស់បំណុល រួមមាន (១) អ្នកតំណាងដែលទទួលការប្រគល់សិទ្ធិពីម្ចាស់បំណុលឱ្យទទួលការសង (២) បុគ្គលដែលទទួលសិទ្ធិពីម្ចាស់បំណុលឱ្យទទួលការសងក្នុងនាមខ្លួនឯងផ្ទាល់ (ជាទូទៅបុគ្គលនេះក៏បានទទួលសិទ្ធិអំណាចក្នុងការទាមទារឱ្យកូនបំណុលធ្វើការសងដោយសកម្មដែរ ដូច្នេះ ការណ៍នេះត្រូវហៅថា "អាណត្តិក្នុងការប្រមូល") និង (៣) បុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការប្រមូលដោយតុលាការ ដោយរឹបអូសសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល (ម្ចាស់បំណុលនៃការអនុវត្ត) ។ ក្នុងករណីទី ១ ម្ចាស់បំណុលក៏រក្សាសិទ្ធិក្នុងការទទួលការសងនៅពេលជាមួយគ្នានេះដែរ ។ ក្នុងករណីទី ២ មានករណីដែលម្ចាស់បំណុលរក្សាសិទ្ធិក្នុងការទទួលការសង និងករណីដែលម្ចាស់បំណុលមិនរក្សាសិទ្ធិនោះ ។ ការរក្សាសិទ្ធិទទួលការសង ឬ មិនរក្សានោះ អាស្រ័យទៅតាមកិច្ចសន្យារវាងម្ចាស់បំណុល និង បុគ្គលដែលទទួលបាននូវសិទ្ធិអំណាចក្នុងការទទួលការសងនោះ ។

ដោយសារការសងនឹងគ្មានសុពលភាព ប្រសិនបើការសងមិនធ្វើចំពោះបុគ្គលដែលមានសិទ្ធិអំណាចក្នុងការទទួលការសង ការសងចាំបាច់ត្រូវធ្វើម្តងទៀត ប្រសិនបើម្ចាស់បំណុលដើមទាមទារឱ្យធ្វើដូច្នោះ ។ ក្នុងករណីនេះ កូនបំណុលត្រូវធ្វើការសងម្តងទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៣៩ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៣៨.-** ការកម្រិតនូវសិទ្ធិទទួលការសងដោយការរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូស ដោយដីកាសម្រេចរឹបអូសរបស់តុលាការ ម្ចាស់បំណុលនោះមិនមានសិទ្ធិទទួលការសងពីកូនបំណុលរបស់ខ្លួន ហើយកូនបំណុលនោះមិនអាចសងទៅម្ចាស់បំណុលនោះបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៣៧ (សិទ្ធិទទួលការសង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលដែលត្រូវបានហាមការសង បានសងទៅម្ចាស់បំណុលរបស់ខ្លួន ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីទំនាក់ទំនងគតិយុត្តក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូស ។

ប្រសិនបើ A រឹបអូសសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល B ទំនាក់ទំនងដែលកើតឡើង មានដូចខាងក្រោម : ម្ចាស់បំណុលនៃការអនុវត្ត A → ម្ចាស់បំណុល (កូនបំណុលនៃការអនុវត្ត) B → កូនបំណុលទី ៣ C ។ ក្នុងករណីនេះ សិទ្ធិអំណាចរបស់ម្ចាស់បំណុល B ក្នុងការទទួលការសង ត្រូវបានកម្រិត ហើយទោះបីជាកូនបំណុលទី ៣ C សងចំពោះម្ចាស់បំណុល B ក៏ដោយ ក៏ការសងនេះមិនមែនជាការសងដែលមានសុពលភាពទេ ។ ចំណុចនេះបានចែងនៅក្នុងបញ្ញត្តិនៃមាត្រាមុនរួចហើយ ប៉ុន្តែ ករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូស កើតឡើងជាញឹកញាប់ ដូច្នេះ មាត្រានេះបញ្ញត្តអំពីករណីរឹបអូសនេះ ដោយសារគិតពិចារណាថា ចាំបាច់ត្រូវកំណត់ចំណុចនេះឱ្យច្បាស់ក្នុងមាត្រានេះ ដោយមិនទុកឱ្យបកស្រាយមាត្រា ៤៣៧ ។

ម្យ៉ាងវិញទៀត កថាខណ្ឌទី ១ នៃមាត្រានេះខ្លាំងក្លាជាងកថាខណ្ឌទី ១ នៃមាត្រា ៤៣៧ ។ មានន័យថា ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូស កូនបំណុលត្រូវមានករណីយកិច្ចដែលមានខ្លឹមសារថា មិនអាចសងទៅម្ចាស់បំណុលបានទេ ។

កថាខណ្ឌទី ២ ប្រើពាក្យ "កូនបំណុលដែលត្រូវបានហាមការសង" ប៉ុន្តែ ដីកាសម្រេចរឹបអូសរបស់តុលាការ កម្រិតត្រឹមតែសិទ្ធិអំណាចរបស់ម្ចាស់បំណុលក្នុងការទទួលការសងដោយផ្ទាល់តែប៉ុណ្ណោះ ។ ដូច្នេះ ដីកាសម្រេចរឹបអូសរបស់តុលាការ មិនហាមឃាត់សកម្មភាពនៃការសងរបស់កូនបំណុលដោយផ្ទាល់នោះទេ ។ មានតែកថាខណ្ឌទី ១ នៃមាត្រានេះប៉ុណ្ណោះដែលហាមឃាត់កូនបំណុលមិនឱ្យធ្វើការសង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៤១ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៣៩.-** ការសងដែលបានធ្វើចំពោះឧបភោគីនៃសិទ្ធិលើបំណុល

១-ចំពោះការសងដែលបានធ្វើទៅអ្នកដែលមិនមែនជាម្ចាស់បំណុល តែមើលទៅហាក់ដូចជាម្ចាស់បំណុល ក្នុងករណីដែលអ្នកសងបានជឿជាក់ថា ភាគីដែលខ្លួនបានសងនោះជាម្ចាស់បំណុលពិតប្រាកដ ការសងនោះត្រូវចាត់ទុកថាជាការសងមានសុពលភាព លើកលែងតែការជឿជាក់នោះកើតឡើងដោយសារកំហុសធ្ងន់ធ្ងរ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលពិតប្រាកដមិនអាចទាមទារឱ្យកូនបំណុលសងម្តងទៀតបានទេ។ ប៉ុន្តែ ម្ចាស់បំណុលពិតប្រាកដអាចទាមទារឱ្យអ្នកដែលបានទទួលការសងពីកូនបំណុល ប្រគល់នូវវត្ថុដែលបានសងនោះឱ្យខ្លួនវិញបាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ការសងដែលធ្វើទៅអ្នកដែលមើលទៅហាក់ដូចជាម្ចាស់បំណុល តែជាក់ស្តែងមិនមែនជាម្ចាស់បំណុលពិតប្រាកដ ពោលគឺគ្រាន់តែជា "ឧបភោគីនៃសិទ្ធិលើបំណុល" មានសុពលភាព ក្រោមល័ក្ខខ័ណ្ឌមួយចំនួន ដើម្បីការពារអ្នកសង ។

កូនបំណុលត្រូវសងកាតព្វកិច្ចភ្លាម ប្រសិនបើម្ចាស់បំណុលទាមទារឱ្យសងកាតព្វកិច្ចនោះនៅពេលកំណត់សង ។ បើប្រៀបធៀបនឹងករណីដែលកូនបំណុលធ្វើប្រតិបត្តិការថ្មីជាមួយនឹងភាគីម្ខាងទៀត កូនបំណុលគ្មានពេលគ្រប់គ្រាន់ដើម្បីស្រាវជ្រាវឱ្យដឹងថា តើបុគ្គលដែលទាមទារឱ្យសងនោះគឺជាម្ចាស់បំណុលពិតប្រាកដមែន ឬ មិនមែន ។ ប្រសិនបើកូនបំណុលត្រូវសងកាតព្វកិច្ចពីរដង ដោយសារខ្លួនបានសងទៅបុគ្គលដែលមើលទៅហាក់បីដូចជាម្ចាស់បំណុល ប៉ុន្តែតាមពិតបែរទៅជាមិនមែនម្ចាស់បំណុលទៅវិញ ហើយត្រូវបានទាមទារឱ្យសងទៅម្ចាស់បំណុលពិតប្រាកដ នោះបន្ទុករបស់កូនបំណុលហាក់ដូចជាធ្ងន់ហួសហេតុ ។ ហេតុដូច្នេះ ប្រព័ន្ធនៃការសងចំពោះ "ឧបភោគីនៃសិទ្ធិលើបំណុល" ដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវបានបង្កើតឡើង ដើម្បីការពារកូនបំណុលក្នុងករណីមួយចំនួន ។ ក្នុងករណីដែលកូនបំណុលសងទៅអ្នកដែលមើលទៅហាក់ដូចជាម្ចាស់បំណុល ដោយមានកាន់ក្នុងដៃនូវលិខិតបញ្ជាក់សិទ្ធិលើបំណុល ឬ សៀវភៅគណនីធនាគារ (ដែលត្រូវហៅថាជា "ឧបភោគីនៃសិទ្ធិលើបំណុល" (possesuer de la créance) តាមទំនៀមទម្លាប់នៃច្បាប់បារាំង) នោះមានភាពចាំបាច់ការពារកូនបំណុលដោយចាត់ទុកថា ការសងនោះមានសុពលភាព ។ ជាលទ្ធផលនៃការការពារកូនបំណុលតាមប្រព័ន្ធនេះ កូនបំណុលព្យាយាមធ្វើការសងទៅបុគ្គលដែលមានកាន់នូវលិខិតបញ្ជាក់សិទ្ធិលើបំណុលឱ្យបានឆាប់រហ័ស ហេតុនេះ ទីបំផុត វាជាប្រយោជន៍ចំពោះម្ចាស់បំណុល (ម្ចាស់បំណុលពិតប្រាកដ) ផងដែរ ។

មានល័ក្ខខ័ណ្ឌតម្រូវពីរចាំបាច់សម្រាប់ឱ្យការសងបែបនេះមានសុពលភាពតាមកថាខណ្ឌទី ១ ។ ល័ក្ខខ័ណ្ឌតម្រូវទី ១ គឺការសងចំពោះ "ឧបភោគីនៃសិទ្ធិលើបំណុល" ។ ល័ក្ខខ័ណ្ឌតម្រូវទី ២ គឺជាល័ក្ខខ័ណ្ឌតម្រូវអត្តនោម័តថា ការសងបានធ្វើឡើងដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ។ ចំពោះល័ក្ខខ័ណ្ឌតម្រូវទី ២ នេះ កូនបំណុលនឹងមិនត្រូវបានការពារទេ

ប្រសិនបើកូនបំណុលធ្វើការសងដោយគ្មានការប្រុងប្រយ័ត្ន ។ ប្រសិនបើធនាគារ (កូនបំណុលក្នុងកាតព្វកិច្ចប្រាក់បញ្ញើ) សងទៅបុគ្គលដែលយកមកជាមួយនូវសៀវភៅគណនីធនាគារ ធនាគារនោះត្រូវពិនិត្យមើលថា តើសៀវភៅគណនីធនាគារនោះជាសៀវភៅធនាគារពិត និង តើហត្ថលេខាបុគ្គលដែលយកសៀវភៅគណនីធនាគារមកនោះ ដូចហត្ថលេខាដែលចុះពេលបើកគណនីដែរ ឬទេ ។ ក្នុងករណីដែលហត្ថលេខាបែរទៅជាក្លែងក្លាយ បន្ទាប់ពីការពិនិត្យមើលយ៉ាងប្រុងប្រយ័ត្នមក អ្នកសងត្រូវចាត់ទុកថាបានធ្វើការសងដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ហើយការសងត្រូវចាត់ទុកថាមានសុពលភាព ។ ភាពសុចរិត គឺជាល័ក្ខខ័ណ្ឌតម្រូវអត្តនោម័ត ជានិច្ចកាល ប៉ុន្តែ មានការពិភាក្សាគ្នាអំពីបញ្ហាថា តើចាំបាច់ ឬ មិនចាំបាច់ក្នុងការបន្ថែមនូវភាពគ្មានកំហុសធ្ងន់ធ្ងរជាល័ក្ខខ័ណ្ឌ ។ យុត្តិសាស្ត្ររបស់ប្រទេសជប៉ុនតម្រូវឱ្យមានភាពគ្មានកំហុស ហើយលើសពីនេះទៀត តាមវិសោធនកម្មឆ្នាំ ២០០៤ នៃក្រមរដ្ឋប្បវេណី មានបញ្ញត្តិដែលបញ្ជាក់ច្បាស់លាស់ថា តម្រូវឱ្យមាន "ភាពគ្មានកំហុស" ។ រីឯមាត្រានេះបញ្ញត្តតម្រូវឱ្យមាន "ភាពគ្មានកំហុសធ្ងន់ធ្ងរ" ។ នេះដោយសារគិតពិចារណាលក្ខណៈពិសេសនៃការសងដែលតម្រូវឱ្យមាននូវភាពឆាប់រហ័ស ។ ទោះជាយ៉ាងណាក៏ដោយ នៅតែអាចមានការពិភាក្សាវែកញែកបានថាតើ "ភាពគ្មានកំហុស" (ជំនួស "ភាពគ្មានកំហុសធ្ងន់ធ្ងរ") អាចទទួលយកបាន ឬ មិនបាន ។ ក្នុងសង្គមទំនើប ករណីភាគច្រើនដែលបញ្ញត្តិនេះអាចបង្កើតឱ្យមានបញ្ហា គឺទាក់ទងនឹងករណីដែលធនាគារធ្វើការសងទៅអ្នកកាន់សៀវភៅគណនីធនាគារដែលបានលួចគេ ។ ប្រសិនបើគិតថាជាការល្អប្រសើរក្នុងការឱ្យធនាគារទទួលខុសត្រូវធ្ងន់ធ្ងរ អាចយកល័ក្ខខ័ណ្ឌនៃ "ភាពគ្មានកំហុស" ។ ប៉ុន្តែ ក្នុងករណីនៃអ្នកជំនាញក្នុងការចាត់ចែងប្រាក់ដូចជាធនាគារនោះ ប្រសិនបើធនាគារមិនពិនិត្យមើលហត្ថលេខាដោយប្រុងប្រយ័ត្នទេនោះ អាចវិនិច្ឆ័យថា ទង្វើនេះគឺជា "កំហុសធ្ងន់ធ្ងរ" ។ ដោយសារហេតុផលទាំងនេះ មាត្រានេះរក្សាទុកនូវពាក្យ "ដោយគ្មានកំហុសធ្ងន់ធ្ងរ" ។

ប្រសិនបើការសងទៅឧបភោគីនៃសិទ្ធិលើបំណុល B មានសុពលភាពនោះ កាតព្វកិច្ចរបស់កូនបំណុល C ត្រូវរលត់ ហើយម្ចាស់បំណុលពិតប្រាកដ A មិនអាចទាមទារឱ្យកូនបំណុល C សងបានទៀតទេ ។ ម្ចាស់បំណុលពិតប្រាកដ A អាចត្រឹមទាមទារឱ្យប្រគល់វិញនូវសេចក្តីចម្រើនដោយឥតហេតុពីឧបភោគី B ដែលបានទទួលការសងនោះតែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៤០ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ៤៧៨-៤៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៤០.- វិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និង តាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

(កំណត់)

មាត្រានេះបញ្ញត្តថា វិធីសងត្រូវមានភាពត្រឹមត្រូវ តាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

ជារឿងធម្មតាដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវស្របតាមខ្លឹមសារ និង គោលបំណងនៃកិច្ចសន្យា ប៉ុន្តែ លើសពីនេះទៀត វិធីសង ជាអាទិ៍ ត្រូវស្របតាមគោលបំណងនៃកិច្ចសន្យា ។ ក្នុងចំណោមបញ្ហាជាច្រើនពាក់ព័ន្ធនឹង "វិធីសង" ក្រមរដ្ឋប្បវេណីនេះមានបញ្ញត្តិជាក់លាក់អំពីម៉ោងសង (មាត្រា ៤៤៤) និង ទីកន្លែងដែលត្រូវសង (មាត្រា ៤៤៥) ជាអាទិ៍ ។ ប៉ុន្តែ ក្រមនេះមិនបញ្ញត្តអំពីគ្រប់វិធីសងនោះទេ ។ ឧទាហរណ៍ ប្រសិនបើការសងនូវចំនួនទឹកប្រាក់ច្រើន ត្រូវបានធ្វើឡើងដោយក្រដាសប្រាក់រាយចំនួនជាច្រើន ដោយមិនប្រើក្រដាសប្រាក់ដុំ (ឧទាហរណ៍ យកក្រដាសប្រាក់មួយដុល្លារដើម្បីសងបំណុលជាប្រាក់ចំនួន ១ លានដុល្លារ) ការសងនេះអាចត្រូវចាត់ទុកថា គ្មានភាពសុចរិត និង ភាពស្មោះត្រង់ ផ្អែកតាមស្ថានការណ៍ ។ម្យ៉ាងវិញទៀត ទាក់ទងនឹងការសងជាក្រដាសប្រាក់ (រូបិយវត្ថុ) ប្រសិនបើភាពស្របច្បាប់ក្នុងការប្រើប្រាស់រូបិយវត្ថុ (ភាពអាចបង្ខំឱ្យទទួលរូបិយវត្ថុ) ត្រូវបានកំណត់ដោយច្បាប់ផ្សេង ជាទូទៅ ការសងដោយយោងតាមបញ្ញត្តិនៃច្បាប់នោះ មិនត្រូវចាត់ទុកថា ផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ទេ ។ ប៉ុន្តែ ប្រសិនបើការសងជាក្រដាសប្រាក់រាយចំនួនច្រើន ត្រូវបានធ្វើឡើងដើម្បីបង្កឱ្យមានភាពលំបាកដល់ម្ចាស់បំណុលនោះ ទោះបីជាការសងនេះស្របតាមភាពស្របច្បាប់ក្នុងការប្រើប្រាស់រូបិយវត្ថុក៏ដោយ ក៏ការសងនេះ ត្រូវចាត់ទុកថា ផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៤១.- ការសងមួយភាគ

ម្ចាស់បំណុលមិនមានករណីយកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបានទទួល ដោយដឹងថាជាការសងមួយភាគ ការសងនោះមានសុពលភាពត្រឹមទំហំដែលបានសង ។

(កំណត់)

មាត្រានេះបញ្ញត្តថា ការសងមួយភាគ មិនមែនជាការសងតាមគោលបំណងនៃកាតព្វកិច្ចទេ ។ សេចក្តីសន្និដ្ឋាននេះ អាចត្រូវបានធ្វើដោយយោងតាមមាត្រា ៤៤០ ផងដែរ ប៉ុន្តែ ដោយសារចំណុចនេះជាបញ្ហាសំខាន់មួយ មាត្រានេះបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះ ដោយមិនទុកឱ្យបកស្រាយមាត្រា ៤៤០ ។

ឧទាហរណ៍ កូនបំណុលដែលមានកាតព្វកិច្ចតម្លៃ ១០០០ ដុល្លារ ប៉ុន្តែ ដោយសារកូនបំណុលនោះអាចរៀបចំតែទឹកប្រាក់ចំនួន ៦០០ ដុល្លារប៉ុណ្ណោះ កូនបំណុលស្នើផ្តល់ការសង ៦០០ ដុល្លារ ទៅម្ចាស់បំណុល ។ ក្នុងករណីនេះ ម្ចាស់បំណុលនោះមិនមានករណីយកិច្ចទទួលការសងមួយភាគទេ ។ ប្រសិនបើម្ចាស់បំណុលបដិសេធមិនទទួលការសងមួយភាគ ការប្រាក់នឹងត្រូវគណនាពីចំនួនសរុប ១០០០ ដុល្លារ ដោយសារមិនទាន់មានការសងពេញលេញនូវចំនួនសរុប

ដែលត្រូវសង ។ ប្រសិនបើមានការសន្យាពិសេសអំពីការសងបន្តិចម្តងៗ ការសងមួយភាគអាចធ្វើទៅបាន ។

ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់បំណុលទទួលការសងមួយភាគ ការសងនោះមានសុពលភាព ហើយកាតព្វកិច្ចត្រូវកាត់បន្ថយមកនៅត្រឹមតុល្យភាពនៃចំនួនសរុប ។

ប្រសិនបើមានវិវាទលើចំនួននៃកាតព្វកិច្ចរវាងម្ចាស់បំណុល និង កូនបំណុល មានករណីខ្លះដែលម្ចាស់បំណុលបដិសេធមិនទទួលការសង ដោយអះអាងថា ចំនួនដែលកូនបំណុលស្នើផ្តល់ការសងមិនគ្រប់តាមចំនួនដែលត្រូវសង (ករណីនេះកើតឡើងជាញឹកញាប់ ក្នុងវិវាទទាក់ទងនឹងថ្លៃឈ្នួលក្នុងភតិសន្យា) ។ ក្នុងករណីនេះ កូនបំណុលអាចទប់ស្កាត់មិនឱ្យមានការទាមទារឱ្យទទួលខុសត្រូវចំពោះការមិនសងកាតព្វកិច្ចគ្រប់ចំនួន ដោយធ្វើការតម្កល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៤៤ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៤៤២.- ការសងដោយយកវត្ថុជំនួស

១-ក្នុងករណីដែលកូនបំណុលផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាពដូចគ្នានឹងការសងដែរ ។

២-ម្ចាស់បំណុល និង កូនបំណុលអាចធ្វើការព្រមព្រៀងគ្នាលើតាវកាលិកផ្សេងជំនួសតាវកាលិកដើមបាន ។ ក្នុងករណីនេះ កូនបំណុលអាចសងដោយជ្រើសរើសតាវកាលិកដើម ឬ តាវកាលិកដោយយកវត្ថុផ្សេងជាជំនួសបាន លើកលែងតែករណីម្ចាស់បំណុលមានសិទ្ធិជ្រើសរើស ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីការសងដោយយកវត្ថុជំនួស ។

ឧទាហរណ៍ ការសងដោយយកវត្ថុជំនួស មានន័យថា កូនបំណុលដែលមានកាតព្វកិច្ចដែលមានតម្លៃ ១០,០០០ ដុល្លារសងកាតព្វកិច្ច ដោយសងដីជំនួសការសងជាប្រាក់ ។ ការសងបែបនេះ មិនអាចធ្វើដោយឆន្ទៈផ្តាច់មុខរបស់កូនបំណុលតែប៉ុណ្ណោះទេ គឺត្រូវតែមានការយល់ព្រមពីម្ចាស់បំណុល (កថាខណ្ឌទី ១) ។ ការព្រមព្រៀងសងដោយយកវត្ថុជំនួសអាចមានតាំងពីដំបូងនៅពេលបង្កើតកិច្ចសន្យា ឬ មានករណីដែលភាគីព្រមព្រៀងនៅពេលកំណត់សងដែរ ។ នៅប្រទេសជប៉ុន ការសងដោយយកវត្ថុជំនួស ត្រូវបានប្រើប្រាស់ ក្នុងគោលបំណងដើម្បីធានាសិទ្ធិលើបំណុល ដូច្នេះ ជារឿងទូទៅភាគីពាក់ព័ន្ធចុះកិច្ចព្រមព្រៀងសងដោយយកវត្ថុជំនួស តាំងពីពេលបង្កើតកិច្ចសន្យា ។

ទោះបីជាមានការព្រមព្រៀងសងដោយយកវត្ថុជំនួសក៏ដោយ ក៏ការព្រមព្រៀងនេះមិនរារាំងការសងនូវកាតព្វកិច្ច

ដើមទេ ។ ការសងកាតព្វកិច្ចដោយផ្តល់តាវកាលិកដើម ឬ ការសងដោយយកវត្ថុជំនួស ត្រូវសម្រេចដោយជម្រើសរបស់បុគ្គលដែលមានសិទ្ធិជ្រើសរើស ។ ក្នុងករណីដែលការព្រមព្រៀងសងដោយយកវត្ថុជំនួសត្រូវបានធ្វើឡើងរវាងភាគីដើម្បីធានាសិទ្ធិលើបំណុល ជាធម្មតា ម្ចាស់បំណុលមានសិទ្ធិជ្រើសរើស ។ ប្រសិនបើគ្មានការសងក្នុងទម្រង់ជាប្រាក់នៅពេលកំណត់សង ម្ចាស់បំណុលជ្រើសរើសការសងដោយយកវត្ថុជំនួស និង ទាមទារការសងដោយយកវត្ថុជំនួស (ដីជំនួសប្រាក់ដែលត្រូវសង) ។ មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណីជប៉ុនចាត់ទុកថា ការសងដោយយកវត្ថុជំនួស មិនមែនជាបញ្ហាសម្រាប់ពេលអនាគតនោះទេ តែជាបញ្ហានៅពេលដែលវត្ថុជំនួសត្រូវបានប្រគល់ជូន និង ពន្យល់អំពីការសងដោយយកវត្ថុជំនួសសម្រាប់ពេលអនាគត ដោយយកទស្សនាទានគតិយុត្តនៃ "ការសន្យាជាមុនអំពីការសងដោយយកវត្ថុជំនួស" ប៉ុន្តែមាត្រានេះបង្កើតឱ្យមានការបកស្រាយថា ភាគីអាចព្រមព្រៀងជាមុនអំពីការសងដោយយកវត្ថុជំនួស ហើយអាចផ្តល់សិទ្ធិជ្រើសរើសទៅភាគីម្ខាង ឬ សងខាងបាន ដោយសារវិធីសាស្ត្រនេះអាចអនុវត្តបានក្នុងករណីផ្សេងៗ ដោយមានលក្ខណៈបត់បែនបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៤៣.-** ពេលនៃការសង ការសងមុនពេលកំណត់

១-កូនបំណុលត្រូវសងនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) នៃក្រមនេះ ។

២-កូនបំណុលអាចសងមុនពេលកំណត់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីពេលនៃការសង ។ ជារឿងទូទៅដែលកូនបំណុលត្រូវសងនៅពេលកំណត់ ។ ចំណុចសំខាន់នៃមាត្រានេះ គឺបញ្ញត្តសម្រាប់ករណីដែលការសងអាចធ្វើមុនពេលកំណត់ ។

ពេលកំណត់ត្រូវសង គឺជាពេលកំណត់ដែលរៀបចំសម្រាប់កូនបំណុល ។ ដូច្នេះ មាត្រានេះត្រូវបានចែងឡើងដោយយកការសន្មតថា ការកំណត់ពេល ជាផលប្រយោជន៍នៃការកំណត់ពេលសម្រាប់កូនបំណុល មកជាបុរេល័ក្ខខ័ណ្ឌ ។ ប៉ុន្តែ ក៏អាចមានករណីដែលមានផលប្រយោជន៍នៃការកំណត់ពេលសម្រាប់ម្ចាស់បំណុលផងដែរ ដោយផ្អែកលើខ្លឹមសារនៃកិច្ចសន្យា និង ខ្លឹមសារនៃកាតព្វកិច្ច ។ មាត្រានេះបញ្ញត្តអំពីពេលកំណត់សងសម្រាប់ករណីនេះ ។

ការសងមុនពេលកំណត់ហាក់ដូចជាអាចទទួលយកបានជានិច្ចកាល ដោយសារពុំមានការខូចខាតផលប្រយោជន៍អ្វីចំពោះម្ចាស់បំណុលទេ ប៉ុន្តែ ជាក់ស្តែង វាមិនមែនដូច្នោះទេ ។ នេះដោយសារមានករណីដែលការសងមុនពេលកំណត់

អាចធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់បំណុល ហើយមិនសមហេតុផលនឹងឱ្យម្ចាស់បំណុលទទួលយកការសងមុនពេលកំណត់បែបនេះទេ ។ ចំពោះកាតព្វកិច្ចដែលមានគោលបំណងធ្វើសកម្មភាពណាមួយ និង កាតព្វកិច្ចដែលមានគោលបំណងផ្តល់តាវកាលិកនូវវត្ថុណាមួយ អាចមានករណីបែបនេះច្រើន ប៉ុន្តែ ក៏មានករណីដែលការសងមុនពេលកំណត់ធ្វើឱ្យម្ចាស់បំណុលខូចខាតផលប្រយោជន៍ផងដែរ ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ។ ឧទាហរណ៍ ក្នុងករណីដែលធនាគារ ជាអាទិ៍ ផ្តល់ប្រាក់កម្ចីទៅអ្នកដទៃ ជាប្រតិបត្តិការមួយនៃប្រាក់បញ្ញើ ប្រសិនបើអ្នកខ្ចីសងមុនពេលកំណត់ ធនាគារដែលទទួលផលចំណេញតាមរយៈប្រតិបត្តិការប្រាក់បែបនេះ ត្រូវរកអ្នកខ្ចីថ្មីផ្សេងទៀត ។ ប្រសិនបើធនាគារអាចរកអ្នកខ្ចីផ្សេងទៀតបានដោយងាយស្រួល នោះគ្មានបញ្ហាទេ ប៉ុន្តែ ប្រសិនបើធនាគារមិនអាចរកបានទេ ការសងមុនពេលកំណត់អាចបង្កឱ្យមានភាពមិនងាយស្រួលសម្រាប់ធនាគារដែលជាម្ចាស់បំណុល ។ ស្រដៀងគ្នានេះដែរ ប្រសិនបើអ្នកលក់ក្នុងកិច្ចសន្យាលក់ប្រគល់វត្ថុជាច្រើនដល់អ្នកទិញ មុនពេលកំណត់តាមកិច្ចសន្យា អ្នកទិញអាចមានភាពលំបាកក្នុងការរកកន្លែងរក្សាទុកវត្ថុនោះ ឬ អាចមានឧបសគ្គក្នុងការរៀបចំផែនការលក់បន្ត ។ ដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះបញ្ញត្តដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រា ៣៣០ ថា កូនបំណុលអាចសង មុនពេលកំណត់បាន លុះត្រាតែ "មិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវដល់ភាគីម្ខាងទៀត (ម្ចាស់បំណុល)" ។ ពោលគឺប្រសិនបើការសងមុនពេលកំណត់នាំឱ្យមានការខូចខាតដល់ម្ចាស់បំណុល ការសងនេះមិនអាចធ្វើបានទេ ។ ដោយសារ ជាគោលការណ៍ ពេលកំណត់សង គឺជាពេលកំណត់សម្រាប់ផលប្រយោជន៍របស់កូនបំណុល ការបញ្ជាក់ថា ការសងមុនពេលកំណត់នាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ ត្រូវធ្វើដោយម្ចាស់បំណុលដែលបដិសេធមិនឱ្យសងមុនពេលកំណត់ ។ សូមមើលសេចក្តីកំណត់នៃមាត្រា ៣៣០ ដើម្បីស្វែងយល់អំពីអត្ថន័យនៃ "មានការខូចខាតដោយមិនត្រឹមត្រូវ" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន និង គោលការណ៍ច្បាប់កិច្ចសន្យារបស់សហគមន៍អឺរ៉ុប ២.១០៨

## មាត្រា ៤៤៤.- ម៉ោងសង

កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀមទម្លាប់ និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីម៉ោងសង ។ បញ្ហាទាក់ទងនឹងម៉ោងសង អាចត្រូវដោះស្រាយដោយការអនុវត្តមាត្រា ៤៤០ ប៉ុន្តែ មាត្រានេះកំណត់ដោយឡែកអំពីបញ្ញត្តិនេះ ដោយសារម៉ោងសងអាចឱ្យគេគិតនូវបទដ្ឋានជាក់លាក់មួយ ហើយការកំណត់ជាក់លាក់អំពីចំណុចនេះមានភាពល្អជាងការវិនិច្ឆ័យដោយផ្អែកលើគោលករណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

ជាញឹកញាប់ ម៉ោងសង អាចកំណត់ដោយទំនៀមទម្លាប់ ។ ឧទាហរណ៍ មានតំបន់ដែលមានទំនៀមទម្លាប់សងក្នុង

ចន្លោះថ្ងៃរះ និង ថ្ងៃលិច ។ ប៉ុន្តែ ដោយគិតពិចារណាថា អាចមានតំបន់ដែលគ្មានទំនៀមទម្លាប់បែបនេះ ឬ ដែលទំនៀមទម្លាប់មិនច្បាស់លាស់ មាត្រានេះបញ្ញត្តថា ជាគោលការណ៍ ម៉ោងសង គឺជា "ម៉ោងធ្វើការធម្មតា" ។ ប្រសិនបើមានទំនៀមទម្លាប់ខុសពីនេះ ត្រូវអនុលោមតាមទំនៀមទម្លាប់ដែលខុសនោះ ។ ចំពោះការសងកាតព្វកិច្ចដែលមិនពាក់ព័ន្ធនឹងកិច្ចការអាជីវកម្ម "ម៉ោងធ្វើការធម្មតា" មិនមែនជាបទដ្ឋានសមហេតុផលទេ ប៉ុន្តែ ករណីទាំងនេះត្រូវវិនិច្ឆ័យតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

## មាត្រា ៤៤៥.– ទីកន្លែងដែលត្រូវសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើង នៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង ។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើង នៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីទីកន្លែងដែលកូនបំណុលត្រូវសង ។

ក្នុងការលក់ទិញវត្ថុជាក់លាក់មួយចំនួន ដូចជាវត្ថុបុរាណ ជាដើម អ្នកលក់អាចប្រគល់វត្ថុបុរាណនោះទៅអ្នកទិញនៅកន្លែងដែលវត្ថុបុរាណនោះស្ថិតនៅ នៅពេលធ្វើកិច្ចសន្យា ។ ក្នុងករណីនៃការលក់ទិញវត្ថុបុរាណក្នុងហាង ហាងគឺជាទីកន្លែងដែលត្រូវសង ។ ចំណុចដែលគួរកត់សម្គាល់ គឺអត្ថន័យនៃការសន្យាដែលអ្នកលក់ និង អ្នកទិញ ព្រមព្រៀងគ្នាថាអ្នកលក់ត្រូវដឹកវត្ថុបុរាណនោះទៅលំនៅឋានរបស់អ្នកទិញ ។ ប្រសិនបើការព្រមព្រៀងនេះមានន័យថា កន្លែងត្រូវសងគឺលំនៅឋានរបស់អ្នកទិញ ការសងមិនត្រូវចាត់ទុកថាបានធ្វើទេ រហូតដល់វត្ថុបុរាណបានមកដល់លំនៅឋានរបស់ម្ចាស់បំណុល ។ ក្នុងករណីនេះ ប្រសិនបើវត្ថុមានការខូចខាតតាមផ្លូវ នេះគឺជាការខូចខាតនៃវត្ថុមុនពេលសង ហើយក្លាយជាបញ្ហានៃការមិនអនុវត្តកាតព្វកិច្ច ឬ ការទទួលបន្ទុកហានិភ័យ ។ ផ្ទុយទៅវិញ ក្នុងករណីដែលការសងត្រូវធ្វើនៅក្នុងហាង ហើយមានចុះកិច្ចសន្យាដាច់ដោយឡែកមួយទៀតអំពីការដឹកជញ្ជូន ប្រសិនបើវត្ថុខូចខាតតាមផ្លូវ បញ្ហាគឺនៅត្រង់ថា អ្នកណាជាអ្នកសងការខូចខាតដែលបង្កមកពីសេវាដឹកជញ្ជូននោះ ។ ការកំណត់ករណីណាមួយក្នុងចំណោមករណីទាំងពីរខាងលើនេះ ពឹងផ្អែកលើការបកស្រាយកិច្ចសន្យា ។

"កាតព្វកិច្ចក្រៅពីនេះ" រួមមានកាតព្វកិច្ចរបស់អ្នកលក់នៃកិច្ចសន្យាលក់ទិញវត្ថុមិនជាក់លាក់ កាតព្វកិច្ចត្រូវធ្វើសកម្មភាព ឬ មិនត្រូវធ្វើសកម្មភាព កាតព្វកិច្ចត្រូវសងជាប្រាក់ ជាអាទិ៍ ហើយក្នុងករណីទាំងនេះ ការសងត្រូវធ្វើនៅលំនៅឋានរបស់ម្ចាស់បំណុល ។ ឆន្ទៈធម្មតារបស់ភាគីនៃកិច្ចសន្យាគឺដូច្នោះ ។ ប៉ុន្តែ ប្រសិនបើភាគីនៃកិច្ចសន្យាព្រមព្រៀងគ្នាថា នឹងសងនៅទីកន្លែងជាក់លាក់ណាមួយ ត្រូវសងនៅកន្លែងនោះ ។ ឧទាហរណ៍ តាមបញ្ញត្តិនេះ

ករណីយកិច្ចរបស់សាស្ត្រាចារ្យ ក្នុងការបង្រៀនសិស្សដែលចូលរៀននៅសាកលវិទ្យាល័យដែលគាត់ធ្វើការ គឺជាកាតព្វកិច្ច ត្រូវធ្វើសកម្មភាព ដូច្នេះ ការសង (ការបង្រៀន) ត្រូវធ្វើនៅលំនៅឋានរបស់កូនសិស្សដែលជាម្ចាស់បំណុល ប៉ុន្តែ កិច្ចសន្យាដែលធ្វើនៅពេលចូលរៀននៅសាកលវិទ្យាល័យ មានការសន្យាពិសេសថា កន្លែងដែលសាស្ត្រាចារ្យត្រូវសង កាតព្វកិច្ច គឺជាលំនៅឋានរបស់កូនបំណុល (=សាកលវិទ្យាល័យ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥១៦ នៃក្រមពាណិជ្ជកម្មជប៉ុន

## មាត្រា ៤៤៦.- សោហ៊ុយនៃការសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីសោហ៊ុយនៃការសងទេ កូនបំណុលត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយនៃការសងកើនឡើងដោយសារការផ្លាស់ប្តូរលំនៅឋាន ឬ អំពើផ្សេងរបស់ម្ចាស់បំណុល ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវចំនួនកំណើននៃសោហ៊ុយនោះ ។

(កំណត់)

ជួនកាល អាចមានសោហ៊ុយលើការសង ។ មាត្រានេះបញ្ញត្តអំពីអ្នកដែលត្រូវទទួលបន្ទុកក្នុងការចេញសោហ៊ុយនេះ ។ ជាគោលការណ៍ កូនបំណុលត្រូវទទួលបន្ទុកនូវសោហ៊ុយនេះ ។

សោហ៊ុយនៃការសងរួមមានកម្រៃជើងសារក្នុងករណីផ្ទេរប្រាក់ និង ប្រាក់កម្រៃចំពោះការប្រគល់ទំនិញនានា ។

ក្នុងករណីលក់ដោយការបញ្ជាទិញតាមប្រៃសណីយ៍ ជាអាទិ៍ ប្រាក់កម្រៃចំពោះការប្រគល់វត្ថុជាញឹកញយ ត្រូវបង់ដោយអ្នកទិញ ។ នេះជាករណីនៃ "កិច្ចព្រមព្រៀងគ្នាផ្សេង" ដែលមាត្រានេះបានចែង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៤៧.- ការចេញលិខិតទទួល

អ្នកសងអាចទាមទារឱ្យអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការទទួលការសងនោះបាន ។

(កំណត់)

កូនបំណុលមានសិទ្ធិទាមទារឱ្យចេញលិខិតបញ្ជាក់នូវការទទួលការសងពីបុគ្គលដែលទទួលការសង ដូច្នេះ មាត្រានេះបញ្ញត្តអំពីសិទ្ធិនេះ ។

ការចេញលិខិតបញ្ជាក់នូវការទទួលការសងដោយម្ចាស់បំណុល និង ការសងដោយកូនបំណុល ត្រូវអនុវត្តព្រមជាមួយគ្នា ដូច្នេះ កូនបំណុលអាចបដិសេធមិនសង រហូតដល់ម្ចាស់បំណុលចេញលិខិតបញ្ជាក់នូវការទទួលការសង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៤៨.-** ការប្រគល់មកវិញនូវលិខិតបញ្ជាក់សិទ្ធិលើបំណុល

ក្នុងករណីដែលមានលិខិតបញ្ជាក់សិទ្ធិលើបំណុល អ្នកសងអាចទាមទារឱ្យប្រគល់លិខិតនោះមកវិញបាន នៅពេលដែលខ្លួនបានសងចំពោះកាតព្វកិច្ចចប់សព្វគ្រប់ហើយ ។

(កំណត់)

រាល់លិខិតបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ត្រូវប្រគល់មកឱ្យកូនបំណុលវិញតាមការទាមទាររបស់កូនបំណុល ប្រសិនបើកាតព្វកិច្ចទាំងមូលត្រូវបានសងចប់សព្វគ្រប់ ។ នេះដោយសារថា ប្រសិនបើមិនប្រគល់មកវិញនូវលិខិតបញ្ជាក់សិទ្ធិលើបំណុលទេនោះ អាចមានការសន្មតថា កាតព្វកិច្ចនៅតែមានអត្ថិភាព ហើយនេះធ្វើឱ្យខូចខាតចំពោះកូនបំណុលដែលបានសងកាតព្វកិច្ចរួចហើយនោះ ។

លិខិតបញ្ជាក់សិទ្ធិលើបំណុល ត្រូវប្រគល់ជូនកូនបំណុលវិញ ក្នុងករណីដែលកាតព្វកិច្ចទាំងស្រុងត្រូវបានសង ប៉ុន្តែមិនត្រូវប្រគល់ជូនកូនបំណុលវិញទេ ក្នុងករណីនៃការសងមួយភាគ ។ នេះដោយសារថា នៅពេលដែលម្ចាស់បំណុលទាមទារឱ្យកូនបំណុលសងចំនួនដែលត្រូវសង លិខិតបញ្ជាក់សិទ្ធិលើបំណុលគឺជាភស្តុតាងដែលអាចបញ្ជាក់អំពីអត្ថិភាពនៃកាតព្វកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ២ ការកាត់បំណុល

**មាត្រា ៤៤៩.-** ការកាត់បំណុលដោយការជ្រើសរើស

១-ក្នុងករណីដែលកូនបំណុលត្រូវទទួលបន្ទុកនូវកាតព្វកិច្ចច្រើនដែលមានគោលបំណងប្រភេទដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ប្រសិនបើតាវកាលិកដែលត្រូវបានផ្តល់ជាការសង នៅមិនទាន់គ្រប់គ្រាន់ដើម្បីឱ្យកាតព្វកិច្ចទាំងអស់រលត់នៅឡើយទេ អ្នកសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួន

ផ្តល់ការកាលិកបាន ។

២-ប្រសិនបើអ្នកសងមិនបានជ្រើសរើសដូចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកទទួលការសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនទទួលការសងបាន ។ ប៉ុន្តែ ប្រសិនបើអ្នកសងបានតវ៉ានឹងការកាត់នោះភ្លាមៗ ការកាត់បំណុលត្រូវធ្វើតាមច្បាប់កំណត់ ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ការកាត់បំណុលត្រូវធ្វើឡើង ដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីបទដ្ឋានសម្រាប់ "ការកាត់បំណុល" ដែលមានន័យថា នៅពេលដែលកូនបំណុលត្រូវសងកាតព្វកិច្ចច្រើន តើកាតព្វកិច្ចណាត្រូវបានសងមុន និង កាតព្វកិច្ចណាត្រូវបានសងក្រោយ ។

ឧទាហរណ៍ កូនបំណុល A មានកាតព្វកិច្ចចំពោះម្ចាស់បំណុល B (១) ចំនួន ៥០០ ដុល្លារ ចំពោះថ្លៃលក់ (២) ៣០០ ដុល្លារ ជាកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ និង (៣) ២០០ ដុល្លារ ជាកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ ។ ប្រសិនបើកូនបំណុល A បង់ជូនម្ចាស់បំណុលចំនួន ៥០០ ដុល្លារ បញ្ហានឹងកើតឡើងនៅត្រង់ចំណុចថា តើត្រូវកាត់បំណុលចំពោះកាតព្វកិច្ចណាមួយក្នុងចំណោមកាតព្វកិច្ចទាំងបីខាងលើ ។ គ្មានបញ្ហាកើតឡើងទេ ប្រសិនបើកូនបំណុលសង ១០០០ ដុល្លារ តែម្តង ដើម្បីឱ្យកាតព្វកិច្ចទាំងអស់រលត់ ។ ប៉ុន្តែ ប្រសិនបើសងតែ ៥០០ ដុល្លារ ត្រូវតម្រូវឱ្យមានបទដ្ឋានជាក់លាក់មួយសម្រាប់កាត់បំណុល ។ នេះគឺជាបញ្ហានៃ "ការកាត់បំណុល" ។

គោលការណ៍ជាមូលដ្ឋានគឺ ជាដំបូង ការកំណត់ដោយកូនបំណុល (កថាខណ្ឌទី ១) ។ នេះដោយសារថា ការជ្រើសរើសឱ្យកាតព្វកិច្ចណាមួយរលត់ មានផលប្រយោជន៍ខ្លាំងបំផុតសម្រាប់កូនបំណុលខ្លួនឯង ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមិនជ្រើសរើសការកាត់បំណុលទេ អ្នកទទួលការសង (ម្ចាស់បំណុល) អាចជ្រើសរើសបាន (កថាខណ្ឌទី ២) ។ ករណីទី ៣ ប្រសិនបើគ្មានភាគីណាមួយធ្វើការជ្រើសរើសទេ ត្រូវកាត់បំណុលតាមវិធីដែលបានកំណត់ដោយច្បាប់ (ការកាត់បំណុលតាមច្បាប់កំណត់) (សូមមើលមាត្រា ៤៥០) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៥០.- ការកាត់បំណុលតាមច្បាប់កំណត់

ក្នុងករណីដែលអ្នកសង និង អ្នកទទួលការសងមិនបានធ្វើការជ្រើសរើសដើម្បីកាត់បំណុលនោះទេ ការកាត់បំណុលនោះ ត្រូវធ្វើឡើងតាមបញ្ញត្តិដូចខាងក្រោមនេះ :

ក-ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងបានមកដល់ និង កាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ ត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន ។

ខ-ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយ ឬ មិនទាន់មកដល់នៅឡើយ ត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេ សម្រាប់កូនបំណុល ។

គ-ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុល ត្រូវកាត់កាតព្វកិច្ចដែលពេលកំណត់ត្រូវសងបានមកដល់មុនគេ ឬ នឹងមកដល់មុនគេ ។

ឃ-ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និង មានពេលកំណត់ដែលត្រូវសងដូចគ្នា ត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ ។

(កំណត់)

ក្នុងករណីដែលគ្មានភាគីណាមួយធ្វើការជ្រើសរើសកាតព្វកិច្ចដែលត្រូវកាត់ដោយការសងទេ ការកាត់បំណុលត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រានេះ ។ ការធ្វើដូច្នេះ ហៅថា "ការកាត់បំណុលតាមច្បាប់កំណត់" ។

ជាមូលដ្ឋាន ការកាត់បំណុល ត្រូវសម្រេចលំដាប់លំដោយ ដើម្បីជាប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌទី ១ ផ្អែកលើគំនិតថា ប្រសិនបើកាតព្វកិច្ចដល់ពេលកំណត់ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវបានកើតឡើង ហេតុដូច្នេះ ការសងចំពោះកាតព្វកិច្ចដល់ពេលកំណត់ជាមុន មានផលប្រយោជន៍សម្រាប់កូនបំណុល ។

កថាខណ្ឌទី ២ ផ្អែកលើគំនិតថា ឧទាហរណ៍ ប្រសិនបើមានកាតព្វកិច្ចណាមួយ បានបង្កើតការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវដែលមានចំនួនច្រើន ការសងការប្រាក់នោះជាមុន សមស្របនឹងផលប្រយោជន៍របស់កូនបំណុល ។ មានភាពពិបាកក្នុងការវិនិច្ឆ័យអំពី "ផលប្រយោជន៍ក្នុងការសង" សម្រាប់កូនបំណុល ក្នុងការប្រតិបត្តិកិច្ចការជាក់ស្តែង ។ ឧទាហរណ៍ មិនមែនជារឿងងាយស្រួលទេ ក្នុងការវិនិច្ឆ័យថា តើកិច្ចសន្យាមួយណាសំខាន់ជាងកិច្ចសន្យាមួយណា ប្រសិនបើការមិនសងអាចនាំដល់ការរំលាយកិច្ចសន្យា ។

កថាខណ្ឌទី ៣ ផ្អែកលើគំនិតថា ប្រសិនបើការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ មានចំនួនដូចគ្នា "ផលប្រយោជន៍ក្នុងការសង" ក៏ដូចគ្នាចំពោះកូនបំណុលដែរ ប៉ុន្តែ ជាធម្មតា កូនបំណុលនឹងសងចំពោះកាតព្វកិច្ចដែលដល់ពេលកំណត់មុន ឬ នឹងដល់ពេលកំណត់មុន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៥១.-** លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម

ក្នុងករណីដែលកូនបំណុលមានករណីយកិច្ចបង់សោហ៊ុយ ការប្រាក់ ព្រមទាំងប្រាក់ដើមចំពោះកាតព្វកិច្ចមួយ ឬ ច្រើន ហើយអ្នកសងផ្តល់តាវកាលិកមិនគ្រប់គ្រាន់ដើម្បីរំលត់កាតព្វកិច្ចទាំងអស់ទេ ត្រូវកាត់តាមលំដាប់ : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើមជាចុងក្រោយ ។ ប៉ុន្តែ ប្រសិនបើមានកិច្ចសន្យាផ្សេងពីនេះរវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តតាមកិច្ចសន្យានោះ ។

(កំណត់)

ប្រសិនបើកាតព្វកិច្ចមួយរួមមានប្រាក់ដើម ការប្រាក់ និង សោហ៊ុយ មានបញ្ហានៅត្រង់ចំណុចថា តើការសងរបស់កូនបំណុល ត្រូវកាត់បំណុលណាមួយ ។ មាត្រានេះបញ្ញត្តអំពីបទដ្ឋានសម្រាប់ការកាត់បំណុលក្នុងករណីនេះ ។

កូនបំណុលគ្មានសិទ្ធិជ្រើសរើសការកាត់បំណុលទេក្នុងករណីនេះ ។ បទដ្ឋានដែលបានចែងក្នុងមាត្រានេះ ត្រូវបានកំណត់ ដោយពិចារណាដល់ផលប្រយោជន៍របស់ម្ចាស់បំណុល ។ ប្រសិនបើការប្រាក់ចំពោះប្រាក់ដើម មិនទាន់បានសង ប៉ុន្តែ ចំនួនប្រាក់ដើម បានថយចុះដោយការសង ម្ចាស់បំណុលនឹងខូចប្រយោជន៍ ។ ដូច្នេះ មាត្រានេះបញ្ញត្តថា កូនបំណុលមិនអាចជ្រើសរើសការសងដោយសេរីនោះទេ ហើយការសងត្រូវធ្វើតាមលំដាប់ សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម ។ ដោយសារលំដាប់លំដោយនេះ ត្រូវរៀបចំឡើងដោយពិចារណាដល់ផលប្រយោជន៍របស់ម្ចាស់បំណុល ភាគីអាចប្តូរលំដាប់លំដោយបាន ប្រសិនបើមានការព្រមព្រៀងគ្នា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩១ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៥២.-** ការកាត់បំណុលក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់

បញ្ញត្តិនៃមាត្រា ៤៤៩ (ការកាត់បំណុលដោយការជ្រើសរើស) មាត្រា ៤៥០ (ការកាត់បំណុលតាមច្បាប់កំណត់) និង មាត្រា ៤៥១ (លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលទទួលបន្ទុកកាតព្វកិច្ចច្រើនចំពោះម្ចាស់បំណុលច្រើននាក់ ហើយមិនច្បាស់លាស់អំពីកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងទេ ។

( កំណត់ )

មាត្រានេះចែងអំពីបញ្ហានៃការកាត់បំណុលក្នុងករណីសងចំពោះកាតព្វកិច្ចច្រើនដែលមានម្ចាស់បំណុលខុសគ្នា ។

ក្នុងករណីដែលអ្នកតំណាងរបស់ម្ចាស់បំណុលទាមទារឱ្យសង ជួនកាល អាចមានករណីដែលអ្នកតំណាងដែលតំណាងឱ្យម្ចាស់បំណុលច្រើននាក់ ទាមទារឱ្យសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលទាំងអស់ ឬ ករណីដែលអ្នកតំណាងទាមទារឱ្យសងចំពោះសិទ្ធិលើបំណុលរបស់អ្នកតំណាងខ្លួនឯង និង របស់ម្ចាស់សិទ្ធិព្រមជាមួយគ្នា ។ ឧទាហរណ៍ ក្នុងករណីដែលក្រុមហ៊ុនគ្រប់គ្រងប័ណ្ណបំណុលសាជីវកម្ម (ជាទូទៅ គឺធនាគារ) នៃក្រុមហ៊ុនដែលចេញប័ណ្ណបំណុលសាជីវកម្មឱ្យខ្ចីជាប្រាក់ទៅក្រុមហ៊ុនដែលបានចេញប័ណ្ណនោះ ប្រសិនបើក្រុមហ៊ុនដែលចេញប័ណ្ណបំណុលសាជីវកម្ម ធ្វើការសងទៅឱ្យក្រុមហ៊ុនដែលគ្រប់គ្រងប័ណ្ណបំណុលសាជីវកម្ម មានករណីខ្លះដែលពុំច្បាស់ថា តើការសងនេះគឺជាការសងបំណុលដែលបានកំណត់នៅក្នុងប័ណ្ណបំណុលសាជីវកម្ម ឬ ការសងប្រាក់កម្ចី ។ ក្នុងករណីដែលការសងធ្វើឡើង ដោយគ្មានការកំណត់កាតព្វកិច្ចណាមួយទេនោះ បញ្ហានឹងកើតមានដូចគ្នានឹងបញ្ហាដែលមានក្នុងការកាត់បំណុលដោយការជ្រើសរើស ។ ប៉ុន្តែ មាត្រា ៤៤៩ និង ៤៥០ មិនអាចយកមកអនុវត្តបានទេ ពីព្រោះមាត្រាទាំងនេះអាចអនុវត្តចំពោះករណីដែលមានកាតព្វកិច្ចច្រើនចំពោះម្ចាស់បំណុលតែមួយ ។

ដូច្នេះ មាត្រានេះធ្វើឱ្យអាចយកមាត្រា ៤៤៩ ជាអាទិ៍ មកអនុវត្តដូចគ្នាផងដែរ ចំពោះករណីខាងលើនេះ ។ គ្មានបញ្ហានោះទេ ប្រសិនបើកូនបំណុលជ្រើសរើសការកាត់បំណុល ប៉ុន្តែ ប្រសិនបើកូនបំណុលមិនធ្វើដូច្នោះទេ បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៤៤៩ ដែលចែងថា ម្ចាស់បំណុលអាចជ្រើសរើសបាន មិនអាចយកមកអនុវត្តបាន ចំពោះករណីដែលមានម្ចាស់បំណុលមានច្រើននាក់ ។

## កថាភាគទី ៣ សំណើផ្តល់ការសង និង ការតម្កល់

**មាត្រា ៤៥៣.-** អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង

១-សំណើផ្តល់ការសង សំដៅទៅលើការដែលកូនបំណុលបានរៀបចំចប់សព្វគ្រប់នូវតារាកាលិកសម្រាប់សង និង ទាមទារឱ្យម្ចាស់បំណុលទទួលការសងនោះ ។

២-ក្នុងករណីដែលកូនបំណុលធ្វើសំណើផ្តល់ការសង តែម្ចាស់បំណុលមិនធ្វើអំពើចាំបាច់ដើម្បីទទួលការសងទេ កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះឡើយ ។

៣-ក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ និង ត្រូវបង់ទាំងការប្រាក់ ហើយបានស្នើផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសង

នោះទេ កូនបំណុលមិនចាំបាច់បង់ការប្រាក់សម្រាប់ពេលក្រោយពីពេលនោះទៀតឡើយ ។

(កំណត់)

មាត្រានេះចែងអំពី "សំណើផ្តល់ការសង" ដែលជាសកម្មភាពរៀបចំការសង ។

កថាខណ្ឌទី ១ កំណត់និយមន័យនៃសំណើផ្តល់ការសង ។ "សំណើផ្តល់ការសង" មានន័យថា កូនបំណុលបានរៀបចំចប់សព្វគ្រប់នូវសកម្មភាពចាំបាច់សម្រាប់ការសង និង រង់ចាំឱ្យម្ចាស់បំណុលធ្វើសកម្មភាពចាំបាច់សម្រាប់ការទទួលការសងនោះ ។ សកម្មភាពនៃការធ្វើ "សំណើផ្តល់ការសង" ខុសប្លែកគ្នាពីមួយទៅមួយ ដោយផ្អែកលើខ្លឹមសារ និងប្រភេទនៃកាតព្វកិច្ច អត្ថិភាព ឬ នត្ថិភាពនៃការសន្យាពិសេសរវាងភាគី ជាដើម ។ ឧទាហរណ៍ ការសងចំពោះកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ ជាគោលការណ៍ ត្រូវធ្វើឡើងដោយកូនបំណុលយកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃកាតព្វកិច្ចទៅលំនៅឋានរបស់ម្ចាស់បំណុល ។ ក្នុងករណីនេះ "សំណើផ្តល់" មានន័យថា កូនបំណុលយកប្រាក់ទៅលំនៅឋានរបស់ម្ចាស់បំណុល ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកទិញ (ម្ចាស់បំណុល) ត្រូវមកដល់លំនៅឋានរបស់អ្នកលក់ដើម្បីយកឡានតាមកិច្ចសន្យាលក់ទិញឡានជំនំ ("ការលក់ទិញវត្ថុដែលបានកំណត់ជាក់លាក់") "សំណើ" មានន័យថា កូនបំណុល (អ្នកលក់) រៀបចំឡាន ដើម្បីប្រគល់ឱ្យអ្នកទិញតាមថ្ងៃកំណត់ ។

កថាខណ្ឌទី ២ បញ្ញត្តអំពីអានុភាពនៃសំណើផ្តល់ការសង ។ ក្នុងករណីដែលបានធ្វើសំណើផ្តល់ដូចបានរៀបរាប់ខាងលើនេះ ទោះបីជាអ្នកលក់មិនអាចប្រគល់ឡានឱ្យទៅអ្នកទិញតាមថ្ងៃកំណត់បាន ដោយសារអ្នកទិញមិនមកតាមកាលបរិច្ឆេទកំណត់ក៏ដោយ ក៏អ្នកលក់មិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះ (ការយឺតយ៉ាវក្នុងការអនុវត្ត) ឡើយ ។

កថាខណ្ឌទី ៣ បញ្ញត្តអំពីអានុភាពពិសេសនៃសំណើផ្តល់ការសង ក្នុងករណីកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលខ្ចីប្រាក់ដើមចំនួន ១,០០០ ដុល្លារ ដោយមានការប្រាក់ចំនួន ៣ ភាគរយ ក្នុង ១ ឆ្នាំ សម្រាប់រយៈពេល ១ ឆ្នាំ ហើយម្ចាស់បំណុលមិនទទួលសំណើផ្តល់ការសងរបស់កូនបំណុល (ប្រាក់ដើម ១០០០ ដុល្លារ បូកនឹងការប្រាក់ ៣០ ដុល្លារ) នៅពេលកំណត់ត្រូវសង តើនឹងមានអ្វីកើតឡើង ? ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ យើងអាចសន្និដ្ឋានថា ទោះបីជាមានការសន្យាអំពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក៏ដោយ (ឧទាហរណ៍ ការសន្យាពិសេសដែលកំណត់ថា "ប្រសិនបើហួសពេលកំណត់ត្រូវសង កូនបំណុលត្រូវបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ តាមអត្រា ៦ ភាគរយក្នុង ១ ឆ្នាំ") ក៏ដោយ ក៏ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះមិនត្រូវកើតឡើងឡើយ ។ ប៉ុន្តែ កថាខណ្ឌទី ២ គ្មានបញ្ញត្តថា តើគួរ ឬ មិនគួរសងការប្រាក់ដែលត្រូវគិតទៅតាមអត្រាដែលបានព្រមព្រៀងគ្នាសម្រាប់អំឡុងពេលនៃកិច្ចសន្យាទេ កុំថាឡើយដល់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ។ ដូច្នេះ កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងថា កូនបំណុលមិនចាំបាច់បង់ការប្រាក់ដែលបានព្រមព្រៀងគ្នានោះទៀតឡើយ ។

ម្យ៉ាងវិញទៀត អ្វីដែលគួរឱ្យកត់សម្គាល់នៅទីនេះ គឺនៅត្រង់ចំណុចថា បើគ្រាន់តែសំណើផ្តល់ការសងរបស់

កូនបំណុលប៉ុណ្ណោះ មិនអាចធ្វើឱ្យរលត់កាតព្វកិច្ចនោះឡើយ ។ ដើម្បីឱ្យរលត់កាតព្វកិច្ច កូនបំណុលត្រូវតែ "តម្កល់ការសង" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៥៧ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ៣០០ ដល់មាត្រា ៣០៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

ប៉ុន្តែ បើពិនិត្យមើលឱ្យហ្មត់ចត់ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់បញ្ញត្តអំពីប្រព័ន្ធនៃ "ការយឺតយ៉ាវ (ក្នុងការទទួលការសង) របស់កូនបំណុល" ហើយក្រមរដ្ឋប្បវេណីបារាំងបញ្ញត្តអំពីប្រព័ន្ធនៃ "សំណើផ្តល់ការសង" ។

## មាត្រា ៤៥៤.- វិធីស្នើផ្តល់ការសង

សំណើផ្តល់ការសងត្រូវធ្វើឡើង ដោយស្នើផ្តល់តាវកាលិកជាក់ស្តែងតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបដិសេធជាមុនក្នុងការទទួលយកសំណើផ្តល់ការសង ឬ ក្នុងករណីដែលម្ចាស់បំណុលចាំបាច់ត្រូវធ្វើអំពើសម្រាប់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល នោះកូនបំណុលគ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំការសង និង ដាស់តឿនឱ្យម្ចាស់បំណុលទទួលការសងនោះតែប៉ុណ្ណោះ ជាការគ្រប់គ្រាន់ហើយ ។

(កំណត់)

មាត្រានេះចែងអំពីវិធីស្នើផ្តល់ការសង ។

"សំណើផ្តល់ការសង" ជាគោលការណ៍ សំដៅលើ "សំណើផ្តល់ការសងជាក់ស្តែង" (offres réelles) ប៉ុន្តែក្នុងករណីមួយចំនួន ពុំចាំបាច់ធ្វើដូច្នេះទេ ហើយអាចយកជាការបានដោយកូនបំណុល "ជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំការសង" ទៅម្ចាស់បំណុល ។ ជាទ្រឹស្តី សំណើផ្តល់ការសងតាមវិធីក្រោយនេះ ហៅថា "សំណើផ្តល់ការសងដោយផ្ទាល់មាត់" ។

ដើម្បីស្វែងយល់បន្ថែមអំពី "សំណើផ្តល់ការសងជាក់ស្តែង" តាមបែបបទជាក់លាក់នោះ សូមមើលសេចក្តីកំណត់នៃកថាខណ្ឌទី ១ មាត្រា ៤៥៣ ។

"សំណើផ្តល់ការសងដោយផ្ទាល់មាត់" មានន័យថា កូនបំណុល "ជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំការសង" ទៅម្ចាស់បំណុល និង "ដាស់តឿនឱ្យម្ចាស់បំណុលទទួលការសងនោះ" (sommation) ។ ការជូនដំណឹងដោយគ្មានការរៀបចំជាក់ស្តែង មិនអាចចាត់ទុកថាជា "សំណើផ្តល់ការសងដោយផ្ទាល់មាត់" បានទេ ។ វាមិនចាំបាច់ត្រូវតែជា "សំណើផ្តល់ការសងជាក់ស្តែង" នោះទេ ប៉ុន្តែ កូនបំណុលត្រូវតែអាចសងភ្លាម ដោយមានការរៀបចំត្រឹមកម្រិតជាក់លាក់

ក្នុងករណីដែលម្ចាស់បំណុលទាមទារឱ្យសងតាមការដាស់តឿន ។ ក្នុងកិច្ចសន្យាលក់ទិញវត្ថុជាក់លាក់ ប្រសិនបើកូនបំណុលត្រូវប្រគល់វត្ថុជាក់លាក់នោះនៅលំនៅឋានរបស់អ្នកទិញ ទោះបីជាវត្ថុជាក់លាក់នោះកំពុងទុកនៅក្នុងឃ្លាំងក៏ដោយ ក៏កូនបំណុលគ្រាន់តែត្រូវត្រៀមខ្លួនឱ្យអាចយកវត្ថុជាក់លាក់នោះចេញពីឃ្លាំងនៅពេលណាមួយ តាមការទាមទាររបស់ម្ចាស់បំណុល ។ ក្នុងករណីដែលមានការសន្យាពិសេសថា វត្ថុត្រូវប្រគល់នៅលំនៅឋានរបស់អ្នកលក់ ក្នុងកិច្ចសន្យាលក់ទិញវត្ថុដែលបានកំណត់ប្រភេទនៃវត្ថុ កូនបំណុលមិនចាំបាច់ "កំណត់ជាក់លាក់" វត្ថុដែលត្រូវប្រគល់ជូនអ្នកទិញនោះដោយបែងចែកពីវត្ថុប្រភេទដូចគ្នា ដទៃទៀតទេ ។ មានន័យថា កូនបំណុលមិនចាំបាច់ "កំណត់ជាក់លាក់" វត្ថុទេ ប្រសិនបើវត្ថុនោះមានចំនួនគ្រប់គ្រាន់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១២៦៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៥៥.–** អានុភាពនៃសំណើផ្តល់ការសង

ក្នុងករណីដែលម្ចាស់បំណុលមិនទទួលនូវសំណើផ្តល់ការសងទេ ក្រៅពីអានុភាពដែលបានកំណត់ក្នុងមាត្រា ៤៥៣ (អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង) នៃក្រមនេះ ត្រូវមានអានុភាពផ្សេងទៀតដូចតទៅ :

ក-ក្នុងករណីដែលកូនបំណុលទទួលបន្ទុកហានិភ័យនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ហានិភ័យនេះត្រូវផ្ទេរទៅម្ចាស់បំណុល ។

ខ-ក្នុងកិច្ចសន្យាអញ្ញមញ្ញ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដែលម្ចាស់បំណុលមាន ត្រូវបាត់បង់ ។

គ-កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបានដោយការតម្កល់ ។

(កំណត់)

មាត្រានេះរៀបរាប់អំពីអានុភាពនានានៃសំណើផ្តល់ការសង ។ អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង គឺជាការដែលកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច ។ កថាខណ្ឌទី ២ នៃមាត្រា ៤៥៣ បញ្ញត្តអំពីចំណុចនេះ ។ ដូច្នេះ មាត្រានេះចែងអំពីអានុភាពផ្សេងទៀតក្រៅពីអានុភាពនេះ ។

អានុភាពនានាដែលបានកំណត់នៅក្នុងមាត្រានេះ អាចកើតឡើង ទោះបីជាគ្មានកំហុសរបស់ម្ចាស់បំណុលក្នុងការមិនទទួលការសងក៏ដោយ ។ ឧទាហរណ៍ ក្នុងកិច្ចសន្យាដែលម្ចាស់បំណុល (អ្នកទិញ) ត្រូវមកលំនៅឋានរបស់កូនបំណុល (អ្នកលក់) ដើម្បីយកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ ទោះបីជាមូលហេតុដែលម្ចាស់បំណុលមិនអាចមកលំនៅឋានរបស់កូនបំណុលនៅថ្ងៃកំណត់ គឺមិនមែនជាការទទួលខុសត្រូវរបស់ម្ចាស់បំណុល ដូចជាការឈឺរបស់ម្ចាស់បំណុល ឬ

ការឈប់ដំណើរការនៃប្រព័ន្ធធ្វើដំណើរក៏ដោយ ក៏ជាការសមរម្យដែរដែលគិតថា បន្ទុកហានិភ័យដោយសារការបាត់បង់វត្ថុដែលជាកម្មវត្ថុ ជាដើម ត្រូវផ្ទេរទៅម្ចាស់បំណុល ។ ឧទាហរណ៍ ក្នុងករណីដែលកូនបំណុលរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ដោយសារម្ចាស់បំណុលមិនអាចមកកាន់លំនៅឋានរបស់កូនបំណុលដោយសារការឈឺ ហើយវត្ថុនោះត្រូវបាត់បង់ដោយសារភ្លើងឆេះដែលចាប់ផ្តើមពីផ្ទះដែលនៅជាប់នោះ ម្ចាស់បំណុលដែលមិនបានមកយកវត្ថុនោះតាមថ្ងៃកំណត់ គួរទទួលបន្ទុកហានិភ័យដោយសារការបាត់បង់វត្ថុនោះ ។

អានុភាពនៃកថាខណ្ឌទី ២ និង ទី ៣ មិនចាំបាច់មានការពន្យល់ពិសេសនោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៥៦.- ការយឺតយ៉ាវក្នុងការទទួល

១-ក្នុងករណីដែលម្ចាស់បំណុលប្រកែកជាមុននូវការទទួលការសង ឬ ករណីដែលកូនបំណុលបានស្នើផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះដោយមានកំហុស កូនបំណុលអាចទាមទារពីម្ចាស់បំណុលនូវសំណងនៃការខូចខាត ដែលបណ្តាលមកពីការមិនទទួលនោះបាន ។

២-ក្នុងករណីដែលការមិនទទួលសំណើផ្តល់ការសងរបស់ម្ចាស់បំណុល គឺជាការបំពានករណីយកិច្ចដ៏ធ្ងន់ធ្ងរពីម្ចាស់បំណុល នោះកូនបំណុលអាចរំលាយកិច្ចសន្យាបាន ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់ម្ចាស់បំណុលចំពោះការយឺតយ៉ាវក្នុងការទទួល ។

ទោះជាកូនបំណុលព្យាយាមអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបានដោយសារពុំមានការសហការពីម្ចាស់បំណុល នោះកូនបំណុលអាចអះអាងនូវអានុភាពនៃ "សំណើផ្តល់ការសង" បាន ។ ជាពិសេស កូនបំណុលអាចអះអាងថា ការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចមិនត្រូវកើតឡើង ។ ប៉ុន្តែ មានករណីមួយចំនួនដែលអានុភាពការនៃសំណើផ្តល់ការសងតែប៉ុណ្ណោះ មិនអាចការពារកូនបំណុលដោយគ្រប់គ្រាន់បានទេ ។ កូនបំណុលអាចទាមទារឱ្យម្ចាស់បំណុលសងសំណងការខូចខាត ចំពោះសោហ៊ុយសម្រាប់រក្សាទុកវត្ថុដែលជាកម្មវត្ថុនៃការសងក្នុងឃ្លាំងដែលកូនបំណុលបានចំណាយដើម្បីរក្សាទុកវត្ថុនោះក្នុងរយៈពេលវែង ដោយសារម្ចាស់បំណុលមិនទទួលការសង ឬ ចំពោះពន្ធលើអចលនវត្ថុដែលជាកម្មវត្ថុនៃការសង ជាអាទិ៍ ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលម្ចាស់បំណុលមិនមកយកវត្ថុ កូនបំណុលអាចពិចារណារំលាយកិច្ចសន្យាចោលបាន ។ ប្រព័ន្ធនៃការយឺតយ៉ាវក្នុងការទទួល ទទួលស្គាល់នូវការទទួលខុសត្រូវចំពោះសំណងការខូចខាតរបស់ម្ចាស់បំណុល (កថាខណ្ឌទី ១) និង ការរំលាយកិច្ចសន្យាដោយកូនបំណុល

(កថាខណ្ឌទី ២) ។ នេះក៏អាចហៅបានថាជាការយឺតយ៉ាវរបស់ម្ចាស់បំណុល ដោយសារប្រព័ន្ធនេះទាមទារឱ្យម្ចាស់បំណុលទទួលខុសត្រូវ ។

ក្នុងកិច្ចសន្យាអញ្ញមញ្ញភាគច្រើន បញ្ហាអាចដោះស្រាយបានដោយការមិនអនុវត្តកាតព្វកិច្ច ទោះបីជាមិនទាមទារឱ្យម្ចាស់បំណុលទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការទទួលការសងក៏ដោយ ។ ឧទហរណ៍ ក្នុងករណីដែលអ្នកទិញ B មិនយកវត្ថុដែលលក់តាមកិច្ចសន្យាលក់ទិញរវាងអ្នកលក់ A និង អ្នកទិញ B ជាធម្មតា អ្នកទិញក៏មិនទាន់បង់ថ្លៃលក់នៅឡើយទេ ហេតុដូច្នេះ អ្នកលក់ A អាចរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចបង់ថ្លៃលក់របស់អ្នកទិញបាន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទិញបង់ថ្លៃលក់រួចហើយ តែមិនមកទទួលយកវត្ថុដែលជាកម្មវត្ថុនៃការសង អ្នកលក់មិនអាចទាមទារឱ្យអ្នកទិញទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចឡើយ ។ មានតែករណីដែលលើកឡើងអំពីការយឺតយ៉ាវក្នុងការទទួលការសងទេដែលអាចទាមទារឱ្យម្ចាស់បំណុលទទួលខុសត្រូវបាន ។

**មាត្រា ៤៥៧.–** ការតម្កល់

១-កូនបំណុលអាចតម្កល់នូវកម្មវត្ថុនៃកាតព្វកិច្ចនៅកន្លែងតម្កល់ដើម្បីឱ្យរួចពីកាតព្វកិច្ចបាន ក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

ក-អ្នកសងបានស្នើផ្តល់ការសង តែម្ចាស់បំណុលបដិសេធមិនទទួល ឬ មិនអាចទទួលការសងនោះបាន ។

ខ-កូនបំណុលមិនអាចដឹងថា អ្នកណាជាម្ចាស់បំណុល ដោយមិនមែនជាកំហុសរបស់ខ្លួន ។

២-នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលមិនព្រមចំពោះការតម្កល់ ឬ ក្នុងអំឡុងពេលដែលសាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាព មិនទាន់ចូលជាស្ថាពរទេ អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន ។[៩] ក្នុងករណីនេះ អ្នកសងត្រូវបានចាត់ទុកថា មិនបានធ្វើការតម្កល់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលសិទ្ធិលើការបញ្ចាំ ឬ សិទ្ធិលើហ៊ីប៉ូតែក ត្រូវបានរលត់ដោយការតម្កល់នោះ ។

៣-សេចក្តីលម្អិតស្តីពីការតម្កល់ ត្រូវកំណត់ក្នុងច្បាប់ស្តីពីការតម្កល់ ។

[៩] វាក្យខណ្ឌទី ១ កថាខណ្ឌទី ២ នៃមាត្រា ៤៥៧ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(កំណត់)

មាត្រានេះបញ្ញត្តថា កូនបំណុលអាចរំលត់កាតព្វកិច្ច ដោយការតម្កល់បាន ។

ប្រព័ន្ធនៃការតម្កល់មានលក្ខណៈចាំបាច់ ដោយសារមូលហេតុដូចខាងក្រោម ។ ក្នុងករណីដែលកូនបំណុលមានបំណងសង តែមិនអាចធ្វើបាន ដោយសារមូលហេតុខាងម្ចាស់បំណុល នោះកូនបំណុលអាចរួចពីការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចបាន ដោយធ្វើសំណើផ្តល់ការសង ។ ម្យ៉ាងទៀត ក្នុងករណីមួយចំនួន ការយឺតយ៉ាវក្នុងការទទួលរបស់ម្ចាស់បំណុលអនុញ្ញាតឱ្យមានការការពារផលប្រយោជន៍របស់កូនបំណុល ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលគ្រាន់តែចង់ឱ្យកាតព្វកិច្ចរបស់ខ្លួនរលត់ដោយការសង សំណើផ្តល់ការសងតែប៉ុណ្ណោះ មិនគ្រប់គ្រាន់នោះទេ ដោយសារសំណើផ្តល់ការសងមិនមែនជាប្រព័ន្ធដែលរំលត់កាតព្វកិច្ចទេ ។ ដូច្នេះ មានភាពចាំបាច់បង្កើតប្រព័ន្ធតម្កល់ដើម្បីរំលត់កាតព្វកិច្ច ។

កថាខណ្ឌទី ១ បញ្ញត្តអំពីករណីដែលអាចធ្វើការតម្កល់បាន ។ កថាខណ្ឌនេះ កំណត់អំពីមូលហេតុនៃការតម្កល់ ។

មានបញ្ហាមួយចំនួនទាក់ទងនឹងចំណុច ក ក្នុងករណីដូចខាងក្រោម ។ ក្នុងករណីដែលភតិបតីទាមទារឱ្យរំលាយភតិសន្យា ដោយសារការមិនអនុវត្តរបស់ភតិកៈ ជាញឹកញាប់ ភតិបតីមិនទទួលយកថ្លៃឈ្នួលទេ ទោះបីជាភតិកៈស្នើផ្តល់ការសងថ្លៃឈ្នួលនោះក៏ដោយ ។ ភតិកៈដែលគិតថា មិនមានការមិនអនុវត្តកាតព្វកិច្ច ចង់បង់ថ្លៃឈ្នួល ដោយសារខ្លាចថាកិច្ចសន្យាអាចត្រូវបានរំលាយ ដោយសារការមិនបង់ថ្លៃឈ្នួល ។

ចំនុច ខ បញ្ញត្តអំពីករណីដែលកូនបំណុលមិនអាចដឹងថា អ្នកណាជាម្ចាស់បំណុល ។ ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានធ្វើអនុប្បទានជាន់គ្នា ហើយអនុប្បទានិកនីមួយៗទាមទារឱ្យកូនបំណុលសង ដោយអះអាងថា ខ្លួនជាម្ចាស់បំណុល កូនបំណុលគួរអាចរួចពីកាតព្វកិច្ចដោយធ្វើការតម្កល់ ដើម្បីជៀសវាងវិវាទរវាងអនុប្បទានិក ។

កថាខណ្ឌទី ២ បញ្ញត្តអំពីពេលវេលាដែលអ្នកធ្វើការតម្កល់ (កូនបំណុល) អាចដកការតម្កល់ និង ទាមទារឱ្យប្រគល់វិញនូវវត្ថុតម្កល់បាន ។ កូនបំណុលធ្វើការតម្កល់ ដោយសារម្ចាស់បំណុលមិនព្រមទទួលការសង ឬ ដោយសារមិនដឹងថា អ្នកណាជាម្ចាស់បំណុល ហេតុដូច្នេះ ទោះបីជាកូនបំណុលយកវត្ថុតម្កល់មកវិញនៅពេលណាក៏ដោយ ក៏ហាក់ដូចជាមិនប៉ះពាល់ផលប្រយោជន៍អ្វីដល់ម្ចាស់បំណុលទេ ។ ប៉ុន្តែ ដោយសារអាចមានករណីដែលម្ចាស់បំណុលពិតប្រាកដពឹងផ្អែកលើការដែលការតម្កល់ត្រូវបានធ្វើឡើង កថាខណ្ឌនេះបញ្ញត្តថា កូនបំណុលមិនអាចយកវត្ថុតម្កល់មកវិញបាន ទេ បន្ទាប់ពីរយៈពេលកំណត់មួយ ។ ឧទាហរណ៍ ក្នុងករណីដែលបុគ្គលពីររូបមានវិវាទលើភាពជាម្ចាស់បំណុលចំពោះសិទ្ធិលើបំណុលដែលត្រូវបានធ្វើអនុប្បទានជាន់គ្នា ប្រសិនបើកូនបំណុលបានតម្កល់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើបំណុលនោះ អនុប្បទានិកទាំងពីររូបនេះអាចដោះស្រាយវិវាទនេះ ដោយខ្លួនគេបាន ដោយមិនចាំបាច់មានវត្តមានរបស់កូនបំណុលទេ (ប្រសិនបើកូនបំណុលមិនធ្វើការតម្កល់ទេ អនុប្បទានិកនីមួយៗនោះចាំបាច់ត្រូវទាមទារឱ្យកូនបំណុលសង) ។ ប្រព័ន្ធនេះនាំឱ្យមានការដោះស្រាយវិវាទដោយមានលក្ខណៈសាមញ្ញ ហើយផ្តល់ផលប្រយោជន៍ជាច្រើន ។ ប្រសិនបើកូនបំណុលអាចដកការតម្កល់ដោយសេរី បន្ទាប់ពីផលប្រយោជន៍កើតឡើង វាអាចនឹងនាំឱ្យដកហូតនូវផលប្រយោជន៍របស់ម្ចាស់បំណុលដែលបានកើតរួចហើយ ដូច្នេះ មិនអាចអនុញ្ញាតឱ្យធ្វើដូច្នេះទេ ។

កថាខណ្ឌទី ៣ ប្រគល់សិទ្ធិទៅច្បាប់ស្តីពីការតម្កល់ក្នុងការបញ្ញត្តសេចក្តីលម្អិតស្តីពីការតម្កល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩៤ មាត្រា ៤៩៥ មាត្រា ៤៩៦ និង មាត្រា ៤៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, ច្បាប់ស្តីពីការតម្កល់នៃប្រទេសជប៉ុន

## មាត្រា ៤៥៨.- សិទ្ធិលក់ដោយខ្លួនឯង

ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការសងមិនសមស្របនឹងការតម្កល់ ឬ មានការបារម្ភខ្លាចមានការបាត់បង់ ឬ ខូចខាត តាមការអនុញ្ញាតពីតុលាការ អ្នកសងអាចលក់វត្ថុនោះដោយដេញថ្លៃ ហើយតម្កល់នូវប្រាក់លក់នោះបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលការរក្សាទុកវត្ថុនោះតម្រូវឱ្យចេញសោហ៊ុយច្រើនហួសហេតុ ។

(កំណត់)

មាត្រានេះបញ្ញត្តថា ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការសងមិនសមស្របនឹងការតម្កល់ អ្នកសងអាចលក់វត្ថុនោះដើម្បីប្តូរជាប្រាក់ដែលអាចតម្កល់បាន ។

ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការសង គឺជាប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន នឹងមានភាពងាយស្រួលក្នុងការតម្កល់វត្ថុបែបនេះ ។ ប៉ុន្តែ ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការសងជាសត្វ ឬ រុក្ខជាតិ ឬ វត្ថុទំហំធំមហិមា ជាអាទិ៍ នឹងមានការពិបាកនឹងធ្វើការតម្កល់នៅការិយាល័យតម្កល់ ។ ក្នុងករណីបែបនេះ ប្រសិនបើកូនបំណុលអាចលក់វត្ថុនោះដើម្បីប្តូរជាប្រាក់ ការតម្កល់អាចធ្វើបាន ។ ដូច្នេះ មាត្រានេះអនុញ្ញាតឱ្យកូនបំណុលមានសិទ្ធិដាក់ពាក្យសុំឱ្យលក់ដោយដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ។

ប៉ុន្តែ ជាទូទៅ ប្រសិនបើលក់វត្ថុណាមួយដោយដេញថ្លៃ វត្ថុនោះត្រូវបានលក់ក្នុងតម្លៃថោកជាងទីផ្សារច្រើន ហើយម្យ៉ាងទៀត ម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ ដោយសារខ្លួនមិនអាចទទួលតាមកាលកំណត់ដែលបានព្រមព្រៀងគ្នាពីដើម ។ ដោយហេតុនេះហើយ តុលាការសក្តិសមនឹងវិនិច្ឆ័យថា តើវត្ថុដែលជាកម្មវត្ថុនៃការសងនោះគួរ ឬ មិនគួរនឹងដាក់ដេញថ្លៃ ។ សូមមើលមាត្រា ៤៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

# កថាភាគទី ៤ ឧបាទេសកម្មដោយការសង

**មាត្រា ៤៥៩.–** ឧបាទេសកម្មដោយការសង

១-អ្នកដែលបានរួចផុតពីការទទួលខុសត្រូវ ដោយបានសង ឬ បានចេញចំណាយរបស់ខ្លួនផ្សេងទៀត ហើយបានទទួលសិទ្ធិទាមទារសំណងចំពោះកូនបំណុល អាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មបាន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិផ្សេងទៀតដែលម្ចាស់បំណុលនោះធ្លាប់មាន ។

២-បញ្ញត្តិនៃមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ការជូនដំណឹងដែលបានកំណត់នៅក្នុងមាត្រា ៩១៣ (ល័ក្ខខ័ណ្ឌនៃការទាមទារសំណង) និង មាត្រា ៩៣៣ (ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង) នៃក្រមនេះ អាចយកជាជំនួសនឹងការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ក្នុងករណីដែលចាំបាច់មានលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរ តាមបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងទៅតាមកថាខណ្ឌទី ២ ខាងលើនេះ ការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌនេះ ក៏ត្រូវធ្វើដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្លាពរដែរ ។

(កំណត់)

(១) ក្នុងករណីដែលបុគ្គលម្នាក់ក្នុងចំណោមកូនបំណុលរួម ឬ តតិយជន បានសង កូនបំណុលបានរួចផុតពីការបន្ទុយ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" ដោយចេញចំណាយរបស់បុគ្គលនោះ ហេតុដូច្នេះ បុគ្គលដែលបានចំណាយនោះ ត្រូវបានទទួលស្គាល់នូវសិទ្ធិទាមទារសំណងរបស់ចំពោះកូនបំណុលនោះ ។ ហើយដើម្បីធានានូវសិទ្ធិទាមទារសំណងនោះ មាត្រានេះទទួលស្គាល់នូវឧបាទេសកម្មដោយអ្នកសង ចំពោះសិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន ព្រមទាំងប្រាតិភោគដែលធានាសិទ្ធិលើបំណុលនោះ ។ ម្យ៉ាងទៀត មានការជជែកគ្នាជាច្រើន ស្តីពីរចនាសម្ព័ន្ធតាមផ្លូវច្បាប់នៃឧបាទេសកម្មដោយការសង ក៏ប៉ុន្តែ ដោយសារតែច្បាប់កម្ពុជាមានប្រភពពីច្បាប់បារាំង យើងខ្ញុំបានទទួលបន្តនូវគំនិតនេះ ហើយបានជ្រើសរើសយកការផ្ទេរទៅឱ្យអ្នកដែលបានសង នូវសិទ្ធិលើបំណុល ព្រមទាំងសិទ្ធិបន្ទាប់បន្សំ ដោយឧបាទេសកម្មមកធ្វើជាមូលដ្ឋានក្នុងនេះ ។

(២) ចំពោះការទទួលស្គាល់នូវឧបាទេសកម្មដោយការសង មានការជជែកច្រើនអំពីបញ្ហាដែលថា តើចាំបាច់ត្រូវមានការយល់ព្រមពីម្ចាស់បំណុលដែរឬទេនោះ ជាពិសេស ចំពោះឧបាទេសកម្មដោយការសងដោយជនដែលត្រូវបានចាត់ទុកថាពុំមានផលប្រយោជន៍ត្រឹមត្រូវក្នុងការសង ។

តាមក្រមរដ្ឋប្បវេណីជប៉ុន ចំពោះអ្នកសងដែលពុំមានផលប្រយោជន៍ត្រឹមត្រូវក្នុងការសងទេ ក្នុងករណីដែលមានការយល់ព្រមពីម្ចាស់បំណុល អ្នកសងត្រូវបានទទួលស្គាល់នូវឧបាទេសកម្មដោយការសង ។ ក៏ប៉ុន្តែ ចំពោះម្ចាស់បំណុលដែលបានទទួលនូវការសងនោះ តែមិនយល់ព្រមនូវឧបាទេសកម្មនោះ ពុំត្រឹមត្រូវទេ ។ ម្យ៉ាងទៀត ចំពោះទស្សនៈ "ផលប្រយោជន៍ត្រឹមត្រូវ" ក្នុងការសង គេច្រើនតែធ្វើការបកស្រាយទូលាយ ក៏ប៉ុន្តែ ន័យទូលាយត្រឹមណា មិនច្បាស់លាស់ទេ ។

ដូច្នេះហើយ ដូចក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុនដែរ កថាខណ្ឌទី ១ នៃមាត្រានេះ ទទួលស្គាល់នូវឧបាទេសកម្មដោយការសង ដោយពុំគិតថា តើមាន ឬគ្មាន ការយល់ព្រមពីម្ចាស់បំណុលនោះទេ ។

(៣) លើសពីនេះ ចំពោះឧបាទេសកម្មដោយការសង ទោះបីជាពុំចាំបាច់មានការយល់ព្រមពីម្ចាស់បំណុលក៏ដោយ ក៏ចំពោះការផ្ទេរសិទ្ធិលើបំណុលដែលកើតឡើងដោយសារអានុភាពនៃឧបាទេសកម្ម ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌតតាំង ។ ដូច្នេះហើយ កថាខណ្ឌទី ២ ចែងថា ចាំបាច់មានល័ក្ខខ័ណ្ឌតតាំង ដូចនឹងល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែរ ។ សូមបញ្ជាក់ថា នៅក្រោមក្រមរដ្ឋប្បវេណីជប៉ុន ស្តីពីឧបាទេសកម្មដោយអ្នកសងដែលមាន "ផលប្រយោជន៍ត្រឹមត្រូវ" ក្នុងការសងនោះ ពុំចាំបាច់មានល័ក្ខខ័ណ្ឌតតាំងទេ ដោយសារតែមានការកម្រិតនូវវិសាលភាពនៃអ្នកសង (មាត្រា ៥០០ នៃក្រមរដ្ឋប្បវេណីជប៉ុន) ក៏ប៉ុន្តែ ចំពោះបញ្ហានេះ មានមតិផ្ទុយពីនេះដែរ ។ ដូចដែលបានលើកឡើងក្នុង (២) ដែរ ទស្សនៈ "ផលប្រយោជន៍ត្រឹមត្រូវ" មិនមែនជាទស្សនៈមួយដែលគ្រប់គ្រាន់ដើម្បីបែងចែកការចាត់ចែងចំពោះការសងនីមួយៗទេ ហេតុនេះហើយ ទោះបីជាមាន ឬ គ្មាន "ផលប្រយោជន៍ត្រឹមត្រូវ" ក្នុងការសងក៏ដោយ តាមទស្សនៈនៃសុវត្ថិភាពក្នុងកិច្ចការជួញដូរ ចំពោះឧបាទេសកម្មដោយការសង គប្បីទាមទារឱ្យមានល័ក្ខខ័ណ្ឌតតាំង ចំពោះតតិយជន ។

(៤) ក៏ប៉ុន្តែ ក្នុងករណីមានការទាមទារឱ្យមានការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌសម្រាប់ការទាមទារសំណងវិញ ការទាមទារឱ្យមានការជូនដំណឹង ឬ យល់ព្រមអំពីឧបាទេសកម្មថែមពីលើនេះទៀត នឹងធ្វើឱ្យមានការស្មុគស្មាញ ហេតុនេះហើយបានជា កថាខណ្ឌទី ៣ ចែងថា អាចយកការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌសម្រាប់ការទាមទារសំណង មកជំនួសនឹងល័ក្ខខ័ណ្ឌតតាំងនៃឧបាទេសកម្មបាន ។ ប៉ុន្តែ ល័ក្ខខ័ណ្ឌតតាំងនឹងតតិយជន ចាំបាច់ត្រូវមានកាលបរិច្ឆេទស្លាក ដូច្នេះហើយ ក្នុងករណីបានយកការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌសម្រាប់ការទាមទារសំណង មកជំនួសល័ក្ខខ័ណ្ឌតតាំងនៃឧបាទេសកម្ម ប្រសិនជាពុំមានកាលបរិច្ឆេទស្លាកទេ ពុំអាចតតាំងឧបាទេសកម្មនឹងតតិយជនបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៩៩ និង មាត្រា ៥០០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៦០.-** ទំហំនៃឧបាទេសកម្ម និង ទំនាក់ទំនងគ្នាទៅវិញទៅមករវាងឧបាទេសិក

១-ឧបាទេសិកនៃម្ចាស់បំណុលតាមបញ្ញត្តិនៃមាត្រា ៩៥៩ (ឧបាទេសកម្មដោយការសង) ខាងលើនេះ អាចប្រើសិទ្ធិទាំងឡាយដែលជាអានុភាព និង ប្រាតិភោគនៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលធ្លាប់មាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះសិទ្ធិរបស់ម្ចាស់បំណុលដែលបានមកពីឋានៈក្នុងកិច្ចសន្យា ។

២-ឧបាទេសិកត្រូវធ្វើតាមបញ្ញត្តិនៃចំណុចដូចតទៅ :

ក-ប្រសិនបើអ្នកធានាដោយបុគ្គល ឬ អ្នកធានាដោយវត្ថុ មិនបានធ្វើការចុះបន្ថែមជាមុន នូវឧបាទេសកម្ម ក្នុងបញ្ជីចុះឯកសិទ្ធិ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកដែលយកទ្រព្យរបស់កូនបំណុលមកជាកម្មវត្ថុទេ អ្នកធានា ឬ អ្នកធានាដោយវត្ថុនោះ មិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ឬ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកនោះទេ ។

ខ-តតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល មិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះអ្នកធានាទេ ។

គ-តតិយជនម្នាក់ក្នុងចំណោមតតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនផ្សេងទៀតដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុលតាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

ឃ-បញ្ញត្តិនៃចំណុច គ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកធានាដោយវត្ថុ ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ ។

ង-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកធានាដោយវត្ថុមានច្រើននាក់ ចំពោះប្រាក់សំណល់ ក្រៅពីភាគដែលជាបន្ទុកអ្នកធានា ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម តាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

(កំណត់)

(១) តាមឧបាទេសកម្មដោយការសង ឧបាទេសិកអាចអនុវត្តបាននូវសិទ្ធិទាំងអស់ដែលម្ចាស់បំណុលមាន ក៏ប៉ុន្តែ ដោយសារតែឧបាទេសកម្មដោយការសងនេះ មានគោលបំណងធានានូវសិទ្ធិទាមទារសំណងរបស់អ្នកសង វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ចែងថា ទំហំដែលអាចធ្វើឧបាទេសកម្មបាន ដូចគ្នានឹងទំហំដែលអាចទាមទារសំណងបាន ។ម្យ៉ាងទៀត ដោយសារតែមានការចាំបាច់គោរពសិទ្ធិ និង ផលប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចសន្យា វាក្យខណ្ឌទី ២ នៃ កថាខណ្ឌទី ១ នេះបញ្ជាក់ច្បាស់លាស់ថា ឋានៈក្នុងកិច្ចសន្យា មិនអាចក្លាយទៅជាកម្មវត្ថុនៃឧបាទេសកម្មបានឡើយ ។

(២) ក្នុងករណីដែលអ្នកបង្កើតប្រាតិភោគ អ្នកធានា និង តតិយជនដែលបានធ្វើលទ្ធកម្ម មានច្រើននាក់ ចំពោះកាតព្វកិច្ច ដែលត្រូវបានសង ប្រសិនបើជនណាម្នាក់ក្នុងចំណោមនោះបានសង តើជននោះអាចធ្វើឧបាទេសកម្មបានត្រឹមណា ចំពោះជន ផ្សេងទៀតនោះ ? កថាខណ្ឌទី ២ ចែងអំពីចំណុចនេះ ។ ប្រសិនបើពុំមានបញ្ញត្តិនេះទេ ជនដែលបានសងមុនគេ នឹងអាច ស្នងម្ចាស់បំណុលដោយឧបាទេសកម្មចំពោះជនដទៃទៀត ចំពោះចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិទាមទារសំណងចំពោះ កូនបំណុល ។ ការអនុញ្ញាតឱ្យមានស្ថានភាពនេះ គឺជាការទទួលស្គាល់លទ្ធផលមួយផ្ទុយនឹងឆន្ទៈរបស់ភាគី ឬ ផ្ទុយនឹង ទស្សនៈនៃសមធម៌ទៅវិញ ។ ហេតុនេះហើយបានជាត្រូវចែងអំពីទំនាក់ទំនងគ្នាទៅវិញទៅមក រវាងអ្នកដែលអាចក្លាយ ទៅជាឧបាទេសិក ដោយផ្អែកទៅលើឆន្ទៈដ៏សមរម្យមួយរបស់ភាគី ឬ ទៅលើគោលការណ៍សមធម៌ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥០១ នៃក្រមរដ្ឋប្បវេណីជប៉ុន , មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីបារាំង , មាត្រា ២៦៨ III, មាត្រា ៤២៦ II និង មាត្រា ៧៧៤ I នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៤៦១.-** ឧបាទេសកម្មមួយភាគ

១-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ឧបាទេសិកនោះអនុវត្តសិទ្ធិព្រមគ្នានឹងម្ចាស់បំណុល ទៅតាមចំនួនប្រាក់ដែលខ្លួនបានសង ។ ប៉ុន្តែ ពេលដែលឧបាទេសិកអនុវត្តសិទ្ធិរបស់ខ្លួន អ្នកនោះត្រូវទទួលការយល់ព្រមពីម្ចាស់ បំណុល ឬ បើម្ចាស់បំណុលទាមទារ អ្នកនោះត្រូវធ្វើអនុប្បទាននូវសិទ្ធិ ឬ អាទិភាពរបស់ ខ្លួន ទៅឱ្យម្ចាស់បំណុល ត្រឹមកម្រិតនៃប្រាក់សំណល់នៃសិទ្ធិលើបំណុលនោះ ដោយមិន យកថ្លៃ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានតែម្ចាស់ បំណុលទេ ដែលអាចរំលាយកិច្ចសន្យាបាន ដោយយកមូលហេតុថាមិនបានអនុវត្ត កាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវសងនូវប្រាក់ដែលឧបាទេសិកបានសង

ព្រមទាំងការប្រាក់ ទៅឧបាទេសិកនោះវិញ ។

(កំណត់)

(១) ទោះបីជាមានការសងនូវសិទ្ធិលើបំណុលមួយភាគក៏ដោយ អ្នកសងនឹងទទួលលទ្ធកម្មនូវសិទ្ធិទាមទារសំណង ចំពោះកូនបំណុល ។ ដូច្នេះហើយ ដើម្បីធានានូវសិទ្ធិទាមទារសំណងនេះ ចាំបាច់ត្រូវមានការទទួលស្គាល់នូវឧបាទេសកម្ម ទៅតាមភាគដែលខ្លួនបានសង ។ នេះគឺជាឧបាទេសកម្មមួយភាគ ។ ក្នុងករណីដែលមានឧបាទេសកម្មទាំងស្រុង សិទ្ធិលើ បំណុលដែលម្ចាស់បំណុលមាន ព្រមទាំងសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុលនោះ ត្រូវផ្ទេរទាំងស្រុងទៅឱ្យអ្នកសង ហើយម្ចាស់បំណុលនឹងឈប់មានទំនាក់ទំនងនឹងសិទ្ធិលើបំណុលនោះ ហេតុនេះហើយបានជាពុំមានបញ្ហាអ្វីកើតឡើងរវាង ឧបាទេសិក និង ម្ចាស់បំណុលឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីឧបាទេសកម្មមួយភាគ ម្ចាស់បំណុលដែលមិនទាន់បានទទួល នូវសំណងមួយភាគនោះ នៅតែមានសិទ្ធិលើបំណុលលើភាគដែលនៅសល់នោះ ហើយចាំបាច់ត្រូវតែពិនិត្យឱ្យបានហ្មត់ចត់ អំពីទំនាក់ទំនងរវាងម្ចាស់បំណុលនេះ និង ឧបាទេសិកដែលបានសងមួយភាគនោះ ។

បញ្ញត្តិច្បាប់នៃប្រទេសនានាដែលមានសព្វថ្ងៃនេះ ស្តីពីទំនាក់ទំនងរវាងម្ចាស់បំណុល និង ឧបាទេសិកដែលបានសង មួយភាគ អាចបែងចែកជាពីរប្រភេទធំៗបាន ។ ទី ១ គឺការតាក់តែងច្បាប់ដែលចាត់ចែងស្មើភាពគ្នា រវាងម្ចាស់បំណុល និង ឧបាទេសិកដែលបានសងមួយភាគ ហើយទទួលស្គាល់នូវការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល និង ឧបាទេសិកនោះ ដោយគណនាទៅតាមសមាមាត្រនៃទឹកប្រាក់នៃសិទ្ធិលើបំណុលដែលនៅសល់ និង ទឹកប្រាក់ដែលបានសង ។ ទី ២ គឺ ការតាក់តែងច្បាប់ដោយឱ្យអាទិភាពទៅលើម្ចាស់បំណុល ហើយឱ្យឧបាទេសិកដែលបានសងមួយភាគនូវលំដាប់ក្រោយម្ចាស់ បំណុល ។ ឧទាហរណ៍ទី ១ មានដូចជាមាត្រា ៥០២ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ រីឯឧទាហរណ៍ទី ២ វិញ មានដូចជា មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ២៦៨ III, មាត្រា ៤២៦ II, មាត្រា ៧៧៤ I នៃក្រមរដ្ឋប្បវេណី អាល្លឺម៉ង់ ដែលចែងថា ឧបាទេសិកដែលបានសងមួយភាគ មិនត្រូវធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលទេ ។

នៅប្រទេសជប៉ុន ទោះបីជាមានបញ្ញត្តិដែលចែងអំពីស្មើភាពរវាងម្ចាស់បំណុល និង ឧបាទេសិកដែលបានសង មួយភាគក៏ដោយ ក៏តាមទស្សនៈទូទៅ គេឱ្យឧបាទេសិកដែលបានសងមួយភាគមានលំដាប់ទាបជាងម្ចាស់បំណុលដែរ ដោយសារមូលហេតុដូចតទៅ : (ក) ទោះជាម្ចាស់បំណុលនៅមានសិទ្ធិលើបំណុលដែលនៅសល់ក៏ដោយ ប្រសិនបើ ឧបាទេសិកដែលបានសងមួយភាគអនុវត្តសិទ្ធិប្រាតិភោគទៅ ម្ចាស់បំណុលនឹងបាត់បង់នូវអានុភាពនៃសិទ្ធិប្រាតិភោគនា អនាគត ដោយខុសពីឆន្ទៈរបស់ខ្លួន ហើយការណ៍នេះនាំឱ្យខូចខាតផលប្រយោជន៍របស់ម្ចាស់បំណុល (ឧទាហរណ៍ ម្ចាស់បំណុលមិនអនុវត្តសិទ្ធិប្រាតិភោគ ដោយសារមានជំនឿទៅលើដំណើរការល្អនៃអាជីវកម្មរបស់កូនបំណុលនាអនាគត ក៏ប៉ុន្តែ ឧបាទេសិកដែលបានសងមួយភាគបែរទៅជាអនុវត្តសិទ្ធិប្រាតិភោគនោះទៅវិញ ក្នុងករណីនេះ ម្ចាស់បំណុលនឹង បាត់បង់នូវផលប្រយោជន៍របស់ខ្លួនដែលជឿជាក់ទៅលើអនាគតកាលរបស់កូនបំណុល) (ខ) ការទទួលស្គាល់នូវការ អនុវត្តសិទ្ធិប្រាតិភោគតាមសមាមាត្រ គឺជាអំពើមួយផ្ទុយនឹងអវិភាគភាពនៃសិទ្ធិប្រាតិភោគ ។

ដោយគិតដល់ចំណុចដែលបានរៀបរាប់ខាងលើនេះ កថាខណ្ឌទី ១ នៃមាត្រានេះ បញ្ជាក់ច្បាស់លាស់នូវគោលគំនិតមិនអនុញ្ញាតនូវឧបាទេសកម្មដោយឧបាទេសិកដែលបានសងមួយភាគ ដែលធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលឡើយ ។

(២) កថាខណ្ឌទី ២ នៃមាត្រានេះត្រូវបានចែងឡើងក្នុងគោលបំណងបញ្ជាក់ជាថ្មីម្តងទៀតក្នុងវាក្យខណ្ឌទី ១ នូវគោលគំនិតនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៤៦០ ហើយការពារផលប្រយោជន៍របស់ឧបាទេសិកដែលបានសងមួយភាគ តាមរយៈវាក្យខណ្ឌទី ២ នៃមាត្រានេះ ។ មានន័យថា ប្រសិនបើម្ចាស់បំណុលបានរំលាយកិច្ចសន្យាដែលជាមូលហេតុនៃការបង្កើតសិទ្ធិលើបំណុល ដោយយកការមិនអនុវត្តសិទ្ធិលើបំណុលដែលនៅសល់ មកធ្វើជាមូលហេតុនោះតាមរយៈការធ្វើបដិទាន សិទ្ធិលើបំណុលនោះនឹងត្រូវរលត់ ហើយសិទ្ធិប្រាតិភោគនោះក៏ត្រូវរលត់តាមដែរ ដូច្នេះការធានានូវសិទ្ធិទាមទារសំណងរបស់ឧបាទេសិកដែលបានសងមួយភាគ ក៏មិនអាចធ្វើបានដែរ ។ ដូច្នេះហើយ វាក្យខណ្ឌទី ២ នេះតម្រូវឱ្យម្ចាស់បំណុលដែលបានរំលាយកិច្ចសន្យា សងនូវប្រាក់ដែលខ្លួនបានទទួលពីឧបាទេសិកដែលបានសងមួយភាគ ព្រមទាំងការប្រាក់នោះ ចំពោះឧបាទេសិកដែលបានសងមួយភាគនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ២៦៨ III, មាត្រា ៤២៦ II និង មាត្រា ៧៧៤ I នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីអ៊ីតាលី

**មាត្រា ៤៦២.-** ការសងជំនួស និង លិខិតបញ្ជាក់សិទ្ធិលើបំណុល ឬ វត្ថុប្រាតិភោគ

១-ម្ចាស់បំណុលដែលបានទទួលការសងទាំងអស់ពីឧបាទេសិក ត្រូវប្រគល់នូវលិខិតដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ និង វត្ថុប្រាតិភោគដែលខ្លួនកាន់កាប់នោះទៅឱ្យឧបាទេសិក ។

២-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ម្ចាស់បំណុលត្រូវធ្វើកំណត់បន្ថែមអំពីឧបាទេសកម្មនេះ ក្នុងលិខិតបញ្ជាក់សិទ្ធិលើបំណុល ហើយឱ្យឧបាទេសិកធ្វើការត្រួតពិនិត្យនូវការរក្សាវត្ថុប្រាតិភោគដែលម្ចាស់បំណុលនោះកាន់កាប់ផងដែរ ។

(កំណត់)

(១) មាត្រានេះតម្រូវឱ្យម្ចាស់បំណុលដែលបានទទួលការសង មានករណីយកិច្ចមួយចំនួន ដើម្បីធានានូវសិទ្ធិឧបាទេសកម្មរបស់អ្នកដែលបានសង ។

(២) ចំពោះម្ចាស់បំណុលដែលបានទទួលការសងទាំងអស់ហើយ ចាំបាច់តម្រូវឱ្យមានករណីយកិច្ចប្រគល់នូវលិខិត

បញ្ជាក់សិទ្ធិលើបំណុលដែលម្ចាស់បំណុលលែងមានភាពចាំបាច់ ប៉ុន្តែ ដែលចាំបាច់សម្រាប់អ្នកសងដើម្បីធ្វើឧបាទេសកម្ម និង ប្រគល់វត្ថុប្រាតិភោគដែលខ្លួនកាន់កាប់ ទៅឱ្យឧបាទេសិក ។

(៣) ម្ចាស់បំណុលដែលបានទទួលការសងមួយភាគវិញ ត្រូវមានករណីយកិច្ចធ្វើកំណត់បន្ថែមអំពីឧបាទេសកម្មនេះ នៅលើលិខិតបញ្ជាក់សិទ្ធិលើបំណុល ព្រមទាំងឱ្យត្រួតពិនិត្យនូវស្ថានភាពគ្រប់គ្រងវត្ថុប្រាតិភោគនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៦៣.- ករណីយកិច្ចរក្សាប្រាតិភោគសម្រាប់ឧបាទេសិក

ក្នុងករណីមានបុគ្គលដែលអាចធ្វើឧបាទេសកម្មតាមបញ្ញត្តិនៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) នៃក្រមនេះ ប្រសិនបើម្ចាស់បំណុលបានធ្វើឱ្យ បាត់បង់ ឬ បន្ថយនូវប្រាតិភោគ ដោយចេតនា ឬ ដោយមានកំហុស បុគ្គលដែលអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មនោះ អាចរួចផុតពីការទទួលខុសត្រូវ ឬ ទាមទារសំណងនៃការខូចខាតបាន ក្នុងកម្រិតដែលខ្លួនមិនអាចទទួលសំណង ដោយសារការបាត់បង់ ឬ ការបន្ថយនោះ ។

(កំណត់)

(១) ការរំពឹងរបស់អ្នកសងថា នឹងអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្ម មានភាពសមរម្យ ហើយចាំបាច់ត្រូវមានការការពារតាមផ្លូវច្បាប់ផងដែរ ។ រីឯម្ចាស់បំណុលដែលទទួលការសងវិញ ក្នុងករណីដែលមានជនដែលអាចនឹងស្នងខ្លួនដោយឧបាទេសកម្ម ត្រូវមានករណីយកិច្ចរក្សាប្រាតិភោគនោះ ដើម្បីការពារផលប្រយោជន៍ក្នុងការធ្វើឧបាទេសកម្មរបស់អ្នកនោះ ។ មាត្រានេះចែងអំពីករណីយកិច្ចរក្សាប្រាតិភោគនេះ ។

(២) ចំពោះបញ្ហាដែលថា តើអ្នកដែលអាចធ្វើឧបាទេសកម្ម គឺជាបុគ្គលយ៉ាងណាដែរនោះ បើយោងតាមឧទាហរណ៍នៃការតាក់តែងច្បាប់ប្រទេសនានា គឺជា "អ្នកដែលមានផលប្រយោជន៍ត្រឹមត្រូវ" ក្នុងការសង ។ ក៏ប៉ុន្តែ ដូចដែលបានពន្យល់នៅក្នុងកំណត់នៃមាត្រា ៤៥៩ "ផលប្រយោជន៍ត្រឹមត្រូវ" ត្រូវបានបកស្រាយទូលាយ ហើយន័យទូលាយត្រឹមណាក៏មិនច្បាស់លាស់ដែរ ។ ដូច្នេះហើយ ក្នុងមាត្រានេះ ពុំមានការយកគោលគំនិតដាក់ករណីយកិច្ចឱ្យម្ចាស់បំណុលរក្សាប្រាតិភោគ ដោយសារទំនាក់ទំនងនឹងជនដែលមាន "ផលប្រយោជន៍ត្រឹមត្រូវ" ទេ តែបានដាក់ករណីយកិច្ចឱ្យម្ចាស់បំណុលរក្សាប្រាតិភោគ ដោយសារទំនាក់ទំនងនឹងឧបាទេសិកឱ្យបានទូលាយទៅវិញ ។ ម្យ៉ាងទៀត ចំពោះជនដែលបានទទួលបន្ទុកនូវកាតព្វកិច្ច ឬ ការទទួលខុសត្រូវដែលទាក់ទងនឹងកាតព្វកិច្ចដែលត្រូវបានសង មានទំនាក់ទំនងនឹងផលប្រយោជន៍ច្រើនក្នុងការសងនេះ ហើយមានការរំពឹងយ៉ាងខ្លាំងទៅលើឧបាទេសកម្មនេះ ។ ហេតុនេះហើយ ចាំបាច់ត្រូវដាក់ករណីយកិច្ចធ្ងន់ក្នុងការរក្សាប្រាតិភោគរបស់ម្ចាស់បំណុល ក្នុងទំនាក់ទំនងនឹងអ្នកទាំងនោះ រីឯចំពោះបុគ្គលក្រៅពីនេះវិញ គេមិនសូវរំពឹង

ទៅលើឧបាទេសកម្មនេះទេ បើប្រៀបធៀបនឹងអ្នកខាងលើនេះ ដូច្នេះហើយ ម្ចាស់បំណុលក៏ពុំមានករណីយកិច្ចធ្ងន់ធ្ងរចំពោះអ្នកទាំងនោះដែរ បើប្រៀបធៀបនឹងអ្នកខាងលើនេះ ។ ចំណុចនេះ នឹងត្រូវបានគិតពិចារណា ក្នុងការវិនិច្ឆ័យអំពីចេតនា ឬ កំហុសរបស់ម្ចាស់បំណុល ទៅតាមស្ថានភាពជាក់ស្តែង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២០៣៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៧៧៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ៥០៣ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស

## ផ្នែកទី ២ ការទូទាត់

**មាត្រា ៤៦៤.-** ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និង កិច្ចសន្យាទូទាត់

១-ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី ។

២-គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ ។ ប៉ុន្តែគូភាគីមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីអត្ថន័យ និង ល័ក្ខខ័ណ្ឌតម្រូវនៃការទូទាត់ ។

កថាខណ្ឌទី ១ ចែងអំពីអត្ថន័យ និង ល័ក្ខខ័ណ្ឌតម្រូវនៃការទូទាត់ដែលច្បាប់បានកំណត់ ។ ការទូទាត់ដែលច្បាប់បានកំណត់ គឺជាការទូទាត់ដែលត្រូវបានធ្វើឡើងដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រានេះ ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនៃកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ទោះបីជាគ្មានការព្រមព្រៀងគ្នាអំពីការទូទាត់រវាងភាគីទាំងពីរក៏ដោយ ។ ការទូទាត់អាចធ្វើបាន ដោយការបង្ហាញឆន្ទៈឯកតោភាគីអំពី "ការទូទាត់" របស់ភាគីម្ខាង ។ ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌតម្រូវចំនួនពីរ ដើម្បីឱ្យការទូទាត់មានអានុភាព ដោយការបង្ហាញឆន្ទៈអំពីការទូទាត់ ។

ល័ក្ខខ័ណ្ឌទី ១ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងពីរនេះ គឺជាការដែលភាគីទាំងពីរ ទទួលបន្ទុកនូវ "កាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក" ។ ហេតុដូច្នេះ ការទូទាត់អាចធ្វើបាន ក្នុងករណីដែលកាតព្វកិច្ចចំពោះ

គ្នាទៅវិញទៅមក គឺជាកាតព្វកិច្ចជាប្រាក់ ឬ កាតព្វកិច្ចដែលមានកម្មវត្ថុជាវត្ថុជំនួសប្រភេទដូចគ្នា (ឧទាហរណ៍ អង្ករ) ។ ក្នុងករណីដែលកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក គឺជាកាតព្វកិច្ចជាប្រាក់ ប្រសិនបើកាតព្វកិច្ចមួយមានចំនួនទឹកប្រាក់ជារូបិយប័ណ្ណជាតិ (រូបិយប័ណ្ណរបស់ប្រទេសកម្ពុជា) ហើយកាតព្វកិច្ចមួយទៀតមានចំនួនទឹកប្រាក់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក មានបញ្ហាថា តើកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកជាកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នា ឬ មិនមែន។ គ្មានបញ្ហាទាក់ទងនឹងការទូទាត់តាមការព្រមព្រៀងទេ ប្រសិនបើភាគីទាំងពីរព្រមព្រៀងគ្នា ប៉ុន្តែ ប្រសិនបើគ្មានការព្រមព្រៀងគ្នាទេ តើអាចធ្វើការទូទាត់ដែលច្បាប់បានកំណត់បាន ឬ ទេ ? ចំពោះកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយប័ណ្ណកម្ពុជាបាន (មាត្រា ៣១៧) ដូច្នេះ កូនបំណុលដែលមានកាតព្វកិច្ចជារូបិយវត្ថុបរទេស អាចធ្វើការទូទាត់បាន ដោយជ្រើសរើសសងជារូបិយប័ណ្ណកម្ពុជា ។

ល័ក្ខខ័ណ្ឌទី ២ គឺជាការដល់ពេលកំណត់សងនូវសិទ្ធិលើបំណុលដែលភាគីម្ខាងដែលបង្ហាញឆន្ទៈអំពីការទូទាត់ មានចំពោះភាគីម្ខាងទៀត (សិទ្ធិលើបំណុលរបស់ភាគីដែលធ្វើការទូទាត់ ត្រូវហៅថា "សិទ្ធិលើបំណុលដែលផ្ដើមការទូទាត់") ។ មូលហេតុនេះ គឺដូចរៀបរាប់ខាងក្រោមនេះ ។ ការទូទាត់រំលត់សិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមករបស់ភាគីទាំងពីរ ហេតុដូច្នេះ ចំពោះសិទ្ធិលើបំណុលរបស់ភាគីដែលធ្វើការទូទាត់ មានអានុភាពដូចគ្នានឹងអានុភាពដែលសិទ្ធិលើបំណុលត្រូវបានសង ។ អាស្រ័យហេតុនេះ សិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈអំពីការទូទាត់ ត្រូវដល់ពេលកំណត់សង ហើយត្រូវបំពេញល័ក្ខខ័ណ្ឌក្នុងការទទួលការសង (ពេលកំណត់សងមកដល់) ។ ចំពោះសិទ្ធិលើបំណុលដែលភាគីម្ខាងទៀតមានចំពោះភាគីដែលធ្វើការទូទាត់ (សិទ្ធិលើបំណុលដែលទទួលការទូទាត់) ជាគោលការណ៍ ពេលកំណត់សងត្រូវមកដល់ផងដែរ ប៉ុន្តែ ដោយសារសិទ្ធិលើបំណុលដែលទទួលការទូទាត់នេះ គឺជាកាតព្វកិច្ចដែលភាគីដែលធ្វើការទូទាត់ មានចំពោះភាគីម្ខាងទៀត ភាគីដែលធ្វើការទូទាត់អាចបោះបង់ចោលនូវប្រយោជន៍នៃការកំណត់ពេលចំពោះសិទ្ធិលើបំណុលដែលទទួលការទូទាត់បាន ។ ប្រសិនបើភាគីដែលធ្វើការទូទាត់បោះបង់ប្រយោជន៍នៃការកំណត់ពេល សិទ្ធិលើបំណុលដែលទទួលការទូទាត់ នឹងដល់ពេលកំណត់សង ហេតុដូច្នេះ ល័ក្ខខ័ណ្ឌតម្រូវដែលអនុញ្ញាតឱ្យមានការទូទាត់ត្រូវបានបំពេញ ។ ស្ថានភាពដែលល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការទូទាត់ត្រូវបានបំពេញ ហៅថា "ស្ថានភាពសមស្របនឹងការទូទាត់" ។

កថាខណ្ឌទី ២ បញ្ញត្តអំពីកិច្ចសន្យាទូទាត់ ។ កិច្ចសន្យាទូទាត់ គឺជាកិច្ចសន្យាដែលរំលត់កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក តាមការព្រមព្រៀងរវាងគូភាគី ។ ជារឿងធម្មតាដែលសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកដែលស្ថិតក្នុងស្ថានភាពសមស្របនឹងការទូទាត់ អាចរំលត់ដោយកិច្ចសន្យាទូទាត់ ។ ចំណុចនេះ មិនត្រូវលើកយកមកបញ្ចេក់ក្នុងមាត្រានេះ ដោយចេតនាទេ ។ លើសពីនេះទៀត តាមកិច្ចសន្យាទូទាត់ ការទូទាត់អាចធ្វើបាន ទោះបីជាល័ក្ខខ័ណ្ឌតម្រូវនៃការទូទាត់ដែលច្បាប់បានកំណត់ មិនត្រូវបានបំពេញក៏ដោយ ។ ទោះបីជាវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចខុសគ្នា ដូចជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ និង សិទ្ធិលើបំណុលដែលទាមទារឱ្យការប្រគល់អង្ករ ជាអាទិ៍ ក៏ដោយ ក៏ការទូទាត់អាចធ្វើបាន តាមកិច្ចសន្យាទូទាត់បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៦៥.–** វិធីទូទាត់

១-ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត ។

២-ការបង្ហាញឆន្ទៈទូទាត់ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន តែមិនអាចដាក់ល័ក្ខខ័ណ្ឌរំលាយ ឬ កំណត់ពេលបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីវិធីទូទាត់ ។

ជាឧទាហរណ៍នៃក្រមរដ្ឋប្បវេណីបារាំង ប្រសិនបើសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក ស្ថិតនៅក្នុងស្ថានភាពសមស្របនឹងការទូទាត់ ការទូទាត់ត្រូវមានអានុភាពដោយស្វ័យប្រវត្តិ ទោះបីជាគ្មានការបង្ហាញឆន្ទៈអំពីការទូទាត់ដោយភាគីក៏ដោយ ។ ប៉ុន្តែ មាត្រានេះបញ្ញត្តថា ការទូទាត់មិនត្រូវមានអានុភាពនោះទេ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដោយភាគី ដោយយោងតាមឧទាហរណ៍នីតិកម្មភាគច្រើនក្នុងចំណោមច្បាប់បណ្តាប្រទេសនានា ។ នេះដោយសារបញ្ញត្តិនេះនឹងបញ្ជាក់ឱ្យច្បាស់ថា តើអានុភាពនៃការទូទាត់កើតមាន ឬ មិនកើតមាន ។ ការបង្ហាញឆន្ទៈអំពីការទូទាត់ដោយភាគីចាំបាច់ត្រូវដល់ភាគីម្ខាងទៀត យោងតាមគោលការណ៍ទូទៅស្តីពីការបង្ហាញឆន្ទៈ (មាត្រា ៣១០) ។ ប៉ុន្តែ ដោយយោងតាមមាត្រា ៤៦៦ ខាងក្រោមនេះ ការទូទាត់មានអានុភាពប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។

កថាខណ្ឌទី ២ បញ្ញត្តថា ការបង្ហាញឆន្ទៈទូទាត់មិនអាចដាក់ល័ក្ខខ័ណ្ឌរំលាយបានទេ ។ ប្រសិនបើអនុញ្ញាតឱ្យមានល័ក្ខខ័ណ្ឌរំលាយ ករណីដូចខាងក្រោមអាចកើតមានឡើង ដូច្នេះ មិនមានភាពសមរម្យទេ ។ ឧទាហរណ៍ (ករណីទី ១) សិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមករវាង A និង B ស្ថិតនៅក្នុងស្ថានភាពសមស្របនឹងការទូទាត់ ។ ប៉ុន្តែ តាមការពិត A ចង់ធ្វើអនុប្បទាននូវសិទ្ធិលើបំណុលចំពោះ B ទៅតតិយជន C ហើយមិនចង់ទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ B បើអាចសងកាតព្វកិច្ចចំពោះ B បាន ។ ក្នុងករណីនេះ ប្រសិនបើ A ដែលទទួលការទាមទារឱ្យសងចំពោះសិទ្ធិលើបំណុលតបដោយ B និយាយថា "ខ្ញុំនឹងធ្វើការទូទាត់សិទ្ធិលើបំណុលនោះជាមួយនឹងសិទ្ធិលើបំណុលដែលខ្ញុំមានចំពោះ B ។ ប៉ុន្តែ ប្រសិនបើខ្ញុំទទួលឥណទានពី C ក្នុងរយៈពេលមួយខែ ខ្ញុំនឹងមិនធ្វើការទូទាត់ទេ" នេះគឺជាការបង្ហាញឆន្ទៈទូទាត់ដោយដាក់ល័ក្ខខ័ណ្ឌរំលាយ ។ ក្នុងករណីនេះ អានុភាពនៃការទូទាត់នឹងកើតឡើងដោយការបង្ហាញឆន្ទៈ ប៉ុន្តែ ប្រសិនបើល័ក្ខខ័ណ្ឌរំលាយដែលថា "A ទទួលឥណទានពី C" ត្រូវបានបំពេញ អានុភាពនៃការទូទាត់នឹងត្រូវបដិសេធ ។ ល័ក្ខខ័ណ្ឌរំលាយដូច្នេះដែលត្រូវបដិសេធនូវការទូទាត់ដែលបានបង្កើតអានុភាពម្តងរួចហើយ មិនគួរអនុញ្ញាតទេ ដោយសារការដាក់

ល័ក្ខខ័ណ្ឌដូច្នេះ នឹងធ្វើឱ្យ B ដែលជាភាគីម្ខាងទៀតនៃការទូទាត់ ស្ថិតក្នុងស្ថានភាពមិនស្ថិតស្ថេរ ។ ផ្ទុយទៅវិញ ការទូទាត់ដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ គឺស្រដៀងនឹងការសន្យាជាមុននូវការទូទាត់ ហើយមិនមែនជានិច្ចកាល សុទ្ធតែមិនសមហេតុផលនោះទេ ។ ឧទាហរណ៍ (ករណីទី ២) ក្នុងករណីដែលមានសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមករវាង A និង B ភាគី A អាចបង្ហាញឆន្ទៈទូទាត់ ដោយមានល័ក្ខខ័ណ្ឌបង្អង់ថា "ខ្ញុំនឹងទូទាត់ជាមួយសិទ្ធិលើបំណុលរបស់ B ប្រសិនបើ B ទទួលចំណាត់ការឱ្យបញ្ចប់ប្រតិបត្តិការពីធនាគារ" ។ ប៉ុន្តែ ប្រសិនបើខ្លឹមសារនៃល័ក្ខខ័ណ្ឌបង្អង់មិនច្បាស់លាស់ នោះនឹងមានភាពមិនច្បាស់លាស់ថា តើអានុភាពនៃការទូទាត់កើតឡើង ឬ មិនកើតឡើង ។ ហេតុដូច្នេះ ដោយសារល័ក្ខខ័ណ្ឌបែបនេះធ្វើឱ្យភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពមិនស្ថិតស្ថេរដោយមិនត្រឹមត្រូវ ការបង្ហាញឆន្ទៈនេះគួរត្រូវបានចាត់ទុកជាមោឃៈ ដោយសារវាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ មូលហេតុដែលកំណត់ពេល មិនអាចអនុញ្ញាតបាន គឺដោយសារថា ទោះបីជាមានកំណត់ពេលក៏ដោយ ក៏ការទូទាត់មានអានុភាពប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របនឹងការទូទាត់ដែរ ដូច្នេះ គ្មានន័យអ្វីនឹងធ្វើដូច្នោះទេ ។

ការបង្ហាញឆន្ទៈទូទាត់ ដោយមានល័ក្ខខ័ណ្ឌបង្អង់ និង ការសន្យាជាមុននូវការទូទាត់មានលក្ខណៈស្រដៀងគ្នា ប៉ុន្តែចាំបាច់ត្រូវស្វែងយល់ពីលក្ខណៈដែលខុសប្លែកគ្នា ។ ការសន្យាជាមុននូវការទូទាត់មានន័យថាជាការសន្យាជាមុននូវការទូទាត់សម្រាប់ពេលអនាគត តាមកិច្ចព្រមព្រៀងរវាងភាគីទាំងពីរអំពីល័ក្ខខ័ណ្ឌនៃការទូទាត់នោះ ហើយអាចចាត់ទុកបានថា មានសុពលភាព ដោយសារភាគីទាំងពីរបានព្រមព្រៀងគ្នា ។ ឧទាហរណ៍ វិធីមួយសម្រាប់ការប្រមូលបំណុលមុនពេលដែលស្ថានភាពហិរញ្ញវត្ថុរបស់ភាគីម្ខាងទៀត កាន់តែធ្លាក់ដុនដាប មានដូចជាកិច្ចព្រមព្រៀងរវាងភាគីដែលមានខ្លឹមសារថា ការទូទាត់នឹងមានអានុភាព ក្នុងករណីដែលហេតុណាជាកំណត់ដែលបង្ហាញថា ភាគីម្ខាងទៀតទំនងនឹងមានស្ថានភាពហិរញ្ញវត្ថុកាន់តែធ្លាក់ដុនដាប បានកើតឡើង ។ ចំណែកឯការបង្ហាញឆន្ទៈទូទាត់ដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ អាចធ្វើដោយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ។ ប៉ុន្តែ វាមានតួនាទីដូចគ្នានឹងការសន្យាជាមុននូវការទូទាត់ ដូច្នេះ មាត្រានេះបញ្ញត្តថា ការទូទាត់ដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មានសុពលភាព ។

## មាត្រា ៤៦៦.- ពេលដែលបង្កើតអានុភាពនៃការទូទាត់

ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការទូទាត់ត្រូវបានបំពេញ ហើយនៅពេលឆន្ទៈទូទាត់ត្រូវបានបង្ហាញ អានុភាពដែលរំលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយមានប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។

(កំណត់)

មាត្រានេះចែងអំពីពេលដែលបង្កើតអានុភាពនៃការទូទាត់ ។

ប្រសិនបើឆន្ទៈទូទាត់ត្រូវបានបង្ហាញ ការទូទាត់មានអានុភាព ហើយសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកត្រូវ

រលត់ ត្រឹមកម្រិតដែលចំនួននីមួយៗមានតម្លៃស្មើគ្នា ប៉ុន្តែ ការរលត់សិទ្ធិលើបំណុលនោះត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលដែលសិទ្ធិលើបំណុលទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។ ឧទាហរណ៍ សិទ្ធិលើបំណុលរបស់ A ចំពោះ B ត្រូវដល់ពេលកំណត់សងនៅថ្ងៃទី ១ ខែ មីនា ហើយសិទ្ធិលើបំណុលរបស់ B ចំពោះ A ត្រូវដល់ពេលកំណត់សងនៅថ្ងៃទី ១ ខែ មេសា ។ ប្រសិនបើ A បង្ហាញឆន្ទៈទូទាត់នៅថ្ងៃទី ១ ខែ ឧសភា អានុភាពនៃការទូទាត់កើតឡើងនៅថ្ងៃទី ១ ខែ មេសា (ពេលមានស្ថានភាពសមរម្យនឹងការទូទាត់) ។ ដោយមូលហេតុនេះ ក្នុងករណីដែល B ធ្វើអនុប្បទាននូវសិទ្ធិលើបំណុលរបស់ខ្លួនឱ្យ C នៅថ្ងៃទី ១៥ ខែ មេសា សិទ្ធិលើបំណុលត្រូវរលត់នៅថ្ងៃទី ១៥ ខែ មេសា នោះ ហើយក្លាយជាលែងមានអត្ថិភាព តាមរយៈអានុភាពប្រតិសកម្មនៃការទូទាត់ ។ ក្នុងករណីនេះ C ដែលទទួលអនុប្បទាននូវសិទ្ធិលើបំណុល ទទួលការខូចខាតផលប្រយោជន៍ ប៉ុន្តែ ផ្ទុយទៅវិញ A ទទួលផលប្រយោជន៍នៃការទូទាត់ មានន័យថា A អាចប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនចំពោះ B ដោយមានសុវត្ថិភាពបាន ។ សិទ្ធិលើការរំពឹងទុកនូវការទូទាត់ត្រូវបានការពារ ចំពោះភាគីដែលមានសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក ។

ម្យ៉ាងវិញទៀត ក្នុងករណីដូចបានរៀបរាប់ខាងលើ សិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក ត្រូវរលត់នៅថ្ងៃទី ១ ខែ មេសា ដោយសារអានុភាពប្រតិសកម្មនៃការទូទាត់ ហេតុដូច្នេះ ការប្រាក់មិនត្រូវកើតឡើងចំពោះសិទ្ធិលើបំណុលដែលបានរលត់ ចាប់ពីថ្ងៃទី ១ ខែ មេសាទេ ។ ឧទាហរណ៍ ក្នុងករណីដែលអត្រាការប្រាក់នៃសិទ្ធិលើបំណុលរបស់ A ចំពោះ B គឺ ៧ ភាគរយក្នុងមួយឆ្នាំ ហើយអត្រាការប្រាក់នៃសិទ្ធិលើបំណុលរបស់ B ចំពោះ A គឺ ១០ ភាគរយក្នុងមួយឆ្នាំ ប្រសិនបើគ្មានការទូទាត់ទេ B នឹងទទួលផលចំណេញពីភាពខុសគ្នាចំនួន ៣ ភាគរយនៃអត្រាការប្រាក់ ចាប់ពីថ្ងៃទី ១ ខែ មេសា ប៉ុន្តែ ប្រសិនបើមានការទូទាត់ ផលចំណេញពីការខុសគ្នានៃអត្រាការប្រាក់នេះ មិនអាចអនុញ្ញាតទេ ចាប់ពីថ្ងៃទី ១ ខែ មេសា តទៅ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៥០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៦៧.– ការកម្រិតចំពោះការទូទាត់

១-ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬ ទាំងពីរ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ ។

២-ក្នុងករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលនីមួយៗមិនអាចទូទាត់បានទេ ។ ប៉ុន្តែ ការសន្យាពិសេសមិនធ្វើការទូទាត់នេះ មិនអាចអះអាងចំពោះតតិយជនសុចរិតបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលមិនសមនឹងអនុញ្ញាតឱ្យធ្វើការទូទាត់ ដោយសារសិទ្ធិលើបំណុលណាមួយ ឬ ទាំងពីរ ក្នុងចំណោមសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក គឺជាសិទ្ធិលើបំណុលពិសេសដែលភាគីចាំបាច់ត្រូវទទួលការបង់ប្រាក់ ។

ឧទាហរណ៍ សិទ្ធិលើបំណុលចំពោះប្រាក់ឈ្នួល ជាអាទិ៍ គឺជាសិទ្ធិលើបំណុលដែលកម្មករនិយោជិតត្រូវការសម្រាប់ជីវភាពរស់នៅ ហើយនិយោជកចាំបាច់ត្រូវបង់ជូនកម្មករនិយោជិត ។ ដូច្នេះ ក្នុងករណីដែលនិយោជកមានសិទ្ធិលើបំណុលចំពោះកម្ចីដល់កម្មករនិយោជិត មិនត្រឹមត្រូវទេក្នុងការរំលត់សិទ្ធិលើបំណុលចំពោះប្រាក់ឈ្នួល ដោយអនុញ្ញាតឱ្យនិយោជកធ្វើការទូទាត់ ។ អាចជាគំនិតល្អក្នុងការអនុញ្ញាតឱ្យកម្មករនិយោជិតបង្កើតអានុភាពនៃការទូទាត់ ។

បញ្ញត្តិនៃច្បាប់ដទៃទៀតនឹងកំណត់អំពីការការពារការបង់នូវសិទ្ធិលើបំណុលជាដើម ។ ឧទាហរណ៍ ដើម្បីហាមឃាត់នូវការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលចំពោះប្រាក់ឈ្នួលការងារ ច្បាប់ស្តីពីការងារគួរចែងពីបញ្ញត្តិដោយឡែក ។ បើទោះជាគ្មានច្បាប់ពិសេសក៏ដោយ ប្រសិនបើចាំបាច់ត្រូវការពារការបង់ថ្លៃ ពាក់ព័ន្ធនឹងការទូទាត់ អាស្រ័យតាមការបកស្រាយ ការទូទាត់បែបនេះមិនគួរត្រូវបានអនុញ្ញាតនោះទេ ។

(មាត្រាពាក់ព័ន្ធ)

វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន និង កថាខណ្ឌទី ២ មាត្រា ២០០ នៃក្រមពាណិជ្ជកម្មជប៉ុន ជាអាទិ៍

**មាត្រា ៤៦៨.-** ការទូទាត់ដោយយកសិទ្ធិលើបំណុលដែលភ្ជាប់នឹងសិទ្ធិតវ៉ា

១-បើសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ភ្ជាប់នឹងសិទ្ធិតវ៉ារបស់ភាគីម្ខាងទៀត ភាគីនោះមិនអាចទូទាត់បានទេ ។

២-ប្រសិនបើសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាល ឬ ផុតអំឡុងពេលដើម្បីអនុវត្តសិទ្ធិ ធ្លាប់នៅសមស្របទៅនឹងការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀត នៅមុនពេលផុតអាជ្ញាយុកាល ឬ អំឡុងពេលនោះ ម្ចាស់បំណុលនោះ អាចទូទាត់បាន ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលភាគីមួយទៀតមានសិទ្ធិតវ៉ានឹងសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ។ ទោះបីជាមានសិទ្ធិលើបំណុលប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមករវាង A និង B ហើយល័ក្ខខ័ណ្ឌតម្រូវផ្សេងទៀតសម្រាប់ការទូទាត់ត្រូវបានបំពេញក៏ដោយ ប្រសិនបើភាគីម្ខាងទៀតមានសិទ្ធិតវ៉ា ក៏ភាគីម្ខាងទៀតនេះអាចបដិសេធមិនសងចំពោះសិទ្ធិលើបំណុលនេះដែរ ដូច្នេះ ការទូទាត់មិនអាចអនុញ្ញាតបានទេ ។

ឧទាហរណ៍ ក្នុងករណីដែល B អាចអះអាងសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ចំពោះការទាមទារឱ្យអនុវត្តពី A នោះ A មិនអាចទូទាត់បានទេ ។ ឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ទាំងនេះ គឺករណីដែល A មិនអាចយកសិទ្ធិលើបំណុលចំពោះ

ផ្ទេរលក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញរវាង A និង B មកធ្វើជាសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ ដើម្បីទូទាត់ជាមួយនឹងកាតព្វកិច្ចដែល A មានចំពោះ B បានឡើយ ប្រសិនបើ A មិនទាន់ប្រគល់ឱ្យទៅ B នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ។ ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ A ផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ហើយ B អាចលើកឡើងនូវអាជ្ញាយុកាលនោះបាន ក៏ A មិនអាចទូទាត់បានឡើយ ។

ប៉ុន្តែ ក្នុងករណីដែលសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ ស្ថិតនៅក្នុងស្ថានភាពសមស្របនឹងការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលតប មុនពេលសិទ្ធិលើបំណុលដែលផ្តើមការទូទាត់នោះ ផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះមានសមធមិដែរដែលទទួលស្គាល់ការទូទាត់ (មាត្រា ៥០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន) ។ កថាខណ្ឌទី ២ ចែងអំពីករណីដែលការទូទាត់អាចធ្វើបានជាករណីលើកលែង ដូចក្នុងករណីនេះ ។ ប៉ុន្តែ ការទូទាត់បែបនេះ តម្រូវឱ្យមានស្ថានភាពសមស្របនឹងការទូទាត់នៃសិទ្ធិលើបំណុលដែលផុតអំឡុងពេលនៃអាជ្ញាយុកាល ជាមួយនឹងសិទ្ធិលើបំណុលតប មុនពេលដែលសិទ្ធិលើបំណុលនោះផុតអំឡុងពេលនៃអាជ្ញាយុកាល ហេតុដូច្នេះ យោងតាមគោលការណ៍វិញ ការទូទាត់មិនអាចធ្វើបានទេ ក្នុងករណីដែលសិទ្ធិលើបំណុលតបកើតឡើង ក្រោយពេលសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ ផុតអំឡុងពេលនៃអាជ្ញាយុកាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។ ពុំមានមាត្រាស្តីពីចំណុចនេះទេក្នុងក្រមរដ្ឋប្បវេណីជប៉ុន ប៉ុន្តែ មាត្រា ៥០៨ គឺជាមាត្រាដែលពាក់ព័ន្ធ ។

## មាត្រា ៤៦៩.- ការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលកើតឡើងដោយអំពើអនីត្យានុកូល

កូនបំណុលដែលទទួលបន្ទុកនូវកាតព្វកិច្ចដែលកើតឡើងដោយអំពើអនីត្យានុកូលចំពោះភាគីម្ខាងទៀត កូនបំណុលនោះ មិនអាចអះអាងនូវការរលត់កាតព្វកិច្ចនេះដោយការទូទាត់ឡើយ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលកម្រិតការទូទាត់ដោយចារីនៃអំពើអនីត្យានុកូល ។

ក្នុងករណីដែល A មានសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីដែល B ជំពាក់ ហើយ B មានសិទ្ធិលើបំណុលចំពោះសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូលរបស់ A នោះ A មិនអាចអះអាងអំពីការរលត់កាតព្វកិច្ចចំពោះសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូលនោះ តាមការអះអាងអំពីការទូទាត់បានឡើយ ។

មូលហេតុដែលមាត្រានេះមិនអនុញ្ញាតឱ្យធ្វើការទូទាត់បែបនេះ មានរៀបរាប់ដូចខាងក្រោម ។ ទីមួយ ប្រសិនបើ

អនុញ្ញាតឱ្យមានការទូទាត់ប្រភេទនេះ អាចនឹងមានការប្រថុយប្រថានថា A ដែលមានសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីដែល B ជំពាក់ អាចព្យាយាមទាមទារឱ្យប្រមូលកាតព្វកិច្ចដោយកំរោលដែលអាចចាត់ទុកថាជាអំពើអនីត្យានុកូល ដោយគិតថា អាចទូទាត់នៅពេលក្រោយ ។ ការមិនអនុញ្ញាតឱ្យធ្វើការទូទាត់បែបនេះ គឺដើម្បីទប់ស្កាត់មិនឱ្យមានការប្រព្រឹត្តអំពើអនីត្យានុកូល ។ ទីពីរ ជនរងគ្រោះដោយសារអំពើអនីត្យានុកូល (B) ចាំបាច់ត្រូវទទួលបាននូវការបង់ជាក់ស្តែងនូវប្រាក់សំណងការខូចខាត ដើម្បីយកប្រាក់នោះធ្វើជាថ្លៃព្យាបាល ជាអាទិ៍ ហេតុដូច្នេះ មានភាពមិនត្រឹមត្រូវទេក្នុងការរំលត់សិទ្ធិលើបំណុលរបស់ B ចំពោះសំណងការខូចខាត ដោយការទូទាត់ពី A ។

ម្យ៉ាងវិញទៀត ទោះបីជា A មានកាតព្វកិច្ចសងសំណងការខូចខាតចំពោះ B ក៏ដោយ ប្រសិនបើកាតព្វកិច្ចដែល B មានចំពោះ A ក៏ជាកាតព្វកិច្ចសងសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល នោះក៏អាចគិតថា ភាគីទាំងពីរអាចទូទាត់បានដែរ ។ ករណីនេះកើតឡើង នៅពេលដែលភាគីទាំងពីរមានសិទ្ធិលើបំណុលចំពោះសំណងការខូចខាតដោយសារឡានរបស់ពួកគេទាំងពីរប៉ះទង្គិចគ្នា ។ ប៉ុន្តែ នេះគួរទុកឱ្យតុលាការធ្វើការវិនិច្ឆ័យនាពេលអនាគតថា តើគួរតែទទួលស្គាល់ការទូទាត់ ឬ មិនគួរ ដោយសារអាចមានលទ្ធភាពផ្សេងគ្នាជាច្រើន អាស្រ័យទៅតាមស្ថានការណ៍ ដូចជាករណីដែលការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតរបស់ភាគីទាំងពីរមានធានារ៉ាប់រង ឬ គ្មាន ឬ ករណីដែលអំពើអនីត្យានុកូលរបស់ភាគីទាំងពីរមានលក្ខណៈដូចគ្នា ឬ ខុសគ្នា ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥០៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៥៧០.- សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានហាមឃាត់មិនឱ្យរឹបអូស កូនបំណុលមិនអាចអះអាងនូវការរលត់សិទ្ធិលើបំណុលនោះដោយការទូទាត់ឡើយ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដើម្បីហាមឃាត់មិនឱ្យរំលត់ដោយការទូទាត់ នូវសិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស ។

សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស សំដៅលើសិទ្ធិលើបំណុលដែលមានភាពចាំបាច់ និង សារៈសំខាន់យ៉ាងចម្បងចំពោះម្ចាស់បំណុលសម្រាប់ជីវភាពរស់នៅ ហើយសិទ្ធិលើបំណុលបែបនេះ ត្រូវបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ។ ឧទាហរណ៍ សិទ្ធិលើបំណុលក្នុងការទទួលប្រាក់ឧបត្ថម្ភជីវភាព សិទ្ធិទាមទារអាហារកាតព្វកិច្ច និង សិទ្ធិលើបំណុលចំពោះប្រាក់បៀវត្សក្នុងវិសាលភាពមួយជាក់លាក់ គឺជាសិទ្ធិលើបំណុលដ៏សំខាន់ដែលមិនអាចខ្វះបានសម្រាប់ជីវិភាពរបស់ម្ចាស់បំណុល ។ សិទ្ធិលើបំណុលទាំងនេះ ត្រូវតែបង់ជាក់លាក់ដោយខានមិនបាន ហើយវាជារឿងមិនត្រឹមត្រូវទេក្នុងការរំលត់សិទ្ធិលើបំណុលនេះដោយការទូទាត់ ទោះបីជាកូនបំណុលនៃសិទ្ធិលើបំណុល

នោះ មានសិទ្ធិលើបំណុលតប ហើយសិទ្ធិលើបំណុលទាំងនេះ ស្ថិតក្នុងស្ថានភាពតបតចំពោះគ្នាទៅវិញទៅមកក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៧១.-** សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវតតិយជនរឹបអូស កូនបំណុលអាចទូទាត់កាតព្វកិច្ចរបស់ខ្លួន ដោយយកសិទ្ធិលើបំណុលចំពោះភាគីម្ខាងទៀតដែលខ្លួនបានទទួលមុនពេលតតិយជនរឹបអូស នៅពេលដែលសិទ្ធិលើបំណុលនោះដល់កំណត់សង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់កូនបំណុលដែលអះអាងនូវការទូទាត់ចំពោះភាគីម្ខាងទៀត ត្រូវដល់ក្រោយពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីធ្វើការសន្យាពិសេសថា អាចទូទាត់គ្នានូវកាតព្វកិច្ចរៀងៗខ្លួនបានដោយមិនគិតអំពីពេលកំណត់មុន ឬ ក្រោយ ។

(កំណត់)

មាត្រានេះចែងអំពីទំនាក់ទំនងរវាងការទូទាត់ និង ការរឹបអូស ។

ប្រសិនបើសិទ្ធិលើបំណុលដែល A មាន ចំពោះ B ត្រូវបានរឹបអូសដោយ C ម្ចាស់បំណុល A ទទួលការកម្រិតលើសិទ្ធិទាមទារឱ្យកូនបំណុល B សងកាតព្វកិច្ច ដោយសារអានុភាពនៃការរឹបអូសនោះ ។ ម្យ៉ាងវិញទៀត កូនបំណុល B ក៏មិនអាចសងកាតព្វកិច្ច ចំពោះម្ចាស់បំណុល A បានដែរ ។ បើធ្វើការវិនិច្ឆ័យពីអានុភាពនៃការរឹបអូស វាហាក់ដូចជាសេចក្តីសន្និដ្ឋានសមហេតុសមផលក្នុងការកំណត់ថា ទោះបីជា B មានសិទ្ធិលើបំណុលតបចំពោះ A ក៏ដោយ ក៏ B មិនអាចផ្តើមការទូទាត់បានឡើយ ។ ប៉ុន្តែ បើពិនិត្យមើលពីទស្សនៈរបស់កូនបំណុល B វិញនោះ B អាចរំពឹងថាខ្លួនឯងមានសិទ្ធិលើបំណុលចំពោះ A ហើយអាចយកសិទ្ធិលើបំណុលចំពោះ A នោះមកធ្វើការទូទាត់កាតព្វកិច្ចរបស់ខ្លួននាពេលអនាគត នៅពេលដែលពេលកំណត់សងមកដល់ ។ ការរំពឹងទុកឱ្យមានការទូទាត់បែបនេះគួរត្រូវបានការពារ ។ ជាពិសេស តាមកិច្ចការអនុវត្តជាក់ស្តែង មានករណីដែលធនាគារ (B) ផ្តល់ប្រាក់កម្ចីទៅឱ្យអតិថិជន (A) ប្រសិនបើ A មានប្រាក់បញ្ញើជាមួយ B ទោះបីជា A មិនមានប្រាតិភោគត្រឹមត្រូវក៏ដោយ ។ នេះដោយសារថា ការទូទាត់សិទ្ធិលើបំណុលចំពោះប្រាក់កម្ចីជាមួយនឹងប្រាក់បញ្ញើ អាចត្រូវចាត់ថាជាប្រាតិភោគលើសិទ្ធិលើបំណុលរបស់ B ចំពោះប្រាក់កម្ចី ។ ការនេះហៅថា "តួនាទីជាប្រាតិភោគនៃការទូទាត់" ដែលទទួលបានការការពារនៅប្រទេសជាច្រើន ។

តាមវិធីនេះ ទោះបីជាតតិយជន C រឹបអូសសិទ្ធិលើបំណុលនៃប្រាក់បញ្ញើរបស់អតិថិជន A ក៏ដោយ ក៏វាជាការត្រឹមត្រូវ ក្នុងការអនុញ្ញាតឱ្យធនាគារ B យកសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើនោះ មកធ្វើការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីដែរ ។ កថាខណ្ឌទី ១ បញ្ញត្តថា ការទូទាត់នេះទទួលការការពារ ដោយមានអាទិភាពជាងការរឹបអូស ។ ប៉ុន្តែ B អាចអះអាងអំពីការទូទាត់ តែនៅក្រោយពេលដែលមានស្ថានភាពសមស្របនឹងការទូទាត់ប៉ុណ្ណោះ ដូច្នេះ B អាចធ្វើការទូទាត់ នៅពេលដែលសិទ្ធិលើបំណុលរបស់ B ចំពោះប្រាក់កម្ចី ដល់ពេលកំណត់ត្រូវសង ។ កថាខណ្ឌទី ១ មិនបញ្ជាក់អំពីពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើទេ ប៉ុន្តែ ក្នុងករណីដែលធនាគារ B អះអាងនូវការទូទាត់នូវសិទ្ធិលើបំណុលចំពោះប្រាក់កម្ចី ជាមួយនឹងសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើ ទោះបីជាសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើមិនទាន់ដល់ពេលកំណត់សងក៏ដោយ ក៏កូនបំណុលនៃសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើ ពោលគឺ ធនាគារ B អាចត្រូវបានចាត់ទុកថា មានឆន្ទៈបោះបង់ប្រយោជន៍នៃការកំណត់ពេល ពាក់ព័ន្ធនឹងពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើ (ឆន្ទៈសងមុនពេលកំណត់) បានដែរ ហេតុដូច្នេះ មិនចាំបាច់ចោទសួរជាពិសេសអំពីពេលកំណត់សងនៃសិទ្ធិលើបំណុលតប (សិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើ) ឡើយ ។

ដើម្បីឱ្យការទូទាត់មានអាទិភាពជាងការរឹបអូស ចាំបាច់ពេលកំណត់សងនៃសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់ (សិទ្ធិលើបំណុលចំពោះប្រាក់កម្ចីរបស់ធនាគារក្នុងករណីខាងដើមនេះ) ត្រូវមកដល់ មុនពេលកំណត់សងនៃសិទ្ធិលើបំណុលតបរបស់ភាគីម្ខាងទៀត ។ ឧទាហរណ៍ ដូចជាករណីដែលពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីត្រូវមកដល់នៅថ្ងៃទី ១ ខែ មីនា ហើយពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើត្រូវមកដល់នៅថ្ងៃទី ១ ខែ មេសា ។ ផ្ទុយទៅវិញ ក្នុងករណីដែលពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់កម្ចីត្រូវមកដល់នៅថ្ងៃទី ១ ខែ មេសា ហើយពេលកំណត់សងនៃសិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើត្រូវមកដល់នៅថ្ងៃទី ១ ខែ មីនា នោះការទូទាត់ដោយធនាគារមិនអាចអនុញ្ញាតបានទេ ។ នេះដោយសារធនាគារ B អាចនាំឱ្យមានស្ថានភាពសមស្របនឹងការទូទាត់ ដោយបដិសេធមិនសងនូវសិទ្ធិលើបំណុល (សិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើ) ដែលពេលកំណត់សងត្រូវមកដល់នៅថ្ងៃទី ១ ខែ មីនា រហូតដល់ថ្ងៃទី ១ ខែ មេសា ប៉ុន្តែ វាមិនត្រឹមត្រូវទេ ក្នុងការការពារក្ដីរំពឹងនៃការទូទាត់ ក្នុងករណីដែលការទូទាត់ទើបនឹងអាចធ្វើបានដោយការធ្វើដូច្នោះ ។

ខាងលើនេះគឺជាគោលការណ៍នៃការទូទាត់ដែលច្បាប់បានកំណត់ ប៉ុន្តែ ប្រសិនបើភាគីនៃការទូទាត់បានព្រមព្រៀងគ្នាថា អាចធ្វើការទូទាត់បាន ដោយមិនគិតអំពីពេលកំណត់សងនូវសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកទេ សិទ្ធិក្នុងការរំពឹងលើការទូទាត់ដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង គួរត្រូវបានការពារ ។ កថាខណ្ឌទី ២ ចែងថា ក្នុងករណីដូច្នេះ ភាគីអាចអះអាងនូវការទូទាត់ចំពោះការរឹបអូសសិទ្ធិលើបំណុលដែលទទួលការទូទាត់ ទោះបីជាពេលកំណត់សងនៃសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់ មកដល់ក្រោយពេលកំណត់សងនៃសិទ្ធិលើបំណុលដែលទទួលការទូទាត់ក៏ដោយ ។ អាចចាត់ទុកថា ការសន្យាពិសេសដែលកូនបំណុលដែលជាភាគីម្ខាងទៀត បាត់បង់ប្រយោជន៍នៃការកំណត់ពេល ចំពោះសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់ ប្រសិនបើតតិយជនដាក់ពាក្យសុំឱ្យរឹបអូសនូវសិទ្ធិលើបំណុលដែលទទួលការទូទាត់ គឺជាកិច្ច

ព្រមព្រៀងប្រភេទនេះ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៥១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៧២.–** ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្តីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

( កំណត់)

មាត្រានេះចែងអំពីបទដ្ឋានសម្រាប់កម្មវត្ថុនៃការទូទាត់ ក្នុងករណីដែលមានសិទ្ធិលើបំណុលច្រើនចំពោះគ្នាទៅវិញទៅមក ។

ឧទាហរណ៍ ក្នុងករណីដែល A មានសិទ្ធិលើបំណុលមួយចំពោះប្រាក់កម្ចីដែល B ជំពាក់ ហើយ B មានសិទ្ធិលើបំណុលតប ចំនួនពីរ ចំពោះ A ទោះបីជា A បង្ហាញឆន្ទៈអំពីការទូទាត់ក៏ដោយ ក៏ពុំមានភាពច្បាស់លាស់ថា តើត្រូវទូទាត់សិទ្ធិលើបំណុលណាមួយក្នុងចំណោមសិទ្ធិលើបំណុលទាំងពីររបស់ B ជាមួយនឹងសិទ្ធិលើបំណុលរបស់ A នោះទេ ។ ក្នុងករណីដូច្នេះ A អាចជ្រើសរើសសិទ្ធិលើបំណុលតបដែលត្រូវរំលត់ដោយការទូទាត់ ។ នេះមានលក្ខណៈស្រដៀងគ្នានឹងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចច្រើន បង់ប្រាក់ឱ្យម្ចាស់បំណុលដើម្បីសងនូវកាតព្វកិច្ច ប៉ុន្តែ កូនបំណុលមិនបានបញ្ជាក់អំពីការសងចំពោះកាតព្វកិច្ចណាទេ ។ ក្នុងករណីនៃការទូទាត់ ការជ្រើសរើសសិទ្ធិលើបំណុលតបដែលត្រូវរំលត់ដោយការទូទាត់ ត្រូវហៅថា "ការកាត់បំណុលដោយការទូទាត់" ។ បទដ្ឋានជាក់លាក់ ត្រូវកំណត់ដោយការអនុវត្តដូចគ្នាផងដែរនូវបញ្ញត្តិពាក់ព័ន្ធនឹងការកាត់បំណុល ( មាត្រា ៤៤៩ ដល់ មាត្រា ៤៥២) ។

ការកាត់បំណុលដោយការទូទាត់ ខុសពីការកាត់បំណុល (ដោយការសង) ត្រង់ចំណុចថា មានករណីដែលភាគីដែលផ្តើមការទូទាត់មានសិទ្ធិលើបំណុលច្រើន ។ ឧទាហរណ៍ ដូចជាករណីដែល A មានសិទ្ធិលើបំណុល ( ៣) និង (៤) ចំពោះ B ហើយនៅពេល B ទាមទារឱ្យ A សងចំពោះសិទ្ធិលើបំណុលនៃប្រាក់កម្ចីដែល B មានចំពោះ A នោះ A គ្រាន់តែបង្ហាញឆន្ទៈទូទាត់ (ដោយមិនបានកំណត់សិទ្ធិលើបំណុលណាមួយរបស់ខ្លួន) ។ ប្រសិនបើមិនបានកំណត់យកសិទ្ធិលើបំណុលណាមួយក្នុងចំណោមសិទ្ធិលើបំណុលរបស់ A មកធ្វើការទូទាត់ទេ ការទូទាត់មិនអាចធ្វើបានឡើយ ។ ហេតុដូច្នេះ ចាំបាច់ត្រូវកំណត់សិទ្ធិលើបំណុលជាក់លាក់ដែលជាកម្មវត្ថុនៃការទូទាត់ ក្នុងចំណោមសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ច្រើននោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ការលើកលែង

**មាត្រា ៤៧៣.-** ការលើកលែងកាតព្វកិច្ច

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់ ។

(កំណត់)

មាត្រានេះចែងអំពីការលើកលែងកាតព្វកិច្ច ។

ការលើកលែងកាតព្វកិច្ច ត្រូវធ្វើដោយការបង្ហាញឆន្ទៈឯកតោភាគីរបស់ម្ចាស់បំណុល ។

កិច្ចសន្យាលើកលែងអាចធ្វើទៅបាន ដើម្បីឱ្យកូនបំណុលរួចពីកាតព្វកិច្ចតាមកិច្ចព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យា។ ដោយសារកិច្ចសន្យាលើកលែង ក៏ជាកិច្ចសន្យាដែរនោះ ការលុបចោលកិច្ចសន្យាអាចធ្វើទៅបាន ដូចកិច្ចសន្យាទូទៅដទៃទៀតដែរ ប្រសិនបើភាគីណាមួយមានវិការៈក្នុងការបង្ហាញឆន្ទៈ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៩៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ១២៨២ ដល់មាត្រា ១២៨៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៤៧៤.-** ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែករបស់កូនបំណុលបាន ។

**មាត្រា ៤៧៥.-** ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬ សិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិត ដោយមូលហេតុផ្សេង ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ ។

(កំណត់)

មាត្រានេះបញ្ញត្តថា មានករណីដែលការលើកលែងត្រូវបានកម្រិត ។

ក្នុងករណីដែលសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានបំណងធ្វើការលើកលែង ត្រូវបានរឹបអូស ការលើកលែងមិនអាចធ្វើបានទេ ដោយសារម្ចាស់បំណុលនោះមិនអាចអនុវត្តសិទ្ធិអំណាចរបស់ម្ចាស់បំណុលបានទេ ។ ក្រៅពីនេះ ម្ចាស់បំណុលមិនអាចលើកលែងឱ្យកូនបំណុលរួចពីកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំ ឬ កម្មវត្ថុនៃអនុប្បទានសិទ្ធិលើបំណុលដែលមានគោលបំណងជាប្រាតិភោគបានទេ ។

បន្ថែមលើការកម្រិតទាំងនេះ ក្នុងករណីដែលគ្មានការកម្រិតលើការចាត់ចែង ប៉ុន្តែ ការរំលត់សិទ្ធិលើបំណុលដោយការលើកលែង អាចប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន នោះមានបញ្ហាថា តើគួរកម្រិតការលើកលែង ឬ មិនគួរ ។ មានឧទាហរណ៍ ដូចជាករណីដែលម្ចាស់បំណុលលើកលែងសិទ្ធិលើបំណុល នៅពេលដែលមានការសន្យាជាមុននូវអនុប្បទានសិទ្ធិលើបំណុលនោះ ។ ក្នុងករណីនេះ ម្ចាស់បំណុលអាចលើកលែងបាន ប៉ុន្តែ ប្រសិនបើការលើកលែងនោះធ្វើឱ្យខូចខាតប្រយោជន៍របស់បុគ្គលដែលមានសិទ្ធិតាមការសន្យាជាមុននូវអនុប្បទានសិទ្ធិលើបំណុល ម្ចាស់បំណុលនឹងត្រូវទទួលខុសត្រូវចំពោះសំណងការខូចខាត ដោយការបំពានកិច្ចសន្យា ឬ អំពើអនីត្យានុកូល ។

## ផ្នែកទី ៤ នវកម្ម

**មាត្រា ៤៧៦.-** និយមន័យនៃនវកម្ម

១-នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វកិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ ។

២-នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់ ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃនវកម្ម ។ ដូចដែលនិយមន័យបានបង្ហាញ នវកម្មគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗដែលអាចនាំឱ្យមានការរំលត់កាតព្វកិច្ចបាន ។ កាតព្វកិច្ចដើមត្រូវរលត់ ដោយនវកម្ម ។

មាននវកម្មចំនួនបីប្រភេទ ប៉ុន្តែ ដូចរៀបរាប់ខាងក្រោមនេះ មាត្រានេះចែងតែអំពីនវកម្មដែលប្តូរគោលបំណងនៃកាតព្វកិច្ច ហើយមិនកំណត់អំពីនវកម្មដែលប្តូរម្ចាស់បំណុល ឬ នវកម្មដែលប្តូរកូនបំណុលទេ ។ ប្រភេទពីរទៀតនៃនវកម្ម អាចលៃលកដោះស្រាយបាន តាមរយៈប្រព័ន្ធនៃអនុប្បទានសិទ្ធិលើបំណុល និង ការទទួលកាតព្វកិច្ច ហើយតាមកិច្ចការជាក់ស្តែង ប្រភេទទាំងពីរនេះកម្រនឹងយកមកអនុវត្តណាស់ ។ ប៉ុន្តែ ដើម្បីឱ្យប្រាកដ ប្រភេទទាំងបីនៃនវកម្ម

ត្រូវបានពិពណ៌នាដូចខាងក្រោម ។

នវកម្មប្រភេទទីមួយ សំដៅលើករណីនៃការផ្លាស់ប្តូរគោលបំណងនៃកាតព្វកិច្ច ។ ឧទាហរណ៍ កាតព្វកិច្ចដែលមានគោលបំណងផ្តល់តាវកាលិកជាវត្ថុ ប្តូរទៅជាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ឬ កាតព្វកិច្ចចំពោះថ្លៃលក់ប្តូរទៅជាកាតព្វកិច្ចជាការខ្ចីបរិភោគ ។ ជាពិសេស ឧទាហរណ៍ទីពីរនេះ ត្រូវហៅថា ឧបសន្យានៃការខ្ចីបរិភោគ ។ តាមកិច្ចការជាក់ស្តែង នវកម្មដែលប្តូរគោលបំណងនៃកាតព្វកិច្ចដូច្នេះ ត្រូវបានប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច ហើយជាប្រព័ន្ធដ៏មានប្រយោជន៍ ។

នវកម្មប្រភេទទីពីរ គឺជានវកម្មដែលប្តូរម្ចាស់បំណុលដែលជាភាគីមួយក្នុងចំណោមភាគីនៃកិច្ចសន្យា ។ នវកម្មដែលប្តូរម្ចាស់បំណុល គឺស្រដៀងនឹងអនុប្បទានសិទ្ធិលើបំណុល ត្រង់ចំណុចថា ម្ចាស់បំណុលត្រូវបានប្តូរ ប៉ុន្តែ នវកម្មនេះខុសពីអនុប្បទានសិទ្ធិលើបំណុល ដោយសារកាតព្វកិច្ចដើមត្រូវរលត់ ហើយកាតព្វកិច្ចថ្មីកើតឡើង ។ ហេតុដូច្នេះ តាមកិច្ចសន្យានវកម្មដែលប្តូរម្ចាស់បំណុល ជាគោលការណ៍ ប្រាតិភោគដែលធានាកាតព្វកិច្ចដើមត្រូវរលត់ ហើយការតវ៉ាដែលកូនបំណុលធ្លាប់មានចំពោះម្ចាស់បំណុលដើម ក៏មិនអាចយកមកអះអាងតតាំងនឹងម្ចាស់បំណុលថ្មីបានដែរ ។ ដូចដែលបានរៀបរាប់ខាងលើ នវកម្មដែលប្តូរម្ចាស់បំណុល ពុំមានខ្លឹមសារសមហេតុផលនោះទេ ហើយប្រសិនបើមានប្រព័ន្ធនៃអនុប្បទានសិទ្ធិបំណុល ប្រព័ន្ធនេះគួរត្រូវយកមកប្រើប្រាស់ ។

នវកម្មប្រភេទទីបី គឺជានវកម្មដែលប្តូរកូនបំណុល ។ ម្ចាស់បំណុល A និង កូនបំណុល B រំលត់កាតព្វកិច្ចរវាង A និង B ហើយបង្កើតកាតព្វកិច្ចថ្មីដែលកូនបំណុល C ទទួលខុសត្រូវជំនួសវិញ ។ ចាំបាច់ត្រូវមានការយល់ព្រមពី C ដើម្បីឱ្យនវកម្មនេះមានអានុភាព ។ នវកម្មនេះមានអានុភាពស្ទើរតែដូចគ្នានឹងការទទួលកាតព្វកិច្ចដែលឱ្យកូនបំណុលរួចផុតពីការទទួលខុសត្រូវ ហេតុដូច្នេះ ខ្លឹមសារនៃនវកម្មនេះមិនមែនមិនសមហេតុផលដូចខ្លឹមសារនៃនវកម្មដែលប្តូរម្ចាស់បំណុលទេ ប៉ុន្តែ អាចត្រូវបានលៃលកដោះស្រាយបាន តាមរយៈប្រព័ន្ធនៃការទទួលកាតព្វកិច្ច ។ ដូច្នេះ មាត្រានេះមិនកំណត់អំពីនវកម្មដែលប្តូរកូនបំណុលទេ ។

កថាខណ្ឌទី ១ ចែងអំពីនវកម្មដែលមិនផ្លាស់ប្តូរម្ចាស់បំណុល ឬ កូនបំណុល ។ ពាក្យថា "រវាងម្ចាស់បំណុល និង កូនបំណុល" គឺសរសេរឡើងដើម្បីគោលបំណងនេះឯង ។ មានន័យថា មាត្រានេះមិនរួមបញ្ចូលនូវនវកម្មដែលប្តូរម្ចាស់បំណុល ដែលតម្រូវឱ្យមានការយល់ព្រមពីម្ចាស់បំណុលថ្មី ជាអាទិ៍ ទេ ។

កថាខណ្ឌទី ២ បញ្ជាក់អំពីអានុភាពនៃនវកម្ម និង បញ្ញត្តថា កាតព្វកិច្ចដើមត្រូវរលត់ នៅខណៈដែលកាតព្វកិច្ចថ្មីត្រូវបានបង្កើត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១២៧១ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៤៧៧.– ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចព្យាករបាន ឬ ប្រសិនបើកាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

(កំណត់)

នវកម្មរំលត់កាតព្វកិច្ចដើម ហើយបង្កើតកាតព្វកិច្ចថ្មីជំនួសកាតព្វកិច្ចដើមនោះវិញ ដូច្នេះ ប្រសិនបើកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុណាមួយ គោលបំណងនៃនវកម្មមិនត្រូវបានសម្រេចទេ ហើយកាតព្វកិច្ចដើមក៏មិនត្រូវរលត់ដែរ ។

ទីមួយ ក្នុងករណីដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុមិនស្របច្បាប់ កាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។ មូលហេតុមិនស្របច្បាប់ដែលលើកមកនេះ មិនត្រឹមតែភាពផ្ទុយនឹងបញ្ញត្តិនៃច្បាប់ប៉ុណ្ណោះទេ រួមមានករណីដែលកាតព្វកិច្ចមិនបានបង្កើតអានុភាពដោយសារមានភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អផងដែរ ។ ឧទាហរណ៍ កិច្ចសន្យានវកម្មដែលរំលត់កាតព្វកិច្ចរបស់ B ដែលត្រូវសងប្រាក់កម្ចីទៅ A ហើយបង្កើតកាតព្វកិច្ចដែល B ត្រូវផ្ដល់សេវាផ្លូវភេទសម្រាប់ A ត្រូវចាត់ទុកជាមោឃៈ ដោយសារកិច្ចសន្យានវកម្មនេះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។ ក្នុងករណីនេះ កាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

ទីពីរ ក្នុងករណីដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលភាគីពាក់ព័ន្ធមិនអាចព្យាករបាន ក៏កាតព្វកិច្ចដើមមិនត្រូវរលត់ទេ ។ ឧទាហរណ៍ ក្នុងករណីដែលកិច្ចសន្យានវកម្មចែងថា កាតព្វកិច្ចប្រគល់អង្ករមួយតោនត្រូវរលត់ ហើយកាតព្វកិច្ចថ្មីក្នុងការប្រគល់ស្នាដៃសិល្បៈជាក់លាក់ណាមួយ ត្រូវបានបង្កើតឡើងជំនួសវិញនោះ ស្នាដៃសិល្បៈជាក់លាក់នោះបានបាត់បង់ និង ត្រូវធ្លាក់ក្នុងនត្ថិភាពទៅហើយ ។ តាមក្រមរដ្ឋប្បវេណីនេះ អលទ្ធភាពតាំងពីដំបូង មិនធ្វើឱ្យកិច្ចសន្យាមោឃៈដោយស្វ័យប្រវត្តិទេ (មាត្រា ៣៩៥) ប៉ុន្តែ ប្រសិនបើម្ចាស់បំណុល និង កូនបំណុលមានការភាន់ច្រឡំ កិច្ចសន្យានវកម្មនេះអាចត្រូវបានលុបចោលបាន ហេតុដូច្នេះ ក្នុងករណីនេះ កាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

ដូចបានរៀបរាប់ក្នុងករណីខាងលើ ក្នុងករណីជាច្រើន ទោះបីជាគ្មានមាត្រានេះក៏ដោយ យើងនៅតែអាចធ្វើសេចក្ដីសន្និដ្ឋានបានថា កាតព្វកិច្ចដើមមិនត្រូវរលត់ ដោយចង្អុលបង្ហាញនូវវិការៈក្នុងកិច្ចសន្យានវកម្មផ្ទាល់ ប៉ុន្តែ មាត្រានេះមានអត្ថន័យក្នុងការបញ្ជាក់ថា កិច្ចសន្យានវកម្ម មិនមែនជា "កិច្ចសន្យាដែលមិនតម្រូវឱ្យមានមូលហេតុ (កិច្ចសន្យាដែលមានអានុភាពទោះបីជាមូលហេតុនៃកិច្ចសន្យាបាត់បង់អត្ថិភាព)" ទេ ដូច្នេះ ប្រសិនបើគោលបំណងនៃនវកម្ម (ការបង្កើតកាតព្វកិច្ចថ្មី) មិនអាចត្រូវបានសម្រេចទេ ស្ថានភាពដើម (អត្ថិភាពនៃកាតព្វកិច្ចដើម) អាចស្ដារឡើងវិញ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៧៨.–** ការផ្ទេរប្រាតិភោគ

១-សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឬ ប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន ។ ប៉ុន្តែ ប្រាតិភោគដែលត្រូវបានដាក់ដោយតតិយជន មិនត្រូវផ្ទេរឡើយ លើកលែងតែមានការយល់ព្រមពីតតិយជននោះ ។

២-ក្នុងឧបសន្យាខ្ចីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់នៅវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីប្រាតិភោគដែលបង្កើតឡើងដើម្បីធានាកាតព្វកិច្ចដើម ក្នុងករណីដែលមាននវកម្ម ។ នេះគឺជាបញ្ហាសារធាតុដែលមានសារៈសំខាន់បំផុតក្នុងចំណោមបញ្ហានានាដែលពាក់ព័ន្ធនឹងនវកម្ម ។ ដូចបានបង្ហាញក្នុងសេចក្ដីកំណត់នៃមាត្រា ៤៧៦ រួចមកហើយ នវកម្មដែលប្ដូរម្ចាស់បំណុល ឬ កូនបំណុល មិនមានចែងនៅទីនេះទេ ដូច្នេះមានតែករណីនៃនវកម្មដែលផ្លាស់ប្ដូរគោលបំណងនៃកាតព្វកិច្ចទេដែលនឹងលើកយកមកពន្យល់នៅទីនេះ ។

កថាខណ្ឌទី ១ បញ្ជាក់ថា ប្រាតិភោគមិនត្រូវបន្តដើម្បីធានាកាតព្វកិច្ចថ្មីដោយស្វ័យប្រវត្តិឡើយ ។ ដោយសារកាតព្វកិច្ចដើមត្រូវរលត់ដោយនវកម្ម ជាគោលការណ៍ ប្រាតិភោគដើម្បីធានាកាតព្វកិច្ចដើមនោះក៏ត្រូវរលត់ដូចគ្នាផងដែរ ។ ប៉ុន្តែ ប្រសិនបើមានការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យានវកម្ម ប្រាតិភោគអាចបន្តជាប្រាតិភោគចំពោះកាតព្វកិច្ចថ្មីនេះ ។ ក្នុងករណីដែលប្រាតិភោគត្រូវបានដាក់ដោយតតិយជន ឬ ករណីដែលតតិយជនជាអ្នកធានា វាជារឿងមិនត្រឹមត្រូវទេ ក្នុងការផ្ទេរប្រាតិភោគ ឬ ការធានានោះទៅកាតព្វកិច្ចថ្មី ដោយការព្រមព្រៀងគ្នារបស់ម្ចាស់បំណុល និង កូនបំណុលតែប៉ុណ្ណោះ ដូច្នេះ ចាំបាច់ត្រូវមានការយល់ព្រមរបស់តតិយជននោះ ។

កថាខណ្ឌទី ២ កំណត់អំពីបញ្ញត្តិពិសេសសម្រាប់ឧបសន្យានៃការខ្ចីបរិភោគ ។ ឧបសន្យានៃការខ្ចីបរិភោគ គឺធ្វើឱ្យកាតព្វកិច្ចចំពោះថ្លៃលក់ ជាអាទិ៍ ទៅជាកាតព្វកិច្ចតាមការខ្ចីបរិភោគ ។ ក្នុងករណីនេះ ត្រូវសន្មតថា មានការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល លើការផ្ទេរប្រាតិភោគ ។ ការសន្មតនេះ ត្រូវបានចែងដោយសារកាតព្វកិច្ចដើម និង កាតព្វកិច្ចថ្មីសុទ្ធតែជាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ហើយវាជារឿងសមហេតុផល ក្នុងការផ្ទេរប្រាតិភោគទៅកាតព្វកិច្ចថ្មី ។ ប៉ុន្តែ ចំពោះប្រាតិភោគដែលដាក់ដោយតតិយជន ចាំបាច់ត្រូវមានការយល់ព្រមរបស់អ្នកដាក់ប្រាតិភោគ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៥ ព្យាកុលភាព

**មាត្រា ៤៧៩.-** ព្យាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយព្យាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ ។

(កំណត់)

មាត្រានេះចែងអំពីព្យាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច ។ ព្យាកុលភាពគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗដែលនាំឱ្យកាតព្វកិច្ចរលត់ ។

ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុល A និង កូនបំណុល B គឺជាបុគ្គលផ្សេងគ្នា នៅពេលដែលកាតព្វកិច្ចនោះត្រូវបានបង្កើត ប៉ុន្តែ ប្រសិនបើ B ធ្វើសន្តតិកម្មនូវមតិករបស់ A ដោយសារមរណភាពរបស់ A ឬ A ធ្វើសន្តតិកម្មនូវមតិករបស់ B ដោយសារមរណភាពរបស់ A ម្ចាស់បំណុល និង កូនបំណុលក្លាយជាបុគ្គលតែម្នាក់ ។ ក្នុងករណីដែលម្ចាស់បំណុល និង កូនបំណុល ជាបុគ្គលតែម្នាក់ គ្មានន័យអ្វីក្នុងការអនុញ្ញាតឱ្យសិទ្ធិលើបំណុល ឬ កាតព្វកិច្ចរបស់បុគ្គលតែម្នាក់ បន្តឱ្យមានអត្ថិភាពឡើយ ដូច្នេះ ជារឿងសមហេតុផលក្នុងការពិចារណាថា កាតព្វកិច្ចត្រូវរលត់ ដូចក្នុងករណីដែលកាតព្វកិច្ចនេះត្រូវបានសង ។ នេះគឺជាហេតុផលដែលយកព្យាកុលភាពមកធ្វើជាមូលហេតុនៃការរលត់កាតព្វកិច្ច ។

ប៉ុន្តែ ក្នុងករណីដែលកាតព្វកិច្ចដែលត្រូវរលត់ជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំរបស់តតិយជន ឬ កម្មវត្ថុនៃការរឹបអូសរបស់តតិយជន ឬ កម្មវត្ថុនៃសិទ្ធិផ្សេងទៀតរបស់តតិយជន ប្រសិនបើកាតព្វកិច្ចត្រូវរលត់ដោយព្យាកុលភាព វានឹងប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ហេតុដូច្នេះ ចាំបាច់ត្រូវបញ្ញត្តថា សិទ្ធិលើបំណុល ឬ កាតព្វកិច្ចមិនត្រូវរលត់ក្នុងករណីបែបនេះនោះឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៥០០ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ៨ អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

(កំណត់)

(ស្តីពីកន្លែងនៃបញ្ញត្តិចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និង វិធីបញ្ញត្ត នៅក្នុងក្រមនេះ)

អាជ្ញាយុកាលនៃការរំលត់សិទ្ធិ គឺជារបបមួយដែលមិនត្រឹមតែមានទំនាក់ទំនងនឹងសិទ្ធលើបំណុលប៉ុណ្ណោះទេ ថែមទាំងមានទំនាក់ទំនងនឹងសិទ្ធិប្រត្យក្ស និង សិទ្ធិផ្សេងទៀត (សិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ជាអាទិ៍) ផងដែរ ។ អាជ្ញាយុកាលនេះគឺជារបបដែលមានពាក់ព័ន្ធទាំងសិទ្ធិលើបំណុល ទាំងសិទ្ធិប្រត្យក្ស ហេតុដូច្នេះ អាចយកបញ្ញត្តិចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ ទៅដាក់ក្នុងគន្ថីស្តីពីបទប្បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីនេះដែរ ។ ក៏ប៉ុន្តែ ក្នុងក្រមនេះ គន្ថីស្តីពីបទប្បញ្ញត្តិទូទៅ ចែងតែបញ្ញត្តិមួយចំនួនអំពីគោលការណ៍មូលដ្ឋានដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិទូទៅនៃនីតិឯកជនប៉ុណ្ណោះ ហេតុនេះហើយបានជាមិនអាចជ្រើសរើសវិធីបញ្ញត្តបែបនេះ ។ ដូច្នេះ ក្នុងក្រមនេះ យើងខ្ញុំបានបង្កើតជំពូកឯករាជ្យមួយ (ជំពូកទី ៨) ដែលបញ្ញត្តស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ ហើយដាក់នៅក្រោយជំពូកស្តីពីការរលត់កាតព្វកិច្ច ។ យើងគិតពិចារណាអំពីលទ្ធភាពក្នុងការបង្កើតជាផ្នែកទី ៦ នៅភាគចុងក្រោយនៃជំពូកស្តីពីការរលត់កាតព្វកិច្ចដែរ ក៏ប៉ុន្តែ ដោយសារតែមានរួមទាំងការរំលត់នៃសិទ្ធិប្រត្យក្ស ជាអាទិ៍ ផងដែរ ហើយបើប្រៀបធៀបទៅនឹងបញ្ញត្តិស្តីពីមូលហេតុដទៃទៀតនៃការរំលត់សិទ្ធិលើបំណុល បញ្ញត្តិស្តីពីការរំលត់សិទ្ធិនេះមានចំនួនច្រើនជាង ហេតុនេះហើយបានជាបានបង្កើតជំពូកមួយដាច់ពីគេ ដើម្បីចែងអំពីបញ្ហានេះ ។ ក៏ប៉ុន្តែ ដោយពិចារណាឃើញថា នេះជាជំពូកមួយក្នុងគន្ថីស្តីពីកាតព្វកិច្ច ចំពោះវិធីបញ្ញត្តិវិញ ត្រូវចែងស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាមុន ហើយបន្ទាប់មកថែមបញ្ញត្តិបញ្ជាក់ឱ្យយកបញ្ញត្តិទាំងអស់នោះមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ក្រៅពីសិទ្ធិលើបំណុល (លើកលែងតែបញ្ញត្តិស្តីពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ) ។

**មាត្រា ៤៨០.-** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិចែងអំពីនិយមន័យមូលដ្ឋាននៃរបបអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ។ ការឱ្យនិយមន័យដូចនេះ គឺដើម្បីឱ្យស្រួលយល់នូវអត្ថន័យនៃរបបនេះ ។ បញ្ញត្តប្រភេទនេះ មាននៅក្នុងមាត្រា ៩២៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាដែរ ដូច្នេះ ក្រមនេះក៏បានបញ្ញត្តទៅតាមទម្លាប់ដែលមានពីមុនមក ។

ស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ មានមតិបី : ការរំលត់នៃសិទ្ធិសារធាតុ ការរំលត់នៃសិទ្ធិប្តឹង និង ការរំលត់នៃសិទ្ធិទាមទារ ។ ក្នុងក្រមនេះ យើងខ្ញុំបានជ្រើសរើសមតិ "ការរំលត់នៃសិទ្ធិសារធាតុ" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៤៨១.-** ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

(កំណត់)

មាត្រានេះចែងថា "ពេលដែលអាចអនុវត្តសិទ្ធិលើបំណុល" គឺជាពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ។

"ពេលដែលអាចអនុវត្តសិទ្ធិលើបំណុល" មានន័យថា ពេលដែលលែងមានឧបសគ្គតាមផ្លូវច្បាប់ ក្នុងការអនុវត្តសិទ្ធិនោះ ។ ឧទាហរណ៍ ក្នុងករណីដែលបុគ្គលម្នាក់បានធ្វើកិច្ចសន្យាឱ្យអ្នកផ្សេងខ្ចីប្រាក់ ដោយកំណត់ឱ្យសងវិញកន្លះឆ្នាំក្រោយ ប្រសិនបើអំឡុងពេលកន្លះឆ្នាំនោះមិនទាន់កន្លងផុតទេ បុគ្គលនោះមិនអាចទាមទារឱ្យសងវិញបានទេ (មានន័យថា មានឧបសគ្គតាមផ្លូវច្បាប់ ក្នុងការអនុវត្តសិទ្ធិនេះ) ដូច្នេះ ប្រសិនបើអំឡុងពេលកន្លះឆ្នាំនេះមិនទាន់កន្លងផុតទេ មិនអាចចាប់ផ្តើមគិតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ៥ ឆ្នាំ (មាត្រា ៤៨២) បានទេ ។ ក្រោយពីពេល ៦ ខែបានកន្លងផុតទៅ ពេលនោះ នឹងលែងមានឧបសគ្គតាមផ្លូវច្បាប់ ហើយត្រូវចាប់ផ្តើមគិតអំឡុងពេល ៥ ឆ្នាំ នៃអាជ្ញាយុកាល ។ ក្នុងករណីដែលពុំបានកំណត់ពេលសង នៅក្នុងកិច្ចសន្យាខ្ចីបរិភោគប្រាក់ អ្នកឱ្យខ្ចីអាចទាមទារឱ្យសងពេលណាក៏បានដែរ ហេតុនេះហើយ អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិត្រូវចាប់ផ្តើមគិតពីពេលឱ្យខ្ចី ។

ទោះបីជាមានឧបសគ្គជាក់ស្តែងក្នុងការអនុវត្តសិទ្ធិ ដូចជាករណីដែលម្ចាស់បំណុលមិនបានដឹងថា ខ្លួនមានសិទ្ធិនោះក៏ដោយ ក៏អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះមានដំណើរការទៅមុខដែរ ។ ឧទាហរណ៍ ក្នុងករណីដែលឪពុក ឬ ម្តាយ នាពេលគាត់នៅរស់ បានឱ្យអ្នកផ្សេងខ្ចីប្រាក់ ដោយមានការសន្យាថា នឹងសង ៦ ខែក្រោយ ទោះបីជាកូនដែលបានធ្វើសន្តតិកម្មនូវសិទ្ធិលើបំណុលនោះ មិនបានដឹងថា មានសិទ្ធិលើបំណុលនោះក៏ដោយ ក៏ឱ្យតែពេលវេលា ៦ ខែបានកន្លងផុតទៅពីពេលដែលបានឱ្យខ្ចីប្រាក់នោះទៅ នោះគឺជា "ពេលដែលអាចអនុវត្តសិទ្ធិ" មានន័យថា ឧបសគ្គតាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិបានរលត់ទៅហើយ ហេតុដូច្នេះ ពីពេលនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងចាប់ផ្តើមមានដំណើរការ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ១៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៨២.-** អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

(កំណត់)

ស្តីពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺជាបញ្ហាមួយដែលមានការពិបាកកំណត់ថា ប៉ុន្មានឆ្នាំជាការត្រឹមត្រូវសមរម្យ ក៏ប៉ុន្តែ ដោយយោងតាមមាត្រា ២៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ និង មាត្រា ៩២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក្នុងក្រមនេះ អំឡុងពេលនេះត្រូវបានកំណត់ ៥ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ និង មាត្រា ៩២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៤៨៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ និង ថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករផ្តល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល ២ (ពីរ) ឆ្នាំ ។

(កំណត់)

ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ពីមាត្រា ១៧០ ទៅ មានបញ្ញត្តិជាច្រើនដែលចែងអំពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិពិសេសនីមួយៗ ក៏ប៉ុន្តែ វិធីតាក់តែងច្បាប់របៀបនេះ មានគេរិះគន់ខ្លាំង ។ ក្នុងក្រមនេះ យើងខ្ញុំមិនបានចែងអំពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិសម្រាប់សិទ្ធិច្រើនប្រភេទផ្សេងៗគ្នាទេ គឺចែងតែចំពោះករណីដែលមានការចាំបាច់ពិតប្រាកដ និង សមរម្យប៉ុណ្ណោះ ។ ករណីទាំងនេះមានដូចជាសិទ្ធិលើបំណុលក្នុងកិច្ចប្រតិបត្តិការរបស់អ្នកប្រើប្រាស់ ។ មានន័យថា ស្តីពីសិទ្ធិលើបំណុលចំពោះអ្នកប្រើប្រាស់ ក្នុងកិច្ចប្រតិបត្តិការរបស់អ្នកប្រើប្រាស់ មានការពិបាកនឹងរក ព្រមទាំងរក្សាទុកនូវភស្តុតាងនៃការសង ហេតុនេះហើយ គួរតែកំណត់អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិឱ្យខ្លី ។ ហេតុដូច្នេះ មាត្រានេះបានកំណត់ ២ ឆ្នាំ សម្រាប់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី ចំពោះសិទ្ធិលើបំណុលស្តីពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករបានលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ ព្រមទាំងថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករបានផ្តល់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ៤ មាត្រា ២២៧២ នៃក្រមរដ្ឋប្បវេណីបារាំង និង ចំណុចទី ១ មាត្រា ១៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៨៤.–** អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬ ដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ នៅពេលនៃការចូលជាស្ថាពរ ។

(កំណត់)

ទោះបីជាអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផ្អាកក៏ដោយ ពេលដែលហេតុនៃការផ្អាកនោះបានចប់ ក៏អាជ្ញាយុកាលនោះនឹងត្រូវចាប់ផ្តើមគិតជាថ្មីទៀតដែរ (កថាខណ្ឌទី ១ នៃមាត្រា ៤៩៤) ។ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចាប់ផ្តើមគិតជាថ្មីនេះ ត្រូវមានស្មើគ្នានឹងអំឡុងពេលអាជ្ញាយុកាលដែលបានកំណត់ពីដើមសម្រាប់សិទ្ធិលើបំណុលនោះ ។ ក៏ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានអាជ្ញាយុកាលនៃការរំលត់សិទ្ធដែលមានអំឡុងពេលខ្លីវិញ ក្នុងករណីដែលសាលក្រម ឬ សាលដីកា ស្តីពីអត្ថិភាពនៃសិទ្ធិលើបំណុលនោះបានចូលជាស្ថាពរ ឬ នីតិវិធីតាមផ្លូវច្បាប់ដែលមានអានុភាពដូចគ្នា បានចូលជាស្ថាពរ មិនគួរយកអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លីមកអនុវត្តឡើយ ។ នេះគឺដោយសារតែម្ចាស់សិទ្ធិលើបំណុល ជាអាទិ៍ ត្រូវធ្វើនីតិវិធីនៃការផ្អាកអាជ្ញាយុកាលដូចជាបណ្តឹង ជាដើម ជាបន្តបន្ទាប់ក្នុងរយៈពេលយ៉ាងខ្លី ប្រសិនបើអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចាប់ផ្តើមគិតជាថ្មីនេះ មានអំឡុងពេលខ្លី ។

ដូច្នេះហើយ កថាខណ្ឌទី ១ នៃមាត្រានេះបានចែងថា ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរដោយសាលក្រម ឬ សាលដីកា ឬ ដោយនីតិវិធីតាមផ្លូវច្បាប់ដែលមានអានុភាពដូចគ្នា អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះមាន ៥ ឆ្នាំ ទោះបីជាមានបញ្ញត្តិកំណត់អំឡុងពេលអាជ្ញាយុកាលនោះខ្លីជាង ៥ ឆ្នាំក៏ដោយ ។

ម្យ៉ាងទៀត ចំពោះសិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ឱ្យសង នាពេលដែលសាលក្រម ឬ សាលដីកានោះបានចូលជាស្ថាពរ មិនត្រូវអនុវត្តកថាខណ្ឌទី ១ នេះទេ (កថាខណ្ឌទី ២) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៧៤-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៨៥.-** អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពប្រតិសកម្ម ចាប់តាំងពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនោះ ។

(កំណត់)

ពេលដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេច ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះត្រូវបានរំលត់ដោយប្រតិសកម្ម ចាប់ពីថ្ងៃដែលចាប់ផ្តើមគិតអាជ្ញាយុកាល ។ ហេតុនេះហើយ កូនបំណុលមិនចាំបាច់បង់ការប្រាក់ ឬបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ សម្រាប់អំឡុងពេលចាប់ពីថ្ងៃដែលបានចាប់ផ្តើមគិតអាជ្ញាយុកាលទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៨៦.-** ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

១-តុលាការមិនអាចសម្រេចសេចក្តីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ។

២-ក្រៅពីកូនបំណុល មានតែកូនបំណុលដោយសាមគ្គីភាព អ្នកធានា អ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ និងបុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ។

៣-ប្រសិនបើកូនបំណុលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល តតិយជនក៏នឹងទទួលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនេះដែរ ។ ប្រសិនបើអ្នកដែលមិនមែនជាកូនបំណុល តែមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកដែលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះបានជ្រើសរើសរបបលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ។ កថាខណ្ឌទី ១ បានចែងអំពីចំណុចនេះដោយផ្ទាល់តែម្តង ។

ក្នុងករណីដែលបានជ្រើសរើសរបបលើកឡើង វិសាលភាពនៃអ្នកមានសិទ្ធិលើកឡើងគឺជាបញ្ហា ដូច្នេះ ក្នុងកថាខណ្ឌទី ២ មានចែងកម្រិតនូវវិសាលភាពនៃអ្នកដែលមានសិទ្ធិលើកឡើង ដែលមានខ្លឹមសារថា "មានតែបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាល" នៃការរំលត់សិទ្ធិលើបំណុលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះបាន ។ "បុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ក្នុងការលើកឡើងនូវអាជ្ញាយុកាល" នៃការរំលត់សិទ្ធិលើបំណុល គឺជាបទដ្ឋានមួយអរូបី ប៉ុន្តែ ក៏មានការពិបាកក្នុងការកំណត់ឱ្យច្បាស់លាស់អំពីវិសាលភាពអ្នកមានសិទ្ធិលើកឡើងដែរ ដូច្នេះហើយមានការពិបាកនឹងជៀសនូវការប្រើឃ្លាទូទៅណាស់ ។ ក៏ប៉ុន្តែ ក្នុងកថាខណ្ឌទី ២ ចែងជាក់ស្តែងអំពីបុគ្គលដែលត្រូវបានទទួលស្គាល់ថាជាបុគ្គលដែលមានសិទ្ធិលើកឡើង ដូច្នេះ អាចមានគំនិតខ្លះដើម្បីបកស្រាយច្បាប់ ។

កថាខណ្ឌទី ៣ ចែងអំពីវិសាលភាពនៃអានុភាពនៃការលើកឡើង ។ ក្នុងករណីដែលកូនបំណុលដែលអាចរួចផុតពីករណីយកិច្ចដោយផ្ទាល់ដោយអាជ្ញាយុកាល លើកឡើងនូវអាជ្ញាយុកាល នោះការរំលត់សិទ្ធិដោយអាជ្ញាយុកាលនឹងបានសម្រេចជាស្ថាពរចំពោះបុគ្គលទាំងអស់ ហើយអានុភាពនៃការលើកឡើងនឹងមានភាពដាច់ខាត ។ ឧទាហរណ៍ ក្នុងករណីដែលមានអ្នកធានាដោយវត្ថុ អានុភាពនៃការរំលត់សិទ្ធិដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិក៏មានឥទ្ធិពលលើអ្នកធានាដោយវត្ថុនោះដែរ ហើយសិទ្ធិប្រាតិភោគក៏ត្រូវបានរលត់ដែរ ។

រីឯចំពោះករណីដែលអ្នកដែលមានសិទ្ធិលើកឡើងក្រៅពីកូនបំណុល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលវិញ មាត្រានេះបានចែងថា អានុភាពនៃការលើកឡើងមានលក្ខណៈមិនដាច់ខាត ក្នុងគោលគំនិតគោរពឆន្ទៈរបស់កូនបំណុល ស្តីពីបញ្ហាថា តើកូនបំណុលមានបំណងទទួលផលប្រយោជន៍ពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកធានាដោយវត្ថុបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានធានា ក្នុងទំនាក់ទំនងរវាងអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគ សិទ្ធិលើបំណុលនោះនឹងរលត់ ហើយអ្នកធានាដោយវត្ថុ នឹងរួចពីបន្ទុកលើវត្ថុដែលត្រូវបានដាក់ធានានោះ តែចំពោះបញ្ហាថា តើកូនបំណុលទទួលនូវអានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះដែរ ឬទេនោះ គឺជាបញ្ហាដែលកូនបំណុលសាមីខ្លួនត្រូវសម្រេចដោយខ្លួនឯង មានន័យថាកូនបំណុលអាចយកជម្រើសមិនលើកឡើងនូវអាជ្ញាយុកាល ហើយមិនទទួលនូវផលប្រយោជន៍ពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះបាន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៩៣៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ១៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន (រីឯមាត្រា ២៧ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ វិញ បានចែងផ្ទុយទៅវិញ) ។

**មាត្រា ៤៨៧.–** ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនអាចបោះបង់ចោលជាមុនបានទេ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

(កំណត់)

ទោះបីជាបានឱ្យកូនបំណុលធ្វើការសន្យាថា ត្រូវតែសងបំណុលនោះ ទោះជាបានសម្រេចនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ដោយមិនឱ្យលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះក៏ដោយ ក៏ការព្រមព្រៀងបែបនេះ ត្រូវទុកជាមោឃៈដោយវាក្យខណ្ឌទី ១ នៃមាត្រានេះដែរ ។ នេះគឺដោយសារតែប្រសិនបើទទួលស្គាល់នូវការសន្យាពិសេសនេះទៅ ម្ចាស់បំណុលនឹងចាប់ចំណុចខ្សោយរបស់កូនបំណុល ដោយបង្ខំថា បើមិនព្រមចំពោះការសន្យាពិសេសនេះទេ មិនអាចបង្កើតកិច្ចសន្យានេះទេ ហើយការធ្វើបែបនេះនឹងធ្វើឱ្យរបបអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះលែងមានន័យទៅវិញ ។

ប៉ុន្តែ ប្រសិនបើការបោះបង់ចោលនូវផលប្រយោជន៍នេះ មិនមែនត្រូវបានធ្វើ "ជាមុន" ទេ ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ នឹងមានអានុភាព ។ មានន័យថា ក្រោយពេលដែលអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុតទៅ អាចបោះបង់នូវផលប្រយោជន៍នៃអាជ្ញាយុកាលនោះបាន (វាក្យខណ្ឌទី ២ នៃមាត្រានេះ) ។

បន្ទាប់មក ក្នុងករណីដែលកូនបំណុលមិនបានដឹងថា អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុតទៅហើយ ហើយបានសន្យាចំពោះម្ចាស់បំណុលថា "ដាច់ខាតនឹងសងកាតព្វកិច្ច" នោះ តែក្រោយពីនោះ កូនបំណុលបានដឹងថា អំឡុងពេលនោះបានកន្លងផុតទៅហើយ ក្នុងករណីនេះ តើគួរអនុញ្ញាតឱ្យកូនបំណុលបដិសេធមិនសងដោយលើកឡើងនូវអាជ្ញាយុកាលនោះដែរ ឬទេ ? ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះ គឺជាការបង្ហាញឆន្ទៈមិនទទួលផលប្រយោជន៍នៃអាជ្ញាយុកាលក្រោយពេលដែលបានដឹងថា អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិបានកន្លងផុត ហេតុដូច្នេះ ករណីឧទាហរណ៍នេះមិនមែនជាករណីដែលបានបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលទេ ហេតុនេះហើយបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តទេ ។ អាស្រ័យហេតុនេះ ការដោះស្រាយករណីនេះ ត្រូវប្រគល់ទៅឱ្យអ្នកបកស្រាយក្រមរដ្ឋប្បវេណីកម្ពុជាវិញ ។ ពេលដែលបានបង្ហាញឆន្ទៈ "នឹងសងជាដាច់ខាតនូវកាតព្វកិច្ច" នោះម្តងហើយ អាចគិតឃើញថា ការដកពាក្យសំដីវិញ ដោយបដិសេធនូវការសងនោះ ដោយលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះជាអំពើមួយផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ដែរ (តាមការបកស្រាយក្រមរដ្ឋប្បវេណីជប៉ុន ចំពោះ

ករណីឧទាហរណ៍នេះ កូនបំណុលនឹងបាត់បង់នូវសិទ្ធិលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ តាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់) ។

មាត្រានេះគឺជាបញ្ញត្តិដែលចែងអំពីអានុភាពនៃការសន្យាពិសេសដែលបោះបង់ចោលជាមុន នូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល តែមិនមែនជាបញ្ញត្តិចែងផ្ទាល់អំពីអានុភាពនៃការសន្យាពិសេសដែលធ្វើឱ្យមានការពិបាកក្នុងការសម្រេចនូវអាជ្ញាយុកាល ដោយការពន្យារអំឡុងពេលនៃអាជ្ញាយុកាលនោះទេ (ឧទាហរណ៍ ដូចជាការសន្យាពិសេស ដោយកំណត់អំឡុងពេល ១០ ឆ្នាំ សម្រាប់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) ។ ដូច្នេះហើយ ចំពោះអានុភាពនៃការសន្យាពិសេសនេះ ត្រូវធ្វើការវិនិច្ឆ័យទៅតាមគោលការណ៍ច្បាប់ទូទៅ ។ ប៉ុន្តែ ពេលអនុវត្តគោលការណ៍ច្បាប់ទូទៅនេះ ត្រូវពិចារណាឱ្យបានហ្មត់ចត់នូវគោលគំនិតនៃមាត្រានេះ ហើយជាទូទៅ ភាគច្រើនត្រូវតែបដិសេធនូវអានុភាពនៃការសន្យាពិសេសប្រភេទនេះ ។ ក៏ប៉ុន្តែ មានករណីខ្លះ ដូចជាករណីដែលមានការកំណត់អំឡុងពេល ១០ ឆ្នាំ សម្រាប់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលចំពោះប្រាក់បញ្ញើនៅធនាគារ ដោយការសន្យាពិសេសរវាងធនាគារ និង អ្នកផ្ញើប្រាក់នៅធនាគារ ជាអាទិ៍ ដែលមិនគួរបដិសេធនូវអានុភាពនៃការសន្យាប្រភេទនេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៨៨.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអានុភាពតែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផលប្រយោជន៍នោះតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា អានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល ជាអានុភាពមិនដាច់ខាត ។ មានន័យថា ខុសពីការលើកឡើងនូវអាជ្ញាយុកាល មិនត្រឹមតែការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលដោយ "តតិយជន" សូម្បីការបោះបង់ចោលដោយ "សាមីខ្លួនផ្ទាល់" ក៏ដោយ ក៏ការបោះបង់ចោលនោះមានអានុភាពមិនដាច់ខាតដែរ ។

## មាត្រា ៤៨៩.- ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ :

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង ។

(កំណត់)

ការផ្អាកអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាល ក្នុងករណីដែលមានហេតុកំណត់មួយចំនួន (ហេតុនៃការផ្អាក) ដែលត្រូវបានយល់ឃើញថា មិនគួរឱ្យអាជ្ញាយុកាលនោះមានដំណើរការបន្តទៀត ។ ក្នុងករណីនេះ ការផ្អាកនូវអាជ្ញាយុកាល គឺមិនត្រឹមតែផ្អាកដំណើរការនៃអាជ្ញាយុកាលនោះមួយរយៈពេលទេ គឺចាត់ទុកថា អំឡុងពេលនៃអាជ្ញាយុកាលដែលមានដំណើរការកន្លងមកនេះ ពុំមានអត្ថន័យតាមផ្លូវច្បាប់ ។ ដូច្នេះហើយ ពេលដែលហេតុនៃការផ្អាកនោះ រលត់ទៅ អំឡុងពេលនៃអាជ្ញាយុកាលនឹងចាប់ផ្តើមមានដំណើរការជាថ្មីម្តងទៀត ។

មាត្រានេះចែងថា ហេតុនៃការផ្អាកអាជ្ញាយុកាលមានបីប្រភេទ ។

ក្នុងចំណោមនោះ ចំណុច ក គឺជាប្រភេទមួយប្រហាក់ប្រហែលនឹង "ការទាមទារ" ដែលបានចែងក្នុងមាត្រា ១៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ក៏ប៉ុន្តែ បើគ្រាន់តែបញ្ញត្តថាជា "ការទាមទារ" ប៉ុណ្ណោះទៅ មិនមែនជាវិធីបញ្ញត្តមួយដែលស្រួលយល់ទេ ហេតុនេះហើយ ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មិនប្រើពាក្យ "ការទាមទារ" ទេ តែបានលើកឡើងនូវហេតុនៃការផ្អាកនីមួយៗ ។ មានន័យថា ក្នុងចំណុច ក នេះ ចង្អុលបង្ហាញករណីជាក់ស្តែងនៃ "ការទាមទារតាមផ្លូវតុលាការ" និង "ការចូលរួមក្នុងនីតិវិធីធនក្ស័យ" ហើយបន្ថែម "ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល" ដើម្បីគ្របដណ្តប់ករណីផ្សេងៗ ។ ម្យ៉ាងទៀត "ការដាស់តឿន" ដែលបានចែងក្នុងមាត្រា ៤៩៥ នៃក្រមនេះ ពុំមែនជាហេតុនៃការផ្អាកទេ គឺជាហេតុនៃការបង្អង់ការសម្រេចនូវអាជ្ញាយុកាល ហេតុនេះហើយ មិនបញ្ចូលក្នុងចំណុច ក ទេ ។

ចំណុច ខ បានលើកឡើងនូវសកម្មភាពអនុវត្តដោយបង្ខំ និង សកម្មភាពចាត់ចែងការរក្សាការពារ ។ សកម្មភាពទាំងពីរនេះ សុទ្ធតែជាការអះអាងសិទ្ធិយ៉ាងខ្លាំង ហេតុនេះហើយ សកម្មភាពទាំងនេះត្រូវជាហេតុនៃការផ្អាកអាជ្ញាយុកាល ។ សកម្មភាពអនុវត្តដោយបង្ខំ គឺជាការរឹបអូស ឬ ការអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារដែលមិនមានគោលបំណងឱ្យសងជាប្រាក់ (ឧទាហរណ៍ សកម្មភាពអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុ) រីឯសកម្មភាពចាត់ចែងការរក្សាការពារ សំដៅទៅលើការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន ។ ការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ ក៏ជាហេតុមួយនៃការផ្អាកអាជ្ញាយុកាលដែរ ដោយសារនីតិវិធីនោះត្រូវបានចាប់ផ្តើមដោយការរឹបអូស ។

ពេលដែលអានុភាពនៃការផ្អាកអាជ្ញាយុកាលកើតឡើងនោះ ចំពោះការរឹបអូស គឺពេលដែលបានដាក់ពាក្យសុំឱ្យ

អនុវត្តដោយបង្ខំ រីឯចំពោះការចាត់ចែងរក្សាការពារវិញ គឺពេលដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេច ។

ចំណុច គ ចែងអំពីការទទួលស្គាល់ ។ ការទទួលស្គាល់ គឺជាការទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ច ដោយកូនបំណុល ។ ក្នុងករណីដែលកូនបំណុលបានទទួលស្គាល់នូវកាតព្វកិច្ច ដោយសកម្មភាពរបស់ខ្លួន ចាំបាច់ត្រូវការពារផលប្រយោជន៍របស់ម្ចាស់បំណុលដែលអាចរង់ចាំ ហើយមិនអនុវត្តសិទ្ធិដោយមានជំនឿទៅលើសកម្មភាពនោះ ផ្ទុយទៅវិញ មិនសូវមានការចាំបាច់ការពារផលប្រយោជន៍កូនបំណុលទេ ដូច្នេះហើយ នេះគឺជាហេតុនៃការផ្អាកអាជ្ញាយុកាល ។ ក្នុងចំណុច គ នេះ ប្រសិនបើចែងតែ "ការទទួលស្គាល់" ប៉ុណ្ណោះ គឺមិនច្បាស់លាស់ទេ ហេតុនេះហើយបានជាក្នុងនេះមានបន្ថែមឧទាហរណ៍ជាក់ស្តែងនៃការទទួលស្គាល់ ដូចជា "ការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ" ហើយបានបន្ថែម "ការទទួលស្គាល់ដោយវិធីផ្សេង" ផងដែរ ដើម្បីគ្របដណ្តប់ករណីផ្សេងៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ១ មាត្រា ២១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៩៣១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, វាក្យខណ្ឌទី ២ មាត្រា ២៦ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ (ស្តីពីចំណុច ក)

## មាត្រា ៤៩០.- វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះកូនបំណុល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាកនេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើង ក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនេះត្រូវកើតឡើង តែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះបានចែងអំពីអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដូចតទៅ ។ ប្រសិនបើការផ្អាកអាជ្ញាយុកាលកើតឡើងចំពោះកូនបំណុល ការផ្អាកនេះនឹងមានអានុភាពដាច់ខាត ហើយក៏មានអានុភាពចំពោះអ្នកមានសិទ្ធិលើកឡើងដទៃទៀតដែរ ។ ផ្ទុយទៅវិញ ប្រសិនបើការផ្អាកនោះកើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើងក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនោះមិនមែនជាអានុភាពដាច់ខាតទេ ។ ឧទាហរណ៍ ទោះបីជាម្ចាស់បំណុលបានរឹបអូសនូវអចលនវត្ថុដែលអ្នកធានាដោយវត្ថុបានដាក់ជាកម្មវត្ថុនៃហ៊ីប៉ូតែកក៏ដោយ ក៏អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពអនុវត្តដោយបង្ខំនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកធានាដោយវត្ថុប៉ុណ្ណោះ ហើយត្រូវចាត់ទុកថា ពុំមានការផ្អាកនូវអាជ្ញាយុកាលចំពោះកូនបំណុលទេ (ប៉ុន្តែ ក្នុងករណីនេះ ត្រូវប្រយ័ត្នដល់ករណី

លើកលែងនៃមាត្រា ៤៩៣) ។

ការដែលបានចែងថា ប្រសិនបើការផ្អាកបានកើតឡើងចំពោះកូនបំណុល អានុភាពនៃការផ្អាកនេះក៏ត្រូវមានចំពោះអ្នកមានសិទ្ធិលើកឡើងដទៃទៀតនេះ គឺដោយសារតែ បើទទួលស្គាល់នូវសិទ្ធិលើកឡើងនៃអាជ្ញាយុកាល ចំពោះអ្នកដទៃក្រៅពីកូនបំណុល ហើយមិនទទួលស្គាល់នូវអានុភាពនៃការផ្អាកនៃអាជ្ញាយុកាលដែលកើតឡើងរវាងម្ចាស់បំណុល និងកូនបំណុលនោះ ឱ្យមានអានុភាពចំពោះអ្នកមានសិទ្ធិលើកឡើងដែរនោះទេ នឹងពុំមានតុល្យភាពឡើយ ។

## មាត្រា ៤៩១.- ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

(កំណត់)

ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ការទាមទារតាមផ្លូវតុលាការពុំបង្កើតនូវអានុភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ។ ការលើកចោលនូវបណ្តឹងក្នុងនេះ គឺមិនត្រឹមតែការលើកចោលដោយមូលហេតុខាងនីតិវិធី ដូចជាខុសសមត្ថកិច្ចសាលាជម្រះក្តី ជាដើមទេ គឺមានរួមទាំងការច្រានចោលនូវបណ្តឹងដោយមូលហេតុសារធាតុផងដែរ ។

យោងតាមមាត្រានេះ ទោះបីជាក្នុងករណីដែលការទាមទារតាមផ្លូវបណ្តឹងមិនបង្កើតអានុភាពនៃការផ្អាកក៏ដោយ ពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ភាគីម្ខាងទៀត នោះយោងតាមមាត្រា ៤៩៥ អាចមានការបង្អង់ការសម្រេចនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយចាត់ទុកថាជាការដាស់តឿនតាមផ្លូវតុលាការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៤៩២.- ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ

ក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់ភាគី ឬ ដោយការខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការពារនេះ ត្រូវចាត់ទុកថា មិនបានកើតឡើងឡើយ ។

(កំណត់)

ក្នុងករណីដែលសកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារមិនបានសម្រេច ដោយសារការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ ការទទួលស្គាល់នូវអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិ គឺជាការមិនត្រឹមត្រូវទេ ។ មាត្រានេះបានចែងច្បាស់លាស់អំពីចំណុចនេះ ។

ក្នុងករណីដែលមានការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងអនុវត្តការចាត់ចែងរក្សាការពារដោយការដកពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬ ពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយអ្នកមានសិទ្ធិ ការផ្អាកនឹងត្រូវលែងមានអានុភាព ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការលុបចោលនូវនីតិវិធីអនុវត្តដោយបង្ខំ ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ឬ ការលុបចោលនូវដីកាសម្រេចចាត់ចែងរក្សាការពារដោយពាក្យសុំតវ៉ា ជាដើម ត្រូវពិចារណាមើលថា តើអាចថាការអនុវត្តសិទ្ធិនោះត្រឹមត្រូវ ឬទេ ហើយធ្វើការវិនិច្ឆ័យថា តើអានុភាពនៃការផ្អាកបានបាត់បង់ឬទេ ។ ឧទាហរណ៍ ក្នុងករណីនៃការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំដោយការដាក់ប្រាតិភោគ ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្នដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ឬ ការលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយការដាក់ប្រាតិភោគ ជាអាទិ៍ ត្រូវបកស្រាយថា អានុភាពនៃការផ្អាក មិនបាត់បង់ទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ២១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៤៩៣.– សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើង ចំពោះបុគ្គល ក្រៅពីកូនបំណុល

សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុល ។

(កំណត់)

មាត្រានេះចែងថា ជាករណីលើកលែងនៃគោលការណ៍នៃមាត្រា ៤៩០ ទោះបីជាសកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារត្រូវបានធ្វើឡើងចំពោះអ្នកក្រៅពីកូនបំណុលក៏ដោយ ប្រសិនបើសកម្មភាពនោះត្រូវបានជូនដំណឹងទៅកូនបំណុល ក៏អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងកើតឡើងចំពោះកូនបំណុលដែរ ។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់បំណុលបានរឹបអូសអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកដែលបានផ្តល់ដោយអ្នកធានាដោយវត្ថុ ឬ ក្នុងករណីដែលម្ចាស់បំណុលបានរឹបអូសទ្រព្យសម្បត្តិរបស់កូនបំណុលដែលស្ថិតនៅក្រោមការកាន់កាប់របស់

តតិយជន ប្រសិនបើបានជូនដំណឹងទៅកូនបំណុល អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងកើតឡើងចំពោះកូនបំណុល ។ម្យ៉ាងទៀត ការជូនដំណឹងនៃករណីនេះ គឺមិនមែនមានតែការជូនដំណឹងពីម្ចាស់បំណុលដែលបានធ្វើសកម្មភាពអនុវត្តដោយបង្ខំ ឬ ធ្វើសកម្មភាពចាត់ចែងរក្សាការពារប៉ុណ្ណោះទេ មានរួមទាំងការជូនដំណឹងពីតុលាការផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៤.-** ដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាក នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការ នឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត បន្ទាប់ពីសេចក្តីសម្រេចចូលជាស្ថាពរ ។

(កំណត់)

ទោះបីជាអាជ្ញាយុកាលត្រូវបានផ្អាក ដោយសារហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (មាត្រា ៤៨៩) បានកើតឡើងក៏ដោយ ប្រសិនបើស្ថានភាពអង្គហេតុដែលជាមូលដ្ឋាននៃអាជ្ញាយុកាលមានអត្ថិភាព អាជ្ញាយុកាលនឹងមានដំណើរការជាថ្មី ចាប់ពីពេលដែលហេតុនៃការផ្អាកនោះចប់ (កថាខណ្ឌទី ១) ។

ពេលដែលហេតុនៃការផ្អាកបានចប់ គឺពេលដែលសេចក្តីសម្រេចបានចូលជាស្ថាពរ ចំពោះករណីដែលជាការទាមទារតាមផ្លូវតុលាការ (កថាខណ្ឌទី ២) ។ ចំពោះករណីនៃសកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារ គឺពេលដែលបានបញ្ចប់នីតិវិធីនោះ ។ ចំពោះករណីទទួលស្គាល់វិញ ហេតុនៃការផ្អាកបានចប់ ព្រមគ្នានឹងពេលដែលអានុភាពនៃការផ្អាកកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៥.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការដាស់តឿន និង ដោយការដាស់តឿនតាមផ្លូវតុលាការ

១-ប្រសិនបើអ្នកមានសិទ្ធិបានដាស់តឿន នៅពេលណាមួយក្នុងអំឡុង៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលរំលត់សិទ្ធិ

លើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការដាស់តឿនឡើយ ។ ប៉ុន្តែ ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្តងទៀតនោះដែរ ។

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញា-យុកាល ដោយសារការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្តឹងបានដាស់តឿនជាបន្ត ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូន ទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្តឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្តឹងនោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្តឹង ឬ ការដកពាក្យបណ្តឹងឡើយ ។

៣-ប្រសិនបើអ្នកមានសិទ្ធិបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្តឹងនោះ ត្រូវចាត់ទុកថា អ្នកនោះដាស់តឿនជាបន្ត ក្នុងពេលដែលបណ្តឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះ អះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្តឹងនោះចូលជាស្ថាពរ ។

(កំណត់)

បញ្ញត្តិចាប់ពីមាត្រានេះ ដល់មាត្រា ៤៩៨ ចែងស្តីពីការបង្អង់ការសម្រេចអាជ្ញាយុកាល ។ ការបង្អង់ គឺជាការបញ្ឈប់នៃដំណើរការនៃអាជ្ញាយុកាលតែក្នុងអំឡុងពេលដែលត្រូវបង្អង់នោះប៉ុណ្ណោះ ដូច្នេះ ខុសពីការផ្អាក អំឡុងពេលដែលបានកន្លងផុតទៅ មិនមែនគ្មានន័យទេ ។ ការបង្អង់នូវអាជ្ញាយុកាលគឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលបានសម្រេចប៉ុណ្ណោះ មានន័យថា គ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាល នៅដំណាក់កាលចុងក្រោយដែលជាពេលបញ្ចប់នៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ។

ក្រមនេះបានជ្រើសរើសយករបបបង្អង់ការសម្រេចអាជ្ញាយុកាល តែមិនបានយកជ្រើសរើសរបបបង្អង់ដំណើរការនៃអាជ្ញាយុកាលទេ ។

កថាខណ្ឌទី ១ នៃមាត្រានេះ បានចែងថា នៅពេលដែលអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជិតកន្លងផុតទៅ ប្រសិនបើអ្នកមានសិទ្ធិបាននឹកឃើញបញ្ហានេះ តែពុំមានពេលវេលាដើម្បីចាត់ចែងឱ្យផ្អាកអាជ្ញាយុកាល

ដូចជាការធ្វើបណ្តឹង ជាអាទិ៍ ពេលនោះ អ្នកមានសិទ្ធិអាចទទួលនូវការពន្យារពេលពេលវេលា ៦ ខែ ស្តីពីការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដោយការដាស់តឿនកូនបំណុល (មានន័យថា ការទាមទារក្រៅតុលាការ) ។ អ្នកមានសិទ្ធិអាចចាត់វិធានការផ្អាកដែលបានចែងក្នុងមាត្រា ៤៨៤ ដើម្បីពិគ្រោះនឹងអ្នកច្បាប់ ដូចជាមេធាវី ជាអាទិ៍ ក្នុងអំឡុងពេល ៦ ខែនោះ ។ មាត្រា ១៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុនបញ្ញត្តបង្កើតនូវអានុភាពនៃការផ្អាកអាជ្ញាយុកាលមិនពេញលេញមួយតាមរយៈការដាស់តឿន ប៉ុន្តែ មាត្រានេះបានយល់ឃើញថា តួនាទីនៃការដាស់តឿន គឺការចាត់វិធានការដើម្បីរកពេលវេលា ដើម្បីធ្វើវិធានការផ្អាកជាផ្លូវការ ហេតុដូច្នេះ មាត្រានេះបានចែងថា ការដាស់តឿន គឺជាហេតុមួយនៃការបង្អង់ការសម្រេចអាជ្ញាយុកាល ។

ម្យ៉ាងទៀត ប្រសិនបើចែងឱ្យអាចពន្យារនូវការសម្រេចនៃអាជ្ញាយុកាលម្តង ៦ ខែ តាមរយៈការដាស់តឿនជាបន្តបន្ទាប់រាល់ពេលទៅ គឺមិនត្រឹមត្រូវទេ ។ ឧទាហរណ៍ ចំពោះសិទ្ធិលើបំណុលដែលមានកំណត់ពេលត្រូវសងនៅចុងខែមិថុនា ឆ្នាំ ២០០១ ក្នុងករណីដែលម្ចាស់បំណុលបានដាស់តឿននៅចុងខែ មេសា ឆ្នាំ ២០០៦ ប្រសិនបើម្ចាស់បំណុលអាចដាស់តឿនម្តងទៀតនៅចុងខែ កញ្ញា ឆ្នាំដដែល ដើម្បីពន្យារពេលសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដល់ចុងខែ មីនា ឆ្នាំ ២០០៧ បាន ហើយប្រសិនបើឱ្យអាចធ្វើការដាស់តឿនជាបន្តបន្ទាប់ដូចនេះ គឺអាចរារាំងមិនឱ្យអាជ្ញាយុកាលនោះសម្រេចទាល់តែសោះបាន ដូច្នេះ មិនត្រឹមត្រូវទេ ។ ក្នុងន័យនេះ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ បានចែងថា "ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្តងទៀតនោះដែរ" ។ ប៉ុន្តែ វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ មិនមែនចែងចំពោះករណីដែលម្ចាស់បំណុលដាស់តឿនម្តងទៀត នៅក្នុងអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដើមទេ ហេតុដូច្នេះ ឱ្យតែក្នុងអំឡុងពេលអាជ្ញាយុកាលដើមនេះ អាចធ្វើការដាស់តឿន (ការទាមទារក្រៅតុលាការ) ប៉ុន្មានដងក៏បានដែរ ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការដាស់តឿនចុងក្រោយទេ ។ ឧទាហរណ៍ ក្នុងករណីខាងលើនេះ ម្ចាស់បំណុលដែលបានដាស់តឿននៅចុងខែ មេសា ឆ្នាំ ២០០៦ បានធ្វើការដាស់តឿនទៀត នៅថ្ងៃទី ១៥ ខែ ឧសភា ហើយបន្ទាប់មក នៅចុងខែ ឧសភា ឆ្នាំដដែល ជាបន្តបន្ទាប់ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេចបានមុនចុងខែវិច្ឆិកា ឆ្នាំដដែលទេ ។

កថាខណ្ឌទី ២ នៃមាត្រានេះបានចែងទទួលស្គាល់នូវអានុភាពនៃការបង្អង់ការសម្រេចអាជ្ញាយុកាល ក្រោមល័ក្ខខ័ណ្ឌមួយចំនួន ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបានបង្កើតអានុភាពផ្អាកអាជ្ញាយុកាល ដោយការលើកចោលបណ្តឹង ឬ ដោយការដកពាក្យបណ្តឹងក៏ដោយ ។ ក្រោយពេលមានការលើកបណ្តឹងចោល ជាអាទិ៍ ប្រសិនបើចង់ដាក់ពាក្យបណ្តឹងទី ២ តែអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិដើម បានកន្លងផុតទៅ ហើយថែមទាំងអំឡុងពេល ៦ ខែ បន្ទាប់ពីការដាស់តឿន ក៏បានកន្លងផុតទៅ ការចែងថា មិនមានវិធីសម្រាប់ឱ្យអ្នកមានសិទ្ធិអាចទាត់ចែងបានទេ មិនត្រឹមត្រូវទេ ហេតុដូច្នេះ កថាខណ្ឌទី ២ នេះ ត្រូវបានរៀបចំឡើង ។

ចំពោះករណីដែលអ្នកមានសិទ្ធិ អះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយ នៅក្នុងបណ្តឹង ក៏អានុភាពនៃការបង្អង់

ការសម្រេចអាជ្ញាយុកាល គួរតែត្រូវបានទទួលស្គាល់ដូចគ្នាដែរ ។ ហេតុដូច្នេះ កថាខណ្ឌទី ៣ នៃមាត្រានេះបានចែងអំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៦.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅពេលណាមួយ ក្នុងអំឡុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលនោះ មិនត្រូវបានសម្រេច ចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។

(កំណត់)

មាត្រានេះបានចែងថា ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅពេលណាមួយក្នុងអំឡុង ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលនោះ មិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីពេលដែលអ្នកនោះ ក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។ ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ទេ ពុំអាចចាត់វិធានការឱ្យផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ហើយធ្វើឱ្យអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលនោះបានសម្រេចទៅ នឹងធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់អ្នកទាំងនោះយ៉ាងខ្លាំង ហេតុដូច្នេះ មាត្រានេះត្រូវបានរៀបចំឡើង ។

បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្ត ចំពោះករណីដែលចូលដល់ ៦ ខែ មុនពេលផុតអំឡុងពេលអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលហើយ ហើយលែងមានអ្នកតំណាងដែលច្បាប់បានកំណត់ ព្រមទាំងករណីដែលពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ មុនពេល ៦ ខែ នោះ ហើយនៅតែពុំមានអ្នកតំណាងនោះពេលចូលដល់ ៦ ខែផងដែរ ។

ក្នុងករណីដែលមានការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម (មាត្រា ២០) ចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធនឹងអាជីវកម្មនោះ មិនត្រូវអនុវត្តមាត្រានេះទេ ។

ម្យ៉ាងទៀត ជននៅក្រោមហិតូបត្ថម្ភអាចធ្វើសកម្មភាពឱ្យផ្អាកដោយខ្លួនឯងបាន ដូច្នេះហើយ មិនអាចទទួលនូវការ

ការពារតាមមាត្រានេះបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៧.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្ដីប្រពន្ធ

ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍ឡើយ ។

(កំណត់)

តាមការជាក់ស្ដែង រវាងប្ដីប្រពន្ធ ការចាត់វិធានការឱ្យផ្អាកអាជ្ញាយុកាលមិនមែនជាការងារស្រួលទេ ហេតុដូច្នេះ មាត្រានេះបានចែងថា ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍ឡើយ ។

ការរលាយអាពាហ៍ពិពាហ៍ គឺក្រៅពីការរលាយដោយការលែងលះ មានរួមទាំងការរលាយដោយមរណភាពរបស់សហព័ទ្ធម្ខាង ដោយការប្រកាសអំពីការបាត់ខ្លួន និង ដោយការលុបចោលអាពាហ៍ពិពាហ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៨.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើអ្នកមានសិទ្ធិមិនអាចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្ដិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្ដិនោះ បានកន្លងផុតឡើយ ។

(កំណត់)

ប្រសិនបើអ្នកមានសិទ្ធិមិនអាចធ្វើវិធានការឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ដូចជាខ្យល់ព្យុះ រញ្ជួយផែនដី ទឹកជំនន់ ជាដើម ឬ "ប្រធានសក្តិផ្សេង" ដូចជា កុប្បកម្ម សង្គ្រាម ជាដើម នៅពេលណាមួយក្នុង ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីហេតុនោះបានកន្លងផុតឡើយ ។

នៅក្នុងមាត្រា ១៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន បានចែងដោយប្រើឃ្លា "ពេលដែលអំឡុងពេលអាជ្ញាយុកាល (នៃការរំលត់សិទ្ធិលើបំណុល) កន្លងផុតទៅ" ដូច្នេះហើយ ឧទាហរណ៍ ក្នុងករណីដែលប្រធានសក្តិបានកន្លងផុត ២ ថ្ងៃ មុនថ្ងៃផុតអាជ្ញាយុកាលនោះ មានការសង្ស័យថា មាត្រា ១៦១ មិនអាចអនុវត្តចំពោះករណីនេះបានទេ ។ រីឯក្នុងមាត្រានេះវិញ មានឃ្លា "នៅពេលណាមួយក្នុង ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល" ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា ទោះបីជាហេតុដែលរារាំងមិនឱ្យធ្វើវិធានការឱ្យផ្អាកអាជ្ញាយុកាលបានរលត់ មុនពេលផុតអំឡុង ពេលអាជ្ញាយុកាលក៏ដោយ ប្រសិនបើពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីចាត់វិធានការឱ្យផ្អាក តាមទស្សនៈទូទៅនៃប្រតិបត្តិការជំនួញទេ ក៏អាចអនុវត្តរបបបង្អង់នូវការសម្រេចអាជ្ញាយុកាលបានដែរ ។ ម្យ៉ាងទៀត មាត្រា ១៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន បានចែងថា អាជ្ញាយុកាលមិនត្រូវបានសម្រេចក្នុងអំឡុងពេល "២ សប្តាហ៍" ឡើយ បន្ទាប់ពីប្រធានសក្តិបានកន្លងផុតទៅ ។ ប៉ុន្តែ អំឡុងពេល "២ សប្តាហ៍" នេះ មិនមែនជាអំឡុងពេលដែលមានភាពសកលទេ ដូច្នេះហើយ ក្នុងនេះបានកំណត់ "៦ ខែ" ដើម្បីតម្រូវទៅនឹងមាត្រាផ្សេងទៀតស្តីពីការបង្អង់នូវការសម្រេចអាជ្ញាយុកាលផងដែរ ។

ម្យ៉ាងទៀត មិនត្រឹមតែមាត្រានេះទេ ចាប់ពីមាត្រា ៤៩៥ នៃក្រមនេះ ក៏បានជ្រើសរើសរបបបង្អង់នូវការសម្រេចអាជ្ញាយុកាលដែរ តែមិនបានជ្រើសរើសរបបបង្អង់ដំណើរការនៃអាជ្ញាយុកាល ដូចដែលប្រទេសអាល្លឺម៉ង់ ឬ ប្រទេសវៀតណាម បានជ្រើសរើសទេ (មាត្រា ២០៦ និង មាត្រា ២០៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, ចំណុច ៦ កថាខណ្ឌទី ១ មាត្រា ១៧០ នៃក្រមរដ្ឋប្បវេណីវៀតណាម) ។ មូលហេតុចម្បងក្នុងការជ្រើសរើសរបបបង្អង់ការសម្រេចអាជ្ញាយុកាល (ប្រសិនបើពន្យល់អំពីករណីនៃមាត្រា ៤៩៨) គឺដោយសារតែបានពិចារណាទៅឃើញថា មានការពិបាកនឹងគណនាអំឡុងពេលដែលមិនអាចធ្វើឱ្យផ្អាកអាជ្ញាយុកាលដោយសារប្រធានសក្តិ នាពេលក្រោយ ដើម្បីដកអំឡុងពេលនោះចេញពីអំឡុងពេលគណនាអាជ្ញាយុកាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៤៩៩.-** តាវកាលិកដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចំពោះតាវកាលិកដែលត្រូវបានផ្តល់ ដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ទោះបីជាអ្នកនោះផ្តល់តាវកាលិក ដោយមិនបានដឹងថា ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ក៏អ្នកនោះមិនអាចទាមទារឱ្យសងតាវកាលិកនោះវិញឡើយ ។

(កំណត់)

ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្រមនេះបានយករបបរំលត់សិទ្ធិលើបំណុលដែលជាសិទ្ធិសារធាតុមកធ្វើជាមូលដ្ឋាន (មាត្រា ៤៨០) ។ ដូច្នេះ ក្នុងករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច ក្រោយពីអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិបានកន្លងផុតទៅ ដោយមិនបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ករណីនេះនឹងបង្កើតនូវចម្ងល់មួយថា តើកូនបំណុលអាចទាមទារឱ្យប្រគល់វិញនូវតាវកាលិកដែលខ្លួនបានផ្តល់ដោយផ្អែកលើមាត្រា ៧៣៨ (ការសងដោយគ្មានកាតព្វកិច្ច) ដែរ ឬទេ ? ហេតុដូច្នេះ មាត្រានេះបានបញ្ជាក់ច្បាស់លាស់ថា ទោះបីជាអ្នកដែលផ្តល់តាវកាលិក បានផ្តល់តាវកាលិកនោះ ដោយមិនបានដឹងថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះបានសម្រេចក៏ដោយ ក៏មិនអាចទាមទារឱ្យប្រគល់មកវិញបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៨ នៃក្រឹត្យ-ច្បាប់ លេខ ៣៨, មាត្រា ៩៣៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, កថាខណ្ឌទី ១ មាត្រា ២១៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៥០០.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ មានអំឡុងពេល ១០ (ដប់) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។ បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ។

(កំណត់)

តើគួរកំណត់អំឡុងពេលអាជ្ញាយុកាលប៉ុន្មានឆ្នាំជាការត្រឹមត្រូវនោះ គឺជាបញ្ហាមួយដែលមិនអាចរកចម្លើយសមហេតុសមផលបានទេ ។ ក៏ប៉ុន្តែ ដោយពិចារណាអំពីតុល្យភាព និង អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមាន ៥ ឆ្នាំនោះ ហើយ ម្យ៉ាងទៀត ច្បាប់កម្ពុជាភាគច្រើន បានកំណត់ពេលវេលាខ្លីសម្រាប់អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដូច្នេះហើយ ក្នុងមាត្រានេះ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ត្រូវបានកំណត់ ១០ ឆ្នាំ ។

ម្យ៉ាងទៀត ជាគោលការណ៍ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺ ៥ ឆ្នាំ ( មាត្រា ៤៨២) រីឯកម្មសិទ្ធិវិញ មិនត្រូវរលត់ដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ ។

# ជំពូកទី ៩ អនុប្បទានសិទ្ធិលើបំណុល ការទទួលភាតព្វកិច្ច

## ផ្នែកទី ១ អនុប្បទានសិទ្ធិលើបំណុល

( កំណត់)

អនុប្បទានសិទ្ធិលើបំណុល (cession de créance) គឺជាការផ្ទេរសិទ្ធិលើបំណុលពីអនុប្បទាយី ទៅអនុប្បទានិក ដោយរក្សានូវអត្តសញ្ញាណដើមនៃសិទ្ធិលើបំណុលនោះ ។ ក្នុងន័យនេះ អនុប្បទានសិទ្ធិលើបំណុល ខុសគ្នាពីនវកម្ម (novation) ។ ម្យ៉ាងវិញទៀត អនុប្បទានសិទ្ធិលើបំណុល ក៏ខុសគ្នាផងដែរពីអនុប្បទានឋានៈក្នុងកិច្ចសន្យា ។ ក៏ប៉ុន្តែ ប្រសិនបើដាក់បញ្ចូលនូវបញ្ញត្តិសម្រាប់កំណត់និយមន័យនៃអនុប្បទានសិទ្ធិលើបំណុលនៅក្នុងនេះ អាចមានការបារម្ភថានឹងមានការយល់ច្រឡំ ពីព្រោះនិយមន័យនៃអនុប្បទានសិទ្ធិលើបំណុលមានការពិបាកយល់ និង ភាពអរូបី ។ ម្យ៉ាងទៀត ដោយសារបញ្ញត្តិស្ដីពីភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល ត្រូវបានដាក់បញ្ចូលនៅក្នុងមាត្រាខាងក្រោមរួចហើយ មិនចាំបាច់ឱ្យមានបញ្ញត្តិសម្រាប់កំណត់និយមន័យនៃអនុប្បទានសិទ្ធិលើបំណុលទៀតទេ ។ ដូច្នេះហើយ ក្នុងក្រមនេះ មិនមានបញ្ញត្តិសម្រាប់កំណត់និយមន័យនៃអនុប្បទានសិទ្ធិលើបំណុលទេ ក៏ប៉ុន្តែ ចាប់ផ្តើមដោយបញ្ញត្តិស្តីពីភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន ។

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន មិនមែនមានតែបញ្ញត្តិស្តីពីអនុប្បទានសិទ្ធិលើបំណុលប៉ុណ្ណោះទេ ក៏ប៉ុន្តែ មានបញ្ញត្តិស្តីពីនវកម្មដោយផ្លាស់ប្តូរម្ចាស់បំណុលផងដែរ ទៅក្នុងបទប្បញ្ញត្តិទូទៅនៃគន្ថីស្តីពីសិទ្ធិលើបំណុល ។ ក្រមរដ្ឋប្បវេណីបារាំងមានបញ្ញត្តិស្តីពី "អនុប្បទានសិទ្ធិលើបំណុល ឬ ទ្រព្យសម្បត្តិអរូបិយផ្សេងទៀត (Du transport des créances et des autres droits incorporels)" នៅក្នុងជំពូកស្តីពីការលក់ទិញ ។ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក៏មានបញ្ចូលផងដែរនូវបញ្ញត្តិស្តីពីអនុប្បទានសិទ្ធិលើបំណុល ទៅក្នុងបទប្បញ្ញត្តិទូទៅនៃគន្ថីស្តីពីសិទ្ធិលើបំណុលដែរ ប៉ុន្តែ មិនមានបញ្ញត្តិស្តីពីនវកម្មទេ ។ ដោយហេតុនេះ ទោះបីជាក្រមនេះមានបញ្ញត្តិស្តីពីនវកម្ម ( មាត្រា ៤៧៦ ដល់ មាត្រា ៤៧៨) ក៏ដោយ ក៏មាត្រាទាំងនេះគ្រាន់តែចែងអំពីករណីដែលកាតព្វកិច្ចថ្មីត្រូវបានបង្កើតជំនួសកាតព្វកិច្ចចាស់ រវាងគូភាគីដដែលប៉ុណ្ណោះ

ហើយគ្មានបញ្ញត្តិស្តីពីនីតិកម្មដែលម្ចាស់បំណុល ឬ កូនបំណុល ត្រូវបានផ្លាស់ប្តូរទេ ។

**មាត្រា ៥០១.-** ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន

១-សិទ្ធិលើបំណុល អាចធ្វើអនុប្បទានទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ។ ក្នុងករណីនេះ អនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ។

២-ទោះបីជាសិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបានក៏ដោយ ក៏គូភាគីអាចហាមមិនឱ្យធ្វើអនុប្បទាន ដោយការបង្ហាញឆន្ទៈបានដែរ ។

៣-ការបង្ហាញឆន្ទៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការបង្ហាញឆន្ទៈនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះមានកំហុសដ៏ធ្ងន់ធ្ងរ ។

(កំណត់)

(១) សិទ្ធិលើបំណុល គឺខុសពីសិទ្ធិប្រត្យក្សត្រង់ថា សិទ្ធិប្រត្យក្សមានលក្ខណៈដាច់ខាត (សិទ្ធិដែលអាចតតាំងចំពោះបុគ្គលគ្រប់រូប) និង អាចធ្វើអនុប្បទានបាន ដោយឡែកសិទ្ធិលើបំណុលវិញ មានតែភាពមិនដាច់ខាត (សិទ្ធិដែលអាចតតាំងបានតែចំពោះកូនបំណុល) ។ ដូច្នេះ សិទ្ធិលើបំណុលអាចត្រូវគេគិតថា មិនអាចធ្វើអនុប្បទានបាន ។ កថាខណ្ឌទី ១ នៃមាត្រានេះ បានបញ្ជាក់យ៉ាងច្បាស់ដោយចែងថា ជាគោលការណ៍ សិទ្ធិលើបំណុលអាចធ្វើអនុប្បទានបានដោយសេរី ។ ក៏ប៉ុន្តែ បញ្ញត្តិនេះក៏ចែងដើម្បីឱ្យប្រុងប្រយ័ត្នដែរថា មានសិទ្ធិលើបំណុលខ្លះដែលមិនអាចធ្វើអនុប្បទានបានទេ ដោយសារតែសិទ្ធិលើបំណុលទាំងនោះ មានអត្ថន័យតែរវាងម្ចាស់បំណុល និង កូនបំណុលប៉ុណ្ណោះ ដោយផ្អែកទៅតាមលក្ខណៈនៃសិទ្ធិលើបំណុលនោះ ។

(២) កថាខណ្ឌទី ២ ចែងថា ភាគីអាចធ្វើការសន្យាពិសេសហាមឃាត់មិនឱ្យធ្វើអនុប្បទានសិទ្ធិលើបំណុលបាន ។ កថាខណ្ឌទី ៣ ចែងថា ការបង្ហាញឆន្ទៈអំពីការសន្យាហាមមិនឱ្យធ្វើអនុប្បទាន មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការណ៍នោះឡើយ (លើកលែងតែតតិយជននោះមិនបានដឹងដោយសារមានកំហុសធ្ងន់ធ្ងរ) ។ ការលើកលែងចំពោះករណីដែលតតិយជននោះមានកំហុសដ៏ធ្ងន់ធ្ងរ ត្រូវបានចែងឡើងដោយយោងទៅលើទ្រឹស្តីជាយុត្តិសាស្ត្ររបស់ជប៉ុន ។

(៣) បញ្ញត្តិពិសេសស្តីពីអនុប្បទានសិទ្ធិលើបំណុលដែលនឹងកើតមាននាពេលអនាគត ឬ សិទ្ធិលើបំណុលដែលប្រមូលផ្តុំ មិនត្រូវបានរៀបចំដោយឡែកទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦៨៩ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣៩៩ និង មាត្រា ៤០០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ១៦៤ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ប្រទេសស្វីស

## មាត្រា ៥០២.- ការបង្កើតអនុប្បទានសិទ្ធិលើបំណុល

អនុប្បទានសិទ្ធិលើបំណុល ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីយកអនុប្បទានសិទ្ធិលើបំណុលនេះទៅតតាំង ចំពោះកូនបំណុល និង តតិយជន ត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ខាងក្រោមនេះ ។

(កំណត់)

(១) ស្របគ្នាទៅនឹងគោលការណ៍នៃការបង្ហាញឆន្ទៈ (មាត្រា ១៣៣) ដែលត្រូវយកមកអនុវត្តចំពោះការផ្លាស់ប្តូរសិទ្ធិប្រត្យក្ស (ដូចជា ការផ្ទេរកម្មសិទ្ធិ) វាក្យខណ្ឌទី ១ នៃមាត្រានេះចែងថា អនុប្បទានសិទ្ធិលើបំណុល ត្រូវបង្កើតអានុភាពដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ ហើយមិនតម្រូវឱ្យរៀបចំលិខិតកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ តាមទម្រង់លិខិតយថាភូត (acte authentique) ឬ លិខិតឯកជន (acte sous seing privé) ទេ ។

(២) ទោះបីជាអនុប្បទានសិទ្ធិលើបំណុលមានអានុភាពដោយសារតែការព្រមព្រៀងគ្នារវាងភាគីប៉ុណ្ណោះក៏ដោយ ក៏វាក្យខណ្ឌទី ២ នៃមាត្រានេះចែងថា អនុប្បទានិកត្រូវបំពេញល័ក្ខខ័ណ្ឌតតាំង ដើម្បីតតាំងអនុប្បទានសិទ្ធិលើបំណុលចំពោះកូនបំណុល ឬ តតិយជន ។ ចំពោះអត្ថន័យ និង ខ្លឹមសារនៃល័ក្ខខ័ណ្ឌតតាំង សូមមើលមាត្រាខាងក្រោម ។

## មាត្រា ៥០៣.- ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬ តតិយជនផ្សេងទៀតបានឡើយ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុល ឬ កូនបំណុលមិនបានយល់ព្រម ចំពោះអនុប្បទាយី ឬ អនុប្បទានិក ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។

(កំណត់)

(១) សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ (nominative claim, créance nominative) គឺជាសិទ្ធិលើបំណុលដែលម្ចាស់បំណុលត្រូវបានកំណត់ជាក់លាក់ ។ មានសិទ្ធិលើបំណុលច្រើនប្រភេទផ្សេងទៀតដូចជា សិទ្ធិលើបំណុលដែលកំណត់ការបញ្ជា (claim payable to order) ឬ សិទ្ធិលើបំណុលដែលមិនកំណត់ឈ្មោះ (claim payable to bearer) ។ សិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ គឺជាសិទ្ធិលើបំណុលដែលសាមញ្ញបំផុត ។ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌដែលអនុប្បទានិកអាចតតាំងចំពោះតតិយជនបាន អំពីអានុភាពនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ ។ ក៏ប៉ុន្តែ ទោះបីជាកូនបំណុលក៏ជាតតិយជន ក្រៅពីភាគីនៃអនុប្បទានសិទ្ធិលើបំណុល (អនុប្បទាយីដែលជាម្ចាស់បំណុល និង អនុប្បទានិក) ផងដែរក៏ដោយ ក៏កូនបំណុលមានឋានៈខុសគ្នាពីតតិយជនដទៃដែរ ។ ដូច្នេះហើយ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ចែងអំពីការចាត់ចែងផ្សេងគ្នាចំពោះជនទាំងពីរប្រភេទនេះ ។

(២) កថាខណ្ឌទី ១ ចែងថា អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬតតិយជនផ្សេងទៀតបានទេ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុលអំពីអនុប្បទាននេះ ឬ បើកូនបំណុលមិនបានផ្តល់នូវការយល់ព្រមអំពីអនុប្បទាននេះ ចំពោះអនុប្បទាយី ឬ អនុប្បទានិក ។ ក្នុងករណីនេះ មិនមានការបញ្ជាក់អំពីទម្រង់នៃការជូនដំណឹង ឬ ការយល់ព្រមទេ ។ ដោយហេតុនេះ ការជូនដំណឹង ឬ ការយល់ព្រម អាចធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន ។ ដរាបណាល័ក្ខខ័ណ្ឌនេះត្រូវបានបំពេញ អនុប្បទានិកអាចតតាំងអនុប្បទានសិទ្ធិលើបំណុលចំពោះកូនបំណុលបាន ហើយអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ក្នុងនាមជាម្ចាស់បំណុលថ្មីបាន ។

(៣) ផ្ទុយទៅវិញ កថាខណ្ឌទី ២ ចែងថា ដើម្បីតតាំងអនុប្បទានសិទ្ធិលើបំណុល ចំពោះតតិយជនដែលមិនមែនជាកូនបំណុល (ឧទាហរណ៍ តតិយជនដែលអះអាងថា ខ្លួនបានទទួលអនុប្បទានសិទ្ធិលើបំណុល) ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ត្រូវធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។ ក្នុងន័យនេះ លិខិតដែលមានកាលបរិច្ឆេទស្ថាពរ សំដៅទៅលើឯកសារដែលមានភាពច្បាស់លាស់ និង ភាពត្រឹមត្រូវនៃកាលបរិច្ឆេទដែលត្រូវបានសរសេរលើឯកសារនោះ ត្រូវបានធានា ដូចជាឯកសារដែលរៀបចំដោយស្ថាប័នរដ្ឋ ឬ លិខិតយថាភូតដែលរៀបចំដោយសារការី ជាដើម ។ ចំពោះបញ្ហាថា ឯកសារណាខ្លះដែលត្រូវទទួលស្គាល់ថាជាលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៥០៤.– អាទិភាពនៃអនុប្បទានសិទ្ធិលើបំណុល ជាច្រើនដង

១-ក្នុងករណីដែលធ្វើអនុប្បទានសិទ្ធិលើបំណុលតែមួយ ត្រូវបានធ្វើឡើងជាច្រើនដង អាទិភាពនៃអនុប្បទាននោះ ត្រូវកំណត់ទៅតាមលំដាប់នៃពេលដែលការជូនដំណឹង

ដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ បានដល់កូនបំណុល ឬ ពេលដែលកូនបំណុលបានយល់ព្រមដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ។ ក្នុងករណីនេះ កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិកដែលមានអាទិភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមិនអាចកំណត់លំដាប់នៃពេលដែលការជូនដំណឹងបានដល់ ឬ ពេលដែលកូនបំណុលបានយល់ព្រមទេ ត្រូវចាត់ទុកថា ការជូនដំណឹងនីមួយៗបានដល់កូនបំណុល នៅពេលជាមួយគ្នា ឬ កូនបំណុលបានយល់ព្រមនៅពេលជាមួយគ្នា ។ ក្នុងករណីនេះ អនុប្បទានិកនីមួយៗអាចទាមទារឱ្យកូនបំណុលសងចំពោះសិទ្ធិលើបំណុលទាំងអស់ដែលខ្លួនបានទទួលដោយអនុប្បទាន ។ ពេលដែលកូនបំណុលបានសងចំពោះម្ចាស់បំណុលណាម្នាក់ កាតព្វកិច្ចត្រូវរលត់ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបាន ដោយតម្កល់នូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចនោះ ។

(កំណត់)

(១) យោងតាមបញ្ញត្តិនៃមាត្រា ៥០៣ ខាងលើនេះ ប្រសិនបើអនុប្បទានិកនៃសិទ្ធិលើបំណុលបានបំពេញល័ក្ខខ័ណ្ឌដើម្បីតតាំងអនុប្បទានសិទ្ធិលើបំណុលចំពោះកូនបំណុលហើយ អនុប្បទានិកអាចអះអាងសិទ្ធិលើបំណុលចំពោះកូនបំណុល (អាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច) បាន ។ ប្រសិនបើអនុប្បទានិកនៃសិទ្ធិលើបំណុលបានបំពេញល័ក្ខខ័ណ្ឌដើម្បីតតាំងអនុប្បទានសិទ្ធិលើបំណុលចំពោះតតិយជនហើយ អនុប្បទានិកអាចអះអាងចំពោះតតិយជនថា ខ្លួនបានទទួលអនុប្បទានសិទ្ធិលើបំណុល (បានក្លាយជាម្ចាស់បំណុល) បាន ។

(២) ប្រសិនបើល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលជាការជូនដំណឹង ការតតាំងនេះនឹងត្រូវមានអានុភាពនៅពេលដែលការជូនដំណឹងបានទៅដល់កូនបំណុល ។ ប្រសិនបើវាជាការយល់ព្រម ការតតាំងនេះនឹងមានអានុភាពនៅពេលការយល់ព្រមត្រូវបានផ្តល់ ។

(៣) ប្រសិនបើបំណុលត្រូវបានធ្វើអនុប្បទានដល់បុគ្គលពីរនាក់ អនុប្បទានិកណាដែលបានបំពេញល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានមុនគេ មានអាទិភាព ។ លំដាប់នៃពេលបំពេញល័ក្ខខ័ណ្ឌតតាំង មិនកំណត់យកតាមកាលបរិច្ឆេទស្ថាពរទេ ប៉ុន្តែត្រូវកំណត់ទៅតាមពេលវេលានៃការមកដល់នូវការជូនដំណឹង ឬ ការយល់ព្រម (ពេលបង្កើតអានុភាព) ។

(៤) ប្រសិនបើមានតតិយជនពីរនាក់ ឬ ច្រើននាក់បានបំពេញល័ក្ខខ័ណ្ឌតតាំង កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចចំពោះអនុប្បទានិកណាដែលមានអាទិភាព ។

(៥) ប្រសិនបើលំដាប់នៃពេលសម្រាប់បំពេញល័ក្ខខ័ណ្ឌតតាំងមិនអាចកំណត់បានទេ នោះអនុប្បទានិកម្នាក់ៗអាចទាមទារឱ្យកូនបំណុលសងកាតព្វកិច្ចដែលត្រូវបានធ្វើអនុប្បទានទាំងស្រុងបាន ។ ដើម្បីដោះស្រាយបញ្ហានេះ កូនបំណុលអាចធ្វើការតម្កល់នូវវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តកាតព្វកិច្ច ហើយប្រសិនបើកូនបំណុលបានអនុវត្តនូវកាតព្វកិច្ច ចំពោះអនុប្បទានិកណាមួយហើយ កាតព្វកិច្ចនោះនឹងត្រូវរលត់ (ដោយមិនគិតថា កូនបំណុលដឹង ឬ មិនដឹងថា មានអនុប្បទានិកផ្សេងទៀត) ។ ប្រសិនបើកូនបំណុលធ្វើការតម្កល់ អនុប្បទានិកនីមួយៗនឹងធ្វើការទាមទារទៅការិយាល័យតម្កល់ឱ្យធ្វើការប្រគល់ឱ្យ ។ ប្រសិនបើអនុប្បទានិកពីរ ឬ ច្រើននាក់ទាមទារឱ្យធ្វើការប្រគល់ឱ្យ ហើយមានភាពមិនច្បាស់ថាតើអនុប្បទានិកមួយណាមានអាទិភាព នោះអនុប្បទានិកនីមួយៗមានសិទ្ធិស្មើៗគ្នា ហើយអាចទាមទារឱ្យប្រគល់ឱ្យនូវចំនួនទឹកប្រាក់ដែលគណនាដោយការយកចំនួននៃសិទ្ធិលើបំណុល មកចែកតាមចំនួននៃអនុប្បទានិក (ប្រសិនបើគ្រប់អនុប្បទានិកទាំងអស់ត្រូវបានធ្វើអនុប្បទាននូវចំនួនសរុបនៃសិទ្ធិលើបំណុល) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥០៥.–** អានុភាពនៃការជូនដំណឹង និង ការយល់ព្រម

១-ប្រសិនបើកូនបំណុលធ្វើការយល់ព្រមដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ដោយគ្មានការតវ៉ា ទោះបីជាខ្លួនមានហេតុដែលអាចតតាំងចំពោះអនុប្បទាយីក៏ដោយ ក៏កូនបំណុលមិនអាចយកហេតុនោះតតាំងចំពោះអនុប្បទានិកបានឡើយ ។[១០] ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរារាំងក្នុងការយកវត្ថុវិញ បើកូនបំណុលប្រគល់វត្ថុណាឱ្យអនុប្បទាយីដើម្បីរំលត់កាតព្វកិច្ច របស់ខ្លួន ឬ ក្នុងការចាត់ទុកថា កាតព្វកិច្ចមិនកើតឡើង បើកូនបំណុលទទួលបន្ទុកនូវ កាតព្វកិច្ចចំពោះអនុប្បទាយី ដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ។

២-ប្រសិនបើអនុប្បទាយីបានជូនដំណឹងអំពីអនុប្បទានតែប៉ុណ្ណោះ កូនបំណុលអាចយកហេតុដែលកើតឡើងចំពោះអនុប្បទាយី រហូតដល់ពេលខ្លួនទទួលដំណឹងនោះទៅតតាំងចំពោះអនុប្បទានិកបាន ។

(កំណត់)

---

[១០] វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥០៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(១) ក្នុងករណីដែលមានតែការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌតតាំងទេ (មានន័យថា មិនមានការយល់ព្រម) នោះកូនបំណុលអាចយកហេតុដែលអាចតតាំងចំពោះម្ចាស់បំណុល (អនុប្បទាយី) មកតតាំងចំពោះអនុប្បទានិកបាន ។

(២) ប្រសិនបើកូនបំណុលផ្ដល់ការយល់ព្រមដោយគ្មានការតវ៉ា កូនបំណុលមិនអាចយកហេតុណាមួយដែលខ្លួនអាចតតាំងចំពោះអនុប្បទាយីមុនពេលផ្ដល់ការយល់ព្រមនោះ មកតតាំងចំពោះអនុប្បទានិកបានទេ ។ ក៏ប៉ុន្តែ ប្រសិនបើកូនបំណុលបានបង់ប្រាក់ដល់អនុប្បទាយីដើម្បីរំលត់កាតព្វកិច្ច កូនបំណុលនោះអាចទាមទារឱ្យអនុប្បទាយីសងប្រាក់នោះមកវិញបាន ។ ប្រសិនបើកូនបំណុលទទួលបន្ទុកកាតព្វកិច្ចមួយទៀត ដើម្បីរំលត់កាតព្វកិច្ចដើម (ឧទាហរណ៍ ប្រសិនបើកាតព្វកិច្ចដើម ត្រូវបានធ្វើនវកម្មទៅកាតព្វកិច្ចថ្មី) នោះកាតព្វកិច្ចថ្មីនោះអាចត្រូវបានចាត់ទុកថា មិនបានកើតឡើងទេ ។ ករណីទាំងពីរនេះ អាចទទួលយកបានពីទស្សនៈនៃសមធម៌រវាងគូភាគី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥០៦.-** អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ

បញ្ញត្តិនៃច្បាប់ពិសេសត្រូវយកមកអនុវត្ត ចំពោះអនុប្បទានសិទ្ធិលើបំណុលដែលកំណត់ការបញ្ជា ឬ សិទ្ធិលើបំណុលផ្សេងដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ ។

(កំណត់)

ក្រមរដ្ឋប្បវេណីនេះមិនមានបញ្ញត្តិស្តីពីអនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រទេ ហើយទុកឱ្យបញ្ហានេះគ្រប់គ្រងដោយច្បាប់ទាក់ទងនឹងឧបករណ៍ដែលអាចជួញដូរបាន ។ ដោយសារតែសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ ត្រូវបានផ្ទេរតាមរយៈបិដ្ឋិលេខលើមូលប័ត្រ (ឬ ការប្រគល់មូលប័ត្រ) យើងមិនចាំបាច់ពិចារណាអំពីល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទាន ដូចក្នុងករណីនៃសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៦៩ ដល់មាត្រា ៤៧២ នៃក្រមរដ្ឋប្បវេណីជប៉ុន (សិទ្ធិលើបំណុលដែលកំណត់ការបញ្ជា (claim payable to order) និង សិទ្ធិលើបំណុលកំណត់ឈ្មោះដែលអាចសងទៅអ្នកដែលកាន់លិខិតបញ្ជាក់សិទ្ធិលើបំណុល (claim payable to creditor or bearer) ។

## ផ្នែកទី ២ ការទទួលភារកាតព្វកិច្ច

(កំណត់)

(១) ក្រមរដ្ឋប្បវេណីនេះ មិនមានបញ្ញត្តអំពីនិយមន័យនៃការទទួលកាតព្វកិច្ចឡើយ ។

(២) ការទទួលកាតព្វកិច្ចមានច្រើនប្រភេទ ។ ក្នុងចំណោមនេះ ក្រមនេះជ្រើសរើសយកគោលការណ៍នៃការទទួលកាតព្វកិច្ចដំណាលគ្នា ហើយក្នុងករណីដែលមានភាពច្បាស់លាស់ថា មានឆន្ទៈឱ្យរួចផុតពីកាតព្វកិច្ច នោះទទួលស្គាល់នូវការទទួលកាតព្វកិច្ចដែលឱ្យកូនបំណុលដើមរួចផុតពីកាតព្វកិច្ច ។

(៣) ក្នុងករណីនៃការទទួលកាតព្វកិច្ចដំណាលគ្នា កូនបំណុលមិនត្រូវបានលើកលែងឱ្យរួចកាតព្វកិច្ចទេ ហើយក៏អាចសងដោយខ្លួនឯងបានដែរ ហេតុដូច្នេះ ការទទួលយកកាតព្វកិច្ចអាចធ្វើទៅបាន ទោះបីជាវាផ្ទុយនឹងឆន្ទៈរបស់កូនបំណុលក៏ដោយ ។ ការចែងបែបនេះស្របនឹងបញ្ញត្តិដែលចែងថា ការសងដោយតតិយជន អាចធ្វើទៅបាន ទោះបីជាការសងនេះផ្ទុយនឹងឆន្ទៈរបស់កូនបំណុលក៏ដោយ ។

**មាត្រា ៥០៧.-** ភាពដែលអាចទទួលកាតព្វកិច្ចបាន

១-ចំពោះកាតព្វកិច្ចដែលអាចអនុវត្តបានដោយតតិយជនក្រៅពីកូនបំណុល តតិយជនអាចទទួលកាតព្វកិច្ចនោះបាន ។

២-គូភាគីអាចហាមមិនឱ្យតតិយជនទទួលកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈបាន ។

(កំណត់)

មាត្រានេះចែងថា ជាគោលការណ៍ ការទទួលកាតព្វកិច្ចអាចធ្វើទៅបាន និង ចែងទៀតថា ការទទួលកាតព្វកិច្ចអាចត្រូវហាមឃាត់ ដោយគូភាគី (គូភាគីនៅទីនេះមិនមែនមានន័យថាជាភាគីនៃការទទួលកាតព្វកិច្ចទេ ប៉ុន្តែ សំដៅទៅលើភាគីនៃកាតព្វកិច្ចនោះផ្ទាល់តែម្តង ដូចជាភាគីនៃកិច្ចសន្យាដែលបង្កើតកាតព្វកិច្ច) ។ ដូចដែលបានចែងក្នុងមាត្រា ៥០៩ ខាងក្រោមនេះ ជាគោលការណ៍ អ្នកទទួលកាតព្វកិច្ច និង កូនបំណុលដើមត្រូវទទួលបន្ទុកកាតព្វកិច្ចដោយសាមគ្គីភាព ប៉ុន្តែ បញ្ញត្តិនេះមិនបានហាមឃាត់មិនឱ្យធ្វើការព្រមព្រៀងពិសេសអំពីការតវ៉ា ឬ ការទាមទារសំណងជាដើមនោះទេ (បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងបញ្ហានេះ ត្រូវបានរៀបចំដោយឡែក) ។

**មាត្រា ៥០៨.-** ការបង្កើតនូវការទទួលកាតព្វកិច្ច

ការទទួលកាតព្វកិច្ច ត្រូវមានអានុភាព ដោយការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួល ឬ ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង អ្នកទទួល ។

(កំណត់)

មាត្រានេះមិនបានចែងអំពីករណីដែលមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុល កូនបំណុល និង អ្នកទទួលឡើយ ។ មូលហេតុគឺដោយសារតែការយល់ព្រមរបស់ម្ចាស់បំណុល មិនមានភាពចាំបាច់ទេ ក្នុងករណីនៃការទទួលកាតព្វកិច្ចដំណាលគ្នា ។ ឆន្ទៈរបស់ម្ចាស់បំណុល ត្រូវបានគិតពិចារណា ដោយមាត្រា ៥០៧ និង មាត្រា ៥០៩ ។

**មាត្រា ៥០៩.-** សិទ្ធិរបស់ម្ចាស់បំណុល

១-ទោះបីជាមានការទទួលកាតព្វកិច្ចក៏ដោយ ក៏ម្ចាស់បំណុលមិនបាត់បង់នូវសិទ្ធិចំពោះកូនបំណុលដែរ ។ ក្នុងករណីនេះ កូនបំណុល និង អ្នកទទួលកាតព្វកិច្ច ត្រូវទទួលបន្ទុកកាតព្វកិច្ចដោយសាមគ្គីភាព ចំពោះម្ចាស់បំណុល ។

២-អ្នកទទួលកាតព្វកិច្ច អាចឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ច ដោយទទួលការយល់ព្រមពីម្ចាស់បំណុលបាន ។

(កំណត់)

(១) កថាខណ្ឌទី ១ ចែងថា ការទទួលកាតព្វកិច្ច ជាគោលការណ៍ គឺជាការទទួលកាតព្វកិច្ចដំណាលគ្នា ។ ក្នុងន័យនេះ ទោះបីជាការទទួលកាតព្វកិច្ចត្រូវបានធ្វើឡើងក៏ដោយ ក៏ម្ចាស់បំណុលនៅតែអាចទាមទារឱ្យកូនបំណុលដើមអនុវត្តកាតព្វកិច្ចបានដែរ ។ ដូច្នេះ កូនបំណុល និង អ្នកទទួលត្រូវទទួលកាតព្វកិច្ចចំពោះម្ចាស់បំណុល ។ ប្រសិនបើបុគ្គលណាម្នាក់ក្នុងចំណោមអ្នកទាំងពីរបានសងកាតព្វកិច្ច បុគ្គលដែលមិនបានអនុវត្តនោះក៏ត្រូវរួចផុតពីកាតព្វកិច្ចដែរ ហេតុដូច្នេះ កថាខណ្ឌទី ១ នេះបញ្ជាក់ថា បុគ្គលទាំងពីរនេះទទួលបន្ទុកកាតព្វកិច្ចដោយសាមគ្គីភាព ។ ម្ចាស់បំណុលអាចទាមទារទៅកូនបំណុលក៏បាន ឬ ទាមទារទៅអ្នកទទួលក៏បាន ដើម្បីឱ្យអនុវត្តកាតព្វកិច្ចទាំងស្រុង ។

(២) កថាខណ្ឌទី ២ ចែងថា អ្នកទទួលអាចឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ចបាន ប៉ុន្តែ គ្មានបញ្ញត្តិណាតម្រូវឱ្យគោរពនូវឆន្ទៈរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលនេះមានឆន្ទៈមិនទទួលការរួចផុតនេះទេ ។ ដូច្នេះ អ្នកទទួលអាចឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ចបាន ទោះបីជាការរួចផុតនោះផ្ទុយនឹងឆន្ទៈរបស់កូនបំណុលក៏ដោយ ។ ការណ៍នេះស្របទៅនឹងបញ្ញត្តិដែលចែងថា តតិយជនដែលមិនមែនជាកូនបំណុល ក៏អាចសងកាតព្វកិច្ចដោយផ្ទុយពីឆន្ទៈរបស់កូនបំណុលបានដែរ (កថាខណ្ឌទី ១ នៃមាត្រា ៤៣៤) ។

**មាត្រា ៥១០.-** ការតវ៉ា ក្នុងការទទួលកាតព្វកិច្ច

ក្នុងករណីដែលការទទួលកាតព្វកិច្ចត្រូវបានធ្វើឡើង អ្នកទទួលនេះអាចយកហេតុដែលកូនបំណុលធ្លាប់មានរហូតដល់ពេលដែលការទទួលកាតព្វកិច្ចនោះត្រូវបានធ្វើឡើងទៅតតាំងចំពោះម្ចាស់បំណុលបាន ។

(កំណត់)

មាត្រានេះបានចែងថា នៅពេលដែលការទទួលកាតព្វកិច្ចត្រូវបានធ្វើឡើង អ្នកទទួលអាចយកហេតុដែលកូនបំណុល

អាចតតាំងចំពោះម្ចាស់បំណុល យកទៅតតាំងចំពោះម្ចាស់បំណុលបាន ។ ឧទាហរណ៍ ប្រសិនបើកូនបំណុលមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាចំពោះម្ចាស់បំណុល អ្នកទទួលក៏អាចអះអាងអំពីសិទ្ធិតវ៉ាចំពោះម្ចាស់បំណុលបានដែរ ។

**មាត្រា ៥១១.-** ការទទួលការអនុវត្តកាតព្វកិច្ច

ប្រសិនបើអ្នកទទួលមិនទទួលកាតព្វកិច្ច តែបានទទួលគ្រាន់តែការអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះ តាមការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួល នោះម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកទទួលនោះ អនុវត្តកាតព្វកិច្ចបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលនូវការអនុវត្តកាតព្វកិច្ច ។ មានន័យថា ក្នុងករណីដែលកាតព្វកិច្ចត្រូវបានទទួល ម្ចាស់បំណុលអាចទាមទារឱ្យអ្នកទទួលអនុវត្តកាតព្វកិច្ចបាន ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបានទទួលគ្រាន់តែការអនុវត្តកាតព្វកិច្ចប៉ុណ្ណោះ ម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកទទួលអនុវត្តកាតព្វកិច្ចបានទេ ។ ក្នុងករណីនេះ ដោយសារតែអ្នកទទួលគ្រាន់តែបានទទួលការអនុវត្តកាតព្វកិច្ច ក្នុងទំនាក់ទំនងជាមួយនឹងកូនបំណុល ហើយកូនបំណុលនៅតែមានកាតព្វកិច្ចចំពោះម្ចាស់បំណុលដដែល ហេតុដូច្នេះ មាត្រានេះបញ្ជាក់ឱ្យកាន់តែច្បាស់អំពីភាពខុសគ្នា រវាងការទទួលការអនុវត្ត និង ការទទួលកាតព្វកិច្ច ។

## ផ្នែកទី ៣ អនុប្បទានឋានៈក្នុងកិច្ចសន្យា

**មាត្រា ៥១២.-** អនុប្បទានឋានៈក្នុងកិច្ចសន្យា

១-បុគ្គលដែលបានធ្វើកិច្ចសន្យាជាមួយនឹងបុគ្គលផ្សេង អាចធ្វើអនុប្បទានឋានៈរបស់ខ្លួនដែលមាននៅក្នុងកិច្ចសន្យានោះ ទៅឱ្យតតិយជនបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលអនុប្បទានឋានៈនោះ មិនអាចធ្វើបាន តាមលក្ខណៈនៃកិច្ចសន្យា ។ ម្យ៉ាងទៀត គូភាគីនៃកិច្ចសន្យា អាចហាមមិនឱ្យធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ដោយការព្រមព្រៀងគ្នាបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៥០១ (ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យា នឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ច

សន្យានោះខូចប្រយោជន៍ធ្ងន់ធ្ងរ បុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ត្រូវទទួលការយល់ព្រមអំពីអនុប្បទាននោះ ពីភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ។

(កំណត់)

កថាខណ្ឌទី ១ ចែងថា ភាគីណាមួយនៃកិច្ចសន្យាអាចធ្វើអនុប្បទាន (ផ្ទេរ) ឋានៈក្នុងកិច្ចសន្យារបស់ខ្លួនទៅតតិយជនបាន ដោយមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតឡើយ ។ ឋានៈក្នុងកិច្ចសន្យារួមមានឋានៈជាម្ចាស់បំណុល និង ឋានៈជាកូនបំណុល ។ ហេតុដូច្នេះ យើងអាចអនុវត្តបញ្ញត្តិស្ដីពីអនុប្បទានសិទ្ធិលើបំណុល និង បញ្ញត្តិស្ដីពីការទទួលកាតព្វកិច្ច ដោយបកស្រាយថា អនុប្បទានសិទ្ធិលើបំណុល និង ការទទួលកាតព្វកិច្ចនោះបានធ្វើឡើងនៅពេលជាមួយគ្នា ។ ក៏ប៉ុន្តែ ច្បាប់នេះចែងនូវបញ្ញត្តិពិសេសស្ដីពីអនុប្បទានឋានៈតែមួយក្នុងកិច្ចសន្យា ។

កថាខណ្ឌទី ២ ចែងអំពីករណីលើកលែង ដោយបញ្ញត្តថា ប្រសិនបើអនុប្បទានឋានៈក្នុងកិច្ចសន្យា នឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យានោះខូចប្រយោជន៍ធ្ងន់ធ្ងរ បុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ត្រូវទទួលការយល់ព្រមពីភាគីម្ខាងទៀតនៃកិច្ចសន្យា ចំពោះការធ្វើអនុប្បទាននោះ ។

## មាត្រា ៥១៣.- ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា

អនុប្បទានឋានៈក្នុងកិច្ចសន្យា ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងភាគីម្ខាងនៃកិច្ចសន្យាដែលមានបំណងធ្វើអនុប្បទានឋានៈនោះ និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីតតាំងចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា និង តតិយជន អនុប្បទាននេះត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់ក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ។

(កំណត់)

(១) ដោយស្របទៅនឹងគោលការណ៍នៃឆន្ទៈ ដែលត្រូវអនុវត្តចំពោះការផ្លាស់ប្ដូរសិទ្ធិប្រត្យក្ស (ឧទាហរណ៍ ការផ្ទេរកម្មសិទ្ធិ) ឬ អនុប្បទានសិទ្ធិលើបំណុល អនុប្បទាន (ការផ្ទេរ) ឋានៈក្នុងកិច្ចសន្យា ក៏នឹងកើតមានអានុភាពដោយការព្រមព្រៀងរវាងភាគីនៃអនុប្បទាន (ការផ្ទេរ) តែប៉ុណ្ណោះ ។

(២) អនុប្បទានិកចាំបាច់បំពេញល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទាន ដើម្បីតតាំងអនុប្បទាន (ការផ្ទេរ) ឋានៈក្នុងកិច្ចសន្យាចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា ឬ ចំពោះតតិយជន ។ ចំពោះអត្ថន័យ និង ខ្លឹមសារនៃល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទាន សូមមើលមាត្រាដែលបានចែងអំពីអនុប្បទានសិទ្ធិលើបំណុល ។

**មាត្រា ៥១៤.-** អានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា

ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវបានធ្វើឡើង សិទ្ធិ និង កាតព្វកិច្ចទាំងអស់ដែលអនុប្បទាយីធ្លាប់មាន ត្រូវផ្ទេរទៅអនុប្បទានិក លើកលែងតែមានការបង្ហាញឆន្ទៈពិសេស ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៥០៥ (អានុភាពនៃការជូនដំណឹង និង ការយល់ព្រម) ស្ដីពីអនុប្បទានសិទ្ធិលើបំណុល និង មាត្រា ៥១០ (ការតវ៉ា ក្នុងការទទួលកាតព្វកិច្ច) ស្ដីពីការទទួលកាតព្វកិច្ច នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(កំណត់)

មាត្រានេះចែងថា ជាគោលការណ៍ ប្រសិនបើអនុប្បទាន (ការផ្ទេរ) ឋានៈក្នុងកិច្ចសន្យាត្រូវបានធ្វើឡើង សិទ្ធិ និង ករណីយកិច្ចនៃកិច្ចសន្យាទាំងអស់ (សិទ្ធិលុបចោល សិទ្ធិរំលាយ ជាដើម) នឹងត្រូវផ្ទេរ ។ ប៉ុន្តែ ចំពោះហេតុតវ៉ា ត្រូវចាត់ចែងដូចគ្នានឹងករណីនៃអនុប្បទានសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ច ។

បោះពុម្ពផ្សាយដោយ

ក្រសួងយុត្តិធម៌

ឧបត្ថម្ភដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ

នៃប្រទេសជប៉ុន (JICA)

9789995083366